ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# របាយការណ៍ ប្រចាំឆ្នាំ២០២២



## ទស្សនវិស័យ

អភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជីស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## បេសកកម្ម

- អភិវឌ្ឍស្របតាមគោលនយោបាយរាជរដ្ឋាភិបាល
- បង្កើនគុណភាពសេវាកម្ម តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ផែ ការធ្វើទំនើបកម្មគ្រប់គ្រងកំពង់ផែ និងការអភិវឌ្ឍធនធានមនុស្ស ស្របតាមនវានុវត្តន៍អន្តរជាតិ
- សហការជាមួយដៃគូអភិវឌ្ឍន៍ សិក្សា និងឆ្ពោះទៅការកសាងផែទឹកជ្រៅ ស្របតាមទស្សនវិស័យ និងកំណើនកុងតែន័រឆ្លងកាត់
- ជម្រុញ និងពង្រឹងគោលការណ៍ ជាកំពង់ផែសម្រាប់ទាំងអស់គ្នា ។

## គុណតម្លៃ

- ទីតាំងភូមិសាស្ត្រល្អបំផុត
- ការបំពេញចិត្តជូនអតិថិជន
- ភាពបរិសកម្ម និងនវានុវត្តន៍
- សុចរិតភាព និងគណនេយ្យភាព
- ភាពរួសរាយរាក់ទាក់ និងការគោរព
- ការងារជាក្រុម និងគុណភាពសេវាកម្ម
- ភាពជឿទុកចិត្ត និងកំណើនប្រកបដោយចីរភាព

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ៣១ ធ្នូ ២០២២ (ពាន់រៀល) | ៣១ ធ្នូ ២០២១ (ពាន់រៀល) (បានរាយការណ៍ឡើងវិញ) | ៣១ ធ្នូ ២០២០ (ពាន់រៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១.៤២៦.១៤៥.៥៩៦ | ១.៤២៧.១៤៩.៦៧០ | ១.៣៨៩.៨៤២.៧០១ |
| បំណុលសរុប | | ៥៦២.៣៤៤.៦៥០ | ៦៤៣.២៥៥.៥១១ | ៦៨៧.៤៨១.២៨៣ |
| មូលធនសរុប | | ៨៦៣.៨០០.៩៤៦ | ៧៨៣.៨៩៤.១៥៩ | ៧០២.៣៦១.៤១៨ |
| លទ្ធផលហិរញ្ញវត្ថុ | | ឆ្នាំ២០២២ (ពាន់រៀល) | ឆ្នាំ២០២១ (ពាន់រៀល) | ឆ្នាំ២០២០ (ពាន់រៀល) |
| ចំណូលសរុប | | ៣៤៣.៧៤៣.៥៤៥ | ៣៤២.៣៤៩.២២៩ | ៣១១.៨១៣.៧៦៩ |
| ចំណេញមុនបង់ពន្ធ | | ៩៧.៨៩៧.០៨០ | ១១១.០៤៥.៦៣៧ | ៤២.១៤០.២២១ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ៨៤.១៥៥.២១៥ | ៩៣.៧០៧.៣៩០ | ២៦.៦០៧.៥៩៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៩៦.០១៤.០៥៥ | ៩៣.៧០៧.៣៩០ | ២៦.៦០៧.៥៩៤ |
| អនុបាតហិរញ្ញវត្ថុ | | ៣១ ធ្នូ ២០២២ | ៣១ ធ្នូ ២០២១ | ៣១ ធ្នូ ២០២០ |
| អនុបាតសាធនភាព | | ២៣,០៩% | ២០,៧៧% | ៩,៤០% |
| អនុបាតបំណុលធៀបនឹងមូលធន | | ០,៦៥ | ០,៨២ | ០,៩៨ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,៦២ | ២,៣១ | ២,៤២ |
| | អនុបាតចរន្តលឿន | ២,២៥ | ២,០០ | ២,១២ |
| | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៥,៩០% | ៦,៥៧% | ១,៩១% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ៩,៧៤% | ១១,៩៥% | ៣,៧៩% |
| | គំលាតចំណេញដុល | ១៦,៥៩% | ២៣,០៣% | ២២,២៩% |
| | គំលាតចំណេញភាព | ២៤,៤៨% | ២៧,៣៧% | ៨,៥៣% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(រៀល) | ៩៨១,១៥ | ១.០៩២,៥២ | ៣១០,២១ |
| អនុបាតលទ្ធភាពសងការប្រាក់ | | ១០,៨៥ | ១០,៩២ | ៤,០៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | | - | ៥០៤ | ៤០៣ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំ២០២២









## ភាគហ៊ុនិករបស់ កសស

| ល.រ | ប្រភេទមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|---|
| ១ | មូលបត្រកម្មសិទ្ធិគ្មានសិទ្ធបោះឆ្នោតប្រភេទ "ក" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៦៤.៥៣០.៨៦១ | ៨០,៩៥% |
| ២ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "ខ" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ | ១៤,២៩% |
| ៣ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "គ" | ឯកជន | ២១.៤៤២.៩៩២ | ៤,៧៦% |
| **សរុប** | | | **៤៥០.៣០២.៨២៨** | **១០០%** |

## ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិប្រភេទ "គ" របស់ កសស

| ល.រ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|
| ១ | ESOP | ២.១៤៤.២៩៩ | ១០% |
| ២ | KAMIGUMI CO., LTD | ១១.១៥០.៣២៤ | ៥២% |
| ៣ | KOBE-OSAKA International Port Corporation | ២.១៤៤.៣០០ | ១០% |
| ៤ | ភាគហ៊ុនិកឯកជនដទៃទៀត | ៦.០០៤.០៦៩ | ២៨% |
| **សរុប** | | **២១.៤៤២.៩៩២** | **១០០%** |



# បំរែបំរួលថ្លៃភាគហ៊ុន និងទំហំជួញដូរ






# ស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ

| បរិយាយ | ឯកត្តា | ផែនការ ឆ្នាំ២០២២ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| បរិមាណទំនិញឆ្លងកាត់ | តោន | ៧.៤១៨.០០០ | ៧.០០៣.១៥៧ | ៦.៩៩០.៣៣៧ | ៦.៦០១.៨០៤ | -៥,៥៩% | ០,១៨% | ៦,០៨% |
| ជាកុងតែន័រ | _ | | ៥.០៣១.៩៨៨ | ៤.៩៤៩.៨០១ | ៤.៣៦៣.៩០៩ | | ១,៦៦% | ១៥,៣១% |
| ទំនិញរាយ | _ | | ១៤២.៩៤៤ | ២៥០.៧៣៤ | ៣៤៩.៨២០ | | -៤២,៩៩% | -៥៩,១៤% |
| ជាប្រេង | _ | | ១.៧២៩.៧០០ | ១.៧៣៧.០៤៧ | ១.៨០៤.៣៥២ | | ៨៦,៧៦% | ១៧,៦៨% |
| ហ្គាស | _ | | ៩៨.៥២៥ | ៥២.៧៥៥ | ៨៣.៧២២ | | ០,៤១% | ៦,៩១% |
| បរិមាណទំនិញនាំចូល | _ | ៥.៥៦៤.០០០ | ៥.២២៥.២៣៦ | ៥.២០៣.៨១៩ | ៤.៨៨៧.៦៨៤ | -៦,០៩% | ០,៤១% | ៦,៩១% |
| បរិមាណទំនិញនាំចេញ | _ | ១.៨៥៤.០០០ | ១.៧៧៧.៩២១ | ១.៧៨៦.៥១៨ | ១.៧១៤.១២០ | -៤,១០% | -០,៤៨% | ៣,៧២% |
| បរិមាណទំនិញលើករៀប | _ | ១០.២៩៨.០០០ | ១១.២៣៩.៤៣៤ | ១០.១៩៩.១៤៨ | ៨.៩៥៤.៣១៧ | ៩,១៤% | ១០,២០% | ២៥,៥២% |
| ប្រគល់ផ្ទាល់ | _ | ២២០.០០០ | ១២១.១៨០ | ២០១.៩២៣ | ២០៨.៣២៩ | | -៣៩,៩៩% | -៤១,៨៣% |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | _ | ១០.០៧៨.០០០ | ១១.១១៨.២៥៣ | ៩.៩៩៧.២២៥ | ៨.៧៤៥.៩៨៨ | | ១១,២១% | ២៧,១២% |
| បរិមាណកុងតែន័រឆ្លងកាត់ | TEUs | ៧៨៧.០០០ | ៧៥០.១៤៨ | ៧៣២.៣៨៧ | ៦៤១.៨៤២ | -៤,៦៨% | ២,៤៣% | ១៦,៨៧% |
| នាំចូល | _ | | ៣៩៥.១១៤ | ៣៨០.១៤៥ | ៣២០.៦៤២ | | ៣,៩៤% | ២៣,២៣% |
| នាំចេញ | _ | | ៣៥៥.០៣៤ | ៣៥២.២៤២ | ៣២១.២០០ | | ០,៧៩% | ១០,៥៣% |
| ចំនួននាវាចូលចត | គ្រឿង | ១.៤៥០ | ១.៤៤២ | ១.៥៨២ | ១.៦៦២ | -០,៥៥% | -៨,៨៥% | -១៣,២៤% |
| ចំណុះផ្ទុកនាវា | តោន | ១៤.១២៨.០០០ | ១៤.១០៨.០៣២ | ១៣.៣៦៦.៣៩៩ | ១៦.៧៨៤.៩៧៩ | -០,១៤% | ៥,៥៥% | -១៥,៩៥% |

# សមាសភាពក្រុមប្រឹក្សាភិបាល



**ឯកឧត្តម លូ គីមឈន់**
ប្រធានអគ្គនាយក



**ឯកឧត្តម ស៊ុយ សាន**
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



**ឯកឧត្តម ផាន់ ផល្លា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម សុខ សុភ័ក្រ្ត**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក ហ៊ិន មុន្នីវណ្ណ**
អភិបាលឯករាជ្យ



**លោក Hidetoshi KUME**
អភិបាលមិនប្រតិបត្តិ
តំណាងភាគហ៊ុនិកឯកជន



**លោក លូ លីខេង**
តំណាងនិយោជិតកម្មករ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ



# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

“ជួសមុខឱ្យក្រុមប្រឹក្សាភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវ របាយការណ៍អាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ របស់ កសស សម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២”។

ដោយមានការគាំទ្រយ៉ាងមុតមាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអាណាព្យាបាលទាំងពីរ កសស បានបន្តការវិវឌ្ឍន៍ យ៉ាងខ្លាំងក្លាដើម្បីបម្រើសកម្មភាពធុរកិច្ចរបស់ខ្លួន ជាលទ្ធផលនៅក្នុងឆ្នាំ២០២២ នេះ កសស ទទួលបានប្រាក់ចំណូលសរុបចំនួន ៣៤៣.៧៤៣.៥៤៥.០០០ រៀល និងទទួលបានប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធក្នុងការិយបរិច្ឆេទចំនួន ៨៤.១៥៥.២១៥.០០០ រៀល បើប្រៀបធៀបនឹងឆ្នាំ២០២១។ ប្រាក់ចំណូលមានការកើនឡើងចំនួន ១.៣៩៤.៣១៦.០០០ រៀល គឺស្មើនឹង ០,៤១% ចំណែកប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះចំនួន ៩.៥៥២.១៧៥.០០០ រៀល គឺស្មើនឹង ១០,១៩%។ លទ្ធផលនេះបណ្តាលមកពីបរិមាណទំនិញ និងបរិមាណកុងតែន័រឆ្លងកាត់ កសស មានការកើនឡើង ដោយឡែកមានការកើនឡើងលើការចំណាយនៃប្រតិបត្តិការកំពង់ផែ ដែលជាកត្តាចម្បង ដោយក្នុងឆ្នាំ២០២២ នេះ តម្លៃប្រេងឥន្ធនៈជាមធ្យម ១.០៦ ដុល្លារ ក្នុងមួយលីត្រ បើធៀបនឹងឆ្នាំ២០២១ គឺត្រឹម ០.៦៨ ដុល្លារ ក្នុងមួយលីត្រ ធ្វើអោយចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះ ជាលទ្ធផលចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធមានចំនួន ៩៨១,១៥ រៀល សម្រាប់ឆ្នាំ២០២២ នេះ។ ហើយក្នុងឆ្នាំ២០២២ នេះ កុងតែន័រសរុបដែលបានឆ្លងកាត់ កសស មានចំនួន ៧៥០.១៤៨ TEUs ពោលគឺ កើនចំនួន ១៧.៧៦១ TEUs ស្មើនឹង ២,៤៣% និងការកើននៃបរិមាណទំនិញឆ្លងកាត់មានចំនួន ១២.៨២០ តោន ស្មើនឹង ០,១៨% បើប្រៀបធៀបទៅនឹងឆ្នាំ២០២១។

កសស នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបំពេញសេវាកម្ម អាជីវកម្មឱ្យកាន់តែល្អប្រសើរ និងសម្រេចបានលទ្ធផលខ្ពស់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន។ កសស បានពង្រឹងប្រសិទ្ធភាពការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មរបស់អតិថិជន និងការរីកចម្រើនសេដ្ឋកិច្ចជាតិ។ ដោយសារតែមានការកើនឡើងនូវបរិមាណទំនិញ និងកុងតែន័រឆ្លងកាត់ កសស បានធ្វើការកែសម្រួលផែច្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ ដើម្បីក្លាយជាចំណតកុងតែន័រមួយបន្ថែមទៀត ដែលបច្ចុប្បន្នមានត្រឹមតែពីរចំណតប៉ុណ្ណោះ។ ជាងនេះទៅទៀត កសស បាននឹងកំពុងអនុវត្តគម្រោងអភិវឌ្ឍន៍ផែកុងតែន័រថ្មី (ដំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក ១៤,៥ ម៉ែត្រ រួមបញ្ចូលទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប ប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង រថលើកកុងតែន័រទទេ (Empty Reach Stacker) ចំនួន ០២ គ្រឿង ក្បាលសណ្តោងកុងតែន័រ ចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម ០១ កំភ្លេ។ សម្រាប់ចំណតផែកុងតែន័រថ្មីនេះ អាចអនុញ្ញាតឱ្យនាវាដឹកជញ្ជូនកុងតែន័រធុនធំក្នុងតំបន់ចូលចតនៅ កសស បាន ដែល

នឹងធ្វើឱ្យឧបសគ្គអំពីជម្រៅទឹកសម្រាប់កំពង់ផែ ត្រូវបានដោះស្រាយ ព្រមទាំងតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ ដែលជាការរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។ តាមការរំពឹងទុកគម្រោងនេះនឹងគ្រោងបញ្ចប់ការសាងសង់នៅពាក់កណ្តាល ឆ្នាំ២០២៥ ហើយសមត្ថភាពលើកដាក់កុងតែន័រដល់ ១.១៥០.០០០ TEUs ក្នុង ១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រនេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៥ ខាងមុខ។

❖ **ដើម្បីឆ្លើយតបនឹងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ ក៏ដូចជាតម្រូវការសេវាកម្ម របស់អតិថិជន កសស មានទិសដៅការងារចម្បងៗដូចខាងក្រោម៖**

- អនុវត្តបន្តការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០២២
- រក្សានូវឧត្តមភាពនៃភាពប្រកួតប្រជែងរបស់ខ្លួន ដោយធានានូវគុណភាពសេវាកម្ម តម្លៃប្រកួតប្រជែង ប្រសិទ្ធភាពការងារ និងការកសាងទំនុកចិត្តជូនអតិថិជន
- ពង្រឹងសមត្ថភាពបុគ្គលិកលើការគ្រប់គ្រង និងបច្ចេកទេស ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា ចំពោះកំណើនតំរូវការសេវាកម្មរបស់កំពង់ផែ
- ជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងគ្រឿងចក្របន្ថែមទៀត ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកកំពស់សមត្ថភាពលើកដាក់ទំនិញរបស់ខ្លួន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រជាមួយកំពង់ផែក្នុងប្រទេស និងក្នុងតំបន់
- ពង្រឹងអភិបាលកិច្ចគ្រប់គ្រងតាមរយៈការបង្កើតគណៈកម្មាធិការសំខាន់ៗ
- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និងលើកកំពស់សុខមាលភាពសង្គម

❖ **ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល**

នៅក្នុងឆ្នាំ២០២២ នេះ ក្រុមប្រឹក្សាភិបាលបានធ្វើការជួបប្រជុំចំនួន ០៤ លើក និងបានសម្រេចការងារដូចខាងក្រោម៖

### ១. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៣ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលឯកភាពលើលទ្ធផលដែលបានសម្រេច និងស្នើអោយបន្តអនុវត្តទៅតាម ស្មារតីសម័យប្រជុំក្រុមប្រឹក្សាភិបាលកន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពតាមរបាយការណ៍របស់គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission បានស្នើអោយ កសស រៀបចំរបាយការណ៍ស្តីពីផលប្រយោជន៍ និងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ ជូនក្រសួងអាណាព្យាបាលទាំងពីរ និងស្នើសុំអោយ លោក KUME Hidetoshi ជួយសម្របសម្រួល និងចរចាបន្ថែមទៀត ទៅភាគីជប៉ុនលើការបញ្ចុះអត្រាការប្រាក់ជាអប្បបរិមា ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័ត ដូចខាងក្រោម ៖
  - ឯកភាពលើ របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ឆ្នាំ២០២១
  - ឯកភាពលើ វិធានការណ៍ដោះស្រាយបន្ទាន់ និងស្នើអោយ កសស ត្រូវរៀបចំលិខិតគោរពជូន ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីស្នើសុំគោលការណ៍ផ្លាស់ប្តូរទីតាំងរបស់សមត្ថកិច្ចត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅដើមទី ពីក្នុងបរិវេណ កសស ទៅក្រៅបរិវេណ កសស វិញ
  - ឯកភាពជាគោលការណ៍លើគម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ក្នុងស្រុក នៅច្រកលេខ១ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ( Financial performance review ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី ការអនុគ្រោះថ្លៃឈ្នួលសេវារបស់ កសស ចំពោះទំនិញរាជរដ្ឋាភិបាល ប្រចាំឆ្នាំ២០២១ មានចំនួនជាទឹកប្រាក់សរុប ៨៨.៣១២,១៩ USD (ប៉ែតសិបប្រាំបីពាន់ បីរយដប់ពីរ ដុល្លារអាមេរិក និងដប់ប្រាំបួនសេន) ។

## ២. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៤ នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីដំហានទី២ និងដំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission និង Appraisal Mission ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ត្រីមាសទី១ ឆ្នាំ២០២២ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី១ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈសម្រាប់មហាសន្និបាតភាគហ៊ុនិក លើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម ៖
  - កាលបរិច្ឆេទ : ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
  - កាលបរិច្ឆេទកំណត់ទុក : ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២
  - ទីកន្លែងប្រារព្ធមហាសន្និបាត (Venue) : សុខា ប៊ិច រីសត, ខេត្តព្រះសីហនុ ជាមួយនឹងប្រព័ន្ធវីដេអូខល ZOOM (ទៅតាមស្ថានភាពជាក់ស្តែង)
  - របៀបវារៈមហាសន្និបាត
    - មតិស្វាគមន៍របស់ ប្រធានមហាសន្និបាត
    - បទបង្ហាញ ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២១ និងទិសដៅអនុវត្តការងារឆ្នាំ២០២២
    - ពិនិត្យ និងអនុម័ត បែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពឱ្យ កសស ស្នើសុំការអនុម័តការបែងចែកភាគលាភ (Dividend) ការកំណត់កាលបរិច្ឆេទកំណត់ទុកដែលត្រូវបែងចែកភាគលាភ (Record Date) និងកាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) ជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ២០២១ នៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម៖

  ១. បែងចែកភាគលាភជូន
    - ភាគហ៊ុនិកប្រភេទ "ខ" ស្មើនឹងទឹកប្រាក់ចំនួន ៥.៣០០.០០០.០០០ រៀល
    - ភាគហ៊ុនិកប្រភេទ "គ" ក្នុងអត្រា ៨%, ៩%, ១០%, ១១% ឬ ១២% នៃតម្លៃមូលបត្របោះផ្សាយលក់លើកដំបូង (IPO Price) ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី៥ ពិនិត្យ និងអនុម័ត
    - ប្រភេទភាគលាភដែលត្រូវបែងចែក : សាច់ប្រាក់
    - រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២១
    - ចំនួនមូលបត្រដែលបានចុះបញ្ជីសរុប : ៨៥.៧៧១.៩៦៧ មូលបត្រ
      - ចំនួនមូលបត្រ ប្រភេទ "ខ" : ៦៤.៣២៨.៩៧៥ មូលបត្រ
      - ចំនួនមូលបត្រ ប្រភេទ "គ" : ២១.៤៤២.៩៩២ មូលបត្រ

  ២. ចំនួនភាគលាភសរុបដែលត្រូវបែងចែក
    - បែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៥.៣០០.០០០.០០០ រៀល
    - បែងចែកជូនភាគហ៊ុនប្រភេទ "គ" : បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
    - អនុបាតនៃការបែងចែកភាគលាភសរុបជូនភាគហ៊ុនប្រភេទ "ខ" និង "គ"
      - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "ខ": ៦,២៨ %
      - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "គ": បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
    - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ
      - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៨២,៣៩ រៀល
      - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "គ" : សម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
    - កាលបរិច្ឆេទកំណត់ទុក (Record Date) : ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២
    - កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) : ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ កសស ស្វែងរកដំណោះស្រាយឱ្យបានអស់ពីលទ្ធភាព ទៅលើការទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ដោយត្រូវអញ្ជើញក្រុមហ៊ុនមកប្រជុំពិភាក្សា និងពន្យល់កាតព្វកិច្ចដែលត្រូវអនុវត្តទៅលើកិច្ចសន្យា ដោយកិច្ចការនេះ ត្រូវមានការចូលរួមពី លោក ណុំ ស៊ីនិត មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស ហើយត្រូវរៀបចំជាកំណត់ហេតុ និងការទទួលស្គាល់អោយបានច្បាស់លាស់រវាងគូភាគី មុននឹងអនុវត្តនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមានបន្តទៀត។ ក្នុងករណីដែលដំណោះស្រាយក្នុងការតឹងទារបំណុលខាងលើពុំមានប្រសិទ្ធភាព ក្រុមប្រឹក្សាភិបាលគាំទ្រទៅលើវិធានការដែលបានស្នើឡើង របស់ កសស ដែលមានលក្ខណៈជាជំហានៗ សម្រាប់អនុវត្តការតឹងទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ។

## ៣. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៥ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការ តែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង។ អង្គប្រជុំបានស្នើអោយ កសស ធ្វើលិខិតគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីស្ថានភាពកកស្ទះចរាចរណ៍ក្នុងកំពង់ផែ និងទំនិញគ្មានការទាមទារ ដើម្បីស្នើសុំគោលការណ៍ណែនាំអនុវត្ត ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែប្រាំងជាផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ដំហានទី១ ប្រវែង ៣៥០ ម៉ែត្រ)។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងពង្រីកចំណតផែកុងតែន័រថ្មី (ដំហានទី២ និងដំហានទី៣) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី គម្រោងពង្រឹងសមត្ថភាពការគ្រប់គ្រង និងប្រតិបត្តិការចំណតផែកុងតែន័រនៅកំពង់ផែក្រុងព្រះសីហនុ-ដំណាក់កាលទី៣ (២០២២-២០២៦) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍ស្តីពី វឌ្ឍនភាពការងារប្រព័ន្ធព័ត៌មានវិទ្យារបស់ កសស និងសូមអោយសហការសិក្សាបន្ថែមជាមួយ JICA Experts Team ដើម្បីជ្រើសរើសជម្រើសដ៏ល្អបំផុត និងជឿទុកចិត្តបាន សម្រាប់ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង កសស ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី២ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។

## ៤. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៦ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការ តែងតាំងនិងលាភការដែលបានលើកឡើង ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពរបាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែប្រាំងជាផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ដំហានទី១ ប្រវែង ៣៥០ ម៉ែត្រ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ០៩ ខែ ដើមឆ្នាំ២០២២ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពគាំទ្រ គម្រោងផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ ២០២៣ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័តដោយឯកភាពអោយ កសស អភិវឌ្ឍទីតាំងដីជួលខាងលើនេះ ទៅជាទីលានស្តុកកុងតែន័រ និងសម្រាប់បម្រើអោយការងារអាជីវកម្មរបស់ កសស នៅក្រោយពេលកិច្ចសន្យាជួលទីតាំង និងមធ្យោបាយលើកដាក់នឹងត្រូវផុតសុពលភាពនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ខាងមុខនេះ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើ ការកំណត់កាលបរិច្ឆេទរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៧ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជានិច្ចកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ កសស រៀងរហូតមក ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ មន្ត្រី-និយោជិត និងកម្មករ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ទាំងអស់ដែលតែងតែយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តព្រះសីហនុ, ថ្ងៃទី៣០ ខែមីនា គ.ស ២០២៣

**ប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ_គឹមឈន់**

# មាតិកា


ទស្សនវិស័យ បេសកកម្ម គុណតម្លៃ ........ I
ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ II
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប. ........ III
ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ. ........ VI
សមាសភាពក្រុមប្រឹក្សាភិបាល ........ VII
សេចក្ដីថ្លែងរបស់ប្រធានអគ្គនាយក ........ VIII

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០១**
ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០២
ខ- លក្ខណៈនៃធុរកិច្ច ........ ០២
គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០៤
ឃ- ព្រឹត្តិការសំខាន់ៗប្រចាំឆ្នាំ. ........ ០៤
ង- ស្ថានភាពទីផ្សារ ........ ០៤
ច- ស្ថានភាពប្រកួតប្រជែង ........ ០៧
ឆ- ផែនការអនាគត ........ ០៨
ជ- កត្តាហានិភ័យ. ........ ១៦

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ១៧**
ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ១៨
ខ- រចនាសម្ព័ន្ធចំណូល ........ ២២

**ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ........ ២៣**
ក- អង្គការលេខ ........ ២៤
ខ- ក្រុមប្រឹក្សាភិបាល ........ ២៥
គ- បុគ្គលិកជាន់ខ្ពស់ ........ ២៥

**ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ២៦**
ក- ព័ត៌មានអំពីមូលបត្រ ........ ២៧
ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ........ ២៧
គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ ........ ២៨
ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន ........ ២៨
ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី)ឆ្នាំចុងក្រោយ ........ ២៨

**ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង..........២៩**

**ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ.............. ៦៤**

**ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍..........................................................................................................១៤៧**

ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ...... ១៤៨

ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់................................................ ១៤៨

គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម.... ១៤៨

ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ.............................................................. ១៤៨

ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ........ ១៤៨

ច- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល ..................................................................................................................... ១៤៨

ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ........១៤៨

ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ...................................................................................... ១៤៨

**ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........................................ ១៤៩**

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ.................................................................................................. ១៥០

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ............................................................................ ១៥៧

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល.............................................................................. ១៥៧

ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ................................................ ១៥៨

ង- ផលប៉ះពាល់នៃអតិផរណា......................................................................................................... ១៥៨

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ................................ ១៥៨

**ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន ................................ ១៦០**

**ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ........................................................ ១៦៥**

# ផ្នែកទី ១

# ព័ត៌មានពាក់ព័ន្ធនឹង
# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ : កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)
ឈ្មោះក្រុមហ៊ុនជាអក្សរ (ឡាតាំង) : PORT AUTONOME DE SIHANOUKVILLE "PAS"
ឈ្មោះក្រុមហ៊ុនជាអក្សរ (អង់គ្លេស) : SIHANOUKVILLE AUTONOMOUS PORT
លេខកូដស្តង់ដារ : KH1000060009
អាសយដ្ឋាន : តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។
លេខទូរស័ព្ទ : (៨៥៥) ៣៤ ៩៣៣ ៤១៦ /៩៣៣ ៥១១
ទំនាក់ទំនងវិនិយោគិន : (៨៥៥) ៧៨ ៤៩៦ ៧៨៩
គេហទំព័រ : www.pas.gov.kh
អ៊ីម៉ែល : pasinfo@pas.gov.kh
លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម : Co.៤៧៨៤ Et / ២០១៧ កាលបរិច្ឆេទ: ២១ កុម្ភៈ ២០១៧
លេខអាជ្ញាបណ្ណអាជីវកម្ម : ០១៥៩ ពណ.ចបព កាលបរិច្ឆេទ: ២២ កុម្ភៈ ២០១៧ ដែលចេញដោយក្រសួងពាណិជ្ជកម្ម
សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ: ០៥៨/១៧/គ.ម.ក/ស.ស.រ
កាលបរិច្ឆេទ : ០៩ ឧសភា ២០១៧
ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ: **ឯកឧត្តម លូ គឹមឈន់**

## ខ- លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីប្រមាណ ១២៥ ហិកតា។ ដោយស្ថិតនៅតាមបណ្តោយឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាក្នុងឈូងសមុទ្រថៃ កសស ទទួលបានភាពអនុគ្រោះពីធម្មជាតិ និងលក្ខខណ្ឌប្រតិបត្តិការយ៉ាងល្អនពេញមួយឆ្នាំ ដោយមានទឹកសមុទ្រស្ងប់ស្ងាត់ល្អ និងពុំមានព្យុះធំៗឡើយ ។

កសស ត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ តាមផ្លូវគោក កសស ត្រូវបានតភ្ជាប់ដោយផ្លូវជាតិសំខាន់ៗពីរ និងផ្លូវល្បឿនលឿនមួយ គឺផ្លូវជាតិលេខ៤ ដែលមានប្រវែង ២២៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញមកក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៣ ដែលកាត់តាមទីរួមខេត្តកំពត មានប្រវែង ២៤៤ គីឡូម៉ែត្រ បន្ថែមពីលើនេះ គឺផ្លូវល្បឿនលឿនដែលទើបនឹងសាងសង់រួច ហើយបានបើកឱ្យប្រើប្រាស់កាលពីខែតុលា ឆ្នាំ២០២២នេះ ដែលមានប្រវែង ១៨៧ គីឡូម៉ែត្រ ពីភ្នំពេញ មក ក្រុងព្រះសីហនុ។ កសស ក៏ត្រូវបានតភ្ជាប់ដោយខ្សែរថភ្លើងភាគខាងត្បូង ពីភ្នំពេញកាត់តាមខេត្តកំពត ដែលមានប្រវែង ២៦៤ គីឡូម៉ែត្រ។ ចំណែកតាមផ្លូវអាកាស កសស ត្រូវបានតភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញដោយអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

ក្នុងនាមជាប្រតិបត្តិករផែ កសស ត្រូវបំពេញអាជីវកម្ម និងសេវាកម្មដូចខាងក្រោម៖

- កណ្តាលរកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរ-ផ្ទុក ទំនិញ
- ស្តុកទំនិញ នៅឃ្លាំង និងទីលាន
- ដឹកជញ្ជូនទំនិញ
- តំបន់សេដ្ឋកិច្ចពិសេស

កសស មានចំណតផែសរុបប្រវែង ១,៨៦០ ម៉ែត្រ ដោយចែកជា ១៣ ចំណតដូចខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយ៍ | ប្រភេទទំនិញ | បណ្តោយ (ម៉ែត្រ) | ទទឹង (ម៉ែត្រ) | ចំណត |
|---|---|---|---|---|---|
| ១ | ស្ថានីយ៍ផែអ្នកដំណើរ (ចំណតផែចាស់) | អ្នកដំណើរ និងទំនិញរាយ | ២៩០ | ២៨ | លេខ ១ និង លេខ ៣៖ ជម្រៅ ៩ ម៉ែត្រ ដល់ ១៣ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅ បាត ៨,៥ ម៉ែត្រ ចូលចតបាន។ លេខ ២ និង លេខ ៤៖ ជម្រៅ ៦,៥ ម៉ែត្រ ដល់ ៨ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅ បាត ៧ ម៉ែត្រ ចូលចតបាន។ |
| ២ | ស្ថានីយ៍ផែថ្មី | កុងតែន័រ | ៣៥០ | ៥០០ | លេខ៥ (ផ្នែកខាងលិច) និងលេខ៦ (ផ្នែកខាងកើត)៖ ជម្រៅ ១០ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាតក្រោម ៨,៥ ម៉ែត្រ ចូលចតបាន។ |
| ៣ | ស្ថានីយ៍ផែកុងតែន័រ | កុងតែន័រ | ៤០០ | ៣៥០ | លេខ៧ និង លេខ៨៖ ជម្រៅ ១១ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាតក្រោម ៨,៥ម៉ែត្រ ចូលចតបាន។ |
| ៤ | ស្ថានីយ៍ផែពហុបំណង | អ្នកដំណើរ ទំនិញរាយ និងរុករកប្រេង | ៣៣០ | ២០០ | ផែពហុបំណង មានប្រវែង ៣៣០ ម៉ែត្រ និងជម្រៅទឹក -១៣,៥ ម៉ែត្រ សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ ដែលអាចអនុញ្ញាតឱ្យនាវាចំណុះ ៥០.០០០ DWT ចូលចតបាន និងចំណតផែមូលដ្ឋាន ផ្គត់ផ្គង់ការរុករករ៉ែប្រេងក្នុងដែនសមុទ្រ មានប្រវែង ២០០ ម៉ែត្រ និងជម្រៅទឹក -៧,៥ ម៉ែត្រ ដើម្បីបម្រើសេវាកស្តុភារកម្ម សម្រាប់ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា។ |
| ៥ | ស្ថានីយ៍ផែថ្ម | ដឹកប្រេង | ៥៣ | ៥ | ចំណតផែប្រេង៖ ជម្រៅ ៤,៥ ម៉ែត្រ ហើយមានប្រវែងសរុបក្រោម ៨០ ម៉ែត្រ។ ឧបករណ៍ទាក់ពួរកៃច្នៃ ត្រូវបានរៀបចំសម្រាប់នាវាប្រេង ដែលមាន ជម្រៅបាតក្រោម ៦ ម៉ែត្រ និងប្រវែងក្រោម ១១០ ម៉ែត្រ ធ្វើការចូលចតបាន។ |

- ស្ថានីយ៍រថភ្លើងដឹកកុងតែន័រ

ក្រៅពីចំណតផែខាងលើ ដោយសហការជាមួយក្រុមហ៊ុន Royal Railway Co., Ltd កសស ក៏មានប្រតិបត្តិការប្រព័ន្ធផ្លូវដែក និងទីលានផ្ទុកទំនិញកុងតែន័រក្នុងបរិវេណកំពង់ផែដើម្បីឱ្យអតិថិជន ឬម្ចាស់ទំនិញអាចដឹកជញ្ជូនទៅវិញទៅមកពី កសស ទៅភ្នំពេញ។ កសស បានជួលដីបរិវេណនេះទៅឱ្យក្រុមហ៊ុន Royal Railway Co., Ltd ហើយផ្តល់សេវាកម្មលើកដាក់កុងតែន័រទៅលើ និងចុះពីរថភ្លើង ។

- តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ក្រៅពីអាជីវកម្ម សេវាកម្មខាងលើ កសស ក៏មានប្រតិបត្តិដំណើរការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុដែលមានទំហំផ្ទៃដីប្រមាណ ៦៤ ហិកតា បានកសាងឡើងតាមបទដ្ឋានប្រទេសជប៉ុន។

## គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ

កសស មិនមានក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនពាក់ព័ន្ធដទៃទៀតទេ ។

## ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ២០២២

ក្នុងឆ្នាំ២០២២ នេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៥ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ បានរៀបចំឡើងនៅ សណ្ឋាគារ សុខា ប៊ិច រីស៊ត និងតាមប្រព័ន្ធអនឡាញ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាតហ៊ុនិកលើកទី៥ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានសម្រេចលទ្ធផលដូចខាងក្រោម៖

- របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្មឆ្នាំ២០២១
- ទិសដៅការងារឆ្នាំ២០២២
- ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១
  - ភាគហ៊ុនិកប្រភេទ "ខ" មានចំនួន ៥.៣០០.០០០.០០០ រៀល
  - ភាគហ៊ុនិកប្រភេទ "គ" មានចំនួន ១០% នៃតម្លៃ IPO ( ៥.០៤០រៀល ) ស្មើនឹង ១០.៨០៧.២៦៧.៩៦៨ រៀល
- ការអនុម័តលើប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២២។

## ង- ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ កសស គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើចរាចរណ៍កុងតែន័រ យើងសង្កេតឃើញថាសម្រាប់ឆ្នាំ២០២២ នេះ បរិមាណកុងតែន័រ (TEUs) សរុប ៧៥០.១៤៨ TEUs ដែលមានកំណើន ២,៤៣% ស្មើនឹង ១៧.៧៦១ TEUs បើធៀបនឹងឆ្នាំ២០២១ និងមានកំណើន ១៦,៨៧% ស្មើនឹង ១០៧.៣០៦ TEUs បើធៀបនឹងឆ្នាំ២០២០។ បើពិនិត្យមើលទៅលើបរិមាណកុងតែន័រនាំចេញ និងនាំចូលឆ្លងកាត់ កសស វិញ កុងតែន័រនាំចេញសម្រាប់ឆ្នាំ២០២២ បានកើនឡើង ២.៧៩២ TEUs ស្មើនឹង ០,៧៩% ចំណែកបរិមាណកុងតែន័រនាំចូលមានការកើនឡើង ១៤.៩៦៩ TEUs ស្មើនឹង ៣,៩៤% បើធៀបនឹងឆ្នាំ២០២១ ។




បើពិនិត្យទៅលើបរិមាណសរុបទំនិញ (តោន) ចរាចរណ៍ឆ្លងកាត់ កសស វិញ សម្រាប់ឆ្នាំ២០២២ មានបរិមាណសរុប ៧.០០៣.១៥៧ តោន ដែលមានកំណើន ០,១៨% ស្មើនឹង ១២.៨២០ តោន ធៀបនឹងឆ្នាំ២០២១ បើប្រៀបធៀបនឹងបរិមាណទំនិញឆ្នាំ២០២០ វិញ មានកំណើន ៤០១.៣៥៤ តោន ស្មើនឹង ៦,០៨%។ ក្នុងនោះទំនិញជាកុងតែន័រសម្រាប់ឆ្នាំ២០២២ មានការកើនឡើងប្រមាណ ១,៦៦% ស្មើនឹង ៨២.១៨៧ តោន និងទំនិញជាប្រេង និងហ្គាសមានការកើនឡើង ២,១៥% ស្មើនឹង ៣៨.៤២៤ តោន រីឯទំនិញរាយ ក៏មានការថយចុះ ៤២,៩៩% ស្មើនឹង ១០៧.៧៩១ តោន បើធៀបនឹងឆ្នាំ២០២១ ។




ចាប់តាំងពីឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន មានចរាចរណ៍កុងតែន័រមួយចំនួនដឹកតាមរយៈរថភ្លើងឆ្លងកាត់ កសស ដែលបានជួយសម្រួលមួយផ្នែក លើស្ថានភាពចរាចរណ៍ផ្លូវជាតិលេខ៤ ក៏ដូចជាផ្តល់នូវជម្រើសសម្រាប់អតិថិជនរបស់ កសស ក្នុងការដឹកទំនិញចេញ-ចូលកំពង់ផែ។ យើងសង្កេតឃើញថា បរិមាណកុងតែន័រដឹកតាមរថភ្លើងឆ្លងកាត់ កសស សម្រាប់ឆ្នាំ២០២២ មានចំនួន ៤៩.៥៨៩ TEUs មានការកើនឡើង ១៣,៧៨% ស្មើនឹង ៦.០០៥ TEUs បើធៀបនឹងឆ្នាំ២០២១ ។




សង្កេតទៅលើប្រភេទទំនិញនាំចេញប្រចាំឆ្នាំ២០២២ មានបរិមាណសរុបចំនួន ១.៧៧៧.៩២១ តោន ដោយថយ ០,៤៨ % ស្មើនឹង ៨.៥៩៧ តោន ធៀបនឹងឆ្នាំ២០២១។ សម្រាប់ឆ្នាំ២០២២ នេះទំនិញនាំចេញជាប្រភេទទំនិញអង្ករមានច្រើនជាងគេ មានចំនួន ៣៣,២៣% ស្មើនឹង ៥៩០.៧១៧ តោន និងទំនិញជាប្រភេទទូទៅមានចំនួន ៣១,៣៤% ស្មើនឹង ៥៥៧.២៣១ តោន នៃទំនិញនាំចេញសរុប។ រីឯក្រណាត់ សំលៀកបំពាក់មាន ២១,៥៩% ហើយទំនិញជាឈើកែច្នៃមាន ៦,០៥% ស្បែកជើង/ស្រោមជើងមាន ៣,៩០% ផ្លែឈើមាន ៣,៦៩% គ្រឿងចក្រមាន ០,០១% និងរថយន្ត ម៉ូតូ កង់ មាន ០,១៣% នៃបរិមាណទំនិញនាំចេញសរុប របស់ កសស ក្នុងឆ្នាំ២០២២ ។




ចំណែកទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០២២ ដែលឆ្លងកាត់ កសស វិញមានបរិមាណ ៥.២២៥.២៣៦ តោន មានការកើនឡើង ០,៤១% ស្មើនឹង ២១.៤១៧ តោន បើធៀបនឹងឆ្នាំ២០២១។ ក្នុងទំនិញនាំចូលនេះ ទំនិញទូទៅមានចំនួន ៥១,៥៤% ប្រេងឥន្ធនៈមាន ៣៤,៩៩% និងក្រណាត់ សំលៀកបំពាក់មានប្រមាណ ៧,៤៧% នៃបរិមាណទំនិញនាំចូលសរុប។ រីឯទំនិញប្រភេទជាគ្រឿងចក្រមាន ២,៣១% ប្រភេទរថយន្ត ម៉ូតូ

កង់មាន ២,៣៦% បារីមាន ០,៨១% លោហៈធាតុមាន ០,៣៨% និងត្បូងថ្មមាន ០,១៤% នៃទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០២២ នេះ។




## ច- ស្ថានភាពប្រកួតប្រជែង

កសស នៅតែរក្សាបានឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- លក្ខណៈអំណោយផលនៃទីតាំងភូមិសាស្ត្រ
  - កសស ស្ថិតក្នុងឆកសមុទ្រខេត្តព្រះសីហនុ ដែលផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនទៅកាន់ទីផ្សារអន្តរជាតិសំខាន់ៗ។ ការដឹកជញ្ជូនពី កសស ទៅកាន់កំពង់ផែក្នុងអាស៊ីប៉ាស៊ីហ្វិច ពុំចាំបាច់ឆ្លងកាត់ចំណតផែមេក្នុងតំបន់ឡើយ ពោលគឺការដឹកជញ្ជូនអាចធ្វើឡើងដោយផ្ទាល់តែម្តង។ ក្រៅពីនេះការដឹកជញ្ជូន ក៏មានភាពងាយស្រួលផងដែរទៅកាន់កំពង់ផែហុងកុង ឬសិង្ហបុរី ដែលជាច្រកទ្វារទៅកាន់ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ។
  - មិនងាយរងគ្រោះដោយកត្តាធម្មជាតិ ដូចជា ព្យុះធំៗ រញ្ជួយដីជាដើម ដោយសារឆកសមុទ្រនេះមាន អំណោយផលស្រាប់ពីធម្មជាតិ ។
  - ចំណតឆ្នេរមិនតម្រូវឱ្យមានការបូមស្តារខ្សាច់ ឬកករច្រើនឡើយ ដែលនេះអាចធ្វើឱ្យ កសស មិនចាំបាច់ចំណាយច្រើនលើការបូមស្តារឃ្លង ឬផ្លូវនាវាឡើយ ។
- ហេដ្ឋារចនាសម្ព័ន្ធសម្បូរបែប និងទំនើប
  - កសស មានបំពាក់នូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បំរើឱ្យប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ដូចជាប្រព័ន្ធគ្រប់គ្រងចរាចរណ៍នាវា VTMS ជាដើម។ បច្ចុប្បន្នសមត្ថភាពលើកដាក់កុងតែន័ររបស់ កសស បានកើនឡើងរហូតដល់ ៨០០.០០០ TEUs ក្រោយពីបានបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ ប្រភេទ QC ចំនួន ០១ គ្រឿង RTG ចំនួន ០២ គ្រឿង និងរថលើកដាក់កុងតែន័រទទេ Empty Reach Stacker ចំនួន ០៤ គ្រឿង បន្ថែមទៀត។ កត្តានេះបានជំរុញផលិតភាពរបស់ កសស ឱ្យកើនជាងមុន និងកាត់បន្ថយពេលវេលាកកស្ទះទំនិញ។

- លើកកំពស់ប្រសិទ្ធភាពការងារ
  - ប្រសិទ្ធការងារត្រូវបានលើកកម្ពស់ តាមរយៈការពង្រឹងការគ្រប់គ្រង ដោយអនុវត្តអភិបាលកិច្ចល្អក្រោយពេលចុះបញ្ជីលក់មូលបត្រ ។
  - ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការអនុវត្តការងារ ដោយមានការគាំទ្រពីបំពាក់ឋបនីយកណ្ដូរផែបន្ថែមដូចជា រថចល័តលើទីលានផែ និងរថចល័តលើគែមផែជាដើម ។
  - ការបណ្តុះបណ្តាល និងការលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំចំពោះបុគ្គលិក និយោជិត ពិសេសអនុវត្តការងារផ្ទាល់ដើម្បីពង្រឹងស្មារតី និងកំលាំងចិត្តក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញសេវាកម្មជូនអតិថិជន។
- តម្លៃសេវាកម្មមានលក្ខណៈប្រកួតប្រជែង
  - កសស នៅរក្សាតម្លៃសេវាកម្មរបស់ខ្លួនឱ្យមានលក្ខណៈប្រកួតប្រជែង ជាការទាក់ទាញអតិថិជនគួបផ្សំនឹងការពង្រឹងគុណភាពសេវាកម្មរបស់ខ្លួន ។
- រក្សាទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ
  - កសស បានរក្សាទំនាក់ទំនងល្អជាមួយអតិថិជនរបស់ខ្លួន ដោយព្យាយាមបំពេញតាមតម្រូវការរបស់អតិថិជន ទទួលយកយោបល់ និងការរិះគន់ក្នុងន័យស្ថាបនា ដើម្បីស្វែងយល់ពីចំនុចខ្វះខាតរបស់ខ្លួនក្នុងទិសដៅកែលម្អបន្ថែមទៀត ។
  - កសស ក៏រក្សាកិច្ចសហប្រតិបត្តិការជាមួយកំពង់ផែក្នុងតំបន់ក្នុងការចែកចាយព័ត៌មាន និងបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីលើកស្ទួយសេវាកម្មរបស់ខ្លួន ។

## ឆ- ផែនការអនាគត

ទស្សនទាន នៃការអភិវឌ្ឍន៍ កសស រយៈពេល ១០ឆ្នាំ (២០២០-២០៣០)
ផែនការអភិវឌ្ឍន៍រយៈពេលខ្លី-មធ្យម-វែង របស់ កសស រួមមាន៖

❖ គម្រោងបំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់

ចាប់ពីឆ្នាំ២០២២ ដល់ ឆ្នាំ២០២៤ កសស គ្រោងនឹងបំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់ប្រភេទរថស្ទូចចល័តលើគែមផែ (QC) ចំនួន ០២ គ្រឿង រថស្ទូចចល័តនៅទីលាន (RTG) ចំនួន ០៦ គ្រឿង បន្ថែមទៀត។ បន្ទាប់ពី កសស បានបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ប្រភេទ QC ចំនួន ០២ គ្រឿង RTG ចំនួន ០៤ គ្រឿង និងរថយន្តសណ្តោងរ៉ឺម៉ក ចំនួន ០៨ គ្រឿង រួចហើយ ធ្វើឱ្យសមត្ថភាពលើកដាក់កុងតែន័ររបស់ កសស ឈានដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២២ នេះ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររបស់ទីលាន កសស |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២២ នេះ |
| ធាតុសំខាន់ៗ នៃគម្រោង | • បំពាក់គ្រឿងចក្រ ប្រភេទ QC ០២ គ្រឿង RTG ០៦ គ្រឿង និងរថយន្តសណ្តោងរ៉ឺម៉ក ចំនួន ០៨ គ្រឿង នៅឆ្នាំ២០២២ ដើម្បបង្កើនសមត្ថភាពលើកដាក់កុងតែន័រនៅទីលានឱ្យបានដល់ ៨០០.០០០TEUs ក្នុង ០១ ឆ្នាំ។ |

| | |
|---|---|
| | • ពង្រីកផ្លូវរត់គ្រឿងចក្រ QC ប្រវែង ២៥ ម៉ែត្រ នៅចំណតផែកុងតែន័រ ដើម្បីអនុញ្ញាតឱ្យនាវាកុងតែន័រ ០២ គ្រឿង ចូលចត និងលើកដាក់បានប្រកបដោយប្រសិទ្ធិភាព និងផលិតភាព (បានរៀបចំក្នុងផែនការអាជីវកម្មឆ្នាំ២០២២)។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាអ្នកអនុវត្ត |
| ប្រភពថវិកា | ថវិកា កសស ផ្ទាល់ |
| តម្លៃប៉ាន់ស្មានគម្រោង | USD ២១.០៣៧.០០០,០០ |

❖ គម្រោងកែសម្រួលផែប្រាំងទំនិញទូទៅ (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ

បរិមាណកុងតែន័រឆ្លងកាត់ កំពង់ផែក្រុងព្រះសីហនុ មានកំណើនខ្ពស់ ដោយសម្រេចបាន ៧៥០.១៤៨ TEUs នៅឆ្នាំ២០២២។ កសស រំពឹងទុកថានឹងមានកំណើនបន្តទៀត ស្របតាមកំណើនសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីការរាលដាលនៃជម្ងឺ Covid-19 ត្រូវបានបញ្ចប់ ។

ជាមួយនឹងកំណើនបរិមាណកុងតែន័រដែលបានឆ្លងកាត់នាពេលអនាគត កសស រំពឹងទុកថានឹងហួសសមត្ថភាពលើកដាក់ទំនិញ (៨០០.០០០ TEUs នៅឆ្នាំ២០២៣) ទោះបីជាបានទិញបន្ថែមនូវមធ្យោបាយគ្រឿងចក្រលើកដាក់កុងតែន័រ និងការងារពង្រីកទីលានរួចរាល់ហើយក៏ដោយ។

ដូច្នេះ ការងារកែសម្រួលផែប្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ ដើម្បីក្លាយជាចំណតកុងតែន័រមួយបន្ថែមទៀត ដែលបច្ចុប្បន្នមានត្រឹមតែពីរចំណតប៉ុណ្ណោះ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររបស់ទីលាន កសស |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២៣ នេះ |
| ជាតុសំខាន់ៗនៃគម្រោង | • ការងារកែសម្រួលផែប្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ម៉ែត្រ) ទៅជាចំណតផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ<br>• ការងារខួងគ្រឹះ និងលទ្ធកម្មដែករ៉ែ សម្រាប់ពង្រីកផ្លូវរត់របស់គ្រឿងចក្រលើកដាក់កុងតែន័រនៅគែមផែ (QC)<br>• ការងាររៀបចំក្រាលទីលានសម្រាប់គ្រឿងចក្រ (RTG) (តំបន់ឃ្លាំងលេខ៥ មិនរាប់បញ្ចូលទីលាន (RTG) និងប្រព័ន្ធបង្ហូរទឹក ...។ ល។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាអ្នកអនុវត្ត |
| ប្រភពថវិកា | ថវិកា JICA ដែលសល់ពីគម្រោងលេខៈ CP-P10 |
| តម្លៃប៉ាន់ស្មានគម្រោង | USD ១០.១០៧.០០០,០០ |

❖ គម្រោងសាងសង់ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ ជម្រៅ -១៤,៥ ម៉ែត្រ

ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ គឺជាគម្រោងអភិវឌ្ឍន៍ផែកុងតែន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក -១៤,៥ ម៉ែត្រ រួមបញ្ចូលទាំង ការបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប ប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង និងមធ្យោបាយលើកដាក់កុងតែន័រមួយចំនួន។ ល។

គម្រោងនេះ ទទួលបានហិរញ្ញប្បទានសម្បទានពីទីភ្នាក់ងារ JICA ដែលគ្រោងនឹងចាប់ផ្តើមការងារសាងសង់នៅចុងឆ្នាំ២០២២ ហើយបញ្ចប់ការងារសាងសង់និងដាក់ឱ្យប្រតិបត្តិការ ឆ្នាំ២០២៦ ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតែន័រនៅកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយរបស់ប្រទេសកម្ពុជា និងប្រសិទ្ធិភាពផ្នែកភស្តុភារកម្ម ដោយការសាងសង់ចំណតផែកុងតែន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ ព្រមទាំងអភិវឌ្ឍន៍បបនីយកណ្ឌផ្សេងទៀត អាចអនុញ្ញាតឱ្យនាវាកុងតែន័រ ដែលមានសមត្ថភាពផ្ទុក ៤.០០០ TEUs (៦០.០០០ DWT) ចូលចតបាន (ប្រមាណ ៩៣% នៃនាវាកុងតែន័រក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក)។ ចំណតផែកុងតែន័រថ្មីនេះ គ្រោងនឹងបញ្ចប់ការសាងសង់ និងដាក់ឱ្យដំណើរការនៅចុងឆ្នាំ២០២៦ ដែលមានសមត្ថភាពឱ្យកុងតែន័រឆ្លងកាត់បានប្រមាណ ៤៥០.០០០ TEUs/១ឆ្នាំ ធ្វើឱ្យសមត្ថភាពសរុបផែកុងតែន័រ កសស នឹងកើនឡើងដល់ ១.២៥០.០០០ TEUs/១ឆ្នាំ នៅឆ្នាំ២០២៦ (សមត្ថភាពបន្ថែមរបស់ផែច្រាំង ១០០.០០០ TEUs/១ឆ្នាំ ព្រមទាំងធ្វើឱ្យតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ដែលអាចរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ។ |
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតែន័រដល់ ១.២៥០.០០០ TEUs ក្នុង១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រ នេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៦ ខាងមុខ។ |
| ធាតុសំខាន់ៗនៃគម្រោង | • សាងសង់ចំណតផែកុងតែន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ ទីលានកុងតែន័រ និងបបនីយកណ្ឌផែ ព្រមទាំងការងារបូមស្តារអាងនាវា និងឃ្លងនាវា ប្រវែង ៤គីឡូម៉ែត និងជម្រៅ -១៣,៥ ម៉ែត្រ។ ល។<br>• បំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់ រួមមាន QC ០៣ គ្រឿង RTG ០៩ គ្រឿង រថលើកកុងតែន័រទទេ (Empty Reach Stacker) ចំនួន ០២ គ្រឿង ក្បាលសណ្តោងកុងតែន័រ ចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម ០១ កំភ្លេ។ ល។ |
| ទីតាំងគម្រោង | ស្ថិតនៅភាគខាងកើតនៃចំណតផែកុងតែន័រមានស្រាប់ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលក ចំងាយប្រមាណ ៣០០ ម៉ែត្រ ពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅកាន់ទីលានផែកុងតែន័រ។ ផ្ទៃដីសរុបទំហំ ១៧,៥ ហិកតា ។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាម្ចាស់គម្រោង (Employer) ។ |

| | |
|---|---|
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA (លេខៈ CP-P21) តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ២៣.៥០២.០០០.០០០ ប្រហាក់ប្រហែលនឹង USD ២០៣.០០០.០០០,០០ |
| ដំណាក់កាលនៃការអនុវត្តន៍គម្រោង | **ដំណាក់កាលទី១ ៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)**<br>-ជំហានទី១ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ក្រុមសិក្សា JICA បានចុះមកសិក្សា និងរៀបចំរបាយការណ៍ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី កំពង់ផែក្រុងព្រះសីហនុ ។<br>-ជំហានទី២ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ទីភ្នាក់ងារ JICA បានចុះមកសិក្សា និងវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី កំពង់ផែក្រុងព្រះសីហនុ ដោយសម្រេចចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាន សម្បទាន លេខៈ CP-P21 នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>**ដំណាក់កាលទី២៖ ការងារជ្រើសរើសកុងស៊ុលតង់គម្រោង (ឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩)**<br>-ការងារជ្រើសរើសកុងស៊ុលតង់នេះត្រូវបានអនុវត្តតាមនីតិវិធី Single Source Selection (SSS)។ ក្នុងដំណាក់កាលនីមួយៗ ត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA។ សេវាកុងស៊ុលតង់នេះរួមមាន ការងារសិក្សាគំនូសផ្នែកវិស្វកម្ម សំណង់ស៊ីវិល និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ជាដើម ។<br>-ក្រុមហ៊ុន Nippon-Koei & Oriental Consultants Global JV (ក្រុមហ៊ុនជប៉ុន) ត្រូវបានចុះកិច្ចសន្យាជាមួយ កសស នៅខែសីហា ឆ្នាំ២០១៩ ។<br>**ដំណាក់កាលទី៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)**<br>-ជំហានទី១ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)៖ ការរៀបចំគំនូសប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Package-1) និង ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (Package-2) ។<br>-ក្រុមហ៊ុនកុងស៊ុលតង់ NK-OCG JV បានចាប់ដំណើរការការងារផ្នែកគំនូសប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃ សម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ តាំងពីខែកក្កដា ឆ្នាំ២០១៩ ហើយបានដាក់ជូន កសស នៅខែមិថុនា ឆ្នាំ២០២០។ ប៉ុន្តែការងារផ្នែកគំនូសប្លង់វិស្វកម្មនេះ ត្រូវបានកែសម្រួលឱ្យស្របតាមកិច្ចសម្រួលពាណិជ្ជកម្ម ព្រមទាំងផលប៉ះពាល់ជាសកលដោយសារជម្ងឺកូវីដ-១៩ បណ្តាលឱ្យមានការពន្យាពេលអនុវត្តគម្រោង និងបានដាក់ជូន កសស សារជាថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២១ ។<br>-ជំហានទី២ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតែន័រថ្មី (Package-1) (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣) និង ②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (Package-2) (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣)។ |

| | |
|---|---|
| | ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ហើយត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតែន័រថ្មី និងផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (ចុងឆ្នាំឆ្នាំ២០២៣ ដល់ចុងឆ្នាំ២០២៦)**<br>-ដំហានទី១ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦)៖ ការងារសាងសង់ចំណតផែកុងតែន័រថ្មីគ្រោងនឹងចាប់ផ្តើមនៅពាក់កណ្តាល ឆ្នាំ២០២២ ហើយបញ្ចប់ការងារនៅឆ្នាំ២០២៥ (៣៦ខែ) ។<br>-ដំហានទី២ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦)៖ ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់គ្រោងនឹងចាប់ផ្តើមនៅ ឆ្នាំ២០២៣ ហើយគ្រោងបញ្ចប់ការងារនៅ ឆ្នាំ២០២៥ (២៨ខែ)។<br>**ដំណាក់កាលទី ៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៧)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ដូចខាងក្រោមៈ<br>-ការងារសាងសង់ចំណតផែកុងតែន័រថ្មី (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៧)<br>-ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៧)។ |
| វឌ្ឍនភាពគម្រោង | កិច្ចព្រមព្រៀងប្រាក់កម្ចី បានចុះហត្ថលេខានៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី ចូលជាធរមាន នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី បញ្ចប់សុពលភាព នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ ។<br>-កិច្ចសន្យាផ្នែកសេវាកុងស៊ុលតង់ រវាង កសស និងក្រុមហ៊ុន NK-OCG JV ចុះថ្ងៃទី ០៨ខែសីហា ឆ្នាំ២០១៩ ។<br>-សេវាកុងស៊ុលតង់ផ្នែកគំនូសប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃសម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ បានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០១៩ ហើយគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២០។ ប៉ុន្តែ គម្រោងនេះ ត្រូវបានពន្យាពេលដោយសារផលប៉ះពាល់ជាសកលដោយសារការរីករាលដាល នៃជម្ងឺកូវីដ១៩ និងការកែសម្រួលគំនូសប្លង់លំអិតឱ្យស្របតាមកិច្ចសម្រួលពាណិជ្ជកម្ម នោះ ឯកសារដេញថ្លៃកែសម្រួលថ្មី បានដាក់ជូន កសស សាជាថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២១ ។<br>-រហូតដល់ដើមខែមីនា ឆ្នាំ២០២៣នេះ ការងារជ្រើសរើសក្រុមហ៊ុនសាងសង់ បានឈានដល់ដំណាក់ កាលវាយតម្លៃលើលក្ខណៈបច្ចេកទេស របស់ក្រុមហ៊ុនដេញថ្លៃ ។ ជាលទ្ធផល ក្រុមហ៊ុន Penta- Ocean & Rinkai JV និង ក្រុមហ៊ុន TOA Corporation បានជាប់លក្ខណៈបច្ចេកទេស។ រីឯ ក្រុមហ៊ុន JV CHEC & SUMEC បានត្រូវវាយតម្លៃធ្លាក់លក្ខណៈបច្ចេកទេស។ របាយការណ៍វាយតម្លៃ លក្ខណៈបច្ចេកទេស (BER) បានដាក់ស្នើសុំគោលការណ៍ពិនិត្យ និងសម្រេចពី ទីភ្នាក់ងារ JICA នៅដើមខែមីនា ឆ្នាំ២០២៣ ។ |

- គម្រោងពង្រីកចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ (ប្រវែង ៤០០ ម៉ែត្រ ជម្រៅទឹក -១៦,៥ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៣០ ម៉ែត្រ ជម្រៅទឹក -១៧,៥ ម៉ែត្រ) ដោយប្រើប្រាស់កម្ចីជប៉ុន

ជាទស្សនវិស័យ កសស នឹងអភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជិស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណា

ចក្រកម្ពុជា។ នៅពេលចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ ដាក់ឱ្យដំណើរការ កសស នឹងអាចស្រូបទាញនាវាកុងតែន័រធុនធំដែលមានផ្លូវដឹកជញ្ជូនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក មកកាន់ប្រទេសកម្ពុជា ដោយផ្ទាល់ ដោយពុំចាំបាច់ ផ្ទេរ-ផ្ទុក នៅតាមបណ្តាកំពង់ផែផ្សេងៗ ដោយទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ច ពីការកាត់បន្ថយតម្លៃ និងការចំណេញពេលវេលា ក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ។

កសស បានកំពុងប្រែក្លាយជាកំពង់ផែក្នុងតំបន់ដ៏មានសក្តានុពល ជាពិសេស គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជា ហើយតភ្ជាប់ប្រទេសកម្ពុជាទៅកាន់តំបន់ និងពិភពលោក។

ហេតុដូច្នេះ កសស ត្រូវការបន្ទាន់ជាបន្ទាន់នូវការពង្រីកចំណតផែកុងតែន័រទឹកជ្រៅថ្មីទាំងពីរជំហានរួមគ្នាឱ្យបានរួចរាល់នៅឆ្នាំ២០២៨-២០២៩ ដែលជាជម្រើសសិក្សាដោយក្រុមសិក្សា JICA Survey Team៖

១- ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ ប្រវែង ៤០០ម៉ែត្រ និងជម្រៅទឹក -១៦,៥ម៉ែត្រ

- សមត្ថភាពនាវាចំណុះ ១២០.000 DWT ផ្ទុកកុងតែន័រជាមធ្យម ១០.000 TEUs ចូលចតបាននិងការបំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់ មួយចំនួន ។

២- ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី៣ ប្រវែង ៤៣០ម៉ែត្រ និងជម្រៅទឹក -១៧,៥ម៉ែត្រ

- សមត្ថភាពនាវាចំណុះ ១៦០.000 DWT ផ្ទុកកុងតែន័រជាមធ្យម ១៥.000 TEUs ចូលចតបាន និងការបំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់ មួយចំនួន ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០៣០ |
| គោលបំណងនៃគម្រោង | ដើម្បីចូលរួមគាំទ្រដល់កិច្ចសម្រួលពាណិជ្ជកម្ម និងធុរកិច្ចនៅកម្ពុជាកាត់បន្ថយពេលវេលា និងតម្លៃឡូជិស្ទិក ដែលធានាបាន នូវនិរន្តរភាព នៃលំហូរទំនិញចេញ-ចូលប្រកបដោយលក្ខណៈប្រកួតប្រជែងគុណភាពសេវា និងមិនកកស្ទះចរាចរទំនិញនាពេលអនាគត ឆ្លើយតបបាននូវ គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម កម្ពុជាឆ្នាំ២០១៥-២០២៥ នោះ កសស ត្រូវការជាបន្ទាន់ និងសាងសង់ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ (ប្រវែង ៤០០ ម៉ែត្រ ជម្រៅទឹក-១៦,៥ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៣០ ម៉ែត្រ ជម្រៅទឹក-១៧.៥ ម៉ែត្រ) រួមគ្នា ក្នុងទស្សនវិស័យ កសស នឹងអភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និង ជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជិស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំណតផែកុងតែន័រទឹកជ្រៅថ្មីនេះ នឹងអាចស្រូបទាញនាវាកុងតែន័រធុនធំដែលមានផ្លូវដឹកជញ្ជូនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក មកកាន់ ប្រទេសកម្ពុជា ដោយផ្ទាល់ ដោយពុំចាំបាច់ ផ្ទេរ-ផ្ទុក នៅតាមបណ្តាកំពង់ផែផ្សេងៗ ដោយទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ច ពីការកាត់បន្ថយតម្លៃ និងការចំណេញពេលវេលា ក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ។ ជាមួយនេះ កសស បានកំពុងប្រែក្លាយជាកំពង់ផែក្នុងតំបន់ដ៏មានសក្តានុពលជាពិសេស គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជា ហើយតភ្ជាប់ប្រទេសកម្ពុជា ទៅកាន់តំបន់ និងពិភពលោក ។ |

| | |
|---|---|
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រឈានដល់ ២.៥០០.០០០ TEUs ក្នុង១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ នេះ ដាក់ឱ្យប្រតិបត្តិការនៅឆ្នាំ ២០៣០ ខាងមុខ។ |
| ធាតុសំខាន់ៗនៃគម្រោង | ១-ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ ប្រវែង ៤០០ ម៉ែត្រ និងជម្រៅទឹក -១៦,៥ ម៉ែត្រ (សមត្ថភាពនាវាចំណុះ ១២០.000DWT ផ្ទុកកុងតែន័រជាមធ្យម ១០.000 TEUs ចូលចតបាន) និងការបំពាក់មធ្យោបាយលើកដាក់កុងតែន័រទំនើប ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។<br>២-ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី៣ ប្រវែង ៤៣០ម៉ែត្រ និងជម្រៅទឹក -១៧.៥ម៉ែត្រ (សមត្ថភាពនាវាចំណុះ ១៦០.000DWT ផ្ទុកកុងតែន័រជាមធ្យម ១៥.000TEUs ចូលចតបាន) និងការបំពាក់មធ្យោបាយលើកដាក់កុងតែន័រទំនើប ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។ |
| ទីតាំងគម្រោង | បន្តពីចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលកចំងាយប្រមាណ ៦៥០ ម៉ែត្រ ពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅទីលានចំណតផែកុងតែន័រថ្មី ។ ផ្ទៃដីសរុបទំហំ ៤២.៥ ហិកតា ។ |
| ភ្នាក់ងារអនុវត្តគម្រោង | កសស ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាម្ចាស់គម្រោង (Employer) ។ |
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ៦៤.៩៧៣.000.000 ស្មើនឹងប្រមាណ USD ៥៧0.000.000,00<br>(បានទទួលប្រាក់កម្ចី JICA លើកទី១៖ ចំនួន JPY ៤១.៣៨៨.000.000 ស្មើនឹងប្រមាណ USD ៣៦0.000.000,00) |
| ដំណាក់កាលនៃគម្រោង | ដំណាក់កាលទី១៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)<br>-ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)៖ ក្រុមសិក្សា JICA Survey Team បានកំពុងចុះសិក្សា និងរៀបចំរបាយការណ៍ ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងទី៣ រួមគ្នា ព្រមទាំងធ្វើការវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ទឹកជ្រៅថ្មីទាំងពីរជំហានរួមគ្នា ដើម្បីផ្តល់ប្រាក់កម្ចីសម្បទាន ។<br>ដំណាក់កាលទី២៖ ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣) ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ សម្រាប់គម្រោងពង្រីកចំណតផែកុងតែន័រ-ជំហានទី២ និងជំហានទី៣ ដោយត្រូវបានអនុវត្តតាមនីតិវិធី ផ្តល់ឈ្មោះបញ្ជីខ្លីក្រុមហ៊ុនកុងស៊ុលតង់ (Shortlisted Consultants) ដោយដៃគូអភិវឌ្ឍន៍។ សេវាកុងស៊ុលតង់នេះ រួមមានការងារសិក្សាគំនូសប្លង់ផ្នែកវិស្វកម្មសំណង់ស៊ីវិល សម្រាប់ NCT2 & NCT3 ជំនួយការរៀបចំឯកសារដេញថ្លៃ និងការងារត្រួតពិនិត្យលើការងារសាងសង់ សម្រាប់ការជ្រើសរើសក្រុមហ៊ុនម៉ៅការសំណង់ សម្រាប់ NCT2 & NCT3 ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប និងការងារផ្គត់នាវាបម្រើប្រតិបត្តិការ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុង |

| | |
|---|---|
| | ពេលធានារយៈពេលសាងសង់ ជាដើម ។<br>**ដំណាក់កាលទី៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសំណង់ និងក្រុមហ៊ុនផ្គត់ផ្គង់មធ្យោបាយលើកដាក់កុងតែន័រទំនើប (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)**<br>-ជំហានទី១ (ដើមឆ្នាំ២០២៣ ដល់ដើមឆ្នាំ២០២៤)៖ ការរៀបចំគំនូសប្លង់វិស្វកម្ម សម្រាប់ ①ការងារសំណង់ស៊ីវិល-ជំហានទី២ (Package-1) ② ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប (Package-2) និង③ ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ជំហានទី២ (ចុងឆ្នាំ២០២៣ ដល់ចុងឆ្នាំ២០២៤)៖ ការរៀបចំគំនូសប្លង់វិស្វកម្ម សម្រាប់ការងារសំណង់ស៊ីវិល-ជំហានទី៣ (Package-4)<br>-ជំហានទី៣ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)៖ ① ការជ្រើសរើសក្រុមហ៊ុនសាងសង់-ជំហានទី២ (Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ជំហានទី៤ (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់-ជំហានទី៣ (Package-4)<br>ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ ការងារផ្គត់ផ្គង់មធ្យោបាយលើកដាក់កុងតែន័រទំនើប និងការងារនាវាបម្រើប្រតិបត្តិការ (ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៩)**<br>-ជំហានទី១ (ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៨) (៣៦ខែ)៖ ①ការងារសាងសង់ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២(Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ជំហានទី២ (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៩) (៤២ខែ)៖ ①ការងារសាងសង់ចំណតផែកុងតែន័រទឹកជ្រៅ ថ្មី-ជំហានទី៣(Package-4) ។<br>**ដំណាក់កាលទី៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៨ ដល់ឆ្នាំ២០៣០)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ។ |
| វឌ្ឍនភាពគម្រោង | នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ កសស បានអញ្ជើញ ក្រុមហ៊ុន Shortlisted Consults ចំនួន ៥ក្រុមហ៊ុន ដែលផ្តល់ដោយទីភ្នាក់ងារ JICA រួមមានក្រុមហ៊ុន៖ ១). ក្រុមហ៊ុន Environmental Consultants for Ocean and Human (ECOH Corporation), ២). ក្រុមហ៊ុន Japan Port Consultants, Ltd (JPC), ៣). ក្រុមហ៊ុន Nippon Koei Co., Ltd (NK), ៤). ក្រុមហ៊ុន Oriental Consultants Global Co., Ltd (OCG) និង៥). ក្រុមហ៊ុន The Overseas Coastal Area Development Institute of Japan (OCDI) មកទទួលយកសំណើសុំ (RFP) ដោយកំណត់កាលបរិច្ឆេទឈប់ទទួលសំណើសុំ (RFP) នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅវេលាម៉ោង ១៤:00 រសៀល។ ជាលទ្ធផល ក្រុមហ៊ុន ចំនួន ០២ បានបដិសេធមិនចូលរួមដាក់សំណើសុំ (RFP) រួមមាន៖ ១) ក្រុមហ៊ុន |

| | |
|---|---|
| | Environmental Consultants for Ocean and Human (ECOH Corporation) និង ២). ក្រុមហ៊ុន Japan Port Consultants, Ltd (JPC) ។ ចំណែកឯក្រុមហ៊ុន ចំនួន ០៣ ផ្សេងទៀត បានធ្វើ Joint Venture ដោយដាក់សំណើសុំ (RFP) រួមតែមួយ ជាក្រុមហ៊ុន JV-Nippon Koei and Oriental Consultant Global in association with OCDI និង បានធ្វើការបើកឯកសារ សំណើសុំ (RFP) ដោយគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម ។ |

## ៩- គត្តាហានិភ័យ

សម្រាប់ឆ្នាំ២០២២ នេះ កសស មិនមានការវិភាគអំពីហានិភ័យនោះទេ ។

# ផ្នែកទី ២

# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

# ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| បរិយាយ | ឯកត្តា | ផែនការ ២០២២ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| បរិមាណទំនិញឆ្លងកាត់ | តោន | ៧.៤១៨.០០០ | ៧.០០៣.១៥៧ | ៦.៩៩០.៣៣៧ | ៦.៦០១.៨០៤ | -៥,៥៩% | ០,១៨% | ៦,០៨% |
| ជាកុងតែន័រ | _ | | ៥.០៣១.៩៨៨ | ៤.៩៩៩.៨០១ | ៤.៣៦៣.៩០៩ | | ១,៦៦% | ១៥,៣១% |
| ទំនិញរាយ | _ | | ១៤២.៩៤៤ | ២៥០.៧៣៤ | ៣៤៩.៨២០ | | -៤២,៩៩% | -៥៩,១៤% |
| ប្រេង | | | ១.៧២៩.៧០០ | ១.៧៣៧.០៤៧ | ១.៨០៤.៣៥២ | | -០,៤២% | -៤,១៤% |
| ហ្គាស | _ | | ៩៨.៥២៥ | ៥២.៧៥៥ | ៨៣.៧២២ | | ៨៦,៧៦% | ១៧,៦៨% |
| បរិមាណទំនិញនាំចូល | _ | ៥.៥៦៤.០០០ | ៥.២២៥.២៣៦ | ៥.២០៣.៨១៩ | ៤.៨៨៧.៦៨៤ | -៦,០៩% | ០,៤១% | ៦,៩១% |
| ជាកុងតែន័រ | _ | | ៣.២៥៤.៤៩៩ | ៣.១៩១.១៨៧ | ២.៦៧០.៧៧០ | | ១,៩៨% | ២១,៨៦% |
| ទំនិញរាយ | _ | | ១.៩៧០.៧៣៧ | ២.០១២.៦៣២ | ២.២១៦.៩១៤ | | -២,០៨% | -១១,១០% |
| បរិមាណទំនិញនាំចេញ | _ | ១.៨៥៤.០០០ | ១.៧៧៧.៩២១ | ១.៧៨៦.៥១៨ | ១.៧១៤.១២០ | -៤,១០% | -០,៤៨% | ៣,៧២% |
| ជាកុងតែន័រ | _ | | ១.៧៧៧.៤៨៩ | ១.៧៥៨.៦១៤ | ១.៦៩៣.១៤០ | | ១,០៧% | ៤,៩៨% |
| ទំនិញរាយ | _ | | ៤៣២ | ២៧.៩០៤ | ២០.៩៨០ | | -៩៨,៤៥% | -៩៧,៩៤% |
| បរិមាណទំនិញលើករៀប | _ | ១០.២៩៨.០០០ | ១១.២៣៩.៤៣៤ | ១០.១៩៩.១៤៨ | ៨.៩៥៤.៣១៧ | ៩,១៤% | ១០,២០% | ២៥,៥២% |
| ប្រគល់ផ្ទាល់ | _ | ២២០.០០០ | ១២១.១៨០ | ២០១.៩២៣ | ២០៨.៣២៩ | | -៣៩,៩៩% | -៤១,៨៣% |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | _ | ១០.០៧៨.០០០ | ១១.១១៨.២៥៣ | ៩.៩៩៧.២២៥ | ៨.៧៤៥.៩៨៨ | | ១១,២១% | ២៧,១២% |
| បរិមាណកុងតែន័រឆ្លងកាត់ | TEUs | ៧៨៧.០០០ | ៧៥០.១៤៨ | ៧៣២.៣៨៧ | ៦៤១.៨៤២ | -៤,៦៨% | ២,៤៣% | ១៦,៨៧% |
| នាំចូល | _ | | ៣៩៥.១១៤ | ៣៨០.១៤៥ | ៣២០.៦៤២ | | ៣,៩៤% | ២៣,២៣% |
| មានទំនិញ | _ | | ៣៤៣.១៥២ | ៣៤០.៥៦៧ | ២៩៥.៦៣១ | | ០,៧៦% | ១៦,០៧% |
| គ្មានទំនិញ | _ | | ៥១.៩៦២ | ៣៩.៥៧៨ | ២៥.០១១ | | ៣១,២៩% | ១០៧,៧៦% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| នាំចេញ | _ | | ៣៥៥.០៣៤ | ៣៥២.២៤២ | ៣២១.២០០ | | ០,៧៩% | ១០,៥៣% |
| មានទំនិញ | _ | | ២១៨.៩១៣ | ២២១.៤៨៥ | ២០០.០៥៨ | | -១,១៦% | ៩,៤២% |
| គ្មានទំនិញ | _ | | ១៣៦.១២១ | ១៣០.៧៥៧ | ១២១.១៤២ | | ៤,១០% | ១២,៣៦% |
| ចំនួននាវាចូលចត | គ្រឿង | ១.៤៥០ | ១.៤៤២ | ១.៥៨២ | ១.៦៦២ | -០,៥៥% | -៨,៨៥% | -១៣,២៤% |
| ចំណុះផ្ទុកនាវា | តោន | ១៤.១២៨.០០០ | ១៤.១០៨.០៣២ | ១៣.៣៦៦.៣៩៩ | ១៦.៧៨៤.៩៧៩ | -០,១៤% | ៥,៥៥% | -១៥,៩៥% |
| នាវាដឹកកុងតែន័រ | គ្រឿង | | ៦៨៨ | ៦៥៥ | ៦៧០ | | ៥,០៤% | ២,៦៩% |
| ចំណុះនាវាដឹកកុងតែន័រ | តោន | | ៩.៥០៨.៩៣៧ | ៩.០៣៤.៤០៩ | ១០.១៨៨.៥៨៥ | | ៥,២៥% | -៦,៦៧% |
| នាវាដឹកប្រេង និងហ្គាស | គ្រឿង | | ៥១៣ | ៤៨៣ | ៥៨៧ | | ៦,២១% | -១២,៦១% |
| ចំណុះនាវាដឹកប្រេង និងហ្គាស | តោន | | ២.១៦៨.៩៨៥ | ២.០០៣.៩៦៤ | ២.៣៦២.០៤៤ | | ៨,២៣% | -៨,១៧% |
| នាវាដឹកទំនិញទូទៅ | គ្រឿង | | ២៣៨ | ៣១០ | ៣០៧ | | -២៣,២៣% | -២២,៤៨% |
| ចំណុះនាវាដឹកទំនិញទូទៅ | តោន | | ២.២៣៦.៤៣៧ | ២.៣២៨.០២៦ | ២.៧៦៥.៧៥៣ | | -៣,៩៣% | -១៩,១៤% |
| នាវាទេសចរណ៍ | គ្រឿង | | ៣ | ០ | ១៨ | | ១០០,០០% | -៨៣,៣៣% |
| នាវាទេសចរណ៍ | តោន | | ១៩៣.៦៧៣ | ០ | ១.៤៦៨.៥៩៧ | | ១០០,០០% | -៨៦,៨១% |
| ចំនួនទេសចរ | នាក់ | | ២៣១ | ០ | ១៧.៧៨៩ | | ១០០,០០% | -៩៨,៧០% |


ចំណុះផ្ទុកនាវាចូលចត កសស
១២,០០០,០០០
១០,០០០,០០០
៨,០០០,០០០
៦,០០០,០០០
៤,០០០,០០០
២,០០០,០០០
០
៩.៥០៨.៩៣៧
៩.០៣៤.៤០៩
១០.១៨៨.៥៨៥
២.១៦៨.៩៨៥
២.០០៣.៩៦៤
២.៣៦២.០៤៤
២.២៣៦.៤៣៧
២.៣២៨.០២៦
២.៧៦៥.៧៥៣
១៩៣.៦៧៣
០
១.៤៦៨.៥៩៧
នាវាកុងតែន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០២២
ឆ្នាំ២០២១
ឆ្នាំ២០២០


ចំនួននាវាចូលចត កសស
៨០០
៦០០
៤០០
២០០
០
៦៨៨
៦៥៥
៦៧០
៥១៣
៤៨៣
៥៨៧
២៣៨
៣១០
៣០៧
៣
០
១៨
នាវាកុងតែន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០២២
ឆ្នាំ២០២១
ឆ្នាំ២០២០


បរិមាណកុងតែន័រឆ្លងកាត់ កសស (TEUs)
ឆ្នាំ២០២០
ឆ្នាំ២០២១
ឆ្នាំ២០២២
នាំចេញគ្មានទំនិញ
១២១.១៩៤២
១៣០.៧៥៧
១៣៦.១២១
នាំចេញមានទំនិញ
២០០.០៥៨
២២១,៤៨៥
២១៨.៩១៣
នាំចូលគ្មានទំនិញ
២៥.០១១
៣៩.៥៧៨
៥១.៩៦២
នាំចូលមានទំនិញ
២៩៥.៦៣១
៣៤០.៥៦៧
៣៤៣.១៩៤២
០
៥០,០០០
១០០,០០០
១៥០,០០០
២០០,០០០
២៥០,០០០
៣០០,០០០
៣៥០,០០០
៤០០,០០០


ប្រទេសនាំចេញកុងតែន័រ ប្រចាំឆ្នាំ២០២២
២%
៦%
១១%
៧%
៧%
៣២%
៣៤%
ចិន
អឺរ៉ុប
អាមេរិក
អាស៊ី
អង់គ្លេស
ជប៉ុន
ផ្សេងៗ


ប្រទេសនាំចូលកុងតែន័រ ប្រចាំឆ្នាំ២០២២
៤%
៣%
០%
២២%
៦១%
៦%
៣%
ចិន
អឺរ៉ុប
អាមេរិក
អាស៊ី
អង់គ្លេស
ជប៉ុន
ផ្សេងៗ

## ខ- រចនាសម្ព័ន្ធចំណូល

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន ( Stevedoring ) | ១៦៤.៨៧៣.៤៤៥ | ៤៧,៩៦% | ១៥៨.៥៦៦.៤៩៩ | ៤៦,៣២% | ១៤៤.៨៣៨.៣៣៩ | ៤៦,៤៥% |
| ចំណូលលើកដាក់លើទីលាន ( LOLO ) | ៩៦.៩២០.១៩៦ | ២៨,២០% | ១០០.៦០២.០៤៦ | ២៩,៣៩% | ៨៣.៨២១.៧៧៥ | ២៦,៨៨% |
| ចំណូលពីសេវាកម្មនាវាចរ | ៦២.២៨៥.០៥០ | ១៨,១២% | ៦៥.០១៦.២៦៧ | ១៨,៩៩% | ៦៧.៥៨៣.៩៨៥ | ២១,៦៧% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ១៥.៥១៦.៩៧៥ | ៤,៥១% | ១៤.៣៧៤.៤៨៨ | ៤,២០% | ១១.៣៧៧.៧៨៥ | ៣,៦៥% |
| ចំណូលដឹកជញ្ជូន | ៩២.០៩០ | ០,០៣% | ១២២.៣២៦ | ០,០៤% | ៦៤.៨១៣ | ០,០២% |
| ចំណូលនាវាទេសចរណ៍ | ០ | ០,០០% | ០ | ០,០០% | ២៦៥.៦៤៥ | ០,០៩% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ២.៣៧៤.៦៩៦ | ០,៦៩% | ២.១៩៥.៨៦៩ | ០,៦៤% | ២.៤០៧.៧២២ | ០,៧៧% |
| ចំណូលជួលទីតាំង | ១.៣៨៥.៥៥៣ | ០,៤០% | ១.១៦៨.២៤៨ | ០,៣៤% | ១.១៤០.៨៣១ | ០,៣៧% |
| ចំណូលផ្សេងៗទៀត | ២៩៥.៥៣៩ | ០,០៩% | ៣០៣.៤៨៦ | ០,០៩% | ៣១២.៨៧៤ | ០,១០% |
| **ចំណូលសរុប** | **៣៤៣.៧៤៣.៥៤៥** | **១០០,០០%** | **៣៤២.៣៤៩.២២៩** | **១០០,០០%** | **៣១១.៨១៣.៧៦៩** | **១០០,០០%** |

# ផ្នែកទី ៣

# ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

# ក- អង្គការលេខ

## រចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ



## ខ- ក្រុមប្រឹក្សាភិបាល

### សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់ អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯ.ឧ លូ គឹមឈន់ | ប្រធាន | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ២ | ឯ.ឧ ស៊ុយ សាន | សមាជិក | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ៣ | ឯ.ឧ ផាន់ផល្លា | សមាជិក | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ៤ | ឯ.ឧ សុខ សុភ័ក្ត្រ | សមាជិក | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | សមាជិក | ២៥-មិថុនា-២០២១ | ២៤-មិថុនា-២០២៤ |
| ៦ | លោក Hidetoshi KUME | សមាជិក | ២៥-មិថុនា-២០២១ | ២៤-មិថុនា-២០២៤ |
| ៧ | លោក លូ លីខេង | សមាជិក | ២១-មិថុនា-២០២១ | ២០-មិថុនា-២០២៤ |

## គ- បុគ្គលិកជាន់ខ្ពស់

### សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះអភិបាល | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯ.ឧ លូ គឹមឈន់ | ប្រុស | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ២ | លោក ណុំ ស៊ីនិត | ប្រុស | មន្ត្រីត្រួតពិនិត្យរដ្ឋ អមកំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ៣ | លោក ថៃ ឬទ្ធី | ប្រុស | អគ្គនាយករង អាជីវកម្ម |
| ៤ | លោក ថោង វីរ៉ូ | ប្រុស | អគ្គនាយករង រដ្ឋបាល-គ្រប់គ្រង |
| ៥ | លោក ទីសាគុណ | ប្រុស | អគ្គនាយករង បច្ចេកទេស |
| ៦ | លោក វ័ន្ទ សិលា | ប្រុស | ប្រធាននាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស |
| ៧ | លោក ពិត ប្រាកដ | ប្រុស | ប្រធាននាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ |
| ៨ | លោក សូ សៀង | ប្រុស | ប្រធាននាយកដ្ឋាន ផែនការ លទ្ធកម្ម និងស្ថិតិ |
| ៩ | លោក អ៊ុក វណ្ណារ៉ា | ប្រុស | ប្រធាននាយកដ្ឋាន បច្ចេកទេស-សម្ភារៈ |
| ១០ | លោកស្រី ជ័យ សុគន្ធា | ស្រី | ប្រធាននាយកដ្ឋាន ទីផ្សារ |
| ១១ | លោក ជីវ ច័ន្ទសុផល | ប្រុស | ប្រធាននាយកដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស |
| ១២ | លោក ងួន រតនា | ប្រុស | ប្រធាននាយកដ្ឋាន អាជីវកម្ម |
| ១៣ | លោក ថៃ ម៉េងលី | ប្រុស | ប្រធាននាយកដ្ឋាន ប្រតិបត្តិការទីលានកុងតែន័រ |
| ១៤ | លោក លូ លីខេង | ប្រុស | ប្រធាននាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ |
| ១៥ | លោក ស៊ឹង សេណូ | ប្រុស | ប្រធាននាយកដ្ឋាន នាវាចរ-កណ្ណធារ និងសន្តិសុខ |
| ១៦ | លោក គឹម ហោ | ប្រុស | ប្រធាននាយកដ្ឋាន គ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី |
| ១៧ | លោក ម៉ែន ចាន់ | ប្រុស | ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង |
| ១៨ | លោក សោម ករណី | ប្រុស | ប្រធាននាយកដ្ឋាន ព័ត៌មានវិទ្យា |
| ១៩ | លោក មាន គឹង | ប្រុស | ប្រធាននាយកដ្ឋាន សំណង់-វិស្វកម្ម |

**សម្គាល់៖ ព័ត៌មានលំអិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាមួយឧបសម្ព័ន្ធ។**

# ផ្នែកទី ៤
# ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- ព័ត៌មានអំពីមូលបត្រ

ឈ្មោះមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”
និមិត្តសញ្ញាមូលបត្រកម្មសិទ្ធ : PAS (កសស)
ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”
តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ១.០០០ រៀល
ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិសទ្ធិ : ៥.០៤០ រៀល (១.២៥៩ ដុល្លារអាមេរិក)
បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: ២១.៤៤២.៩៩២ មូលបត្រ
មូលធនូបនីយកម្មទីផ្សារ : ១០៨.០៧២.៦៧៩.៦៨០ រៀល (២៦.៩៩១.១៧៩ ដុល្លារអាមេរិក)
ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : ផ្សារមូលបត្រកម្ពុជា
កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ : ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបរមា | ១៣.៣៦០ | ១៤.១០០ | ១៤.៣០០ | ១៤.១០០ | ១៤.៣២០ | ១៤.៥០០ | ១៣.៨៦០ | ១៣.៦៨០ | ១៣.២៨០ | ១៣.០០០ | ១៣.២៤០ | ១៣.៣២០ |
| | អប្បបរមា | ១៣.២៨០ | ១៣.២៨០ | ១៣.៧៦០ | ១៣.៨៤០ | ១៣.៨៨០ | ១៣.៨០០ | ១៣.៦៨០ | ១៣.១៨០ | ១២.៨០០ | ១២.៨០០ | ១២.៩៨០ | ១២.៩២០ |
| | មធ្យម | ១៣.៣១៧ | ១៣.៥៦០ | ១៤.០៣២ | ១៣.៩៤៥ | ១៤.០៣៨ | ១៤.២២៤ | ១៣.៧៧៣ | ១៣.៣៦១ | ១៣.១២០ | ១២.៩០២ | ១៣.១២៩ | ១៣.១០៤ |
| បរិមាណជួញដូរ (ភាគហ៊ុន) | អតិបរមា | ២.០៧០ | ៧.៣២០ | ១០.២៥០ | ៣.៥១១ | ៥.៣១២ | ២១.៧៩៥ | ៥.០៧៦ | ៧.០៤៧ | ១១.៨៥៣ | ៣.៨៤៤ | ១.៥៥៩ | ៤.៦២៧ |
| | អប្បបរមា | ៤៩ | ១៥៨ | ២១៧ | ៩៦ | ១០៧ | ២៣៩ | ៩៤ | ៨៣ | ៧៧ | ១៣៨ | ១០៨ | ៣៦ |
| | មធ្យម | ៨២៨ | ២.៧៣៦ | ១.៩៤០ | ១.០៩៥ | ១.៨១០ | ៤.២៤៨ | ១.២៦៥ | ១.៣៥៤ | ១.៦៦២ | ១.០៨២ | ៧០៩ | ១.២២៩ |

## គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោត ចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៦៤.៣២៨.៩៧៥ | ៧៥,០០% |
| **សរុប** | | | **៦៤.៣២៨.៩៧៥** | **៧៥,០០%** |

## ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | KAMIGUMI CO., LTD | ជប៉ុន | ១១.១៥០.៣២៤ | ១៣,០០% |
| **សរុប** | | | **១១.១៥០.៣២៤** | **១៣,០០%** |

## ខ- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|
| ចំណេញសុទ្ធ | ៩៣.៧០៧.៣៩០.០០០ រៀល | ២៦.៦០៧.៥៩៨.០០០ រៀល | ៤៣.៤៦៣.៥០០.០០០ រៀល |
| ភាគលាភជាសាច់ប្រាក់សរុប | ១៦.១០៧.២៦៧.៩៦៨ រៀល | ១២.១៧៤.៦៤៩.២៧៦ រៀល | ១២.១៧៤.៦៤៩.២៧៦ រៀល |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | មិនមាន | មិនមាន | មិនមាន |
| ភាគលាភផ្សេងទៀត | មិនមាន | មិនមាន | មិនមាន |
| អនុបាតនៃការបែងចែកភាគលាភ (%) | ១៧,១៩% | ៤៥,៧៦% | ៣១,១២% |
| ទិន្នផលភាគលាភ(%) | ១០,០០% | ៨,០០% | ៨,០០% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៥០៤ រៀល | ៤០៣ រៀល | ៤០៣ រៀល |

# ផ្នែកទី ៥

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# ផ្នែក ក: ខ្លឹមសារសង្ខេប

## ១. សាវតារ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានធ្វើសវនកម្មលើសកម្មភាពគ្រប់គ្រងប្រតិបត្តិការ អនុលោមភាពនិងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលដំណើរការដោយ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ ២០២២ ដែលជាផ្នែកមួយនៃផែនការសកម្ម ភាពសវនកម្មឆ្នាំ២០២២ ក្នុងកម្មវិធីសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០២២-២០២៤ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។ របាយការណ៍នេះ ឆ្លុះបញ្ចាំងអំពីលទ្ធផលសវនកម្ម អនុសាសន៍របស់សវនករ និងវិធានការកែលម្អរបស់សវនដ្ឋាន ។

## ២. ហានិភ័យគន្លឹះ

**ជាទូទៅហានិភ័យរួមមាន៖**

- ហានិភ័យប្រតិបត្តិការ : ជាហានិភ័យលើការបាត់បង់ ដែលជាលទ្ធផលបរាជ័យនៃដំណើរការអនុវត្តរបស់មនុស្ស និងប្រព័ន្ធគ្រប់គ្រង ឬ ពីហេតុការណ៍ខាងក្រៅ;
- ហានិភ័យហិរញ្ញវត្ថុ : ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងមិនត្រឹមត្រូវធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប
- ហានិភ័យអនុលោមភាព : ជាលទ្ធភាពដែលសកម្មភាពអនុវត្ត មិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ដោយឡែក ការធ្វើសវនកម្មនៅតាមសវនដ្ឋានខាងលើ សវនករបានកំណត់ហានិភ័យគន្លឹះមួយចំនួនដូចខាងក្រោម៖

- លទ្ធភាពប៉ះពាល់លើគុណភាពនៃការផ្តល់សេវាកម្មសាធារណៈ;
- លទ្ធភាពប៉ះពាល់ដល់ការគ្រប់គ្រងបុគ្គលិក វិន័យ និងប្រសិទ្ធភាពការងារ;
- លទ្ធភាពប៉ះពាល់ដល់អនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន; និង
- លទ្ធភាពប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

## ៣. វិសាលភាពសវនកម្ម

ដំណើរការសវនកម្មនេះ គ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងកិច្ចប្រតិបត្តិការដែលបានអនុវត្តដោយនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ ២០២២។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើសវនកម្មត្រូវបានធ្វើឡើងនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសស។ ក្រុមការងារសវនកម្មនឹងរាយការណ៍តែអំពីចំណុចខ្វះខាត និងចំណុចដែលត្រូវផ្តល់អនុសាសន៍កែលម្អប៉ុណ្ណោះ ។

របាយការណ៍សវនកម្មជាភាសាអង់គ្លេស ត្រូវបានរៀបចំឡើងពីរបាយការណ៍សវនកម្មជាភាសាខ្មែរ។ ក្នុងករណីមានភាពខុសប្លែកគ្នារវាងភាសាទាំងពីរ របាយការណ៍សវនកម្មជាភាសាខ្មែរ ត្រូវមានអាទិភាពក្នុងការបកស្រាយ។

## ៤. គោលបំណងសវនកម្ម

គោលបំណងក្នុងការធ្វើសវនកម្មនេះ គឺដើម្បីវាយតម្លៃនិងធ្វើឱ្យប្រសើរឡើង នូវប្រសិទ្ធភាពនៃដំណើរការគ្រប់ គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អក្នុងទីសវនកម្ម ដែលស្ថិតក្នុងវិសាលភាពសវនកម្ម ។

ជាទូទៅ ការងារសវនកម្មផ្តោតសំខាន់លើការបញ្ជាក់ថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្តល់នូវការធានាសមហេតុផលដើម្បីសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- គោលបំណងប្រតិបត្តិការ : ការសម្រេចបានប្រកបដោយប្រសិទ្ធភាព នូវគោលបំណងប្រតិបត្តិការការងារជាក់ស្តែង;
- គោលបំណងព័ត៌មានហិរញ្ញវត្ថុ : ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ;
- គោលបំណងអនុលោមភាព : ការអនុលោមតាមច្បាប់ គោលការណ៍ និងនីតិវិធីជាធរមាន។

ក្នុងការធ្វើសវនកម្មនេះ សវនករបានកំណត់គោលបំណងសវនកម្មសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ពង្រឹងអនុលោមភាព ប្រសិទ្ធភាពអនុវត្ត និងប្រសិទ្ធផលការងារ;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង ប្រើប្រាស់និងថែរក្សាមធ្យោបាយ សម្ភារ ឧបករណ៍;
- ពង្រឹងប្រសិទ្ធភាពអនុវត្ត ជំនាញបច្ចេកទេស ថែទាំ-ជួសជុល គ្រឿងចក្រ;
- ពង្រឹងប្រសិទ្ធភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យា និងការផ្សព្វផ្សាយព័ត៌មាននៅក្នុងគេហទំព័រ;
- ពង្រឹងប្រសិទ្ធិភាពប្រតិបត្តិការអាជីវកម្ម-សេវាកម្ម ការថែទាំបរិស្ថាន និងទ្រព្យសម្បត្តិនៅក្នុង តសព;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង ថែទាំម៉ាស៊ីនភ្លើង;
- ពង្រឹងអនុលោមភាព និងប្រសិទ្ធភាពអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ កសស;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងបំណុល និងចំណូលអាជីវកម្មរបស់ កសស; និង
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្មផ្តោតសំខាន់លើដំណើរការមានហានិភ័យ ដែលត្រូវបានប្រើប្រាស់ក្នុងការងារសវនកម្មនេះ ។ អភិក្រមសវនកម្មរាប់បញ្ចូល៖

- ការកត់ត្រាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង តាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធ និងការសម្ភាសន៍មន្ត្រី;
- ការកំណត់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងគន្លឹះ និងប្រៀបធៀបជាមួយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលបានរំពឹងទុក;
- ការធ្វើតេស្តសវនកម្មអំពីប្រសិទ្ធភាពប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ។

តាមរយៈនេះ ក្រុមការងារសវនកម្មបានសហការជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាន ដើម្បីកំណត់ការរំពឹងទុក។

## ៦. សង្ខេបលទ្ធផលគន្លឹះ

**ក្រុមការងារសវនកម្ម បានសង្កេតឃើញចំណុចខ្វះចន្លោះមួយចំនួន តាមរយៈការពិនិត្យ៖**

១. របាយការណ៍វឌ្ឍនភាពការងារក្នុងត្រីមាសទី ១ ឆ្នាំ ២០២២;

២. ទំនិញស្តុកទុករយៈពេលយូរនៅក្នុងឃ្លាំងលេខ ៤ នៃ កសស;
៣. របាយការណ៍ចំណាយប្រេងឥន្ធនៈសម្រាប់មធ្យោបាយលើកដាក់;
៤. បញ្ជីសារពើភណ្ឌរថយន្ត និងគ្រឿងចក្រ;
៥. ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងឃ្លាំងលេខ ៣ និងឃ្លាំងលេខ ៥ នៃ កសស;
៦. មធ្យោបាយជើងទឹក (នាវាសណ្តោង);
៧. របាំងការពារនាវា (Fenders);
៨. របាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានសំណង់-វិស្វកម្ម;
៩. តារាងរថយន្តនិងគ្រឿងចក្រ នៃផ្នែកគ្រឿងចក្រសំណង់;
១០. របាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានបច្ចេកទេស-សម្ភារ;
១១. វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស ថែទាំ-ជួសជុល គ្រឿងចក្រ;
១២. របាយការណ៍សម្ភាសន៍តំណាងក្រុមហ៊ុនដឹកជញ្ជូនដោយនាវា (Shipping Lines) ក្រុមហ៊ុនផែស្ងួត សមាគមភស្តុភារកម្ពុជា និងសមាគមកម្ពុជាដឹកជញ្ជូនដោយរថយន្ត អំពីសេវាប្រតិបត្តិការ និងការនាំចូល-ចេញតាមច្រកទ្វារ កសស;
១៣. ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារ ២០២៣-២០២៥;
១៤. បច្ចុប្បន្នភាពនៃគេហទំព័ររបស់ កសស;
១៥. កម្មវិធី Mobile App (Mobile Application Program) របស់ កសស;
១៦. របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ក្នុងត្រីមាសទី ៣ ឆ្នាំ ២០២២ នៅ តសព នៃ កសស;
១៧. ស្ថានភាពបរិស្ថាននៅជុំវិញបរិវេណអាគារ Service Apartment និងអន្តេវាសិកដ្ឋាន (Dormitory);
១៨. វគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញបើកបរគ្រឿងចក្រ;
១៩. របាយការណ៍ម៉ាស៊ីនភ្លើងនិងការថែទាំ;
២០. ការគោរពគោលការណ៍វិន័យ និងពេលវេលាធ្វើការរបស់និយោជិត កម្មករ កសស ដែលបម្រើការងារផ្នែកអាជីវកម្ម និងផ្នែកប្រយោល (នាយកដ្ឋាន);
២១. តារាងទូទាត់ប្រាក់បៀវត្សនិយោជិតក្នុងក្របខណ្ឌ កសស;
២២. ឯកសារដេញថ្លៃផ្គត់ផ្គង់ទំនិញ សម្រាប់ឆមាសទី១ ឆ្នាំ២០២២;
២៣. របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២;
២៤. របាយការណ៍ស្ថានភាពបំណុលអតិថិជនជំពាក់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ; និង
២៥. តារាងសរុបសារពើភណ្ឌអចលនទ្រព្យឆ្នាំ២០២២ ។

## ៧. សេចក្តីសន្និដ្ឋានរួម

ផ្អែកតាមលទ្ធផលសវនកម្មសម្រាប់ការិយបរិច្ឆេទ ២០២២ នៅ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តូជានិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ក្រុមការងារសវនកម្មបានពិនិត្យឃើញថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយចំនួនត្រូវបានរៀបចំបានល្អប្រសើរ និងមានកិច្ចសហការពីមន្ត្រី បុគ្គលិក កម្មករ គ្រប់ជាន់ថ្នាក់

ទោះបីជាការអនុវត្តមួយចំនួននៅមិនទាន់បានពេញលេញ និងគ្រប់ជ្រុងជ្រោយដើម្បីធានាបាន នូវប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនៅពេលអនាគតក៏ដោយ ។ ក្រុមការងារសវនកម្មបានកត់សម្គាល់ឃើញថា ចំណុចខ្វះខាតខាងលើពាក់ព័ន្ធនឹងអនុលោមភាពតាមច្បាប់ ប្រសិទ្ធភាពអនុវត្ត និងប្រសិទ្ធផលនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើការពង្រឹងនិងកែលម្អជាបន្តបន្ទាប់ ។

## ៨. វិធានការកែលម្អ

អនុសាសន៍ដែលបានផ្តល់ជូន ក្នុងគោលបំណងដើម្បីធ្វើឱ្យល្អប្រសើរឡើង នូវការអនុវត្តដំណើរការធុរកិច្ច និងការគ្រប់គ្រងរបស់សវនដ្ឋាន ត្រូវបានបញ្ចូលក្នុងលទ្ធផលលម្អិត (ផ្នែក ខ)។ អនុសាសន៍អំពីការខ្វះចន្លោះមួយចំនួនត្រូវបានឯកភាព ជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាននីមួយៗជាលាយលក្ខណ៍អក្សរ ។ លទ្ធផលលម្អិត (ផ្នែក ខ) ក៏បានរំលេចអំពីការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងសវនដ្ឋាន ចំពោះអនុសាសន៍របស់សវនករ និងចំណុចខ្វះខាតផងដែរ។

វិធានការរបស់ថ្នាក់ដឹកនាំសវនដ្ឋាន ត្រូវបានរំលេចនៅក្នុងផែនការកែលម្អដូចមានចែងនៅក្នុង ឧបសម្ព័ន្ធទី២ ដែលបានភ្ជាប់មកជាមួយ ។

## ៩. អំណរគុណ

ក្រុមការងារសវនកម្មដែលដឹកនាំដោយលោក **ម៉ែន ចាន់** សូមថ្លែងអំណរគុណចំពោះលោកនាយក លោកស្រីនាយិកាគ្រប់នាយកដ្ឋានរួមមាន នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ព្រមទាំងសហការីដែលបានសហការផ្តល់ព័ត៌មាន ឯកសារនិងមតិយោបល់ដ៏មានតម្លៃដើម្បីជួយជំរុញឱ្យការងារសវនកម្មនេះអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក ។

# ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត

## ១. សមាសភាពចូលរួម និងខណៈគោល

### ១.១ សមាសភាពក្រុមការងារសវនកម្មផ្ទៃក្នុង

| | | |
|---|---|---|
| - លោក ម៉ែន ចាន់ | នាយក | ប្រធានក្រុម |
| - លោក ជីវ ច័ន្ទសុភាព | នាយករង | អនុប្រធាន |
| - លោក ហោ សុជី | នាយករង | អនុប្រធាន |
| - លោក មាស សុវណ្ណា | ប្រធានការិយាល័យ | សមាជិក |
| - លោក ជីវ ច័ន្ទសុធា | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី ទូច វណ្ណា | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី វ័ត្ន និមល | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី ឧន សុខុម | បុគ្គលិក | សមាជិក |
| - លោកស្រី ឈុន ហឿនរីណា | បុគ្គលិក | សមាជិក |
| - លោក ភាព ម៉េងស្រៀន | បុគ្គលិក | សមាជិក |
| - លោកស្រី តេង សុវណ្ណស្រីរ័ត្ន | បុគ្គលិក | សមាជិក |

## ១.២ សមាសភាពរួមសវនដ្ឋាន

### ១.២.១ នាយកដ្ឋានអាជីវកម្ម

| | | |
|---|---|---|
| - លោក ងួន វេតនា | នាយក | សវនដ្ឋាន |
| - លោក ស៊ូ ឡុងស្រ៊ីន | នាយករង | សវនដ្ឋាន |

### ១.២.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ

| | | |
|---|---|---|
| - លោក ថៃ ម៉េងលី | នាយក | សវនដ្ឋាន |
| - លោក ហ៊ាង សុផល | នាយករង | សវនដ្ឋាន |
| - លោក សេក សុវណ្ណារ៉ា | នាយករង | សវនដ្ឋាន |

### ១.២.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ

| | | |
|---|---|---|
| - លោក លូ លីខេង | នាយក | សវនដ្ឋាន |
| - លោក អ៊ុក សុវណ្ណារិទ្ធ | នាយករង | សវនដ្ឋាន |
| - លោក យឹង កុយ | នាយករង | សវនដ្ឋាន |

### ១.២.៤ នាយកដ្ឋាននាវាចរ-កណ្ណធារនិងសន្តិសុខ

| | | |
|---|---|---|
| - លោក ស៊ឹង សេណូ | នាយក | សវនដ្ឋាន |
| - លោក ចាន់ សុខា | នាយករង | សវនដ្ឋាន |
| - លោក សែន សុថា | នាយករង | សវនដ្ឋាន |

### ១.២.៥ នាយកដ្ឋានសំណង់ - វិស្វកម្ម

| | | |
|---|---|---|
| - លោក មាន គឹង | នាយក | សវនដ្ឋាន |
| - លោក ងឹម ញ៉ | នាយករង | សវនដ្ឋាន |
| - លោក ឈឹម ហ៊រ | នាយករង | សវនដ្ឋាន |

### ១.២.៦ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ

| | | |
|---|---|---|
| - លោក អ៊ុក វណ្ណារ៉ា | នាយក | សវនដ្ឋាន |
| - លោកស្រី សរ ម៉ាលីន | នាយិការង | សវនដ្ឋាន |

### ១.២.៧ នាយកដ្ឋានទីផ្សារ

| | | |
|---|---|---|
| - លោកស្រី ជ័យ សុគន្ធា | នាយិកា | សវនដ្ឋាន |
| - លោក ម៉ៅ សាម៉ន | ប្រធានការិយាល័យ | សវនដ្ឋាន |
| - លោក យិន រី | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.៨ នាយកដ្ឋានព័ត៌មានវិទ្យា

| | | |
|---|---|---|
| - លោក សោម ករណី | នាយក | សវនដ្ឋាន |
| - លោក ស្រ៊ន់ ពិសី | បុគ្គលិក | សវនដ្ឋាន |

### ១.២.៩ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស

| | | |
|---|---|---|
| - លោក ជីវ ច័ន្ទសុផល | នាយក | សវនដ្ឋាន |
| - លោក ហេង សុខសាន្ត | នាយករង | សវនដ្ឋាន |
| - លោក ហាក់ ណារិទ្ធ | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.១០ នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី

| | | |
|---|---|---|
| - លោក គឹម ហោ | នាយក | សវនដ្ឋាន |
| - លោក យ៉ែម សល់ | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

| | | |
|---|---|---|
| - លោក វ័ត្ថ សិលា | នាយក | សវនដ្ឋាន |
| - លោក សាន ឈន់ | នាយករង | សវនដ្ឋាន |

### ១.២.១២ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ

| | | |
|---|---|---|
| - លោក សូ សៀង | នាយក | សវនដ្ឋាន |
| - លោក អ៊ុក សុមេធី | នាយករង | សវនដ្ឋាន |
| - លោក ខឹម ស៊ីថា | នាយករង | សវនដ្ឋាន |

### ១.២.១៣ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

| | | |
|---|---|---|
| - លោក ពិត ប្រាកដ | នាយក | សវនដ្ឋាន |
| - លោក សម សុភាព | នាយករង | សវនដ្ឋាន |
| - លោក អ៊ូ សុវណ្ណឫទ្ធិ | នាយករង | សវនដ្ឋាន |
| - លោក សែម សុភា | នាយករង | សវនដ្ឋាន |

## ១.៣ ខណៈគោល

**ខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្ម៖**

| | |
|---|---|
| ➢ សេចក្តីព្រាងលើកទី ១ បានបញ្ចប់ | ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២៣ |
| ➢ ការធ្វើសវនកម្មបានបញ្ចប់ | ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៣ |
| ➢ ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំសវនដ្ឋាន | ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២៣ |
| ➢ របាយការណ៍ស្ថាពរ | ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៣ |

# ២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុង គឺដើម្បីជួយថ្នាក់ដឹកនាំសវនដ្ឋាន ក្នុងដំណើរការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុងនិងអភិបាលកិច្ចល្អ ។ ការគ្រប់គ្រងផ្ទៃក្នុងត្រូវបានអនុវត្ត ដោយថ្នាក់ដឹកនាំសវនដ្ឋាននិងមន្ត្រីមួយចំនួនទៀត ដើម្បីធានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- ➢ ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ
- ➢ របាយការណ៍ហិរញ្ញវត្ថុដែលអាចទុកចិត្តបាន
- ➢ អនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន ។

ការធ្វើសវនកម្មនេះ ក៏ពិនិត្យលើការរៀបចំនិងប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផងដែរ ។

## ៣. ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

ក្រុមការងារសវនកម្ម បានវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដោយផ្អែកលើសមត្ថភាពនៃដំណើរការគ្រប់គ្រងដើម្បីសម្រេចលក្ខណៈវិនិច្ឆ័យគ្រប់ចំនួន ៧ រួមមាន៖ ការផ្តល់សិទ្ធិ ភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព ការការពារសុវត្ថិភាពនិងសន្តិសុខរូបវន្ត ព្រមទាំងការដោះស្រាយកំហុសឆ្គងនិងការបែងចែកការងារ ស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ចរបស់ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ។

## ៤. ព័ត៌មានអំពីសវនដ្ឋាន

នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ស្ថិតក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយអនុលោមតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតនិងការប្រព្រឹត្តិទៅនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) និងដំណើរការតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងតួនាទី-ភារកិច្ចសម្រាប់នាយកដ្ឋាននីមួយៗ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **កសស** ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ និងសេចក្តីសម្រេចកែសម្រួលរចនាសម្ព័ន្ធ និងការបំពេញបន្ថែមតួនាទី-ភារកិច្ច ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២០ ។

### ៤.១ នាយកដ្ឋានអាជីវកម្ម (អជក)

នាយកដ្ឋានអាជីវកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៤ នាក់ ក្នុងនេះមានស្ត្រី ០៣ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប និងប្រធានការិយាល័យ ០៦ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦៤ សសរ/កសស/អជក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ប្រតិបត្តិការ និងកិច្ចសន្យា;

(២) ការិយាល័យ អាជីវកម្ម និងសរុបរបាយការណ៍;

(៣) ការិយាល័យ ទំនាក់ទំនង និងគ្រប់គ្រងការដឹកជញ្ជូន;

(៤) ការិយាល័យ ប្រព័ន្ធព័ត៌មានវិទ្យា;

(៥) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍; និង

(៦) ការិយាល័យ តំណាង **កសស** ប្រចាំភ្នំពេញ ។

### ៤.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ (ប្រទក)

នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកកម្មករសរុបចំនួន ៥១១ នាក់ ក្នុងនេះមានស្ត្រី ៣៩ នាក់ បុគ្គលិកជាប់កិច្ចសន្យា ២១២ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៨ រូបជាជំនួយការស្របតាមតួនាទី-

ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៨ សសរ/កសស/ប្រទក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ទិន្នន័យ និងរបាយការណ៍;
(២) ការិយាល័យ ផែនការនាវា;
(៣) ការិយាល័យ ផែនការទីលាន;
(៤) ការិយាល័យ ប្រតិបត្តិការ;
(៥) ការិយាល័យ គ្រប់គ្រងបុគ្គលិក;
(៦) ការិយាល័យ គ្រឿងចក្រ;
(៧) ការិយាល័យ ទីលានសំបកកុងតែន័រ (ECD); និង
(៨) ការិយាល័យឃ្លាំង (LCL) ។

## ៤.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ (ប្រទទ)

នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិក សរុបចំនួន ២៣២ នាក់ ក្នុងនេះមានស្ត្រី ១០ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៦៥ នាក់ និងបុគ្គលិកជួល ៥ នាក់ និង ត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៦ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៩ សសរ/ កសស/ប្រទទ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍ និងគ្រប់គ្រងសុវត្ថិភាព;
(២) ការិយាល័យ គ្រប់គ្រង ឃ្លាំង-ទីលានទំនិញទូទៅ;
(៣) ការិយាល័យ កត់ត្រា-ជញ្ជីង និងគ្រប់គ្រងព័ត៌មាននាវា;
(៤) ការិយាល័យ គ្រប់គ្រងឯកសារ និងរបាយការណ៍;
(៥) ការិយាល័យ គ្រឿងចក្រទំនិញទូទៅ; និង
(៦) ការិយាល័យ លើកដាក់ទំនិញ ។

## ៤.៤ នាយកដ្ឋាននាវាចរ-កណ្តាលជារនិងសន្តិសុខ (នវកជ)

នាយកដ្ឋាននាវាចរ-កណ្តាលជារនិងសន្តិសុខ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិក កម្មករ សរុបចំនួន ១៣៣ នាក់ ក្នុងនេះមានស្ត្រី ០២ នាក់ បុគ្គលិកជាប់កិច្ចសន្យា ១៥ នាក់ និងត្រូវបាន ដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៥ រូប និងប្រធានការិយាល័យ ១០ រូបជាជំនួយការ ស្របតាម តួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦០ សសរ/កសស/នវកជ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ កណ្តាលជារ;
(២) ការិយាល័យ ទិន្នន័យ និងសរុប;
(៣) ការិយាល័យ នាវាចរ;
(៤) ការិយាល័យ VTMS និង បណ្តុះបណ្តាល;
(៥) ការិយាល័យ ទំនាក់ទំនងសាធារណៈ ស្រាវជ្រាវ និងអភិវឌ្ឍន៍;
(៦) ការិយាល័យ គ្រប់គ្រងមធ្យោបាយដើងទឹក;
(៧) ការិយាល័យ គ្រប់គ្រងអាងនាវាសណ្តោង;

(៨) ការិយាល័យ សន្តិសុខ និងសុវត្ថិភាព; និង

(៩) ការិយាល័យ រៀបចំសណ្តាប់ធ្នាប់សាធារណៈ ។

## ៤.៥ នាយកដ្ឋានសំណង់-វិស្វកម្ម (សណវក)

នាយកដ្ឋានសំណង់-វិស្វកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិក កម្មករសរុប ចំនួន ១១៥ នាក់ ក្នុងនេះមានស្ត្រី ០២ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៤៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៥ រូប និងប្រធានការិយាល័យ ១២ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ចដូច មានចែងនៅក្នុងសេចក្តីសម្រេចលេខ ០២៤ សសរ/កសស/សណវក ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២០៖

(១) ការិយាល័យ សំណង់-ជួសជុល និងថែទាំ;

(២) ការិយាល័យ អគ្គិសនី;

(៣) ការិយាល័យ ស្ថាបត្យកម្ម និងសិក្សាគម្រោង;

(៤) ការិយាល័យ ឃ្លាំងសម្ភារសំណង់;

(៥) ការិយាល័យ គ្រប់គ្រងឯកសារលទ្ធកម្មសំណង់;

(៦) ការិយាល័យ វិស្វកម្ម;

(៧) ការិយាល័យ វាស់ស្ទង់;

(៨) ការិយាល័យ សរុបនិងរបាយការណ៍;

(៩) ការិយាល័យ គ្រឿងចក្រសំណង់;

(១០) ការិយាល័យ ឃ្លាំងប្រេង;

(១១) ការិយាល័យ អ៊ូនាវា; និង

(១២) ការិយាល័យ ពោងសញ្ញា ។

## ៤.៦ នាយកដ្ឋានបច្ចេកទេស-សម្ភារ (បទស)

នាយកដ្ឋានបច្ចេកទេស-សម្ភារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកកម្មករ សរុបចំនួន ៧៥ នាក់ ក្នុងនេះមានស្ត្រី ០៣ នាក់ បុគ្គលិកជាប់កិច្ចសន្យា ២២ នាក់ និងត្រូវបានដឹកនាំដោយ នាយក ០១ រូប អមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៩ រូបជាជំនួយការ៖

(១) ការិយាល័យ សម្ភារបច្ចេកទេស-បន្លាស់;

(២) ការិយាល័យ គ្រប់គ្រងឯកសារលទ្ធកម្ម;

(៣) ការិយាល័យ ឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់;

(៤) ការិយាល័យ ប្រេងឥន្ធនៈ-ប្រេងរំអិល;

(៥) ការិយាល័យ ស្រាវជ្រាវអេកិវឡូន៍;

(៦) ការិយាល័យ ព័ត៌មានវិទ្យា;

(៧) ការិយាល័យ ជួសជុល-ថែទាំ មេកានិច គ្រឿងចក្រ;

(៨) ការិយាល័យ យានដ្ឋាន; និង

(៩) ការិយាល័យ យន្តសាស្ត្រ កប៉ាល់-នាវាសណ្តោង ។

## ៤.៧ នាយកដ្ឋានទីផ្សារ (ទផ)

នាយកដ្ឋានទីផ្សារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិក សរុបចំនួន ១០ នាក់ ក្នុងនេះមានស្ត្រី ០៣ នាក់ និងត្រូវបានដឹកនាំដោយនាយិកា ០១ រូប អមដោយប្រធានការិយាល័យ ០៣ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៧ សសរ/កសស/ទផ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវទីផ្សារ និងអភិវឌ្ឍគុណភាពសេវាកម្ម;
(២) ការិយាល័យ ព័ត៌មានទីផ្សារ;
(៣) ការិយាល័យ ទំនាក់ទំនងអតិថិជន; និង
(៤) ការិយាល័យ សម្របសម្រួល ។

## ៤.៨ នាយកដ្ឋានព័ត៌មានវិទ្យា (ពមវ)

នាយកដ្ឋានព័ត៌មានវិទ្យា នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៥ នាក់ ក្នុងនេះមានស្ត្រី ០១ នាក់ និងបុគ្គលិកស្ម័គ្រចិត្ត ០៣ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ១១៥ សសរ/កសស/ពម.វ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍ និងផ្សព្វផ្សាយ;
(២) ការិយាល័យ គ្រប់គ្រងបណ្តាញ; និង
(៣) ការិយាល័យ ប្រព័ន្ធព័ត៌មានវិទ្យា ។

## ៤.៩ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស (តសព)

នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១០ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៣ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ៣៩៧ សសរ/កសស/តសព ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០៖

(១) ការិយាល័យ រដ្ឋបាល និងព័ត៌មានវិទ្យា;
(២) ការិយាល័យ ភស្តុភារ និងស្រាវជ្រាវ-អភិវឌ្ឍន៍;
(៣) ការិយាល័យ សេវាអតិថិជន; និង
(៤) ការិយាល័យ ថែទាំ និងជួសជុល ។

## ៤.១០ នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី (គ្រចយអន)

នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ៦៧ នាក់ ក្នុងនេះមានស្ត្រី ០១ នាក់ បុគ្គលិកជួល ០១ នាក់ និងស្ម័គ្រចិត្ត ២០ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៤ រូបជាជំនួយការ៖

(១) ការិយាល័យ បច្ចេកទេសអគ្គិសនី;
(២) ការិយាល័យ រដ្ឋបាលសរុបរបាយការណ៍;
(៣) ការិយាល័យ ជួសជុលថែទាំគ្រឿងចក្រ; និង
(៤) ការិយាល័យ គ្រប់គ្រងស្ថានីយអគ្គិសនី ។

## ៤.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស (របធម)

នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **(កសស)** មានមន្ត្រី បុគ្គលិកសរុបចំនួន ១០៨ នាក់ ក្នុងនេះមានស្ត្រី ៣២ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៥៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូបអមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៧ និងជំនួយការឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលឋានៈស្មើប្រធានការិយាល័យ ០១ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៥៩ សសរ/កសស/របធម ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យរដ្ឋបាលនិងកិច្ចការទូទៅ;
(២) ការិយាល័យថែទាំនិងជួសជុល;
(៣) ការិយាល័យគ្រប់គ្រងឃ្លាំង សម្ភាររដ្ឋបាល;
(៤) ការិយាល័យពិធីការ;
(៥) ការិយាល័យថែទាំសុខភាព;
(៦) ការិយល័យព័ត៌មានវិទ្យា;
(៧) ការិយាល័យធនធានមនុស្ស និងស្រាវជ្រាវ-អភិវឌ្ឍន៍;
(៨) ការិយាល័យគ្រប់គ្រងមធ្យោបាយ និងប្រេងឥន្ធនៈ;
(៩) ការិយាល័យបរិស្ថាន និងអនាម័យ; និង
(១០) ការិយាល័យរបៀបនិងឯកសារ ។

## ៤.១២ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ (ផលស)

នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **(កសស)** មានមន្ត្រី បុគ្គលិកសរុបចំនួន ១២ នាក់ ក្នុងនេះមានស្ត្រី ០៥ នាក់ បុគ្គលិកស្ម័គ្រចិត្ត ០១ រូប និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៤ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៦ សសរ/កសស/ផលស ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យផែនការ-វិនិយោគ;
(២) ការិយាល័យលទ្ធកម្មសាធារណៈ;
(៣) ការិយាល័យស្ថិតិ; និង
(៤) ការិយាល័យគ្រប់គ្រងគម្រោង ។

## ៤.១៣ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ (គណហវ)

នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **(កសស)** មានមន្ត្រី បុគ្គលិកសរុបចំនួន ២០ នាក់ ក្នុងនេះមានស្ត្រី ០៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៤ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦២ សសរ/កសស/គណ.ហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យបេឡា;
(២) ការិយាល័យគណនេយ្យ;
(៣) ការិយាល័យអចលនទ្រព្យ;
(៤) ការិយាល័យទីផ្សារមូលបត្រ;
(៥) ការិយាល័យហិរញ្ញកិច្ច;

(៦) ការិយាល័យគ្រប់គ្រងបំណុល;និង
(៧) ការិយាល័យទូទាត់ ។

## ៥. លទ្ធផលសវនកម្ម

## ៥.១ ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្មរបស់ **កសស** ក្នុងគោលបំណងដើម្បីផ្តល់សេវាកម្ម ជូនអតិថិជននិងអ្នកប្រើប្រាស់ផែប្រកបដោយភាពរលូន និងឆាប់រហ័សនិងជួយជំរុញឱ្យសវនដ្ឋាននីមួយៗ អនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន ស្របតាមសេចក្តីកំណត់និងតម្រូវការរបស់អង្គភាព និងអនុលោមតាមលក្ខន្តិកៈបុគ្គលិករបស់ **កសស** ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ៥.២ លទ្ធផលនៃការអង្កេតវិជ្ជមាន

ក្រុមការងារសវនកម្មបានពិនិត្យឃើញថា នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាលធារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ រួមទាំងការិយាល័យនិងផ្នែកពាក់ព័ន្ធ បាននិងកំពុងអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី-ភារកិច្ចដែល **កសស** បានកំណត់ និងបានយកចិត្តទុកដាក់អនុវត្តការងារ តាមមុខជំនាញរៀងៗខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសហការផ្តល់ឯកសារជូនសវនករ ដើម្បីជួយជំរុញឱ្យកិច្ចដំណើរការសវនកម្មផ្ទៃក្នុងរបស់ **កសស** អាចប្រព្រឹត្តទៅបាន ស្របតាមផែនការសកម្មភាពការងារសវនកម្ម និងប្រកបដោយភាពរលូន ។

## ៥.៣ លទ្ធផលនៃការអង្កេតអវិជ្ជមាន

## ៥.៣.១ នាយកដ្ឋានអាជីវកម្ម

### ៥.៣.១.១ ការពិនិត្យរបាយការណ៍វឌ្ឍនភាពការងារក្នុងត្រីមាសទី ១ ឆ្នាំ ២០២២

តាមការឆ្លើយតប ក្នុងកម្រងសំណួរប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សវនករបានកត់សម្គាល់ឃើញថាក្នុងត្រីមាសទី ១ ឆ្នាំ ២០២២ នេះ ការិយាល័យអភិវឌ្ឍនិងស្រាវជ្រាវ ដែលស្ថិតក្នុងក្របខ័ណ្ឌនាយកដ្ឋានអាជីវកម្ម នៅមិនទាន់បានរៀបចំធ្វើរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ០៦៤ សសរ/កសស/អជក ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន តួនាទីនិងភារកិច្ចរបស់បណ្តាការិយាល័យនៃនាយកដ្ឋានអាជីវកម្ម ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០ នៅឡើយ ។

ប្រការនេះ អាចបណ្តាលមកពីការិយាល័យអភិវឌ្ឍ និងស្រាវជ្រាវ/សវនដ្ឋានពុំទាន់មានព័ត៌មានជាមូលដ្ឋានចាំបាច់ដើម្បីរៀបចំវឌ្ឍនភាពការងារ ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃការអនុវត្តតួនាទី-ភារកិច្ចរបស់សវនដ្ឋាន ជាពិសេសពាក់ព័ន្ធនឹងការងារអភិវឌ្ឍនិងស្រាវជ្រាវ ។

ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តតួនាទី-ភារកិច្ចឱ្យកាន់តែល្អប្រសើរឡើងថែមទៀត សវនករយល់ឃើញថាសវនដ្ឋានគួរជម្រុញ ឱ្យការិយាល័យអភិវឌ្ឍនិងស្រាវជ្រាវធ្វើការសិក្សា ខិតខំស្រាវជ្រាវនិង

ប្រមូលព័ត៌មានសំខាន់ៗ ដើម្បីបានជាធាតុចូលសម្រាប់រៀបចំវឌ្ឍនភាពការងារនៅក្នុងសវនដ្ឋាន ក៏ដូចជាក្នុងក្របខ័ណ្ឌ **កសស** ទាំងមូល ។

*ចាប់តាំងពីមានការរាតត្បាតដោយជម្ងឺកូវីដ-១៩ មន្ត្រីទទួលបន្ទុកការងារផ្នែកអភិវឌ្ឍនិងស្រាវជ្រាវតែងតែជួបការលំបាកក្នុងការស្នើសុំជួប អ្នកតំណាងក្រុមហ៊ុននិងកំពង់ផែក្នុងស្រុកនានាដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រ និងគោលដៅអភិវឌ្ឍនៅពេលអនាគត ជាពិសេសគឺគោលនយោបាយតម្លៃ ។ ទោះជាយ៉ាងនេះក្តី សវនដ្ឋាននឹងបន្តខិតខំឱ្យអស់ពីសមត្ថភាព។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

## ៥.៣.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ

### ៥.៣.២.១. ការពិនិត្យទំនិញស្តុកទុករយៈពេលយូរនៅក្នុងឃ្លាំងលេខ ៤ នៃ កសស

យោងតាមរបាយការណ៍សន្និធិរបស់ឃ្លាំងលេខ ៤ គិតត្រឹមថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ សវនករបានពិនិត្យឃើញសន្និធិចម្រុះក្នុងឃ្លាំង តាំងពីអំឡុងឆ្នាំ ១៩៩១, ១៩៩២, ១៩៩៧ ដល់បច្ចុប្បន្នមានចំនួន ៩,៤៥១ ដុំ ស្មើនឹង ៣២១,០៩៦ តោន ហើយហួតដល់ត្រីមាសទី ១ ឆ្នាំ ២០២២ នេះ នៅពុំទាន់មានក្រុមហ៊ុន/តំណាងម្ចាស់ទំនិញណាមួយ ស្នើសុំសមត្ថកិច្ចពាក់ព័ន្ធដើម្បីបញ្ចេញទំនិញទាំងនេះពីឃ្លាំងនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមច្បាប់និងបទប្បញ្ញត្តិគយ បោះពុម្ពលើកទី ៣ ចុះខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងជំពូកទី ៩ មាត្រា ៥៤ ស្តីពីទំនិញគ្មានការទាមទារ ដូចមានចែងក្នុងចំណុចៈ ក) ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬ នៅក្នុងភណ្ឌាគារគយមានដែនកំណត់ ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃច្បាប់នេះ ខ) ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្បជនបដិសេធមិនទទួលយក ឬ គម្បជនពុំត្រូវបានរកឃើញ និងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន គ) ទំនិញនិងមធ្យោបាយដឹកជញ្ជូនពុំជាប់អាយ័តដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ស្របតាមបញ្ញត្តិមាត្រា ៥៥ នៃច្បាប់ស្តីពីគយ កាលណាពុំមានការទាមទារក្នុងរយៈពេលហុកសិប (៦០) ថ្ងៃគិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង ។ ក្នុងករណីពុំអាចរកម្ចាស់ឃើញ ប្រវេសន៍សាធារណៈត្រូវធ្វើតាមពេល និងរបៀបដែលនឹងកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃគិតចាប់ពីថ្ងៃចេញប្រវេសន៍ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ស្របតាមបញ្ញត្តិនៃមាត្រា ៥៥ នៃច្បាប់ស្តីពីគយ ។

មូលហេតុខាងលើ អាចបណ្តាលមកពីភាពខ្វះចន្លោះ ឬ មានការពន្យាពេលក្នុងការរៀបចំបែបបទស្នើសុំបញ្ចេញទំនិញដោយក្រុមហ៊ុន ឬ ភាគីតំណាងម្ចាស់ទំនិញ ។

ប្រការនេះអាចបណ្តាលឱ្យខ្វះទីធ្លាស្តុកទំនិញ ខាតបង់ថ្លៃស្តុក និងប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃ្លាំងជារួម ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការជាមួយក្រុមហ៊ុន ឬ តំណាងម្ចាស់ទំនិញជាទៀងទាត់និងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ឱ្យបានឆាប់ ដើម្បីស្នើសុំស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជួយអន្តរាគមន៍ក្នុងការបញ្ចេញទំនិញឱ្យបានសមស្របតាមច្បាប់និងបទប្បញ្ញត្តិគយ ដូចបានរៀបរាប់ខាងលើ ។

*នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នឹងធ្វើបច្ចុប្បន្នភាពទំនិញដែលស្តុកយូរតាមមុខទំនិញនីមួយៗ ហើយរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីជំរុញខាងសមត្ថកិច្ចគយ ដើម្បីយកទំនិញស្តុកយូរទាំងនេះចេញពីឃ្លាំងលេខ ៤ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

#### ៥.៣.២.២. ការពិនិត្យរបាយការណ៍ចំណាយប្រេងឥន្ធនៈ លើមធ្យោបាយលើកដាក់

យោងតាមរបាយការណ៍ចំណាយប្រេងឥន្ធនៈលើមធ្យោបាយលើកដាក់ សវនករបានពិនិត្យឃើញៈ ១) មធ្យោបាយលើកដាក់-RTG លេខសម្គាល់ 213, 214 ផលិតឆ្នាំ 2017 និង RTG ម៉ាក ZPMC លេខសម្គាល់ 217, 218 ផលិតឆ្នាំ 2018, ២) មធ្យោបាយលើកដាក់-RTG ម៉ាក ZPMC លេខសម្គាល់ 215, 216 ផលិតឆ្នាំ 2017, ៣) STACKER ម៉ាក KALMAR លេខសម្គាល់ 111, 112, 113, 114 ផលិតឆ្នាំ 2019 កំពុងប្រើប្រាស់ប្រេងឥន្ធនៈក្នុងកម្រិតៈ 2.04 L/Box, 1.87 L/Box, និង 1.21 L/Box ជាដំណាក់កាលសាកល្បង ។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមសេចក្តីកំណត់លេខ ០០៨ សកណ/កសស/រប.ធម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលការកំណត់បទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់រថយន្តដឹកកុងតែន័រ រថយន្តដឹកទំនិញ និងតារាងសរុបឧបសម្ព័ន្ធទី ២ ស្តីពីការកំណត់បទដ្ឋានផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់មធ្យោបាយលើកដាក់ និងគ្រឿងចក្រនៅឡើយ ។

មូលហេតុខាងលើ អាចបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ ក្នុងការរៀបចំបែបបទស្នើសុំ ការកំណត់បទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈ ពីគណៈកម្មការកំណត់បទដ្ឋានប្រេងឥន្ធនៈរបស់ **កសស**។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ។

ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួរណែនាំឱ្យមន្ត្រីទទួលបន្ទុកការងារផ្ទាល់ពិនិត្យគ្រឿងចក្រចាស់និងថ្មី រួមទាំងមធ្យោបាយលើកដាក់ដែលមិនទាន់មានបទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈឱ្យបានច្បាស់លាស់ និងរៀបចំស្នើសុំបទដ្ឋានប្រើប្រាស់ពីគណៈកម្មការកំណត់បទដ្ឋានប្រេងឥន្ធនៈរបស់ **កសស** ឱ្យបានសមស្របតាមសេចក្តីកំណត់ខាងលើ ។

*នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ ស្នើសុំឱ្យធ្វើបទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់បណ្តាគ្រឿងចក្រ បម្រើការក្នុងនាយកដ្ឋានឡើងវិញ ទាំងបណ្តាគ្រឿងចក្រចាស់ៗ និងគ្រឿងចក្រ ដែលមិនទាន់មានបទដ្ឋានប្រើប្រាស់ប្រេង ព្រោះស្ថានភាពគ្រឿងចក្រមួយ ចំនួនមានសភាពចាស់ទ្រុឌទ្រោម និងស្ថានភាពប្រតិបត្តិការលើកដាក់កុងតែន័រ មានការកកស្ទះជាងពេលមុន ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

### ៥.៣.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ

#### ៥.៣.៣.១ ការពិនិត្យបញ្ជីសារពើភណ្ឌរថយន្ត និងគ្រឿងចក្រ

ក្នុងចំណោមរថយន្ត និងគ្រឿងចក្រសរុបចំនួន ៣៣ គ្រឿង (រថយន្តស្ទូច ០៨ គ្រឿង H.M.C ០២ គ្រឿង រថយន្តដឹក ១៧ គ្រឿង និងរថចូក ០៦ គ្រឿង) និងរ៉ឺម៉ក ២៤ គ្រឿងដែលត្រូវបានគ្រប់ គ្រងនិងប្រើប្រាស់ ដើម្បីបម្រើប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ដោយនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ សវនករបានពិនិត្យឃើញរថយន្តស្ទូច ១ គ្រឿង រថយន្តដឹក ២ គ្រឿង និងរ៉ឺម៉ក ៥ គ្រឿងមានលក្ខណៈចាស់ទ្រុឌទ្រោម ត្រូវបានខូចនិងរក្សាទុករយៈពេលយូរៈ

| | | | |
|---|---|---|---|
| - រថយន្តស្ទូច M.H.C 301 | ផលិតឆ្នាំ 2001 | ខូចថ្ងៃទី | 10/05/2014 |
| - រថយន្ត KAMAZ លេខ 1684 | ផលិតឆ្នាំ 2002 | ខូចថ្ងៃទី | 28/11/2019 |
| - រថយន្ត KAMAZ លេខ 1686 | ផលិតឆ្នាំ 2002 | ខូចថ្ងៃទី | 23/03/2021 |
| - រ៉ឺម៉កលេខ 4085 | ផលិតឆ្នាំ 1986 | ខូចថ្ងៃទី | 01/01/2010 |
| - រ៉ឺម៉កលេខ 4088 | ផលិតឆ្នាំ 1986 | ខូចថ្ងៃទី | 01/01/2010 |
| - រ៉ឺម៉កលេខ 4089 | ផលិតឆ្នាំ 1986 | ខូចថ្ងៃទី | 01/01/2010 |
| - រ៉ឺម៉កលេខ 4119 | ផលិតឆ្នាំ 2002 | ខូចថ្ងៃទី | 17/03/2017 |
| - រ៉ឺម៉កលេខ 4095 | ផលិតឆ្នាំ 2002 | ខូចថ្ងៃទី | 17/03/2017 |

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សានិងទុកដាក់ឱ្យបានគង់វង្ស និងចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍ សម្ភារការងារពេញលេញនៅឡើយ ។

មូលហេតុនេះ អាចកើតមានឡើងដោយសារភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ក្នុងការធ្វើរបាយការណ៍ អំពីស្ថានភាពរថយន្តនិងគ្រឿងចក្រ ដែលមានលក្ខណៈចាស់ទ្រុឌទ្រោមនិងខូចជូនថ្នាក់ដឹកនាំសវនដ្ឋាន ដើម្បីពិនិត្យនិងស្នើសុំជួសជុលឱ្យបានឆាប់រហ័ស និងសមស្របតាមតម្រូវការរបស់ **កសស** ។

កត្តានេះ អាចប៉ះពាល់ដល់គុណភាព និងផលិតភាពនៃប្រតិបត្តិការអាជីវកម្ម សេវាកម្ម ក៏ដូចជាប្រសិទ្ធភាពនៃការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ **កសស** ។

សវនករយល់ឃើញថាថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំនិងចាត់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ឱ្យចុះពិនិត្យនិងធ្វើរបាយការណ៍ជាក់លាក់អំពីស្ថានភាព រថយន្ត គ្រឿងចក្រ និងរ៉ឺម៉កចាស់ៗដែលខូច និង/ឬ ប្រើប្រាស់លែងបាន ដើម្បីពិនិត្យនិងស្នើសុំថ្នាក់ដឹកនាំ **កសស** ជួសជុល ឬ ចាត់វិធានការតាមលក្ខណៈជាក់ស្តែង ។

***H.M.C 301៖***

- *គ្រឿងបន្លាស់ជាច្រើនអន្លើត្រូវបានដោះដូរជាមួយនឹង H.M.C 302 ។*
- *ប្រព័ន្ធបញ្ជាភ្លើងខូច ។*
- *ជើងជំរឹទាំងអស់មានស្នាមជ្រាបប្រេង ។*
- *កង់ទាំងអស់ អស់គុណភាពប្រើប្រាស់ ។*
- *ប្រព័ន្ធទុយោបូម អស់គុណភាព រួមទាំងប្រព័ន្ធបូមខ្លាញ់បាញ់ប្រេងគាំងដោយអន្លើ ។*
- *ម៉ាស៊ីនមិនដែលបានបញ្ឆេះ តាំងពីឆ្នាំ ២០១៣ មកម្លេះ ។*
- *យោងតាមការវាយតម្លៃរបស់លោក អ៊ុក វណ្ណាក់ និងលោក គឹម ហោ H.M.C 301 នេះ នៅអាចជួលជុលប្រើបាន (ក្នុងករណីរកគ្រឿងបន្លាស់បាន) ។*
- *នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើពាក្យស្នើសុំថ្នាក់ដឹកនាំដើម្បីជួលជុលឡើងវិញ។*

***រថយន្តដឹក ៖***

- *រថយន្តដឹក KAMAZ លេខសំគាល់ 1684 និងរថយន្តដឹក KAMAZ លេខសំគាល់ 1686 ដែលបច្ចុប្បន្ននៅពេងដាងរបស់ **កសស** ទាំង 02 (ពីរ) បានដាក់ពាក្យស្នើសុំជួសជុលតាំងពីឆ្នាំ 2019 និង 2021 ។ រថយន្តនេះមានសភាពច្រេះស៊ីកាប៊ីនពុកផុយស្ទើគ្រប់កន្លែងទាំងអស់ ចំណែកម៉ាស៊ីនរថ*

*យន្ត ក្រោយពីបានដោះទម្លាក់និងពិនិត្យឃើញម៉ាស៊ីនមានសភាព (ឡេក) និងពិបាកក្នុងការស្វែងរកគ្រឿងបន្លាស់មកប្តូរ ។ ដោយឡែកកង់រថយន្តទាំងអស់ខូចគុណភាពប្រើលែងបាន ។*

- *យោងការវាយតម្លៃរបស់ជាងជួសជុល រថយន្តទាំងនេះពិបាករកគ្រឿងបន្លាស់មកជួសជុល ។*
- *នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើពាក្យស្នើសុំថ្នាក់ដឹកនាំ ដើម្បីដាក់ដេញថ្លៃ ។*

***រ៉ឺម៉ករថយន្តដឹក ៖***

- *រ៉ឺម៉ក (វែង) ដែលមានលេខសម្គាល់ 4119 និង 4095 បាក់សាកស៊ីប្រើលែងបាន ។ កង់រថយន្តដែលនៅល្អប្រើបាន ត្រូវបានដោះដូរផ្លាស់ជាមួយនឹងរថយន្តដែលកំពុងប្រើរាល់ថ្ងៃអស់ហើយ ។*
- *រ៉ឺម៉ក (ខ្លី) ដែលមានលេខសម្គាល់ 4085, 4088 និង 4089 ពុំត្រូវនឹងតម្រូវការដឹកទំនិញបច្ចុប្បន្នទេ។ ចំណែកកង់រថយន្តទាំងអស់ ត្រូវបានដោះដូរផ្លាស់ជាមួយនឹងរថយន្តដែលកំពុងប្រើរាល់ថ្ងៃអស់ហើយ ។*

*នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើពាក្យស្នើសុំ ថ្នាក់ដឹកនាំដើម្បីដាក់ដេញថ្លៃ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

### ៥.៣.៣.២ ការពិនិត្យប្រព័ន្ធការពារអគ្គិភ័យនៅក្នុងឃ្លាំងលេខ ៣ និងឃ្លាំងលេខ ៥ នៃ កសស

យោងតាមការចុះពិនិត្យ ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងឃ្លាំងលេខ ៣ និងឃ្លាំងលេខ ៥ សវនករ បានសង្កេតឃើញបំពង់ពន្លត់អគ្គិភ័យសរុបចំនួន ២២ (ម្ភៃពីរ) គ្រឿង ក្នុងនេះរួមមានបំពង់ពន្លត់អគ្គិភ័យធន់ធំ ០៤ (បួន) គ្រឿង និងបំពង់ពន្លត់អគ្គិភ័យធន់តូច ១៨ (ដប់ប្រាំបី) គ្រឿងត្រូវបានខូចគុណភាពនិងប្រើប្រាស់លែងបាន ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីលក្ខខណ្ឌនិងវិធានការនានា ការបង្ការនិងពន្លត់អគ្គិភ័យ ក្នុងជំពូកទី ៣ មាត្រា ៩ អ្នកគ្រប់គ្រងគោលដៅ ទីកន្លែងផលិតកែច្នៃ និង/ឬ ស្តុកទុកសារធាតុងាយឆេះ ប្រភពភ្លើងនិងប្រភពកម្តៅ ត្រូវគោរពតាមលក្ខខណ្ឌនិងវិធាន រួមមានឧបករណ៍ស្រូបផ្សែង ស្រូបកម្តៅ ម៉ាស៊ីនបាញ់ទឹកពន្លត់អគ្គិភ័យស្វ័យប្រវត្តិ បំពង់ពន្លត់អគ្គិភ័យគ្រប់ប្រភេទ ប្រព័ន្ធទឹកដើរដោយស្វ័យប្រវត្តិសម្រាប់ពន្លត់អគ្គិភ័យ បង្គោលទឹកសម្រាប់ផ្តល់ឱ្យរថយន្តពន្លត់អគ្គិភ័យ មានប្រព័ន្ធការពាររន្ទះ និងហាមដាក់វត្ថុផ្សេងៗដែលអាចប្រតិកម្មបង្កើតបានជាប្រភពភ្លើង និងប្រភពកម្តៅនៅក្បែរគោលដៅ ដែលងាយឆេះនិងងាយផ្ទុះឆេះ ។

ប្រការនេះ អាចកើតមានឡើងដោយសារភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ក្នុងការត្រួតពិនិត្យគុណភាព និងស្នើសុំបំពាក់ឧបករណ៍ការពារអគ្គិភ័យ ដើម្បីប្រើប្រាស់ឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស និងតម្រូវការចាំបាច់ ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពនៃការគ្រប់គ្រងអគ្គិភ័យ នាំឱ្យខូចខាតគុណភាពទំនិញ និង/ឬ ប៉ះពាល់អាយុជីវិតមន្ត្រី និយោជិត កម្មករ ដែលបម្រើការងារនៅក្នុងឃ្លាំងជាយថាហេតុ ។

ដើម្បីធានាប្រសិទ្ធភាពអនុវត្ត វិធានការបង្ការនិងពន្លត់អគ្គិភ័យ សំដៅកាត់បន្ថយហានិភ័យ និងការបំផ្លាញទ្រព្យសម្បត្តិដោយគ្រោះអគ្គិភ័យ សវនករយល់ឃើញថាសវនដ្ឋានត្រូវបង្កើនការប្រុងប្រយ័ត្ន និងស្នើសុំបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យ (Fire Extinguishers) ឱ្យបានឆាប់និងសមស្របតាមតម្រូវការចាំបាច់ ។

*នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងពិនិត្យអំពីចំនួននិងប្រភេទនៃបំពង់ពន្លត់អគ្គិភ័យដែលត្រូវការចាំបាច់តាមផ្នែកនីមួយៗ និងធ្វើពាក្យស្នើសុំពីថ្នាក់ដឹកនាំ **ក.ស.ស** ទៅតាមចំនួនជាក់ស្តែង ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្ត អនុសាសន៍សវនកម្មជាបន្តទៀត ។

## ៥.៣.៤ នាយកដ្ឋាននាវាចរ-កណ្ណាធារនិងសន្តិសុខ

### ៥.៣.៤.១ ការពិនិត្យមធ្យោបាយជើងទឹក (នាវាសណ្តោង)

យោងតាមការចុះពិនិត្យមធ្យោបាយជើងទឹក (នាវាសណ្តោង) ដែលគ្រប់គ្រង ថែទាំនិងប្រើប្រាស់ដោយ ការិយាល័យគ្រប់គ្រងមធ្យោបាយជើងទឹក សវនករបានកត់សម្គាល់ឃើញ៖

- **នាវាសណ្តោង កោះ វ៉ៃ**
  - ខ្វះភ្លើងបំភ្លឺនៅពេលបើកបរ (សុំបានហើយតែមិនទាន់បានបំពាក់-រង់ចាំឡើងអ៊ូ)
  - ត្រើយមុខ បានខូចក្នុងឆ្នាំ ២០២០ ដោយសារច្រែះស៊ីខ្លាំង (អ្នកគ្រប់គ្រងបានស្នើសុំជួសជុល/ប្តូរត្រើយថ្មី - មកដល់ត្រីមាសទី ២ ឆ្នាំ ២០២២ នេះ នៅពុំទាន់ជួសជុល/ប្តូរថ្មីទេ)
  - បន្ទប់ដេកនិងបន្ទប់ទឹក បានខូចទ្រង់ទ្រាយ-នៅពុំទាន់បានជួសជុលនៅឡើយ។
- **នាវាសណ្តោង កោះ សេះ**
  - ម៉ាស៊ីនត្រជាក់បំពាក់នៅក្នុងបន្ទប់ដេករបស់ នាវិក បន្ទប់បើកបរ បន្ទប់ដេករបស់ ប្រធាននាវា និងបន្ទប់ទទួលភ្ញៀវ ប្រើប្រាស់លែងបាន
  - ពុំទាន់មានសម្ភារប្រើប្រាស់នៅក្នុងបន្ទប់ដេក ដូចជា ពូក ខ្នើយ ជាដើម ។
- **នាវាសណ្តោង កោះ តាង**
  - ពុំទាន់បានជួសជុលបន្ទប់ដេករបស់នាវិកផ្នែកខាងក្រោម
  - ខ្វះអាវពោងការពារសុវត្ថិភាព
  - ពុំមានយុថ្កា (បាត់)
  - ទ្វារដែកសម្រាប់បិទ-បើក នៅជុំវិញកាប៊ីនបើកបរត្រូវបានច្រែះស៊ី(ពុកផុយ)-ពុំទាន់បានជួសជុល ។
- **នាវាសណ្តោង កោះ រ៉ុង**

* ម៉ាស៊ីននាវាត្រូវបានប្តូរថ្មីក្នុងឆ្នាំ ២០២០ ប៉ុន្តែនៅពុំទាន់បានចេញប្រតិបត្តិការនៅឡើយពីព្រោះ ប្រព័ន្ធខាងក្រោម នៅពុំទាន់បានភ្ជាប់សមស្របតាមលក្ខណៈបច្ចេកទេស៖

  - ប្រព័ន្ធចង្កូតខូច (ត្រូវជួសជុល ឬ ប្តូរថ្មី)
  - ពុំទាន់មានច្រវ៉ាក់យុថ្កាគ្រប់គ្រាន់ (ខ្វះប្រមាណជា ៧០ - ៨០ ម៉ែត្រ)
  - ត្រើយក្រោយ និង ត្រើយមុខបានខូច - ពុំទាន់បានជួសជុល
  - ប្រព័ន្ធខ្សែភ្លើងបំពាក់ក្នុងនាវាមានសភាពចាស់
  - ពុំមានភ្លើងបំភ្លឺជុំវិញនាវា គ្មានភ្លើងហ្វាផ្នែកខាងមុខ និងភ្លើងហ្វាផ្នែកខាងក្រោយ
  - ពុំទាន់បានបំពាក់សម្ភារប្រើប្រាស់ប្រចាំថ្ងៃ នៅតាមបន្ទប់នីមួយៗ (ដូចជាម៉ាស៊ីនត្រជាក់ និង កង្ហារ ។ល។)
  - ផ្ទះបាយ បន្ទប់ទឹក បន្ទប់ដេក ខាងក្រោមសម្រាប់នាវិក និងបន្ទប់ដេកសម្រាប់ ប្រធាននាវានៅ ផ្នែកខាងលើពុំទាន់បានជួសជុល
  - កាប៊ីនបញ្ជាបើកបរ ពុំទាន់បានជួសជុល ហើយទ្វារបិទបើកចំនួន ០២ (ពីរ) និងកញ្ចក់កាប៊ីនចំនួន ០១ (មួយ) ដែលត្រូវបានស្នើសុំរួចហើយនោះ នៅពុំទាន់បានផ្តល់ជូននៅឡើយ

- ស្នើសុំឡើងអ៊ូបាញ់ខ្សាច់ និងលាបថ្នាំថ្មី សុំ Rada និង GPS ថ្មី (ដោយ GPS មានស្រាប់មានលក្ខណៈចាស់ និងត្រូវបានប្រើប្រាស់រយៈពេល ៨ ឆ្នាំមកហើយ) ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សានិងទុកដាក់ឱ្យបានគង់វង្សនៅឡើយ ។

ករណីនេះ អាចកើតមានឡើងដោយសារភាពសឹករេចរឹលនៃឧបករណ៍ និងសម្ភារដែលត្រូវបានប្រើប្រាស់រយៈពេលយូរ ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់សុវត្ថិភាព ផលិតភាពការងារ និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ **កសស** ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋាន គួររាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** និងស្នើសុំនាយកដ្ឋានជំនាញធ្វើការជួសជុល និង/ឬ ផ្លាស់ប្តូរថ្មីនូវឧបករណ៍និងសម្ភារដែលខ្វះខាត និងខូចពិតប្រាកដឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ។

*ជាមួយនេះ នាយកដ្ឋាន **នកស** បានកំពុងតែធ្វើការទំនាក់ទំនងជាមួយផ្នែកពាក់ព័ន្ធរបស់ **កសស** ក្នុងការស្នើសុំជួសជុល បំពាក់បន្ថែមលើនាវាសណ្តោងទាំងបួនខាងលើនេះ រួចមកហើយ ហើយមានផ្នែកខ្លះ ក៏ត្រូវបានបំពេញជាបណ្តើរៗរួចមកហើយ ។ ដោយនាវាសណ្តោងទាំងនោះចេញធ្វើប្រតិបត្តិការបណ្តើរៗ ធ្វើឱ្យការងារជួសជុលត្រូវសម្របសម្រួល តាមពេលវេលាដែលទំនេរជាក់ស្តែង ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

### ៥.៣.៤.២ ការពិនិត្យរបាំងការពារនាវា (Fenders)

យោងតាមការចុះពិនិត្យរបាំងការពារនាវា (Fenders) និងជណ្តើរដែកចុះ- ឡើងទឹកសមុទ្រនៅតាមចំណតផែកុងតែន័រ និងការសាកសួរមន្ត្រីជំនាញ ទទួលបន្ទុកការងារគ្រប់គ្រង ប្រើប្រាស់និងថែរក្សា សវនករបានសង្កេតឃើញ៖ Fenders No. C.1-C.27 បំពាក់នៅតាមបណ្តោយ Post 5 និង Post 6, Fenders No. D.1-D.32 បំពាក់នៅតាមបណ្តោយ Post 7 និង Post 8 និងជណ្តើរដែកសម្រាប់ចុះពិនិត្យស្ថានភាពគែមផែក្នុងទឹកសមុទ្រ ត្រូវបានបាក់ដាច់ និងមានស្នាមប្រេះបែក ក្នុងស្ថានភាពដូចខាងក្រោម៖

- **របាំងការពារនាវា** (Fenders No. C.1-C.27) **និងជណ្តើរដែកនៅ** Post 5 **និង** Post **6**
  - Fenders នៅប្រើបាន : ១៧ គ្រឿង
  - Fender បាក់ដាច់(ខូច) : ០១ គ្រឿង
  - Fenders ដែលមានចងកង់ឡាន ២ ផ្គោបគ្នា: ០២ គ្រឿង
  - Fenders ដែលមានកង់ឡានតែ ១ : ០៧ គ្រឿង
  - ជណ្តើរដែក (ច្រេះស៊ីខូចទាំងស្រុង) : ០៧ គ្រឿង
- **របាំងការពារនាវា** (Fenders No. D.1-D.32) **និងជណ្តើរដែកនៅ** Post 7 **និង** Post 8
  - Fenders នៅប្រើបាន : ១៥ គ្រឿង
  - Fenders បាក់ដាច់(ខូច) : ០៥ គ្រឿង
  - Fenders ដែលមានចងកង់ឡាន ២ ផ្គោបគ្នា: ០៧ គ្រឿង
  - Fenders ដែលមានកង់ឡាន ១ : ០៥ គ្រឿង

- ជណ្ដើរដែក : ០២ គ្រឿង (ប្រេះស៊ីខូច ០១)។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/បេ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស នៅឡើយ ។

ប្រការនេះ អាចបណ្ដាលមកពីភាពសឹករេចរឹល ដោយសារការប្រើប្រាស់រយៈពេលយូរ និង/ឬ ការប៉ះទង្គិចដោយសកម្មភាពចូលចត-ចេញដំណើរ នៃនាវាដឹកទំនិញ/កុងតែន័រដែលចូលមកធ្វើការលើកដាក់ ផ្ទេរ-ផ្ទុកនៅ Post 5 - Post 6 និង Post 7 - Post 8 ។

កត្តានេះ អាចបណ្ដាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព របាំងការពារនាវា (Fenders) និងនាំឱ្យចលនានាវាចូលចត-ចេញដំណើរ ប៉ះទង្គិចគែមផែនិងខូចខាតថែមទៀត ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំការិយាល័យទទួលបន្ទុកនិងសវនដ្ឋាន គួរចុះពិនិត្យស្ថានភាពជាក់ស្ដែងនិងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំនាយកដ្ឋានជំនាញធ្វើការជួសជុល និងផ្លាស់ប្ដូរថ្មីឱ្យបានសមស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ **កសស** ។

*ស្ថានភាព Fenders របស់ **កសស** នាបច្ចុប្បន្ន ពិតជាមានសភាពទ្រុឌទ្រោម ដូចការរក ឃើញខាងលើប្រាកដមែន ហើយនាយកដ្ឋាន **នកស** បានស្នើសុំនាយកដ្ឋានពាក់ព័ន្ធអោយធ្វើការជួសជុលជាបន្ទបន្ទាប់ មានដូចជាការដាក់កង់ឡានជំនួសជាដើម ដោយឡែក Fenders ខ្លះដាច់ដំរ្លាក់ចុះតែម្ដង ហើយនាយកដ្ឋាន **នកស** ក៏បានរាយការណ៍ និងដាក់ពាក្យស្នើសុំឱ្យជួសជុលដែរកន្លងមក ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

### ៥.៣.៥ នាយកដ្ឋានសំណង់-វិស្វកម្ម

#### ៥.៣.៥.១. ការពិនិត្យរបាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋានសំណង់-វិស្វកម្ម

យោងតាមការពិនិត្យរបាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានសំណង់-វិស្វកម្មក្នុងត្រីមាសទី ២ នៃការិយបរិច្ឆេទ ២០២២ សវនករបានសង្កេតឃើញមានរបាយការណ៍វឌ្ឍនភាពការងាររួមក្នុងក្របខ័ណ្ឌសវនដ្ឋាន ស្របតាមរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែ របស់ការិយាល័យជំនាញនីមួយៗ ដោយសម្រេចបានលទ្ធផលការងារសំខាន់ៗជាច្រើន ទៅតាមតួនាទី-ភារកិច្ចដែល **កសស** បានកំណត់ ប៉ុន្តែក្នុងនេះផ្នែកគ្រប់គ្រងឯកសារលទ្ធកម្មសំណង់ នៅមានភាពខ្វះចន្លោះនិងពុំទាន់រៀបចំឯកសារបានសមស្រប និងទាន់ពេលវេលាតាមតម្រូវការរបស់ **កសស** នៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្ដីសម្រេចលេខ ០២៤ សសរ/ កសស/សណ.វក ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន តួនាទី-ភារកិច្ចរបស់បណ្ដាការិយាល័យនៃនាយកដ្ឋានសំណង់-វិស្វកម្ម ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២០ នៅឡើយ ។

ប្រការនេះ អាចបណ្ដាលមកពីមន្ត្រីទទួលបន្ទុកការងារ ក្នុងក្របខ័ណ្ឌការិយាល័យគ្រប់គ្រងឯកសារលទ្ធកម្មសំណង់មានភាពមមាញឹកច្រើន ក្នុងការចូលរួមសិក្សាគម្រោងចាក់បេតុងទីលានកុងតែន័រ ការងារជួសជុលនាវាកោះសេះ និងដំបូលឃ្លាំងនានារបស់ **កសស** ។

ទោះជាយ៉ាងនេះក្តី កត្តាខាងលើអាចបណ្ដាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃការអនុវត្ត តួនាទី-ភារកិច្ចរបស់សវនដ្ឋាន ជាពិសេសអាចធ្វើឱ្យមានការយឺតយ៉ាវដល់ការអនុវត្ត គម្រោងប្លង់ជួសជុលសំណង់មូលដ្ឋាននៅក្នុងក្របខ័ណ្ឌ **កសស** ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួរណែនាំឱ្យការិយាល័យគ្រប់គ្រងឯកសារលេទ្ធកម្មសំណង់ យកចិត្តទុកដាក់ក្នុងការអនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន និងសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីជម្រុញឱ្យការរៀបចំឯកសារលទ្ធកម្ម ប្រព្រឹត្តទៅបានទាន់ពេលវេលានិងស្របតាមតម្រូវការចាំបាច់របស់ **កសស** ។

*នាយកដ្ឋានសំណង់-វិស្វកម្ម នឹងណែនាំការិយាល័យគ្រប់គ្រង ឯកសារលទ្ធកម្មសំណង់ ឱ្យសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកែលម្អចំណុចខ្វះខាតដូចបានលើកឡើងខាងលើ និងរៀបចំឯកសារលទ្ធកម្មសំណង់ឱ្យបានឆាប់រហ័ស និងសមស្របតាមតម្រូវការរបស់ **កសស** ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

## ៥.៣.៥.២. ការពិនិត្យតារាងរថយន្តនិងគ្រឿងចក្រ នៃផ្នែកគ្រឿងចក្រសំណង់

យោងតាមតារាងរថយន្តនិងគ្រឿងចក្រ និងតាមការសាកសួរមន្ត្រីជំនាញនៃផ្នែកគ្រឿងចក្រសំណង់ សវនករបានសង្កេតឃើញ៖

- រថយន្តចូកដី ០១ គ្រឿង ម៉ាក Wheel Loader Hitachi LX-150 ឆ្នាំប្រើប្រាស់ ១៩៩៨ លេខសម្គាល់គ្មាន បានខូចម៉ាស៊ីនក្នុងឆ្នាំ ២០១៧ (ជួសជុលលែងបាន)
- រថយន្តស៊ីទែន ០១ គ្រឿង ម៉ាក Maz ឆ្នាំប្រើប្រាស់ ១៩៨២ លេខសម្គាល់ ៤០១០ បានខូចម៉ាស៊ីនគ្មានគ្រឿងបន្លាស់ផ្លាស់ប្តូរ
- រថយន្តស៊ីទែន ០១ គ្រឿង ម៉ាក Maz ឆ្នាំប្រើប្រាស់ ១៩៨២ លេខសម្គាល់ ៤០១១ បានខូចម៉ាស៊ីនគ្មានគ្រឿងបន្លាស់ផ្លាស់ប្តូរ ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សានិងទុកដាក់ឱ្យបានគង់វង្សនៅឡើយ ។

ករណីនេះ អាចកើតមានឡើងដោយសារភាពសឹករេចរឹលនៃគ្រឿងបន្លាស់ ដែលត្រូវបានប្រើប្រាស់រយៈពេលយូរ ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ផលិតភាពការងារ ប្រសិទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ **កសស** និងនាំឱ្យខាតបង់ទ្រព្យសម្បត្តិរដ្ឋ ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋាន ពិសេសផ្នែកគ្រឿងចក្រសំណង់គួររៀបចំតារាងត្រួតពិនិត្យប្រចាំថ្ងៃ (Daily Checklist) ដាក់ឱ្យប្រតិបត្តិករនីមួយៗ ពិនិត្យតាមដានដំណើរការគ្រឿងចក្រគ្រប់ប្រភេទ និងរៀបចំផែនការថែទាំ-ជួសជុលប្រចាំសប្តាហ៍/ខែ ឱ្យបានទៀងទាត់។

*១. ដោយសារគ្រឿងចក្រមួយចំនួនធំប្រើប្រាស់យូរឆ្នាំ មានការខូចជាញឹកញាប់ ។*

*២. កន្លងមកគ្រឿងចក្រសំណង់ បានអនុវត្តទៀងទាត់លើការជួសជុលថែទាំជាប្រចាំ ដូចខាងក្រោម៖*

- *មានក្រុមជាងជួសជុល-ថែទាំគ្រឿងចក្រ*
- *ផ្លាស់ប្តូរប្រេងរំអិល បូមខ្លាញ់ ប្តូរតម្រងប្រេង តាមម៉ោងកំណត់របស់គ្រឿងចក្រ*
- *លាងសម្អាតគ្រឿងចក្រជាប្រចាំ*

*៣. ចំពោះគ្រឿងបន្លាស់គ្រឿងចក្រ កន្លងមកជួបការលំបាក ដោយសារពេលខ្លះ កំពុងតែអនុវត្តការងារហើយខូច ចាំបាច់ត្រូវរកទិញមកផ្លាស់ប្តូរភ្លាម ប៉ុន្តែជាញឹកញាប់ត្រូវស្វះស្វែងរកបន្លាស់ដោយពុំសូវមានក្នុងទីផ្សារ ព្រោះគ្រឿងចក្រមានអាយុយូរឆ្នាំ ។*

*៤. គ្រឿងចក្រមួយចំនួនប្រើប្រាស់ច្រើនឆ្នាំ ពុំមានគ្រឿងបន្លាស់សម្រាប់ផ្លាស់ប្តូរ ធ្វើឱ្យគ្រឿងចក្រខូចលែងដំណើរការ ។*

*ការិយាល័យគ្រឿងចក្រ-ឃ្លាំងប្រេង នឹងបន្តអនុវត្តពិនិត្យតាមដានដំណើរការគ្រឿងចក្រ វេយន្តគ្រប់ប្រភេទ និងរៀបចំផែនការជួសជុល-ថែទាំជាប្រចាំឱ្យបានទៀងទាត់ និងសំណូមពរជម្រះបញ្ជីគ្រឿងចក្រចាស់ៗមួយចំនួនចេញ ។*

- *មាន Wheel Loader មួយផ្សេងទៀតកំពុងប្រើប្រាស់*
- *វេយន្ត Fuel Tankers យើងទិញបន្ថែមចំនួន ០២ គ្រឿង ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

## ៥.៣.៦ នាយកដ្ឋានបច្ចេកទេស-សម្ភារ

### ៥.៣.៦.១ ការពិនិត្យរបាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានបច្ចេកទេស-សម្ភារ

យោងតាមរបាយការណ៍វឌ្ឍនភាពការងាររបស់ នាយកដ្ឋានបច្ចេកទេស-សម្ភារ សម្រាប់ត្រីមាសទី ២ ឆ្នាំ ២០២២ សវនករបានពិនិត្យឃើញសវនដ្ឋាន សម្រេចបានលទ្ធផលការងារសំខាន់ៗ ជាច្រើនពាក់ព័ន្ធនឹងការថែទាំ-ជួសជុលគ្រឿងចក្រ មធ្យោបាយលើកដាក់ និងដឹកជញ្ជូនធន់ធ្ងន់/ស្រាលរួមទាំងការថែរក្សាស្តុកសម្ភារ-បន្លាស់ និងការជួសជុលនាវាសណ្តោងរបស់ **កសស** ប៉ុន្តែលើកលែងតែការិយាល័យឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់ និងការិយាល័យយន្តសាស្ត្រកប៉ាល់-នាវាសណ្តោង សវនដ្ឋាន នៅពុំទាន់បានតម្រូវឱ្យការិយាល័យផ្សេងៗទៀត រៀបចំរបាយការណ៍វឌ្ឍនភាពការងារទៅតាមមុខជំនាញ និងតួនាទី-ភារកិច្ចរៀងៗខ្លួននៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ២៣០ សសរ/កសស/បទស ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទី-ភារកិច្ចរបស់បណ្តាការិយា ល័យនៃនាយកដ្ឋានបច្ចេកទេស-សម្ភារ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០ នៅឡើយ ។

ករណីនេះ អាចបណ្តាលមកពីការិយាល័យផ្សេងៗទៀត ជាប់មមាញឹកក្នុងការងារអាទិភាព ពិសេសការថែទាំ-ជួសជុលគ្រឿងចក្រ និងមធ្យោបាយលើកដាក់ ដឹកជញ្ជូនរបស់ **កសស** ។

ទោះជាយ៉ាងនេះក្តី កត្តាខាងលើអាចបណ្តាលឱ្យប៉ះពាល់ ដល់ប្រសិទ្ធភាពនៃការអនុវត្តតួនាទី-ភារកិច្ចរបស់បណ្តាការិយាល័យ នៅក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

សវនករយល់ឃើញថាថ្នាក់ដឹកនាំសវនដ្ឋាន គួរជម្រុញឱ្យការិយាល័យនីមួយៗធ្វើរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែ ស្របតាមតួនាទី-ភារកិច្ចដែល **កសស** បានប្រគល់ជូន ។

*ឆ្លើយតបនឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ទាក់ទងទៅនឹងការងារតាមការិយាល័យនីមួយៗ របស់នាយកដ្ឋានបច្ចេកទេស-សម្ភារ បានរៀបចំទៅតាមរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងភាពទទួលខុសត្រូវទៅតាមមុខជំនាញជាប្រចាំ ក្នុងការងារជួសជុលថែទាំគ្រឿងចក្រ បម្រើអោយការងារអាជីវកម្មគ្រប់ប្រភេទរបស់ **កសស** និងសហការជាមួយនាយកដ្ឋានផ្សេងៗបានល្អប្រសើរផងដែរ ។ តាមការិយាល័យនីមួយៗ មិនបានធ្វើរបាយការណ៍ដាច់ដោយឡែកពីគ្នាបានទេ ដោយការងារប្រចាំថ្ងៃមានទំនាក់ទំនងគ្នាទៅវិញទៅមក និងបានបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែជារៀងរាល់ខែ ហើយបានបញ្ជូនទៅ នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ ជាប្រចាំផងដែរ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

#### ៥.៣.៦.២ ការពិនិត្យវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស ថែទាំ-ជួសជុល គ្រឿងចក្រ

យោងតាមការសម្ភាសន៍មន្ត្រីជំនាញ នៅនាយកដ្ឋានបច្ចេកទេស-សម្ភារ សវនករបានកត់សម្គាល់ឃើញថា គិតត្រឹមត្រីមាសទី ២ ឆ្នាំ ២០២២ នេះ នាយកដ្ឋានបច្ចេកទេស-សម្ភារ នៅពុំទាន់បានបើកវគ្គបណ្តុះបណ្តាលជំនាញថែទាំ-ជួសជុល គ្រឿងចក្រធុនធ្ងន់ និងបច្ចេកទេសមេកានិចគ្រឿងចក្រដល់ បុគ្គលិក កម្មករ/ប្រតិបត្តិករគ្រឿងចក្ររបស់ **កសស** នៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុឆ្នាំ ២០២២ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ក្នុងឧបសម្ព័ន្ធទី ៨: ផែនការបណ្តុះបណ្តាលធនធានមនុស្សឆ្នាំ ២០២២ ត្រង់ចំណុច ក-២២ ស្តីពីទ្រឹស្តីត្រួតពិនិត្យ ថែទាំ-ជួសជុល គ្រឿងចក្រធុនធ្ងន់ពេញលេញនៅឡើយ ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីជំនាញ ក្នុងក្របខ័ណ្ឌសវនដ្ឋាននិងបុគ្គលិក កម្មករ គ្រឿងចក្រមានការមមាញឹកច្រើន ក្នុងការបម្រើប្រតិបត្តិការអាជីវកម្ម សេវាកម្ម របស់ **កសស** ។

ទោះជាយ៉ាងនេះក្តី កត្តាខាងលើអាចបណ្តាលឱ្យប៉ះពាល់ដល់គុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រឿងចក្រ មធ្យោបាយលើកដាក់ ដឹកជញ្ជូន ធន់ធ្ងន់/ស្រាលរបស់ **កសស** ដោយថាហេតុ ។

សវនករយល់ឃើញថា នាយកដ្ឋានបច្ចេកទេស-សម្ភារ គួររៀបចំផែនការបណ្តុះបណ្តាលនិងស្នើសុំថ្នាក់ដឹកនាំ **កសស** បើកវគ្គបណ្តុះបណ្តាលជំនាញថែទាំ-ជួសជុល និងបច្ចេកទេសមេកានិច ដល់បុគ្គលិក កម្មករ គ្រឿងចក្រ ស្របតាមផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ ឆ្នាំ ២០២២ ។

*ទាក់ទងនឹងការបើកវគ្គ បណ្តុះបណ្តាលជំនាញថែទាំ និងជួសជុលគ្រឿងចក្រធុនធ្ងន់ យើងបានធ្វើការបណ្តុះបណ្តាលដល់ក្រុមជាង តាំងពី **កសស** បានបំពាក់នូវមធ្យោបាយលើកដាក់ធុនធ្ងន់មក ។ ដោយការបណ្តុះបណ្តាលនេះ ជាការអនុវត្តជាក់ស្តែងផ្ទាល់នឹងការងារតែម្តង (On Job Training) ដោយការបណ្តុះបណ្តាលនេះ ក្រុមជាងរបស់យើងងាយយល់និងងាយចាប់បានរាល់ការងារនីមួយៗ ។ សំរាប់ការបណ្តុះបណ្តាលជាទ្រឹស្តី (Class Room Training) យើងក៏មានរៀបចំបានមួយចំនួនដែរ ដោយការងារត្រួតពិនិត្យ ថែទាំ និងជួសជុលគ្រឿងចក្ររបស់យើងមានភាពមមាញឹកខ្លាំង ។ ក្រៅពីនេះបុគ្គលិកផ្នែកជួសជុលថែទាំ របស់យើងមួយចំនួនបានទៅរៀនជំនាញនៅឯភ្នំពេញរាល់ចុងសប្តាហ៍ ដោយទទួលបានការឧបត្ថម្ភជាបន្តបន្ទាប់ពី **កសស** ផងដែរ ។ ទោះជាយ៉ាងនេះក្តី ដើម្បីធានានិរន្តរភាពប្រតិបត្តិការអាជីវកម្ម ការប្រើប្រាស់គ្រឿងចក្រ មធ្យោបាយលើកដាក់ ផ្ទេរ-ផ្ទុកនិងដឹកជញ្ជូន/កុងតែន័គ្រប់ប្រភេទ សវនដ្ឋាននឹងរៀបចំផែនការបណ្តុះបណ្តាលឱ្យបានសមស្របតាមគោលការណ៍ណែនាំ ដូចមានចែងនៅក្នុងផែនការអាជីវកម្ម (សេវាកម្ម) ឆ្នាំ ២០២២ របស់ **កសស** ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

### ៥.៣.៧ នាយកដ្ឋានឱផ្សារ (នឋ)

#### ៥.៣.៧.១ របាយការណ៍សម្ភាសន៍តំណាងក្រុមហ៊ុនដឹកជញ្ជូនដោយនាវា (Shipping Lines) ក្រុមហ៊ុនផែស្ងួត សមាគមកស្តុភារកម្មជា និងសមាគមកម្ពុជាដឹកជញ្ជូនដោយរថយន្ត អំពីសេវាប្រតិបត្តិការ និងការនាំចូល-ចេញ តាមច្រកទ្វារ កសស

យោងតាមរបាយការណ៍សម្ភាសន៍ តំណាងក្រុមហ៊ុនដឹកជញ្ជូនដោយនាវា (Shipping Lines) ក្រុមហ៊ុនផែស្ងួត (Dry Ports) សមាគមកស្តុភារកម្ពុជា និងសមាគមកម្ពុជាដឹកជញ្ជូនដោយរថយន្ត (Cambodia Trucking Association) មួយចំនួនរួមមាន៖ ក្រុមហ៊ុន Maersk (SHV-PNP), RCL (SHV-PNP), Teng Lay (SHV), SITC (SHV-PNP), Straits International (Wan Hai Samudera), Cambodia Logistics Association (CLA), Cambodia Trucking Association (CAMTA), Hong Leng Huor Dry Port (PNP), GMAC, So Nguon Dry Port (PNP), និងក្រុមហ៊ុន JMG Co., LTD (PNP) អំពីសេវាប្រតិបត្តិការ

និងការនាំចូល-ចេញតាមច្រកទ្វារ **កសស** សវនករបានកត់សម្គាល់ឃើញថា៖ អតិថិជនខាងលើបានពេញចិត្តនឹងសេវាប្រតិបត្តិការ កិច្ចសហការ និងការឆ្លើយតបរបស់ **កសស** ប៉ុន្តែទន្ទឹមនឹងនេះ នៅមានចំណុចលើកឡើងមួយចំនួន ពាក់ព័ន្ធនឹងដំណើរការយឺតយ៉ាវនៃប្រតិបត្តិការផ្ទុកសំបកកុងតែន័រចូលនាវា ការថយចុះនៃការនាំចូល-នាំចេញតាម **កសស** នៅពេលថ្មីៗនេះ ពេលវេលា Transit កុងតែន័រពីប្រទេសវៀតណាមទៅសហរដ្ឋអាមេរិកតាម **កសក** ហាក់ដូចជាឆាប់ហើសជាងតាម **កសស** និងមានការថយចុះការនាំចូលវត្ថុធាតុដើមពីប្រទេសចិន ព្រមទាំងតម្រូវការចំណតផ្ទៃកុងតែន័រនិងឋបនីយកណ្ឌផែសំខាន់ៗមួយចំនួនទៀត ។

ទោះជាកត្តាសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងវិបត្តិសេដ្ឋកិច្ចសាកល និង/ឬ ការថយចុះនៃការបញ្ជាទិញក៏ដោយ ប៉ុន្តែភាពយឺតយ៉ាវនៃប្រតិបត្តិការផ្ទុកសំបកកុងតែន័រចូលនាវា នៅមិនទាន់ឆ្លើយតបពេញលេញតាមតម្រូវការរបស់អតិថិជននៅឡើយ ។

ប្រការនេះ អាចបណ្តាលមកពីភាពអាក់អួលនៃមធ្យោបាយគ្រឿងចក្រ ការរើសំបកកុងតែន័រច្រើនដង និង/ឬ ក្រុមហ៊ុន Shipping Lines ដឹកជញ្ជូនសំបកកុងតែន័រមកនាវាមិនទាន់ពេល ។

ករណីខាងលើ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពការងារ និងទំនុកចិត្តរបស់អតិថិជន។ សវនដ្ឋានគួរសហការសម្របសម្រួល និងសិក្សាអំពីមូលហេតុសំខាន់ៗពាក់ព័ន្ធនឹងករណីខាងលើបន្ថែមទៀត ។

*នាយកដ្ឋានទីផ្សារ នឹងសហការសម្របសម្រួលការងារជូនអតិថិជនឱ្យបានសមស្រប និងបន្តសិក្សាអំពីសេវាប្រតិបត្តិការនិងការនាំចូល-ចេញតាមច្រកទ្វារ **កសស** និង **កសក** តាមលទ្ធភាពដែលអាចធ្វើបាន។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្ទាប់ទៀត ។

## ៥.៣.៧.២ ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារ ២០២៣-២០២៥

យោងតាមពង្រាងផែនការយុទ្ធសាស្ត្រទីផ្សាររបស់ **កសស** ឆ្នាំ ២០២៣-២០២៥ ដែលទទួលបានពីសវនដ្ឋាន សវនករបានពិនិត្យឃើញមានគោលការណ៍យុទ្ធសាស្ត្រសំខាន់ៗពាក់ព័ន្ធនឹងចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង ព្រមទាំងធាតុចូលសំខាន់ៗជាច្រើនផ្សេងទៀតដើម្បីវាស់វែង និងពង្រឹងប្រសិទ្ធភាពអនុវត្តផែនការសកម្មភាពរបស់ **កសស** ប៉ុន្តែ ដោយផែនការយុទ្ធសាស្ត្រខាងលើនៅមិនទាន់បានបញ្ចប់ សវនករបានសង្កេតឃើញចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដែលត្រូវធ្វើការកែលម្អបន្ថែមទៀត ។

ចំណុចខាងលើគឺពាក់ព័ន្ធនឹងបរិបទទីផ្សារសេរី ដូច្នេះការរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ (Marketing Strategic Plan) ត្រូវឈរលើគោលការណ៍នៃផែនការទីផ្សារ (Marketing Plan) ហើយផែនការទាំងពីរ ត្រូវអនុវត្តស្របគ្នាក្នុងពេលតែមួយ និងមិនអាចប្រើប្រាស់ជំនួយគ្នាបានទេ។ ក្នុងបរិបទនេះ ផែនការយុទ្ធសាស្ត្រទីផ្សាររំលេចអំពីគោលបំណងនៃ Marketing Efforts និងគោលដៅរយៈពេលវែង (End Goal) ដែលអង្គភាពបានកំណត់ ។ ដោយឡែក ផែនការទីផ្សាររំលេចអំពីការអនុវត្តជាក់ស្តែងនៃ Marketing Efforts និងជាផែនការលំអិតស្តីពីរបៀបដែលអង្គភាពគ្រោងសម្រេចគោលដៅរយៈពេលវែង (End Goal) របស់ខ្លួន ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីទទួលបន្ទុកការងារ ក្នុងក្របខណ្ឌសវនដ្ឋាននៅមានភាពខ្វះចន្លោះក្នុងការរៀបចំភាពប្រទាក់ក្រឡាគ្នានៃបែបបទ និង/ឬ គោលការណ៍ដែលត្រូវកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រទីផ្សារ (Marketing Strategic Plan) និងផែនការទីផ្សារ (Marketing Plan) ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពអនុវត្ត ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារ ដែលសវនដ្ឋានបាននិងកំពុងព្រាងឡើង ។

សវនដ្ឋានគួរធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាពិសេសពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទីផ្សារ (Marketing Strategy) និងផែនការទីផ្សារ (Marketing Plan) ដើម្បីបញ្ចប់ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារដែលមានស្រាប់ ឱ្យបានឆាប់រហ័សនិងសមស្របតាមតម្រូវការរបស់ **កសស** ។

*នាយកដ្ឋានទីផ្សារ សូមឯកភាពតាមអនុសាសន៍របស់សវនករ និងប្រឹងប្រែងសិក្សាស្រាវ ជ្រាវបន្ថែមដើម្បីរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ ឱ្យចេញជារូបរាងឡើងនៅត្រីមាសទី ៤ ឆ្នាំ ២០២២ តាមធនធាននិងលទ្ធភាពមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងស្ថានការណ៍តម្រូវការ សម្រាប់ការអភិវឌ្ឍន៍របស់ **កសស** ពេលបច្ចុប្បន្ននិងអនាគត ។*

*ទោះយ៉ាងណាក្តី សូមបញ្ជាក់ជូនបន្ថែមថា នាយកដ្ឋានទីផ្សារយើងខ្ញុំមានបញ្ហាប្រឈមមួយចំនួន ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារនោះគឺ ៖ ១. បទពិសោធន៍និងជំនាញវិភាគស៊ីជម្រៅដែលទាមទារនូវសមត្ថភាពខ្ពស់ របស់អ្នករៀបចំយុទ្ធសាស្ត្រទីផ្សារនេះ (ធនធានមនុស្ស) ២. ប្រភពព័ត៌មានទាំងផ្ទៃក្នុង (ស្ថិតិនានា) និងខាងក្រៅ (តួលេខសេដ្ឋកិច្ច) ៣. ការយល់ដឹងនិងផ្តល់សារសំខាន់ចំពោះកិច្ចការនេះនៅមានកម្រិត។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសទី ៤ ជាបន្តទៀត ។

## ៥.៣.៨ នាយកដ្ឋានព័ត៌មានវិទ្យា (ពមវ)

### ៥.៣.៨.១. បច្ចុប្បន្នភាពនៃគេហទំព័ររបស់ កសស

យោងតាមការពិនិត្យព័ត៌មានពាក់ព័ន្ធនឹងសកម្មភាព សមិទ្ធផលការងារ និងការអភិវឌ្ឍន៍ដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ **កសស** សវនករបានសង្កេតឃើញមានភាពយឺតយ៉ាវ កំហុសឆ្គងតួលេខ និងចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដូចខាងក្រោម៖ ១) ការចូលរួមក្នុងការងារសង្គម (CSR “Corporate Social Responsibility”) របស់ **កសស** នៅលើទំព័រដើម (Homepage) មានសកម្មភាពត្រឹមឆ្នាំ ២០១៩; ២) តារាងស្ថិតិបរិមាណទំនិញនិងកុងតែន័រឆ្លងកាត់ត្រូវបានចុះផ្សាយត្រឹមឆ្នាំ ២០១៨; ៣) ទំហំផ្ទៃដីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានចុះផ្សាយចំនួន ៦៨ ហិកតារ ដែលបច្ចុប្បន្នមានត្រឹម ៦៣.២ ហិកតារ; ៤) រូបភាព Background ក្នុង link ផ្សេងៗទៀតនៅមិនទាន់បានប្តូរថ្មី (រូបភាពចាស់តាំងពីចំណតផែពហុបំណង នៅមិនទាន់បានសាងសង់រួច); ៥) រថយន្តស្ទូចចល័តលើគែមផែ (QC) ត្រូវបានចុះចំនួន ៤ គ្រឿង ដែលបច្ចុប្បន្នមាន ៥ គ្រឿង; ៦) ច្បាប់និងបទប្បញ្ញត្តិផ្សេងៗនៅមិនទាន់បាន Update ទាន់ពេល; ៧) ផែនការអភិវឌ្ឍន៍ទាំង ៥ គម្រោងដែលកំពុងផ្សព្វផ្សាយក្នុងគេហទំព័រ ត្រូវបានបញ្ចប់តាំងពីឆ្នាំ ២០១៧; ៨) ពុំទាន់បាន Update ដៃគូអាជីវកម្ម/ចំនួនក្រុមហ៊ុន Shipping Lines ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **កសស** គ្រប់ចំនួន; ៩) នៅមិនទាន់បាន Update តួលេខ/ចំនួនអ្នកចូលទស្សនា ព័ត៌មាននីមួយៗនៅក្នុងគេហទំព័ររបស់ **កសស** ។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ១១៥ សសរ/ កសស/ពមវ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២០ ស្តីពីការរៀបចំរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ចរបស់បណ្តាការិយាល័យនៃនាយកដ្ឋានព័ត៌មានវិទ្យា ដែលត្រូវចុះប្រមូល និងរៀបចំមាតិកាព័ត៌មាន រូបភាព វីដេអូ និងឯកសារនានាដើម្បីផ្សព្វផ្សាយអំពីសកម្មភាព និងសមិទ្ធផលការងារពាក់ព័ន្ធនឹង **កសស** តាមរយៈគេហទំព័រនិងប្រព័ន្ធបណ្តាញសង្គម។

ករណីនេះបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ក្នុងក្របខ័ណ្ឌការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍ នៃនាយកដ្ឋានព័ត៌មានវិទ្យា ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្ត សេចក្តីសម្រេចស្តីពីការរៀបចំរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ចរបស់សវនដ្ឋាន។

យោងបរិបទខាងលើ ថ្នាក់ដឹកនាំសវនដ្ឋានគួរណែនាំការិយាល័យជំនាញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ឱ្យបន្តពិនិត្យមាតិកាព័ត៌មាន រូបភាព វីដេអូ និងឯកសារនានាឡើងវិញនិង Update ព័ត៌មានពាក់ព័ន្ធនឹងសកម្មភាព សមិទ្ធផលការងារ និងការអភិវឌ្ឍន៍ដែលបានផ្សព្វ ផ្សាយក្នុងគេហទំព័រ និងបណ្តាញសង្គមរបស់ **កសស** ក្នុងរយៈពេលកន្លងមកឱ្យបានសមស្របនិងទាន់ពេលវេលា។

*នាយកដ្ឋានព័ត៌មានវិទ្យានឹងធ្វើការ **Update Website** ឡើងវិញឱ្យរួចរាល់នៅក្នុងខែមករា ឆ្នាំ ២០២៣ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសទី ១ ឆ្នាំ ២០២៣ ។

### ៥.៣.៨.២. កម្មវិធី Mobile App (Mobile Application Program) របស់ កសស

តាមការចុះពិនិត្យ និងសម្ភាសន៍មន្ត្រីជំនាញ ក្នុងក្របខ័ណ្ឌនាយកដ្ឋានព័ត៌មានវិទ្យា សវនករបានសង្កេតឃើញថា ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ **កសស** កាលពីដើមត្រីមាសទី ២ ឆ្នាំ ២០២២ សវនដ្ឋានបានបង្កើតកម្មវិធី Mobile App (Application Program) ថ្មីមួយដែលមាន ៦ (ប្រាំមួយ) Menu សំខាន់ៗដូចខាងក្រោម៖ ១) Gate Registration, ២) Container Information, ៣) Vessel, ៤) News Feed , ៥) Report, និង ៦) Camera ដោយក្នុងចំណោម Menu ទាំង ៦ មាន Menu ៤ ស្តីពី Gate Registration, Container Information, Vessel និង News Feed ត្រូវបានធ្វើរួចរាល់ហើយ ប៉ុន្តែនៅមិនទាន់បានប្រើប្រាស់ជាផ្លូវការនៅឡើយ ពីព្រោះសវនដ្ឋានត្រូវធ្វើការកែសម្រួលលក្ខណៈបច្ចេកទេសបន្ថែមទៀត ។ ដោយឡែក Menu ២ ទៀតស្តីពី Report និង Camera នៅមិនទាន់បានធ្វើរួចរាល់នៅឡើយទេ ។

ដើម្បីអនុលោមតាមកំពង់ផែនានាក្នុងតំបន់ និងឆ្លើយតបតាមតម្រូវការរបស់ **កសស** ក៏ដូចជាអតិថិជន និងអ្នកប្រើប្រាស់ផែ សវនដ្ឋានគួរបន្តធ្វើ Menu ២ ទៀតស្តីពី Report និង Camera អោយបានឆាប់ដើម្បីបានដាក់ប្រើប្រាស់ក្នុងពេលដំណាលគ្នា ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីទទួលបន្ទុកការងារ ក្នុងក្របខ័ណ្ឌការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍នៃនាយកដ្ឋានព័ត៌មានវិទ្យា ត្រូវធ្វើការសិក្សាអំពីលក្ខណៈបច្ចេកទេស និងតម្រូវការសំខាន់ៗរបស់នាយកដ្ឋានពាក់ព័ន្ធក្នុងក្របខ័ណ្ឌ **កសស** បន្ថែមទៀត ។

កត្តាខាងលើអាចបណ្តាលឱ្យខាតបង់ពេលវេលា ក្នុងការងារគ្រប់គ្រងនិងសម្របសម្រួលកិច្ចប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ។

សវនដ្ឋានគួរជំរុញការងារខាងលើឱ្យបានឆាប់រហ័ស និងសមស្របតាមទំហំការងារ ក៏ដូចជាតម្រូវការរបស់ **កសស** និងអតិថិជនដែលកំពុងប្រើប្រាស់សេវាកំពង់ផែ ។

*នាយកដ្ឋាននឹងស្នើសុំថ្នាក់ដឹកនាំដាក់ Mobile App ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៣ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មនៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៥.៣.៩ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស (តសព)

### ៥.៣.៩.១ របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ក្នុងត្រីមាសទី ៣ ឆ្នាំ ២០២២ នៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (តសព)

យោងតាមការពិនិត្យរបាយការណ៍ ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ក្នុងត្រីមាសទី ៣ (កក្កដា-សីហា) ឆ្នាំ ២០២២ នៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ និងការចុះពិនិត្យស្ថានភាពទីតាំងផ្ទាល់

សវនករបានសង្កេតឃើញចំណូលសរុប ដែលទទួលបានពីការជួលរោងចក្រ ឃ្លាំង ដីឡូតិ៍ និងការិយាល័យចំនួន 645,799.93 USD ដោយរាប់បញ្ចូលទាំង VAT 10% ។ បន្ថែមលើនេះ សវនដ្ឋានបានរៀបចំផែនការសំអាត ថែទាំ និងជួសជុលអាគារ Service Apartment ចំនួន ០៨ Units ស្មើនឹង ៤៤ បន្ទប់ជាប្រចាំ និងអាគារអន្តេវាសិកដ្ឋាន (Dormitory) ចំនួន ០២ Units ស្មើនឹង ៩២ បន្ទប់តាមផែនការ Periodical Maintenance រៀបចំប្រជុំដោះស្រាយបញ្ហាប្រចាំខែ (Tenant Meeting) ស្នើសុំបញ្ជាក់សិទ្ធិជួលរយៈពេលវែងជូនក្រុមហ៊ុន Aeon Mall រួចរាល់ ផ្តល់ព័ត៌មានជូន Advisor Team ដើម្បីផលិត Promotion Tolls ចូលរួមប្រជុំស្តីពីវឌ្ឍនភាពគម្រោង Free Port ជាមួយអង្គការ JICA, GDCE និងក្រុមហ៊ុន Aeon Mall ព្រមទាំងកំណត់បញ្ហាប្រឈម និងដំណោះស្រាយ និងទិសដៅការងារសម្រាប់ត្រីមាសទី ៤ ឆ្នាំ ២០២២ ។ល។

ពាក់ព័ន្ធនឹងលទ្ធផលការងារខាងលើ សវនករបានពិនិត្យឃើញថាតំបន់សេដ្ឋកិច្ចពិសេសនៅមានការងារមួយចំនួនដែលត្រូវបំពេញបន្ថែម រួមមានការបើកច្រកទ្វារថ្មីមួយទៀតនៅជិតការដ្ឋានសាងសង់របស់ក្រុមហ៊ុន Aeon Mall ការបន្ថែមកម្លាំងសន្តិសុខដើម្បីយាមល្បាតឱ្យបានទៀតទាត់ និងការបង្កើនប្រសិទ្ធភាពថាមពល ពីព្រោះបណ្តាញភ្លើងអគ្គិសនីនៅក្នុង **តសព** ក្នុងរយៈពេលកន្លងមកមានភាពអាក់អួលគួរឱ្យកត់សម្គាល់ ហើយក្នុងពេលឆាប់ៗខាងមុខនេះ **កសស** ក៏ត្រូវផ្គត់ផ្គង់ថាមពលអគ្គិសនីជូនក្រុមហ៊ុន Aeon Mall តាមរយៈ**តសព** ផងដែរ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមលក្ខន្តិកៈ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៩ ក្នុងប្រការ ៥ ស្តីពីកម្មវត្ថុអាជីវកម្ម៖ **កសស** មានកម្មវត្ថុអាជីវកម្ម សេវាកម្មកំពង់ផែ ព្រមទាំងគ្រប់គ្រង ថែទាំបរិយកណ្ឌផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍន៍ សម្រាប់តម្រូវការនៃពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សេវាកម្មទេសចរណ៍និងអ្នកដំណើរ ព្រមទាំងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឱ្យ **កសស** បានរីកចម្រើននិងលូតលាស់ទៅមុខ ។

ភាពយឺតយ៉ាវនៃការរៀបចំបែបបទ ស្នើសុំបំពេញការងារខាងលើនេះ អាចបណ្តាលមកពីកង្វះខាតបុគ្គលិកនៅក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

ប្រការនេះ អាចបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិរបស់ **កសស** ប៉ះពាល់ដំណើរការធុរកិច្ចនិងបាត់បង់ចំណូលអាជីវកម្មរបស់ **កសស** ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឱ្យរៀបចំតារាងពេលវេលា/ផែនការសមស្រប ដើម្បីងាយស្រួលក្នុងការចុះពិនិត្យ សំអាត ថែរក្សា និងជួសជុលផ្នែកខូចខាតនៃ អាគារអន្តេវាសិកដ្ឋាន (Dormitory) ឱ្យបានទៀងទាត់ និងបន្តផ្សព្វផ្សាយអំពីសក្តានុពល **តសព** ដើម្បីទាក់ទាញវិនិយោគិន និងបង្កើនប្រភពចំណូលជូន **កសស** បន្ថែមទៀត ។

*នាយកដ្ឋាននិងបន្តអនុវត្តផែនការថែទាំ ជួសជុលសម្បទាបន្តទៀត ។ ជាពិសេស Dormitory បន្តទៀតតាមរូបភាព Preventive Nature រួមទាំងបរិវេណជុំវិញនិងបន្តផ្សព្វផ្សាយ តសព ដើម្បីទាក់ទាញ Foreign Direct Investment (FDI) បន្ថែមទៀត ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្ទាប់ទៀត ។

### ៥.៣.៩.២ ស្ថានភាពបរិស្ថាននៅជុំវិញបរិវេណអាគារ Service Apartment និង អន្តេវាសិកដ្ឋាន (Dormitory)

តាមការចុះពិនិត្យស្ថានភាពបរិស្ថាននៅជុំវិញបរិវេណអាគារ Service Apartment និង អន្តេវាសិកដ្ឋាន (Dormitory) សវនករបានសង្កេតឃើញសវនដ្ឋាន កំពុងរៀបចំស្តារភក់/យកដីចេញពីប្រព័ន្ធលូជុំវិញបរិវេណអាគារ កាត់ស្មៅក្រាស់ៗដែលដុះគ្របលើផ្លូវចូល-ចេញតាមច្រកទ្វារទី ៣ ដើម្បីសម្រួលលំហូរទឹកភ្លៀង និងយក

កូនឈើ និង/ឬ វល្លិ ដែលដុះក្នុងទទឹកភ្លៀងជុំវិញដំបូល អាគារ ប៉ុន្តែដោយកម្លាំងពលកម្មមានកម្រិត សវនដ្ឋាននៅពុំទាន់បានរៀបចំស្តារប្រឡាយ និងសំអាតស្លែដែលកាន់ជាប់ផ្ទៃជញ្ជាំងជុំវិញអាគារនៅឡើយ ។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមបទបញ្ជាផ្ទៃក្នុងរបស់ **កសស** លេខ ០០១.បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងប្រការ V ចំណុចទី ៣ ត្រូវប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិសម្ភារ មធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាត ថែរក្សានិងទុកដាក់ឱ្យបានគង់វង្ស។

កត្តានេះ អាចបណ្តាលមកពីពុំមានកម្លាំងពលកម្ម/បុគ្គលិកសំអាតនិងអនាម័យគ្រប់គ្រាន់ ។

ប្រការនេះ អាចបណ្តាលឱ្យស្ទះលំហូរទឹកភ្លៀង ប៉ះពាល់សោភ័ណភាពអាគារ មិនមានភាពទាក់ទាញ និងការប្រើប្រាស់ពុំទាន់មានប្រសិទ្ធភាព ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរបន្តណែនាំមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឱ្យចុះពិនិត្យស្ថានភាពបរិស្ថាន និងសម្ភារប្រើប្រាស់គ្រប់ប្រភេទនៅក្នុងអាគារ Service Apartment និងអន្តេវាសិកដ្ឋាន (Dormitory) ក៏ដូចជា **តសព** ទាំងមូលឱ្យបានទៀងទាត់ ដើម្បីឱ្យសវនដ្ឋានអាចចាត់វិធានការសំអាតនិងជួសជុលបានទាន់ពេលវេលា ។

*នាយកដ្ឋាននិងបន្តបញ្ជូនអ្នកទទួលបន្ទុក ចុះត្រួតពិនិត្យទៅតាមតារាងពេលវេលាថែទាំដើម្បីរក្សាបាននូវសម្បទាដែល **តសព** អាចប្រើប្រាស់បានតាមអាយុកាលរបស់វា និងជួសជុលទាន់ពេល ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្ទាប់ទៀត ។

## ៥.៣.១០ នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី (គ្រចយអន)

### ៥.៣.១០.១ វគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញបើកបរគ្រឿងចក្រ

យោងតាមការឆ្លើយតប ក្នុងកម្រងសំណួរស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សវនករបានកត់សម្គាល់ឃើញថា គិតត្រឹមត្រីមាសទី ៣ ឆ្នាំ ២០២២ នេះ សវនដ្ឋាននៅពុំទាន់បានរៀបចំបើកវគ្គបណ្តុះបណ្តាលបន្ថែមអំពីបច្ចេកទេស និងជំនាញបើកបរគ្រឿងចក្រធន់ធ្ងន់ រួមទាំងបច្ចេកទេសអគ្គិសនី ដល់កម្មករ/ប្រតិបត្តិករគ្រឿងចក្រ និងបុគ្គលិកអគ្គិសនីនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ ឆ្នាំ ២០២២ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ក្នុងឧបសម្ព័ន្ធទី ៨: ផែនការបណ្តុះបណ្តាលធនធានមនុស្សឆ្នាំ ២០២២ ចំណុច ក-២ ហ្វឹកហ្វឺនបើកបរគ្រឿងចក្រធន់ធ្ងន់ និងចំណុច ក-២២ ស្តីពីទ្រឹស្តីត្រួតពិនិត្យ ថែទាំ-ជួសជុល គ្រឿងចក្រធន់ធ្ងន់ ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីជំនាញក្នុងក្របខ័ណ្ឌសវនដ្ឋាន មានភាពមមាញឹកក្នុងការងារជួសជុល ថែទាំ គ្រឿងចក្រ និងឋបនីយភណ្ឌអគ្គិសនីសំខាន់ៗ ដែលជាការងារអាទិភាពក្នុងការបម្រើប្រតិបត្តិការអាជីវកម្មសេវាកម្មរបស់ **កសស** ។

ទោះជាយ៉ាងណាក៏ដោយ កត្តានេះអាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្តផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុរបស់ **កសស** ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួររៀបចំផែនការ និងស្នើសុំថ្នាក់ដឹកនាំ **កសស** បើកវគ្គបណ្តុះបណ្តាលអំពី បច្ចេកទេសនិងជំនាញបើកបរ រួមទាំងបច្ចេកទេសអគ្គិសនី និងទ្រឹស្តីត្រួតពិនិត្យ ថែទាំ-ជួសជុល គ្រឿងចក្រធន់ធ្ងន់និងអគ្គិសនី ដល់កម្មករ/ប្រតិបត្តិករ និងបុគ្គលិកអគ្គិសនីស្របតាមគោលការណ៍ ដូចមានចែងនៅក្នុងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុឆ្នាំ ២០២២ របស់ **កសស** ។

*១. ការបណ្តុះបណ្តាលបច្ចេកទេសអគ្គិសនី*

- *ដោយសារស្ថានភាពការងារ មានភាពមមាញឹកខ្លាំង គួបផ្សំនឹងចំនួនបុគ្គលិកមានចំនួនតិច ដូច្នេះនាយកដ្ឋានមិនអាចមានឱកាស និងធ្វើការបែងចែកកម្លាំងសម្រាប់ទទួលការបណ្តុះបណ្តាលបានឡើយ ។*

*២. ការបណ្តុះបណ្តាលបើកបរគ្រឿងចក្រ*

- *ការបណ្តុះបណ្តាលត្រូវបានពន្យាពេល ដោយសារនាយកដ្ឋានទើបតែមានការរួមបញ្ចូលរវាងអគ្គិសនី និងគ្រឿងចក្រនិងដឹកជញ្ជូនជាមួយគ្នានេះផងដែរ អតីតអ្នកទទួលបន្ទុកកិច្ចការបណ្តុះបណ្តាលមានជម្ងឺប្រចាំកាយត្រូវសម្រាកព្យាបាលអស់មួយរយៈពេលយូរ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម/វិធានការបន្ទាប់របស់សវនដ្ឋាន ។

## ៥.៣.១០.២ របាយការណ៍ម៉ាស៊ីនភ្លើងនិងការថែទាំ

យោងតាមរបាយការណ៍ម៉ាស៊ីនភ្លើង ការថែទាំ និងការសម្ភាសន៍មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រង សវនករបានពិនិត្យឃើញ **កសស** បំពាក់ម៉ាស៊ីនភ្លើងសរុបចំនួន ១៣ (ដប់បី) គ្រឿងដើម្បីផ្គត់ផ្គង់ថាមពលអគ្គិសនីនៅក្នុងតំបន់ **កសស** ទាំងមូល ។ ម៉ាស៊ីនភ្លើងទាំងនេះរួមមាន៖

| | |
|---|---|
| ១. IVECO 200 KVA | គ្មានលេខសម្គាល់ |
| ២. IVECO 300 KVA | គ្មានលេខសម្គាល់ |
| ៣. IVECO 300 KVA | គ្មានលេខសម្គាល់ |
| ៤. MITSUBISHI 250 KVA | លេខសម្គាល់ 201 |
| ៥. MITSUBISHI 250 KVA | លេខសម្គាល់ 202 |
| ៦. IVECO 500 KVA | លេខសម្គាល់ 306 |
| ៧. MITSUBISHI 1000 KVA | លេខសម្គាល់ 307 |
| ៨. MITSUBISHI 1000 KVA | លេខសម្គាល់ 308 |
| ៩. MITSUBISHI 1000 KVA | លេខសម្គាល់ 309 |
| ១០. MITSUBISHI 1000 KVA | លេខសម្គាល់ 310 |
| ១១. MITSUBISHI 1000 KVA | លេខសម្គាល់ 311 |
| ១២. MITSUBISHI 1000 KVA | លេខសម្គាល់ 312, និង |
| ១៣. MITSUBISHI 1000 KVA | លេខសម្គាល់ 313 ។ |

ពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងថែទាំម៉ាស៊ីនភ្លើងខាងលើ សវនដ្ឋានបានរៀបចំផែនការ/តារាងពេលវេលាដោយមានការកំណត់កាលបរិច្ឆេទ លេខសម្គាល់ អំណានចាស់/ថ្មី ដើម្បីប្តូរប្រេងម៉ាស៊ីន តម្រងប្រេង លាងសំអាត បាញ់ខ្លាញ់ បូមធូលី ។ល។ និងគម្រោងពេលថែទាំ ជួសជុលត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

ជាមួយនេះ ចាប់តាំងពីពេលដែល **កសស** បានប្រើប្រាស់បណ្តាញអគ្គិសនីកម្ពុជា (EDC) ពីថ្ងៃទី ៣១ ខែមីនា ដល់ត្រីមាសទី ៣ ឆ្នាំ ២០២២ សវនដ្ឋានបានរៀបចំចាត់ចែងការងារនិងត្រៀមលក្ខណៈដូចខាងក្រោម៖ ១) ត្រៀមម៉ាស៊ីនភ្លើង ០៥ (ប្រាំ) គ្រឿងម៉ាក MITSUBISHI 1000 KVA លេខសម្គាល់ 308, 309, 310, 311 និង 312 ដើម្បីប្រើប្រាស់នៅពេលអគ្គិសនីកម្ពុជាមានភាពរអាក់ រអួល/ដាច់ការផ្គត់ផ្គង់ជាយថាហេតុ, ២) រៀបចំជួសជុលម៉ាស៊ីនភ្លើង ០២ (ពីរ) គ្រឿងរួមមាន MITSUBISHI 1000 KVA លេខសម្គាល់ 307 (ខូចនៅថ្ងៃទី ២៥ ខែ

ឧសភា ឆ្នាំ ២០២១) កំពុងជួសជុលធំនៅភ្នំពេញ និង MITSUBISHI 1000 KVA លេខសម្គាល់ 313 (ខូចនៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២១) កំពុងរៀបចំយកទៅជួសជុលនៅភ្នំពេញ។

ទោះជាយ៉ាងណាក៏ដោយ សវនករបានសង្កេតឃើញថា គិតចាប់តាំងពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២១ រហូតដល់ត្រីមាសទី ៣ ឆ្នាំ ២០២២ នេះម៉ាស៊ីនភ្លើងម៉ាក MITSUBISHI 1000 KVA លេខសម្គាល់ 307 ដែលបាននិងកំពុងជួសជុលធំនៅភ្នំពេញនោះ នៅពុំទាន់រួចរាល់នៅឡើយ។

ប្រការខាងលើអាចបណ្តាលមកពីក្រុមហ៊ុនផ្គត់ផ្គង់ មានកង្វះខាតគ្រឿងបន្លាស់ ឬ បញ្ហាបច្ចេកទេសរបស់ផ្នែក Mechanics ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពការងារ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ **កសស** ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនផ្គត់ផ្គង់ និងជួយជំរុញឱ្យក្រុមជាងធ្វើការជួសជុលឱ្យបានឆាប់។

*នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី និងសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីធ្វើទំនាក់ទំនងជាមួយក្រុមជាង និងជំរុញការងារជួសជុលម៉ាស៊ីនភ្លើងទាំងពីរគ្រឿងឱ្យបានឆាប់។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មនៅត្រីមាសបន្ទាប់ទៀត ។

## ៥.៣.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

### ៥.៣.១១.១ ការគោរពគោលការណ៍វិន័យ និងពេលវេលាធ្វើការរបស់ និយោជិត កម្មករ កសស ដែលបម្រើការងារផ្នែកអាជីវកម្ម និងផ្នែកប្រយោល (នាយកដ្ឋាន)

តាមការណែនាំរបស់រាជរដ្ឋាភិបាល **កសស** បានចូលរួមអនុវត្តវិធានការការពារនិងរក្សាគម្លាតសុវត្ថិភាពសង្គម ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដល់និយោជិត កម្មករយ៉ាងខ្ជាប់ខ្ជួន។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីពេលដែលរាជរដ្ឋាភិបាល បានប្រកាសបើកប្រទេសជាសាកលឡើងវិញ សវនករបានសង្កេតឃើញនិយោជិត កម្មករ មួយចំនួននៅបន្តអូសបន្លាយពេលវេលាធ្វើការ ពិសេស ផ្នែកប្រយោល (នាយកដ្ឋាន) នៅមិនទាន់បានអនុវត្តគោលការណ៍វិន័យ ជាប្រក្រតីភាពឡើងវិញនៅឡើយ ។

ប្រការខាងលើ អាចនាំឱ្យមានគម្លាតអនុលោមភាពគោលការណ៍ ដែលបានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ កសស លេខ ០០១.បបផក/កសស/បេ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងប្រការ I ចំណុចទី ៦៖ និយោជិត កម្មករ កសស ត្រូវគោរពទង់ជាតិនៅរៀងរាល់ពេលព្រឹក លើកលែងតែមានបញ្ហាបេសកកម្ម ឬ ធុរៈចាំបាច់បន្ទាន់ដែលត្រូវបានចាត់តាំង ឬ ទទួលស្គាល់ដោយមន្ត្រីគ្រប់គ្រងផ្ទាល់ និងប្រការ II ចំណុច ២.២ ស្តីពីថេរៈវេលាបំពេញការងារ (ពេលម៉ោងផ្នែកប្រយោល "នាយកដ្ឋាន") ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១៦:០០ ដោយឈប់សម្រាកពីម៉ោង ១២:០០ ដល់ម៉ោង ១៣:០០ រសៀល ។

ករណីនេះ អាចបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតែបន្តកើតមាន ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ការងារ និងប្រសិទ្ធភាពអនុវត្តបទបញ្ជាផ្ទៃក្នុង **កសស** ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរពិចារណារៀបចំឱ្យមានការគោរពទង់ជាតិឡើងវិញ ដើម្បីពង្រឹងវិធានការវិន័យ និងពេលម៉ោងបម្រើការងារស្របតាមគោលការណ៍ ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **កសស** ។

*នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលយកអនុសាសន៍របស់សវនកម្មផ្ទៃក្នុង ហើយនឹងខិតខំពង្រឹងវិធានការវិន័យ និងពេលម៉ោងបម្រើការងារស្របតាមគោលការណ៍ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **កសស**។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

### ៥.៣.១១.២ តារាងទូទាត់ប្រាក់បៀវត្សនិយោជិតក្នុងក្របខ័ណ្ឌ កសស

យោងតាមតារាងទូទាត់ប្រាក់បៀវត្សនិយោជិត ក្នុងក្របខ័ណ្ឌ **កសស** សម្រាប់ខែតុលានិងខែវិច្ឆិកា ឆ្នាំ ២០២២ សវនករបានពិនិត្យឃើញថា សវនដ្ឋាននៅពុំទាន់បានបន្ថែមជួរ (*Column*) ស្តីពីប្រាក់ទ្រទ្រង់សុខភាព សម្រាប់កម្មករដែលប្រើប្រាស់ពលកម្មផ្ទាល់ (ក្របខ័ណ្ឌផលិត) ចំនួន ៥០,០០០ រៀល/នាក់ខែ សម្រាប់កម្មករទាំង ៣ កងនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ និងកម្មករបច្ចេកទេសលើកដាក់នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នៅក្នុងតារាងប្រាក់បៀវត្សប្រចាំខែនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្តីកំណត់លេខ ០៦៦ សកណ/កសស/រប.ប ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៩ ស្តីពីការផ្តល់ប្រាក់ទ្រទ្រង់សុខភាព ក្នុងប្រការ ១ ផ្តល់ប្រាក់ទ្រទ្រង់សុខភាពជូនកម្មករ ដែលប្រើប្រាស់ពលកម្មផ្ទាល់ (ក្របខ័ណ្ឌផលិត) ចំនួន ៥០,០០០ (ហាសិបពាន់រៀល) រៀល/នាក់ខែ រួមមាន៖ ១) កម្មករទាំង ៣ កងនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ២) កម្មករបច្ចេកទេសលើកដាក់ នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រនិងប្រការ ២ ការឧបត្ថម្ភប្រាក់ទ្រទ្រង់សុខភាពនេះ ត្រូវបានគិតបញ្ចូលក្នុងតារាងប្រាក់បៀវត្សប្រចាំខែ ។

ករណីនេះ អាចបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

កត្តានេះ អាចបណ្តាលឱ្យខាតបង់អត្ថប្រយោជន៍កម្មករ ក្នុងក្របខ័ណ្ឌផលិតនិងប៉ះពាល់ប្រសិទ្ធភាពអនុវត្តសេចក្តីកំណត់ ស្តីពីការផ្តល់ប្រាក់ទ្រទ្រង់សុខភាពរបស់ កសស ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឱ្យពិនិត្យនិងរៀបចំបញ្ចូលជួរ (*Column*) ស្តីពីប្រាក់ទ្រទ្រង់សុខភាព សម្រាប់កម្មករក្នុងក្របខ័ណ្ឌផលិតខាងលើ ក្នុងតារាងប្រាក់បៀវត្សប្រចាំខែ ស្របតាមសេចក្តីកំណត់ស្តីពីការផ្តល់ប្រាក់ទ្រទ្រង់សុខភាព និងលក្ខន្តិកៈបុគ្គលិករបស់ **កសស** ។

*ករណីនេះ ដោយសារនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស បានប្រើប្រាស់ឃ្លា "ប៉ះពាល់សុខភាពជំនួសពាក្យ ប្រាក់ទ្រទ្រង់សុខភាព" នៅក្នុងជួរឈរ (Column) នៃតារាងបៀវត្ស ។*

*នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលយកអនុសាសន៍ និងកែសម្រួលពាក្យពេចន៍ឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារ នៃសេចក្តីកំណត់លេខ ០៦៦ សកណ/កសស/រប.ប ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៥.៣.១២ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ

### ៥.៣.១២.១ ឯកសារដេញថ្លៃផ្គត់ផ្គង់ទំនិញសម្រាប់ឆមាសទី ១ ឆ្នាំ ២០២២

យោងតាមការពិនិត្យ ឯកសារដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ស្តីពីការផ្គត់ផ្គង់ទំនិញសម្រាប់ឆមាសទី ១ ឆ្នាំ ២០២២ សវនករបានកត់សម្គាល់ឃើញមានភាពខ្វះចន្លោះ ឯកសារមួយចំនួនពាក់ព័ន្ធនឹងសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មដូចខាងក្រោម៖

- ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីក្រមសីលធម៌លទ្ធកម្ម។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីក្រមសីលធម៌លទ្ធកម្ម ក្នុងប្រការ ៨ ចែងថា គណៈកម្មាធិការលទ្ធកម្មត្រូវចុះហត្ថលេខា លើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម នៅគ្រប់ពេលចូលរួមក្នុងការវាយតម្លៃសំណើដេញថ្លៃ ។

ករណីនេះ អាចបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារលទ្ធកម្ម។

ប្រការនេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្ត ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីក្រមសីលធម៌លទ្ធកម្ម។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំមន្ត្រីទទួលបន្ទុកការងារលទ្ធកម្ម ឱ្យអនុវត្តតាមប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម នៅគ្រប់ពេលចូលរួមក្នុងការវាយតម្លៃសំណើដេញថ្លៃ ស្របតាមប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

*សវនដ្ឋានសូមទទួលយក និងខិតខំអនុវត្តឱ្យបានពេញលេញតាមអនុសាសន៍ របស់សវនករសម្រាប់ឆ្នាំបន្តបន្ទាប់ទៅមុខទៀត ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

### ៥.៣.១២.២ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២

យោងតាមការពិនិត្យ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ សវនករបានកត់សម្គាល់ឃើញ សវនដ្ឋានដាក់ចេញនូវផែនការប្រចាំឆ្នាំ និងលទ្ធផលអនុវត្តជាក់ស្តែងដោយធ្វើការប្រៀបធៀបបរិមាណទំនិញ/កុងតែន័រឆ្លងកាត់ និងចំនួននាវាចូលចតជាមួយបរិមាណឆ្នាំ ២០២១ ដើម្បីកំណត់អត្រាកំណើន/ថយចុះនៃការិយបរិច្ឆេទនីមួយៗ ។ ក្នុងនេះ បរិមាណទំនិញឆ្លងកាត់មានចំនួន ៧,០០៣,១៥៨ តោន កើនឡើង ១.៦៦% បរិមាណកុងតែន័រឆ្លងកាត់ ចំនួន ៧៥០,១៤៨ *TEUs* កើនឡើង ២.៤៣% និងចំនួននាវាចូលចតចំនួន ១,៤៤២ គ្រឿងថយចុះ ០.៤១% ។ ប៉ុន្តែ ភ្ជាប់នឹងករណីខាងលើ សវនករបានសង្កេតឃើញពុំមានការបញ្ជាក់គោលដៅ និងប្រភពនាំទំនិញ/កុងតែន័រ ចូល-ចេញ នៅក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារនោះទេ ។

ប្រការខាងលើ អាចបណ្តាលឱ្យមានភាពមិនច្បាស់លាស់ ក្នុងការកត់សម្គាល់បរិមាណទំនិញ/កុងតែន័រនាំចូល-នាំចេញនៅតាមគោលដៅ និងប្រភពសំខាន់ៗមួយចំនួនដូចជា អាស៊ី អឺរ៉ុប និងអាមេរិកជាដើម ។ល។

មូលហេតុនេះ អាចបណ្តាលមកពីនាយកដ្ឋានពាក់ព័ន្ធ ខកខានមិនបានផ្តល់ឯកសារទំនិញ និង/ឬព័ត៌មានពាក់ព័ន្ធនឹងគោលដៅ និងប្រភពទំនិញ/កុងតែន័រនាំចូល-នាំចេញទាន់ពេលវេលា។

កត្តានេះ អាចនាំឱ្យមានការយល់ច្រឡំ និងពិបាកកត់សម្គាល់គោលដៅនាំទំនិញ/កុងតែន័រ ចូលនិងប្រភពនាំចេញច្បាស់លាស់ ។

សវនដ្ឋានគួរសហការ/ស្នើសុំឯកសារទំនិញ ដែលមានឈ្មោះប្រទេសនាំចូល-នាំចេញច្បាស់ លាស់ដើម្បីកំណត់គោលដៅនាំទំនិញ/កុងតែន័រ ចូលនិងប្រភពនាំចេញបានសមស្រប ។

- *នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ បានទទួលប្រភេទទំនិញ ប្រភព និងប្រទេសគោលដៅ ពីនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ និងនាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រដោយកត់ត្រាតាម BL & Manifest ។ ទំនិញភាគច្រើនឆ្លងកាត់តាមកំពង់ផែសិង្ហបុរី នៅពេលនោះក្រុមហ៊ុនមួយចំនួនច្រើនតែប្រកាសគោលដៅនិងប្រភពមកពីកំពង់ផែសិង្ហបុរី ។ ប្រភេទទំនិញផ្សេងៗទៀត ច្រើនតែដាក់ក្នុងកុងតែន័រមួយដែលមានមុខទំនិញជាច្រើនមុខ។*
- *ករណីនេះ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ បានស្នើសុំឱ្យនាយកដ្ឋានពាក់ព័ន្ធ ពិនិត្យនិងសហការជាមួយក្រុមហ៊ុនដឹកជញ្ជូនបំពេញទិន្នន័យឱ្យបានច្បាស់លាស់សម្រាប់យកមកបំពេញបន្ថែម ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៥.៣.១៣ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

### ៥.៣.១៣.១ របាយការណ៍ស្ថានភាពបំណុលអតិថិជនជំពាក់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ

យោងតាមរបាយការណ៍ស្តីពីស្ថានភាពបំណុល ដែលអតិថិជនជំពាក់ **កសស** គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២ សវនករបានសង្កេតឃើញក្រុមហ៊ុនចំនួន ៣៤ ក្រុមហ៊ុនជំពាក់បំណុល **កសស** ជាទឹកប្រាក់សរុបចំនួន ៧,៣៤១,៤២១.៨១ ដុល្លារអាមេរិក ស្មើនឹង ៣០,២២៤,៦៣៣,៥៩១.៧៧ រៀល ។ បំណុលទាំងនេះ រាប់បញ្ចូលទាំងបំណុលរបស់ក្រុមហ៊ុន Shipping Lines ០៥ ក្រុមហ៊ុន និងក្រុមហ៊ុន Royal Railway Co., Ltd ចំនួន ៖

១). ក្រុមហ៊ុន Maersk ជំពាក់ : ២,០៣៣,៨២០.៣៨ ដុល្លារអាមេរិក

២). ក្រុមហ៊ុន Arrow Shipping ជំពាក់ : ៣១៧,១៧៧.៦០ ដុល្លារអាមេរិក

៣). ក្រុមហ៊ុន SITC Container ជំពាក់ : ១,១៧២,២៩៧.៦៨ ដុល្លារអាមេរិក

៤). ក្រុមហ៊ុន Danaka Logistics Co., Ltd ជំពាក់ : ១,៥០៥,៥៥២.៦០ ដុល្លារអាមេរិក

៥). ក្រុមហ៊ុន STRAITS INTERNATIONAL PTE., Ltd ជំពាក់: ៨៣២,៦៧៩.១៩ ដុល្លារអាមេរិក; និង

៦). ក្រុមហ៊ុន Royal Railway Co., Ltd ជំពាក់ : ៣៨០,២៩៦.៤០ ដុល្លារអាមេរិក។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមលក្ខខណ្ឌកិច្ចព្រមព្រៀង រវាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) និងក្រុមហ៊ុន Shipping Lines ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២២ ក្នុងប្រការ ៧ ចែងថា Line (s) ត្រូវពិនិត្យនិងចុះហត្ថលេខាលើវិក្កយបត្រក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ក្រោយពីបានបញ្ចប់ប្រតិបត្តិការផ្ទេរ-ផ្ទុកកុងតែន័រ និងត្រូវធ្វើការទូទាត់ក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃបន្ទាប់ពីបានចុះហត្ថលេខាលើវិក្កយបត្ររួច។ ប្រសិនបើ Line (s) មិនបានទូទាត់ថ្លៃឈ្នួលក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃក្រោយពីបានចុះហត្ថលេខាលើវិក្កយបត្រ នោះប្រតិបត្តិករ (**កសស**) មានសិទ្ធិផ្អាកសកម្មភាពនាវា ឬ ការបញ្ចេញកុងតែន័ររបស់ Line (s) រហូតដល់ Line (s) បានទូទាត់បំណុលរួចរាល់ ។

មូលហេតុខាងលើ អាចបណ្តាលមកពីតំណាងក្រុមហ៊ុននាវា (Shipping Lines) ក្នុងស្រុកត្រូវការពេលវេលាបញ្ជូនវិក្កយបត្រទាំងអស់ទៅការិយាល័យ (Head Office) នៃក្រុមហ៊ុននាវាមេនៅក្រៅប្រទេសដើម្បីពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃវិក្កយបត្រ និងភាពត្រឹមត្រូវក្នុងការប្រើប្រាស់សេវា ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់ ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងរវាង **កសស** និងបណ្តាក្រុមហ៊ុននាវា ។

ថ្នាក់ដឹកនាំសវនដ្ឋាន ត្រូវខិតខំអនុវត្តឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរវាង **កសស** និងក្រុមហ៊ុននាវា (Shipping Lines) និងត្រូវខិតខំទារបំណុលឱ្យបានទាន់ពេលវេលា ។

***បំណុលដែលក្រុមហ៊ុននាវាមួយចំនួននៅជំពាក់ កសស រួមមាន៖***

- *ក្រុមហ៊ុននាវាមួយចំនួន ដែលមានតំណាងការិយាល័យនៅកម្ពុជា ត្រូវការពេលវេលា បញ្ជូនវិក្កយបត្រទាំងអស់ទៅក្រុមហ៊ុននាវាមេនៅក្រៅប្រទេស ដើម្បីធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់មុននឹងធ្វើការទូទាត់ប្រាក់ជូន **កសស**។ ជាមួយគ្នាផងដែរ ក្នុងការអនុវត្តកិច្ចព្រមព្រៀងរវាង **កសស** និងក្រុមហ៊ុននាវា គឺក្រុមហ៊ុននាវាបានតម្កល់ប្រាក់កក់ជូន **កសស** ។*
- *សវនដ្ឋានបានអនុវត្តជាប្រចាំ ដោយធ្វើលិខិតទារបំណុលជាទៀងទាត់ ចំពោះក្រុមហ៊ុននាវាណាដែលបានជំពាក់ **កសស** ។*

- *រហូតមកដល់បច្ចុប្បន្ន មិនមានក្រុមហ៊ុននាវាណាដែលជំពាក់បំណុល **កសស** ហើយមិនបានទូទាត់ជូន **កសស** នោះទេ គ្រាន់តែក្រុមហ៊ុននាវាត្រូវការពេលវេលាក្នុងការបញ្ជូនវិក្កយបត្រទៅក្រុមហ៊ុននាវាមេនៅក្រៅប្រទេសប៉ុណ្ណោះ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

### ៥.៣.១៣.២. តារាងសរុបសារពើភណ្ឌអចលនទ្រព្យ ឆ្នាំ ២០២២

យោងតាមការពិនិត្យ តារាងសរុបសារពើភណ្ឌអចលនទ្រព្យ បញ្ចប់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២ សវនករបានកត់សម្គាល់ឃើញថា បណ្តាគ្រឿងចក្រមួយចំនួនដូចជា៖ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនទៀតដែលអស់តម្លៃរំលស់ និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត នៅពុំទាន់មានការលើកសំណើសុំជម្រះបញ្ជី ចេញពីតារាងសារពើភណ្ឌរបស់ **កសស** នៅឡើយ ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមប្រកាសរបស់ **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** លេខ ០០២ សហវ.ប្រក ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ២០២០ ស្តីពីវិធាននិងនីតិវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្នុងប្រការ ១២ ចែងថា ប្រភេទទ្រព្យសម្បត្តិរដ្ឋដូចមានចែងក្នុងប្រការ ១១ ក្រៅពីដីដែលជាកម្មវត្ថុនៃការអនុញ្ញាតឱ្យជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះមានស្ថានភាពចាស់ទ្រុឌទ្រោម ប្រើប្រាស់លែងកើត ខូចខាតធ្ងន់ធ្ងរ បាត់បង់ ឬ ខូចខាតធ្ងន់ធ្ងរ បាត់បង់ដោយមូលហេតុប្រធានស័ក្តិ ឬ ជាការផ្ទេរការប្រើប្រាស់រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ករណីនេះ អាចបណ្តាលមកពីសវនដ្ឋាន កំពុងពិនិត្យផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌអចលនទ្រព្យដូចជា៖ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនទៀតដែលអស់តម្លៃរំលស់ និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត ជាមួយបណ្តាសាមីនាយកដ្ឋានដែលប្រើប្រាស់ដើម្បីស្នើសុំជម្រះបញ្ជីចេញពីតារាងសារពើភណ្ឌរបស់ **កសស** ។

កត្តាខាងលើ អាចបណ្តាលឱ្យរថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនទៀតដែលផុតកំណត់ប្រើប្រាស់ អស់តម្លៃរំលស់ និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើតស្ថិតនៅក្នុងបញ្ជីសារពើភណ្ឌអចលនទ្រព្យច្រើន និងប៉ះពាល់ប្រសិទ្ធភាពនៃការគ្រប់គ្រងអចលនទ្រព្យរបស់ **កសស** ។

សវនដ្ឋាន គួរស្នើសុំថ្នាក់ដឹកនាំ **កសស** ជម្រះចេញនូវ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់និងឧបករណ៍-សម្ភារមួយចំនួន ដែលផុតកំណត់នៃការប្រើប្រាស់ អស់តម្លៃរំលស់និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត ចេញពីបញ្ជីសារពើភណ្ឌរបស់ **កសស** ។

*សវនដ្ឋាន បានរៀបចំរួចរាល់នូវបញ្ជីសារពើភណ្ឌអចលនទ្រព្យ **កសស** ក្នុងឆ្នាំ ២០២២ ដោយបានបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (Standard Registration Management System "SARMIS") របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

*ចំពោះ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនដែលបានបាត់បង់រូបរាងចាស់ទ្រុឌទ្រោម និងអស់តម្លៃរំលស់ សវនដ្ឋានបាននឹងកំពុងសហការជាមួយសាមីនាយកដ្ឋានដែលប្រើប្រាស់ដើម្បីពិនិត្យនិងកំណត់មុខសញ្ញាឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការសម្រេចពីថ្នាក់ដឹកនាំ **កសស** ដាក់ក្នុងរបៀបវារៈអង្គប្រជុំក្រុមប្រឹក្សាភិបាល **កសស** ដើម្បីពិនិត្យ និងសម្រេច ក្នុងការជម្រះចេញពីបញ្ជីសារពើភណ្ឌរបស់ **កសស** ស្របតាមប្រកាសលេខ ០០២ សហវ.ប្រក ស្តីពី " វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ" ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៦. សេចក្តីសន្និដ្ឋានរួម

នៅក្នុងអំឡុងពេលនៃការធ្វើសវនកម្មនេះ សវនករបានពិនិត្យឃើញសវនដ្ឋាននីមួយៗខិតខំប្រឹងប្រែងរៀបចំដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាព ផលិតភាពប្រតិបត្តិការនិងការទទួលខុសត្រូវ ។ ជាមួយនេះ ក្រុមការងារសវនកម្មបានសង្កេតឃើញថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកគ្រប់នាយកដ្ឋាន មានឆន្ទៈរួមសហការ និងយកចិត្តទុកដាក់បំពេញតួនាទី-ភារកិច្ចរបស់ខ្លួន ដោយអនុលោមតាមលក្ខន្តិកៈបុគ្គលិក **កសស** គោលការណ៍ច្បាប់និងបទប្បញ្ញត្តិ ជាធរមាន ។

## ៧. ផែនការសកម្មភាពកែលម្អ

ដើម្បីជានាប្រសិទ្ធភាពអនុវត្ត និងកែលម្អតាមអនុសាសន៍ដែលសវនករបានផ្តល់ជូន ថ្នាក់ដឹកនាំនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ បានឯកភាពតាមផែនការសកម្មភាពកែលម្អ ដូចបានកំណត់នៅក្នុងតារាងនៃ **ឧបសម្ព័ន្ធទី ២** ។

ថ្ងៃព្រហស្បតិ៍ ០៩ កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តព្រះសីហនុ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៣

**នាយកសវនកម្មផ្ទៃក្នុង**

**ម៉ែន ចាន់**

**បានឃើញ និងឯកភាព**

ខេត្តសៀមរាប ថ្ងៃទី..៣......ខែ.កុម្ភៈ..... ឆ្នាំ ២០២៣

**ប្រធានគណៈកម្មាធិការសវនកម្ម**

**ហ៊ុន មុន្នីវណ្ណា**

**ហ៊ុន មុន្នីវណ្ណា**

# ផ្នែកទី ៦

# របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្ស ក្នុងការដាក់ជូនរបាយការណ៍របស់ខ្លួនរួមជាមួយ និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស" ឬ "ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

### ក្រុមហ៊ុន

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស" ឬ "ក្រុមហ៊ុន") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលរបស់ខ្លួន នៅក្នុងខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិបុគ្គលដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពទូទៅឲ្យក្រុមហ៊ុនជាស្ថាប័នស្វយ័តសាធារណៈ។

ក.ស.ស បានចុះបញ្ជីជាសហគ្រាសសាធារណៈគ្រប់គ្រងដោយរដ្ឋ នៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៩៧៨៩ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផមក") នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។

សកម្មភាពចម្បងរបស់ ក.ស.ស គឺទាក់ទងនឹងការផ្តល់សេវាកម្មនៃឋបនីយភណ្ឌកំពង់ផែសមុទ្រ និងសេវាកម្មទាក់ទងនឹងកំពង់ផែ និងប្រតិបត្តិការភតិសន្យា នៃតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួន។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានទីតាំងស្ថិតនៅតិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

### លទ្ធផលហិរញ្ញវត្ថុ និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។ ភាគលាភបានប្រកាស និងទូទាត់ក្នុងអំឡុងឆ្នាំ ត្រូវបានកំណត់នៅក្នុងកំណត់សម្គាល់លេខ 30 នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ក្រុមប្រឹក្សាភិបាល

អភិបាលក្រុមប្រឹក្សាភិបាលដែលបានកាន់តំណែងចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍មុនរួមមាន៖

| | | |
|---|---|---|
| ឯកឧត្តម លូ គឹមឈន់ | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក | ប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ផាន់ ផល្លា | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

| | | |
|---|---|---|
| ឯកឧត្តម ស៊ុយ សាន | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ឯកឧត្តម សុខ សុភ័ក្ត្រ | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| លោក លូ លីខេង | តំណាងនិយោជិត ក.ស.ស | សមាជិក |
| លោក ហ៊ុន មុន្នីវណ្ណ | អភិបាលឯករាជ្យ | សមាជិក |
| លោក Hidetoshi Kume | អភិបាលមិនប្រតិបត្តិ | សមាជិក |

**ទ្រព្យសកម្ម**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ព្រឹត្តិការណ៍ណាមួយដែលនឹងបណ្តាលឲ្យតម្លៃសន្មតលើទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស មិនត្រឹមត្រូវជាសារវន្តនោះទេ។

**វិធីសាស្ត្រក្នុងការវាយតម្លៃ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ព្រឹត្តិការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឲ្យមានការអនុវត្តវិធីសាស្ត្រដែលមានស្រាប់ នៃការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬ មិនសមស្របជាសារវន្តណាមួយនោះទេ។

**បំណុលយថាភាព និងបំណុលផ្សេងៗទៀត**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក) មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ ក.ស.ស ដែលបានកើតឡើងចាប់តាំងពីចុងបញ្ចប់នៃកាលបរិច្ឆេទហិរញ្ញវត្ថុដោយសារការដាក់បញ្ចាំ សម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(ខ) មិនមានបំណុលយថាភាពណាមួយរបស់ ក.ស.ស ដែលបានកើតឡើងចាប់តាំងពីចុងបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុ លើកលែងតែក្នុងដំណើរការអាជីវកម្មធម្មតា។

ពុំមានបំណុលយថាភាព ឬ បំណុលផ្សេងៗរបស់ ក.ស.ស ដែលត្រូវបានទាមទារឲ្យសង ឬ អាចត្រូវបានទាមទារឲ្យសងក្នុងរយៈពេលពេល ១២ខែ បន្ទាប់ពីការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ដែលនឹងអាចមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ ក.ស.ស ក្នុងការបំពេញកាតព្វកិច្ច របស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

**បម្រែបម្រួលកាលៈទេសៈ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានកត់សម្គាល់ពីកាលៈទេសៈណាមួយដែលបាន កើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ដែលធ្វើឲ្យតួលេខ រាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គងជាសារវន្តណាមួយនោះទេ។

## **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

## **សមាសធាតុមិនប្រក្រតី**

តាមមតិយោបល់របស់គណៈគ្រប់គ្រង លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ ក.ស.ស ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយធាតុណាមួយ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ជាសារវន្ត និងព្រឹត្តិការណ៍មិនប្រក្រតីនោះទេ។ មិនមានសមាសធាតុ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ជាសារវន្ត និងជាលក្ខណៈមិនប្រក្រតីណាមួយកើតឡើងនៅក្នុងចន្លោះពេលរវាងចុងបញ្ចប់នៃការិយបរិច្ឆេទហិរញ្ញវត្ថុ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ (តាមមតិរបស់គណៈគ្រប់គ្រង) ដែលទំនងជាប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនៃរបាយការណ៍បានរៀបចំឡើងនោះទេ។

## **សវនករ**

ក្រុមហ៊ុនអឺនស្ទ័ អ៊ែន យ៉ាំង (ខេមបូឌា) គឺជាសវនកររបស់ក្រុមហ៊ុន។

## **របាយការណ៍ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs")។ ក្រុមប្រឹក្សាភិបាលត្រូតពិនិត្យមើលទៅលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរៀបចំដោយគណៈគ្រប់គ្រងដោយតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របដោយគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនោះឲ្យបានខ្ជាប់ខ្ជួន
- អនុលោមតាម ("CIFRSs") ប្រសិនបើមានគម្លាតនៃការអនុវត្តណាមួយ ដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត ត្រូវធានាថាគំលាតទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- រក្សាកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាពអាជីវកម្ម លើកលែងតែក្នុងករណីដែលសន្មតថា ក.ស.ស មិនអាចបន្តសកម្មភាពអាជីវកម្មនាពេលអនាគតដែលអាចព្យាករណ៍បាន
- បង្កើតគោលនយោបាយទូទៅសម្រាប់ ក.ស.ស អនុម័តរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងឡាយណាដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលប្រតិបត្តិការរបស់ ក.ស.ស ហើយនិងធានាថាប្រតិបត្តិការ និងលទ្ធផលទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យត្រូវបានរក្សាទុក និងលាតត្រដាង អំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស ជាមួយសុក្រឹត្យភាពឲ្យសមហេតុផលគ្រប់ពេលវេលា និងត្រូវធានាដែរថាបញ្ជីគណនេយ្យអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏ជាអ្នកទទួលខុសត្រូវផងដែរក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន ដោយត្រូវចាត់វិធានការឲ្យបានសមស្រប ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក.ស.ស បានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយនេះ ថាបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាម CIFRSs។

តំណាងឲ្យក្រុមប្រឹក្សាភិបាល

ឯកឧត្តម លូ គឹមឈន់
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ

លោក ពិត ប្រាកដ
នាយក គណនេយ្យ និងហិរញ្ញវត្ថុ

ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
#64 Norodom Boulevard corner Street 178
Sangkat Chey Chumneah, Khan Daun Penh
12206 Phnom Penh, Kingdom of Cambodia

Tel: +855 23 860 450/451
Fax: +855 23 217 805
ey.com

យោង៖ 61803762/66906078

# របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះ៖ ភាគទុនិក នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## *មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងរបាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ជាមួយនេះបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs")។

## *មូលដ្ឋានក្នុងការផ្តល់មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារទាំងនោះត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ *"ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ"* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានឯករាជ្យភាពពី ក.ស.ស ដោយយោងទៅតាមក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា រួមជាមួយតម្រូវការផ្នែកសីលធម៌ដែលពាក់ព័ន្ធនឹងការងារសវនកម្មចំពោះរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

## *បញ្ហាសវនកម្មសំខាន់*

បញ្ហាសវនកម្មសំខាន់យោងតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ គឺជាបញ្ហាដែលមានសារៈសំខាន់បំផុតនៅក្នុងការងារសវនកម្មរបស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហានេះត្រូវបានដោះស្រាយនៅក្នុងបរិបទនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល និងក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ ហើយយើងខ្ញុំមិនផ្តល់មតិយោបល់ដាច់ដោយឡែកលើបញ្ហាទាំងនេះទេ។

***បញ្ហាសវនកម្មសំខាន់*** (តពីទំព័រមុន)

*ការវាយតម្លៃលើកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

ដូចដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ១៧ ក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ដល់បុគ្គលិករបស់ខ្លួនអនុលោមតាមគោលនយោបាយចូលនិវត្តន៍របស់ក្រុមហ៊ុនដែលមានបំណុលប្រាក់សោធននិវត្តន៍ចំនួន ៧៦.០៣៨.៤១៦ ពាន់រៀល ដែលត្រូវជា ១៥% នៃបំណុលសរុបរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងមានបរិបទសំខាន់សម្រាប់ស្ថានភាពហិរញ្ញវត្ថុទាំងមូលរបស់ក្រុមហ៊ុន។ គណៈគ្រប់គ្រងបានវាយតម្លៃកាតព្វកិច្ចដោយផ្អែកលើទិន្នន័យប្រវត្តិសាស្ត្រ និងប្រជាសាស្ត្រ និងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន។ គណៈគ្រប់គ្រងក៏បានជួលអ្នកជំនាញគណនាពីខាងក្រៅ (external actuary) ដើម្បីធ្វើការគណនាដ៏មានភាពស្មុគស្មាញនេះ។

ការវាយតម្លៃលើកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ តម្រូវឲ្យមានការវិនិច្ឆ័យកម្រិតខ្ពស់ និងជំនាញបច្ចេកទេស នៅក្នុងការជ្រើសរើសការសន្មតដែលសមស្រប។ ការសន្មតសំខាន់ៗ ដែលរួមកំណើនប្រាក់បៀវត្សរ៍ អតិផរណា អត្រាអប្បហារ និងអត្រាមរណៈភាព អាចមានផលប៉ះពាល់ជាសារវន្តលើការគណនាបំណុលនេះ។

នីតិវិធីសវនកម្មរបស់យើងខ្ញុំទៅលើការប៉ាន់ស្មានបំណុលរបស់គណៈគ្រប់គ្រង រួមមាន៖

- ស្វែងយល់អំពីដំណើរគ្រប់គ្រងលើការវាយតម្លៃ រួមទាំងការពឹងផ្អែកលើអ្នកជំនាញគណនាពីខាងក្រៅក្នុងការអនុវត្តនៃការវាយតម្លៃ (actuarial valuation) លើតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍។
- ដោយផ្អែកលើមូលដ្ឋានគំរូ (on a sample basis) យើងធ្វើតេស្តលើភាពពេញលេញ និងភាពត្រឹមត្រូវនៃទិន្នន័យបុគ្គលិកដែលត្រូវបានប្រើនៅក្នុងការគណនាកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍។
- វាយតម្លៃលើឯករាជ្យភាព ភាពមិនលម្អៀង និងសមត្ថភាពរបស់អ្នកជំនាញគណនាពីខាងក្រៅរបស់ក្រុមហ៊ុន។
- ដោយមានជំនួយពីអ្នកជំនាញ យើងខ្ញុំបានធ្វើការវាយតម្លៃលើការប្រើប្រាស់ការសន្មតសម្រាប់គណនារបស់គណៈគ្រប់គ្រង និងវិធីសាស្ត្រវាយតម្លៃទាក់ទងនឹងកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍។
- បានត្រួតពិនិត្យរបាយការណ៍ការគណនាដើម្បីបញ្ជាក់ពីភាពស្របគ្នានៃទិន្នន័យដែលបានប្រើក្នុងការវាយតម្លៃ។

***បញ្ហាផ្សេងទៀត***

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិយោបល់មិនមានបញ្ហាលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២។

### ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងទៀតដែលយើងខ្ញុំទទួលបាននាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមាន របាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ មិនគ្របដណ្តប់លើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនធ្វើ ហើយនិងមិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយលើព័ត៌មានផ្សេងៗដែរ។

ទាក់ទងនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺអានព័ត៌មានផ្សេងៗនេះ ហើយធ្វើការពិចារណាថាតើព័ត៌មានផ្សេងៗនេះមានភាពខុសគ្នាជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬ ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការងារសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ (ដោយផ្អែកលើការងារដែលបានអនុវត្ត) យើងខ្ញុំត្រូវតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាម CIFRSs ហើយនិងទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពបន្តនិរន្តរភាពអាជីវកម្មរបស់ ក.ស.ស និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ ក.ស.ស លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការរបស់ ក.ស.ស ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ចមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ ក.ស.ស។

### ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុ ទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា ការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមទៅតាម CISAs តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្ត ដែលបានកើតឡើងនោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាមានភាពជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

## *ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* (តពីទំព័រមុន)

ជាផ្នែកមួយនៃការងារសវនកម្ម អនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យ នៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ មានកម្រិតខ្ពស់ជាងហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ ក.ស.ស ទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមានភាពមិនប្រាកដប្រជា ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌទាំងឡាយណាដែលនាំឲ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ ក.ស.ស ឬ ទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍របស់សវនករលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នោះពុំមានលក្ខណៈគ្រប់គ្រាន់ទេ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺ ពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬ លក្ខខណ្ឌនាពេលអនាគត ក៏អាចបង្កឲ្យ ក.ស.ស មិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃលើការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

***ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកនៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ឡុន ស៊ុនរតនា

ដៃគូសវនករ

**អឹនស្ទ៍ អែន យ៉ាំង (ខេមបូឌា)**

ក្រុមហ៊ុនគណនេយ្យករជំនាញ

សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល (បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* |
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យ និងបរិក្ខារ | ៦ | ៩៦៣.៧១២.៧៨១ | ៩៦៦.១៦៥.៨៤៤ |
| ទ្រព្យវិនិយោគ | ៧ | ២៤៨.២៩៦.៧០៥ | ២៥៣.១៩៥.៦៩៩ |
| ទ្រព្យសកម្មអរូបី | ៨ | ៤.០១៩.០៩១ | ៤.៩៣៦.៣៣២ |
| | | **១.២១៦.០២៨.៥៧៧** | **១.២២៤.២៩៧.៨៧៥** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៩ | ២៩.០៨៣.៣៦៤ | ២៧.២២៥.០០៦ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ១០ | ៣៧.៩៥៦.៨៦២ | ៣៥.៦៥៩.៩១១ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១១ | ១០២.៩០៨.២៦៤ | ១០១.៣០៦.៦៨១ |
| សាច់ប្រាក់ | ១២ | ២៣.៥៨៦.៣៦៨ | ២២.៤៦៨.៩២៩ |
| | | **១៩៣.៥៣៤.៨៥៨** | **១៨៦.៦៦០.៥២៧** |
| ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | ១៣ | ១៦.៥៨២.១៦១ | ១៦.១៩១.២៦៨ |
| | | **២១០.១១៧.០១៩** | **២០២.៨៥១.៧៩៥** |
| **ទ្រព្យសកម្មសរុប** | | **១.៤២៦.១៤៥.៥៩៦** | **១.៤២៧.១៤៩.៦៧០** |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន | ១៤ | ៤៥០.៣០២.៨២៨ | ៤៥០.៣០២.៨២៨ |
| បុព្វលាភភាគហ៊ុន | ១៤ | ៦៧.៧១៥.២៣៥ | ៦៧.៧១៥.២៣៥ |
| ទុនបម្រុងផ្សេងៗ | ១៥ | ៤១.០៩០.៥៧២ | ៣១.៧១៩.៨៣២ |
| ប្រាក់ចំណេញរក្សាទុក | | ៣០៤.៦៩២.៣១១ | ២៣៤.១៥៦.២៦៤ |
| **មូលធនសរុប** | | **៨៦៣.៨០០.៩៤៦** | **៧៨៣.៨៩៤.១៥៩** |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៦ | ៣៦៤.៦៧៧.០៨៧ | ៤៣៥.០២៥.៤២៥ |
| ប្រាក់តម្កល់ពីភតិក: | | ១.០២៩.២៥០ | ១.០១៨.៥០០ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៧ | ៦៩.៨២៤.០៥៣ | ៨៣.៦៤៦.៥៥៩ |
| កាតព្វកិច្ចប្រាក់បំណាច់អតីតភាពការងារ | | ១.៣១៦.៧១៦ | ១.០៨០.១៤៩ |
| ចំណូលពន្យារ | ១៨ | ១២.២០៣.២០០ | ៥.៣១០.៤៥៩ |
| បំណុលពន្ធពន្យារ | ២៦ | ៣៣.០០៣.៣៥៤ | ២៩.៤១៩.០១៤ |
| | | **៤៨២.០៥៣.៦៦០** | **៥៥៥.៥០០.១០៦** |

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** (តពីទំព័រមុន)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល (បានធ្វើចំណាត់ថ្នាក់ឡើងវិញ កំណត់សម្គាល់លេខ ៣២)* |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ១៩ | ៣៥.០៦៦.០៧៣ | ៤៣.១៨៩.៦៥៩ |
| កម្ចី | ១៦ | ៣០.៨៣៣.៨៩០ | ៣៣.៩៦១.៥៧២ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៧ | ៦.២១៤.៣៦៣ | ៤.៥៣៨.៤២៥ |
| កាតព្វកិច្ចប្រាក់បំណាច់អតីតភាពការងារ | | ១២៧.៧៣៩ | - |
| ចំណូលពន្យារ | ១៨ | ១៧១.៦៧៩ | ១៣៨.៤៤២ |
| បំណុលពន្ធលើប្រាក់ចំណូល | ២៦ | ៨.២៧៧.៦៤៦ | ៥.៩៣៥.៣០៧ |
| | | **៨០.៦៩០.៩៩០** | **៨៧.៧៥៥.៤០៥** |
| **បំណុលសរុប** | | **៥៦២.៣៨៤.៦៥០** | **៦៤៣.២៥៥.៥១១** |
| **មូលធន និងបំណុលសរុប** | | **១.៤២៦.១៩៥.៥៩៦** | **១.៤២៧.១៩៩.៦៧០** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* |
| **ចំណូល** | | | |
| ចំណូលពីកិច្ចសន្យាជាមួយអតិថិជន | ២០ | ៣៩១.៣៦៨.៨៧៩ | ៣៩០.១៥៣.៣៦០ |
| ចំណូលពីការជួល | ៧ | ២.៣៧៤.៦៩៦ | ២.១៩៥.៨៦៩ |
| | | **៣៩៣.៧៤៣.៥៧៥** | **៣៩២.៣៤៩.២២៩** |
| **ចំណាយ** | | | |
| សម្ភារៈផ្គត់ផ្គង់ការប្រើប្រាស់ | ២១ | (១០៦.៣៦៤.៨៦១) | (៩៣.៧៣៩.២៧៦) |
| ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២២ | (១០៥.៦៧២.០៩៧) | (១០៤.៣៦៦.៩៧៩) |
| ចំណាយរំលស់ទ្រព្យរូបី និងអរូបី | ២៣ | (៤៥.៦៩៧.៧៧៨) | (៣៩.៩២២.៦៧៧) |
| ការជួសជុល និងថែទាំ | | (២.២៨៨.១១៦) | (៤.៨៥៧.០៥៣) |
| ចំណាយផ្សេងៗ | ២៤ | (២៧.១២៦.៨៩៩) | (២០.៣៤៧.៤០៦) |
| ចំណេញ (ខាត) ផ្សេងៗ - សុទ្ធ | | ៤៧៩.៥៨៥ | (២៧៣.៣០០) |
| | | **(២៨៦.៧០០.១៣៦)** | **(២៦៣.៥០៦.៦៣១)** |
| **ចំណេញប្រតិបត្តិការ** | | **៥៧.០៤៣.៤០៩** | **៧៨.៨៤២.៥៩៨** |
| ចំណូល ហិរញ្ញវត្ថុ - សុទ្ធ | ២៥ | ៤០.៨៥៣.៦៧១ | ៣២.២០៣.០៣៩ |
| **ចំណេញមុនគិតពន្ធលើប្រាក់ចំណូល** | | **៩៧.៨៩៧.០៨០** | **១១១.០៤៥.៦៣៧** |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៦ | (១៣.៧៤១.៨៦៥) | (១៧.៣៣៨.២៤៧) |
| **ចំណេញក្នុងគ្រា** | | **៨៤.១៥៥.២១៥** | **៩៣.៧០៧.៣៩០** |
| **ចំណេញក្នុងគ្រារបស់ភាគហ៊ុនិក** | | **៨៤.១៥៥.២១៥** | **៩៣.៧០៧.៣៩០** |
| ចំណេញពីការវាស់វែងឡើងវិញលើការកំណត់ | | | |
| កាតព្វកិច្ចអត្ថប្រយោជន៍ - ក្រោយគិតពន្ធ | ១៧, ២៦ | ១១.៨៥៨.៨៤០ | - |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រាក្រោយគិតពន្ធរបស់ភាគហ៊ុនិក** | | **៩៦.០១៤.០៥៥** | **៩៣.៧០៧.៣៩០** |

ប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិករបស់ ក.ស.ស សម្រាប់ការិយបរិច្ឆេទបញ្ចប់មានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| មូលដ្ឋានប្រាក់ចំណេញក្នុងមួយភាគហ៊ុន (រៀល) | ២៧ | **៩៨១,១៥** | **១.០៩២,៥២** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *ដើមទុនដែលបានបោះផ្សាយ* | *បុព្វលាភភាគហ៊ុន* | *ទុនបម្រុង* | *ប្រាក់ចំណេញរក្សាទុក* | *សរុប* |
|---|---|---|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | | ៤៥០.៣០២.៨២៨ | ៦៧.៧១៥.២៣៥ | ៣១.៧១៩.៨៣២ | ២៣៤.១៥៦.២៦៤ | ៧៨៣.៨៩៤.១៥៩ |
| ប្រាក់ចំណេញក្នុងគ្រា | | - | - | - | ៨៤.១៥៥.២១៥ | ៨៤.១៥៥.២១៥ |
| ចំណេញពីការវាស់វែងឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍ | ១៧, ២៦ | - | - | - | ១១.៨៥៨.៨៤០ | ១១.៨៥៨.៨៤០ |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រា** | | **-** | **-** | **-** | **៩៦.០១៤.០៥៥** | **៩៦.០១៤.០៥៥** |
| ផ្ទេរទៅទុនបម្រុង | ១៥ | - | - | ៩.៣៧០.៧៤០ | (៩.៣៧០.៧៤០) | - |
| ភាគលាភដែលបានប្រកាស | ៣០.២ | - | - | - | (១៦.១០៧.២៦៨) | (១៦.១០៧.២៦៨) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៤១.០៩០.៥៧២** | **៣០៤.៦៩២.៣១១** | **៨៦៣.៨០០.៩៤៦** |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | | ៤៥០.៣០២.៨២៨ | ៦៧.៧១៥.២៣៥ | ២៩.០៥៩.០៧២ | ១៥៥.២៨៤.២៨៣ | ៧០២.៣៦១.៤១៨ |
| ប្រាក់ចំណេញក្នុងគ្រា | | - | - | - | ៩៣.៧០៧.៣៩០ | ៩៣.៧០៧.៣៩០ |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រា** | | **-** | **-** | **-** | **៩៣.៧០៧.៣៩០** | **៩៣.៧០៧.៣៩០** |
| ផ្ទេរទៅទុនបម្រុង | ១៥ | - | - | ២.៦៦០.៧៦០ | (២.៦៦០.៧៦០) | - |
| ភាគលាភដែលបានប្រកាស | ៣០.២ | - | - | - | (១២.១៧៤.៦៤៩) | (១២.១៧៤.៦៤៩) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៣១.៧១៩.៨៣២** | **២៣៤.១៥៦.២៦៤** | **៧៨៣.៨៩៤.១៥៩** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* |
| **សកម្មភាពប្រតិបត្តិការ** | | | |
| ប្រាក់ចំណេញមុនគិតពន្ធ | | ៩៧.៨៩៧.០៨០ | ១១១.០៥៥.៦៣៧ |
| *និយ័តកម្ម៖* | | | |
| ចំណូលហិរញ្ញវត្ថុ - សុទ្ធ | ២៥ | (៤០.៨៥៣.៦៧១) | (៣២.២០៣.០៣៩) |
| ចំណាយរំលស់ទ្រព្យរូបី និងទ្រព្យអរូបី | ២៣ | ៤៥.៦៩៧.៧៤៨ | ៣៩.៩២២.៦៧៧ |
| បម្រែបម្រួលកាតព្វកិច្ចប្រាក់សោធននិវត្តន៍ | | ២.៦៨០.៩៨១ | ១.៦៩៩.០១៧ |
| បម្រែបម្រួលប្រាក់បំណាច់អតីតភាពការងារ | | ៣៦៤,៣០៦ | (៣.០២៩.០២៩) |
| រំលស់អត្ថប្រយោជន៍ឥណទានបុគ្គលិក | | - | ៣២៧.៧២៨ |
| *បម្រែបម្រួលដើមទុន៖* | | | |
| សន្និធិ | | (១.៨៥៨.៣៥៨) | (៣.៣៧១.៩៨៤) |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | | (១.៩៩៩.០៨៩) | (៦.០៨៧.៨៥៣) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | | (១០.៣៤៣.៦៥០) | ២២.១២៦.០៣៧ |
| ចំណូលពន្យារ | | ៦.៩២៩.៩៧៨ | (៩៤.៧២៧) |
| | | **៩៨.៥១៥.៣៣៥** | **១៣០.៣៣៤.៤៦៤** |
| ពន្ធលើប្រាក់ចំណូលបានបង់ | ២៦ | (១០.៧៧៩.៨៩៥) | (៨.១៤១.៩៣៨) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **៨៧.៧៣៥.៤៤០** | **១២២.១៩២.៥២៦** |
| **សកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ៦ | (៣៤.៣៨២.៨២៦) | (៨៥.៣៣១.២៣៨) |
| ការទិញទ្រព្យវិនិយោគ | ៧ | (១.២៧៧.៦៤៥) | (១.៨៧៤.១៧០) |
| ការទិញទ្រព្យអរូបី | ៨ | (២៥១.២៩៨) | (៣៦៦.៩៣១) |
| ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | | ៥២៦.៥៣៨ | - |
| ប្រាក់ទទួលបានពីប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | | ៩៩.៦៣៨.៩៤៤ | ១៥.៤៤១.៩៧០ |
| ការដាក់ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | | (១០០.៨៥២.៥៩០) | (១២.១៦៥.០០០) |
| ការប្រាក់បានទទួល | | ៣.៨៧០.៤៣៣ | ៣.៨៦៧.៣២៤ |
| ប្រាក់សំណងទទួលបានពីឥណទានបុគ្គលិក | | - | ១.២៤៣.៣៦៣ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(៣២.៧២៨.៤៤៤)** | **(៧៩.១៨៤.៦៨២)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | ១.៧៩៦.០៨២ | ១.១៣៧.៥៣២ |
| ការសងប្រាក់កម្ចី | | (២៨.៩៤០.៤៥២) | (៣២.៤៤២.៥១១) |
| ភាគលាភបានបង់ | ៣០.២ | (១៦.១០៧.២៦៨) | (៨.៦៤១.៥២៧) |
| ការប្រាក់បានបង់ | | (១០.៦៣៧.៩១៩) | (១១.៣៧៣.៨៨៤) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(៥៣.៨៨៩.៥៥៧)** | **(៥១.៣១៩.៩៩០)** |
| **កំណើន (តំហាយ) សុទ្ធលើសាច់ប្រាក់** | | **១.១១៧.៤៣៩** | **(៨.២៧២.១៤៦)** |
| សាច់ប្រាក់ដើមគ្រា | | ២២.៤៦៨.៩២៩ | ៣០.៧៤១.០៧៥ |
| **សាច់ប្រាក់ចុងគ្រា** | ១២ | **២៣.៥៨៦.៣៦៨** | **២២.៤៦៨.៩២៩** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

### ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការត្រួតពិនិត្យលើផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលរបស់ខ្លួននៅក្នុងខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិបុគ្គលដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពទូទៅឲ្យក្រុមហ៊ុនជាស្ថាប័នស្វយ័តសាធារណៈ។

ក.ស.ស បានចុះបញ្ជីជាសហគ្រាសសាធារណៈគ្រប់គ្រងដោយរដ្ឋ នៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៤ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផមក") នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។

បច្ចុប្បន្ន ក.ស.ស គឺជាកំពង់ផែសមុទ្រអន្តរជាតិ និងជាកំពង់ផែសមុទ្រជ្រៅពាណិជ្ជកម្មតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមទៅតាមអនុក្រឹត្យស្តីពី បេសកកម្មរបស់ ក.ស.ស គឺផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗ ដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រដូចខាងក្រោម៖

- កណ្តាធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា ធ្វើបែបបទនាវា ចេញ ចូល
- លើកដាក់ ផ្ទេរចេញ និងដឹកជញ្ជូនទំនិញ
- រក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរបស់ ក.ស.ស ដែលមានស្រាប់
- ទទួលខុសត្រូវ លើសុខមាលភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង និង
- ប្តេជ្ញាធ្វើការគ្រប់គ្រង និងចាត់ចែងសកម្មភាពប្រតិបត្តិការឲ្យមានប្រសិទ្ធភាព និងមានការរីកចម្រើន។

ក.ស.ស ក៏មានប្រតិបត្តិការនៅតំបន់សេដ្ឋកិច្ចពិសេស ប្រតិបត្តិការភតិសន្យាជាភតិបតី។

ក្នុងនាមជាស្ថាប័នស្វយ័តសាធារណៈ ក.ស.ស ទទួលអំណាច និងកាតព្វកិច្ចទាំងឡាយពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុទាំងនេះ។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានអាសយដ្ឋាននៅតិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានអនុម័តឲ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

## ២. មូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំអនុលោមតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs") ដែលបានចេញផ្សាយដោយ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀល ត្រូវបានរៀបចំឡើងដោយមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ។ ចំនួនទឹកប្រាក់ត្រូវបានបង្គត់ជាខ្ទង់ពាន់ លុះត្រាតែមានការ បង្ហាញផ្សេងទៀត។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងគ្នា ហើយចំនួនសុទ្ធបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលមានសិទ្ធិដែលអាចអនុវត្តបានស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានទទួលស្គាល់ ហើយមានចេតនាដើម្បីទូទាត់តាមមូលដ្ឋានសុទ្ធ ឬ ដើម្បីទទួលស្គាល់ទ្រព្យសកម្ម ហើយធ្វើការទូទាត់បំណុលក្នុងពេលជាមួយគ្នា។

*ឆ្នាំសារពើពន្ធ*

ឆ្នាំសារពើពន្ធរបស់ ក.ស.ស ចាប់ផ្តើមនៅថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

*ការប្តូររូបិយប័ណ្ណបរទេស*

*រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបង្ហាញ*

ធាតុទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណ នៃស្ថានភាពសេដ្ឋកិច្ចចម្បង ដែល ក.ស.ស ធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណមុខងារ")។ ក.ស.ស រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល (រៀល) ជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណបង្ហាញ។

*ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារ តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការបកប្រែអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទ នៃទ្រព្យសកម្មសន្ទនីយភាព និងបំណុលជាសាច់ប្រាក់ដែលជារូបិយប័ណ្ណផ្សេងក្រៅពីប្រាក់រៀល ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ខាត។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងប្រាក់ចំណេញ ឬ ខាត នៅក្នុង "ចំណូល និងចំណាយហិរញ្ញវត្ថុ"។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

### *៣.១ ស្តង់ដារថ្មី និងវិសោធនកម្ម និងការបកស្រាយ*

គោលនយោបាយគណនេយ្យដែលត្រូវបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គឺស្របជាមួយនឹងអ្វីដែលបានអនុវត្តតាមឆ្នាំមុន លើកលែងតែការអនុម័ត (ដែលអាចអនុវត្តបាន) នៃវិសោធនកម្មចំពោះ CIFRSs ដែលនឹងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។ ក្រុមហ៊ុនមិនទាន់បានអនុម័តស្តង់ដារ ឬ វិសោធនកម្មផ្សេងទៀតដែលបានចេញផ្សាយ តែមិនទាន់មានប្រសិទ្ធភាពនោះទេ។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១ ស្តង់ដារថ្មី និងវិសោធនកម្ម និងការបកស្រាយ* (តពីទំព័រមុន)

វិសោធនកម្មមួយចំនួនដូចដែលបានសង្ខេបខាងក្រោមអនុវត្តជាលើកដំបូងក្នុងឆ្នាំ២០២២ ប៉ុន្តែមិនមានឥទ្ធិពលលើស្ថានភាពហិរញ្ញវត្ថុ និងដំណើរការរបស់ ក.ស.ស ទេ។

- វិសោធនកម្មចំពោះ CIFRS ៩ *ឧបករណ៍ហិរញ្ញវត្ថុ* - ថ្លៃសេវា "១០ ភាគរយ"សម្រាប់ការមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុ
- វិសោធនកម្មចំពោះ CIFRS ៣៖ *ការរួមបញ្ចូលអាជីវកម្ម*- យោងទៅក្របខ័ណ្ឌគោលគំនិត
- វិសោធនកម្មចំពោះ CIAS ១៦៖ *ទ្រព្យ រោងចក្រ និងបរិក្ខារ*- ប្រាក់ទទួលបានមុនប្រើប្រាស់តាមគោលបំណង
- វិសោធនកម្មចំពោះ CIAS ៣៧៖ *សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព* - កិច្ចសន្យាធ្ងន់ធ្ងរ - ចំណាយលើការបំពេញកិច្ចសន្យា
- វិសោធនកម្មចំពោះ CIFRS ១៖ *ការអនុម័តលើកដំបូងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា* - ក្រុមហ៊ុនបុត្រសម្ព័ន្ធជាអ្នកអនុម័តលើកដំបូង
- វិសោធនកម្មចំពោះ CIAS ៤១៖ *កសិកម្ម* - ការវាស់វែងពន្ធដារក្នុងតម្លៃសមស្រប

### *៣.២ ស្តង់ដារ និងការបកស្រាយដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព*

ស្តង់ដារ និងវិសោធនកម្មដែលបានចេញផ្សាយ (ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព) រហូតដល់ថ្ងៃចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានលាតត្រដាងដូចខាងក្រោម។ ស្តង់ដារ និងការបកស្រាយទៅលើ CIFRSs ទាំងនេះដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ត្រូវបានរំពឹងនឹងមិនមានផលប៉ះពាល់ជាសារវន្តទៅលើស្ថានភាពហិរញ្ញវត្ថុ ឬ លទ្ធផលរបស់ក្រុមហ៊ុនទេ។

មានប្រសិទ្ធភាពនៅដើម ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

(i) CIFRS ១៧ *កិច្ចសន្យាធានារ៉ាប់រង*

(ii) វិសោធនកម្មចំពោះ CIAS ៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរនៃការប៉ាន់ស្មានគណនេយ្យ និងកំហុសគណនេយ្យ* - និយមន័យនៃការប៉ាន់ស្មានគណនេយ្យ

(iii) វិសោធនកម្មចំពោះ CIAS ១ ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្ត CIFRS របាយការណ៍លេខ២ *ការប្រើប្រាស់ការវិនិច្ឆ័យជាសារវន្ត*- ការបង្ហាញគោលនយោបាយគណនេយ្យ។

(iv) វិសោធនកម្មចំពោះ CIAS ១២ *ពន្ធលើប្រាក់ចំណូល* ពន្ធពន្យារទាក់ទងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការមួយ

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៣.២ *ស្តង់ដារ និងការបកស្រាយដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព* (តពីទំព័រមុន)

មានប្រសិទ្ធភាពនៅដើម ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤

(i) វិសោធនកម្មចំពោះ CIFRS ១៦ *ភតិសន្យា* - បំណុលភតិសន្យា ក្នុងការលក់ និងភតិសន្យាត្រឡប់មកវិញ

(ii) វិសោធនកម្មចំពោះ CIAS ១ *ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ* - ការចាត់ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី និងរយៈពេលវែង

### ៣.៣ *រូបិយប័ណ្ណមុខងារ*

ក្រុមហ៊ុនរក្សាកំណត់ត្រាគណនេយ្យរបស់ខ្លួន និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដើម្បីឆ្លុះបញ្ចាំងពីប្រតិបត្តិការ ព្រឹត្តិការណ៍ និងលក្ខខណ្ឌដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន។

ប្រាក់ចំណូលរបស់ក្រុមហ៊ុនត្រូវបានចេញវិក្កយបត្រ និងប្រមូលជារូបិយប័ណ្ណគោលជាប្រាក់រៀល។ ថ្លៃដើមនៃការលក់ ការចំណាយទូទៅ និងរដ្ឋបាល ព្រមទាំងចំណូល និងចំណាយផ្សេងទៀតត្រូវបានទិញ និងបង់ជាប្រាក់រៀលផងដែរ។ ផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃកាលៈទេសៈដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន ប្រាក់រៀលគឺជារូបិយប័ណ្ណដែលក្រុមហ៊ុនបានទទួល និងចំណាយយ៉ាងច្រើន នៅក្នុងប្រទេសដែលខ្លួនធ្វើប្រតិបត្តិការ។

### ៣.៤ *ទ្រព្យ និងបរិក្ខារ*

ទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយដោយ ផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យ និងបរិក្ខារទាំងអស់នោះ។

សំណង់កំពុងសាងសង់ ត្រូវបានកត់ត្រាតាមថ្លៃដើម ដកអ៊ីមភែរមិនបង្គរ (បើសិនជាមាន)។

ចំណាយបន្តបន្ទាប់ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ឬ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែក (តាមការសមស្រប) នៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូល ក.ស.ស ហើយចំណាយទាំងនោះអាចវាស់វែងគួរឲ្យជឿជាក់បាន។ តម្លៃយោងនៃ ផ្នែកដែលត្រូវបានជំនួសឡើងវិញត្រូវបានឈប់កត់ត្រា។ រាល់ចំណាយលើការជួសជុល និងថែទាំផ្សេងៗត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬ ខាតក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលប្រតិបត្តិការនោះបានកើតឡើង។

ដីធ្លីមិនត្រូវបានធ្វើការរំលស់ទេ។ សំណង់កំពុងសាងសង់មិនត្រូវបានធ្វើរំលស់ទេរហូតដល់ទ្រព្យ និងបរិក្ខារពាក់ព័ន្ធមានភាពរួចរាល់សម្រាប់ការប្រើប្រាស់។ រំលស់លើទ្រព្យសកម្មផ្សេងៗត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីបែងចែក ថ្លៃដើមនៃទ្រព្យសកម្មដកតម្លៃសំណល់ របស់ទ្រព្យសកម្មលើអាយុកាលប្រើប្រាស់បានប៉ាន់ស្មានដូចខាងក្រោម៖

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.៤ ទ្រព្យ និងបរិក្ខារ* (តពីទំព័រមុន)

| | *ឆ្នាំ* |
|---|---|
| ការកែលម្អដីធ្លី | ៧ - ៥០ |
| អគារ | ៧ - ៥០ |
| បរិក្ខារបច្ចេកទេស | ៥ - ៣០ |
| គ្រឿងសង្ហារិម និងបរិក្ខារបំពាក់ | ៣ - ១០ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៣ - ៥ |
| យានយន្ត | ៥ - ១៥ |
| បរិក្ខារកំពង់ផែសមុទ្រ | ២០ - ៣០ |
| ប៉ាឡែត | ១០ |

តម្លៃកាកសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ (និងកែតម្រូវ តាមភាពសមស្រប) នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។

ចំណេញ និងខាតពីការលក់ទ្រព្យ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀប សាច់ប្រាក់លក់បានជាមួយនឹងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬ ខាត។

### *៣.៥ ទ្រព្យវិនិយោគ*

ទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់សម្រាប់ការជួលរយៈពេលវែង ឬ សម្រាប់ការកើនតម្លៃដើមទុន ឬ ទាំងពីរយ៉ាង និងមិនត្រូវបានប្រតិបត្តិដោយ ក.ស.ស ត្រូវបានចាត់ថ្នាក់ជាទ្រព្យវិនិយោគ។ ទ្រព្យវិនិយោគ ក៏រួមបញ្ចូលនូវទ្រព្យសម្បត្តិដែលកំពុងសាងសង់ ដើម្បីអភិវឌ្ឍសម្រាប់ការប្រើប្រាស់ពេលអនាគតឲ្យជាទ្រព្យវិនិយោគ។ ទ្រព្យវិនិយោគត្រូវបានកត់ត្រាជាដំបូងតាមថ្លៃដើមដករំលស់បង្គរ និងអ៊ីមភែរមិន។ ក.ស.ស ប្រើប្រាស់គំរូថ្លៃដើម និងគណនីសម្រាប់ទ្រព្យវិនិយោគដោយអនុលោមទៅតាម CIAS ១៦ *ទ្រព្យ និងបរិក្ខារ*។

ទ្រព្យវិនិយោគត្រូវបានផ្ទេរទៅជាសន្និធិ តែនៅពេលដែលមានការផ្លាស់ប្តូរក្នុងការប្រើប្រាស់ដោយមានភស្តុតាងបង្ហាញពីការចាប់ផ្តើមការអភិវឌ្ឍ ក្នុងទស្សនវិស័យដើម្បីលក់។ នៅពេលដែល ក.ស.ស សម្រេចលក់ទ្រព្យវិនិយោគមួយចេញដោយមិនមានការអភិវឌ្ឍ ក្រុមហ៊ុនបន្តចាត់ទុក ទ្រព្យសម្បត្តិនោះជាទ្រព្យវិនិយោគរហូតដល់ពេលឈប់ទទួលស្គាល់ និងត្រូវបានលុបចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយមិនចាត់ទុកវាជាសន្និធិទេ។ ប្រសិនបើទ្រព្យវិនិយោគ ត្រូវបាន អភិវឌ្ឍឡើងវិញដើម្បីប្រើប្រាស់បន្តទៅទៀតជាទ្រព្យវិនិយោគនោះ ទ្រព្យសម្បត្តិនោះ នៅរក្សាទុកជាទ្រព្យវិនិយោគដដែល ហើយមិនត្រូវបានចាត់ថ្នាក់ឡើងវិញជាទ្រព្យសម្បត្តិ ដែល កាន់កាប់ដោយម្ចាស់ក្នុងអំឡុងពេលការអភិវឌ្ឍឡើងវិញទេ។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៣.៥ *ទ្រព្យវិនិយោគ* (តពីទំព័រមុន)

នៅពេលលក់ទ្រព្យវិនិយោគមួយ ឬ នៅពេលដែលទ្រព្យវិនិយោគណាមួយ ត្រូវបានដកចេញពីការប្រើប្រាស់ជាអចិន្ត្រៃយ៍ និងមិនមានការរំពឹងថានឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការលក់ទ្រព្យវិនិយោគនោះនឹងត្រូវឈប់ទទួលស្គាល់ (លុបចេញពីតារាងតុល្យការ)។ ចំនួនលម្អៀងរវាងសាច់ប្រាក់សុទ្ធដែលបានពីការលក់ និងតម្លៃយោង ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ខាត ក្នុងការិយបរិច្ឆេទឈប់ប្រើ ឬ ការិយបរិច្ឆេទលក់។

ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ ចំណែកការកែលម្អដីធ្លី និងអគារត្រូវបានធ្វើរំលស់ដោយប្រើវិធីសាស្ត្ររំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានក្នុងរយៈពេលពី ១០ឆ្នាំ ទៅ ៥០ឆ្នាំ។

### ៣.៦ *ទ្រព្យសកម្មអរូបី*

ទ្រព្យសកម្មអរូបីរួមមានប្រព័ន្ធគណនេយ្យ និងប្រព័ន្ធប្រតិបត្តិការកំពង់ផែ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងអ៊ឹមភែរមិន (ប្រសិនបើមាន)។ ទ្រព្យសកម្មអរូបីទាំងនេះត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញ និងយកកម្មវិធីនោះមកប្រើប្រាស់។ ក.ស.ស បានធ្វើរំលស់ទ្រព្យសកម្មអរូបីដែលនៅមានអាយុកាលប្រើប្រាស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមរយៈពេលដូចខាងក្រោម៖

| | *ឆ្នាំ* |
|---|---|
| កម្មវិធីគណនេយ្យ | ១០ |
| ប្រព័ន្ធប្រតិបត្តិការកំពង់ផែ | ១០ |

### ៣.៧ *អ៊ឹមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនាកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានសូចនាករណ៍ណាមួយនៃអ៊ឹមភែរមិនឬទេ។ ការខាតបង់លើអ៊ឹមភែរមិន ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម លើសពីតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន។ តម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងរវាង តម្លៃសមស្របនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃអាចប្រើប្រាស់បានរបស់ទ្រព្យសកម្មនោះ។ តាមគោលបំណងនៃការវាយតម្លៃអ៊ឹមភែរមិន ទ្រព្យសកម្មត្រូវបានបែងចែក ជាក្រុមតូចៗបំផុតដែលបង្កើតលំហូរចូលសាច់ប្រាក់ដោយឯករាជ្យ (ឧបករណ៍បង្កើតសាច់ប្រាក់)។ ខាតអ៊ឹមភែរមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

បញ្រ្ចាស់នៃខាតលើអ៊ឹមភែរមិន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ ត្រឹមកម្រិតមួយដែលតម្លៃយោងនៃទ្រព្យសកម្មត្រូវបានកំណត់ពីមុន (តម្លៃសុទ្ធក្រោយការរំលស់ទ្រព្យរូបី និងអរូបី) មិនដែលមានអ៊ឹមភែរមិនត្រូវបានទទួលស្គាល់លើទ្រព្យសកម្មក្នុងឆ្នាំមុន។ បន្ទាប់ពីបញ្រ្ចាស់បែបនេះ រំលស់ទ្រព្យរូបី និងអរូបី ត្រូវបានកែតម្រូវក្នុងពេលអនាគត ដើម្បីបែងចែកតម្លៃយោងរបស់ទ្រព្យសកម្មដែលបានកែសម្រួល (ដកតម្លៃកាកសំណល់ទាំងអស់) ដោយផ្អែកលើមូលដ្ឋានជាប្រព័ន្ធលើអាយុកាលនៅសល់។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.៨ សន្និធិ*

សន្និធិត្រូវបានកត់ត្រាតាមតម្លៃមួយណាដែលទាបជាងរវាងថ្លៃដើម (ថ្លៃដើមក្នុងការទិញ និងថ្លៃដើមផ្សេងៗ ទៀតក្នុងការនាំយកសន្និធិនោះមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា) និងតម្លៃពិតជាក់ស្តែង។ តម្លៃពិតជាក់ស្តែងសុទ្ធ គឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកការប៉ាន់ស្មានថ្លៃដើមដើម្បីបញ្ចប់ និងការប៉ាន់ស្មានថ្លៃដើមសំខាន់ៗដើម្បីលក់។

សន្និធិរួមមានវត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិផ្សេងៗដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ត្រូវបានវាយតម្លៃតាមថ្លៃដើមជាក់ស្តែងសុទ្ធ ក្នុងការនាំយកសន្និធិនោះមកប្រើប្រាស់ទៅតាមគោលបំណង ដែលបានគ្រោងទុក ដក សំវិធានធនលើការបែកបាក់ ខូចខាត និងមានចលនាយឺតដោយប្រើប្រាស់វិធីសាស្រ្តមូលដ្ឋានចូលមុន - ចេញមុន។

### *៣.៩ ឧបករណ៍ហិរញ្ញវត្ថុ*

ឧបករណ៍ហិរញ្ញវត្ថុ គឺជាកិច្ចសន្យាទាំងឡាយណាដែលផ្តល់នូវការកើនឡើងនៃទ្រព្យសកម្ម និងទ្រព្យអសកម្ម ឬ ឧបករណ៍មូលធន របស់អង្គភាពមួយផ្សេងទៀត។

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ*

#### *៣.១០.១ ការធ្វើចំណាត់ថ្នាក់*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់តាមការទទួលស្គាល់ដំបូង បន្ទាប់មកទៀតត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម តម្លៃសមស្របតាមលទ្ធផលពេញលេញផ្សេងៗ (OCI) និងតម្លៃសមស្របតាមប្រាក់ចំណេញ ឬ ខាត ("FVTPL")។

ក.ស.ស បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនផ្លាស់ប្តូរតែប៉ុណ្ណោះ។

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ, ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងសាច់ប្រាក់ដែលបានបំពេញតាមលក្ខខណ្ឌក្នុងការសងតែប្រាក់ដើម និងការប្រាក់ (SPPI) ដោយតាមលក្ខខណ្ឌក្នុងកិច្ចសន្យាបានធ្វើឲ្យលំហូរសាច់ប្រាក់កើនឡើង ព្រមទាំងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីមូលដ្ឋានដើម។ ទ្រព្យសកម្មទាំងនេះក៏ត្រូវបានប្រមូលផ្តុំនៅក្នុងគំរូអាជីវកម្មកាន់កាប់ដល់ប្រមូលត្រលប់ ដូច្នេះនឹងត្រូវបានចាត់ថ្នាក់ និងវាស់វែងតាមរំលស់ថ្លៃដើម។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

*៣.១០.២ ការទទួលស្គាល់ និងការវាស់វែង*

នៅពេលទទួលស្គាល់ដំបូង ក.ស.ស វាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូក (ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនវាស់វែងតម្លៃសមស្របតាមប្រាក់ចំណេញ ឬ ខាត (FVTPL)) ចំណាយប្រតិបត្តិការដោយផ្ទាល់ភ្ជាប់ជាមួយការទិញទ្រព្យសកម្មហិរញ្ញវត្ថុ។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុយោងតាម FVPL ត្រូវបានកត់ត្រាជាចំណាយនៅក្នុងប្រាក់ចំណេញ ឬ ខាត។

បម្រែបម្រួលតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុតាម FVPL ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬ ខាតផ្សេងៗ នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាត តាមការជាក់ស្តែង។

ទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានចាត់ថ្នាក់ឡើងវិញបន្ទាប់ពី ការទទួលស្គាល់ដំបូងឡើយ លើកលែងតែក្រុមហ៊ុនផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីនេះទ្រព្យហិរញ្ញវត្ថុដែលរងផលប៉ះពាល់ទាំងអស់ ត្រូវបានចាត់ថ្នាក់ឡើងវិញនៅថ្ងៃដំបូងនៃការិយបរិច្ឆេទរាយការណ៍ដំបូង បន្ទាប់ពីការផ្លាស់ប្តូរគំរូអាជីវកម្ម។

*រំលស់ថ្លៃដើម*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុបំពេញលក្ខខណ្ឌដែលមិនបានកំណត់ដូចនៅ FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងនៅក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងរក្សាទ្រព្យសកម្មដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ការកើនឡើងនៅកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) លើសមតុល្យប្រាក់ដើម។

*FVOCI - មូលបត្របំណុល*

មូលបត្របំណុលត្រូវបានវាស់វែងតាម FVOCI ប្រសិនបើបំពេញលក្ខខណ្ឌ និងមិនបានកំណត់ដូចនៅ FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងនៅក្នុងគំរូអាជីវកម្ម ដែលគោលបំណងត្រូវបានសម្រេចទាំងពីរតាមរយៈការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ការកើនឡើងនៅកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់តែប្រាក់ដើម និងការប្រាក់លើ សមតុល្យប្រាក់ដើម។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

*៣.១០.២ ការទទួលស្គាល់ និងការវាស់វែង* (តពីទំព័រមុន)

*FVOCI - មូលបត្រមូលធន*

លើការទទួលស្គាល់ដំបូងនៃការវិនិយោគភាគហ៊ុន ដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ក្រុមហ៊ុនអាចជ្រើសរើសដោយមិនបង្ហាញការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃសមស្របនៅក្នុង OCI លើមូលដ្ឋានតាមវិនិយោគនីមួយៗនោះទេ។

*FVPL*

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលមិនត្រូវបានចាត់ថ្នាក់ជាការវាស់វែងតាមថ្លៃដើមរំលស់ ឬ FVOCI ដូចដែលបានពិពណ៌នាខាងលើត្រូវបានវាស់វែងតាម FVPL។ នៅពេលទទួលស្គាល់ដំបូង ក្រុមហ៊ុនមិនអាចកំណត់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមតម្រូវការដើម្បីវាស់វែងរំលស់តាមថ្លៃដើម ឬ តាម FVOCI ដូចតាម FVPL ប្រសិនបើការធ្វើដូច្នេះលុបបំបាត់ ឬកាត់បន្ថយយ៉ាងខ្លាំងនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ (លើកលែងតែការវាស់វែងតាម FVPL និងការវិនិយោគភាគហ៊ុនត្រូវបានវាស់វែងតាម FVOCI) ជាកម្មវត្ថុនៃការវាយតម្លៃលើអ៊ីមភែរមិន។

*ការវាយតម្លៃអាជីវកម្មគំរូ*

ក្រុមហ៊ុនបានធ្វើការវាយតម្លៃលើគោលបំណងនៃគំរូអាជីវកម្ម ដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងនៅកម្រិតផលប័ត្រ ពីព្រោះវាឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីវិធីដែលអាជីវកម្មត្រូវបានគ្រប់គ្រងហើយព័ត៌មានត្រូវបានផ្តល់ជូនដល់អ្នកគ្រប់គ្រង។ ព័ត៌មានដែលបានពិចារណារួមមាន៖

- គោលនយោបាយ និងកម្មវត្ថុដែលបានចែងសម្រាប់ផលប័ត្រ និងប្រតិបត្តិការនៃគោលនយោបាយទាំងនោះក្នុងការអនុវត្ត។ ទាំងនេះរួមបញ្ចូលថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រងផ្តោតលើការទទួលប្រាក់ចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សាទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ការផ្គូផ្គងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេល នៃបំណុលដែលពាក់ព័ន្ធ ឬ លំហូរចេញសាច់ប្រាក់ដែលបានរំពឹងទុក ឬ ការសម្រេចលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- របៀបដែលលទ្ធផលនៃផលប័ត្រត្រូវបានវាយតម្លៃ និងរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន
- ហានិភ័យដែលជះឥទ្ធិពលដល់ការអនុវត្តគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងរបៀបដែលហានិភ័យទាំងនោះត្រូវបានគ្រប់គ្រង
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មត្រូវបានផ្តល់សំណង - ឧ. ថាតើសំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬ លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងកាលបរិច្ឆេទមុន មូលហេតុសម្រាប់ការលក់ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

#### *៣.១០.២ ការទទួលស្គាល់ និងការវាស់វែង* (តពីទំព័រមុន)

*ការវាយតម្លៃលើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការបង់ប្រាក់តែប្រាក់ដើម និងការប្រាក់*

ក្នុងគោលបំណងនៃការវាយតម្លៃនេះ 'ប្រាក់ដើម' ត្រូវបានកំណត់ថាជាតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង។

'ការប្រាក់' ត្រូវបានកំណត់ថាជាការពិចារណាលើតម្លៃពេលវេលានៃសាច់ប្រាក់ និងសម្រាប់ហានិភ័យឥណទានដែលទាក់ទងនឹងសមតុល្យប្រាក់ដើម ក្នុងអំឡុងការិយបរិច្ឆេទជាក់លាក់នៃពេលវេលា និងសម្រាប់ហានិភ័យលើប្រាក់កម្ចី និងចំណាយជាមូលដ្ឋានគោល (ឧ. ហានិភ័យសាច់ប្រាក់ និងចំណាយរដ្ឋបាល) ក៏ដូចជាកម្រិតប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា ជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ក្រុមហ៊ុនពិចារណាលើលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។ នេះរួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬ បរិមាណនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលវានឹងមិនបំពេញតាមលក្ខខណ្ឌនេះ។ ក្នុងការធ្វើការវាយតម្លៃនេះ ក្រុមហ៊ុនចាត់ទុកថា៖

- ព្រឹត្តិការណ៍យថាភាពដែលអាចនឹងផ្លាស់ប្តូរចំនួន ឬ ពេលវេលានៃលំហូរសាច់ប្រាក់។
- លក្ខខណ្ឌដែលអាចកែតម្រូវអត្រាខ័ណ្ឌប័ណ្ណតាមកិច្ចសន្យា រួមទាំងលក្ខណៈពិសេសអត្រាអថេរ
- ចំណាយបង់មុន និងពង្រីកនូវទម្រង់ និង
- លក្ខខណ្ឌដែលកំណត់ការទាមទារសំណងរបស់ក្រុមហ៊ុន ចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មដែលបានបញ្ជាក់ (ឧ. ទម្រង់ដែលមិនមានការកែថ្លៃ)។

លក្ខណៈនៃការបង់ប្រាក់ជាមុនគឺស្របជាមួយនឹងលក្ខណៈវិនិច្ឆ័យ 'ការទូទាត់តែប្រាក់ដើម និងការប្រាក់' ប្រសិនបើចំនួនទឹកប្រាក់បង់ប្រាក់ជាមុនតំណាងឲ្យតម្លៃមិនទាន់ទូទាត់នៃប្រាក់ដើម និងការប្រាក់ លើសមតុល្យប្រាក់ដើម ដែលអាចរួមបញ្ចូលសំណងបន្ថែមសមហេតុផលសម្រាប់ការបញ្ចប់កិច្ចសន្យាមុនកាលកំណត់។ លើសពីនេះទៀត សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានទិញតាមតម្លៃអប្បហារចំពោះកិច្ចសន្យានៃតម្លៃ លក្ខណៈដែលអនុញ្ញាត ឬ តម្រូវឲ្យបង់ប្រាក់ជាមុនតាមតម្លៃដែលដែលតំណាងឲ្យចំនួនសរុបនៃកិច្ចសន្យា បូកនឹងការប្រាក់តាមកិច្ចសន្យាដែលបានបង្គរ (ប៉ុន្តែមិនទាន់ទូទាត់) កិច្ចសន្យាការប្រាក់ (ដែលអាចរួមបញ្ចូលផងដែរនូវសំណងបន្ថែមសមរម្យសម្រាប់ការបញ្ចប់មុនកាលកំណត់) ត្រូវបានចាត់ទុកថាស្របនឹងលក្ខណៈវិនិច្ឆ័យនេះ ប្រសិនបើតម្លៃទីផ្សារនៃការបង់ប្រាក់ជាមុនគឺមិនសំខាន់នៅពេលទទួលស្គាល់ដំបូង។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

#### *៣.១០.៣ ការឈប់ទទួលស្គាល់*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្នុងករណីដែលអាចអនុវត្តបាន ផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ផ្នែកនៃក្រុមទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) មិនត្រូវបានទទួលស្គាល់ជាចម្បង (ឧ. ដកចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន) នៅពេលៈ

- សិទ្ធិទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្មបានផុតកំណត់ ឬ
- ក្រុមហ៊ុនបានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ បានសន្មតកាតព្វកិច្ចទូទាត់លំហូរសាច់ប្រាក់ដែលបានទទួលពេញលេញ ដោយគ្មានការពន្យាពេលជាសារវន្តដល់ភាគីទីបីក្រោមការរៀបចំ 'ឆ្លងកាត់' (pass-through) និងណាមួយនៃ (ក) ក្រុមហ៊ុនបានផ្ទេរហានិភ័យ និងផលប្រយោជន៍ទាំងអស់នៃទ្រព្យសកម្ម ឬ ក្រុមហ៊ុនមិនបានផ្ទេរ ឬ រក្សានូវហានិភ័យ និងផលប្រយោជន៍ទាំងអស់នៃទ្រព្យសកម្មនោះទេ ប៉ុន្តែបានផ្ទេរការគ្រប់គ្រងនៃទ្រព្យសកម្ម។

នៅពេលដែលក្រុមហ៊ុនបានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ បានចូលទៅក្នុងការរៀបចំឆ្លងកាត់ នោះវាបានវាយតម្លៃថាតើវានៅរក្សាហានិភ័យ និងផលប្រយោជន៍ដែលសំខាន់ក្នុងនាមជាម្ចាស់កម្មសិទ្ធិដល់កម្រិតណា។ នៅពេលដែលក្រុមហ៊ុនមិនបានផ្ទេរ ឬ រក្សានូវហានិភ័យ និងផលប្រយោជន៍ទាំងអស់របស់ទ្រព្យសកម្ម ឬមិនបានផ្ទេរការគ្រប់គ្រងទ្រព្យសកម្មនោះ ក្រុមហ៊ុននៅតែបន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរត្រឹមកម្រិតនៃការចូលរួមបន្តរបស់ទ្រព្យសកម្មនោះ។ ក្នុងករណីនោះ ក្រុមហ៊ុនក៏ទទួលស្គាល់បំណុលដែលពាក់ព័ន្ធផងដែរ។ ទ្រព្យសកម្មដែលបានផ្ទេរ និងបំណុលដែលពាក់ព័ន្ធត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានដែលឆ្លុះបញ្ចាំងពីសិទ្ធិ និងកាតព្វកិច្ចដែលក្រុមហ៊ុនបានរក្សាទុក។

ការបន្តចូលរួមដែលបង្កើតទម្រង់នៃការធានាលើទ្រព្យសកម្មដែលបានផ្ទេរ គឺត្រូវបានវាស់វែងនៅកម្រិតទាបជាងរវាងតម្លៃយោងដើមនៃទ្រព្យសកម្ម និងតម្លៃពិចារណាអតិបរមាដែលក្រុមហ៊ុនអាចត្រូវបានទាមទារឲ្យទូទាត់វិញ។

#### *៣.១០.៤ អ៊ីមភែរមិនលើទ្រព្យសកម្មហិរញ្ញវត្ថុ*

ក្រុមហ៊ុនទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក (ECLs) សម្រាប់ឧបករណ៍បំណុលទាំងអស់ដែលមិនវាស់វែងតាមតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាត។ ECLs គឺផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់ពេលកំណត់ដោយអនុលោមតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ទាំងអស់ដែលក្រុមហ៊ុនរំពឹងថានឹងទទួលបាន ដោយធ្វើអប្បហារក្នុងអត្រាការប្រាក់ប្រសិទ្ធិភាពដើម។ លំហូរសាច់ប្រាក់ដែលរំពឹងទុក រួមបញ្ចូលលំហូរសាច់ប្រាក់ពីការលក់វត្ថុបញ្ចាំ ឬ ការបង្កើនឥណទានផ្សេងទៀត ដែលរួមបញ្ចូលទៅនឹងលក្ខខណ្ឌនៃកិច្ចសន្យា។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

#### *៣.១០.៤ អ៊ីមភែរមិនលើទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

ECLs ត្រូវបានចែកចេញជាពីរដំណាក់កាល។ សម្រាប់ការបង្ហាញឥណទានដែលមិនមានការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ECLs ត្រូវបានផ្តល់សម្រាប់ការបាត់បង់ឥណទានដែលបណ្តាលមកពីព្រឹត្តិការណ៍លំនាំដើម ដែលអាចធ្វើទៅបានក្នុងរយៈពេល ១២ខែបន្ទាប់ (ECL ១២ខែ)។ ចំពោះហានិភ័យឥណទានទាំងនោះ ដែលមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង សំវិធានធនគឺត្រូវបានទាមទារសម្រាប់ការបាត់បង់ឥណទាន ដែលរំពឹងទុកក្នុងអាយុកាលដែលនៅសល់នៃហានិភ័យនោះ ដោយមិនគិតពីពេលវេលានៃលំនាំដើម (Lifetme ECL )។

សម្រាប់គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ក្រុមហ៊ុនអនុវត្តវិធីសាស្ត្រសាមញ្ញក្នុងការគណនា ECLs។ ដូច្នេះហើយ ក្រុមហ៊ុនមិនបានតាមដានការផ្លាស់ប្តូរហានិភ័យឥណទានទេ ប៉ុន្តែជំនួសមកវិញនូវសំវិធានធនទៅលើការខាតបង់ដោយផ្អែកលើ Lifetime ECLs នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ក្រុមហ៊ុនបានបង្កើតតារាងសំវិធានធនដែលផ្អែកលើបទពិសោធន៍ការបាត់បង់ឥណទាននៅពេលអតីតកាល ដោយកែសម្រួលសម្រាប់អថេរឆ្ពោះទៅមុខដែលជាក់លាក់ចំពោះអ្នកជំពាក់ និងបរិយាកាសសេដ្ឋកិច្ច។

ក្រុមហ៊ុនចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុមានការខូចខាត នៅពេលដែលការទូទាត់តាមកិច្ចសន្យាគឺហួសកំណត់ក្នុងរយៈពេល ៦០ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីខ្លះ ក្រុមហ៊ុនក៏អាចពិចារណាលើទ្រព្យសកម្មហិរញ្ញវត្ថុមិនមានការខូចខាត នៅពេលដែលព័ត៌មានខាងក្នុង ឬ ខាងក្រៅបង្ហាញថាក្រុមហ៊ុនទំនងជា ទទួលបានទឹកប្រាក់កិច្ចសន្យាដែលនៅសេសសល់ពេញលេញមុនពេលពិចារណាលើការបង្កើនឥណទានដែលគ្រប់គ្រងដោយក្រុមហ៊ុន។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាត់ចេញនៅពេលដែលមិនមានការរំពឹងទុកសមហេតុផល ក្នុងការស្តារលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

ក.ស.ស បានវាយតំលៃលើមូលដ្ឋានអថេរឆ្ពោះទៅមុខ សម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុ កត់ត្រាតាមរំលស់ថ្លៃដើម។ វិធីសាស្ត្រអ៊ីមភែរមិនត្រូវបានអនុវត្តអាស្រ័យលើ ថាតើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ឬ ទេ។

ចំពោះគណនីអតិថិជនត្រូវទទួល ក.ស.ស អនុវត្តវិធីសាស្ត្រសាមញ្ញដែលអនុញ្ញាតឲ្យប្រើប្រាស់ដោយ CIFRS ៩ ដែលទាមទារឲ្យមានការទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុកពេញមួយជីវិតចាប់តាំងពីពេលទទួលស្គាល់ដំបូងសម្រាប់គណនីអតិថិជនត្រូវទទួល *(កំណត់សម្គាល់លេខ ៣០.១)*។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១១ គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ*

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ជាទឹកប្រាក់ដែលត្រូវទទួលបានពីការផ្តល់សេវាកម្មផ្សេងៗដល់អតិថិជនក្នុងដំណើរការអាជីវកម្មធម្មតា។ ប្រសិនបើការប្រមូលប្រាក់កំណត់ក្នុងរយៈពេល ១ឆ្នាំ ឬ តិចជាង (ឬ នៅក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា) គណនីអតិថិជនត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលខ្លី។ ប្រសិនបើលើសពី ១ឆ្នាំ វាត្រូវបានចាត់ទុកជាទ្រព្យសកម្មរយៈពេលវែង។

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មក ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ដកសំវិធានធនលើអ៊ីមភែរមិន និងការខាតបង់ឥណទានរំពឹងទុក *(កំណត់សម្គាល់លេខ ៣០.១)*។

### *៣.១២ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី*

ការវិនិយោគរយៈពេលខ្លី តំណាងឲ្យប្រាក់បញ្ញើមានកាលកំណត់ដែលដាក់នៅធនាគារ មានកាលកំណត់ពី ៦ខែ ទៅ ១២ខែ។ ចំណូលបានពីការប្រាក់ និងការប្រាក់ត្រូវទទួល បានទទួលស្គាល់ទៅតាមកាលកំណត់នៃប្រាក់បញ្ញើ។

### *៣.១៣ សាច់ប្រាក់*

សាច់ប្រាក់ រួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារ និងការវិនិយោគរយៈពេលខ្លីដែលអាចបង្វិលទៅជាសាច់ប្រាក់បានភ្លាមៗ និងមានកាលកំណត់បីខែ ឬ តិចជាងបីខែ។

### *៣.១៤ បំណុលហិរញ្ញវត្ថុ*

*ការទទួលស្គាល់ និងការវាស់វែងដំបូង*

បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ (តាមការទទួលស្គាល់ដំបូង) ជាបំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របក្នុងប្រាក់ចំណេញ ឬ ខាត ឥណទាននិងប្រាក់កម្ចី គណនីត្រូវទូទាត់ ឬ ជាឧបករណ៍និស្សន្ទដែលបានកំណត់ជាឧបករណ៍ការពារហានិភ័យដ៏មានប្រសិទ្ធភាពមួយ។

បំណុលហិរញ្ញវត្ថុទាំងអស់ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃទីផ្សារនិង (ក្នុងករណីឥណទាននិងកម្ចី និងគណនីត្រូវទូទាត់) តម្លៃសុទ្ធនៃថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធផ្ទាល់។

*ការវាស់វែងជាបន្តបន្ទាប់*

ចំពោះគោលបំណងនៃការវាស់វែងជាបន្តបន្ទាប់ បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាពីរប្រភេទ៖

- បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬ ខាត
- បំណុលហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម (ឥណទាន និងកម្ចី)។

## ៣. សេចក្ដីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១៤ បំណុលហិរញ្ញវត្ថុ* (តពីទំព័រមុន)

*បំណុលហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម (ឥណទាន និងកម្ចី)*

បំណុលហិរញ្ញវត្ថុប្រភេទនេះ គឺប្រភេទដែលទាក់ទងនឹងក្រុមហ៊ុនបំផុត។ បន្ទាប់ពីការទទួលស្គាល់ដំបូង ឥណទាន និងប្រាក់កម្ចីដែលមានការប្រាក់ត្រូវបានវាស់វែងជាបន្តបន្ទាប់តាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្រ្តអត្រាការប្រាក់មានប្រសិទ្ធភាព (EIR)។ ប្រាក់ចំណេញ និងខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ នៅពេលដែលបំណុលត្រូវបានឈប់ទទួលស្គាល់ក៏ដូចជាតាមរយៈដំណើរការរំលស់ EIR។

រំលស់ថ្លៃដើមត្រូវបានគណនាដោយគិតពីអប្បហារ ឬ បុព្វលាភលើការទិញ និងថ្លៃសេវា ឬចំណាយដែលជាផ្នែកសំខាន់នៃ EIR។ រំលស់តាម EIR ត្រូវបានរួមបញ្ចូលជាការចំណាយហិរញ្ញវត្ថុនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ប្រភេទនេះជាទូទៅអនុវត្តចំពោះឥណទាន និងប្រាក់កម្ចីដែលមានការប្រាក់។

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលវាស់វែងតាមតម្លៃរំលស់រួមមាន គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ បំណុលភតិសន្យា និងកម្ចី។

*ការឈប់ទទួលស្គាល់*

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចបំណុលត្រូវបានលុបចោល ឬ ផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយបំណុលមួយផ្សេងទៀតពីអ្នកឲ្យខ្ចីដូចគ្នា ក្នុងលក្ខខណ្ឌខុសគ្នាខ្លាំង ឬ លក្ខខណ្ឌនៃការទទួលខុសត្រូវដែលមានស្រាប់ត្រូវបានកែប្រែយ៉ាងច្រើន ការផ្លាស់ប្ដូរ ឬ ការកែប្រែនេះត្រូវបានចាត់ទុកថាជាការឈប់ទទួលស្គាល់បំណុលដើម និងទទួលស្គាល់បំណុលថ្មី។ ភាពលម្អៀងគ្នានៃតម្លៃយោងនីមួយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### *៣.១៥ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងជាមួយគ្នា ហើយចំនួនសុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានកត់ត្រា និងនៅពេលដែលក្រុមហ៊ុនមានបំណងទូទាត់តាមមូលដ្ឋានសុទ្ធបន្ទាប់ពីកាត់កង ឬ មានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។ តែនេះមិនមែនជាករណីនេះទេចំពោះការកាត់កងកិច្ចសន្យាមេ និងទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុពាក់ព័ន្ធ ត្រូវបានបង្ហាញនៅតម្លៃដុលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១៦ ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់*

ទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មសម្រាប់លក់) ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មសម្រាប់លក់ នៅពេលដែលតម្លៃយោងរបស់ទ្រព្យសកម្មនោះ ត្រូវបានទទួលយកមកវិញជាចម្បងតាមរយៈប្រតិបត្តិការលក់ ហើយការលក់នោះត្រូវបានចាត់ទុកថាមានភាពច្បាស់លាស់។ ទ្រព្យសកម្មទាំងនោះ ត្រូវបានវាស់វែងតាមតម្លៃដែលទាបជាងរវាងតម្លៃយោង ជាមួយនឹងតម្លៃសមស្របដកចំណាយលើការលក់ លើកលែងតែទ្រព្យសកម្មទាំងនោះជាទ្រព្យវិនិយោគវាស់វែងតាមតម្លៃសមស្រប ឬ ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតក្នុងវិសាលភាពរបស់ CIFRS ៩ ករណីនេះទ្រព្យសកម្មទាំងនោះត្រូវបានវាស់វែងស្របតាមស្តង់ដារទាំងនោះ។

### *៣.១៧ ដើមទុន និងបុព្វលាភភាគហ៊ុន*

ដើមទុនដែលបានបង់ ត្រូវបានវាស់វែងតាមតម្លៃចារឹកលើភាគហ៊ុនទាំងអស់ដែលបានបោះផ្សាយ និងនៅសល់។ នៅពេលដែលភាគហ៊ុនត្រូវបានលក់ក្នុងតម្លៃបុព្វលាភ ភាពខុសគ្នារវាងប្រាក់ទទួលបាន និងតម្លៃចារឹកលើភាគហ៊ុនត្រូវបានបញ្ចូលទៅក្នុងបុព្វលាភភាគហ៊ុន។

ភាគហ៊ុនធម្មតាដែលមានភាគលាភ ត្រូវបានចាត់ថ្នាក់ជាមូលធន។ ការបែងចែកភាគលាភទៅម្ចាស់ភាគហ៊ុន ត្រូវបានកត់ត្រាដោយផ្ទាល់ក្នុងមូលធន។

### *៣.១៨ ភាគលាភ*

ភាគលាភលើភាគហ៊ុនធម្មតា ត្រូវបានទទួលស្គាល់ជាបំណុលនៅពេលប្រកាសមុនកាលបរិច្ឆេទរាយការណ៍។ ភាគលាភដែលបានប្រកាសបន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតចេញផ្សាយ មិនត្រូវបានទទួលស្គាល់ថាជាបំណុលនាកាលបរិច្ឆេទរបាយការណ៍នោះទេ។

សំវិធានធនត្រូវបានធ្វើឡើងសម្រាប់ទឹកប្រាក់នៃភាគលាភណាមួយដែលបានប្រកាស ដែលត្រូវបានអនុម័តត្រឹមត្រូវ និងលែងជាការសម្រេចចិត្តរបស់ ក.ស.ស នៅឬមុនចុងបញ្ចប់នៃរយៈពេលរាយការណ៍ ប៉ុន្តែមិនត្រូវបានចែកចាយនៅចុងបញ្ចប់នៃកាលបរិច្ឆេទរាយការណ៍នោះទេ។

### *៣.១៩ ប្រាក់កម្ចី*

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលបានកើតឡើង។ ប្រាក់កម្ចីត្រូវបានយោងបន្តតាមរំលស់ថ្លៃដើម ។ ភាពលម្អៀងរវាងសាច់ប្រាក់ទទួលបាន (ដកចំណាយប្រតិបត្តិការ) និងទឹកប្រាក់ដែលបង្វិលសងវិញត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬ ខាតលើរយៈពេលនៃប្រាក់កម្ចី ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់មានប្រសិទ្ធិភាព។

កម្រៃបានបង់លើដំណើរការចាប់ផ្តើមឥណទាន ត្រូវបានកត់ត្រាជាចំណាយប្រតិបត្តិការប្រាក់កម្ចីត្រឹមទំហំដែរកម្រៃនោះមានភាពជឿជាក់ថាឥណទានទាំងអស់ដែលត្រូវដក។ ក្នុងករណីនេះ កម្រៃបានបង់លើដំណើរការឥណទានត្រូវបានពន្យាររហូតដល់ពេលដកសាច់ប្រាក់ជាក់ស្តែង។ នៅពេលមិនមានភស្តុតាងបញ្ជាក់ថាមានការដកឥណទានមួយចំនួន ឬ ឥណទានទាំងអស់ នោះកម្រៃបានបង់លើដំណើរការឥណទាន ត្រូវបានចាត់ថ្នាក់ជាចំណាយបង់មុនសម្រាប់សេវាសាច់ប្រាក់ និងត្រូវបានធ្វើរំលស់លើរយៈពេលឥណទានដែលពាក់ព័ន្ធ។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១៩ ប្រាក់កម្ចី* (តពីទំព័រមុន)

***ថ្លៃដើមនៃប្រាក់កម្ចី***

ថ្លៃដើមនៃកម្ចីជាក់លាក់ និងទូទៅដែលបានចំណាយផ្ទាល់ក្នុងការទិញ ក្នុងការសាងសង់ ឬ ការផលិតទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវចំណាយពេលវេលាចាំបាច់សម្រាប់បញ្ចប់ ដើម្បីអាចប្រើប្រាស់តាមការគ្រោងទុករបស់ ឬ សម្រាប់លក់ ត្រូវបានកត់ត្រាបន្ថែមនៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ទ្រព្យសកម្មនោះមានភាពរួចរាល់សម្រាប់ការប្រើប្រាស់ ឬ អាចលក់បាន។

ចំណូលលើការវិនិយោគដែលបានពីការវិនិយោគបណ្តោះអាសន្ននៃប្រាក់កម្ចីជាក់លាក់ ដែលមិនទាន់ជាចំណាយរបស់ទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានដកចេញពីថ្លៃដើមនៃប្រាក់កម្ចីដែលត្រូវធ្វើមូលធនកម្ម។

ថ្លៃដើមនៃប្រាក់កម្ចីផ្សេងៗទៀតទាំងអស់ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាត ក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង។

*ការឈប់ទទួលស្គាល់*

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចបំណុលត្រូវបានរំសាយ លុបចោល ឬ ផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយបំណុលមួយផ្សេងទៀតពីអ្នកឲ្យខ្ចីដូចគ្នា ក្នុងលក្ខខណ្ឌខុសគ្នាខ្លាំង ឬ លក្ខខណ្ឌនៃការទទួលខុសត្រូវដែលមានស្រាប់ត្រូវបានកែប្រែយ៉ាងច្រើន ការផ្លាស់ប្តូរឬការកែប្រែនេះត្រូវបានចាត់ទុកថាជាការឈប់ទទួលស្គាល់បំណុលដើម និងត្រូវទទួលស្គាល់បំណុលថ្មី។ ភាពលម្អៀងគ្នានៃតម្លៃយោងនីមួយៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក*

*៣.២០.១ អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី*

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីរួមមាន ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល ប្រាក់បុព្វលាភបន្ថែម ប្រាក់បំណាច់អតីតភាពការងារ និងការរួមចំណែកដល់មូលនិធិសន្តិសុខសង្គម ត្រូវបានទទួលស្គាល់ជាចំណាយក្នុងអំឡុងការិយបរិច្ឆេទដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ដោយនិយោជិត។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

ក.ស.ស បានផ្តល់ឲ្យគម្រោងចំនួនពីរសម្រាប់អត្ថប្រយោជន៍បុគ្គលិក ទៅដល់បុគ្គលិកនៅពេលដែលដល់អាយុចូលនិវត្តន៍៖

- កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍
- ប្រាក់លើកទឹកចិត្ត

ក.ស.ស ក៏បានប្រតិបត្តិគម្រោងអត្ថប្រយោជន៍នេះដូចខាងក្រោម៖

- វិភាគទានរបស់បុគ្គលិក ១០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានប្រចាំខែរបស់បុគ្គលិក
- វិភាគទានរបស់ ក.ស.ស ១០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានប្រចាំខែរបស់បុគ្គលិក
- ជាមូលដ្ឋានប្រចាំឆ្នាំ ក្រុមប្រឹក្សាភិបាលសម្រេចលើប្រាក់បន្ថែមដែលនឹងត្រូវបញ្ចូលទៅក្នុងគម្រោងអត្ថប្រយោជន៍នេះ អាស្រ័យទៅតាមលទ្ធផលក្នុងអំឡុងឆ្នាំរបស់ ក.ស.ស។

បុគ្គលិកត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នេះ៖

- ជាបុគ្គលិកអចិន្ត្រៃយ៍។
- បានបំពេញការងារជូន ក.ស.ស ចំនួន ២៥ឆ្នាំ ឬ ច្រើនជាងនេះ
- បានចូលរួមវិភាគទុនក្នុងគម្រោងអត្ថប្រយោជន៍នេះដែលបានតម្រូវ
- មានប័ណ្ណបុគ្គលិក និង

ប្រសិនបើចូលនិវត្តមុនពេលដល់អាយុចូលនិវត្ត ការចូលនិវត្តនោះ ត្រូវមានការអនុម័តដោយប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(i) កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

(ក) បុគ្គលិកដែលបានបម្រើការងាររយៈពេល២៥ឆ្នាំ ឬ ច្រើនឆ្នាំជាងនេះ មានជម្រើសក្នុងការជ្រើសរើសទទួលបានអត្ថប្រយោជន៍នេះ គឺបើកប្រាក់ផ្តាច់តែមួយដងនៅពេលដល់អាយុចូលនិវត្ត ឬ បើកប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណៈភាព។ ការបង់ប្រាក់ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ គឺអាស្រ័យទៅតាមប្រការ និងលក្ខខណ្ឌដូចខាងក្រោមៈ

*ការបង់ប្រាក់ផ្តាច់ៈ*

បុគ្គលិក ដែលសម្រេចទទួលយកការបង់ប្រាក់ផ្តាច់នៅពេលដល់អាយុចូលនិវត្តនឹងទទួលបាននូវទឹកប្រាក់ស្មើនឹង ១២,៥ដង នៃប្រាក់បៀវត្សរ៍មូលដ្ឋានខែចុងក្រោយរបស់ពួកគេ។

*ការបង់ប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណៈភាពៈ*

ការបង់ប្រាក់ប្រចាំខែជូនបុគ្គលិក ដែលសម្រេចជ្រើសរើសយកអត្ថប្រយោជន៍ប្រចាំខែរហូតដល់ពេលទទួលមរណៈភាព អាស្រ័យទៅតាមចំនួនឆ្នាំនៃអតីតភាពការងាររបស់បុគ្គលិក ដូចបានកំណត់ខាងក្រោមៈ

| *អតីតភាពការងារ* | *អត្ថប្រយោជន៍* |
|---|---|
| ២៥ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍មូលដ្ឋានសុទ្ធនៃខែចុងក្រោយរបស់ពួកគេ។ |
| ២៦ឆ្នាំ ដល់ ៤០ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍មូលដ្ឋានសុទ្ធនៃខែចុងក្រោយសុទ្ធរបស់ពួកគេ បូកនឹង ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ២៥ឆ្នាំ។ |
| ៤០ឆ្នាំឡើងទៅ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៩០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានសុទ្ធនៃខែចុងក្រោយរបស់ពួកគេ។ |

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

#### *៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(i) កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

(ខ) បុគ្គលិកដែលបានបម្រើការងាររយៈពេលតិចជាង ២៥ឆ្នាំ មិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នេះទេ ក៏ប៉ុន្តែពួកគេមានសិទ្ធិទទួលបានការបង់ប្រាក់ផ្តាច់មួយចំនួនដូចខាងក្រោម៖

| *អតីតភាពការងារ* | *អត្ថប្រយោជន៍* |
|---|---|
| តិចជាង ១០ឆ្នាំ | មិនទទួលបានអត្ថប្រយោជន៍ និងមិនទទួលបានវិភាគទានសរុបមកវិញទេ។ វិភាគទានសរុបនឹងក្លាយទៅជាចំណូលអត្ថប្រយោជន៍។ |
| ១០ឆ្នាំ ដល់ ២៤ឆ្នាំ | ទទួលបាន ២០០% នៃវិភាគទានសរុបពី ក.ស.ស និងបុគ្គលិក។ |

ប្រសិនបើគម្រោងនេះត្រូវបានលុបចោលដោយមូលហេតុណាមួយ បុគ្គលិកអាចទាមទារនូវចំណែកបដិភាគរបស់ខ្លួនពីគម្រោងនេះវិញបាន អាស្រ័យទៅតាមលក្ខខណ្ឌជាក់ស្តែងរបស់គម្រោង ព្រមទាំងនីតិវិធីដែលបានចែងក្នុងគោលការណ៍។

(គ) អត្ថប្រយោជន៍ចូលនិវត្តមុនកំណត់

បុគ្គលិកដែលបានចូលនិវត្ត ឬ ត្រូវបណ្តេញចេញមុនពេលដល់អាយុចូលនិវត្ត នឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

| *អតីតភាពការងារ* | *អត្ថប្រយោជន៍* |
|---|---|
| តិចជាង ១០ឆ្នាំ | មិនទទួលបានវិភាគទានសរុបរបស់បុគ្គលិកមកវិញទេ។ |
| ពី ១០ឆ្នាំ ដល់ ២០ឆ្នាំ | ១២០% នៃវិភាគទានសរុបរបស់បុគ្គលិក និងបូក ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ១០ឆ្នាំ។ |
| ពី ២១ឆ្នាំ ដល់ ៣០ឆ្នាំ | ១៣៥% នៃវិភាគទានសរុបរបស់បុគ្គលិក និងបូក ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ២១ឆ្នាំ។ |
| ពី ៣១ឆ្នាំ ដល់ ៤០ឆ្នាំ | ១៥៥% នៃវិភាគទានសរុបរបស់បុគ្គលិក និងបូក ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ៣១ឆ្នាំ។ |
| លើសពី ៤០ឆ្នាំ | ១៦៤% នៃវិភាគទានសរុបរបស់បុគ្គលិក។ |

(ឃ) អត្ថប្រយោជន៍មរណៈភាព

ការបង់ប្រាក់ផ្តាច់មួយដង នឹងធ្វើការទូទាត់នៅពេលដែលបុគ្គលិកដែលទទួលមរណៈភាព។ អត្ថប្រយោជន៍នេះ អាស្រ័យទៅលើការចូលរួមវិភាគទានសរុបពី ក.ស.ស និងបុគ្គលិក និងអាស្រ័យលើចំនួនឆ្នាំនៃអតីតភាពការងាររបស់បុគ្គលិកនោះ៖

| *អតីតភាពការងារ* | *មរណៈភាពទាក់ទងនឹងការងារ* | *មរណៈភាពមិនទាក់ទងនឹងការងារ* |
|---|---|---|
| តិចជាង ១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១ - ២០ ឆ្នាំ | ១៤៥% | ១៣៥% |
| ពី ២១ - ៣០ ឆ្នាំ | ១៥៥% | ១៤៥% |
| ពី ៣០ឆ្នាំឡើងទៅ | ១៦៥% | ១៥៥% |

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(i) កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

(ង) អត្ថប្រយោជន៍ពិការភាព៖

បុគ្គលិកដែលបានបម្រើការងារតិចជាង២៥ឆ្នាំ ហើយបានធ្លាក់ខ្លួនពិការ នឹងទទួលបានការបង់ប្រាក់ផ្តាច់មួយដង អាស្រ័យទៅតាមការចូលរួមវិភាគទានរបស់ ក.ស.ស និងបុគ្គលិកដូចខាងក្រោម៖

| *អតីតភាពការងារ* | *ពិការភាពបណ្តាលមកពីការងារ* | *ពិការភាពមិនបណ្តាលមកពីការងារ* |
|---|---|---|
| តិចជាង ១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១ឆ្នាំ ដល់ ២៥ឆ្នាំ | ១២៥% បូក ៣% លើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ១០ឆ្នាំ។ | ១១៥% បូក ៣% លើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ១០ឆ្នាំ។ |
| លើសពី ២៥ឆ្នាំ | | |
| ជម្រើសទី១ | ១៧០% | ១៦០% |
| ជម្រើសទី២ | អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ប្រចាំខែ | អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ប្រចាំខែ |

*(ii) ប្រាក់លើកទឹកចិត្ត*

ក.ស.ស ក៏បានផ្តល់ឲ្យនូវគម្រោងអត្ថប្រយោជន៍បុគ្គលិកផ្សេងមួយទៀត (ប្រាក់លើកទឹកចិត្ត) ដល់បុគ្គលិកដែលបម្រើការងារឲ្យ ក.ស.ស រហូតដល់អាយុចូលនិវត្តន៍។

នៅពេលចូលនិវត្តន៍ បុគ្គលិកនឹងទទួលបានប្រាក់លើកទឹកចិត្ត (ចំនួនទឹកប្រាក់សរុប) ដែលបានកំណត់ក្នុងរូបមន្ត = (ក) × (ខ)

(ក) ចំនួនឆ្នាំដែលបានបម្រើការងាររបស់បុគ្គលិក គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងាររហូតដល់អាយុចូលនិវត្តន៍

(ខ) អត្រាអត្ថប្រយោជន៍អាស្រ័យលើឆ្នាំដែលបានបម្រើការងាររបស់ពួកគេ ដែលបានចែងដូចខាងក្រោម៖

| *អតីតភាពការងារ* | *អត្រាអត្ថប្រយោជន៍* |
|---|---|
| រហូតដល់ ២៥ឆ្នាំ | ៧៥% នៃប្រាក់បៀវត្សរ៍គោលនៃខែចុងក្រោយរបស់ពួកគេនៅអាយុចូលនិវត្តន៍ |
| ២៦ឆ្នាំ ដល់ ៩០ឆ្នាំ | ៧៥% បូមបន្ថែម ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ២៥ឆ្នាំ នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់ពួកគេ នៅអាយុចូលនិវត្តន៍ |
| លើសពី ៩០ឆ្នាំ | ៩០% គត់នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់ពួកគេនៅអាយុចូលនិវត្តន៍ |

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(ii) ប្រាក់លើកទឹកចិត្ត* (តពីទំព័រមុន)

(ខ) អត្រាអត្ថប្រយោជន៍អាស្រ័យលើឆ្នាំដែលបានបម្រើការងាររបស់ពួកគេ ដែលបានចែងដូចខាងក្រោមៈ (តពីទំព័រមុន)

បំណុលដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយអនុវត្តតាមគម្រោងអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ (កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ និងប្រាក់លើកទឹកចិត្ត) ជាតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍បានកំណត់ នាចុងការិយបរិច្ឆេទនៃរាយការណ៍ ដកតម្លៃសមស្របនៃគម្រោងទ្រព្យសកម្ម (ប្រសិនបើមាន)។ ការកំណត់កាតព្វកិច្ចប្រាក់សោធននិវត្តន៍ ត្រូវបានគណនាដោយប្រើវិធីសាស្រ្តប៉ាន់ស្មានឯកតាឥណទាន (projected unit credit)។ តម្លៃបច្ចុប្បន្ននៃការកំណត់កាតព្វកិច្ចប្រាក់សោធននិវត្តន៍ ត្រូវបានកំណត់ដោយអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ចើមធ្យម នៃប្រាក់បម្រុងមូលនិធិ សម្រាប់បង់អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ដែលបានផ្ញើរនៅធនាគានាកាលបរិច្ឆេទ ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណសាជីវកម្មមានគុណភាពខ្ពស់ ឬ មិនមានប័ណ្ណបំណុលដោយរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។

ចំណេញ និងខាតពីការវាយតម្លៃឡើងវិញដែលកើតពីការធ្វើនិយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មតការគណនាឬការវាយតម្លៃ (actuarial assumption) ត្រូវបានទទួលស្គាល់ក្នុងការិយបរិច្ឆេទ នៅពេលដែលកើតឡើង ដោយផ្ទាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

ក៏ប៉ុន្តែនៅក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានធ្វើវិសោធនកម្មលើគោលការណ៍ដោយកំណត់រយៈពេលអតិបរមាដែលនិយោជិតផ្តល់សេវាគឺ ៤០ឆ្នាំ។

*៣.២០.៣ កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ*

*ប្រាក់បំណាច់អតីតភាពការងារ*

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ("MoLVT") បានចេញសេចក្តីប្រកាសលេខ ៩៤៣ ដល់គ្រប់សហគ្រាស គ្រឹះស្ថាន និងអ្នកដែលត្រូវបានគ្របដណ្តប់ដោយមាត្រា ៨៩ (ថ្មី) នៃច្បាប់ការងារ ជាមួយនឹងសេចក្តីណែនាំស្តីពីការអនុវត្តដែលបានចេញនៅ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។ ប្រកាសនេះតម្រូវឲ្យធ្វើការទូទាត់ប្រាក់បំណាច់អតីតភាពការងារស្មើនឹងដប់ប្រាំថ្ងៃក្នុងមួយឆ្នាំនៃសេវាកម្មនិយោជិត សម្រាប់រយៈពេលអតិបរមាមិនលើសពី ៦ខែដោយផ្អែកលើប្រាក់ឈ្នួលសុទ្ធជាមធ្យមសម្រាប់ឆ្នាំនីមួយៗ។ និយោជិតមិនមានសិទ្ធិទទួលបានការទូទាត់ទេ ប្រសិនបើពួកគេលាលែងពីតំណែងមុននឹងទទួលបានការទូទាត់។ ការទូទាត់នឹងត្រូវបែកចែងតាមពេលពេលវេលាចាប់ពីខែធ្នូ ឆ្នាំ២០២១ ដូចខាងក្រោមៈ

- ស្មើនឹងបីថ្ងៃដែលត្រូវបង់រៀងរាល់ខែធ្នូ និង
- ស្មើនឹងបីថ្ងៃដែលត្រូវបង់រៀងរាល់ខែមិថុនា

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.៣ កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ* (តពីទំព័រមុន)

*ប្រាក់បំណាច់អតីតភាពការងារ* (តពីទំព័រមុន)

ប្រាក់បំណាច់អតីតភាពការងារ ឡើងវិញមិនត្រូវលើសពីប្រាំមួយខែនៃប្រាក់ឈ្នួលជាមធ្យមរបស់និយោជិតនៃឆ្នាំបន្តបន្ទាប់នីមួយៗ។ និយោជិតមិនមានសិទ្ធិទទួលបានការទូទាត់ទេ ប្រសិនបើពួកគេលាលែងពីតំណែងមុនដល់កំណត់ការបង់ប្រាក់។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ក្រសួងបានចេញសេចក្តីណែនាំស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ ដែលបញ្ជាក់ថាការទូទាត់ប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ អាចពន្យារពេលដល់ខែមិថុនា ឆ្នាំ២០២២។ ប៉ុន្តែក្រុមហ៊ុនបានចាប់ផ្តើមការទូទាត់ប្រាក់បំណាច់អតីតភាពការងារចាប់ពីខែធ្នូ ឆ្នាំ២០២១។

ក.ស.ស ប៉ាន់ប្រមាណការផ្តល់ប្រាក់បំណាច់អតីតភាពការងារដោយប្រើតម្លៃបច្ចុប្បន្ននៃការទូទាត់ដែលរំពឹងទុកនាពេលអនាគត ដោយប្រើការសន្មតជាក់លាក់លើការលាឈប់របស់បុគ្គលិក ដោយផ្អែកលើបទពិសោធន៍ថ្មីៗរបស់ក្រុមហ៊ុន អត្រាមរណៈភាព និងអត្រាការប្រាក់ទីផ្សារ។

### *៣.២១ ពន្ធលើប្រាក់ចំណូល*

ចំណាយពន្ធរួមមានពន្ធក្នុងគ្រា និងពន្ធពន្យារ។ ពន្ធត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ពេញលេញ។

*៣.២១.១ ពន្ធលើប្រាក់ចំណូលក្នុងគ្រា*

ពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាលើមូលដ្ឋាននៃអត្រាពន្ធ និងច្បាប់ដែលបានអនុម័ត នៅចុងបញ្ចប់នៃកាលបរិច្ឆេទរាយការណ៍នៅក្នុងប្រទេសកម្ពុជា ដែល ក.ស.ស បង្កើតប្រាក់ចំណូលជាប់ពន្ធ។

*៣.២១.២ ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានផ្តល់ជូនដោយប្រើវិធីសាស្រ្តបំណុល លើភាពខុសគ្នាបណ្តោះអាសន្នរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងទ្រព្យសកម្ម សម្រាប់គោលបំណងការរាយការណ៍នៃរបាយការណ៍ហិរញ្ញវត្ថុនៅចុងបញ្ចប់នៃកាលបរិច្ឆេទ។

បំណុលពន្ធពន្យារត្រូវបានទទួលស្គាល់រាល់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ លើកលែងតែករណីដែលបំណុលពន្ធពន្យារកើតឡើងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬ បំណុលនៅក្នុងប្រតិបត្តិការដែលមិនមែនជាការរួមបញ្ចូលអាជីវកម្ម និងនាពេលប្រតិបត្តិការ មិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ ឬ ប្រាក់ចំណេញ ឬខាតតាមពន្ធ។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២១ ពន្ធលើប្រាក់ចំណូល* (តពីទំព័រមុន)

*៣.២១.២ ពន្ធពន្យារ* (តពីទំព័រមុន)

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់រាល់ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន នៃឥណទានពន្ធដែលមិនបានប្រើប្រាស់ និងការខាតពន្ធមិនបានប្រើប្រើប្រាស់ ក្នុងកម្រិតមួយដែលអាចជឿជាក់បានថាប្រាក់ចំណេញជាប់ពន្ធនឹងមានសម្រាប់ការកាត់កង ជាមួយភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន និងយោងទៅមុខនៃឥណទានពន្ធមិនទាន់ប្រើប្រាស់ និង ខាតពន្ធមិនទាន់ប្រើប្រាស់ ដែលអាចប្រើប្រាស់បានលើកលែងតែករណីដែលទ្រព្យសកម្មពន្ធពន្យារ ទាក់ទងនឹងភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន កើតឡើងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬ បំណុលក្នុងប្រតិបត្តិការដែលមិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ ឬ ប្រាក់ចំណេញឬខាតតាមពន្ធ។

តម្លៃយោងសុទ្ធនៃទ្រព្យសកម្មពន្ធពន្យារ ត្រូវបានពិនិត្យឡើងវិញនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយដល់កម្រិតដែលមានភាពជឿជាក់ថា ប្រាក់ចំណេញជាប់ពន្ធមិនមានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យទ្រព្យសកម្មពន្ធពន្យារ អាចប្រើប្រាស់ទាំងអស់ ឬ មួយផ្នែក។ ទ្រព្យសកម្មពន្ធពន្យារដែលមិនទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនៅចុងបញ្ចប់នៃកាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានទទួលស្គាល់ក្នុងកម្រិតដែលមានភាពជឿជាក់ថា ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត នឹងអនុញ្ញាតឲ្យទ្រព្យសកម្មពន្ធពន្យារត្រូវបានប្រមូលមកវិញ។

ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងអនុវត្តចំពោះឆ្នាំ ដែលទ្រព្យសកម្មត្រូវបានសម្រេច ឬ បំណុលត្រូវបានទូទាត់ដោយផ្អែកលើអត្រាពន្ធ (និងច្បាប់ពន្ធ) ដែលត្រូវបានអនុម័ត ឬ អនុម័តយ៉ាងសំខាន់ក្នុងអំឡុងពេលនៃការរាយការណ៍។

ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារត្រូវបានកាត់កង ប្រសិនបើក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងទ្រព្យសកម្មពន្ធក្នុងគ្រា ជាមួយបំណុលពន្ធក្នុងគ្រា និងចំណូលពន្ធពន្យារទាក់ទងជាមួយក្រុមហ៊ុនដែលជាប់ពន្ធតែមួយ និងអាជ្ញាធរពន្ធដារដូចគ្នា។

ពន្ធ និងពន្ធពន្យារក្នុងគ្រាត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬ ខាត លើកលែងក្នុងកម្រិតមួយដែលវាទាក់ទងនឹងការទទួលស្គាល់នៃធាតុនៅក្នុងលទ្ធផលលេញលេញផ្សេងៗ ឬ ដោយផ្ទាល់នៅក្នុងមូលធន។ ក្នុងករណីនេះ ពន្ធក៏ត្រូវទទួលស្គាល់នៅក្នុងលទ្ធផលពេញលេញផ្សេងៗ ឬ ដោយផ្ទាល់នៅក្នុងមូលធនដែរ (រៀងគ្នា)។

### *៣.២២ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន*

ក.ស.ស ទទួលស្គាល់ប្រាក់ចំណូលនៅពេលដែល ក.ស.ស បំពេញកាតព្វកិច្ចអនុវត្តដោយការផ្ទេរទំនិញ ឬ សេវាកម្មដែលបានសន្យាទៅឲ្យអតិថិជន (នៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងលើទំនិញ ឬ សេវាកម្មនោះ)។ កាតព្វកិច្ចអនុវត្ត គឺជាការសន្យាដើម្បីផ្ទេរទំនិញ ឬ សេវាកម្មជាក់លាក់មួយទៅកាន់អតិថិជន។ ប្រាក់ចំណូលដែលត្រូវបានទទួលស្គាល់ គឺជាចំនួនដែលបានបែងចែកដើម្បីបំពេញកាតព្វកិច្ចអនុវត្ត។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### ៣.២២ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* (តពីទំព័រមុន)

*ចំណូលកំពង់ផែ*

ចំណូលកំពង់ផែជាចម្បងរួមមាន កម្រៃដែលទទួលបានពីការដឹកជញ្ជូនទំនិញ (ការលើកដាក់ទំនិញពីនាវា/ចូលនាវា) ការលើកដាក់ទំនិញ (ការលើកដាក់ទំនិញពីយានយន្ត/ចូលយានយន្ត) សេវាកម្មច្រកចេញចូលកំពង់ផែ (ការបញ្ជានាវា/ចំណត) ការរក្សាទុកកុងតឺន័រ និងសេវាផ្សេងៗ។ ប្រាក់ចំណូលពីការផ្តល់សេវាទាំងនេះត្រូវបានកត់ត្រានៅពេលដែលបានបំពេញសេវាជូនអតិថិជន។

*បម្រែបម្រួលនៃការពិចារណា*

កិច្ចសន្យាជាមួយអតិថិជនមិនរួមបញ្ចូលបម្រែបម្រួលនៃការពិចារណាដូចជា សិទ្ធបង្វិលត្រលប់អប្បហារអតិថិជន ឬ ការបង្វិលត្រលប់។

*ចំណូលពីការជួល - ក.ស.ស គឺជាភតិបតី*

ភតិសន្យាដែលផ្ទេរកសខាន់មួយនៃហានិភ័យ និងផលប្រយោជន៍ជាម្ចាស់កម្មសិទ្ធ ត្រូវបានរក្សាទុកដោយភតិបតី ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ចំណូលពីការជួលរបស់ភតិសន្យាប្រតិបត្តិត្រូវបានកត់ត្រាក្នុងរយៈពេលនៃភតិសន្យាតាមមូលដ្ឋានរំលស់ថេរ។

ទ្រព្យដែលបានជួលក្រោមប្រតិបត្តិការភតិសន្យា ត្រូវបានបញ្ចូលនៅក្នុងទ្រព្យវិនិយោគ *(កំណត់សម្គាល់លេខ ៧)* នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ចំណូលផ្សេងៗ*

ចំណូលផ្សេងៗរួមមាន កម្រៃពីការចូលឡានធំៗ និងកម្រៃផ្សេងៗ។ ចំណូលផ្សេងៗត្រូវបានទទួលស្គាល់នៅពេលសេវាកម្មត្រូវបានបំពេញ។

### ៣.២៣ *ចំណូលការប្រាក់*

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់ដោយប្រើវិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព EIR និងកត់ត្រាក្នុងចំណូលហិរញ្ញវត្ថុនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ៣.២៤ *ចំណេញក្នុងមួយភាគហ៊ុន*

*(i) មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន (Basic Earnings Per Share)*

មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ត្រូវបានបែងចែកការគណនាដោយៈ

- យកចំណេញរបស់ម្ចាស់ភាគហ៊ុន ក.ស.ស មិនរាប់បញ្ចូលចំណាយក្នុងការលក់ភាគហ៊ុនក្រៅពីភាគហ៊ុនធម្មតា
- ចែកជាមួយនឹងចំនួនភាគហ៊ុនធម្មតាជាមធ្យមដែលនៅសល់ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ (កែតម្រូវសម្រាប់ធាតុបន្ថែមនៅក្នុងភាគហ៊ុនធម្មតា ដែលបានបោះផ្សាយក្នុងអំឡុងឆ្នាំ និងមិនរាប់បញ្ចូលភាគហ៊ុនដែលអាចទិញយកមកវិញ (treasury shares) (ប្រសិនបើមាន))។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### ៣.២៤ *ចំណេញក្នុងមួយភាគហ៊ុន* (តពីទំព័រមុន)

*(ii) ការថយចុះចំណេញក្នុងមួយភាគហ៊ុន (Diluted Earnings Per Share)*

ការថយចុះចំណេញក្នុងមួយភាគហ៊ុន កែតម្រូវតួលេខដែលបានប្រើប្រាស់ក្នុងការកំណត់មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុនដោយគិតទៅលើះ

- ផលប៉ះពាល់ក្រោមប្រាក់ចំណូលក្រោយគិតពន្ធ នៃការប្រាក់ និងចំណាយហិរញ្ញវត្ថុផ្សេងៗ ដែលទាក់ទិននឹងសក្តានុពលនៃការថយចុះភាគហ៊ុនធម្មតា
- ចំនួនមធ្យមនៃភាគហ៊ុនធម្មតាបន្ថែម ដែលអាចត្រូវបានសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលនៃការថយចុះភាគហ៊ុនធម្មតាទាំងអស់។

### ៣.២៥ *សំវិធានធន និងបំណុលយថាភាព*

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែល ក.ស.ស មានកាតព្វកិច្ចស្របច្បាប់ ឬ កាតព្វកិច្ចនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល។ វាទំនងថាលំហូរចេញនៃធនធានតំណាងឲ្យផលផលប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានតម្រូវឲ្យទូទាត់កាតព្វកិច្ចនោះ ហើយការប៉ាន់ស្មានដែលអាចទុកចិត្តបានអាចត្រូវបានធ្វើឡើងពីចំនួនទឹកប្រាក់នៃកាតព្វកិច្ច។ ប្រសិនបើតម្លៃពេលវេលានៃទឹកប្រាក់មានភាពជាសារវន្ត នោះសំវិធានធននឹងអប្បហារដោយប្រើប្រាស់អត្រាមុនគិតពន្ធក្នុងគ្រា ដែលឆ្លុះបញ្ចាំង (ដែលសមរម្យ) អំពីហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ នៅពេលដែលការធ្វើអប្បហារត្រូវបានបើប្រាស់ កំណើននៃសំវិធានធនដោយសារ ពេលវេលាកន្លងផុតត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

បំណុលយថាភាព មិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។ បំណុលយថាភាពត្រូវបានលាតត្រដាង ប្រសិនបើលទ្ធភាពនៃលំហូរចេញនៃធនធានតំណាងផលប្រយោជន៍សេដ្ឋកិច្ចមានកម្រិតទាប។ ទ្រព្យសកម្មយថាភាពមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវបានលាតត្រដាងនៅពេល ដែលលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអាចកើតមាន។ ទ្រព្យសកម្មយថាភាព ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដើម្បីធានាថាការអភិវឌ្ឍន៍ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើមានភាពពិតប្រាកដថាលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងកើតឡើង ទ្រព្យសកម្ម និងប្រាក់ចំណូលដែលពាក់ព័ន្ធត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

នៅពេលដែលការចំណាយមួយចំនួន ឬ ទាំងអស់តម្រូវឲ្យទូទាត់សំវិធានធន ត្រូវបានរំពឹងថានឹងត្រូវសងដោយភាគីផ្សេងមួយទៀត សំណងនឹងត្រូវទទួលស្គាល់ថានៅពេលដែល នឹងតែនៅពេលដែល ភាពប្រាកដប្រជានៃសំណងនឹងទទួលបានប្រសិនបើក្រុមហ៊ុនទូទាត់កាតព្វកិច្ច។ សំណងត្រូវចាត់ទុកជាទ្រព្យសកម្មដាច់ដោយឡែក។ ចំនួនទឹកប្រាក់បានទទួលស្គាល់សម្រាប់សំណង មិនត្រូវលើសពីទឹកប្រាក់សំវិធានធនទេ។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២៦ ការរាយការណ៍តាមផ្នែក*

ប្រតិបត្តិការតាមផ្នែកត្រូវបានរាយការណ៍ឲ្យស៊ីសង្វាក់ជាមួយនឹងការរាយការណ៍ផ្ទៃក្នុង ដែល បាន ផ្តល់ជូនប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (អគ្គនាយក)។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ជាអ្នកទទួលខុសត្រូវលើការបែងចែកធនធាន និងជាអ្នកវាយតម្លៃលទ្ធផលប្រតិបត្តិការតាមផ្នែក) ត្រូវបានកំណត់ជាក្រុមគណៈគ្រប់គ្រង (រួមបញ្ចូលទាំងអគ្គនាយកទូទៅ និង អគ្គនាយករងទាំងអស់) ដែលធ្វើការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រ។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRSs តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលប៉ះពាល់ដល់តួរលេខដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការកំណត់សម្គាល់ដែលភ្ជាប់ជាមួយ។

នៅក្នុងមតិយោបល់របស់គណៈគ្រប់គ្រង របាយការណ៍ហិរញ្ញវត្ថុទាំងនេះឆ្លុះបញ្ចាំងពីការកែតម្រូវទាំងអស់ដែលចាំបាច់ដើម្បីបង្ហាញលទ្ធផលសមស្រប សម្រាប់ការិយបរិច្ឆេទដែលបានបង្ហាញ។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនេះ ហើយឥទ្ធិពលនៃការផ្លាស់ប្តូរណាមួយនៅក្នុងការប៉ាន់ស្មាន នឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលការប៉ាន់ស្មានទាំងនេះត្រូវបានកំណត់ដោយសមហេតុផល។

*ការវិនិច្ឆ័យ*

នៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យដូចខាងក្រោម ក្រៅពីអ្វីដែលមានការទាក់ទងនឹងការប៉ាន់ស្មាន ដែលមានឥទ្ធិពលខ្លាំងបំផុតទៅលើទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

*ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន*

ក្រុមហ៊ុនបានអនុវត្តការវិនិច្ឆ័យដូចខាងក្រោមដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ការកំណត់ចំនួន និងពេលវេលានៃប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជនៈ

- *ការកំណត់អត្តសញ្ញាណកាតព្វកិច្ចអនុវត្ត*

  ក្រុមហ៊ុនកំណត់កាតព្វកិច្ចអនុវត្តដោយពិចារណា ថាតើសេវាកម្មដែលបានសន្យានៅក្នុងកិច្ចសន្យាមានភាពខុសគ្នាដែរ ឬ ទេ។ សេវាកម្មមួយមានភាពខុសគ្នានៅពេលដែលអតិថិជនអាចទទួលបានអត្ថប្រយោជន៍ពីសេវាកម្មដោយខ្លួនឯង ឬ រួមជាមួយធនធានផ្សេងៗដែលមានសម្រាប់អតិថិជន ហើយក្រុមហ៊ុនសន្យាក្នុងការផ្ទេរសេវាកម្មទៅឲ្យអតិថិជន អាចកំណត់អត្តសញ្ញាណដាច់ដោយឡែកពីការសន្យាផ្សេងទៀតនៅក្នុងកិច្ចសន្យា។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន* (តពីទំព័រមុន)

- *ការកំណត់អត្តសញ្ញាណកាតព្វកិច្ចអនុវត្ត* (តពីទំព័រមុន)

  ក្រុមហ៊ុនវាយតម្លៃកាតព្វកិច្ចអនុវត្តជាក្រុមនៃទំនិញ និងសេវាកម្មដាច់ដោយឡែកដែលមានលក្ខណៈដូចគ្នា និងមានលំនាំនៃការផ្ទេរដូចគ្នា ប្រសិនបើ (i) រាល់ទំនិញ ឬ សេវាកម្មផ្សេងគ្នាជាក្រុមត្រូវបានផ្ទេរតាមពេលវេលា និង (ii) វិធីសាស្ត្រដូចគ្នានៃវឌ្ឍនភាពនឹងត្រូវបានប្រើ (ឧ. ឯកតានៃការដឹកជញ្ជូន) ដើម្បីវាស់វែងវឌ្ឍនភាពរបស់អង្គភាពឆ្ពោះទៅរកការបំពេញការចិត្ត នៃកាតព្វកិច្ចអនុវត្ត។

- *ការកំណត់ពេលវេលានៃការបំពេញសេវាកម្មកំពង់ផែ*

  ក្រុមហ៊ុនទទួលស្គាល់ប្រាក់ចំណូល នៅពេលដែលបានបំពេញកាតព្វកិច្ចអនុវត្តដែលបានកំណត់ដោយផ្ទេរសេវាកម្មដែលបានសន្យាទៅឲ្យអតិថិជន។ សេវាកម្មមួយត្រូវបានចាត់ទុកថាត្រូវបានផ្ទេរនៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រង។ ក្រុមហ៊ុនកំណត់ (នៅពេលចាប់ផ្តើមកិច្ចសន្យា) ថាតើវានឹងផ្ទេរការគ្រប់គ្រងលើសេវាកម្មដែលបានសន្យាតាមរយៈពេលដែរ ឬទេ។ ប្រសិនបើក្រុមហ៊ុនមិនបំពេញកាតព្វកិច្ចអនុវត្តតាមរយៈពេលនោះ កាតព្វកិច្ចអនុវត្តត្រូវបានបំពេញក្នុងពេលមួយជាក់លាក់។

- *ការកំណត់វិធីសាស្ត្រសម្រាប់ការវាស់វែងវឌ្ឍនភាពនៃប្រាក់ចំណូលដែលត្រូវបានទទួលស្គាល់តាមពេលវេលា*

  ក្រុមហ៊ុនកំណត់វិធីសាស្ត្រសមស្របក្នុងការវាស់វែងវឌ្ឍនភាព ដែលតាមរយៈការប្រើប្រាស់វិធីសាស្ត្រធាតុចូល ឬ ធាតុចេញ។ វិធីសាស្ត្រធាតុចូល ទទួលស្គាល់ប្រាក់ចំណូលដោយផ្អែកលើលទ្ធភាពរបស់ក្រុមហ៊ុន ឬ ធាតុចូលក្នុងការបំពេញកាតព្វកិច្ចអនុវត្ត ខណៈពេលដែលវិធីសាស្ត្រធាតុចេញ ទទួលស្គាល់ប្រាក់ចំណូលដោយផ្អែកលើការវាស់វែងដោយផ្ទាល់នៃតម្លៃដល់អតិថិជននៃសេវាកម្មដែលបានផ្ទេរដល់ការិយបរិច្ឆេទ។

  ក្រុមហ៊ុនបានកំណត់ថា វិធីសាស្ត្រធាតុចេញ ជាវិធីសាស្ត្រល្អបំផុតក្នុងការវាស់វែងវឌ្ឍនភាពសម្រាប់សេវាកម្មកំពង់ផែ ហើយក៏ត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងតម្លៃប្រតិបត្តិការផងដែរ។

- *ការកំណត់វិធីសាស្ត្រក្នុងការប៉ាន់ស្មានការពិចារណាអថេរ និងវាយតម្លៃឧបសគ្គ*

  ក្រុមហ៊ុនរួមបញ្ចូលនូវចំនួនមួយចំនួន ឬ ទាំងអស់នៃការពិចារណាអថេរដែលបានប៉ាន់ស្មាន ប៉ុន្តែត្រឹមតែក្នុងកម្រិត ដែលវាមានលទ្ធភាពខ្ពស់នៃការកត់ត្រាបញ្រ្ចាស់យ៉ាងសំខាន់នៃចំណូលបង្គបានទទួលស្គាល់ នឹងមិនកើតឡើងនៅពេលដែលភាពមិនច្បាស់លាស់ដែលទាក់ទងនឹងការពិចារណាអថេរត្រូវបានដោះស្រាយជាបន្តបន្ទាប់។ ក្រុមហ៊ុនពិចារណាទាំងលទ្ធភាព និងទំហំនៃការកត់ត្រាបញ្រ្ចាសនៃប្រាក់ចំណូល ក្នុងការវាយតម្លៃវិសាលភាពនៃការពិចារណាអថេរដែលក្រុមហ៊ុននឹងត្រូវដាក់កំហិត។ កត្តាដូចជា (i) ភាពងាយរងគ្រោះខ្លាំងចំពោះកត្តាដែលនៅក្រៅឥទ្ធិពលរបស់ក្រុមហ៊ុន (ii) ពេលវេលានៃការដោះស្រាយភាពមិនច្បាស់លាស់ និង (iii) មានចំនួនច្រើន និងទូលំទូលាយនៃការពិចារណាដែលអាចធ្វើបាន ត្រូវបានពិចារណា។

### ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន* (តពីទំព័រមុន)

- *ការកំណត់វិធីសាស្ត្រក្នុងការប៉ាន់ស្មានការពិចារណាអថេរ និងវាយតម្លៃឧបសគ្គ* (តពីទំព័រមុន)

  ក្រុមហ៊ុនបានកំណត់ថាវិធីសាស្ត្រតម្លៃដែលរំពឹងទុក គឺជាវិធីសាស្ត្រសមស្របដើម្បីប្រើក្នុងការប៉ាន់ស្មានការពិចារណាអថេរដោយផ្តល់នៃលទ្ធផលអាចកើតមាន។

  មុននឹងរួមបញ្ចូលចំនួនណាមួយនៃការពិចារណាអថេរទៅក្នុងតម្លៃប្រតិបត្តិការ ក្រុមហ៊ុនពិចារណាថាតើតម្លៃនៃការពិចារណាអថេរត្រូវបានរឹតបន្តឹង។ ក្រុមហ៊ុនបានកំណត់ថាការប៉ាន់ស្មាននៃការពិចារណាអថេរត្រូវដាក់រឹតបន្តឹងយ៉ាងពេញលេញ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្ររបស់ខ្លួន (ចន្លោះនៃលទ្ធផលដែលអាចកើតមាន) និងភាពមិនអាចព្យាករណ៍មុនបាននៃកត្តាផ្សេងទៀតនៅខាងក្រៅឥទ្ធិពលរបស់ក្រុមហ៊ុន។

*ចំណាត់ថ្នាក់នៃភតិសន្យា - ក្រុមហ៊ុនជាភតិបតី*

ក្រុមហ៊ុនបានកំណត់ (ដោយផ្អែកលើការវាយតម្លៃបញ្ញត្តិ និងលក្ខខណ្ឌនៃការរៀបចំ ដូចជារយៈពេលជួលនៃការជួលបន្តដែលបង្កើតរយៈពេលដែលនៅសល់នៃការជួល ថាវាមិនរក្សាបាននូវហានិភ័យ និងផលប្រយោជន៍ដែលកើតឡើងចំពោះកម្មសិទ្ធិរបស់ទ្រព្យសម្បត្តិ និងគណនីសម្រាប់កិច្ចសន្យាជាភតិសន្យាហិរញ្ញវត្ថុ។

*ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ*

ក្រុមហ៊ុនអនុវត្តការវិនិច្ឆ័យក្នុងការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ (ឬផ្នែកសមាសភាគរបស់ឧបករណ៍ហិរញ្ញវត្ថុ) លើការទទួលស្គាល់ដំបូងជាទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬ ឧបករណ៍មូលធនស្របតាមខ្លឹមសារនៃការរៀបចំកិច្ចសន្យា និងនិយមន័យនៃទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬ ឧបករណ៍មូលធន។ ខ្លឹមសារនៃឧបករណ៍ហិរញ្ញវត្ថុ (ជាជាងទម្រង់ច្បាប់របស់វា) គ្រប់គ្រងការចាត់ថ្នាក់របស់ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ការវាស់វែងតម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ*

នៅពេលវាស់តម្លៃទីផ្សារនៃទ្រព្យសកម្ម ឬ បំណុល ក្រុមហ៊ុនប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានតាមទីផ្សារតាមដែលអាចធ្វើទៅបាន។ តម្លៃទីផ្សារ ត្រូវបានចាត់ថ្នាក់ទៅតាមកម្រិតផ្សេងៗគ្នាក្នុងឋានានុក្រមតម្លៃសមរម្យ ដោយផ្អែកលើធាតុចូលដែលបានប្រើក្នុងបច្ចេកទេសវាយតម្លៃខាងក្រោម៖

កម្រិតទី១៖ តម្លៃដែលបានដកស្រង់ (មិនបានកែតម្រូវ) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ បំណុលដូចគ្នា។

កម្រិតទី២៖ ធាតុចូលក្រៅពីតម្លៃដែលបានដកស្រង់ដែលបានរួមបញ្ចូលក្នុងកម្រិតទី១ ដែលអាចសង្កេតបានលើទ្រព្យសកម្ម ឬ បំណុលដោយផ្ទាល់ (ឧ. ជាតម្លៃ) ឬ ដោយប្រយោល (ឧ. បានមកពីតម្លៃ)។

កម្រិតទី៣៖ ធាតុចូលនៃទ្រព្យសកម្ម ឬ បំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុដែលមិនអាចសង្កេតបាន)។

## ៤. **ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ** (តពីទំព័រមុន)

***ការវិនិច្ឆ័យ*** (តពីទំព័រមុន)

*ការវាស់វែងតម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ* (តពីទំព័រមុន)

នៅពេលដែលតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មិនអាចវាស់វែងបានដោយផ្អែកលើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម តម្លៃសមស្របរបស់ពួកគេត្រូវបានវាស់វែងដោយប្រើបច្ចេកទេសវាយតម្លៃ រួមទាំងលំហូរសាច់ប្រាក់អប្បហារ ("DCF")។ ធាតុចូលសម្រាប់ម៉ូឌែលទាំងនេះគឺត្រូវបានយកចេញពីទីផ្សារដែលអាចសង្កេតបាន (ប្រសិនបើអាចធ្វើទៅបាន) ប៉ុន្តែនៅពេលដែលវាមិនអាចទៅរួចកម្រិតនៃការវិនិច្ឆ័យគឺត្រូវបានតម្រូវឲ្យបង្កើតតម្លៃសមស្រប។ ការវិនិច្ឆ័យរួមមានការពិចារណាលើធាតុចូលដូចជា ហានិភ័យសន្ទនីយភាពសាច់ប្រាក់ ហានិភ័យឥណទាន និងម៉ូឌែលធាតុចូលដូចជាការប្រែប្រួលសម្រាប់និស្សន្ទវត្ថុដែលមានកាលបរិច្ឆេទយូរជាង និងអត្រាអប្បហារ អត្រាការបង់ប្រាក់មុន និងការសន្មតអត្រាលំនាំដើមសម្រាប់មូលបត្រដែលផ្អែកលើទ្រព្យសកម្ម។

សម្រាប់ការវិភាគលំហូរសាច់ប្រាក់អប្បហារ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត និងអត្រាអប្បហារ គឺផ្អែកលើព័ត៌មានទីផ្សារបច្ចុប្បន្ន និងអត្រាអនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុដែលគុណភាពឥណទាន និងលក្ខណៈដែលដល់កាលកំណត់ស្រដៀងគ្នា។ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតត្រូវបានជះឥទ្ធិពលដោយកត្តាដូចជា លក្ខខណ្ឌសេដ្ឋកិច្ច (រួមទាំងហានិភ័យជាក់លាក់របស់ប្រទេស) ការប្រមូលផ្តុំនៅក្នុងឧស្សាហកម្មជាក់លាក់ ប្រភេទឧបករណ៍ ឬរូបិយប័ណ្ណ សាច់ប្រាក់ងាយស្រួលទីផ្សារ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់ដៃគូ។ អត្រាអប្បហារត្រូវបានជះឥទ្ធិពលដោយមិនមានហានិភ័យអត្រាការប្រាក់ និងហានិភ័យឥណទាន។ បម្រែបម្រួលនៃការសន្មតទាក់ទងនឹងកត្តាទាំងនេះអាចប៉ះពាល់ដល់តម្លៃទីផ្សារ ដែលបានរាយការណ៍នៅក្នុងឧបករណ៍ហិរញ្ញវត្ថុ។

*រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ*

ស្តង់ដារ CIAS ២១ ស្តីពីផលប៉ះពាល់នៃការប្តូរអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស តម្រូវឲ្យគណៈគ្រប់គ្រងប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន ដើម្បីកំណត់នូវរូបិយប័ណ្ណមុខងាររបស់ក.ស.ស ដែលវាបង្ហាញយ៉ាងច្បាស់នូវឥទ្ធិពលសេដ្ឋកិច្ច នៃប្រតិបត្តិការព្រឹត្តិការណ៍ និងលក្ខខណ្ឌទាំងឡាយដែលមានការពាក់ព័ន្ធទៅនឹងក.ស.ស។ ដើម្បីធ្វើការវិនិច្ឆ័យនេះ ក.ស.ស ត្រូវពិចារណាដូចខាងក្រោម៖

(i) រូបិយប័ណ្ណដែលមានឥទ្ធិពលជាសារវន្តលើតម្លៃឧបករណ៍ហិរញ្ញវត្ថុ និងសេវាកម្ម (នេះច្រើនតែជារូបិយប័ណ្ណដែលដាក់តម្លៃលើឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន និង សេវាត្រូវបានកំណត់ និងធ្វើការទូទាត់)

(ii) រូបិយប័ណ្ណមានក្នុងមូលនិធិដែលទទួលបានពីសកម្មភាពហិរញ្ញប្បទាន និង

(iii) រូបិយប័ណ្ណដែលចំណូលទទួលបានពីសកម្មភាពប្រតិបត្តិការ តែងតែត្រូវបានរក្សាទុក។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ* (តពីទំព័រមុន)

ដោយផ្អែកទៅតាមខ្លឹមសារសេដ្ឋកិច្ច នៃព្រឹត្តិការណ៍ និងហេតុការណ៍សំខាន់ៗ របស់ក.ស.ស

រូបិយប័ណ្ណមុខងាររបស់ ក.ស.ស ត្រូវបានកំណត់ជាខ្មែររៀល។ ខ្មែររៀល គឺជារូបិយប័ណ្ណ នៃស្ថានភាពសេដ្ឋកិច្ចចម្បងក្នុងប្រតិបត្តិការរបស់ ក.ស.ស និងជារូបិយប័ណ្ណមានឥទ្ធិពលចម្បងទៅលើចំណូល និងចំណាយ។

*ការប៉ាន់ស្មាន និងការសន្មត*

ការសន្មតសំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃភាពមិនប្រាកដប្រជានៃការប៉ាន់ស្មាននាកាលបរិច្ឆេទរបាយការណ៍ ដែលមានហានិភ័យជាសារវន្តក្នុងការបង្កឲ្យមានការកែតម្រូវជាសារវន្តទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ត្រូវបានពិពណ៌នាខាងក្រោម។ ក្រុមហ៊ុនផ្អែកលើការសន្មត និងការប៉ាន់ស្មានរបស់ខ្លួនលើព័ត៌មានដែលមាននៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ។ ទោះជាយ៉ាងនេះក្តី កាលៈទេសៈ និងការសន្មតដែលមានស្រាប់អំពីការវិវឌ្ឍនាពេលអនាគតអាចផ្លាស់ប្តូរដោយសារតែ បម្រែបម្រួលទីផ្សារ ឬ កាលៈទេសៈដែលកើតឡើងដែលក្រុមហ៊ុនមិនអាចគ្រប់គ្រងបាន។ បម្រែបម្រួលបែបនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសន្មតនៅពេលដែលវាកើតឡើង។

*សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុកចំពោះគណនីអតិថិជន*

ការវាស់វែងសំវិធានធន នៃការខាតបង់ឥណទានដែលរំពឹងទុកចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមវិធីរំលស់ថ្លៃដើម និង FVOCI គឺជាផ្នែកដែលទាមទារការប្រើប្រាស់ម៉ូឌែលស្មុគស្មាញ និងការសន្មតសំខាន់ៗអំពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត និងឥរិយាបទឥណទាន (ឧទាហរណ៍ លទ្ធភាពនៃការខូចខាតរបស់អតិថិជន និងលទ្ធផលខាតបង់)។

ក.ស.ស អនុវត្តស្តង់ដារ CIFRS ៩ តាមវិធីសាស្រ្តសាមញ្ញ ក្នុងការវាស់វែកការខាតបង់ឥណទានដែលរំពឹងទុក (ECL) ដែលប្រើការខាតបង់ដែលរំពឹងទុកមួយអាយុកាល (Lifetime ECL) សម្រាប់គណនីអតិថិជនទាំងអស់។

ដើម្បីវាស់វែងការបាត់បង់ឥណទានដែលរំពឹងទុក គណនីអតិថិជនត្រូវបានចាត់ថ្នាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យឥណទានរួម និងថ្ងៃផុតកំណត់។

*ពន្ធ*

ពន្ធត្រូវបានគណនាលើមូលដ្ឋាននៃបទប្បញ្ញត្តិច្បាប់ពន្ធ និងការបកស្រាយនាពេលបច្ចុប្បន្ន។ តែទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះមានការប្រែប្រួលតាមកាលកំណត់ ហើយការកំណត់ចុងក្រោយលើចំណាយពន្ធ នឹងត្រូវធ្វើតាមការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ ("GDT")។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយនៃបញ្ហាទាំងនេះ ខុសពីចំនួនដែលបានកត់ត្រាដំបូងដោយក្រុមហ៊ុន ភាពខុសគ្នានេះនឹងជះឥទ្ធិពលលើសំវិធានធនពន្ធលើប្រាក់ចំណូល និងពន្ធពន្យារក្នុងគ្រាដែលការកំណត់ចុងក្រោយនេះត្រូវបានធ្វើឡើងដោយ GDT។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការប៉ាន់ស្មាន និងការសន្មត* (តពីទំព័រមុន)

*តម្លៃពិតជាក់ស្តែងសុទ្ធនៃសន្និធិ*

ក្រុមហ៊ុនលុបថ្លៃដើមនៃសន្និធិ ដែលបណ្តាលមកពីការខូចខាត ខូចទ្រង់ទ្រាយនៃរូបរាង ភាពហួសសម័យ បម្រែបម្រួលកម្រិតតម្លៃ ឬ មូលហេតុផ្សេងៗ។ តម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃពិតជាក់ស្តែងសុទ្ធរបស់សន្និធិ ត្រូវបានពិនិត្យជារៀងរាល់ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ធាតុនៃសន្និធិ ដែលត្រូវបានកំណត់ថាលែងប្រើប្រាស់ និងមិនអាចប្រើប្រាស់បានក៏ត្រូវបានលុបចេញ និងគិតជាការចំណាយសម្រាប់ការិយបរិច្ឆេទការរាយការណ៍។

*ការប៉ាន់ស្មាន់អាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបី*

អាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបី ត្រូវបានប៉ាន់ស្មានដោយផ្អែកលើរយៈពេលដែលទ្រព្យសកម្មទាំងនេះ ត្រូវបានគេរំពឹងថានឹងមានសម្រាប់ប្រើប្រាស់។ អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មទាំងនេះត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពប្រសិនបើមានការរំពឹងទុកខុសពីការប៉ាន់ស្មានពីមុន ដោយសារតែភាពហួសសម័យ បច្ចេកទេស និងពាណិជ្ជកម្ម និងដែនកំណត់ផ្សេងទៀតលើការប្រើប្រាស់ទ្រព្យសកម្ម។ រាល់ការថយចុះនៃតម្លៃកាកសំណល់ និងការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃទ្រព្យ រោងចក្រនិងបរិក្ខារ និងទ្រព្យអរូបី អាចបង្កើនការចំណាយប្រតិបត្តិការដែលបានកត់ត្រារបស់ក្រុមហ៊ុន និងកាត់បន្ថយទ្រព្យសកម្មដែលពាក់ព័ន្ធ។

*ការវាស់វែងតម្លៃសមស្របនៃទ្រព្យវិនិយោគ*

តម្លៃសមស្របនៃទ្រព្យវិនិយោគ ត្រូវបានកំណត់ដោយការប្រើប្រាស់បច្ចេកទេសវាយតម្លៃ។ សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីវិធីសាស្ត្រនៃការវាយតម្លៃ សូមមើលនូវកំណត់សម្គាល់លេខ ៧។

*អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

ក្រុមហ៊ុនវាយតម្លៃរាល់កាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ថាតើមានសូចនាករណាមួយនៃអ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទាំងអស់ (ទ្រព្យ រោងចក្រនិងបរិក្ខារ និងទ្រព្យអរូបី)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទាំងនេះ ត្រូវបានពិនិត្យមើលថាមានអ៊ីមភែរមិន នៅពេលណាដែលព្រឹត្តិការណ៍ ឬ បម្រែបម្រួលកាលៈទេសៈណាមួយបង្ហាញថាតម្លៃយោងនៃទ្រព្យសកម្ម អាចនឹងមិនអាចប្រមូលមកវិញបាន។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការប៉ាន់ស្មាន និងការសន្មត* (តពីទំព័រមុន)

*អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ* (តពីទំព័រមុន)

ទាំងនេះតម្រូវឲ្យមានការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម។ តម្លៃដែលអាចប្រមូលមកវិញបាន ជាតម្លៃដែលខ្ពស់ជាងវាងតម្លៃសមស្របរបស់ទ្រព្យសកម្មមួយ ដកចំណាយក្នុងការលក់ និងតម្លៃប្រើប្រាស់។ តម្លៃសមស្រប ដកថ្លៃដើមដើម្បីលក់ ជាតម្លៃដែលអាចទទួលបានពីការលក់ទ្រព្យសកម្មក្នុងប្រតិបត្តិការជហោងដៃ (arm's length transaction) ខណៈពេលដែលតម្លៃប្រើប្រាស់ ជាតម្លៃបច្ចុប្បន្ននៃការរំពឹងទុកនៃលំហូរសាច់ប្រាក់បានប៉ាន់ស្មាននាពេលអនាគត ថានឹងកើតឡើងពីការបន្តប្រើប្រាស់ទ្រព្យសកម្ម និងពីការលក់ទ្រព្យសកម្មនោះនៅចុងបញ្ចប់អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ។ តម្លៃដែលអាចទទួលបានមកវិញត្រូវបានប៉ាន់ស្មានចំពោះទ្រព្យសកម្មនីមួយៗ (ប្រសិនបើវាមិនអាចធ្វើទៅបាន) សម្រាប់ឯកតាបង្កើតសាច់ប្រាក់ដែលជាកម្មសិទ្ធិរបស់ទ្រព្យសកម្ម។

*ការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ*

ក្រុមហ៊ុនពិនិត្យលើតម្លៃយោង នៃទ្រព្យសកម្មពន្ធពន្យារនៅចុងគ្រានៃកាលបរិច្ឆេទរាយការណ៍នីមួយៗ និងកាត់បន្ថយពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ដល់កម្រិតមួយដែលវាលែងមានលទ្ធភាពដែលនឹងអាចមានប្រាក់ចំណូលជាប់ពន្ធគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យប្រើប្រាស់ទាំងអស់ ឬ ផ្នែកមួយនៃពន្ធពន្យារលើប្រាក់ចំណូល។

*កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ពឹងផ្អែកលើកត្តាមួយចំនួន ដែលត្រូវបានកំណត់នៅក្នុងមូលដ្ឋានការគណនា/វាយតម្លៃ (actuarial) ដោយប្រើការប៉ាន់ស្មានមួយចំនួន។ ការប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃសុទ្ធនៃប្រាក់ចូលនិវត្តន៍រួមមាន អត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សន៍ អត្រាចលនានៃបុគ្គលិក និងការរំពឹងទុកអាយុជីវិត។ បម្រែបម្រួលណាមួយក្នុងប៉ាន់ស្មានទាំងនេះ នឹងប៉ះពាល់ដល់ តម្លៃយោងគណនេយ្យនៃកាតព្វកិច្ចប្រាក់សោធននិវត្តន៍។

## ៥. ព័ត៌មានតាមផ្នែក

ចំណូលសំខាន់ៗ បានមកពីសេវាកំពង់ផែ។ លើសពីនេះ ក.ស.ស ក៏មានតំបន់សេដ្ឋកិច្ចពិសេសដែលកំពុងធ្វើប្រតិបត្តិការជាភតិបតី និងរកចំណូលបានពីការជួលផងដែរ*(កំណត់សម្គាល់លេខ ៧)*។

ក.ស.ស មានប្រតិបត្តិការតាមផ្នែកមួយដែលអាចរាយការណ៍បាន ហៅថាសេវាកំពង់ផែ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (អគ្គនាយកប្រតិបត្តិ) ពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផលនៃសេវាតាមផ្នែករបស់កំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ ("CODM") ដោយផ្អែកការវាស់វែងចំណូលដុល។ CODM ក៏ពិនិត្យឡើងវិញលើចំណេញមុនគិតពន្ធ និងចំណេញសុទ្ធទាំងមូលធៀបនឹងការិយបរិច្ឆេទមុនៗ។

ក.ស.ស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយប្រាក់ចំណូលភាគច្រើនមានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

ប្រាក់ចំណូលចំនួន ១២២.១៥២ ពាន់រៀល បានមកពីអតិថិជនធំៗចំនួនបីក្រុមហ៊ុនក្នុងអំឡុងឆ្នាំ។

## ៦. ទ្រព្យ និងបរិក្ខារ

| | *២០២២* | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | *ដីធ្លី* | *ការកែលម្អដីធ្លី* | *អគារ* | *បរិក្ខារ បច្ចេកទេស* | *គ្រឿងសង្ហារិម និងបរិក្ខារបំពាក់* | *កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ* | *យានយន្ត* | *បរិក្ខារ កំពង់ផែសមុទ្រ* | *ប៉ាឡែត* | *សំណង់កំពុង សាងសង់* | *សរុប* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ២៩៦.៧៣៥.៤០៩ | ៥៨.៨៥០.៩២២ | ៣៤៧.៥០៧.៦៩៥ | ៣៧.៥០៨.១០០ | ២.៤៧១.៧៧៦ | ១១.៧២៨.១២៦ | ៤៨.៨០៤.៦៥៩ | ២៧៦.៩៦៦.៩៦៩ | ១.០២២.៧៦១ | ២៥.៥២៤.៨០១ | ១.១០៧.១២១.២១៨ |
| ទិញបន្ថែម | - | ១.៥១៧.៣០៦ | ១.៦៥០.៨០៥ | ២.២៣៤.២១៧ | ៣៨៥.៣៣៣ | ១.៤៥៩.១៥២ | ១២.៤៧៧.០៣៥ | ៥៨៧.៤០៨ | ៩៤.០៩៤ | ១៦.០២០.៦៩៥ | ៣៦.៤២៦.០៤៥ |
| ការលក់ | - | - | - | - | - | - | (៩៧៣.១០០) | - | - | - | (៩៧៣.១០០) |
| ការផ្ទេរ | - | - | ៩៩.៥៥៨ | - | - | - | - | - | - | (៩៩.៥៥៨) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២៩៦.៧៣៥.៤០៩** | **៦០.៣៦៨.២២៨** | **៣៤៩.២៥៨.០៥៨** | **៣៩.៧៤២.៣១៧** | **២.៨៥៧.១០៩** | **១៣.១៨៧.២៧៨** | **៦០.៣០៨.៥៩៤** | **២៧៧.៥៥៤.៣៧៧** | **១.១១៦.៨៥៥** | **៤១.៤៤៥.៩៣៨** | **១.១៤២.៥៧៤.១៦៣** |
| **រំលស់បង្គរ** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | (៧.៣២២.៣៣៧) | (៣៩.៩២៣.១៩៣) | (១៣.៨២៧.៥៤១) | (១.៧៦៣.១២០) | (៧.៧១២.៦១១) | (១៣.២៥២.៣៣២) | (៥៦.១៣៦.៨៤៣) | (១.០១៧.៣៩៧) | - | (១៤០.៩៥៥.៣៧៤) |
| រំលស់ | - | (២.៩៦២.៥២១) | (៩.៧០៩.៩៤៦) | (៤.១០២.៤៨៣) | (៤៧០.៦០០) | (២.៧៤២.៣៥៤) | (៤.៣៨៦.៥២១) | (១៣.៩៥៨.៦២៥) | (១៩.៥២០) | - | (៣៨.៣៥២.៥៧០) |
| ការលក់ | - | - | - | - | - | - | ៤៤៦.៥៦២ | - | - | - | ៤៤៦.៥៦២ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **(១០.២៨៤.៨៥៨)** | **(៤៩.៦៣៣.១៣៩)** | **(១៧.៩៣០.០២៤)** | **(២.២៣៣.៧២០)** | **(១០.៤៥៤.៩៦៥)** | **(១៧.១៩២.២៩១)** | **(៧០.០៩៥.៤៦៨)** | **(១.០៣៦.៩១៧)** | **-** | **(១៧៨.៨៦១.៣៨២)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | | | | | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២៩៦.៧៣៥.៤០៩** | **៥០.០៨៣.៣៧០** | **២៩៩.៦២៤.៩១៩** | **២១.៨១២.២៩៣** | **៦២៣.៣៨៩** | **២.៧៣២.៣១៣** | **៤៣.១១៦.៣០៣** | **២០៧.៤៥៨.៩០៩** | **៧៩.៩៣៨** | **៤១.៤៤៥.៩៣៨** | **៩៦៣.៧១២.៧៨១** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៦. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

| | *២០២១* | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | *ដីធ្លី* | *ការកែលម្អដីធ្លី* | *អគារ* | *បរិក្ខារ បច្ចេកទេស* | *គ្រឿងសង្ហារិម និងបរិក្ខារបំពាក់* | *កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ* | *យានយន្ត* | *បរិក្ខារ កំពង់ផែសមុទ្រ* | *ប៉ាឡែត* | *សំណង់កំពុង សាងសង់* | *សរុប* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ២៥០.៩២៩.៩០៩ | ៣៨.១២១.៦៣៨ | ៣៤៦.៦៩៣.៩៣៥ | ៣៥.៨២៨.៣៣៤ | ២.១៣៦.៣៤៦ | ៩.០៣៨.៧៤៦ | ៤១.៨៩៥.៦៥៥ | ២៣២.០៨៨.៣៥៥ | ១.០២២.៧៦១ | ៦៦.២៥៦.៣២៧ | ១.០២៤.០១២.០០៦ |
| ទិញបន្ថែម | ៤៥.៨០៥.៥០០ | ៦៨១.១៥២ | ៨១៣.៧៦០ | ៣២០.៦៦៦ | ៣៣៥.៤៣០ | ២.៦៨៩.៣៨០ | ៧.០៩២.២៨៤ | ៧.៤១៨.៥៦០ | - | ១៨.១៣៥.៧៦០ | ៨៣.២៩២.៤៩២ |
| លុបចោល | - | - | - | - | - | - | (១៨៣.២៨០) | - | - | - | (១៨៣.២៨០) |
| ការផ្ទេរ | - | ២០.០៤៨.១៣២ | - | ១.៣៥៩.១០០ | - | - | - | ៣៧.៤៦០.០៥៤ | - | (៥៨.៨៦៧.២៨៦) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **២៩៦.៧៣៥.៤០៩** | **៥៨.៨៥០.៩២២** | **៣៤៧.៥០៧.៦៩៥** | **៣៧.៥០៨.១០០** | **២.៤៧១.៧៧៦** | **១១.៧២៨.១២៦** | **៤៨.៨០៤.៦៥៩** | **២៧៦.៩៦៦.៩៦៩** | **១.០២២.៧៦១** | **២៥.៥២៤.៨០១** | **១.១០៧.១២១.២១៨** |
| **រំលស់បង្គរ** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | (៥.៧៥០.៥៤១) | (៣០.២៧៨.៦៦៣) | (៩.៨១១.១៨៥) | (១.៣២៩.៧០៦) | (៦.៣២៧.១៨៩) | (៩.៦៣៨.៤៥៧) | (៤៤.៥៣៤.៧៤៥) | (៩៧២.៥០៥) | - | (១០៨.៦៤២.៩៩១) |
| រំលស់ | - | (១.៥៧១.៧៩៦) | (៩.៦៤៤.៥៣០) | (៤.០១៦.៣៥៦) | (៤៣៣.៤១៤) | (១.៣៨៥.៤២២) | (៣.៧៩៧.១៥៥) | (១១.៦០២.០៩៨) | (៤៤.៨៩២) | - | (៣២.៤៩៥.៦៦៣) |
| លុបចោល | - | - | - | - | - | - | ១៨៣.២៨០ | - | - | - | ១៨៣.២៨០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **-** | **(៧.៣២២.៣៣៧)** | **(៣៩.៩២៣.១៩៣)** | **(១៣.៨២៧.៥៤១)** | **(១.៧៦៣.១២០)** | **(៧.៧១២.៦១១)** | **(១៣.២៥២.៣៣២)** | **(៥៦.១៣៦.៨៤៣)** | **(១.០១៧.៣៩៧)** | **-** | **(១៤០.៩៥៥.៣៧៤)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | | | | | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **២៩៦.៧៣៥.៤០៩** | **៥១.៥២៨.៥៨៥** | **៣០៧.៥៨៤.៥០២** | **២៣.៦៨០.៥៥៩** | **៧០៨.៦៥៦** | **៤.០១៥.៥១៥** | **៣៥.៥៥២.៣២៧** | **២២០.៨៣០.១២៦** | **៥.៣៦៤** | **២៥.៥២៤.៨០១** | **៩៦៦.១៦៥.៨៤៤** |

## ៦. **ទ្រព្យ និងបរិក្ខារ** (តពីទំព័រមុន)

សូមយោងទៅលើការផ្ទៀងផ្ទាត់ជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់នៃការទិញបន្ថែមខាងក្រោម (ការទិញទ្រព្យ និងបរិក្ខារ) សម្រាប់កាលបរិច្ឆេទបញ្ចប់។

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ការទិញ (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) ក្នុងគ្រា (មិនរួមបញ្ចូលថ្លៃកម្ចីមូលធន) | ៣៦.២៩១.៨៥៦ | ៨៣.១៩៥.៧៨៤ |
| (កំណើន) តំហយទឹកប្រាក់ត្រូវទូទាត់ទៅអ្នកផ្គត់ផ្គង់ | (១.៨៥៩.០៣០) | ២.១៨៥.៩៥៤ |
| **សាច់ប្រាក់ដែលប្រើក្នុងការទិញទ្រព្យ និង បរិក្ខារ** | **៣៤.៣៨២.៨២៦** | **៨៥.៣៣១.២៣៨** |

ចំណាយការប្រាក់លើកម្ចី ដែលត្រូវបានធ្វើមូលធនកម្មលើទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កាលបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានចំនួន ១៨៤.១៨៩ ពាន់រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ១៩៦.៧០៨ ពាន់រៀល)។

តារាងខាងក្រោមសង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោង។

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ | ៤៦.៥៤០.៥០០ | ៤៦.៥៤០.៥០០ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ២៥០.១៩៤.៩០៩ | ២៥០.១៩៤.៩០៩ |
| | **២៩៦.៧៣៥.៤០៩** | **២៩៦.៧៣៥.៤០៩** |

ដីដែលមិនមានប័ណ្ណកម្មសិទ្ធិ ជាដីដែលមានប័ណ្ណកម្មសិទ្ធិប្លង់ទន់ចុះបញ្ជីត្រឹមស្រុក។

## ៧. ទ្រព្យវិនិយោគ

| | *ដីធ្លី* | *អគារ និង ការកែលម្អដីធ្លី* | *សំណង់កំពុង សាងសង់* | *សរុប* |
|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ *(បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* | ១២១.៦៣៣.៥៦៣ | ១៦៨.៥៧៩.៦៥៣ | - | ២៩០.២១៣.២១៦ |
| ទិញបន្ថែម | - | ១៩៥.២៤៥ | ១.០៨២.៤០០ | ១.២៧៧.៦៤៥ |
| ការផ្ទេរ | ១.០៨២.៤០០ | - | (១.០៨២.៤០០) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១២២.៧១៥.៩៦៣** | **១៦៨.៧៧៤.៨៩៨** | **-** | **២៩១.៤៩០.៨៦១** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | (៣៧.០១៧.៥១៧) | - | (៣៧.០១៧.៥១៧) |
| រំលស់ | - | (៦.១៧៦.៦៣៩) | - | (៦.១៧៦.៦៣៩) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **(៤៣.១៩៤.១៥៦)** | **-** | **(៤៣.១៩៤.១៥៦)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១២២.៧១៥.៩៦៣** | **១២៥.៥៨០.៧៤២** | **-** | **២៤៨.២៩៦.៧០៥** |

| | *ដីធ្លី* | *អគារ និង ការកែលម្អដីធ្លី* | *សំណង់កំពុង សាងសង់* | *សរុប* |
|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១៣៦.០៣០.៨៨៥ | ១៦៨.១៤០.១៩៩ | ៣៥៩.២៨០ | ៣០៤.៥៣០.៣១៤ |
| ទិញបន្ថែម | - | ១៦៥.៣១០ | ១.៧០៨.៨៦០ | ១.៨៧៤.១៧០ |
| ការផ្ទេរ | ២.០៦៨.១៤០ | - | (២.០៦៨.១៤០) | - |
| ផ្ទេរទៅទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ *(កំណត់សម្គាល់លេខ ១៣)* | (១៣.០៥៨.៧០៨) | - | - | (១៣.០៥៨.៧០៨) |
| ចំណាត់ថ្នាក់ឡើងវិញ *(កំណត់សម្គាល់លេខ ៣២)* | (៣.៤០៦.៧៥៤) | ២៧៤.១៩៤ | - | (៣.១៣២.៥៦០) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** *(បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* | **១២១.៦៣៣.៥៦៣** | **១៦៨.៥៧៩.៦៥៣** | **-** | **២៩០.២១៣.២១៦** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | (៣០.៦៩៤.៨៤៧) | - | (៣០.៦៩៤.៨៤៧) |
| រំលស់ | - | (៦.៣២២.៦៧០) | - | (៦.៣២២.៦៧០) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **-** | **(៣៧.០១៧.៥១៧)** | **-** | **(៣៧.០១៧.៥១៧)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** *(បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* | **១២១.៦៣៣.៥៦៣** | **១៣១.៥៦២.១៣៦** | **-** | **២៥៣.១៩៥.៦៩៩** |

## ៧. **ទ្រព្យវិនិយោគ** (តពីទំព័រមុន)

*ដំណើរការនៃការវាយតម្លៃ (បច្ចេកទេស/ធាតុចូល) ប្រើប្រាស់ដើម្បីកំណត់តម្លៃសមស្រប*

ទ្រព្យវិនិយោគត្រូវបានវាយតម្លៃ ដោយក្រុមហ៊ុនវាយតម្លៃដែលមានការទទួលស្គាល់ដោយ និយ័តករមូលបត្រនៃកម្ពុជា។ ក.ស.ស បានទទួលការវាយតម្លៃឯករាជ្យចំពោះទ្រព្យវិនិយោគរបស់ខ្លួន គិតត្រឹមថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ហើយគណៈគ្រប់គ្រងជឿជាក់ថា មិនមានបម្រែបម្រួលជាសារវន្តណាមួយទៅលើការវាយតម្លៃរហូតដល់កាលបរិច្ឆេទការវាយការណ៍នេះទេ។

តម្លៃសមស្របកម្រិតបី របស់ទ្រព្យវិនិយោគ ត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ជាមួយនឹងវិធីសាស្ត្រវាយតម្លៃដីធ្លី និងវិធីសាស្ត្រថ្លៃដើមសម្រាប់អគារ។ ដីធ្លីត្រូវបានវាយតម្លៃដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ គិតទៅតាមដីធ្លីដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ តម្លៃទាំងនេះត្រូវបានកែតម្រូវសម្រាប់ភាពខុសគ្នាក្នុងការសន្មតសំខាន់ៗដូចជា ទំហំ ទីតាំង ស្ថានភាព និងកត្តាពាក់ព័ន្ធផ្សេងទៀត។

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ដីធ្លីតាមតម្លៃសមស្រប | ៣.០៣១.១៩៩.៨៩៦ | ២.៨៦២.៧៣២.៥៧៩ |
| អគារ និងការកែលម្អដីធ្លីតាមតម្លៃសមស្រប | ១២០.៥០៥.៥៩០ | ១៣៧.៦៦៨.៦០៨ |
| | **៣.១៥១.៦៥៤.៨៨៦** | **៣.០០០.៤០១.១៨៧** |

តារាងខាងក្រោមនេះសង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោង៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់សេដ្ឋកិច្ចពិសេស(*) | ៨៣.២៧៣.៦០៤ | ៨១.៨០៥.៦១៦ |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់ផ្សេងៗ | ៩.៥០៨.៨៥៥ | ៩.៤០២.៩៥៥ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ៣៩.៩៣៣.៥០៤ | ៣៥.៤២៥.៩៩២ |
| | **១៣២.៧១៥.៩៦៣** | **១២៦.៦៣៣.៥៦៣** |

ចំនួនទឹកប្រាក់ខាងក្រោមដែលត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬ ខាត ដែលបានមកពីការធ្វើអាជីវកម្មនៃទ្រព្យវិនិយោគ៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណូលពីការជួល | ២.៣៧៤.៦៩៦ | ២.១៩៥.៨៦៩ |
| ចំណាយរំលស់ | (៦.១៧៦.៦៣៩) | (៦.៣២២.៦៧០) |
| ចំណាយប្រតិបត្តិការផ្ទាល់ដែលកើតចេញពីទ្រព្យវិនិយោគដែលបង្កើតប្រាក់ចំណូលពីការជួល | (២.៨៦៩.៥៨៥) | (២.៥៩៥.៦០២) |

## ៧. ទ្រព្យវិនិយោគ (តពីទំព័រមុន)

ប្រាក់អប្បបរមាបានពីការជួលទ្រព្យវិនិយោគមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ក្នុងអំឡុង១ឆ្នាំ | ៥៦៨.១៨៦ | ៧៣.៣៣២ |
| ចន្លោះពី១ឆ្នាំ ដល់ ២ឆ្នាំ | ៥៦៨.១៨៦ | ៥៦២.២១២ |
| ចន្លោះពី២ឆ្នាំ ដល់ ៣ឆ្នាំ | ៥៦៨.១៨៦ | ១.៥៣៩.៩៧២ |
| ចន្លោះពី៣ឆ្នាំ ដល់ ៤ឆ្នាំ | ៥៧៦.៣៨០ | ១.៥៣៩.៩៧២ |
| ចន្លោះពី៤ឆ្នាំ ដល់ ៥ឆ្នាំ | ៥៧៦.៣៨០ | ១.៥៥៨.១២០ |
| លើសពី ៥ឆ្នាំ | ៣៨.៤៧២.៧០៦ | ៣៩.៩៧៨.៣៧៤ |
| | **៤១.៣២៩.៨០៤** | **៤៥.២៤១.៩៨២** |

## ៨. ទ្រព្យអរូបី

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | |
| នាថ្ងៃទី១ ខែមករា | ១១.២៨៨.០៨៣ | ១០.៩២១.១៥២ |
| បន្ថែម | ២៥១.២៩៨ | ៣៦៦.៩៣១ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **១១.៥៣៩.៣៨១** | **១១.២៨៨.០៨៣** |
| **រំលស់បង្គរ** | | |
| នាថ្ងៃទី១ ខែមករា | (៦.៣៥១.៧៥១) | (៥.២៤៧.៤០៧) |
| រំលស់ | (១.១៦៨.៥៣៩) | (១.១០៤.៣៤៤) |
| **នាថ្ងៃទី៣១ ខែធ្នូ** | **(៧.៥២០.២៩០)** | **(៦.៣៥១.៧៥១)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៤.០១៩.០៩១** | **៤.៩៣៦.៣៣២** |

## ៩. សន្និធិ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| សម្ភារៈផ្គត់ផ្គង់ប្រើប្រាស់ | ២៥.៥០៧.៥៦៣ | ២៤.០០៧.៧៨៧ |
| វត្ថុធាតុដែលងាយឆេះ | ២.០២១.៦៧៨ | ២.៧០៩.៩៩៧ |
| ប្រេង និងប្រេងរំអិល | ១.៦៤៩.៥២៧ | ១.២៥០.២១៦ |
| សំវិធានធនលើអ៊ីមភែរមិននៃសន្និធិ | (៩៥.៤០៤) | (៧៤២.៩៩៤) |
| | **២៩.០៨៣.៣៦៤** | **២៧.២២៥.០០៦** |

## ៩. **សន្និធិ** (តពីទំព័រមុន)

បម្រែម្រួលនៃសំវិធានធនលើអ៊ីមភែរមិននៃសន្និធិមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៧៤២.៩៩៤ | ៧៤២.៩៩៤ |
| បញ្ច្រាស់ក្នុងអំឡុងគ្រា | (៦៤៧.៥៩០) | - |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៩៥.៤០៤** | **៧៤២.៩៩៤** |

សន្និធិដែលបានទទួលស្គាល់ជាចំណាយសម្រាប់កាលបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានចំនួន ១០២.៣៣៦ លានរៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ៨៩.០០៦ លានរៀល)។

## ១០. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអតិថិជន | ៣០.៥៦៧.៩១០ | ៣៣.៩៨៥.៥១៩ |
| សំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក *(ក)* | (២៣២.៩៥០) | (៣២៩.២៤១) |
| **គណនីអតិថិជនសុទ្ធ** | **៣០.៣៣៤.៩៦០** | **៣៣.៦៥៦.២៧៨** |
| បុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន *(ខ)* | ៧.២២១.៣០៣ | ១.២២១.៣០៣ |
| បុរេប្រទាន | ៣១៤.៤៨៨ | ៦៩៦.៥០២ |
| ចំណាយបង់មុន | ៨៦.១១១ | ៨៥.៨២៨ |
| **គណនីត្រូវទទួលផ្សេងៗ** | **៧.៦២១.៩០២** | **២.០០៣.៦៣៣** |
| | **៣៧.៩៥៦.៨៦២** | **៣៥.៦៥៩.៩១១** |

គណនីអតិថិជនរបស់ ក.ស.ស គឺជាគណនីត្រូវទទួលរយៈពេលខ្លីបានពីក្រុមហ៊ុន និងភ្នាក់ងារដឹកជញ្ជូនក្នុងស្រុក និងអន្តរជាតិ។

(ក) បម្រែបម្រួលសំវិធានធន លើការខាត់បង់ឥណទានរំពឹងទុករបស់គណនីអតិថិជនមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៣២៩.២៤១ | ២.៦៥៥.៤៧៨ |
| បញ្ច្រាស់ក្នុងអំឡុងគ្រា | (៩៦.២៩១) | (២.៣២៦.២៣៧) |
| **នាថ្ងៃទី៣១ ខែធ្នូ** *(កំណត់សម្គាល់លេខ ៣០.១)* | **២៣២.៩៥០** | **៣២៩.២៤១** |

## ១០. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ (តពីទំព័រមុន)

(ខ) គណនីនេះជាសមតុល្យបុរេប្រទានសាច់ប្រាក់ទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានចំនួន ១.២២១.៣០៣ ពាន់រៀល ដោយយោងទៅតាមលិខិតចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ និងត្រូវសងក្នុងឆ្នាំ២០១៩។ បុរេប្រទានសាច់ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់អគារការិយាល័យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ រយៈពេលនៃការទូទាត់សងមិនត្រូវបានបញ្ជាក់។

ក្នុងឆ្នាំ២០២២ បុរេប្រទានសាច់ប្រាក់បន្ថែមចំនួន ៦ ពាន់លានរៀលត្រូវបានផ្តល់ទៅក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីប្រើប្រាស់សម្រាប់ការសាងសង់ផ្លូវ ដោយយោងទៅលិខិតស្នើសុំចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ក្រសួងសាធារណការ និងដឹកជញ្ជូនបានសង ៥ ពាន់លានរៀល ដល់ ក.ស.ស។

បុរេប្រទានដែលនៅសល់របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន មិនទាន់សងនៅឡើយទេ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

## ១១. ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១០០.៨៥២.៥៩០ | ៩៩.៦៣៨.៩៤៤ |
| បង្គរការប្រាក់ត្រូវទទួល | ២.០៧៤.៧៩២ | ១.៦៦៧.៧៣៧ |
| | **១០២.៩២៧.៣៨២** | **១០១.៣០៦.៦៨១** |
| សំវិធានធនសម្រាប់ការបាត់បង់ឥណទានបានរំពឹងទុក | (១៩.១១៨) | - |
| | **១០២.៩០៨.២៦៤** | **១០១.៣០៦.៦៨១** |

ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី គឺជាប្រាក់បញ្ញើមានកាលកំណត់ដែលបានដាក់តម្កល់នៅគ្រឹះស្ថានហិរញ្ញវត្ថុ ហើយមានកាលកំណត់រយៈពេលពី ៦ខែ ទៅ ១២ខែ ហើយទទួលបានការប្រាក់ចន្លោះពី ២,៧៥% ទៅ ៦,៥០% ក្នុងមួយឆ្នាំ (ឆ្នាំ២០២១៖ ២,៧៥% ទៅ ៤,៥០% ក្នុងមួយឆ្នាំ)។

## ១២. សាច់ប្រាក់

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| សាច់ប្រាក់ក្នុងដៃ | ៧៣០.៨១៧ | ១.៣៤១.៨០៨ |
| សាច់ប្រាក់នៅធនាគារ | ២២.៨៥៥.៥៥១ | ២១.១២៧.១២១ |
| | **២៣.៥៨៦.៣៦៨** | **២២.៤៦៨.៩២៩** |

សាច់ប្រាក់នៅធនាគារគឺជាគណនីចរន្ត ដែលមិនមានការប្រាក់ និងបានដាក់តម្កល់នៅធនាគារពាណិជ្ជកម្មក្នុងស្រុក។

## ១៣. ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ក.ស.ស បានចុះហត្ថលេខាលើកិច្ចសន្យាលក់ និងទិញជាមួយអតិថិជនដើម្បីលក់ដីទំនេរមួយកន្លែង (ទំហំ ១៣០ហិកតា) មានទីតាំងស្ថិតនៅឃុំបិតត្រាង ដែលដីនេះត្រូវបានទិញក្នុងគោលបំណងដើម្បីទុកចំណេញ។ តម្លៃក្នុងកិច្ចសន្យាសរុបមានចំនួន ២៦ លានដុល្លារអាមេរិក ឬ ១០៥.៣០០ លានរៀល ដែលមានតម្លៃ ២០ ដុល្លារអាមេរិក ឬ ៨១.០០០ រៀលក្នុងមួយម៉ែត្រការ៉េ។ ក.ស.ស បានទទួលទឹកប្រាក់ចំនួន ២ លានដុល្លារអាមេរិក ជាប្រាក់កក់នៅថ្ងៃចុះកិច្ចសន្យា ហើយអ្នកទិញនឹងទូទាត់ប្រាក់ដែលនៅសល់នៅពេលបញ្ចប់ការផ្ទេរសិទ្ធ។ ទំហំដីអាចនឹងត្រូវកាត់បន្ថយ ក្នុងដំណើរការការផ្ទេរសិទ្ធដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដោយសារគម្រោង និងការសាងសង់ផ្លូវសារធារណៈ)។ អ្នកទិញនឹងទូទាត់តាមទំហំដីដែលបានបញ្ជាក់ក្នុងប្លង់ជាក់ស្តែងក្នុងតម្លៃ ២០ ដុល្លារអាមេរិក ឬ ៨១ ពាន់រៀល ក្នុងមួយម៉ែតការ៉េ។ ពីពេលនោះមក ទ្រព្យសកម្មនោះត្រូវបានចាត់ថ្នាក់ និងបង្ហាញជាទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ មានចំនួន ១៦.៥៨២.១៦១ ពាន់រៀល (ឆ្នាំ២០២១៖ ១៦.១៩១.២៦៨ ពាន់រៀល)។ មិនមានការទទួលស្គាល់ចំណេញណាមួយនោះទេក្នុងអំឡុងឆ្នាំ ដោយសារប្រតិបត្តិនេះមិនទាន់បានបញ្ចប់នៅឡើយ ហើយហានិភ័យ និងកម្មសិទ្ធមិនទាន់ត្រូវបានផ្ទេរទៅអ្នកទិញពេញលេញនោះទេ។

នៅខែមករា ឆ្នាំ២០២៣ ដំណើរការផ្ទេរសិទ្ធិប្លង់រឹងត្រូវបានបញ្ចប់។ តម្លៃចារឹកតាមកិច្ចសន្យាដែលនៅសល់ត្រូវបានទូទាត់ និងទទួលបាននៅខែកុម្ភៈ ឆ្នាំ២០២៣។

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន

| | *ភាគហ៊ុនប្រភេទ "ក"* | | *ភាគហ៊ុនប្រភេទ "ខ"* | | *ភាគហ៊ុនប្រភេទ "គ"* | | *ដើមទុន* | | *បុព្វលាភភាគហ៊ុន* | *សរុប* |
|---|---|---|---|---|---|---|---|---|---|---|
| | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៣៦៤.៥៣០.៨៦១** | **៣៦៤.៥៣០.៨៦១** | **៦៤.៣២៨.៩៧៥** | **៦៤.៣២៨.៩៧៥** | **២១.៤៤២.៩៩២** | **២១.៤៤២.៩៩២** | **៤៥០.៣០២.៨២៨** | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៥១៨.០១៨.០៦៣** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **៣៦៤.៥៣០.៨៦១** | **៣៦៤.៥៣០.៨៦១** | **៦៤.៣២៨.៩៧៥** | **៦៤.៣២៨.៩៧៥** | **២១.៤៤២.៩៩២** | **២១.៤៤២.៩៩២** | **៤៥០.៣០២.៨២៨** | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៥១៨.០១៨.០៦៣** |

(*) យោងតាមមាត្រា ៥ នៃលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ដើមទុនដែលមានស្រាប់ចំនួន ៤២៨.៨៥៩.៨៣៦.០០០ រៀល ត្រូវបានបែងចែកទៅជាភាគហ៊ុនប្រភេទ "ក" ចំនួន ៣៦៤.៥៣០.៨៦១ ហ៊ុន ដើមទុនប្រភេទ "ខ" ចំនួន ៦៤.៣២៨.៩៧៥ ហ៊ុន ដោយមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនទាំងពី ប្រភេទ "ក" និងភាគហ៊ុនប្រភេទ "ខ" ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ភាគហ៊ុនប្រភេទ "ក" មិនមានសិទ្ធិទទួលបានភាគលាភទេ ហើយក៏មិនមានសិទ្ធិបោះឆ្នោតដែរ លើកលែងតែលក្ខខណ្ឌមួយចំនួនដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈក្រុមហ៊ុនចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិទទួលបានភាគលាភ នៅពេលដែលក្រុមប្រឹក្សាភិបាលបានអនុម័ត។

(**) សេចក្ដីលម្អិតនៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតមានដូចខាងក្រោមៈ

| **ភាគហ៊ុនិក** | *ភាគរយ* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* |
|---|---|---|---|
| ភាគហ៊ុនប្រភេទ "ខ" | | | |
| រាជរដ្ឋាភិបាលកម្ពុជា | ៧៥% | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ |
| ភាគហ៊ុនប្រភេទ "គ" | | | |
| ក្រុមហ៊ុន Kamigumi | ១៣% | ១១.១៥០.៣២៤ | ១១.១៥០.៣២៤ |
| អ្នកវិនិយោគសាធារណ | ១២% | ១០.២៩២.៦៦៨ | ១០.២៩២.៦៦៨ |
| | ២៥% | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ |
| | **១០០%** | **៨៥.៧៧១.៩៦៧** | **៨៥.៧៧១.៩៦៧** |

ចំនួនភាគហ៊ុនដែលបានបោះផ្សាយក្នុងប្រភេទ "គ" មានចំនួន ២១.៤៤២.៩៩២ ភាគហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀលក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ "គ" ដែលបានបោះផ្សាយទាំងអស់ ត្រូវបានបង់ប្រាក់រួចរាល់ទាំងស្រុង។

## ១៥. ទុនបម្រុងផ្សេងៗ

| | ២០២២ | ២០២១ |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៣១.៧១៩.៨៣២ | ២៩.០៥៩.០៧២ |
| បូក៖ ទុនបម្រុងទូទៅ | ៤.៦៨៥.៣៧០ | ១.៣៣០.៣៨០ |
| បូក៖ ទុនបម្រុងតាមច្បាប់ | ៤.៦៨៥.៣៧០ | ១.៣៣០.៣៨០ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៤១.០៩០.៥៧២** | **៣១.៧១៩.៨៣២** |

មាត្រា ៦៥ នៃលក្ខិន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ចែងថា ប្រាក់ចំណេញប្រចាំឆ្នាំរបស់ ក.ស.ស បន្ទាប់ពីទូទាត់ការខាតយោងទៅមុខ (ប្រសិនបើមាន) ត្រូវបានបែងចែកទៅជាទុនបម្រុងទូទៅក្នុងអត្រា ៥% និងទុនបម្រុងតាមច្បាប់នៅអត្រា ៥%។ នៅថ្ងៃទី៧ខែឧសភា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានអនុម័តផ្ទេរប្រាក់ចំណេញរក្សាទុកសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ទៅជាទុនបម្រុងទូទៅចំនួន ៤.៦៨៥.៣៧០ ពាន់រៀល និងទៅទុនបម្រុងតាមច្បាប់ចំនួន ៤.៦៨៥.៣៧០ ពាន់រៀល។

## ១៦. ប្រាក់កម្ចី

| | ២០២២ | ២០២១ |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៣ | ៤៤.៤១៨.៩០៣ | ៥៧.៧៣៥.៨១៣ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៤ | ៩១.៤៦៦.៤៧២ | ៩៨.០៥៣.៩១៨ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៦ | ៥.៣៥៤.៣៨៦ | ៦.៦១៤.៦៧៧ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៨ | ៩០.៥៩០.០០៩ | ១០៨.២៨១.៧៧០ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P១០ | ១៤៩.៥៨២.០៣៩ | ១៨៣.២២៧.៧១២ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P២១ | ១៣.៦៩៨.៧៥៨ | ១៥.០៧៣.១០៧ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយ JICA និង JBIC ទាក់ទិនទៅនឹងប្រតិបត្តិការដែលពាក់ព័ន្ធនឹង ក.ស.ស។ ប្រាក់កម្ចីត្រូវបាន JICA និង JBIC ទូទាត់ដោយផ្ទាល់ទៅឲ្យអ្នកផ្គត់ផ្គង់របស់ ក.ស.ស។ ក.ស.ស នឹងសងប្រាក់ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកាលវិភាគសងប្រាក់។

## ១៦. **ប្រាក់កម្ចី** (តពីទំព័រមុន)

កាលកំណត់របស់ប្រាក់កម្ចីទាំងនេះមានដូចខាងក្រោមៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **រយៈពេលខ្លី** | | |
| មិនលើសមួយឆ្នាំ | **៣០.៤៣៣.៤៩០** | **៣៣.៩៦១.៥៧២** |
| **រយៈពេលវែង** | | |
| លើសមួយឆ្នាំ ប៉ុន្តែតិចជាងពីរឆ្នាំ | ២៨.០៧២.៧៥៣ | ៣១.០៦៧.៩៣៨ |
| លើសពីរឆ្នាំ ប៉ុន្តែតិចជាងប្រាំឆ្នាំ | ៨៤.២១៨.២៦០ | ៩៣.២០៣.៨១៣ |
| លើសប្រាំឆ្នាំ | ២៥២.៣៨៦.០៧៤ | ៣១០.៧៥៣.៦៧៤ |
| | **៣៦៤.៦៧៧.០៨៧** | **៤៣៥.០២៥.៤២៥** |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

តម្លៃសមស្របរបស់ប្រាក់កម្ចីមានដូចខាងក្រោមៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| រយៈពេលខ្លី | ៣០.៤៣៣.៤៩០ | ៣៣.៩៦១.៥៧២ |
| រយៈពេលវែង | ៣៦៤.៦៧៧.០៨៧ | ៤៣៥.០២៥.៤២៥ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

តម្លៃសមស្របត្រូវបានគណនាអាស្រ័យទៅតាមកិច្ចសន្យាលំហូរសាច់ប្រាក់អប្បហារនាពេលអនាគត់ ដោយប្រើអត្រាប្រាក់កម្ចីក្នុងគ្រា។ ប្រាក់កម្ចីទាំងនោះត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្របដោយសារ មានការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមានហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

## ១៦. ប្រាក់កម្ចី (តពីទំព័រមុន)

ប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណមុខងារមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | ៣០៣.៦៤៤.១០៥ | ៣៧០.៩៣៣.០៧៩ |
| ប្រាក់ដុល្លារអាមេរិក | ៩១.៤៦៦.៤៧២ | ៩៨.០៥៣.៩១៨ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់កម្ចីនីមួយៗមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៣ | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៤ | ៣,៧០% | ៣,៧០% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៦ | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៨ | ២,៦៥% | ២,៦៥% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P១០ | ១,៦៥% | ១,៦៥% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P២១ | ១,២៦% | ១,២៦% |

## ១៧. កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍

បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៨៨.១៨០.៩៨៤ | ៨៦.៤៨១.៩៦៧ |
| ចំណាយលើសេវាកម្មក្នុងគ្រា | ២.០៥៧.៧៥៩ | ១.៧០៩.០០០ |
| ចំណាយការប្រាក់ | ៤.៦៣៨.៤៤៦ | ៤.៦១៤.០០០ |
| អត្ថប្រយោជន៍បានបង់ | (៤.០១៥.២២៤) | (៤.៦២៣.៩៨៣) |
| ចំណេញពីការវាយតម្លៃឡើងវិញនៃបម្រែបម្រួល ការសន្មតនៃការវាយតម្លៃ | (១៤.៨២៣.៥៤៩) | - |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៧៦.០៣៨.៤១៦** | **៨៨.១៨០.៩៨៤** |

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| រយៈពេលខ្លី | ៦.២១៤.៣៦៣ | ៤.៥៣៨.៤២៥ |
| រយៈពេលវែង | ៦៩.៨២៤.០៥៣ | ៨៣.៦៤៦.៥៥៩ |
| | **៧៦.០៣៨.៤១៦** | **៨៨.១៨០.៩៨៤** |

## ១៧. **ភាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍** (តពីទំព័រមុន)

ចំណាយអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ និងការវាស់វែងឡើងវិញកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នៅក្នុងរបាយការណ៍ពេញលេញមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណាយលើសេវាកម្មក្នុងគ្រា | ២.០៥៧.៧៥៩ | ១.៧០៩.០០០ |
| ចំណាយការប្រាក់ | ៤.៦៣៨.៤៤៦ | ៤.៦១៤.០០០ |
| **ទឹកប្រាក់សរុបបានទទួលស្គាល់ ក្នុងប្រាក់ចំណេញ ឬខាត***(កំណត់សម្គាល់លេខ ២២)* | **៦.៦៩៦.២០៥** | **៦.៣២៣.០០០** |

ការសន្មតសំខាន់ជាចម្បងមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| អត្រាអប្បហារក្នុងមួយឆ្នាំ | ៦,៥% | ៦,០% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ក្នុងមួយឆ្នាំ | ៥,០% | ៥,០% |
| អត្រាបម្រែបម្រួលបុគ្គលិកក្នុងមួយឆ្នាំ | ០,៥% | ០,៥% |
| អត្រាមរណៈ | ១០០%នៃតារាងមរណៈភាព ធម្មតារបស់ប្រទេសថៃឆ្នាំ២០១៧ | ១០០%នៃតារាងមរណៈភាព ធម្មតារបស់ប្រទេសថៃឆ្នាំ២០១៧ |
| អត្រាពិការភាព | ១០% នៃអត្រាមរណៈ មុនពេលចូលនិវត្តន៍ | ១០% នៃអត្រាមរណៈ មុនពេលចូលនិវត្តន៍ |

តារាងក្រោមនេះ បង្ហាញពីវិយិតភាព (sensitivity) នៃបម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍តាមការសន្មតការគណនា/វាយតម្លៃ (actuarial assumption) ដូចខាងក្រោម៖

| *វិយិតភាព* | *ការសន្មត* | *រៀល* |
|---|---|---|
| ២០២២ | | |
| *អត្រាអប្បហារ* | | |
| មូលដ្ឋានការសន្មត | ៦,៥% | ៧៦.០៣៨ |
| + ១,០០% | ៧,៥% | ៦៧.៦៦៨ |
| - ១,០០% | ៥,៥% | ៨៩.១៩៨ |
| *អត្រាកើនឡើងនៃប្រាក់បៀវត្សរ៍* | | |
| មូលដ្ឋានការសន្មត | ៥,០% | ៧៦.០៣៨ |
| + ១,០០% | ៦,០% | ៧៩.១៧១ |
| - ១,០០% | ៤,០% | ៧៣.០៤០ |
| ២០២១ | | |
| *អត្រាអប្បហារ* | | |
| មូលដ្ឋានការសន្មត | ៦,០% | ៨៨.១៨១ |
| + ០,៥០% | ៦,៥% | ៨៣.៦៤២ |
| - ០,៥០% | ៥,៥% | ៩៣.១៨៤ |
| *អត្រាកើនឡើងនៃប្រាក់បៀវត្សរ៍* | | |
| មូលដ្ឋានការសន្មត | ៥,០% | ៨៨.១៨១ |
| + ២,៥០% | ៧,៥% | ៩៩.១០១ |
| - ២,៥០% | ២,៥% | ៨០.១៩៨ |

## ១៨. ចំណូលពន្យារ

ទ្រព្យវិនិយោគរបស់ ក.ស.ស ត្រូវបានដាក់ជួល ក្រោមកិច្ចសន្យាភតិសន្យាប្រតិបត្តិរយៈពេលពី ២ឆ្នាំ ទៅ ៥០ឆ្នាំ។ ប្រាក់ដែលទទួលបានមុនត្រូវបានកត់ត្រាក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាតតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| រយៈពេលខ្លី | ១៧១.៦៧៩ | ១៣៤.៥៤២ |
| រយៈពេលវែង | ១២.២០៣.២០០ | ៥.៣១០.៥៥៩ |
| | **១២.៣៧៤.៨៧៩** | **៥.៤៤៤.៩០១** |

បម្រែបម្រួលចំណូលពន្យារក្នុងគ្រាមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៥.៤៤៤.៩០១ | ៥.៥៣៩.៦២៨ |
| ប្រាក់ទទួល | ៧.៥៥២.៧៩៨ | ៣២៥.៤៣៩ |
| ការទទួលស្គាល់ជាចំណូលជួល | (៧៤៧.៣៥៨) | (៩៦០.៩៣០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ១២៤.៥៣៨ | ៩០.៧៦៤ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **១២.៣៧៤.៨៧៩** | **៥.៤៤៤.៩០១** |

## ១៩. គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអ្នកផ្គត់ផ្គង់ | ៨៧៩.២០៤ | ៦.៩០១.០៣៤ |
| លាភការបង្គរ | ១៦.៩២០.៩៣៧ | ១៧.៧២៣.៧៩៦ |
| បុរេប្រទានពីអតិថិជន | ៨.៥៩២.៦៩៨ | ៨.៦០៦.៣១៣ |
| បង្គរវិភាគទានមូលនិធិសង្គម | ៥.៦១៩.៦៨៥ | ៥.៦៩៥.១០៧ |
| ប្រាក់តម្កល់ពីភតិកៈ | ១.៦៥៥.២៩១ | ១.៨៣៨.៧៩៣ |
| ធាតុចេញនៃអាករលើតម្លៃបន្ថែមត្រូវបង់ - សុទ្ធ | ១.៦៣៨.១០២ | ១.៥១២.៣១៥ |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | ៣៣៥.៩៨៥ | ៤៣៩.៩៩៧ |
| ផ្សេងៗ | ៩២៤.៦៧១ | ៩៧៧.៩៥៥ |
| | **៣៥.០៦៦.០៧៣** | **៤៣.១៨៩.៦៥៩** |

## ២០. ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

### *២០.១ ព័ត៌មានការបែងចែកចំណូល*

ខាងក្រោមនេះគឺជាការបែងចែកប្រាក់ចំណូលរបស់ ក.ស.ស ពីកិច្ចសន្យាជាមួយអតិថិជន៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណូលលើកដាក់ពីនាវា | ១៦៩.៨៧៣.៩៤៥ | ១៥៨.៥៦៦.៩៩៩ |
| ចំណូលពីការលើកដាក់ និងចំណូលពីការរក្សាទុកកុងតឺន័រ | ១១២.៩៣៧.១៧១ | ១១៩.៩៧៦.៥៣៤ |
| ចំណូលពីសេវាកម្មកំពង់ផែ | ៦២.២៨៥.០៥០ | ៦៥.០១៦.២៦៧ |
| ផ្សេងៗ | ១.៧៧៣.១៨៣ | ១.៥៩៤.០៦០ |
| | **៣៤៦.៣៦៨.៨៤៩** | **៣៤០.១៥៣.៣៦០** |
| ពេលវេលានៃការទទួលស្គាល់ចំណូល | | |
| នៅពេលតែមួយ | ៣២៩.៤៦៦.៣២០ | ៣២៤.៦១០.៦២៤ |
| តាមដំណាក់កាល | ១៦.៩០២.៥២៩ | ១៥.៥៤២.៧៣៦ |
| | **៣៤៦.៣៦៨.៨៤៩** | **៣៤០.១៥៣.៣៦០** |

### *២០.២ សមតុល្យកិច្ចសន្យា*

សមតុល្យកិច្ចសន្យារបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអតិថិជន *(កំណត់សម្គាល់លេខ ១០)* | **៣០.៣៣៩.៩៦០** | **៣៣.៦៥៦.២៧៨** |

### *២០.៣ កាតព្វកិច្ចអនុវត្ត*

*ចំណូលលើកដាក់ពីនាវា ចំណូលលើកដាក់លើទីលាន (LO-LO) និងចំណូលពីការរក្សាទុកកុងតឺន័រ និងចំណូលពីសេវាកម្មកំពង់ផែ*

ប្រាក់ចំណូលពីសេវាកម្មកំពង់ផែ ត្រូវបានទទួលស្គាល់នៅពេលតែមួយ និងទទួលស្គាល់តាមដំណាក់កាល នៅពេលកាតព្វកិច្ចអនុវត្តបានបំពេញ និងកំពុងបានបំពេញ ដែលស្របពេលជាមួយនឹងការផ្តល់សេវាកម្ម និងការទទួលយកដោយអតិថិជន។

មិនមានសមាសភាពហិរញ្ញប្បទានជាសារវន្ត នៅក្នុងចំណូលដែលបានពីសេវាកម្មកំពង់ផែទេ ដោយសារសេវាកម្មត្រូវបានផ្តល់ជូនក្នុងលក្ខខណ្ឌឥណទានធម្មតាដែលមិនលើសពីដប់ពីរខែ។

## ២១. សម្ភារៈផ្គត់ផ្គង់ការប្រើប្រាស់

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណាយលើសម្ភារងាយឆេះ | ៥៥.៣៧៧.២៩៥ | ៤៥.៦៧៦.៩២២ |
| គ្រឿងបន្លាស់ | ៣៦.៥៨៥.២៧៨ | ៣២.៩០៨.០១៧ |
| សម្ភារផ្គត់ផ្គង់ឃ្លាំង | ៦.៦៩៧.០៧៨ | ៧.៦០៩.៦៧០ |
| ប្រេង និងប្រេងរំអិល | ៣.៧២៦.៧៣៤ | ៣.៨១០.៩១៤ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ២.១៧៩.៦៧០ | ២.៨៣៦.៧១៥ |
| ផ្សេងៗ | ១.៨៤៨.៨០៦ | ១.៨៩៧.០០៨ |
| | **១០៦.៣៦៤.៨៦១** | **៩៣.៧៣៩.២៤៦** |

## ២២. ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់បៀវត្សរ៍បុគ្គលិក | ៧០.៨៩០.៨៨៩ | ៦៩.៣១៨.៩៥៨ |
| លាភការ | ១៦.៤២០.៨៣៧ | ១៧.៧២៣.៧៤៦ |
| អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ *(កំណត់សម្គាល់លេខ ១៧)* | ៦.៦៩៦.២០៥ | ៦.៣២៣.០០០ |
| ប្រាក់រំលឹកអតីតភាពការងារ | ៤.០៣១.៧២៩ | ៣.៨៧០.៩២៨ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ១.៥៤៦.៨០០ | ១.៣៩៦.៨០០ |
| សន្តិសុខសង្គម | ១.៥៨៦.៥៣១ | ៧៨៣.០២២ |
| ចំណាយផ្សេងៗ | ៤.៥៣៩.៥០៦ | ៥.៣៥០.៨៥៥ |
| | **១០៥.៦៧២.០៩៧** | **១០៤.៣៦៦.៨៥៥** |

## ២៣. ចំណាយរំលស់ទ្រព្យរូបី និងទ្រព្យអរូបី

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ទ្រព្យ និងបរិក្ខារ *(កំណត់សម្គាល់លេខ ៦)* | ៣៨.៣៥២.៥៧០ | ៣២.៤៩៥.៦៦៣ |
| ទ្រព្យវិនិយោគ *(កំណត់សម្គាល់លេខ ៧)* | ៦.១៧៦.៦៣៩ | ៦.៣២២.៦៧០ |
| ទ្រព្យសកម្មអរូបី *(កំណត់សម្គាល់លេខ ៨)* | ១.១៦៨.៥៣៩ | ១.១០៤.៣៤៤ |
| | **៤៥.៦៩៧.៧៤៨** | **៣៩.៩២២.៦៧៧** |

## ២៤. ចំណាយផ្សេងៗ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| វិភាគទាន និងអំណោយ | ១១.១៩៣.៩០៦ | ១២.០២៩.៣២៦ |
| ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស | ២.៨៦៩.៥៨៥ | ២.៥៥៥.៦០២ |
| ទឹកភ្លើង | ២.៨៤៨.៩៩២ | ៣៦៦.៣៧៤ |
| ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | ២.៤៩២.២៩៤ | ១.៩២២.៧៥៧ |
| ការផ្គត់ផ្គង់ | ១.៨០១.៣៥៤ | ២.២០៣.២១៨ |
| បេសកម្ម | ១.៦១៦.០៨៤ | ៧៨៤.៩០៧ |
| កម្រៃសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធ | ១.៦១៥.៣៦៣ | ១.០៥១.២៥០ |
| ការបោះផ្សាយ | ១.១៩៦.៥៦៥ | ១.០១៥.៣៥៩ |
| កម្មសិក្សារ ពោងជាង និងសិក្ខាសាលា | ៥៣០.៧៧២ | ២៤៣.៩៩១ |
| ការទំនាក់ទំនង | ៣៩៣.៩៦៧ | ៣៩០.២៣៤ |
| ការជួលបរិក្ខារ និងឡាន | ២២៤.២៤៦ | ២៦.៨៤៥ |
| ការផ្គត់ផ្គង់សម្ភារថៃទាំសុខភាព | ២១៩.៣៤៤ | ៣៩៩.៤២៨ |
| បញ្ច្រាស់នៃសំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក | (៧៧.១៧៣) | (២.៣២៦.២៣៧) |
| ចំណាយផ្សេងៗ | ២០២.៣០០ | ២៤៩.៨៥២ |
| | **២៧.១២៦.៨៩៩** | **២០.៣៩៧.៤០៦** |

## ២៥. ចំណូលហិរញ្ញវត្ថុ - សុទ្ធ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| *ចំណូលហិរញ្ញវត្ថុ៖* | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ | ៤.២៧៧.៤៨៨ | ៣.៨១០.៧៧៦ |
| ចំណេញសុទ្ធពីការប្តូររូបិយវត្ថុរបស់ប្រាក់កម្ចី (គ) | ៤៦.៥១៥.៩៧៦ | ៣៩.៥៣១.៣៦៧ |
| ចំណូលការប្រាក់ពីការកត់ត្រាអប្បហារត្រឡប់មកវិញរបស់ឥណទានផ្តល់ឲ្យបុគ្គលិក | - | ៥៥.៣៤២ |
| | **៥០.៧៩៣.៤៦៤** | **៤៣.៣៩៧.៤៨៥** |
| *ចំណាយហិរញ្ញវត្ថុ៖* | | |
| ចំណាយការប្រាក់លើប្រាក់កម្ចី *(កំណត់សម្គាល់លេខ ១៦)* | **(៩.៩៣៩.៧៩៣)** | **(១១.១៩៤.៤៤៦)** |
| **ចំណូលហិរញ្ញវត្ថុ - សុទ្ធ** | **៤០.៨៥៣.៦៧១** | **៣២.២០៣.០៣៩** |

## ២៥. ចំណូលហិរញ្ញវត្ថុ - សុទ្ធ (តពីទំព័រមុន)

ក.ស.ស មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក *(កំណត់សម្គាល់លេខ ១៦)*។ ក.ស.ស ក៏មានប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លីជាប្រាក់ដុល្លារអាមេរិកផងដែរ *(កំណត់សម្គាល់លេខ ១១)*។ ដោយសារតែការឡើងចុះនៃតម្លៃប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក បណ្តាលឲ្យមានការចំណេញ/ខាតជាសារវន្តពីការប្តូរអត្រារូបិយប័ណ្ណលើប្រាក់កម្ចី និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លីរបស់ ក.ស.ស។ អត្រាប្តូរប្រាក់ ត្រូវបានផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជាគិតត្រឹមដំណាច់កាលបរិច្ឆេទការរាយការណ៍។ ចំណេញពីការប្តូររូបិយប័ណ្ណភាគច្រើនបណ្តាលមកពីការធ្លាក់ចុះនៃប្រាក់យ៉េនជប៉ុនធៀបទៅនឹងការិយបរិច្ឆេទមុនៗ។

| | *២០២២* | *២០២១* | *២០២០* | *២០១៩* |
|---|---|---|---|---|
| ប្រាក់យ៉េនជប៉ុន/ប្រាក់រៀល | ៣០,៩៥៥ | ៣៥,៥៩០ | ៣៩,២៧៥ | ៣៧,៦២០ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.១១៧ | ៤.០៧៤ | ៤.០៩៥ | ៤.០៧៥ |

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល

អនុលោមតាមបទប្បញ្ញត្តិពន្ធដារក្នុងប្រទេសកម្ពុជា ពន្ធលើប្រាក់ចំណូលក្នុងគ្រាត្រូវបានគណនាតាមភាពខ្ពស់ជាងរវាង ប្រាក់ចំណូលជាប់ពន្ធសម្រាប់ការិយបរិច្ឆេទ គុណនឹងអត្រាពន្ធលើប្រាក់ចំណូលតាមច្បាប់ ២០% នាកាលបរិច្ឆេទនៃការរាយការណ៍ និង ១% នៃចំណូល។

### *(ក) ចំណាយពន្ធលើប្រាក់ចំណូល*

សមាសភាគសំខាន់ៗនៃចំណាយពន្ធលើប្រាក់ចំណូលក្នុងគ្រាមានៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| *ចំណាយពន្ធលើប្រាក់ចំណូលទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលចំណេញ* | | |
| ពន្ធលើប្រាក់ចំណូលក្នុងគ្រា | ១១.៩៩២.៦៣៤ | ៧.៥៩៥.៥៤៩ |
| កង្វះសំវិធានធនសម្រាប់ពន្ធក្នុងគ្រានៃការិយបរិច្ឆេទមុន | ១.៦២៩.៦០០ | - |
| ពន្ធពន្យារ | ៦១៩.៦៣១ | ៩.៧៤២.៦៩៨ |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **១៣.៧៤១.៨៦៥** | **១៧.៣៣៨.២៤៧** |
| *ចំណាយពន្ធលើប្រាក់ចំណូលទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ* | | |
| **ពន្ធពន្យាទាក់ទងនឹងចំណេញពីការវាយតម្លៃឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍** | **២.៩៦៤.៧០៩** | - |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល (តពីទំព័រមុន)

### *(ក) ចំណាយពន្ធលើប្រាក់ចំណូល* (តពីទំព័រមុន)

ការផ្ទៀងផ្ទាត់នៃពន្ធលើប្រាក់ចំណូលដែលបានគណនាតាមអត្រាពន្ធតាមច្បាប់ ២០% ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់ចំណូលគណនេយ្យមុនគិតពន្ធលើប្រាក់ចំណូល៖ | **៩៧.៨៩៧.០៨០** | **១១១.០៤៥.៦៣៧** |
| ចំណូលពន្ធគិតតាមអត្រា ២០% | ១៩.៥៧៩.៤១៦ | ២២.២០៩.១២៧ |
| ផលប៉ះពាល់នៃចំណាយមិនអាចកាត់កងបាន | ៣.២៦០.៤០០ | ៣.០៣៥.៣៩០ |
| ផលប៉ះពាល់នៃប្រាក់ចំណូលមិនជាប់ពន្ធ | (៨.៨៥៨.១៣២) | (៧.៩០៦.២៧០) |
| ផលប៉ះពាល់នៃពន្ធពន្យារមិនទទួលស្គាល់ពីមុន | (១.៨៦៩.៤១៩) | - |
| កង្វះសំវិធានធនលើពន្ធក្នុងគ្រានៃការិយបរិច្ឆេទមុន | ១.៦២៩.៦០០ | - |
| | **១៣.៧៤១.៨៦៥** | **១៧.៣៣៨.២៤៧** |

### *(ខ) បំណុលពន្ធពន្យារ - សុទ្ធ*

ពន្ធពន្យារ ត្រូវបានគណនាទៅលើភាពខុសគ្នាបណ្តោះអាសន្នក្រោមវិធីសាស្រ្តបំណុលដោយប្រើប្រាស់អត្រាពន្ធតាមច្បាប់ ២០%។

ចំនួនខាងក្រោមត្រូវបានកំណត់បន្ទាប់ពីបានកាត់កងយ៉ាងត្រឹមត្រូវ បានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ទ្រព្យសកម្មពន្ធពន្យារ | ១៩.៦៨២.៨៤៧ | ១៩.១៦៧.៨៥៩ |
| បំណុលពន្ធពន្យារ | (៥២.៦៨៦.២០១) | (៤៨.៥៨៦.៨៧៣) |
| **បំណុលពន្ធពន្យារ -សុទ្ធ** | **(៣៣.០០៣.៣៥៤)** | **(២៩.៤១៩.០១៤)** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ២៦. **ចំណាយពន្ធលើប្រាក់ចំណូល** (តពីទំព័រមុន)

### *(ខ) បំណុលពន្ធពន្យារ - សុទ្ធ* (តពីទំព័រមុន)

ពន្ធពន្យារជាទ្រព្យសកម្ម (បំណុល) មានដូចខាងក្រោមទៅះ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ទ្រព្យសកម្មពន្ធពន្យារលើះ | | |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៥.២០៧.៦៨៣ | ១៧.៦៣៦.១៩៧ |
| ចំណូលពន្យារ | ២.៩៧៤.៩៧៤ | ១.០៨៨.៩៨០ |
| បុរេប្រទានទទួលពីអតិថិជន | ១.៦២៩.៦០០ | - |
| កាតព្វកិច្ចលើប្រាក់បំណាច់អតីតភាពការងារ | ២៨៨.៨៩១ | ២១៦.០៣០ |
| សំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក | ៦២.៦១៨ | ៧៨.០៥៣ |
| សំវិធានធនលើអ៊ឹមភែរមិននៃសន្និធិ | ១៩.០៨១ | ១៩៨.៥៩៩ |
| | **១៩.៦៨២.៨៤៧** | **១៩.១៦៧.៨៥៩** |
| បំណុលពន្ធពន្យារលើះ | | |
| រំលស់ទ្រព្យអរូបី និងទ្រព្យរូបី | (៥២.៦៨៦.២០១) | (៤៨.៥៨៦.៨៧៣) |
| **បំណុលពន្ធពន្យារ - សុទ្ធ** | **(៣៣.០០៣.៣៥៤)** | **(២៩.៤១៩.០១៤)** |

### *(គ) បំណុលពន្ធលើប្រាក់ចំណូល*

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៥.៩៣៥.៣០៧ | ៧.៦០៧.៩៩៣ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១១.៩៩២.៦៣៤ | ៧.៥៩៥.៥៩៩ |
| កង្វះសំវិធានធនពន្ធក្នុងគ្រាពីការិយបរិច្ឆេទមុន | ១.៦២៩.៦០០ | - |
| ពន្ធលើប្រាក់ចំណូលបានបង់ | (១០.៧៧៩.៨៩៥) | (៨.១៩១.៩៣៨) |
| ឥណទានពន្ធកាត់ទុក | - | (១.១២៥.៧៩៧) |
| | **៨.២៧៧.៦៤៦** | **៥.៩៣៥.៣០៧** |

## ២៧. ប្រាក់ចំណេញក្នុងមួយភាគហ៊ុន

### *(i) មូលដ្ឋានប្រាក់ចំណេញក្នុងមួយភាគហ៊ុន*

មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ភាគហ៊ុនិក របស់ ក.ស.ស ចែកនឹងចំនួនជាមធ្យមនៃភាគហ៊ុនធម្មតាបោះផ្សាយក្នុងការិយបរិច្ឆេទ។

| | *២០២២* | *២០២១* |
|---|---|---|
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក *(ពាន់រៀល)* | ៨៩.១៥៥.២១៥ | ៩៣.៧០៧.៣៩០ |
| ចំនួនភាគហ៊ុនជាមធ្យម | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |
| **មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន** *(រៀល)* | **៩៨១,១៥** | **១.០៩២,៥២** |

### *(ii) ការថយចុះចំណេញក្នុងមួយភាគហ៊ុន (Diluted earnings per share)*

ការថយចុះចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយនិយ័តកម្មលើចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ ក.ស.ស មិនមានការថយចុះភាគហ៊ុនដែលមានសក្តានុពល ផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ នាចុងការិយបរិច្ឆេទនេះ។ ដូចនេះ ការថយចុះចំណេញក្នុងមួយភាគហ៊ុន គឺមានតម្លៃស្មើនឹងមូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន។

## ២៨. ប្រតិបត្តិការភាគីពាក់ព័ន្ធ

ក.ស.ស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("MoEF") និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសដោយក្រសួងសាធារណការ និងដឹកជញ្ជូន ("MoPWT")។ ប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានចាត់ទុកថាជាភាគីពាក់ព័ន្ធ។

### *(ក) សមតុល្យភាគីពាក់ព័ន្ធ*

(i) ទឹកប្រាក់ជំពាក់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| *ប្រាក់កម្ចីពី៖* | | |
| MoEF – (JICA) | ១៦៣.២៨០.៧៩៧ | ១៩៨.៣០០.៨១៩ |
| MoEF – (JBIC) | ២៣១.៨២៩.៧៨០ | ២៧០.៦៨៦.១៧៨ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

## ២៨. ប្រតិបត្តិការភាគីពាក់ព័ន្ធ (តពីទំព័រមុន)

### *(ក) សមតុល្យភាគីពាក់ព័ន្ធ* (តពីទំព័រមុន)

(ii) គណនីត្រូវទទួលពីក្រសួងសាធារណការ និងដឹកជញ្ជូន

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| បុរេប្រទានទៅឲ្យ MoPWT *(កំណត់សម្គាល់លេខ ១០)* | **៧.២២១.៣០៣** | **១.២២១.៣០៣** |

### *(ខ) ប្រតិបត្តិការភាគីពាក់ព័ន្ធ*

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| បុរេប្រទានទៅ MoPWT *(កំណត់សម្គាល់លេខ ១០)* | ៦.០០០.០០០ | - |
| ចំណាយការប្រាក់លើប្រាក់កម្ចីពី MoEF *(កំណត់សម្គាល់លេខ ១៦)* | ៩.៩៣៩.៧៩៣ | ១១.១៩៤.៥៤៦ |

### *(គ) ចំណាយលើគណៈគ្រប់គ្រងសំខាន់ៗ*

ចំណាយលើគណៈគ្រប់គ្រងសំខាន់ៗសម្រាប់ការិយបរិច្ឆេទបញ្ចប់មានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **ក្រុមប្រឹក្សាភិបាល** | | |
| កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | **១.៣៩៦.៨០០** | **១.៣៩៦.៨០០** |
| **គណៈគ្រប់គ្រងសំខាន់ៗ** | | |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | **៣.២៦៨.១៩៧** | **៣.០៦៣.៤៩៥** |
| ចំណាយអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ (*) | **២៣៥.៣៦៦** | **២៤៥.៧១៨** |

គណៈគ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយកប្រតិបត្តិ និងនាយកប្រតិបត្តិ ដែលជាអ្នកសម្រេចចិត្តលើយុទ្ធសាស្ត្រនៃការដឹកនាំលើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ ក.ស.ស។

(*) គម្រោងអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ត្រូវបានដាក់ឲ្យប្រតិបត្តិក្នុង ក.ស.ស ទាំងមូល ក្នុងនោះគណៈគ្រប់គ្រងសំខាន់ៗ ក៏ទទួលបានគម្រោងអត្ថប្រយោជន៍នេះដូចគ្នានឹងបុគ្គលិក ក.ស.ស ដទៃទៀតដែរ។

## ២៩. ភាគព្វកិច្ច

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក.ស.ស មានកាតព្វកិច្ចលើការចំណាយមូលធនចំនួន ១.១៣៨.០០៧ លានរៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ៨២១.៥១៦ លានរៀល) សម្រាប់ការសាងសង់ និងការទិញទ្រព្យ និងបរិក្ខារ។

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ*

សកម្មភាពរបស់ ក.ស.ស អាចប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជា៖ ហានិភ័យទីផ្សារ (រួមបញ្ចូលទាំងហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ និងហានិភ័យអត្រាប្តូររូបិយប័ណ្ណ) ហានិភ័យឥណទាន និងហានិភ័យសន្ទនីយភាព។ ក.ស.ស គ្រប់គ្រង និងសន្ទុតហានិភ័យទាំងនេះដោយការតាមដានអត្រាការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃដៃគូរបស់ ក.ស.ស អត្រាប្តូររូបិយប័ណ្ណ និងលំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដើម្បីការពារហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណរបស់ខ្លួននោះទេ។

***ហានិភ័យទីផ្សារ***

*ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលបម្រែបម្រួលការប្រាក់លើទីផ្សារនាពេលអនាគតនឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ ក.ស.ស។

ក.ស.ស បានទទួលប្រាក់កម្ចី (តាមអត្រាការប្រាក់ថេរ) ពី Japan International Cooperation Agency ("JICA") និង Japan Bank for International Cooperation ("JBIC") តាមរយៈ MoEF។ ក.ស.ស មិនមានការផ្តោះប្តូរអត្រាការប្រាក់ ឬ ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដើម្បីការពារហានិភ័យអត្រាការប្រាក់ទេ។ ក្រុមហ៊ុនមានផលប៉ះពាល់ដល់ហានិភ័យតម្លៃសមស្រប ទោះជាយ៉ាងណាក៏ដោយ គណៈគ្រប់គ្រងកំពុងពិនិត្យមើលយ៉ាងជិតដល់នូវការប្រែប្រួលនៅក្នុងទីផ្សារ ហើយនឹងឈានដល់ការផ្តោះប្តូរអត្រាការប្រាក់ ប្រសិនបើចាំបាច់។ ប្រាក់កម្ចីរបស់ ក.ស.ស ត្រូវបានយោងតាមរំលស់ថ្លៃដើម។

*ហានិភ័យតម្លៃ*

ក.ស.ស មិនប្រឈមនឹងហានិភ័យតម្លៃទេ។ បន្ថែមពីនេះ ក.ស.ស ក៏មិនប្រឈមនឹងហានិភ័យតម្លៃមូលបត្រដែរ ដោយសារ ក.ស.ស មិនមានឧបករណ៍ហិរញ្ញវត្ថុដែលត្រូវកត់ត្រាតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ។

*ហានិភ័យអត្រាប្តូររូបិយប័ណ្ណ*

ក.ស.ស ប្រឈមមុខនឹងហានិភ័យអត្រាប្តូររូបិយប័ណ្ណ ដែលសំខាន់គឺការប្តូរពីប្រាក់រៀល ទៅជាប្រាក់យ៉េនជប៉ុន និងទៅជាប្រាក់ដុល្លារអាមេរិក ដោយសារប្រាក់កម្ចីពី JICA និង JIBC តាមរយៈ MoEF ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក ក៏ប៉ុន្តែ ក.ស.ស កត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណមុខងារ។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ការការពារ ឬ ប្រើកិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត ដើម្បីការពារហានិភ័យនេះទេ។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

***ហានិភ័យទីផ្សារ*** (តពីទំព័រមុន)

*ហានិភ័យអត្រាប្តូររូបិយប័ណ្ណ* (តពីទំព័រមុន)

ភាពងាយទទួលរងនូវផលប៉ះពាល់របស់ ក.ស.ស ពីអត្រាប្តូររូបិយប័ណ្ណទៅលើឧបករណ៍ហិរញ្ញវត្ថុជាប្រាក់យ៉េនជប៉ុន និងឧបករណ៍ហិរញ្ញវត្ថុជាប្រាក់ដុល្លារអាមេរិករបស់ខ្លួន ត្រូវបានវិភាគដូចខាងក្រោម។ ឧបករណ៍ហិរញ្ញវត្ថុជាចម្បងរបស់ ក.ស.ស គឺរូបិយប័ណ្ណបរទេសទាំងពីរនេះ។ ក.ស.ស បានវិភាគបម្រែបម្រួលនៃរូបិយប័ណ្ណទាំងនេះក្នុងរយៈពេលបីឆ្នាំចុងក្រោយ ហើយបានសន្និដ្ឋានថាអត្រាបម្រែបម្រួល ៨,៩៥% (ឆ្នាំ២០២១៖ ៥,៥០%) និង ០,៨៥% (ឆ្នាំ២០២១៖ ០,៩៦%) សម្រាប់ប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក (រៀងគ្នា) គឺមានភាពសមហេតុផល។

ខាងក្រោមនេះ បង្ហាញពីផលប៉ះពាល់ទៅលើចំណូលក្រោយគិតពន្ធដែលបណ្តាលមកពីបម្រែបម្រួលនៃអត្រាប្តូរប្រាក់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖

*២០២២*

| *វិយិតភាព* | *បម្រែបម្រួលនៃអត្រាប្តូរប្រាក់* | *ផលប៉ះពាល់ទៅលើចំណូលក្រោយគិតពន្ធ* |
|---|---|---|
| | | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | - ៨,៩៥% ការធ្លាក់ចុះ | ២១.៧២៧.០០០ |
| ប្រាក់យ៉េនជប៉ុន | + ៨,៩៥% ការកើនឡើង | (២១.៧២៧.០០០) |
| ប្រាក់ដុល្លារអាមេរិក | - ០,៨៥% ការធ្លាក់ចុះ | (៣៦៩.០០០) |
| ប្រាក់ដុល្លារអាមេរិក | + ០,៨៥% ការកើនឡើង | ៣៦៩.០០០ |

*២០២១*

| *វិយិតភាព* | *បម្រែបម្រួលនៃអត្រាប្តូរប្រាក់* | *ផលប៉ះពាល់ទៅលើចំណូលក្រោយគិតពន្ធ* |
|---|---|---|
| | | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | - ៥,៥០% ការធ្លាក់ចុះ | ១៦.៤១៧.០០០ |
| ប្រាក់យ៉េនជប៉ុន | + ៥,៥០% ការកើនឡើង | (១៦.៤១៧.០០០) |
| ប្រាក់ដុល្លារអាមេរិក | - ០,៩៦ % ការធ្លាក់ចុះ | (២៩២,០០០) |
| ប្រាក់ដុល្លារអាមេរិក | + ០,៩៦% ការកើនឡើង | ២៩២,០០០ |

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យទីផ្សារ* (តពីទំព័រមុន)

តារាងខាងក្រោមនេះ សង្ខេបពីការប្រឈមមុខនឹងហានិភ័យនៃអត្រាប្តូរប្រាក់រូបិយប័ណ្ណរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ក្នុងតារាងខាងក្រោម គឺជាឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោងជារូបិយប័ណ្ណជាសមមូលពាន់រៀល។

| | *សមមូលនឹងពាន់រៀល* | | | |
|---|---|---|---|---|
| | *ប្រាក់យ៉េនជប៉ុន* | *ប្រាក់ដុល្លារអាមេរិក* | *ប្រាក់រៀល* | *សរុប* |
| **ឆ្នាំ២០២២** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗដុល | - | ៣០.៣៣៥.៩៦០ | ៧.៥៣៥.៧៩១ | ៣៧.៨៧០.៧៥១ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | - | ៩៧.១២១.៨៤៥ | ៥.៧៨៦.៤១៩ | ១០២.៩០៨.២៦៤ |
| សាច់ប្រាក់ | - | ២២.៨៨៣.១៨៨ | ៧០៣.១៨០ | ២៣.៥៨៦.៣៦៨ |
| | - | **១៥០.៣៣៩.៩៩៣** | **១៤.០២៥.៣៩០** | **១៦៤.៣៦៥.៣៨៣** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣០៣.៦៤៤.១០៥) | (៩១.៤៦៦.៤៧២) | - | (៣៩៥.១១០.៥៧៧) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | - | (២.៧១៧.៤២៣) | - | (២.៧១៧.៤២៣) |
| ប្រាក់តម្កល់ពីភតិក: | | (១.០២៩.២៥០) | | (១.០២៩.២៥០) |
| | **(៣០៣.៦៤៤.១០៥)** | **(៩៥.២១៣.១៤៥)** | - | **(៣៩៨.៨៥៧.២៥០)** |
| **ស្ថានភាពសុទ្ធ** | **(៣០៣.៦៤៤.១០៥)** | **៥៥.១២៦.៨៤៨** | **១៤.០២៥.៣៩០** | **(២៣៤.៤៩១.៨៦៧)** |
| **ឆ្នាំ២០២១** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗដុល | - | ៣៣.៩៨៥.៥១៩ | ១.៩១៧.៨០៥ | ៣៥.៩០៣.៣២៤ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | - | ៩៥.៨៧២.៣៦៧ | ៥.៤៣៤.៣១៤ | ១០១.៣០៦.៦៨១ |
| សាច់ប្រាក់ | - | ២១.៩៨០.៦៨៨ | ៤៨៨.២៤១ | ២២.៤៦៨.៩២៩ |
| | - | **១៥១.៨៣៨.៥៧៤** | **៧.៨៤០.៣៦០** | **១៥៩.៦៧៨.៩៣៤** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣៧០.៩៣៣.០៧៩) | (៩៨.០៥៣.៩១៨) | - | (៤៦៨.៩៨៦.៩៩៧) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | - | (១៤.៦៣៦.៦៦៩) | (៦.០២៥.២៣៦) | (២០.៦៦១.៩០៥) |
| ប្រាក់តម្កល់ពីភតិក: | - | (១.០១៨.៥០០) | - | (១.០១៨.៥០០) |
| | **(៣៧០.៩៣៣.០៧៩)** | **(១១៣.៧០៩.០៨៧)** | **(៦.០២៥.២៣៦)** | **(៤៩០.៦៦៧.៤០២)** |
| **ស្ថានភាពសុទ្ធ** | **(៣៧០.៩៣៣.០៧៩)** | **៣៨.១២៩.៤៨៧** | **១.៨១៥.១២៤** | **(៣៣០.៩៨៨.៤៦៨)** |

### ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

*៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យឥណទាន*

ក.ស.ស ប្រឈមមុខនឹងហានិភ័យឥណទាន ដែលពាក់ព័ន្ធជាចម្បងទៅនឹង គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងសាច់ប្រាក់នៅធនាគារ យោងតាមថ្លៃដើមរំលស់។

*ការគ្រប់គ្រងហានិភ័យ*

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ក.ស.ស តម្រូវឲ្យក្រុមហ៊ុនដឹកជញ្ជូនតាមនាវានីមួយៗ តម្កល់ប្រាក់កក់មុននឹងបំពេញសេវាណាមួយឲ្យក្រុមហ៊ុននោះ។ ចំពោះគ្រឹះស្ថានរបស់រដ្ឋាភិបាល មិនតម្រូវឲ្យមានប្រាក់កក់ទេ ដោយសារ ក.ស.ស ជឿជាក់ថាខ្លួនអាចប្រមូលប្រាក់ពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ដែលជាប្រភពហិរញ្ញវត្ថុ នៃគ្រឹះស្ថានរដ្ឋទាំងនោះ)។ ចំពោះក្រុមហ៊ុនដឹកជញ្ជូនតាមនាវាដែលមិនប្រើប្រាស់សេវាញឹកញាប់របស់ ក.ស.ស មិនតម្រូវឲ្យកក់ប្រាក់នោះទេ ដោយសារក្រុមហ៊ុនដឹកជញ្ជូនទាំងនោះតម្រូវឲ្យទូទាត់ប្រាក់នៅពេលទទួលបានសេវាកម្មរួចរាល់។ ក.ស.ស មានគោលការណ៍កាត់ប្រាក់កក់ចំពោះអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេ ទៅតាមលក្ខខណ្ឌ និងកិច្ចសន្យាឥណទាន។ ហានិភ័យឥណទានរបស់ ក.ស.ស ចំពោះគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានកំណត់ឲ្យនៅត្រឹមតម្លៃយោងនៃគណនីអតិថិជននោះ ដកសំវិធានធនចំពោះការខាតឥណទានបានរំពឹងទុក នៃគណនីអតិថិជន ផ្អែកតាមការត្រួតពិនិត្យលើចំនួនដែលនៅមិនទាន់ទូទាត់នាការិយបរិច្ឆេទបញ្ចប់។ មិនមានការប្រមូលផ្តុំហានិភ័យឥណទានជាសារវន្តទេ ទាំងហានិភ័យតាមរយៈអតិថិជនម្នាក់ៗ អាជីវកម្មជាក់លាក់ និង/ឬ តំបន់អាជីវកម្ម។

ចំពោះប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងសាច់ប្រាក់នៅធនាគារ ការដាក់ប្រាក់ត្រូវបានធ្វើឡើងតែជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកេរ្តិ៍ឈ្មោះល្អតែប៉ុណ្ណោះ។

*ទ្រព្យធានា*

ចំពោះគណនីអតិថិជនពាណិជ្ជកម្មខ្លះ ក.ស.ស ទទួលទ្រព្យធានាក្នុងទម្រង់ជាការតម្កល់ជាសាច់ប្រាក់ ដែលអាចឲ្យបង់ប្រាក់បាន ប្រសិនបើភាគីដៃគូខកខានមិនបានបង់ប្រាក់តាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀង។

*អ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ក.ស.ស មានទ្រព្យសកម្មហិរញ្ញវត្ថុដូចជា សាច់ប្រាក់ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗដែលត្រូវអនុវត្តតាមគំរូការខាតឥណទានរំពឹងទុក។

សាច់ប្រាក់ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី គឺមិនមានហានិភ័យឥណទានសំខាន់ទេ។ យោងតាមតម្រូវការនៃអ៊ីមភែរមិនរបស់ CIFRS ៩ ការខាតបង់បណ្តាលមកពីអ៊ីមភែរមិន ដែលគេបានរកឃើញ គឺមិនមានភាពជាសារវន្តទេ ដោយសារ ក.ស.ស ធ្វើការដាក់ប្រាក់តែជាមួយធនាគារដែលមានកេរ្តិ៍ឈ្មោះ និងប្រវត្តិល្អតែប៉ុណ្ណោះ។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យឥណទាន* (តពីទំព័រមុន)

គណនីអតិថិជន

ក.ស.ស អនុវត្តវិធីសាស្ត្រដែលមានលក្ខណៈសាមញ្ញក្នុង CIFRS ៩ ដើម្បីវាស់វែងការខាតបង់ឥណទានរំពឹងទុក (ECL) ដែលប្រើប្រាស់អាយុកាលសំវិធានធនខាតបង់រំពឹងទុក ចំពោះគណនីអតិថិជនទាំងអស់។

ក្នុងការវាស់វែងការខាតបង់ឥណទានរំពឹងទុក គណនីអតិថិជនបានដាក់ជាក្រុម អាស្រ័យទៅតាមលក្ខណៈនៃហានិភ័យឥណទានជារួម និងចំនួនថ្ងៃផុតកំណត់។

ជាទូទៅគណនីអតិថិជនរបស់ ក.ស.ស រួមមានទឹកប្រាក់ត្រូវទទួលពីកូនបំណុលចន្លោះពី ៣១ ទៅ ៣៩ កូនបំណុល ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២២។ យោងទៅតាមបទពិសោធន៍នៃការខាតបង់ឥណទានរបស់ ក.ស.ស ក្នុងគ្រាកន្លងមកចំពោះគណនីអតិថិជន មិនមានករណីមិនសងប្រាក់រយៈពេល ៨ឆ្នាំចុងក្រោយនេះទេ។ វិក្កិយបត្រទាំងអស់ត្រូវបានទូទាត់មិនលើសរយៈពេលមួយឆ្នាំទេ។ ផ្អែកទៅតាមរបាយការណ៍នៃចិរវេលាកំណត់សងដែលបានផ្តល់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ភាគច្រើននៃសមតុល្យដែលមានចិរវេលាកំណត់សងលើសពី ១២០ថ្ងៃ ត្រូវបានទូទាត់រួចរាល់នាពេលបន្ទាប់ក្នុងខែមករា ឆ្នាំ២០២៣។

អត្រាការខាតបង់ក្នុងគ្រាកន្លងមក ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីព័ត៌មាននាពេលបច្ចុប្បន្ន និងព័ត៌មាននាពេលអនាគត ទៅលើកត្តាម៉ាក្រូសេដ្ឋកិច្ចផ្សេងៗ ដែលមានផលប៉ះពាល់ដល់លទ្ធភាពរបស់អតិថិជនក្នុងការទូទាត់សង។ ក.ស.ស បានកំណត់អំពីផលិតផលសរុបក្នុងស្រុក និងអត្រាកំណើននៅប្រទេសកម្ពុជា ដែល ក.ស.ស កំពុងផ្តល់សេវារបស់ខ្លួនត្រូវបានចាត់ទុកថាជាកត្តាដែលមានការពាក់ព័ន្ធក្នុងចំណោមកត្តាផ្សេងៗទៀត ដូចនេះហើយ ក.ស.ស បានកែតម្រូវអត្រាខាតបង់ក្នុងគ្រាកន្លងមក អាស្រ័យទៅតាមបម្រែបម្រួលរំពឹងទុកនៃកត្តាទាំងអស់នេះ។

គណនីអតិថិជនត្រូវបានលុបចោលពីបញ្ជី នៅពេលដែលមិនមានការរំពឹងទុកសមហេតុផលណាមួយដែលអាចប្រមូលបានមកវិញ។ សញ្ញាណដែលបង្ហាញថាមិនមានការរំពឹងទុកសមហេតុផលក្នុងការប្រមូលបានមកវិញរួមមានកត្តាមួយចំនួនក្នុងចំណោមកត្តាជាច្រើនដូចជា បរាជ័យរបស់កូនបំណុលក្នុងការសងប្រាក់តាមពេលវេលាកំណត់ និងបរាជ័យក្នុងការសងប្រាក់តាមកិច្ចសន្យាក្នុងរយៈពេលមួយលើសថ្ងៃផុតកំណត់សងជាក់លាក់ នឹងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ការខាតបង់អ៊ីមភែរមិនលើគណនីអតិថិជន ត្រូវបានដាក់បង្ហាញដោយការខាតបង់អ៊ីមភែរមិនសុទ្ធក្នុងប្រាក់ចំណេញប្រតិបត្តិការ។ ការប្រមូលបានមកវិញនាពេលបន្ទាប់ នៃចំនួនទឹកប្រាក់ដែលបានលុបចោលពីបញ្ជីរួចហើយ ត្រូវបានកត់ត្រាក្នុងខ្ទង់ឥណទាន ក្នុងប្រភេទគណនីដូចគ្នា។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

***ហានិភ័យឥណទាន*** (តពីទំព័រមុន)

គណនីអតិថិជន (តពីទំព័រមុន)

យោងតាមមូលដ្ឋាននេះ សំវិធានធនសម្រាប់ការខាតបង់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានកំណត់ដូចខាងក្រោមចំពោះគណនីអតិថិជនៈ

| | *២០២២* | | |
|---|---|---|---|
| | *អត្រាខាតបង់រំពឹងទុក* | *តម្លៃយោងដុល* | *សំវិធានធនសម្រាប់ការខាតបង់* |
| | *%* | *ពាន់រៀល* | *ពាន់រៀល* |
| ក្នុងគ្រា | 0% | ២៦.៩១០.៨៣៦ | - |
| ហួសកាលកំណត់លើសពី ៣០ថ្ងៃ | 0% | ១.៦១៤.៥៥៩ | - |
| ហួសកាលកំណត់លើសពី ៦០ថ្ងៃ | 0% | ៥៨៦.៥៥៣ | - |
| ហួសកាលកំណត់លើសពី ៩០ថ្ងៃ | 0% | ៧៩១.១២៧ | - |
| ហួសកាលកំណត់លើសពី ១២០ថ្ងៃ | (*) ១៩.៩៩% | ១.១៦៥.៣៣៥ | ២៣២.៩៥០ |
| សរុប | | **៣០.៥៦៧.៩១០** | **២៣២.៩៥០** |

| | *២០២១* | | |
|---|---|---|---|
| | *អត្រាខាតបង់រំពឹងទុក* | *តម្លៃយោងដុល* | *សំវិធានធនសម្រាប់ការខាតបង់* |
| | *%* | *ពាន់រៀល* | *ពាន់រៀល* |
| ក្នុងគ្រា | 0% | ២៥.៥៨០.២៨៧ | - |
| ហួសកាលកំណត់លើសពី ៣០ថ្ងៃ | 0% | ៤.៦១៦.០៥៩ | - |
| ហួសកាលកំណត់លើសពី ៦០ថ្ងៃ | 0% | ៨៣៤.២៥៤ | - |
| ហួសកាលកំណត់លើសពី ៩០ថ្ងៃ | 0% | ៣២១.៩៧១ | - |
| ហួសកាលកំណត់លើសពី ១២០ថ្ងៃ | (*) ១០,៨៦% | ៣.០៣២.៩៩៨ | ៣២៩.២៩១ |
| | | **៣៣.៨៨៥.៥១៩** | **៣២៩.២៩១** |

(*) ផលប៉ះពាល់ចំពោះការវាស់វែង ECL គឺដោយសារតែការផ្លាស់ប្តូរប្រូបាបនៃការមិនសងប្រាក់ ("PD") ដែលកើតឡើងពីការធ្វើនិយ័តកម្មនាពេលអនាគតចំពោះការព្យាករម៉ាក្រូសេដ្ឋកិច្ច។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យសាច់ប្រាក់ងាយស្រួល*

ក.ស.ស ប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួល កើតពីការបង្វិលសាច់ប្រាក់ទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ហានិភ័យសាច់ប្រាក់ងាយស្រួលរួមមានហានិភ័យដែលអាចធ្វើឲ្យ ក.ស.ស មិនមានលទ្ធភាពបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនឲ្យទាន់ពេលវេលា។

គោលការណ៍របស់ ក.ស.ស គឺត្រូវរក្សាទុកសាច់ប្រាក់ ឲ្យបានគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទានជាមួយនឹងមូលនិធិផ្ទាល់ដើម្បីបង់ការចំណាយវិនិយោគ។

ក.ស.ស មានប្រាក់កម្ចីមិនទាន់ដកយកដូចខាងក្រោមនាការិយបរិច្ឆេទបញ្ចប់៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **អត្រាការប្រាក់ថេរ** | | |
| មានកាលកំណត់លើសពី ១ឆ្នាំ | **៧១៣.៦១៨.២៧៧** | **៨២១.៩១៥.៩៦២** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យសាច់ប្រាក់ងាយស្រួល* (តពីទំព័រមុន)

ទម្រង់កាលកំណត់នៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលត្រូវបានប្រើដើម្បីគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងបំណុលហិរញ្ញវត្ថុត្រូវបានសង្ខេបដូចខាងក្រោម៖

| | *២០២២* | | | *២០២១* | | |
|---|---|---|---|---|---|---|
| | *ក្នុងមួយឆ្នាំ* | *ច្រើនជាងមួយឆ្នាំ* | *សរុប* | *ក្នុងមួយឆ្នាំ* | *ច្រើនជាងមួយឆ្នាំ* | *សរុប* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| *ទ្រព្យសកម្មហិរញ្ញវត្ថុ* | | | | | | |
| គណនីអតិថិជន | | | | | | |
| និងគណនីត្រូវទទួលផ្សេងដុល | ៣៧.៨៧០.៧៥១ | - | ៣៧.៨៧០.៧៥១ | ៣៥.៥៧៤.០៨៣ | - | ៣៥.៥៧៤.០៨៣ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១០២.៩០៨.២៦៤ | - | ១០២.៩០៨.២៦៤ | ១០១.៣០៦.៦៨១ | - | ១០១.៣០៦.៦៨១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ២៣.៥៨៦.៣៦៨ | - | ២៣.៥៨៦.៣៦៨ | ២២.៤៦៨.៩២៩ | - | ២២.៤៦៨.៩២៩ |
| | **១៦៤.៣៦៥.៣៨៣** | **-** | **១៦៤.៣៦៥.៣៨៣** | **១៥៩.៣៤៩.៦៩៣** | **-** | **១៥៩.៣៤៩.៦៩៣** |
| *បំណុលហិរញ្ញវត្ថុ* | | | | | | |
| ប្រាក់កម្ចី | ៣០.៤៣៣.៤៩០ | ៣៦៤.៦៧៧.០៨៧ | ៣៩៥.១១០.៥៧៧ | ៣៣.៩៦១.៥៧២ | ៤៣៥.០២៥.៤២៥ | ៤៦៨.៩៨៦.៩៩៧ |
| គណនីអ្នកផ្គត់ផ្គង់ | | | | | | |
| និងគណនីត្រូវទូទាត់ផ្សេងៗ | ២.៧១៧.៤២៣ | - | ២.៧១៧.៤២៣ | ២.៧១៧.៤២៣ | - | ២.៧១៧.៤២៣ |
| ប្រាក់តម្កល់ពីភតិក: | - | ១.០២៩.២៥០ | ១.០២៩.២៥០ | - | ១.០១៨.៥០០ | ១.០១៨.៥០០ |
| | **៣៣.១៥០.៩១៣** | **៣៦៥.៧០៦.៣៣៧** | **៣៩៨.៨៥៧.២៥០** | **៣៦.៦៧៨.៩៩៥** | **៤៣៦.០៤៣.៩២៥** | **៤៧២.៧២២.៩២០** |

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យសាច់ប្រាក់ងាយស្រួល* (តពីទំព័រមុន)

តារាងវិភាគខាងក្រោមនៃបំណុលហិរញ្ញវត្ថុរបស់ ក.ស.ស ដោយតាមរយៈពេលដែលនៅសល់រហូតដល់កំណត់ការិយបរិច្ឆេទនៃតារាងតុល្យការ។ តួរលេខដែលបានលាតត្រដាងខាងក្រោម លំហូរសាចប្រាក់មិនមានអប្បហារតាមកិច្ចសន្យារ។

| | *តិចជាង ១ឆ្នាំ* | *ពី ១ឆ្នាំ ដល់ ២ឆ្នាំ* | *ពី ២ឆ្នាំ ដល់ ៥ឆ្នាំ* | *លើសពី ៥ឆ្នាំ* | *លំហូរសាច់ប្រាក់ តាមកិច្ចសន្យាសរុប* | *បំណុល តម្លៃយោងសរុប* |
|---|---|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ឆ្នាំ២០២២** | | | | | | |
| ប្រាក់កម្ចី | ៣៧.៧៤៧.៩៣៧ | ៣៧.០៣៥.៤០៨ | ១០៦.៦១៣.១៦២ | ២៩៣.៩១៩.១៣៩ | ៤៧៥.៣១៥.៦៤៦ | ៣៩៥.១១០.៥៧៧ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២.៧១៧.៤២៣ | - | - | - | ២.៧១៧.៤២៣ | ២.៧១៧.៤២៣ |
| ប្រាក់តម្កល់ពីភតិក: | | | | ១.០២៩.២៥០ | ១.០២៩.២៥០ | ១.០២៩.២៥០ |
| | **៤០.៤៦៥.៣៦០** | **៣៧.០៣៥.៤០៨** | **១០៦.៦១៣.១៦២** | **២៩៤.៩៤៨.៣៨៩** | **៤៧៩.០៦២.៣១៩** | **៣៩៨.៨៥៧.២៥០** |
| **ឆ្នាំ២០២១** | | | | | | |
| ប្រាក់កម្ចី | ៤៧.០៧៤.២៣៩ | ៤៣.២៥១.៣៦១ | ១២៤.២២៤.១៩៦ | ៣៦៦.៧៦៤.៣០៩ | ៥៨១.៣១៤.១០៥ | ៤៦៨.៩៨៦.៩៩៧ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២០.៦៦១.៩០៥ | - | - | - | ២០.៦៦១.៩០៥ | ២០.៦៦១.៩០៥ |
| ប្រាក់តម្កល់ពីភតិក: | - | - | - | ១.០១៨.៥០០ | ១.០១៨.៥០០ | ១.០១៨.៥០០ |
| | **៦៧.៧៣៦.១៤៤** | **៤៣.២៥១.៣៦១** | **១២៤.២២៤.១៩៦** | **៣៦៧.៧៨២.៨០៩** | **៦០២.៩៩៤.៥១០** | **៤៩០.៦៦៧.៤០២** |

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.២ ការគ្រប់គ្រងហានិភ័យដើមទុន*

ទិសដៅរបស់ ក.ស.ស ក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគហ៊ុនិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុតដើម្បីកាត់បន្ថយចំណាយដើមទុន។

ក.ស.ស មិនមានគោលការណ៍ជាក់លាក់ចំពោះអនុបាតបំណុលធៀបនឹងដើមទុននោះទេ។

*ភាគលាភ*

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ និងថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានអនុម័តបែងចែកភាគលាភ ចំពោះប្រាក់ចំណេញសម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (រៀងគ្នា) ដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ភាគលាភបានបង់ឲ្យភាគហ៊ុនប្រភេទ ខ | ៥.៣០០.០០០ | ៣.៥៣៣.១២២ |
| ភាគលាភបានបង់ឲ្យភាគហ៊ុនប្រភេទ គ | ១០.៨០៧.២៦៨ | ៨.៦៤១.៥២៧ |
| **ភាគលាភបានបង់សរុប** | **១៦.១០៧.២៦៨** | **១២.១៧៤.៦៤៩** |

ប្រតិបត្តិការមិនមែនជាសាច់ប្រាក់គឺជាភាគលាភដែលបានបង់ទៅភាគហ៊ុនប្រភេទ ខ គិតជាប្រាក់រៀលស្មើសូន្យ ដែលបានកាត់កងបុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ៣.៥៣៣.១២២ ពាន់រៀល នៃចំនួនភាគលាភសរុបដែលបានបញ្ចេញចំនួន ១២.១៧៤.៦៤៩ ពាន់រៀល ត្រូវបានកាត់កងបុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន)។

### *៣០.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម*

វិធីសាស្ត្រ និងការសន្មតដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

(ក) សាច់ប្រាក់ និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របដោយសារវាមានរយៈពេលខ្លី។

(ខ) គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ - តម្លៃយោងដកសំវិធានធនដែលបណ្តាលមកពីអ៊ីមភែរមិន មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ - តម្លៃយោងនៃគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ ត្រូវបានចាត់ទុកថាមានតម្លៃស្មើគ្នានឹងតម្លៃសមស្របរបស់វា ដោយសារវាមានរយៈពេលខ្លី។

(ឃ)ប្រាក់កម្ចី - តម្លៃសមស្របនៃប្រាក់កម្ចីត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ចេញក្នុងកិច្ចសន្យានាពេលអនាគតដោយប្រើអត្រាប្រាក់កម្ចីនាដំណាច់ឆ្នាំ។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម* (តពីទំព័រមុន)

*ឋានានុក្រមតម្លៃសមរម្យ*

ក្រុមហ៊ុនប្រើប្រាស់ឋានានុក្រោមដូចខាងក្រោមសម្រាប់ការវាស់វែង និងលាតត្រដាងតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ តាមបច្ចេកទេសវាយតម្លៃដូចខាងក្រោម៖

- តម្លៃដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ បំណុលដូចគ្នា (កម្រិតទី១)
- ធាតុចូលក្រៅពីតម្លៃដែលបានដកស្រង់ដែលបានរួមបញ្ចូលក្នុងកម្រិតទី១ ដែលអាចសង្កេតបានលើទ្រព្យសកម្ម ឬ បំណុលដោយផ្ទាល់ (ឧ. ជាតម្លៃ) ឬ ដោយប្រយោល (ឧ. បានមកពីតម្លៃ) (កម្រិតទី២)
- ធាតុចូលនៃទ្រព្យសកម្ម ឬ បំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុដែលមិនអាចសង្កេតបាន) (កម្រិតទី៣)។

មិនមានការផ្ទេររវាងរង្វាស់តម្លៃសមស្របកម្រិតទី១ និងកម្រិតទី២ និងគ្មានការផ្ទេរចូល និងចេញពីកម្រិតទី៣ ទេ។

*ការកាត់កងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

មិនមានការកាត់កងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំនោះទេ។

## ៣១. **យថាភាពពន្ធ**

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួលសេចក្តីជូនដំណឹងអំពីការវាយតម្លៃសារពើពន្ធឡើងវិញ ("NTR") ពី GDT សម្រាប់សវនកម្មលើលិខិតស្នាមចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្រុមហ៊ុនបាននឹងកំពុងបន្តពិភាក្សាជាមួយ GDT អំពីបញ្ហាពន្ធដែលនៅសល់ទាំងនេះ ជាមួយនឹងជំហររឹងមាំដែលមិនយលស្របជាមួយ GDT។ ដោយមើលឃើញពីភាពមិនច្បាស់លាស់ នៃលទ្ធផលចុងក្រោយ នៃការវាយតម្លៃឡើងវិញទាំងនេះ គណៈគ្រប់គ្រងជឿជាក់ថាលំហូរចេញ នៃធនធានមិនអាចប៉ាន់ស្មានដោយភាពជឿជាក់បាននាកាលបរិច្ឆេទបច្ចុប្បន្ន។

ប្រព័ន្ធពន្ធដារនៅកម្ពុជាមានលក្ខណៈដោយពន្ធជាច្រើន និងច្បាប់ដែលមានការផ្លាស់ប្តូរជាញឹកញាប់ ដែលតែងតែមិនច្បាស់លាស់ផ្ទុយគ្នានិងមានការបកស្រាយ។ ជានិច្ចកាល ការបកស្រាយផ្សេងៗគ្នាមានក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការជាច្រើន។ ពន្ធគឺជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការស៊ើបអង្កេតដោយអាជ្ញាធរមួយចំនួន ដែលត្រូវបានអនុញ្ញាតដោយច្បាប់ដើម្បីដាក់ពិន័យធ្ងន់ធ្ងរ ការដាកពិន័យ និងការគិតការប្រាក់។ គណៈគ្រប់គ្រងជឿជាក់ថា ខ្លួនបានផ្តល់យ៉ាងគ្រប់គ្រាន់សម្រាប់បំណុលពន្ធដោយផ្អែកលើការបកស្រាយច្បាប់ពន្ធដាររបស់ខ្លួន។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរពាក់ព័ន្ធអាចមានការបកស្រាយខុសគ្នា និងផលប៉ះពាល់អាចមានសារៈសំខាន់។

ការបង្ហាញផ្សេងទៀតដែលទាមទារដោយ CIFRSs មិនត្រូវបានផ្តល់ឱ្យទេព្រោះវាអាចប៉ះពាល់ដល់ទីតាំងរបស់ក្រុមហ៊ុនក្នុងការវាយតម្លៃពន្ធដែលកំពុងបន្តនោះទេ។

## ៣២. ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃតួលេខប្រៀបធៀប

តួលេខប្រៀបធៀបជាក់លាក់ ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញដើម្បីអនុលោមតាមការបង្ហាញក្នុងការិយបរិច្ឆេទដូចតទៅ៖

| | *២០២១* | | |
|---|---|---|---|
| | *ពាន់រៀល (បានបង្ហាញពីមុន)* | *ពាន់រៀល (ធ្វើចំណាត់ថ្នាក់ឡើងវិញ)* | *ពាន់រៀល (បានធ្វើចំណាត់ថ្នាក់ឡើងវិញ)* |
| *របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ* | | | |
| ទ្រព្យវិនិយោគ - ដីធ្លី | ១២៥.០៤០.៣១៧ | (៣.៤០៦.៧៥៤) | ១២១.៦៣៣.៥៦៣ |
| ទ្រព្យវិនិយោគ - អគារ និងការកែលម្អដីធ្លី | ១៦៨.៣០៥.៤៥៩ | ២៧៤.១៩៤ | ១៦៨.៥៧៩.៦៥៣ |
| ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | ១៣.០៥៨.៧០៨ | ៣.១៣២.៥៦០ | ១៦.១៩១.២៦៨ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ៨៤.២០៨.១៥៩ | (១.០១៨.៥០០) | ៨៣.១៨៩.៦៥៩ |
| ប្រាក់តម្កល់ពីភតិកៈ | - | ១.០១៨.៥០០ | ១.០១៨.៥០០ |

## ៣៣. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

ក្រៅពីអ្វីដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ពុំមានព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងគួរឲ្យកត់សម្គាល់ណាមួយឡើង បន្ទាប់ពីការិយបរិច្ឆេទរបាយការណ៍ដែលតម្រូវឲ្យមានការកែតម្រូវ ឬ បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

# ផ្នែកទី ៧

# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

**ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**គ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ឃ- ប្រតិបត្តិការសំខាន់ៗ ជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ង- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលកាន់មុខតំណែងណាមួយ នៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ជ- ប្រតិបត្តិការសំខាន់ៗ ជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

# ផ្នែកទី ៨

# ការពិភាក្សា និងការវិភាគ

# របស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

កសស គឺជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ ហិកតា ដែលមានទីតាំងនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ កំណត់ក្នុង អនុក្រឹត្យលេខ ៥០ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ កសស មានតួនាទីជាប្រតិបត្តិករផែ ដូចមានលម្អិតនូវអាជីវកម្ម និងសេវាកម្មក្នុងផ្នែកទី១ ចំណុចទី២ ខាងលើនៃរបាយការណ៍ឆ្នាំ២០២២ នេះ ។

សម្រាប់ឆ្នាំ២០២២ នេះ បរិមាណកុងតែន័ររបស់ កសស មានការកើនឡើងចំនួន ១៧.៧៦១ TEUs ស្មើនឹង ២,៤៣% បើធៀបនឹងឆ្នាំ២០២១។ ចំណែកបរិមាណទំនិញឆ្លងកាត់គិតជាតោនមានកំណើន ០,១៨% ស្មើនឹង ១២.៨២០ តោន ដែលក្នុងនោះទំនិញកុងតែន័រ គិតជាតោនមានកំណើន ១,៦៦% ស្មើនឹង ៨២.១៨៧ តោន ប្រេង និងហ្គាសកើនឡើង ២,១៥% ស្មើនឹង ៣៨.៤២៤ តោន ចំណែកទំនិញរាយឆ្លងកាត់មានការថយចុះ ៤២,៩៩% ស្មើនឹង ១០៧.៧៩១តោន បើធៀបនឹងឆ្នាំ២០២១។ ចំពោះនាវាឆ្លងកាត់ កសស មានការថយចុះចំនួន ១៤០ នាវា ប្រមាណជា ៨,៨៥% រីឯចំណុះផ្ទុកនាវាមានការកើនឡើង ៥,៥៥% ស្មើនឹង ៧៤១.៦៣៣ តោន សម្រាប់ឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ កសស និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ ដោយសវនករឯករាជ្យសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២១ ដូចបង្ហាញក្នុងផ្នែកទី៦ នៃរបាយការណ៍ឆ្នាំ២០២២ នេះ ។

កសស មានប្រភពចំណូលសំខាន់ដូចខាងក្រោម ៖

- ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services)៖ គឺជាចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ចំណូលលើចំណុះផ្ទុក សំចតផែ ប្រឡាយ ថ្លៃឈ្នួលកណ្តជារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលប្រមូលសំរាម ។
- ចំណូលពីសេវាកម្មលើកដាក់កុងតែន័រពីនាវាទៅទីលានកុងតែន័រ (Stevedoring Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតែន័រចូល ឬចេញពីនាវានៅលើស្ពានផែ ។
- ចំណូលពីសេវាកម្មលើកដាក់កុងតែន័រនៅលើទីលាន (LOLO Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតែន័រ ចូល ឬចេញនៅលើទីលាន ។
- ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតែន័រ (Storage Fees)៖ គឺជាចំណូលដែលបានមកពីការស្តុកទំនិញរាយ ឬកុងតែន័រនៅក្នុងឃ្លាំង និងលើទីលាន ។
- ចំណូលដឹកជញ្ជូន (Transportation Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មដឹកជញ្ជូនទំនិញ ឬកុងតែន័រក្នុងបរិវេណផែ ។
- ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស (Special Economic Zone)៖ គឺជាចំណូលដែលទទួលបានពីការជួលដីធ្វើរោងចក្រ អគារ ពីតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កសស កត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិរបស់ខ្លួន ចំណែកប្រតិបត្តិការដែលជារូបិយប័ណ្ណអន្តរជាតិផ្សេងៗ ត្រូវបានបង្ហាញជាប្រាក់រៀលដោយប្រើអត្រាប្តូរប្រាក់ផ្លូវការជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ ។

## ១. ការវិភាគចំណូល

សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូល | ៣៤៣.៧៤៣.៥៤៥ | ៣៤២.៣៤៩.២២៩ | ១.៣៩៤.៣១៦ | 0,៤១% |

សម្រាប់ឆ្នាំ២០២២ នេះ ចំណូលរបស់ កសស មានការកើនឡើងចំនួន ១.៣៩៤.៣១៦.000 រៀល ស្មើនឹង 0,៤១% ដោយកើនពី ៣៤២.៣៤៩.២២៩.000 រៀល សម្រាប់ឆ្នាំ២០២១ មក ៣៤៣.៧៤៣.៥៤៥.000 រៀល សម្រាប់ឆ្នាំ២០២២។ ការកើនឡើងនៃចំណូលនេះ បណ្តាលមកពីសេវាកម្មលើកដាក់កុងតែន័រ ពីនាវាទៅទីលាន ( Stevedoring Charges ) និងចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតែន័រជាដើម។

## ១.១. ការវិភាគចំណូលតាមផ្នែក

តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកទៅនឹងប្រាក់ចំណូលសរុបសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន ( Stevedoring ) | ១៦៤.៨៧៣.៤៤៥ | ៤៧,៩៦% | ១៥៨.៥៦៦.៤៩៩ | ៤៦,៣២% |
| ចំណូលលើកដាក់លើទីលាន ( LOLO ) | ៩៦.៩២០.១៩៦ | ២៨,២0% | ១00.៦0២.0៤៦ | ២៩,៣៩% |
| ចំណូលពីសេវាកម្មនាវាចរ | ៦២.២៨៥.0៥0 | ១៨,១២% | ៦៥.0១៦.២៦៧ | ១៨,៩៩% |
| ចំណូលស្តុកឃ្លាំងនិងទីលាន | ១៥.៥១៦.៩៧៥ | ៤,៥១% | ១៤.៣៧៤.៤៨៨ | ៤,២0% |
| ចំណូលដឹកជញ្ជូន | ៩២.0៩0 | 0,0៣% | ១២២.៣២៦ | 0,0៤% |
| ចំណូលនាវាទេសចរណ៍ | 0 | 0,00% | 0 | 0,00% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ២.៣៧៤.៦៩៦ | 0,៦៩% | ២.១៩៥.៨៦៩ | 0,៦៤% |
| ចំណូលជួលទីតាំង | ១.៣៨៥.៥៤៣ | 0,៤0% | ១.១៦៨.២៤៨ | 0,៣៤% |
| ចំណូលផ្សេងៗទៀត | ២៩៥.៥៣៩ | 0,0៩% | ៣0៣.៤៨៦ | 0,0៩% |
| **ចំណូលសរុប** | **៣៤៣.៧៤៣.៥៤៥** | **១00,00%** | **៣៤២.៣៤៩.២២៩** | **១00,00%** |

សម្រាប់ឆ្នាំ២០២២ ក៏ដូចជាឆ្នាំ២០២១ មានចំណូលសំខាន់ ៤ ប្រភេទដែលមានចំនួនប្រមាណ ៩៨% នៃចំណូលអាជីវកម្ម និងសេវាកម្មសរុបរបស់ កសស។ ចំណូលទាំងនោះរួមមាន ៖ ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) ចំណូលលើកដាក់លើទីលាន (LOLO) ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services) និងចំណូលស្តុកឃ្លាំង និងទីលាន ។

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ១៦៤.៨៧៣.៤៤៥ | ១៥៨.៥៦៦.៤៩៩ | ៦.៣០៦.៩៤៦ | ៣,៩៨% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ៩៦.៩២០.១៩៦ | ១០០.៦០២.០៤៦ | (៣.៦៨១.៨៥០) | -៣,៦៦% |
| ចំណូលពីសេវាកម្មនាវាចរ | ៦២.២៨៥.០៥០ | ៦៥.០១៦.២៦៧ | (២.៧៣១.២១៧) | -៤,២០% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ១៥.៥១៦.៩៧៥ | ១៤.៣៧៤.៤៨៨ | ១.១៤២.៤៨៧ | ៧,៩៥% |

ចំណូលពីការលើកដាក់ពីនាវាទៅទីលានកុងតែន័រ (Steverdoring) កើនឡើងចំនួន ៦.៣០៦.៩៤៦.០០០ រៀល ស្មើនឹង ៣,៩៨% សម្រាប់ឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ និងចំណូលពីការលើកដាក់នៅលើទីលាន (LOLO) មានការថយចុះប្រមាណ ៣,៦៦% ស្មើនឹង ៣.៦៨១.៨៥០.០០០ រៀល បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១។ ការកើនឡើងលើចំណូលលើកដាក់ពីនាវាទៅទីលាន គឺបណ្តាលមកពីការកើនឡើងនៃបរិមាណកុងតែន័រឆ្លងកាត់ កសស មានចំនួន ១៧.៧៦១ TEUs ស្មើនឹង ២,៤៣% សម្រាប់ឆ្នាំ២០២២ នេះ និងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ចំនួន ០,១៨%។ ទន្ទឹមគ្នានេះផងដែរការថយចុះចំណូលលើកដាក់លើទីលាននៅឆ្នាំ២០២២ គឺមកពីបរិមាណទំនិញលើករៀបដោយការប្រគល់ដោយផ្ទាល់ មានការថយចុះចំនួន ៣៩,៩៩%។

ចំពោះចំណូលសេវាកម្មនាវាចរ (Port Charges for Vessel Services) គឺអាស្រ័យលើចំនួន និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ កសស ហើយសម្រាប់ឆ្នាំ២០២២ នេះ នាវាសរុបដែលឆ្លងកាត់ កសស មានការថយចុះ ១៤០ នាវា ស្មើនឹង ៨,៨៥% ហើយចំណុះផ្ទុកនាវាមានការកើនឡើងប្រមាណ ៥,៥៥% ស្មើនឹង ៧៤១.៦៣៣ តោន ធ្វើឱ្យចំណូលពីសេវាកម្មផែមានការថយចុះបន្តិចពី ៦៥.០១៦.២៦៧.០០០ រៀល សម្រាប់ឆ្នាំ២០២១ មក ៦២.២៨៥.០៥០.០០០ រៀល សម្រាប់ឆ្នាំ២០២២ គឺប្រមាណ ៤,២០% ស្មើនឹង ២.៧៣១.២១៧.០០០ រៀល។ ការថយចុះនៃចំណូលសេវាកម្មនាវាចរនេះ ដោយនាវាដឹកទំនិញទូទៅ ក្នុងឆ្នាំ២០២២ ចំណុះផ្ទុកនាវាដឹកទំនិញទូទៅមានការថយចុះប្រមាណ ៣,៩៣% និងចំនួននាវាដឹកទំនិញទូទៅថយចុះ ៧២ គ្រឿង បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។

ចំណូលពីសេវាកម្មស្តុកឃ្លាំង និងទីលានមានការកើនឡើងចំនួន ១.១៤២.៤៨៧.០០០ រៀល ស្មើនឹង ៧,៩៥% បើប្រៀបធៀបចំណូលឆ្នាំ២០២២ មាន ១៥.៥១៦.៩៧៥.០០០ រៀល និងឆ្នាំ២០២១ មានចំណូល ១៤.៣៧៤.៤៨៨.០០០ រៀល។ ការកើនឡើងនេះបណ្តាលមកពី បរិមាណកុងតែន័រ និងទំនិញកើន ។

## ២. ការវិភាគតំលាតចំណេញដុល

កសស បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមយថាប្រភេទ ដូចនេះ ពុំមានការបង្ហាញឱ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការបានដោយទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ ។

ចំណាយប្រតិបត្តិការនឹងលើកមកពិភាក្សា និងវិភាគនៅផ្នែកខាងក្រោមគឺ ចំណុច គ-ការវិភាគចំណេញមុនបង់ពន្ធ។

## ៣. ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធ គឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិ និងចំណូល ឬចំណាយហិរញ្ញវត្ថុ-សុទ្ធ។ ក្នុងការវិភាគនៃចំណាយប្រតិបត្តិការ យើងនឹងលើកយកចំណាយសម្ភារៈផ្គត់ផ្គង់ ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ចំណាយរំលស់ (ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) ចំណាយជួសជុល និងថែទាំ ចំណាយផ្សេងៗ និងចំណេញ (ឬខាត) ផ្សេងៗ សុទ្ធ ដូចខាងក្រោម៖

**សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១**

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូលសរុប | ៣៨៣.៧៨៣.៥៤៥ | ៣៨២.៣៨៩.២២៩ | ១.៣៩៤.៣១៦ | ០,៤១% |
| ចំណាយសម្ភារៈផ្គត់ផ្គង់ | (១០៦.៣៦៤.៨៦១) | (៩៣.៧៣៩.២៤៦) | (១២.៦២៥.៦១៥) | ១៣,៤៧% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (១០៥.៦៧២.០៩៧) | (១០៤.៣៦៦.៩៤៩) | (១.៣០៥.១៤៨) | ១,២៥% |
| ចំណាយរំលស់(ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) | (៤៥.៦៩៧.៧៤៨) | (៣៩.៩២២.៦៧៧) | (៥.៧៧៥.០៧១) | ១៤,៤៧% |
| ចំណាយជួសជុល និងថែទាំ | (២.២៨៨.១១៦) | (៤.៨៥៧.០៥៣) | ២.៥៦៨.៩៣៧ | -៥២,៨៩% |
| ចំណាយផ្សេងៗ | (២៧.១២៦.៨៩៩) | (២០.៣៤៧.៤០៦) | (៦.៧៧៩.៤៩៣) | ៣៣,៣២% |
| ខាត/(ចំណេញ)ផ្សេងៗ-សុទ្ធ | ៤៤៩.៥៨៥ | (២៧៣.៣០០) | ៧២២.៨៨៥ | -២៦៤,៥០% |
| (ចំណាយ)/ចំណូលហិរញ្ញវត្ថុ-សុទ្ធ | ៤០.៨៥៣.៦៧១ | ៣២.២០៣.០៣៩ | ៨.៦៥០.៦៣២ | ២៦,៨៦% |
| ចំណេញមុនបង់ពន្ធ | ៩៧.៨៩៧.០៨០ | ១១១.០៤៥.៦៣៧ | (១៣.១៤៨.៥៥៧) | -១១,៨៤% |

សម្រាប់ឆ្នាំ២០២២ កសស មានចំណាយសម្ភារៈផ្គត់ផ្គង់ ១០៦.៣៦៤.៨៦១.០០០ រៀល ដែលមានការកើនឡើងចំនួន ១២.៦២៥.៦១៥.០០០ រៀល ស្មើនឹង ១៣,៤៧% បើធៀបនឹងឆ្នាំ២០២១ ដែលមានចំណាយ ៩៣.៧៣៩.២៤៦.០០០ រៀល។ កត្តាចម្បងដែលបណ្តាលឱ្យមានការកើនឡើងនេះ គឺដោយសារចំណាយសម្ភារៈងាយឆេះ (ប្រេងឥន្ធនៈ) កើនឡើង ២៣,៩៥% ស្មើនឹង ១០.៧០០.៣៧៣.០០០ រៀល ដោយតម្លៃជាមធ្យមរបស់ប្រេងឥន្ធនៈមានការកើនឡើងពី ០,៦៨ ដុល្លារ ក្នុងមួយលីត្រ សម្រាប់ឆ្នាំ២០២១ ទៅ ១,០៦ ដុល្លារ ក្នុងមួយលីត្រ សម្រាប់ឆ្នាំ២០២២។ ចំពោះចំណាយលើគ្រឿងបន្លាស់មានការកើនឡើង ១១,១៧% ស្មើនឹង ៣.៦៧៧.២៦១.០០០ រៀល បើធៀបនឹងឆ្នាំ២០២១ ។

មូលដ្ឋានក្នុងការគណនាប្រាក់បៀវត្សរបស់ កសស គឺយោងទៅលើទិន្នផល (ចំណូលពីការលើកដាក់) ពោលគឺនៅពេលចំណូលពីការលើកដាក់កើនឡើង ចំណាយបៀវត្សនឹងកើនឡើង ផ្ទុយទៅវិញបើចំណូលពីការលើកដាក់មានការថយចុះ ចំណាយលើប្រាក់បៀវត្សនឹងត្រូវថយចុះដូចគ្នា ហើយយើងសង្កេតឃើញថាចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) និងចំណូលលើកដាក់លើទីលាន (LOLO) មានការកើនឡើងបន្តិចសម្រាប់ ឆ្នាំ២០២២នេះ។ ចំពោះចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ មានការកើនឡើងប្រមាណ ១,២៥% ស្មើនឹង ១.៣០៥.១៤៨.០០០ រៀល បើប្រៀបធៀបចំណាយសម្រាប់ឆ្នាំ២០២២ ដែលមានចំនួន ១០៥.៦៧២.០៩៧.០០០ រៀល និងឆ្នាំ២០២១ ដែលមានចំណាយ ១០៤.៣៦៦.៩៤៩.០០០ រៀល។ កត្តាសំខាន់ដែលធ្វើអោយមានកំណើននេះ គឺបណ្តាលមកពីប្រាក់បៀវត្សបុគ្គលិកមានការកើនឡើង ២,២៧% ស្មើនឹង ១.៥៧១.៨៩១.០០០ រៀល និងការចំណាយលើចំណាយសន្តិសុខសង្គមផ្សេងៗ មានការកើនឡើងចំនួន ៧៦៣.៥០៩.០០០រៀល ស្មើនឹង ៩៧,៥១% សម្រាប់ឆ្នាំ២០២២នេះ ។

ចំណាយរំលស់រួមមាន រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបីនៅក្នុងឆ្នាំ២០២២ មានចំនួន ៤៥.៦៩៧.៧៤៨.០០០ រៀល មានកំណើន ៥.៧៧៥.០៧១.០០០ រៀល ស្មើនឹង ១៤,៤៧% បើធៀបនឹងឆ្នាំ២០២១ ដែលមានចំនួន ៣៩.៩២២.៦៧៧.០០០ រៀល។ កត្តាដែលធ្វើឱ្យមានការកើនឡើងនេះគឺដោយសារចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារមានកំណើន ៥.៨៥៦.៩០៧.០០០ រៀល ស្មើនឹង ១៨,០២% និងកំណើនលើចំណាយរំលស់ទ្រព្យសម្បត្តិអរូបី ៥,៨១% ស្មើនឹង ៦៤.១៩៥.០០០ រៀល ។

ចំណែកចំណាយជួសជុល និងថែទាំមានការថយចុះ ២.៥៦៨.៩៣៧.០០០ រៀល ស្មើនឹង ៥២,៨៩% ដោយមានចំណាយសរុបស្មើនឹង ២.២៨៨.១១៦.០០០ រៀល សម្រាប់ឆ្នាំ២០២២ និង ៤.៨៥៧.០៥៣.០០០ រៀល សម្រាប់ឆ្នាំ២០២១ ។

ចំពោះចំណាយផ្សេងៗសរុប មានការកើនឡើងប្រមាណ ៣៣,៣២% ស្មើនឹង ៦.៧៧៩.៤៩៣.០០០ រៀល ពោលគឺកើនឡើងពី ២០.៣៤៧.៤០៦.០០០ រៀល សម្រាប់ឆ្នាំ២០២១ មក ២៧.១២៦.៨៩៩.០០០ រៀល សម្រាប់ឆ្នាំ២០២២។ កត្តាដែលធ្វើអោយមានការកើនឡើងនេះ គឺបណ្តាលមកពីការកើនឡើងចំណាយទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច ៧៥,១៧% ស្មើនឹង ១.០៦៩.៥៣៧.០០០រៀល និងចំណាយលើបេសកកម្មមន្ត្រី-បុគ្គលិកកើនឡើងប្រមាណ ១០៥,៨៩% ស្មើនឹង ៨៣១.១៧៧.០០០ រៀល ហើយចំណាយទឹកភ្លើងមានការកើនឡើងប្រហែល ៦៧៧,៤៣% ស្មើនឹង ២.៤៨១.៩១៨ បើធៀបនឹងឆ្នាំ២០២១ គឺដោយសារការប្រើប្រាស់អគ្គិសនីរបស់ កសស។ សម្រាប់ឆ្នាំកន្លងៗមក កសស បានប្រើប្រាស់អគ្គិសនីដោយដំណើរការម៉ាស៊ីនភ្លើងដោយខ្លួនឯងសម្រាប់ប្រើប្រាស់អគ្គិសនីក្នុងតំបន់ កសស នេះផ្ទាល់។ ដោយឡែកសម្រាប់ឆ្នាំ២០២២ វិញ កសស បានតបណ្តាញអគ្គិសនីរដ្ឋចូលដើម្បីប្រើប្រាស់ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២២ មក ទើបធ្វើអោយចំណាយទឹកភ្លើងមានការកើនឡើងខ្លាំងសម្រាប់ឆ្នាំ២០២២ នេះ។

ខាត/(ចំណេញ)ផ្សេងៗ-សុទ្ធ (Realized Foreign Exchange Gain-Losses) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេច ដែលសម្រាប់ឆ្នាំ២០២២ នេះ មានការចំណេញចំនួន ៤៤៩.៥៨៥.០០០ រៀល បើធៀបនឹងឆ្នាំ២០២១ មានការខាតចំនួន ២៧៣.៣០០.០០០ រៀល ធ្វើឱ្យមានការកើនឡើងពីការចំណេញប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេចប្រមាណ ២៦៤,៥០% ស្មើនឹង ៧២២.៨៨៥.០០០ រៀល ក្នុងឆ្នាំ២០២២ នេះ។

ចំណែក ចំណាយ/(ចំណូល)ហិរញ្ញវត្ថុ-សុទ្ធ (Unrealized Foreign Exchange Gain-Loss ) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទមិនទាន់សម្រេច ដោយឆ្នាំ២០២២ មាន ចំណាយ/(ចំណូល) ហិរញ្ញវត្ថុ-សុទ្ធ ចំនួន ៤០.៨៥៣.៦៧១.០០០ រៀល ដែលមានការកើនឡើងប្រមាណ ២៦,៨៦%

ស្មើនឹង ៨.៦៥០.៦៣២.០០០ រៀល បើធៀបនឹងឆ្នាំ២០២១ ដែលមានចំណាយ/(ចំណូល)ហិរញ្ញវត្ថុ-សុទ្ធ ចំនួន ៣២.២០៣.០៣៩.០០០ រៀល។ កត្តាសំខាន់ដែលបណ្តាលឱ្យមានបំរែបំរួលលើចំណាយ/(ចំណូល)ហិរញ្ញវត្ថុ-សុទ្ធ គឺដោយសារការកើនឡើងនៃការចំណេញពីការប្តូររូបិយវត្ថុមិនទាន់សម្រេចរបស់ប្រាក់កម្ចី (ប្រាក់យ៉េន) ប្រមាណ ១២,០៤% ស្មើនឹង ៤.៧៥៩.៤២៨.០០០ រៀល ដោយក្នុង ឆ្នាំ២០២២ មានការចំណេញចំនួន ៤៤.២៩០.៧៩៤.០០០ រៀល ធៀបនឹងឆ្នាំ២០២១ មានការចំណេញចំនួន ៣៩.៥៣១.៣៦៦.០០០ រៀល។

ជាសរុប ចំណេញមុនបង់ពន្ធសម្រាប់ឆ្នាំ២០២២ របស់ កសស មានចំនួន ៩៧.៨៩៧.០៨០.០០០ រៀល ថយចុះចំនួន ១៣.១៤៨.៥៥៧.០០០ រៀល ប្រមាណជា ១១,៨៤% បើធៀបនឹងឆ្នាំ២០២១ ចំណេញមុនបង់ពន្ធមានចំនួន ១១១.០៤៥.៦៣៧.០០០ រៀល ។

## ៤. ការវិភាគចំណេញក្រោយបង់ពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា ២០%។ ចាប់ពីឆ្នាំ២០២០ នេះតទៅ កសស នឹងបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួន ក្នុងអត្រា ២០% វិញ ក្រោយពីទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រចំនួនបីឆ្នាំកន្លងមក (ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩) ។

### សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណេញមុនបង់ពន្ធ (ក) | ៩៧.៨៩៧.០៨០ | ១១១.០៤៥.៦៣៧ | (១៣.១៤៨.៥៥៧) | -១១,៨៤% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (១៣.៧៤១.៨៦៥) | (១៧.៣៣៨.២៤៧) | ៣.៥៩៦.៣៨២ | -២០,៧៤% |
| ចំណេញក្នុងការិយបរិច្ឆេទ | ៨៤.១៥៥.២១៥ | ៩៣.៧០៧.៣៩០ | (៩.៥៥២.១៧៥) | -១០,១៩% |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ | ១១.៨៥៨.៨៤០ | ០ | ១១.៨៥៨.៨៤០ | ១០០,០០% |
| លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក | ៩៦.០១៤.០៥៥ | ៩៣.៧០៧.៣៩០ | ២.៣០៦.៦៦៥ | ២,៤៦% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ១៤,០៤% | ១៥,៦១% | | |

កសស មានចំណេញក្នុងការិយបរិច្ឆេទចំនួន ៨៤.១៥៥.២១៥.០០០ រៀល សម្រាប់ឆ្នាំ២០២២ ដែលមានការថយចុះចំនួន ៩.៥៥២.១៧៥.០០០ រៀល ស្មើនឹង ១០,១៩% ធៀបនឹងឆ្នាំ២០២១ ដែលមានចំណេញក្នុងការិយបរិច្ឆេទចំនួន ៩៣.៧០៧.៣៩០.០០០ រៀល។ កត្តាដែលធ្វើឱ្យចំណេញក្នុងការិយបរិច្ឆេទមានការថយចុះនេះ គឺបណ្តាលមកពីចំណាយប្រតិបត្តិការមានការកើនឡើង ក្នុងឆ្នាំ២០២២ បើធៀបនឹងឆ្នាំ២០២១ ។

បើសង្កេតទៅលើអត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញមានការថយចុះពី ១៥,៦១% សម្រាប់ឆ្នាំ២០២១ ដល់ ១៤,០៤% សម្រាប់ឆ្នាំ២០២២ ដោយសារមានការថយចុះនៃចំណេញមុនបង់ពន្ធ ក្នុងឆ្នាំ២០២២ នេះ ។

## ៥. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កត្តាមួយចំនួនអាចមានឥទ្ធិពលលើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ កសស ដូចជា៖

- **កត្តានានាដែលធ្វើឱ្យមានកំរិតលើការធ្វើពាណិជ្ជកម្មអន្តរជាតិ**

ដោយសារប្រភពចំណូលចម្បងរបស់ កសស បានមកពីចរាចរណ៍ទំនិញឆ្លងកាត់ដែលជាការធ្វើ ពាណិជ្ជកម្មអន្តរជាតិ ដូចនេះកត្តានានាដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ និងមានឥទ្ធិពលលើអាជីវកម្មរបស់ កសស ដែលកត្តាទាំងនោះមានដូចជា ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ក្នុងតំបន់ និងសាកលលោក ស្ថេរភាពសង្គម បញ្ហាសន្តិសុខ ឬកិច្ចសហប្រតិបត្តិការនាវាចរតាមសមុទ្រ។ យោងតាមមូលនិធិរូបិយ ប័ណ្ណអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៣,២% សម្រាប់ឆ្នាំ២០២២ ចំណែកសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៥,៣% យោងតាម ASIAN DEVELOPMENT BANK (ADB) នេះបង្ហាញថាស្ថានភាពសេដ្ឋកិច្ចកម្ពុជានៅតែមានភាពរឹងមាំ ដែលជាកត្តាវិជ្ជមានចំពោះអាជីវកម្មកំពង់ផែ ។

- **សមត្ថភាព និងប្រសិទ្ធភាពបំពេញការងាររបស់ កសស**

សម្រាប់ឆ្នាំ២០២២ កសស មានសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់មធ្យោបាយលើកដាក់កុងតែន័រ ធុនធ្ងន់ ប្រភេទ រថស្ទូចចល័តលើគែមផែ (QC) ចំនួន ០១ គ្រឿង និងរថស្ទូចចល័តនៅទីលាន (RTG) ចំនួន ០២ គ្រឿង រថលើកដាក់កុងតែន័រទទេ (Empty Reach Stacker) ចំនួន ០៤ គ្រឿង បន្ថែមទៀត កាលពីឆ្នាំ២០២១នេះ។ កត្តានេះធ្វើឱ្យសមត្ថភាព និងប្រសិទ្ធភាពការងារមានការកើនឡើងក្នុងការបំពេញសេវាកម្មរបស់ខ្លួន ស្របទៅនឹងកំណើនទំនិញឆ្លងកាត់របស់ កសស ។

- **ស្ថានភាពបណ្តាញដឹកជញ្ជូនក្នុងស្រុក**

សម្រាប់ ឆ្នាំ២០២២ នេះ បណ្តាញដឹកជញ្ជូនក្នុងស្រុក ពិសេសផ្លូវជាតិលេខ៤ ដែលតភ្ជាប់ពី កសស ទៅរាជធានីភ្នំពេញ ពុំមានបង្កជាឧបសគ្គដល់ការដឹកជញ្ជូនទំនិញឡើយ។ រីឯការដឹកជញ្ជូនតាមផ្លូវដែកបច្ចុប្បន្នក្រុមហ៊ុន Royal Railway ឆ្លងកាត់ កសស មានចំនួន ៦ជើង ក្នុងមួយសប្តាហ៍ក្នុងការនាំទំនិញចេញចូល ហើយការដឹកជញ្ជូនតាមផ្លូវដែកនេះ ក៏ប្រព្រឹត្តទៅដោយរលូនតាមធម្មតាមិនមានបញ្ហាធ្វើឱ្យខកខានដំណើរនោះទេ ។

- **កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់**

កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់ ពិសេសគឺការតភ្ជាប់ជាមួយកំពង់ផែមេក្នុងតំបន់មានសារៈសំខាន់ក្នុងការសំរួលចរាចរណ៍ទំនិញរវាង កសស និងទីផ្សារអន្តរជាតិសំខាន់ៗ ដោយមានឥទ្ធិពលលើចំណាយ និងរយៈពេលដឹកជញ្ជូន ដែលជាលទ្ធផលធ្វើឱ្យមានផលប៉ះពាល់លើភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនានា។ ក្នុងករណីនេះ កសស បានខិតខំរក្សាទំនាក់ទំនងល្អជាមួយបណ្តាកំពង់ផែសំខាន់ៗ ក្នុងតំបន់ដើម្បីធានាឱ្យប្រតិបត្តិការមានភាពរលូន។

- **រំលស់**

ដោយអាជីវកម្មរបស់ កសស មានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រើន ចំណាយលើរំលស់លើហេដ្ឋា រចនាសម្ព័ន្ធផែដូចជា ចំណតនាវា គ្រឿងចក្រ អគារ មានទំហំធំដែលអាចប៉ះពាល់ដល់អាជីវកម្មរបស់ កសស។ ដូចនេះ កសស ចាំបាច់ត្រូវមានការត្រួតពិនិត្យលើគោលនយោបាយរំលស់ឱ្យបានសមស្រប និងធ្វើការកែតម្រូវ តាមការចាំបាច់រៀងរាល់ការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ។ សម្រាប់ឆ្នាំ២០២២នេះ ពុំមានការកែសម្រួល ឬការស្នើឱ្យមានការកែសម្រួលគោលនយោបាយរំលស់នេះពីសវនករឯករាជ្យឡើយ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សកម្មភាពអាជីវកម្មរបស់ កសស មានទំនាក់ទំនងដោយផ្ទាល់ជាមួយសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសាកលលោក។ ជាពិសេសនៅពេលសេដ្ឋកិច្ចជាតិមានបម្រែបម្រួល និងមានឥទ្ធិពលដោយផ្ទាល់ទៅលើអាជីវកម្ម សេវាកម្មកំពង់ផែ ពោលគឺនៅពេលសេដ្ឋកិច្ចជាតិកើនឡើងនាំឱ្យអាជីវកម្ម សេវាកម្ម កំពង់ផែក៏កើនឡើងស្របនឹងនេះផលចំណូលរបស់ កសស ក៏មានកំណើនដូចគ្នា ផ្ទុយទៅវិញ បើសេដ្ឋកិច្ចជាតិថយចុះ នឹងមានផលអវិជ្ជមានទៅលើផលចំណូល កសស ផងដែរ។ យោងតាម ASIAN DEVELOPMENT BANK (ADB) សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងអត្រារំពឹងទុកប្រមាណ ៣,២% ចំណែកសេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៥,៣% (IMF) សម្រាប់ឆ្នាំ២០២២ នេះ។ ទោះយ៉ាងណាក៏ដោយ កសស អាចមានកត្តាផលប៉ះពាល់ទៅដល់តម្រូវការ និងការផ្គត់ផ្គង់ដោយសារស្ថានភាពសង្គ្រាម រុស្ស៊ីនិងអ៊ុយក្រែនបច្ចុប្បន្ន និងការនាំចេញនាំចូលទៅប្រទេស ចិនដោយសារការបិទខ្ទប់ព្រោះគោលនយោបាយCovidសូន្យផងដែរ ។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រេងឥន្ធនៈ ជាវត្ថុធាតុដើមចម្បងបំផុតក្នុងការបម្រើសេវាកម្មកំពង់ផែ ដោយជាតម្រូវការសំខាន់សម្រាប់ប្រតិបត្តិការគ្រឿងចក្រ។ កសស នៅតែរក្សាតម្លៃសេវារបស់ខ្លួនដដែល បើទោះជាតម្លៃប្រេងឥន្ធនៈមានការកើនឡើង ឬថយចុះ ក៏ដោយ។ ហេតុដូចនេះ កសស បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លៃរបស់វត្ថុធាតុដើមទាំងនេះមានភាពសមស្រប និងប្រកួតប្រជែងក្នុងតម្លៃទីផ្សារ ។

### ៣. ការវិភាគលើពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ កសស ត្រូវបង់ពន្ធអាករទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំចាប់ពីឆ្នាំ២០២០ នេះតទៅ កសស ត្រូវបំពេញកាតព្វកិច្ចបង់ពន្ធក្នុងអត្រា ២០% វិញក្រោយពីទទួលបានការលើកទឹកចិត្តក្នុងវិស័យមូលបត្ររយៈពេលបីឆ្នាំកន្លងមក ចំណែកពន្ធផ្សេងៗ កសស បានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ កសស មានចំណូលលើកដាក់ និងចំណូលពីសេវាកម្មផែដែលរួមចំណែកប្រមាណ ៩៨% នៃចំណូលសរុបសម្រាប់ឆ្នាំ២០២២ ហើយកត្តាចម្បងដែលជំរុញឱ្យមានការកើនឡើងនៃប្រាក់ចំណូល គឺកំណើននៃនាវា និងទំនិញឆ្លងកាត់កំពង់ផែ ជាពិសេសទំនិញកុងតែន័រ ដែលជាប្រភពចំណូលដ៏សំខាន់របស់ កសស។ ការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យសំណង់ និងវិស័យឧស្សាហកម្ម គឺបានឆ្លុះបញ្ចាំងនូវស្ថានភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ហើយស្របនឹងនេះក៏មានឥទ្ធិពលជាវិជ្ជមានលើអាជីវកម្មសេវាកម្ម និងផលចំណូលរបស់ កសស ផងដែរ។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ( Commodity )

### ១. ផលប៉ះពាល់ពីអត្រាប្តូរប្រាក់

កសស បានទទួលប្រាក់កម្ចីបន្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី JICA និង JBIC ដោយតម្រូវឱ្យ កសស សងប្រាក់ដើម និងការប្រាក់ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក នៅពេលដែលរូបិយវត្ថុមុខងាររបស់ កសស គឺជាប្រាក់រៀល។ ដូចនេះ បំរែបំរួលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េនជប៉ុន នឹងមានផលប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ កសស ។

### ២. ផលប៉ះពាល់ពីអត្រាការប្រាក់

បច្ចុប្បន្ន កសស មិនមានកម្ចីណាដែលមានអត្រាការប្រាក់ប្រែប្រួលនោះទេ។ កសស បានទទួលប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាកម្ចីបន្តពី JICA និង JBIC ក្នុងអត្រាការប្រាក់ចាប់ពី ២,៦៥% ដល់ ៣,៧០%។ ហេតុដូចនេះ សម្រាប់ឆ្នាំ២០២២ នេះ មិនមានផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នេះទេ ។

### ៣. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ការប្រែប្រួលតម្លៃប្រេងឥន្ធនៈនឹងមានផលប៉ះពាល់ដល់ផលចំណេញរបស់ កសស ដោយប្រតិបត្តិការកំពង់ផែពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រដែលប្រើប្រាស់ប្រេងឥន្ធនៈ។ ហេតុដូចនេះ កសស បានពង្រឹងប្រសិទ្ធភាពលើកដាក់ និងការគ្រប់គ្រងទីលានកុងតែន័រ ដើម្បីកាត់បន្ថយការរើ ឬការបំលាស់ទីកុងតែន័រដែលមិនចាំបាច់ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកំពស់សេវាកម្មរបស់ខ្លួន ។

## ង- ផលប៉ះពាល់នៃអតិផរណា

កសស បានរក្សានូវតម្លៃសេវាកម្មរបស់ខ្លួនថេរ ដោយមិនធ្វើការប្រែប្រួល ឬកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុបានយ៉ាងប្រសើរ ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

គោលនយោបាយ សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើអាជីវកម្មរបស់ កសស ដោយសារគោលនយោបាយនេះមានទិសដៅគាំទ្រ និងលើកស្ទួយវិស័យពាណិជ្ជកម្មអន្តរជាតិ និងផ្តល់ផលវិជ្ជមានដល់អាជីវកម្មរបស់ កសស។ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន៖

- គោលនយោបាយលើកស្ទួយវិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលមានគំរោងប្រែក្លាយខេត្តព្រះសីហនុ ឱ្យទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឡូជីស្ទីក និងផលិតកម្ម តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផែ ពង្រីកផ្លូវជាតិលេខ៤ និងហេដ្ឋារចនាសម្ព័ន្ធព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុផងដែរ ។
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវល្បឿនលឿនពី ភ្នំពេញ-ខេត្តព្រះសីហនុ ចំណេញពេលវេលា និងចំណាយផ្សេងៗ។
- វិស័យឧស្សាហកម្មរ៉ែ ថាមពល ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា កំពុងមានការអភិវឌ្ឍន៍ ហើយ កសស បានត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រវិស័យទាំងនោះ
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- គោលនយោបាយនាំចេញអង្ករចេញទៅទីផ្សារក្រៅប្រទេស កំពុងផ្តល់ផលវិជ្ជមានដល់ កសស

- គោលនយោបាយលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ ដោយខិតខំកាត់បន្ថយឧបសគ្គនានា ចំពោះការធ្វើពាណិជ្ជកម្មរវាងកម្ពុជា និងបណ្តាប្រទេសជាដៃគូក្នុងសាកលលោក
- រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិ បានអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈយន្តការ ទីផ្សារប្តូរប្រាក់សេរីតែស្ថិតនៅក្រោមអន្តរាគមន៍ ដើម្បីរក្សាស្ថិរភាពរូបិយប័ណ្ណជាតិ ហើយលំនឹងរូបិយវត្ថុនេះបានរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលបានកសាងទំនុកចិត្តចំពោះវិនិយោគិន និងជម្រុញការធ្វើអាជីវកម្មវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាននឹងកំពុងជម្រុញឱ្យសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជនចូលទីផ្សារមូលបត្រកាន់តែច្រើនដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

# ផ្នែកទី ៩

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

សម្រាប់ឆ្នាំ២០២២ នេះ កសស មានព័ត៌មានចាំបាច់សម្រាប់ការ ការពារវិនិយោគិនដូចខាងក្រោម ៖

❖ ក្រុមប្រឹក្សាភិបាលបានធ្វើការជួបប្រជុំចំនួន ០៤ លើក

**១. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៣ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២**

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission និងបានស្នើអោយ កសស រៀបចរបាយការណ៍ស្តីពីផលប្រយោជន៍ និងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ ជូនក្រសួងអាណាព្យាបាលទាំងពីរ និងស្នើសុំអោយ លោក KUME Hidetoshi ជួយសម្របសម្រួល និងចរចារបន្ថែមទៀតទៅភាគីជប៉ុនលើការបញ្ចុះអត្រាការប្រាក់ជាអប្បបរិមា ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័ត ដូចខាងក្រោម ៖
    - ឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ឆ្នាំ២០២១
    - ឯកភាពលើវិធានការណ៍ដោះស្រាយបន្ទាន់ និងស្នើអោយ កសស ត្រូវរៀបចំលិខិតគោរពជូនឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីស្នើសុំគោលការណ៍ផ្លាស់ប្តូរទីតាំងរបស់សមត្ថកិច្ចត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅដើមទី ពីក្នុងបរិវេណ កសស ទៅក្រៅបរិវេណ កសស វិញ
    - ឯកភាពជាគោលការណ៍លើ គម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ក្នុងស្រុក នៅប្រកលេខ១ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ( Financial performance review ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី ការអនុគ្រោះថ្លៃឈ្នួល សេវារបស់ កសស ចំពោះទំនិញរាជរដ្ឋាភិបាល ប្រចាំឆ្នាំ២០២១ មានចំនួនជាទឹកប្រាក់សរុប ៨៨.៣១២,១៩ USD ( ប៉ែតសិបប្រាំបីពាន់ បីរយដប់ពីរ ដុល្លារអាមេរិក និងដប់ប្រាំបួនសេន ) ។

**២. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៤ នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២**

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission និង Appraisal Mission ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ត្រីមាសទី១ ឆ្នាំ២០២២ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី១ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young ( Financial Performance Review ) ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈសម្រាប់មហាសន្និបាតភាគហ៊ុនិក លើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម ៖
  - កាលបរិច្ឆេទ : ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
  - កាលបរិច្ឆេទកំណត់ទុក : ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២
  - ទីកន្លែងប្រារព្ធមហាសន្និបាត (Venue) : សុខា ប៊ិច រីសត, ខេត្តព្រះសីហនុ ជាមួយនឹងប្រព័ន្ធវីដេអូខល ZOOM (ទៅតាមស្ថានភាពជាក់ស្តែង)
  - របៀបវារៈមហាសន្និបាត
    - មតិស្វាគមន៍របស់ ប្រធានមហាសន្និបាត
    - បទបង្ហាញ ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២១ និងទិសដៅអនុវត្តការងារ ឆ្នាំ២០២២
    - ពិនិត្យ និងអនុម័ត បែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពឱ្យ កសស ស្នើសុំការអនុម័តការបែងចែកភាគលាភ (Dividend) ការកំណត់កាលបរិច្ឆេទកំណត់ទុកដែលត្រូវបែងចែកភាគលាភ (Record Date) និងកាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) ជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ២០២១ នៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម ៖
  - បែងចែកភាគលាភជូន
    - ភាគហ៊ុនិកប្រភេទ "ខ" ស្មើនឹងទឹកប្រាក់ចំនួន ៥,៣០០,០០០,០០០ រៀល
    - ភាគហ៊ុនិកប្រភេទ "គ" ក្នុងអត្រា ៨%, ៩%, ១០%, ១១% ឬ ១២% នៃតម្លៃមូលបត្របោះផ្សាយលក់លើកដំបូង (IPO Price) ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី៥ ពិនិត្យ និងអនុម័ត
    - ប្រភេទភាគលាភដែលត្រូវបែងចែក : សាច់ប្រាក់
    - រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២១
  - ចំនួនមូលបត្រដែលបានចុះបញ្ជីសរុប : ៨៥.៧៧១.៩៦៧ មូលបត្រ
    - ចំនួនមូលបត្រ ប្រភេទ "ខ" : ៦៤.៣២៨.៩៧៥ មូលបត្រ
    - ចំនួនមូលបត្រ ប្រភេទ "គ" : ២១.៤៤២.៩៩២ មូលបត្រ
  - ចំនួនភាគលាភសរុបដែលត្រូវបែងចែក
    - បែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៥.៣០០.០០០.០០០ រៀល
    - បែងចែកជូនភាគហ៊ុនប្រភេទ "គ": បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
  - អនុបាតនៃការបែងចែកភាគលាភសរុបជូនភាគហ៊ុនប្រភេទ "ខ" និង "គ"
    - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "ខ": ៦,២៨ %
    - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "គ": បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
  - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ
    - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៨២,៣៩ រៀល
    - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "គ" : សម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥

- ○ កាលបរិច្ឆេទកំណត់ទុក (Record Date) : ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២២
- ○ កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) : ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ កសស ស្វែងរកដំណោះស្រាយឱ្យបានអស់ពីលទ្ធភាពទៅលើការតឹងទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ដោយត្រូវអញ្ជើញក្រុមហ៊ុនមកប្រជុំពិភាក្សា និងពន្យល់កាតព្វកិច្ច ដែលត្រូវអនុវត្តទៅលើកិច្ចសន្យា ដោយកិច្ចការនេះ ត្រូវមានការចូលរួមពី លោក ណុំ ស៊ីនិត មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស ហើយត្រូវរៀបចំជាកំណត់ហេតុ និងការទទួលស្គាល់អោយបានច្បាស់លាស់រវាងគូភាគី មុននឹងអនុវត្តនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមានបន្តទៀត។ ក្នុងករណីដែលដំណោះស្រាយក្នុងការតឹងទារបំណុលខាងលើពុំមានប្រសិទ្ធភាព ក្រុមប្រឹក្សាភិបាលគាំទ្រទៅលើវិធានការដែលបានស្នើឡើង របស់ កសស ដែលមានលក្ខណៈជាជំហានៗ សម្រាប់អនុវត្តការតឹងទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ។

## ៣. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៥ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្មគណៈកម្មាធិការតែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង។ អង្គប្រជុំបានស្នើអោយ កសស ធ្វើលិខិតគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីស្ថានភាពកកស្ទះចរាចរណ៍ក្នុងកំពង់ផែ និងទំនិញគ្មានការទាមទារ ដើម្បីស្នើសុំគោលការណ៍ណែនាំអនុវត្ត ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែច្រាំងជាផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងពង្រីកចំណតផែកុងតែន័រថ្មី (ជំហានទី២ និងជំហានទី៣) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី គម្រោងពង្រឹងសមត្ថភាពការគ្រប់គ្រង និងប្រតិបត្តិការចំណតផែកុងតែន័រនៅកំពង់ផែក្រុងព្រះសីហនុ-ដំណាក់កាលទី៣ (២០២២-២០២៦) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពការងារប្រព័ន្ធព័ត៌មានវិទ្យារបស់ កសស និងសូមអោយសហការសិក្សាបន្ថែមជាមួយ JICA Experts Team ដើម្បីជ្រើសរើសជម្រើសដ៏ល្អបំផុត និងជឿទុកចិត្តបាន សម្រាប់ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង កសស ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័ត ដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុ ត្រីមាសទី២ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។

### ៤. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៦ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២

- បានអនុម័តឯកភាពរបាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែច្រាំងជាផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ដំហានទី១ ប្រវែង ៣៥០ ម៉ែត្រ) ។
- បានអនុម័តឯកភាពលើ របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ០៩ ខែ ដើមឆ្នាំ២០២២ ។
- បានអនុម័តឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។
- បានអនុម័តឯកភាពគាំទ្រ គម្រោងផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ២០២៣ ។
- បានឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- បានអនុម័តដោយឯកភាពអោយ កសស អភិវឌ្ឍទីតាំងដីជួលខាងលើនេះ ទៅជាទីលានស្តុកកុងតែន័រ និងសម្រាប់បម្រើអោយការងារអាជីវកម្មរបស់ កសស នៅក្រោយពេលកិច្ចសន្យាជួលទីតាំង និងមធ្យោបាយលើកដាក់ នឹងត្រូវផុតសុពលភាពនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ខាងមុខនេះ ។

# ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**លូ គឹមឈន់**
ប្រធានអគ្គនាយក

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ុយ សាន**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ផាន់ ផល្លា**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**សុខ សុភ័ក្ត្រ**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ុន មុន្នីវណ្ណ**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
Hidetoshi KUME
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**លូ លីខេង**
អភិបាល

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ




**អាសយដ្ឋាន**

តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ព្រះរាជាណាចក្រកម្ពុជា

**ទំនាក់ទំនង**

០៣៤ ៩៣៣ ៤១៦
០៣៤ ៩៣៣ ៥១១
០៧៨ ៤៩៦ ៧៨៩
pas.gov.kh
pasinfo@pas.gov.kh
Sihanoukville Autonomous Port

## ទស្សនវិស័យ

អភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជីស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## បេសកកម្ម

- អភិវឌ្ឍស្របតាមគោលនយោបាយរាជរដ្ឋាភិបាល
- បង្កើនគុណភាពសេវាកម្ម តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ផែ ការធ្វើទំនើបកម្មគ្រប់គ្រងកំពង់ផែ និងការអភិវឌ្ឍធនធានមនុស្ស ស្របតាមនវានុវត្តន៍អន្តរជាតិ
- សហការជាមួយដៃគូអភិវឌ្ឍន៍ សិក្សា និងឆ្ពោះទៅការកសាងផែទឹកជ្រៅ ស្របតាមទស្សនវិស័យ និងកំណើនកុងតែន័រឆ្លងកាត់
- ជម្រុញ និងពង្រឹងគោលការណ៍ ជាកំពង់ផែសម្រាប់ទាំងអស់គ្នា ។

## គុណតម្លៃ

- ទីតាំងភូមិសាស្ត្រល្អបំផុត
- ការបំពេញចិត្តជូនអតិថិជន
- ភាពបរិសកម្ម និងនវានុវត្តន៍
- សុចរិតភាព និងគណនេយ្យភាព
- ភាពរួសរាយរាក់ទាក់ និងការគោរព
- ការងារជាក្រុម និងគុណភាពសេវាកម្ម
- ភាពជឿទុកចិត្ត និងកំណើនប្រកបដោយចីរភាព

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ៣១ ធ្នូ ២០២២<br>(ពាន់រៀល) | ៣១ ធ្នូ ២០២១<br>(ពាន់រៀល)<br>(បានរាយការណ៍ឡើងវិញ) | ៣១ ធ្នូ ២០២០<br>(ពាន់រៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១.៤២៦.១៤៥.៥៩៦ | ១.៤២៧.១៤៩.៦៧០ | ១.៣៨៩.៨៤២.៧០១ |
| បំណុលសរុប | | ៥៦២.៣៤៤.៦៥០ | ៦៤៣.២៥៥.៥១១ | ៦៨៧.៤៨១.២៨៣ |
| មូលធនសរុប | | ៨៦៣.៨០០.៩៤៦ | ៧៨៣.៨៩៤.១៥៩ | ៧០២.៣៦១.៤១៨ |
| លទ្ធផលហិរញ្ញវត្ថុ | | ឆ្នាំ២០២២<br>(ពាន់រៀល) | ឆ្នាំ២០២១<br>(ពាន់រៀល) | ឆ្នាំ២០២០<br>(ពាន់រៀល) |
| ចំណូលសរុប | | ៣៤៣.៧៤៣.៥៤៥ | ៣៤២.៣៤៩.២២៩ | ៣១១.៨១៣.៧៦៩ |
| ចំណេញមុនបង់ពន្ធ | | ៩៧.៨៩៧.០៨០ | ១១១.០៤៥.៦៣៧ | ៤២.១៤០.២២១ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ៨៤.១៥៥.២១៥ | ៩៣.៧០៧.៣៩០ | ២៦.៦០៧.៥៩៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៩៦.០១៤.០៥៥ | ៩៣.៧០៧.៣៩០ | ២៦.៦០៧.៥៩៤ |
| អនុបាតហិរញ្ញវត្ថុ | | ៣១ ធ្នូ ២០២២ | ៣១ ធ្នូ ២០២១ | ៣១ ធ្នូ ២០២០ |
| អនុបាតសាធនភាព | | ២៣,០៩% | ២០,៧៧% | ៩,៤០% |
| អនុបាតបំណុលធៀបនឹងមូលធន | | ០,៦៥ | ០,៨២ | ០,៩៨ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,៦២ | ២,៣១ | ២,៤២ |
| | អនុបាតចរន្តលឿន | ២,២៥ | ២,០០ | ២,១២ |
| | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៥,៩០% | ៦,៥៧% | ១,៩១% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ៩,៧៤% | ១១,៩៥% | ៣,៧៩% |
| | គំលាតចំណេញដុល | ១៦,៥៩% | ២៣,០៣% | ២២,២៩% |
| | គំលាតចំណេញភាព | ២៤,៤៨% | ២៧,៣៧% | ៨,៥៣% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(រៀល) | ៩៨១,១៥ | ១.០៩២,៥២ | ៣១០,២១ |
| អនុបាតលទ្ធភាពសងការប្រាក់ | | ១០,៨៥ | ១០,៩២ | ៤,០៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | | - | ៥០៤ | ៤០៣ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំ២០២២









## ភាគហ៊ុនិករបស់ កសស

| ល.រ | ប្រភេទមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|---|
| ១ | មូលបត្រកម្មសិទ្ធិគ្មានសិទ្ធបោះឆ្នោតប្រភេទ "ក" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៦៤.៥៣០.៨៦១ | ៨០,៩៥% |
| ២ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "ខ" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ | ១៤,២៩% |
| ៣ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "គ" | ឯកជន | ២១.៤៤២.៩៩២ | ៤,៧៦% |
| **សរុប** | | | **៤៥០.៣០២.៨២៨** | **១០០%** |

## ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិប្រភេទ "គ" របស់ កសស

| ល.រ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|
| ១ | ESOP | ២.១៤៤.២៩៩ | ១០% |
| ២ | KAMIGUMI CO., LTD | ១១.១៥០.៣២៤ | ៥២% |
| ៣ | KOBE-OSAKA International Port Corporation | ២.១៤៤.៣០០ | ១០% |
| ៤ | ភាគហ៊ុនិកឯកជនដទៃទៀត | ៦.០០៤.០៦៩ | ២៨% |
| **សរុប** | | **២១.៤៤២.៩៩២** | **១០០%** |



# បំរែបំរួលថ្លៃភាគហ៊ុន និងទំហំជួញដូរ






# ស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ

| បរិយាយ | ឯកត្តា | ផែនការ ឆ្នាំ២០២២ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| បរិមាណទំនិញឆ្លងកាត់ | តោន | ៧.៤១៨.000 | ៧.00៣.១៥៧ | ៦.៩៩0.៣៣៧ | ៦.៦0១.៨0៤ | -៥,៥៩% | 0,១៨% | ៦,0៨% |
| ជាកុងតែន័រ | _ | | ៥.0៣១.៩៨៨ | ៤.៩៤៩.៨0១ | ៤.៣៦៣.៩0៩ | | ១,៦៦% | ១៥,៣១% |
| ទំនិញរាយ | _ | | ១៤២.៩៤៤ | ២៥0.៧៣៤ | ៣៤៩.៨២0 | | -៤២,៩៩% | -៥៩,១៤% |
| ជាប្រេង | _ | | ១.៧២៩.៧00 | ១.៧៣៧.0៤៧ | ១.៨0៤.៣៥២ | | ៨៦,៧៦% | ១៧,៦៨% |
| ហ្គាស | _ | | ៩៨.៥២៥ | ៥២.៧៥៥ | ៨៣.៧២២ | | 0,៤១% | ៦,៩១% |
| បរិមាណទំនិញនាំចូល | _ | ៥.៥៦៤.000 | ៥.២២៥.២៣៦ | ៥.២0៣.៨១៩ | ៤.៨៨៧.៦៨៤ | -៦,0៩% | 0,៤១% | ៦,៩១% |
| បរិមាណទំនិញនាំចេញ | _ | ១.៨៥៤.000 | ១.៧៧៧.៩២១ | ១.៧៨៦.៥១៨ | ១.៧១៤.១២0 | -៤,១0% | -0,៤៨% | ៣,៧២% |
| បរិមាណទំនិញលើករៀប | _ | ១0.២៩៨.000 | ១១.២៣៩.៤៣៤ | ១0.១៩៩.១៩៨ | ៨.៩៥៤.៣១៧ | ៩,១៤% | ១0,២0% | ២៥,៥២% |
| ប្រគល់ផ្ទាល់ | _ | ២២0.000 | ១២១.១៨0 | ២0១.៩២៣ | ២0៨.៣២៩ | | -៣៩,៩៩% | -៤១,៨៣% |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | _ | ១0.0៧៨.000 | ១១.១១៨.២៥៣ | ៩.៩៩៧.២២៥ | ៨.៧៤៥.៩៨៨ | | ១១,២១% | ២៧,១២% |
| បរិមាណកុងតែន័រឆ្លងកាត់ | TEUs | ៧៨៧.000 | ៧៥0.១៤៨ | ៧៣២.៣៨៧ | ៦៤១.៨៤២ | -៤,៦៨% | ២,៤៣% | ១៦,៨៧% |
| នាំចូល | _ | | ៣៩៥.១១៤ | ៣៨0.១៤៥ | ៣២0.៦៤២ | | ៣,៩៤% | ២៣,២៣% |
| នាំចេញ | _ | | ៣៥៥.0៣៤ | ៣៥២.២៤២ | ៣២១.២00 | | 0,៧៩% | ១0,៥៣% |
| ចំនួននាវាចូលចត | គ្រឿង | ១.៤៥0 | ១.៤៤២ | ១.៥៨២ | ១.៦៦២ | -0,៥៥% | -៨,៨៥% | -១៣,២៤% |
| ចំណុះផ្ទុកនាវា | តោន | ១៤.១២៨.000 | ១៤.១0៨.0៣២ | ១៣.៣៦៦.៣៩៩ | ១៦.៧៨៤.៩៧៩ | -0,១៤% | ៥,៥៥% | -១៥,៩៥% |

# សមាសភាពក្រុមប្រឹក្សាភិបាល



**ឯកឧត្តម លូ គឹមឈន់**
ប្រធានអគ្គនាយក



**ឯកឧត្តម ស៊ុយ សាន**
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



**ឯកឧត្តម ផាន់ ផល្លា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម សុខ សុភ័ក្រ្ត**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក ហ៊ិន មុន្នីវណ្ណ**
អភិបាលឯករាជ្យ



**លោក Hidetoshi KUME**
អភិបាលមិនប្រតិបត្តិ
តំណាងភាគហ៊ុនិកឯកជន



**លោក លូ លីខេង**
តំណាងនិយោជិតកម្មករ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក



"ជូសមុខឱ្យក្រុមប្រឹក្សាភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវ របាយការណ៍អាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ របស់ កសស សម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២"។

ដោយមានការគាំទ្រយ៉ាងមុតមាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអាណាព្យាបាលទាំងពីរ កសស បានបន្តការវិវឌ្ឍន៍ យ៉ាងខ្លាំងក្លាដើម្បីបម្រើសកម្មភាពធុរកិច្ចរបស់ខ្លួន ជាលទ្ធផលនៅក្នុងឆ្នាំ២០២២ នេះ កសស ទទួលបានប្រាក់ចំណូលសរុបចំនួន ៣៤៣.៧៤៣.៥៤៥.០០០ រៀល និងទទួលបានប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធក្នុងការិយបរិច្ឆេទចំនួន ៨៤.១៥៥.២១៥.០០០ រៀល បើប្រៀបធៀបនឹងឆ្នាំ២០២១។ ប្រាក់ចំណូលមានការកើនឡើងចំនួន ១.៣៩៤.៣១៦.០០០ រៀល គឺស្មើនឹង ០,៤១% ចំណែកប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះចំនួន ៩.៥៥២.១៧៥.០០០ រៀល គឺស្មើនឹង ១០,១៩%។ លទ្ធផលនេះបណ្តាលមកពីបរិមាណទំនិញ និងបរិមាណកុងតែន័រឆ្លងកាត់ កសស មានការកើនឡើង ដោយឡែកមានការកើនឡើងលើការចំណាយនៃប្រតិបត្តិការកំពង់ផែ ដែលជាកត្តាចម្បង ដោយក្នុងឆ្នាំ២០២២ នេះ តម្លៃប្រេងឥន្ធនៈជាមធ្យម ១.០៦ ដុល្លារ ក្នុងមួយលីត្រ បើធៀបនឹងឆ្នាំ២០២១ គឺត្រឹម ០.៦៨ ដុល្លារ ក្នុងមួយលីត្រ ធ្វើអោយចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះ ជាលទ្ធផលចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធមានចំនួន ៩៨១,១៥ រៀល សម្រាប់ឆ្នាំ២០២២ នេះ។ ហើយក្នុងឆ្នាំ២០២២ នេះ កុងតែន័រសរុបដែលបានឆ្លងកាត់ កសស មានចំនួន ៧៥០.១៤៨ TEUs ពោលគឺ កើនចំនួន ១៧.៧៦១ TEUs ស្មើនឹង ២,៤៣% និងការកើននៃបរិមាណទំនិញឆ្លងកាត់មានចំនួន ១២.៨២០ តោន ស្មើនឹង ០,១៨% បើប្រៀបធៀបទៅនឹងឆ្នាំ២០២១។

កសស នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបំពេញសេវាកម្ម អាជីវកម្មឱ្យកាន់តែល្អប្រសើរ និងសម្រេចបានលទ្ធផលខ្ពស់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន។ កសស បានពង្រឹងប្រសិទ្ធភាពការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មរបស់អតិថិជន និងការរីកចម្រើនសេដ្ឋកិច្ចជាតិ។ ដោយសារតែមានការកើនឡើងនូវបរិមាណទំនិញ និងកុងតែន័រឆ្លងកាត់ កសស បានធ្វើការកែសម្រួលផែប្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ ដើម្បីក្លាយជាចំណតកុងតែន័រមួយបន្ថែមទៀត ដែលបច្ចុប្បន្នមានត្រឹមតែពីរចំណតប៉ុណ្ណោះ។ ជាងនេះទៅទៀត កសស បាននឹងកំពុងអនុវត្តគម្រោងអភិវឌ្ឍន៍ផែកុងតែន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក ១៤,៥ ម៉ែត្រ រួមបញ្ចូលទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប ប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង រថលើកកុងតែន័រទទេ (Empty Reach Stacker) ចំនួន ០២ គ្រឿង ក្បាលសណ្តោងកុងតែន័រ ចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម ០១ កំភ្លៅ។ សម្រាប់ចំណតផែកុងតែន័រថ្មីនេះ អាចអនុញ្ញាតឱ្យនាវាដឹកជញ្ជូនកុងតែន័រធុនធំក្នុងតំបន់ចូលចតនៅ កសស បាន ដែល

នឹងធ្វើឱ្យឧបសគ្គអំពីជម្រៅទឹកសម្រាប់កំពង់ផែ ត្រូវបានដោះស្រាយ ព្រមទាំងតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ ដែលជាការរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។ តាមការរំពឹងទុកគម្រោងនេះនឹងគ្រោងបញ្ចប់ការសាងសង់នៅពាក់កណ្តាល ឆ្នាំ២០២៥ ហើយសមត្ថភាពលើកដាក់កុងតែន័រដល់ ១.១៥០.០០០ TEUs ក្នុង ១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រនេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៥ ខាងមុខ។

❖ **ដើម្បីឆ្លើយតបនឹងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ ក៏ដូចជាតម្រូវការសេវាកម្ម របស់អតិថិជន កសស មានទិសដៅការងារចម្បងៗដូចខាងក្រោម៖**

- អនុវត្តបន្តការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០២២
- រក្សានូវឧត្តមភាពនៃភាពប្រកួតប្រជែងរបស់ខ្លួន ដោយធានានូវគុណភាពសេវាកម្ម តម្លៃប្រកួតប្រជែង ប្រសិទ្ធភាពការងារ និងការកសាងទំនុកចិត្តជូនអតិថិជន
- ពង្រឹងសមត្ថភាពបុគ្គលិកលើការគ្រប់គ្រង និងបច្ចេកទេស ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាចំពោះកំណើនតំរូវការសេវាកម្មរបស់កំពង់ផែ
- ជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងគ្រឿងចក្របន្ថែមទៀត ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកកំពស់សមត្ថភាពលើកដាក់ទំនិញរបស់ខ្លួន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រជាមួយកំពង់ផែក្នុងប្រទេស និងក្នុងតំបន់
- ពង្រឹងអភិបាលកិច្ចគ្រប់គ្រងតាមរយៈការបង្កើតគណៈកម្មាធិការសំខាន់ៗ
- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និងលើកកំពស់សុខមាលភាពសង្គម

❖ **ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល**

នៅក្នុងឆ្នាំ២០២២ នេះ ក្រុមប្រឹក្សាភិបាលបានធ្វើការជួបប្រជុំចំនួន ០៤ លើក និងបានសម្រេចការងារដូចខាងក្រោម៖

**១. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៣ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលឯកភាពលើលទ្ធផលដែលបានសម្រេច និងស្នើអោយបន្តអនុវត្តទៅតាម ស្មារតីសម័យប្រជុំក្រុមប្រឹក្សាភិបាលកន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពតាមរបាយការណ៍របស់គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission បានស្នើអោយ កសស រៀបចំរបាយការណ៍ស្តីពីផលប្រយោជន៍ និងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ ជូនក្រសួងអាណាព្យាបាលទាំងពីរ និងស្នើសុំអោយ លោក KUME Hidetoshi ជួយសម្របសម្រួល និងចរចាបន្ថែមទៀត ទៅភាគីជប៉ុនលើការបញ្ចុះអត្រាការប្រាក់ជាអប្បបរិមា ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័ត ដូចខាងក្រោម ៖
  - ឯកភាពលើ របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ឆ្នាំ២០២១
  - ឯកភាពលើ វិធានការណ៍ដោះស្រាយបន្ទាន់ និងស្នើអោយ កសស ត្រូវរៀបចំលិខិតគោរពជូន ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីស្នើសុំគោលការណ៍ផ្លាស់ប្តូរទីតាំងរបស់សមត្ថកិច្ចត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅដើមទី ពីក្នុងបរិវេណ កសស ទៅក្រៅបរិវេណ កសស វិញ
  - ឯកភាពជាគោលការណ៍លើគម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ក្នុងស្រុក នៅច្រកលេខ១ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC (Financial performance review) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី ការអនុគ្រោះថ្លៃឈ្នួលសេវារបស់ កសស ចំពោះទំនិញរាជរដ្ឋាភិបាល ប្រចាំឆ្នាំ២០២១ មានចំនួនជាទឹកប្រាក់សរុប ៨៨.៣១២,១៩ USD (ប៉ែតសិបប្រាំបីពាន់ បីរយដប់ពីរ ដុល្លារអាមេរិក និងដប់ប្រាំបួនសេន) ។

## ២. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៤ នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័ថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission និង Appraisal Mission ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ត្រីមាសទី១ ឆ្នាំ២០២២ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី១ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈសម្រាប់មហាសន្និបាតភាគហ៊ុនិក លើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម ៖
  - កាលបរិច្ឆេទ : ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
  - កាលបរិច្ឆេទកំណត់ទុក : ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២
  - ទីកន្លែងប្រារព្ធមហាសន្និបាត (Venue) : សុខា ប៊ិច រីសត, ខេត្តព្រះសីហនុ ជាមួយនឹងប្រព័ន្ធវីដេអូឧល ZOOM (ទៅតាមស្ថានភាពជាក់ស្តែង)
  - របៀបវារៈមហាសន្និបាត
    - មតិស្វាគមន៍របស់ ប្រធានមហាសន្និបាត
    - បទបង្ហាញ ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២១ និងទិសដៅអនុវត្តការងារឆ្នាំ២០២២
    - ពិនិត្យ និងអនុម័ត បែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពឱ្យ កសស ស្នើសុំការអនុម័តការបែងចែកភាគលាភ (Dividend) ការកំណត់កាលបរិច្ឆេទកំណត់ទុកដែលត្រូវបែងចែកភាគលាភ (Record Date) និងកាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) ជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ២០២១ នៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម៖

  ១. បែងចែកភាគលាភជូន
    - ភាគហ៊ុនិកប្រភេទ "ខ" ស្មើនឹងទឹកប្រាក់ចំនួន ៥.៣០០.០០០.០០០ រៀល
    - ភាគហ៊ុនិកប្រភេទ "គ" ក្នុងអត្រា ៨%, ៩%, ១០%, ១១% ឬ ១២% នៃតម្លៃមូលបត្របោះផ្សាយលក់លើកដំបូង (IPO Price) ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី៥ ពិនិត្យ និងអនុម័ត
    - ប្រភេទភាគលាភដែលត្រូវបែងចែក : សាច់ប្រាក់
    - រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២១
    - ចំនួនមូលបត្រដែលបានចុះបញ្ជីសរុប : ៨៥.៧៧១.៩៦៧ មូលបត្រ
      - ចំនួនមូលបត្រ ប្រភេទ "ខ" : ៦៤.៣២៨.៩៧៥ មូលបត្រ
      - ចំនួនមូលបត្រ ប្រភេទ "គ" : ២១.៤៤២.៩៩២ មូលបត្រ

  ២. ចំនួនភាគលាភសរុបដែលត្រូវបែងចែក
    - បែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៥.៣០០.០០០.០០០ រៀល
    - បែងចែកជូនភាគហ៊ុនប្រភេទ "គ" : បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
    - អនុបាតនៃការបែងចែកភាគលាភសរុបជូនភាគហ៊ុនប្រភេទ "ខ" និង "គ"
      - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "ខ": ៦,២៨ %
      - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "គ": បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
    - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ
      - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៨២,៣៩ រៀល
      - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "គ" : សម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
    - កាលបរិច្ឆេទកំណត់ទុក (Record Date) : ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២
    - កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) : ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ កសស ស្វែងរកដំណោះស្រាយឱ្យបានអស់ពីលទ្ធភាព ទៅលើការទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ដោយត្រូវអញ្ជើញក្រុមហ៊ុនមកប្រជុំពិភាក្សា និងពន្យល់កាតព្វកិច្ចដែលត្រូវអនុវត្តទៅលើកិច្ចសន្យា ដោយកិច្ចការនេះ ត្រូវមានការចូលរួមពី លោក ណុំ ស៊ីនិត មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស ហើយត្រូវរៀបចំដាក់កំណត់ហេតុ និងការទទួលស្គាល់អោយបានច្បាស់លាស់រវាងគូភាគី មុននឹងអនុវត្តនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមានបន្តទៀត។ ក្នុងករណីដែលដំណោះស្រាយក្នុងការតឹងទារបំណុលខាងលើពុំមានប្រសិទ្ធភាព ក្រុមប្រឹក្សាភិបាលគាំទ្រទៅលើវិធានការដែលបានស្នើឡើង របស់ កសស ដែលមានលក្ខណៈជាជំហានៗ សម្រាប់អនុវត្តការតឹងទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ។

## ៣. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៥ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការ តែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង។ អង្គប្រជុំបានស្នើអោយ កសស ធ្វើលិខិតគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីស្ថានភាពកកស្ទះចរាចរណ៍ក្នុងកំពង់ផែ និងទំនិញគ្មានការទាមទារ ដើម្បីស្នើសុំគោលការណ៍ណែនាំអនុវត្ត ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែច្រាំងជាផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ)។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងពង្រីកចំណតផែកុងតែន័រថ្មី (ជំហានទី២ និងជំហានទី៣) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី គម្រោងពង្រឹងសមត្ថភាពការគ្រប់គ្រង និងប្រតិបត្តិការចំណតផែកុងតែន័រនៅកំពង់ផែក្រុងព្រះសីហនុ-ដំណាក់កាលទី៣ (២០២២-២០២៦) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍ស្តីពី វឌ្ឍនភាពការងារប្រព័ន្ធព័ត៌មានវិទ្យារបស់ កសស និងសូមអោយសហការសិក្សាបន្ថែមជាមួយ JICA Experts Team ដើម្បីជ្រើសរើសជម្រើសដ៏ល្អបំផុត និងជឿទុកចិត្តបាន សម្រាប់ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង កសស ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី២ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។

## ៤. សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៦ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការ តែងតាំងនិងលាភការដែលបានលើកឡើង ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពរបាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែច្រាំងជាផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ០៩ ខែ ដើមឆ្នាំ២០២២ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young ( Financial Performance Review ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពគាំទ្រ គម្រោងផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ ២០២៣ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័តដោយឯកភាពអោយ កសស អភិវឌ្ឍទីតាំងដីជួលខាងលើនេះ ទៅជាទីលានស្តុកកុងតែន័រ និងសម្រាប់បម្រើអោយការងារអាជីវកម្មរបស់ កសស នៅក្រោយពេលកិច្ចសន្យាជួលទីតាំង និងមធ្យោបាយលើកដាក់នឹងត្រូវផុតសុពលភាពនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ខាងមុខនេះ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើ ការកំណត់កាលបរិច្ឆេទរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៧ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជានិច្ចកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ កសស រៀងរហូតមក ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ មន្ត្រី-និយោជិត និងកម្មករ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ទាំងអស់ដែលតែងតែយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តព្រះសីហនុ, ថ្ងៃទី៣០ ខែមីនា គ.ស ២០២៣

**ប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ_គីមឈន់**

# មាតិកា


ទស្សនវិស័យ បេសកកម្ម គុណតម្លៃ ........ I
ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ II
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ III
ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ ........ VI
សមាសភាពក្រុមប្រឹក្សាភិបាល ........ VII
សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ VIII

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០១**

ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០២
ខ- លក្ខណៈនៃធុរកិច្ច ........ ០២
គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០៤
ឃ- ព្រឹត្តិការសំខាន់ៗប្រចាំឆ្នាំ ........ ០៤
ង- ស្ថានភាពទីផ្សារ ........ ០៤
ច- ស្ថានភាពប្រកួតប្រជែង ........ ០៧
ឆ- ផែនការអនាគត ........ ០៨
ជ- កត្តាហានិភ័យ ........ ១៦

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ១៧**

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ១៨
ខ- រចនាសម្ព័ន្ធចំណូល ........ ២២

**ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ........ ២៣**

ក- អង្គការលេខ ........ ២៤
ខ- ក្រុមប្រឹក្សាភិបាល ........ ២៥
គ- បុគ្គលិកជាន់ខ្ពស់ ........ ២៥

**ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ២៦**

ក- ព័ត៌មានអំពីមូលបត្រ ........ ២៧
ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ........ ២៧
គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ ........ ២៨
ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន ........ ២៨
ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី)ឆ្នាំចុងក្រោយ ........ ២៨

**ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង.......... ២៩**

**ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ.............. ៦៤**

**ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍............................................................................................................................១៤៧**

ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ...... ១៤៨

ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់.............................................. ១៤៨

គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម.... ១៤៨

ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ....................................................... ១៤៨

ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ........ ១៤៨

ច- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល ...................................................................................................... ១៤៨

ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ....... ១៤៨

ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ................................................................ ១៤៨

**ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........................................ ១៤៩**

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ..................................................................................... ១៥០

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ............................................................ ១៥៧

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល......................................................... ១៥៧

ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ.................................... ១៥៨

ង- ផលប៉ះពាល់នៃអតិផរណា........................................................................................ ១៥៨

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ............................ ១៥៨

**ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន ................................. ១៦០**

**ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ.............................................. ១៦៥**

# ផ្នែកទី ១

# ព័ត៌មានពាក់ព័ន្ធនឹង
# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ

| | | |
|---|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | : | កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) |
| ឈ្មោះក្រុមហ៊ុនជាអក្សរ (ឡាតាំង) | : | PORT AUTONOME DE SIHANOUKVILLE "PAS" |
| ឈ្មោះក្រុមហ៊ុនជាអក្សរ (អង់គ្លេស) | : | SIHANOUKVILLE AUTONOMOUS PORT |
| លេខកូដស្តង់ដារ | : | KH1000060009 |
| អាសយដ្ឋាន | : | តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។ |
| លេខទូរស័ព្ទ | : | (៨៥៥) ៣៤ ៩៣៣ ៤១៦ /៩៣៣ ៥១១ |
| ទំនាក់ទំនងវិនិយោគិន | : | (៨៥៥) ៧៨ ៤៩៦ ៧៨៩ |
| គេហទំព័រ | : | www.pas.gov.kh |
| អ៊ីម៉ែល | : | pasinfo@pas.gov.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | : | Co.៤៧៨៤ Et / ២០១៧ កាលបរិច្ឆេទ: ២១ កុម្ភៈ ២០១៧ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | : | ០១៥៩ ពណ.ចបព កាលបរិច្ឆេទ: ២២ កុម្ភៈ ២០១៧ ដែលចេញដោយក្រសួងពាណិជ្ជកម្ម |

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ: ០៥៨/១៧/គ.ម.ក/ស.ស.រ

| | | |
|---|---|---|
| កាលបរិច្ឆេទ | : | ០៩ ឧសភា ២០១៧ |

ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ: **ឯកឧត្តម លូ គឹមឈន់**

## ខ- លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីប្រមាណ ១២៥ ហិកតា។ ដោយស្ថិតនៅតាមបណ្តោយឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាក្នុងឈូងសមុទ្រថៃ កសស ទទួលបានភាពអនុគ្រោះពីធម្មជាតិ និងលក្ខខណ្ឌប្រតិបត្តិការយ៉ាងរលូនពេញមួយឆ្នាំ ដោយមានទឹកសមុទ្រស្ងប់ស្ងាត់ល្អ និងពុំមានព្យុះធំៗឡើយ ។

កសស ត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ តាមផ្លូវគោក កសស ត្រូវបានតភ្ជាប់ដោយផ្លូវជាតិសំខាន់ៗពីរ និងផ្លូវល្បឿនលឿនមួយ គឺផ្លូវជាតិលេខ៤ ដែលមានប្រវែង ២២៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញមកក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៣ ដែលកាត់តាមទីរួមខេត្តកំពត មានប្រវែង ២៤៤ គីឡូម៉ែត្រ បន្ថែមពីលើនេះ គឺផ្លូវល្បឿនលឿនដែលទើបនឹងសាងសង់រួច ហើយបានបើកឱ្យប្រើប្រាស់កាលពីខែតុលា ឆ្នាំ២០២២នេះ ដែលមានប្រវែង ១៨៧ គីឡូម៉ែត្រ ពីភ្នំពេញ មក ក្រុងព្រះសីហនុ។ កសស ក៏ត្រូវបានតភ្ជាប់ដោយខ្សែរថភ្លើងភាគខាងត្បូង ពីភ្នំពេញកាត់តាមខេត្តកំពត ដែលមានប្រវែង ២៦៤ គីឡូម៉ែត្រ។ ចំណែកតាមផ្លូវអាកាស កសស ត្រូវបានតភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញដោយអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

ក្នុងនាមជាប្រតិបត្តិករផែ កសស ត្រូវបំពេញអាជីវកម្ម និងសេវាកម្មដូចខាងក្រោម៖

- កណ្តាជារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរ-ផ្ទុក ទំនិញ
- ស្តុកទំនិញ នៅឃ្លាំង និងទីលាន
- ដឹកជញ្ជូនទំនិញ
- តំបន់សេដ្ឋកិច្ចពិសេស

កសស មានចំណតផែសរុបប្រវែង ១,៨៦០ ម៉ែត្រ ដោយចែកជា ១៣ ចំណតដូចខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយ៍ | ប្រភេទទំនិញ | បណ្តោយ (ម៉ែត្រ) | ទទឹង (ម៉ែត្រ) | ចំណត |
|---|---|---|---|---|---|
| ១ | ស្ថានីយ៍ផែអ្នកដំណើរ (ចំណតផែចាស់) | អ្នកដំណើរ និងទំនិញរាយ | ២៩០ | ២៨ | លេខ ១ និង លេខ ៣៖ ជម្រៅ ៩ ម៉ែត្រ ដល់ ១៣ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅ បាត ៨,៥ ម៉ែត្រ ចូលចតបាន។ លេខ ២ និង លេខ ៤៖ ជម្រៅ ៦,៥ ម៉ែត្រ ដល់ ៨ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅ បាត ៧ ម៉ែត្រ ចូលចតបាន។ |
| ២ | ស្ថានីយ៍ផែថ្មី | កុងតែន័រ | ៣៥០ | ៥០០ | លេខ៥ (ផ្នែកខាងលិច) និងលេខ៦ (ផ្នែកខាងកើត)៖ ជម្រៅ ១០ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាតក្រោម ៨,៥ ម៉ែត្រ ចូលចតបាន។ |
| ៣ | ស្ថានីយ៍ផែកុងតែន័រ | កុងតែន័រ | ៤០០ | ៣៥០ | លេខ៧ និង លេខ៨៖ ជម្រៅ ១១ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាតក្រោម ៨,៥ម៉ែត្រ ចូលចតបាន។ |
| ៤ | ស្ថានីយ៍ផែពហុបំណង | អ្នកដំណើរ ទំនិញរាយ និងរុករកប្រេង | ៣៣០ | ២០០ | ផែពហុបំណង មានប្រវែង ៣៣០ ម៉ែត្រ និងជម្រៅទឹក -១៣,៥ ម៉ែត្រ សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ ដែលអាចអនុញ្ញាតឱ្យនាវាចំណុះ ៥០.០០០ DWT ចូលចតបាន និងចំណតផែមូលដ្ឋាន ផ្គត់ផ្គង់ការរុករករ៉ែប្រេងក្នុងដែនសមុទ្រ មានប្រវែង ២០០ ម៉ែត្រ និងជម្រៅទឹក -៧,៥ ម៉ែត្រ ដើម្បីបម្រើសេវាភស្តុភារកម្ម សម្រាប់ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា។ |
| ៥ | ស្ថានីយ៍ផែថ្ម | ដឹកប្រេង | ៥៣ | ៥ | ចំណតផែប្រេង៖ ជម្រៅ ៤,៥ ម៉ែត្រ ហើយមានប្រវែងសរុបក្រោម ៨០ ម៉ែត្រ។ ឧបករណ៍ទាក់ពួរកៃច្នៃ ត្រូវបានរៀបចំសម្រាប់នាវាប្រេង ដែលមាន ជម្រៅបាតក្រោម ៦ ម៉ែត្រ និងប្រវែងក្រោម ១១០ ម៉ែត្រ ធ្វើការចូលចតបាន។ |

- ស្ថានីយ៍រថភ្លើងដឹកកុងតែន័រ

ក្រៅពីចំណុតផែខាងលើ ដោយសហការជាមួយក្រុមហ៊ុន Royal Railway Co., Ltd កសស ក៏មានប្រតិបត្តិការប្រព័ន្ធផ្លូវដែក និងទីលានផ្ទុកទំនិញកុងតែន័រក្នុងបរិវេណកំពង់ផែដើម្បីឱ្យអតិថិជន ឬម្ចាស់ទំនិញអាចដឹកជញ្ជូនទៅវិញទៅមកពី កសស ទៅភ្នំពេញ។ កសស បានជួលដីបរិវេណនេះទៅឱ្យក្រុមហ៊ុន Royal Railway Co., Ltd ហើយផ្តល់សេវាកម្មលើកដាក់កុងតែន័រទៅលើ និងចុះពីរថភ្លើង ។

- តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ក្រៅពីអាជីវកម្ម សេវាកម្មខាងលើ កសស ក៏មានប្រតិបត្តិដំណើរការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុដែលមានទំហំផ្ទៃដីប្រមាណ ៦៤ ហិកតា បានកសាងឡើងតាមបទដ្ឋានប្រទេសជប៉ុន។

## គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ

កសស មិនមានក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនពាក់ព័ន្ធដទៃទៀតទេ ។

## ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ២០២២

ក្នុងឆ្នាំ២០២២ នេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៥ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ បានរៀបចំឡើងនៅ សណ្ឋាគារ សុខា ប៊ិច រីស៊ត និងតាមប្រព័ន្ធអនឡាញ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាតហ៊ុនិកលើកទី៥ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានសម្រេចលទ្ធផលដូចខាងក្រោម៖

- របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្មឆ្នាំ២០២១
- ទិសដៅការងារឆ្នាំ២០២២
- ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១
  - ភាគហ៊ុនិកប្រភេទ "ខ" មានចំនួន ៥.៣០០.០០០.០០០ រៀល
  - ភាគហ៊ុនិកប្រភេទ "គ" មានចំនួន ១០% នៃតម្លៃ IPO (៥.០៤០រៀល) ស្មើនឹង ១០.៨០៧.២៦៧.៩៦៨ រៀល
- ការអនុម័តលើប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្រ្តីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២២។

## ខ- ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ កសស គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើចរាចរណ៍កុងតែន័រ យើងសង្កេតឃើញថាសម្រាប់ឆ្នាំ២០២២ នេះ បរិមាណកុងតែន័រ (TEUs) សរុប ៧៥០.១៤៨ TEUs ដែលមានកំណើន ២,៤៣% ស្មើនឹង ១៧.៧៦១ TEUs បើធៀបនឹងឆ្នាំ២០២១ និងមានកំណើន ១៦,៨៧% ស្មើនឹង ១០៧.៣០៦ TEUs បើធៀបនឹងឆ្នាំ២០២០។ បើពិនិត្យមើលទៅលើបរិមាណកុងតែន័រនាំចេញ និងនាំចូលឆ្លងកាត់ កសស វិញ កុងតែន័រនាំចេញសម្រាប់ឆ្នាំ២០២២ បានកើនឡើង ២.៧៩២ TEUs ស្មើនឹង ០,៧៩% ចំណែកបរិមាណកុងតែន័រនាំចូលមានការកើនឡើង ១៤.៩៦៩ TEUs ស្មើនឹង ៣,៩៤% បើធៀបនឹងឆ្នាំ២០២១ ។




បើពិនិត្យទៅលើបរិមាណសរុបទំនិញ (តោន) ចរាចរណ៍ឆ្លងកាត់ កសស វិញ សម្រាប់ឆ្នាំ២០២២ មានបរិមាណសរុប ៧.០០៣.១៥៧ តោន ដែលមានកំណើន ០,១៨% ស្មើនឹង ១២.៨២០ តោន ធៀបនឹងឆ្នាំ២០២១ បើប្រៀបធៀបនឹងបរិមាណទំនិញឆ្នាំ២០២០ វិញ មានកំណើន ៤០១.៣៥៤ តោន ស្មើនឹង ៦,០៨%។ ក្នុងនោះទំនិញជាកុងតែន័រសម្រាប់ឆ្នាំ២០២២ មានការកើនឡើងប្រមាណ ១,៦៦% ស្មើនឹង ៨២.១៨៧ តោន និងទំនិញជាប្រេង និងហ្គាសមានការកើនឡើង ២,១៥% ស្មើនឹង ៣៨.៤២៤ តោន រីឯទំនិញរាយ ក៏មានការថយចុះ ៤២,៩៩% ស្មើនឹង ១០៧.៧៩១ តោន បើធៀបនឹងឆ្នាំ២០២១ ។




ចាប់តាំងពីឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន មានចរាចរណ៍កុងតែន័រមួយចំនួនដឹកតាមរយៈរថភ្លើងឆ្លងកាត់ កសស ដែលបានជួយសម្រួលមួយផ្នែក លើស្ថានភាពចរាចរណ៍ផ្លូវជាលេខ៤ ក៏ដូចជាផ្តល់នូវជម្រើសសម្រាប់អតិថិជនរបស់ កសស ក្នុងការដឹកទំនិញចេញ-ចូលកំពង់ផែ។ យើងសង្កេតឃើញថា បរិមាណកុងតែន័រដឹកតាមរថភ្លើងឆ្លងកាត់ កសស សម្រាប់ឆ្នាំ២០២២ មានចំនួន ៤៩.៥៨៩ TEUs មានការកើនឡើង ១៣,៧៨% ស្មើនឹង ៦.០០៥ TEUs បើធៀបនឹងឆ្នាំ២០២១ ។




សង្កេតទៅលើប្រភេទទំនិញនាំចេញប្រចាំឆ្នាំ២០២២ មានបរិមាណសរុបចំនួន ១.៧៧៧.៩២១ តោន ដោយថយ ០,៤៨ % ស្មើនឹង ៨.៥៩៧ តោន ធៀបនឹងឆ្នាំ២០២១។ សម្រាប់ឆ្នាំ២០២២ នេះទំនិញនាំចេញជាប្រភេទទំនិញអង្ករមានច្រើនជាងគេ មានចំនួន ៣៣,២៣% ស្មើនឹង ៥៩០.៧១៧ តោន និងទំនិញជាប្រភេទទូទៅមានចំនួន ៣១,៣៤% ស្មើនឹង ៥៥៧.២៣១ តោន នៃទំនិញនាំចេញសរុប។ រីឯក្រណាត់ សំលៀកបំពាក់មាន ២១,៥៩% ហើយទំនិញជាឈើកែច្នៃមាន ៦,០៥% ស្បែកជើង/ស្រោមជើងមាន ៣,៩០% ផ្លែឈើមាន ៣,៦៩% គ្រឿងចក្រមាន ០,០១% និងរថយន្ត ម៉ូតូ កង់ មាន ០,១៣% នៃបរិមាណទំនិញនាំចេញសរុប របស់ កសស ក្នុងឆ្នាំ២០២២ ។




ចំណែកទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០២២ ដែលឆ្លងកាត់ កសស វិញមានបរិមាណ ៥.២២៥.២៣៦ តោន មានការកើនឡើង ០,៤១% ស្មើនឹង ២១.៤១៧ តោន បើធៀបនឹងឆ្នាំ២០២១។ ក្នុងទំនិញនាំចូលនេះ ទំនិញទូទៅមានចំនួន ៥១,៥៤% ប្រេងឥន្ធនៈមាន ៣៤,៩៩% និងក្រណាត់ សំលៀកបំពាក់មានប្រមាណ ៧,៤៧% នៃបរិមាណទំនិញនាំចូលសរុប។ រីឯទំនិញប្រភេទជាគ្រឿងចក្រមាន ២,៣១% ប្រភេទរថយន្ត ម៉ូតូ

កង់មាន ២,៣៦% បារីមាន ០,៨១% លោហៈធាតុមាន ០,៣៨% និងធ្យូងថ្មមាន ០,១៤% នៃទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០២២ នេះ។




## ច- ស្ថានភាពប្រកួតប្រជែង

កសស នៅតែរក្សាបានឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- លក្ខណៈអំណោយផលនៃទីតាំងភូមិសាស្ត្រ
  - កសស ស្ថិតក្នុងឆកសមុទ្រខេត្តព្រះសីហនុ ដែលផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនទៅកាន់ទីផ្សារអន្តរជាតិសំខាន់ៗ។ ការដឹកជញ្ជូនពី កសស ទៅកាន់កំពង់ផែក្នុងអាស៊ីប៉ាស៊ីហ្វិច ពុំចាំបាច់ឆ្លងកាត់ចំណតផែមេក្នុងតំបន់ឡើយ ពោលគឺការដឹកជញ្ជូនអាចធ្វើឡើងដោយផ្ទាល់តែម្តង។ ក្រៅពីនេះការដឹកជញ្ជូន ក៏មានភាពងាយស្រួលផងដែរទៅកាន់កំពង់ផែហុងកុង ឬសិង្ហបុរី ដែលជាច្រកទ្វារទៅកាន់ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ។
  - មិនងាយរងគ្រោះដោយកត្តាធម្មជាតិ ដូចជា ព្យុះធំៗ រញ្ជួយដីជាដើម ដោយសារឆកសមុទ្រនេះមាន អំណោយផលស្រាប់ពីធម្មជាតិ ។
  - ចំណតឆ្នេរមិនតម្រូវឱ្យមានការបូមស្តារខ្សាច់ ឬកករច្រើនឡើយ ដែលនេះអាចធ្វើឱ្យ កសស មិនចាំបាច់ចំណាយច្រើនលើការបូមស្តារឃ្លង ឬផ្លូវនាវាឡើយ ។
- ហេដ្ឋារចនាសម្ព័ន្ធសម្បូរបែប និងទំនើប
  - កសស មានបំពាក់នូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បំរើឱ្យប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ដូចជាប្រព័ន្ធគ្រប់គ្រងចរាចរណ៍នាវា VTMS ជាដើម។ បច្ចុប្បន្នសមត្ថភាពលើកដាក់កុងតែន័ររបស់ កសស បានកើនឡើងរហូតដល់ ៨០០.០០០ TEUs ក្រោយពីបានបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ ប្រភេទ QC ចំនួន ០១ គ្រឿង RTG ចំនួន ០២ គ្រឿង និងរថលើកដាក់កុងតែន័រទទេ Empty Reach Stacker ចំនួន ០៤ គ្រឿង បន្ថែមទៀត។ កត្តានេះបានជំរុញផលិតភាពរបស់ កសស ឱ្យកើនជាងមុន និងកាត់បន្ថយពេលវេលាកកស្ទះទំនិញ។

- លើកកំពស់ប្រសិទ្ធភាពការងារ
  - ប្រសិទ្ធការងារត្រូវបានលើកកម្ពស់ តាមរយៈការពង្រឹងការគ្រប់គ្រង ដោយអនុវត្តអភិបាលកិច្ចល្អក្រោយពេលចុះបញ្ជីលក់មូលបត្រ ។
  - ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការអនុវត្តការងារ ដោយមានការគាំទ្រពីបំពាក់ឋបនីយភណ្ឌផែបន្ថែមដូចជា រថចល័តលើទីលានផែ និងរថចល័តលើគែមផែជាដើម ។
  - ការបណ្ដុះបណ្ដាល និងការលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំចំពោះបុគ្គលិក និយោជិត ពិសេសអនុវត្តការងារផ្ទាល់ដើម្បីពង្រឹងស្មារតី និងកំលាំងចិត្តក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញសេវាកម្មជូនអតិថិជន។
- តម្លៃសេវាកម្មមានលក្ខណៈប្រកួតប្រជែង
  - កសស នៅរក្សាតម្លៃសេវាកម្មរបស់ខ្លួនឱ្យមានលក្ខណៈប្រកួតប្រជែង ជាការទាក់ទាញអតិថិជនគួបផ្សំនឹងការពង្រឹងគុណភាពសេវាកម្មរបស់ខ្លួន ។
- រក្សាទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ
  - កសស បានរក្សាទំនាក់ទំនងល្អជាមួយអតិថិជនរបស់ខ្លួន ដោយព្យាយាមបំពេញតាមតម្រូវការរបស់អតិថិជន ទទួលយកយោបល់ និងការរិះគន់ក្នុងន័យស្ថាបនា ដើម្បីស្វែងយល់ពីចំនុចខ្វះខាតរបស់ខ្លួនក្នុងទិសដៅកែលម្អបន្ថែមទៀត ។
  - កសស ក៏រក្សាកិច្ចសហប្រតិបត្តិការជាមួយកំពង់ផែក្នុងតំបន់ក្នុងការចែកចាយព័ត៌មាន និងបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីលើកស្ទួយសេវាកម្មរបស់ខ្លួន ។

## ឆ- ផែនការអនាគត

ទស្សនទាន នៃការអភិវឌ្ឍន៍ កសស រយៈពេល ១០ឆ្នាំ (២០២០-២០៣០)

ផែនការអភិវឌ្ឍន៍រយៈពេលខ្លី-មធ្យម-វែង របស់ កសស រួមមាន៖

❖ គម្រោងបំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់

ចាប់ពីឆ្នាំ២០២២ ដល់ ឆ្នាំ២០២៤ កសស គ្រោងនឹងបំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់ប្រភេទរថស្ទូចចល័តលើគែមផែ (QC) ចំនួន ០២ គ្រឿង រថស្ទូចចល័តនៅទីលាន (RTG) ចំនួន ០៦ គ្រឿង បន្ថែមទៀត។ បន្ទាប់ពី កសស បានបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ប្រភេទ QC ចំនួន ០២ គ្រឿង RTG ចំនួន ០៤ គ្រឿង និងរថយន្តសណ្ដោងរ៉ឺម៉ក ចំនួន ០៨ គ្រឿង រួចហើយ ធ្វើឱ្យសមត្ថភាពលើកដាក់កុងតែន័ររបស់ កសស ឈានដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២២ នេះ។

| សេចក្ដីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររបស់ទីលាន កសស |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២២ នេះ |
| ធាតុសំខាន់ៗ នៃគម្រោង | • បំពាក់គ្រឿងចក្រ ប្រភេទ QC ០២ គ្រឿង RTG ០៦ គ្រឿង និងរថយន្តសណ្ដោងរ៉ឺម៉ក ចំនួន ០៨ គ្រឿង នៅឆ្នាំ២០២២ ដើម្បបង្កើនសមត្ថភាពលើកដាក់កុងតែន័រនៅទីលានឱ្យបានដល់ ៨០០.០០០TEUs ក្នុង ០១ ឆ្នាំ។ |

| | |
|---|---|
| | • ពង្រីកផ្លូវរត់គ្រឿងចក្រ QC ប្រវែង ២៥ ម៉ែត្រ នៅចំណតផែកុងតែន័រ ដើម្បីអនុញ្ញាតឱ្យនាវាកុងតែន័រ ០២ គ្រឿង ចូលចត និងលើកដាក់បានប្រកបដោយប្រសិទ្ធិភាព និងផលិតភាព (បានរៀបចំក្នុងផែនការអាជីវកម្មឆ្នាំ២០២២)។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាអ្នកអនុវត្ត |
| ប្រភពថវិកា | ថវិកា កសស ផ្ទាល់ |
| តម្លៃប៉ាន់ស្មានគម្រោង | USD ២១.០៣៧.០០០,០០ |

❖ គម្រោងកែសម្រួលផែប្រាំងទំនិញទូទៅ (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ

បរិមាណកុងតែន័រឆ្លងកាត់ កំពង់ផែក្រុងព្រះសីហនុ មានកំណើនខ្ពស់ ដោយសម្រេចបាន ៧៥០.១៤៨ TEUs នៅឆ្នាំ២០២២។ កសស រំពឹងទុកថានឹងមានកំណើនបន្តទៀត ស្របតាមកំណើនសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីការរាលដាលនៃជម្ងឺ Covid-19 ត្រូវបានបញ្ចប់ ។

ជាមួយនឹងកំណើនបរិមាណកុងតែន័រដែលបានឆ្លងកាត់នាពេលអនាគត កសស រំពឹងទុកថានឹងហួសសមត្ថភាពលើកដាក់ទំនិញ (៨០០.០០០ TEUs នៅឆ្នាំ២០២៣) ទោះបីជាបានទិញបន្ថែមនូវមធ្យោបាយគ្រឿងចក្រលើកដាក់កុងតែន័រ និងការងារពង្រីកទីលានរួចរាល់ហើយក៏ដោយ។

ដូច្នេះ ការងារកែសម្រួលផែប្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រ ប្រវែង ២៥៣ ម៉ែត្រ ដើម្បីក្លាយជាចំណតកុងតែន័រមួយបន្ថែមទៀត ដែលបច្ចុប្បន្នមានត្រឹមតែពីរចំណតប៉ុណ្ណោះ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររបស់ទីលាន កសស |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២៣ នេះ |
| ជាតុសំខាន់ៗនៃគម្រោង | • ការងារកែសម្រួលផែប្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ម៉ែត្រ) ទៅជាចំណតផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ<br>• ការងារខួងគ្រឹះ និងលទ្ធកម្មដែករ៉ែ សម្រាប់ពង្រីកផ្លូវរត់របស់គ្រឿងចក្រលើកដាក់កុងតែន័រនៅគែមផែ (QC)<br>• ការងាររៀបចំក្រាលទីលានសម្រាប់គ្រឿងចក្រ (RTG) (តំបន់ឃ្លាំងលេខ៥ មិនរាប់បញ្ចូលទីលាន (RTG) និងប្រព័ន្ធបង្ហូរទឹក ...។ ល។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាអ្នកអនុវត្ត |
| ប្រភពថវិកា | ថវិកា JICA ដែលសល់ពីគម្រោងលេខ: CP-P10 |
| តម្លៃប៉ាន់ស្មានគម្រោង | USD ១០.១០៧.០០០,០០ |

❖ គម្រោងសាងសង់ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ ជម្រៅ -១៤,៥ ម៉ែត្រ

ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ គឺជាគម្រោងអភិវឌ្ឍន៍ផែកុងតែន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក -១៤,៥ ម៉ែត្រ រួមបញ្ចូលទាំង ការបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប ប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង និងមធ្យោបាយលើកដាក់កុងតែន័រមួយចំនួន។ ល។

គម្រោងនេះ ទទួលបានហិរញ្ញប្បទានសម្បទានពីទីភ្នាក់ងារ JICA ដែលគ្រោងនឹងចាប់ផ្តើមការងារសាងសង់នៅចុងឆ្នាំ២០២២ ហើយបញ្ចប់ការងារសាងសង់និងដាក់ឱ្យប្រតិបត្តិការ ឆ្នាំ២០២៦ ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតែន័រនៅកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយរបស់ប្រទេសកម្ពុជា និងប្រសិទ្ធិភាពផ្នែកភស្តុភារកម្ម ដោយការសាងសង់ចំណតផែកុងតែន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ ព្រមទាំងអភិវឌ្ឍន៍ឋបនីយកណ្ឌផ្សេងទៀត អាចអនុញ្ញាតឱ្យនាវាកុងតែន័រ ដែលមានសមត្ថភាពផ្ទុក ៤.០០០ TEUs (៦០.០០០ DWT) ចូលចតបាន (ប្រមាណ ៩៣% នៃនាវាកុងតែន័រក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក)។ ចំណតផែកុងតែន័រថ្មីនេះ គ្រោងនឹងបញ្ចប់ការសាងសង់ និងដាក់ឱ្យដំណើរការនៅចុងឆ្នាំ២០២៦ ដែលមានសមត្ថភាពឱ្យកុងតែន័រឆ្លងកាត់បានប្រមាណ ៤៥០.០០០ TEUs/១ឆ្នាំ ធ្វើឱ្យសមត្ថភាពសរុបផែកុងតែន័រ កសស នឹងកើនឡើងដល់ ១.២៥០.០០០ TEUs/១ឆ្នាំ នៅឆ្នាំ២០២៦ (សមត្ថភាពបន្ថែមរបស់ផែប្រាំង ១០០.០០០ TEUs/១ឆ្នាំ ព្រមទាំងធ្វើឱ្យតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ដែលអាចរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ។ |
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតែន័រដល់ ១.២៥០.០០០ TEUs ក្នុង១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រ នេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៦ ខាងមុខ។ |
| ធាតុសំខាន់ៗនៃគម្រោង | • សាងសង់ចំណតផែកុងតែន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ ទីលានកុងតែន័រ និងឋបនីយកណ្ឌផែ ព្រមទាំងការងារបូមស្តារអាងនាវា និងឃ្លងនាវា ប្រវែង ៤គីឡូម៉ែត និងជម្រៅ -១៣,៥ ម៉ែត្រ។ ល។<br>• បំពាក់មធ្យោបាយលើកដាក់កុងតែន័រធុនធ្ងន់ រួមមាន QC ០៣ គ្រឿង RTG ០៩ គ្រឿង រថលើកកុងតែន័រទទេ (Empty Reach Stacker) ចំនួន ០២ គ្រឿង ក្បាលសណ្តោងកុងតែន័រ ចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម ០១ កំភ្លេ។ ល។ |
| ទីតាំងគម្រោង | ស្ថិតនៅភាគខាងកើតនៃចំណតផែកុងតែន័រមានស្រាប់ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលក ចំងាយប្រមាណ ៣០០ ម៉ែត្រ ពីប្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅកាន់ទីលានផែកុងតែន័រ។ ផ្ទៃដីសរុបទំហំ ១៧,៥ ហិកតា ។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាម្ចាស់គម្រោង (Employer) ។ |

| | |
|---|---|
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA (លេខៈ CP-P21) តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ២៣.៥០២.០០០.០០០ ប្រហាក់ប្រហែលនឹង USD ២០៣.០០០.០០០,០០ |
| ដំណាក់កាលនៃការអនុវត្តន៍គម្រោង | **ដំណាក់កាលទី១ ៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)**<br>-ជំហានទី១ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ក្រុមសិក្សា JICA បានចុះមកសិក្សា និងរៀបចំរបាយការណ៍ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី កំពង់ផែក្រុងព្រះសីហនុ ។<br>-ជំហានទី២ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ទីភ្នាក់ងារ JICA បានចុះមកសិក្សា និងវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី កំពង់ផែក្រុងព្រះសីហនុ ដោយសម្រេចចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាន សម្បទាន លេខៈ CP-P21 នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>**ដំណាក់កាលទី២៖ ការងារជ្រើសរើសកុងស៊ុលតង់គម្រោង (ឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩)**<br>-ការងារជ្រើសរើសកុងស៊ុលតង់នេះត្រូវបានអនុវត្តតាមនីតិវិធី Single Source Selection (SSS)។ ក្នុងដំណាក់កាលនីមួយៗ ត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA។ សេវាកុងស៊ុលតង់នេះរួមមាន ការងារសិក្សាគំនូសផ្នែកវិស្វកម្ម សំណង់ស៊ីវិល និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ជាដើម ។<br>-ក្រុមហ៊ុន Nippon-Koei & Oriental Consultants Global JV (ក្រុមហ៊ុនជប៉ុន) ត្រូវបានចុះកិច្ចសន្យាជាមួយ កសស នៅខែសីហា ឆ្នាំ២០១៩ ។<br>**ដំណាក់កាលទី៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)**<br>-ជំហានទី១ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)៖ ការរៀបចំគំនូសប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Package-1) និង ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (Package-2) ។<br>-ក្រុមហ៊ុនកុងស៊ុលតង់ NK-OCG JV បានចាប់ដំណើរការការងារផ្នែកគំនូសប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃ សម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ តាំងពីខែកក្កដា ឆ្នាំ២០១៩ ហើយបានដាក់ជូន កសស នៅខែមិថុនា ឆ្នាំ២០២០។ ប៉ុន្តែការងារផ្នែកគំនូសប្លង់វិស្វកម្មនេះ ត្រូវបានកែសម្រួលឱ្យស្របតាមកិច្ចសម្រួលពាណិជ្ជកម្ម ព្រមទាំងផលប៉ះពាល់ជាសកលដោយសារជម្ងឺកូវីដ-១៩ បណ្តាលឱ្យមានការពន្យាពេលអនុវត្តគម្រោង និងបានដាក់ជូន កសស សារជាថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២១ ។<br>-ជំហានទី២ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតែន័រថ្មី (Package-1) (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣) និង ②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (Package-2) (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣)។ |

| | |
|---|---|
| | ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ហើយត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតែន័រថ្មី និងផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (ចុងឆ្នាំឆ្នាំ២០២៣ ដល់ចុងឆ្នាំ២០២៦)**<br>-ជំហានទី១ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦)៖ ការងារសាងសង់ចំណតផែកុងតែន័រថ្មីគ្រោងនឹងចាប់ផ្តើមនៅពាក់កណ្តាល ឆ្នាំ២០២២ ហើយបញ្ចប់ការងារនៅឆ្នាំ២០២៥ (៣៦ខែ) ។<br>-ជំហានទី២ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦)៖ ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់គ្រោងនឹងចាប់ផ្តើមនៅ ឆ្នាំ២០២៣ ហើយគ្រោងបញ្ចប់ការងារនៅ ឆ្នាំ២០២៥ (២៨ខែ)។<br>**ដំណាក់កាលទី ៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៧)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ដូចខាងក្រោមៈ<br>-ការងារសាងសង់ចំណតផែកុងតែន័រថ្មី (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៧)<br>-ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៧)។ |
| វឌ្ឍនភាពគម្រោង | កិច្ចព្រមព្រៀងប្រាក់កម្ចី បានចុះហត្ថលេខានៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី ចូលជាធរមាន នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី បញ្ចប់សុពលភាព នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ ។<br>-កិច្ចសន្យាផ្នែកសេវាកុងស៊ុលតង់ រវាង កសស និងក្រុមហ៊ុន NK-OCG JV ចុះថ្ងៃទី ០៨ខែសីហា ឆ្នាំ២០១៩ ។<br>-សេវាកុងស៊ុលតង់ផ្នែកគំនូសប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃសម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ បានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០១៩ ហើយគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២០។ ប៉ុន្តែ គម្រោងនេះ ត្រូវបានពន្យាពេលដោយសារផលប៉ះពាល់ជាសកលដោយសារការរីករាលដាល នៃជម្ងឺកូវីដ១៩ និងការកែសម្រួលគំនូសប្លង់លំអិតឱ្យស្របតាមកិច្ចសម្រួលពាណិជ្ជកម្ម នោះ ឯកសារដេញថ្លៃកែសម្រួលថ្មី បានដាក់ជូន កសស សាជាថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២១ ។<br>-រហូតដល់ដើមខែមីនា ឆ្នាំ២០២៣នេះ ការងារជ្រើសរើសក្រុមហ៊ុនសាងសង់ បានឈានដល់ដំណាក់ កាលវាយតម្លៃលើលក្ខណៈបច្ចេកទេស របស់ក្រុមហ៊ុនដេញថ្លៃ ។ ជាលទ្ធផល ក្រុមហ៊ុន Penta- Ocean & Rinkai JV និង ក្រុមហ៊ុន TOA Corporation បានជាប់លក្ខណៈបច្ចេកទេស។ រីឯ ក្រុមហ៊ុន JV CHEC & SUMEC បានត្រូវវាយតម្លៃធ្លាក់លក្ខណៈបច្ចេកទេស។ របាយការណ៍វាយតម្លៃ លក្ខណៈបច្ចេកទេស (BER) បានដាក់ស្នើសុំគោលការណ៍ពិនិត្យ និងសម្រេចពី ទីភ្នាក់ងារ JICA នៅដើមខែមីនា ឆ្នាំ២០២៣ ។ |

❖ គម្រោងពង្រីកចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ (ប្រវែង ៤០០ ម៉ែត្រ ជម្រៅទឹក -១៦,៥ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៣០ ម៉ែត្រ ជម្រៅទឹក -១៧,៥ ម៉ែត្រ) ដោយប្រើប្រាស់កម្ចីជប៉ុន

ជាទស្សនវិស័យ កសស នឹងអភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជិស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណា

ចក្រកម្ពុជា។ នៅពេលចំណតផែកុងតែន័ទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ ដាក់ឱ្យដំណើរការ កសស នឹងអាចស្រូបទាញនាវាកុងតែន័ធុនធំដែលមានផ្លូវដឹកជញ្ជូនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក មកកាន់ប្រទេសកម្ពុជា ដោយផ្ទាល់ ដោយពុំចាំបាច់ ផ្ទេរ-ផ្ទុក នៅតាមបណ្តាកំពង់ផែផ្សេងៗ ដោយទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ច ពីការកាត់បន្ថយតម្លៃ និងការចំណេញពេលវេលា ក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ។

កសស បានកំពុងប្រែក្លាយជាកំពង់ផែក្នុងតំបន់ដ៏មានសក្តានុពល ជាពិសេស គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជា ហើយតភ្ជាប់ប្រទេសកម្ពុជាទៅកាន់តំបន់ និងពិភពលោក។

ហេតុដូច្នេះ កសស ត្រូវការបន្ទាន់ជាបន្ទាន់នូវការពង្រីកចំណតផែកុងតែន័ទឹកជ្រៅថ្មីទាំងពីរជំហានរួមគ្នាឱ្យបានរួចរាល់នៅឆ្នាំ២០២៨-២០២៩ ដែលជាជម្រើសសិក្សាដោយក្រុមសិក្សា JICA Survey Team៖

១- ចំណតផែកុងតែន័ទឹកជ្រៅថ្មី-ជំហានទី២ ប្រវែង ៤០០ម៉ែត្រ និងជម្រៅទឹក -១៦,៥ម៉ែត្រ

- សមត្ថភាពនាវាចំណុះ ១២០.000 DWT ផ្ទុកកុងតែន័ជាមធ្យម ១០.000 TEUs ចូលចតបាននិងការបំពាក់មធ្យោបាយលើកដាក់កុងតែន័ធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័ស្វ័យប្រវត្តិកម្ម TOS ចាំបាច់ មួយចំនួន ។

២- ចំណតផែកុងតែន័ទឹកជ្រៅថ្មី-ជំហានទី៣ ប្រវែង ៤៣០ម៉ែត្រ និងជម្រៅទឹក -១៧,៥ម៉ែត្រ

- សមត្ថភាពនាវាចំណុះ ១៦០.000 DWT ផ្ទុកកុងតែន័ជាមធ្យម ១៥.000 TEUs ចូលចតបាន និងការបំពាក់មធ្យោបាយលើកដាក់កុងតែន័ធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័ស្វ័យប្រវត្តិកម្ម TOS ចាំបាច់ មួយចំនួន ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២២ ដល់ឆ្នាំ២០៣០ |
| គោលបំណងនៃគម្រោង | ដើម្បីចូលរួមគាំទ្រដល់កិច្ចសម្រួលពាណិជ្ជកម្ម និងធុរកិច្ចនៅកម្ពុជាកាត់បន្ថយពេលវេលា និងតម្លៃឡូជីស្ទិក ដែលធានាបាន នូវនិរន្តរភាព នៃលំហូរទំនិញចេញ-ចូលប្រកបដោយលក្ខណៈប្រកួតប្រជែងគុណភាពសេវា និងមិនកកស្ទះចរាចរទំនិញនាពេលអនាគត ឆ្លើយតបបាននូវ គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម កម្ពុជាឆ្នាំ២០១៥-២០២៥ នោះ កសស ត្រូវការជាបន្ទាន់ និងសាងសង់ចំណតផែកុងតែន័ទឹកជ្រៅថ្មី-ជំហានទី២ (ប្រវែង ៤០០ ម៉ែត្រ ជម្រៅទឹក-១៦,៥ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៣០ ម៉ែត្រ ជម្រៅទឹក-១៧.៥ ម៉ែត្រ) រួមគ្នា ក្នុងទស្សនវិស័យ កសស នឹងអភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និង ជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជិស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំណតផែកុងតែន័ទឹកជ្រៅថ្មីនេះ នឹងអាចស្រូបទាញនាវាកុងតែន័ធុនធំដែលមានផ្លូវដឹកជញ្ជូនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក មកកាន់ ប្រទេសកម្ពុជា ដោយផ្ទាល់ ដោយពុំចាំបាច់ ផ្ទេរ-ផ្ទុក នៅតាមបណ្តាកំពង់ផែផ្សេងៗ ដោយទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ច ពីការកាត់បន្ថយតម្លៃ និងការចំណេញពេលវេលា ក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ។ ជាមួយនេះ កសស បានកំពុងប្រែក្លាយជាកំពង់ផែក្នុងតំបន់ដ៏មានសក្តានុពលជាពិសេស គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជា ហើយតភ្ជាប់ប្រទេសកម្ពុជា ទៅកាន់តំបន់ និងពិភពលោក ។ |

| | |
|---|---|
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតែន័រឈានដល់ ២.៥០០.០០០ TEUs ក្នុង១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ នេះ ដាក់ឱ្យប្រតិបត្តិការនៅឆ្នាំ ២០៣០ ខាងមុខ។ |
| ធាតុសំខាន់ៗនៃគម្រោង | ១-ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ ប្រវែង ៤០០ ម៉ែត្រ និងជម្រៅទឹក -១៦,៥ ម៉ែត្រ (សមត្ថភាពនាវាចំណុះ ១២០.០០០DWT ផ្ទុកកុងតែន័រជាមធ្យម ១០.០០០ TEUs ចូលចតបាន) និងការបំពាក់មធ្យោបាយលើកដាក់កុងតែន័រទំនើប ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។<br>២-ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី៣ ប្រវែង ៤៣០ម៉ែត្រ និងជម្រៅទឹក -១៧.៥ម៉ែត្រ (សមត្ថភាពនាវាចំណុះ ១៦០.០០០DWT ផ្ទុកកុងតែន័រជាមធ្យម ១៥.០០០TEUs ចូលចតបាន) និងការបំពាក់មធ្យោបាយលើកដាក់កុងតែន័រទំនើប ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។ |
| ទីតាំងគម្រោង | បន្តពីចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលកចំងាយប្រមាណ ៦៥០ ម៉ែត្រ ពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅទីលានចំណតផែកុងតែន័រថ្មី ។ ផ្ទៃដីសរុបទំហំ ៤២.៥ ហិកតា ។ |
| ភ្នាក់ងារអនុវត្តគម្រោង | កសស ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាម្ចាស់គម្រោង (Employer) ។ |
| ប្រភពថវិកានិងចំនួនថវិកា | ប្រាក់កម្ចីពី JICA តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ៦៤.៩៧៣.០០០.០០០ ស្មើនឹងប្រមាណ USD ៥៧០.០០០.០០០,០០<br>(បានទទួលប្រាក់កម្ចី JICA លើកទី១៖ ចំនួន JPY ៤១.៣៨៨.០០០.០០០ ស្មើនឹងប្រមាណ USD ៣៦០.០០០.០០០,០០) |
| ដំណាក់កាលនៃគម្រោង | ដំណាក់កាលទី១៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)<br>-ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)៖ ក្រុមសិក្សា JICA Survey Team បានកំពុងចុះសិក្សា និងរៀបចំរបាយការណ៍ ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងទី៣ រួមគ្នា ព្រមទាំងធ្វើការវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ទឹកជ្រៅថ្មីទាំងពីរជំហានរួមគ្នា ដើម្បីផ្តល់ប្រាក់កម្ចីសម្បទាន ។<br>ដំណាក់កាលទី២៖ ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣) ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ សម្រាប់គម្រោងពង្រីកចំណតផែកុងតែន័រ-ជំហានទី២ និងជំហានទី៣ ដោយត្រូវបានអនុវត្តតាមនីតិវិធី ផ្តល់ឈ្មោះបញ្ជីខ្លីក្រុមហ៊ុនកុងស៊ុលតង់ (Shortlisted Consultants) ដោយដៃគូអភិវឌ្ឍន៍។ សេវាកុងស៊ុលតង់នេះ រួមមានការងារសិក្សាគំនូសប្លង់ផ្នែកវិស្វកម្មសំណង់ស៊ីវិល សម្រាប់ NCT2 & NCT3 ជំនួយការរៀបចំឯកសារដេញថ្លៃ និងការងារត្រួតពិនិត្យលើការងារសាងសង់ សម្រាប់ការជ្រើសរើសក្រុមហ៊ុនម៉ៅការសំណង់ សម្រាប់ NCT2 & NCT3 ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប និងការងារផ្គត់នាវាបម្រើប្រតិបត្តិការ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុង |

| | |
|---|---|
| | ពេលធានារយៈពេលសាងសង់ ជាដើម ។<br>**ដំណាក់កាលទី៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសំណង់ និងក្រុមហ៊ុនផ្គត់ផ្គង់មធ្យោបាយលើកដាក់កុងតែន័រទំនើប (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)**<br>-ជំហានទី១ (ដើមឆ្នាំ២០២៣ ដល់ដើមឆ្នាំ២០២៤)៖ ការរៀបចំគំនូសប្លង់វិស្វកម្ម សម្រាប់ ①ការងារសំណង់ស៊ីវិល-ជំហានទី២ (Package-1) ② ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប (Package-2) និង③ ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ជំហានទី២ (ចុងឆ្នាំ២០២៣ ដល់ចុងឆ្នាំ២០២៤)៖ ការរៀបចំគំនូសប្លង់វិស្វកម្ម សម្រាប់ការងារសំណង់ស៊ីវិល-ជំហានទី៣ (Package-4)<br>-ជំហានទី៣ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)៖ ① ការជ្រើសរើសក្រុមហ៊ុនសាងសង់-ជំហានទី២ (Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ជំហានទី៤ (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់-ជំហានទី៣ (Package-4)<br>ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ ការងារផ្គត់ផ្គង់មធ្យោបាយលើកដាក់កុងតែន័រទំនើប និងការងារនាវាបម្រើប្រតិបត្តិការ (ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៩)**<br>-ជំហានទី១ (ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៨) (៣៦ខែ)៖ ①ការងារសាងសង់ចំណតផែកុងតែន័រទឹកជ្រៅថ្មី-ជំហានទី២(Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ជំហានទី២ (ឆ្នាំ២០២៦ ដល់ឆ្នាំ២០២៩) (៤២ខែ)៖ ①ការងារសាងសង់ចំណតផែកុងតែន័រទឹកជ្រៅ ថ្មី-ជំហានទី៣(Package-4) ។<br>**ដំណាក់កាលទី៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៨ ដល់ឆ្នាំ២០៣០)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ។ |
| វឌ្ឍនភាពគម្រោង | នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ កសស បានអញ្ជើញ ក្រុមហ៊ុន Shortlisted Consults ចំនួន ៥ក្រុមហ៊ុន ដែលផ្តល់ដោយទីភ្នាក់ងារ JICA រួមមានក្រុមហ៊ុន៖ ១). ក្រុមហ៊ុន Environmental Consultants for Ocean and Human (ECOH Corporation), ២). ក្រុមហ៊ុន Japan Port Consultants, Ltd (JPC), ៣). ក្រុមហ៊ុន Nippon Koei Co., Ltd (NK), ៤). ក្រុមហ៊ុន Oriental Consultants Global Co., Ltd (OCG) និង៥). ក្រុមហ៊ុន The Overseas Coastal Area Development Institute of Japan (OCDI) មកទទួលយកសំណើសុំ (RFP) ដោយកំណត់កាលបរិច្ឆេទឈប់ទទួលសំណើសុំ (RFP) នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅវេលាម៉ោង ១៤:00 រសៀល។ ជាលទ្ធផល ក្រុមហ៊ុន ចំនួន ០២ បានបដិសេធមិនចូលរួមដាក់សំណើសុំ (RFP) រួមមាន៖ ១) ក្រុមហ៊ុន |

| | |
|---|---|
| | Environmental Consultants for Ocean and Human (ECOH Corporation) និង ២). ក្រុមហ៊ុន Japan Port Consultants, Ltd (JPC) ។ ចំណែកឯក្រុមហ៊ុន ចំនួន ០៣ ផ្សេងទៀត បានធ្វើ Joint Venture ដោយដាក់សំណើសុំ (RFP) រួមតែមួយ ជាក្រុមហ៊ុន JV-Nippon Koei and Oriental Consultant Global in association with OCDI និង បានធ្វើការបើកឯកសារ សំណើសុំ (RFP) ដោយគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម ។ |

## ៨- ភត្តាហានិភ័យ

សម្រាប់ឆ្នាំ២០២២ នេះ កសស មិនមានការវិភាគអំពីហានិភ័យនោះទេ ។

# ផ្នែកទី ២

# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

# ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| បរិយាយ | ឯកត្តា | ផែនការ ២០២២ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| បរិមាណទំនិញឆ្លងកាត់ | តោន | ៧.៤១៨.០០០ | ៧.០០៣.១៥៧ | ៦.៩៩០.៣៣៧ | ៦.៦០១.៨០៤ | -៥,៥៩% | ០,១៨% | ៦,០៨% |
| ជាកុងតែន័រ | _ | | ៥.០៣១.៩៨៨ | ៤.៩៤៩.៨០១ | ៤.៣៦៣.៩០៩ | | ១,៦៦% | ១៥,៣១% |
| ទំនិញរាយ | _ | | ១៤២.៩៤៤ | ២៥០.៧៣៤ | ៣៤៩.៨២០ | | -៤២,៩៩% | -៥៩,១៤% |
| ប្រេង | | | ១.៧២៩.៧០០ | ១.៧៣៧.០៤៧ | ១.៨០៤.៣៥២ | | -០,៤២% | -៤,១៤% |
| ហ្គាស | _ | | ៩៨.៥២៥ | ៥២.៧៥៥ | ៨៣.៧២២ | | ៨៦,៧៦% | ១៧,៦៨% |
| បរិមាណទំនិញនាំចូល | _ | ៥.៥៦៤.០០០ | ៥.២២៥.២៣៦ | ៥.២០៣.៨១៩ | ៤.៨៨៧.៦៨៤ | -៦,០៩% | ០,៤១% | ៦,៩១% |
| ជាកុងតែន័រ | _ | | ៣.២៥៤.៤៩៩ | ៣.១៩១.១៨៧ | ២.៦៧០.៧៧០ | | ១,៩៨% | ២១,៨៦% |
| ទំនិញរាយ | _ | | ១.៩៧០.៧៣៧ | ២.០១២.៦៣២ | ២.២១៦.៩១៤ | | -២,០៨% | -១១,១០% |
| បរិមាណទំនិញនាំចេញ | _ | ១.៨៥៤.០០០ | ១.៧៧៧.៩២១ | ១.៧៨៦.៥១៨ | ១.៧១៤.១២០ | -៤,១០% | -០,៤៨% | ៣,៧២% |
| ជាកុងតែន័រ | _ | | ១.៧៧៧.៤៨៩ | ១.៧៥៨.៦១៤ | ១.៦៩៣.១៤០ | | ១,០៧% | ៤,៩៨% |
| ទំនិញរាយ | _ | | ៤៣២ | ២៧.៩០៤ | ២០.៩៨០ | | -៩៨,៤៥% | -៩៧,៩៤% |
| បរិមាណទំនិញលើករៀប | _ | ១០.២៩៨.០០០ | ១១.២៣៩.៤៣៤ | ១០.១៩៩.១៤៨ | ៨.៩៥៤.៣១៧ | ៩,១៤% | ១០,២០% | ២៥,៥២% |
| ប្រគល់ផ្ទាល់ | _ | ២២០.០០០ | ១២១.១៨០ | ២០១.៩២៣ | ២០៨.៣២៩ | | -៣៩,៩៩% | -៤១,៨៣% |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | _ | ១០.០៧៨.០០០ | ១១.១១៨.២៥៣ | ៩.៩៩៧.២២៥ | ៨.៧៤៥.៩៨៨ | | ១១,២១% | ២៧,១២% |
| បរិមាណកុងតែន័រឆ្លងកាត់ | TEUs | ៧៨៧.០០០ | ៧៥០.១៤៨ | ៧៣២.៣៨៧ | ៦៤១.៨៤២ | -៤,៦៨% | ២,៤៣% | ១៦,៨៧% |
| នាំចូល | _ | | ៣៩៥.១១៤ | ៣៨០.១៤៥ | ៣២០.៦៤២ | | ៣,៩៤% | ២៣,២៣% |
| មានទំនិញ | _ | | ៣៤៣.១៥២ | ៣៤០.៥៦៧ | ២៩៥.៦៣១ | | ០,៧៦% | ១៦,០៧% |
| គ្មានទំនិញ | _ | | ៥១.៩៦២ | ៣៩.៥៧៨ | ២៥.០១១ | | ៣១,២៩% | ១០៧,៧៦% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| នាំចេញ | _ | | ៣៥៥.០៣៤ | ៣៥២.២៤២ | ៣២១.២០០ | | ០,៧៩% | ១០,៥៣% |
| មានទំនិញ | _ | | ២១៨.៩១៣ | ២២១.៤៨៥ | ២០០.០៥៨ | | -១,១៦% | ៩,៤២% |
| គ្មានទំនិញ | _ | | ១៣៦.១២១ | ១៣០.៧៥៧ | ១២១.១៤២ | | ៤,១០% | ១២,៣៦% |
| ចំនួននាវាចូលចត | គ្រឿង | ១.៤៥០ | ១.៤៤២ | ១.៥៨២ | ១.៦៦២ | -០,៥៥% | -៨,៨៥% | -១៣,២៤% |
| ចំណុះផ្ទុកនាវា | តោន | ១៤.១២៨.០០០ | ១៤.១០៨.០៣២ | ១៣.៣៦៦.៣៩៩ | ១៦.៧៨៤.៩៧៩ | -០,១៤% | ៥,៥៥% | -១៥,៩៥% |
| នាវាដឹកកុងតែន័រ | គ្រឿង | | ៦៨៨ | ៦៥៥ | ៦៧០ | | ៥,០៤% | ២,៦៩% |
| ចំណុះនាវាដឹកកុងតែន័រ | តោន | | ៩.៥០៨.៩៣៧ | ៩.០៣៤.៤០៩ | ១០.១៨៨.៥៨៥ | | ៥,២៥% | -៦,៦៧% |
| នាវាដឹកប្រេង និងហ្គាស | គ្រឿង | | ៥១៣ | ៤៨៣ | ៥៨៧ | | ៦,២១% | -១២,៦១% |
| ចំណុះនាវាដឹកប្រេង និងហ្គាស | តោន | | ២.១៦៨.៩៨៥ | ២.០០៣.៩៦៤ | ២.៣៦២.០៤៤ | | ៨,២៣% | -៨,១៧% |
| នាវាដឹកទំនិញទូទៅ | គ្រឿង | | ២៣៨ | ៣១០ | ៣០៧ | | -២៣,២៣% | -២២,៤៨% |
| ចំណុះនាវាដឹកទំនិញទូទៅ | តោន | | ២.២៣៦.៤៣៧ | ២.៣២៨.០២៦ | ២.៧៦៥.៧៥៣ | | -៣,៩៣% | -១៩,១៤% |
| នាវាទេសចរណ៍ | គ្រឿង | | ៣ | ០ | ១៨ | | ១០០,០០% | -៨៣,៣៣% |
| នាវាទេសចរណ៍ | តោន | | ១៩៣.៦៧៣ | ០ | ១.៤៦៨.៥៩៧ | | ១០០,០០% | -៨៦,៨១% |
| ចំនួនទេសចរ | នាក់ | | ២៣១ | ០ | ១៧.៧៨៩ | | ១០០,០០% | -៩៨,៧០% |


ចំណុះផ្ទុកនាវាចូលចត កសស
១២,000,000
១0,000,000
៨,000,000
៦,000,000
៤,000,000
២,000,000
0
៩.៥០៨.៩៣៧
៩.០៣៤.៤០៩
១០.១៨៨.៥៨៥
២.១៦៨.៩៨៥
២.០០៣.៩៦៤
២.៣៦២.០៤៤
២.២៣៦.៤៣៧
២.៣២៨.០២៦
២.៧៦៥.៧៥៣
១៩៣.៦៧៣
0
១.៤៦៨.៥៩៧
នាវាកុងតែន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០២២
ឆ្នាំ២០២១
ឆ្នាំ២០២០


ចំនួននាវាចូលចត កសស
៨00
៦00
៤00
២00
0
៦៨៨
៦៥៥
៦៧០
៥១៣
៤៨៣
៥៨៧
២៣៨
៣១០
៣០៧
៣
0
១៨
នាវាកុងតែន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០២២
ឆ្នាំ២០២១
ឆ្នាំ២០២០


បរិមាណកុងតែន័រឆ្លងកាត់ កសស (TEUs)
ឆ្នាំ២០២០
ឆ្នាំ២០២១
ឆ្នាំ២០២២
នាំចេញគ្មានទំនិញ
១២១.១៩៤២
១៣០.៧៥៧
១៣៦.១២១
នាំចេញមានទំនិញ
២០០.០៥៨
២២១,៤៨៥
២១៨.៩១៣
នាំចូលគ្មានទំនិញ
២៥.០១១
៣៩.៥៧៨
៥១.៩៦២
នាំចូលមានទំនិញ
២៩៥.៦៣១
៣៤០.៥៦៧
៣៤៣.១៩៥២
0
៥0,000
១00,000
១៥0,000
២00,000
២៥0,000
៣00,000
៣៥0,000
៤00,000


ប្រទេសនាំចេញកុងតៃន័រ ប្រចាំឆ្នាំ២០២២
១១%
៣២%
៣៤%
៧%
៧%
២%
៦%
ចិន
អឺរ៉ុប
អាមេរិក
អាស៊ី
អង់គ្លេស
ជប៉ុន
ផ្សេងៗ


ប្រទេសនាំចូលកុងតៃន័រ ប្រចាំឆ្នាំ២០២២
៦១%
៣%
៦%
២២%
0%
៤%
៣%
ចិន
អឺរ៉ុប
អាមេរិក
អាស៊ី
អង់គ្លេស
ជប៉ុន
ផ្សេងៗ

## ខ- រចនាសម្ព័ន្ធចំណូល

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន ( Stevedoring ) | ១៦៤.៨៧៣.៤៤៥ | ៤៧,៩៦% | ១៥៨.៥៦៦.៤៩៩ | ៤៦,៣២% | ១៤៤.៨៣៨.៣៣៩ | ៤៦,៤៥% |
| ចំណូលលើកដាក់លើទីលាន ( LOLO ) | ៩៦.៩២០.១៩៦ | ២៨,២០% | ១០០.៦០២.០៤៦ | ២៩,៣៩% | ៨៣.៨២១.៧៧៥ | ២៦,៨៨% |
| ចំណូលពីសេវាកម្មនាវាចរ | ៦២.២៨៥.០៥០ | ១៨,១២% | ៦៥.០១៦.២៦៧ | ១៨,៩៩% | ៦៧.៥៨៣.៩៨៥ | ២១,៦៧% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ១៥.៥១៦.៩៧៥ | ៤,៥១% | ១៤.៣៧៤.៤៨៨ | ៤,២០% | ១១.៣៧៧.៧៨៥ | ៣,៦៥% |
| ចំណូលដឹកជញ្ជូន | ៩២.០៩០ | ០,០៣% | ១២២.៣២៦ | ០,០៤% | ៦៤.៨១៣ | ០,០២% |
| ចំណូលនាវាទេសចរណ៍ | ០ | ០,០០% | ០ | ០,០០% | ២៦៥.៦៤៥ | ០,០៩% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ២.៣៧៤.៦៩៦ | ០,៦៩% | ២.១៩៥.៨៦៩ | ០,៦៤% | ២.៤០៧.៧២២ | ០,៧៧% |
| ចំណូលជួលទីតាំង | ១.៣៨៥.៥៥៣ | ០,៤០% | ១.១៦៨.២៤៨ | ០,៣៤% | ១.១៤០.៨៣១ | ០,៣៧% |
| ចំណូលផ្សេងៗទៀត | ២៩៥.៥៣៩ | ០,០៩% | ៣០៣.៤៨៦ | ០,០៩% | ៣១២.៨៧៤ | ០,១០% |
| **ចំណូលសរុប** | **៣៤៣.៧៤៣.៥៤៥** | **១០០,០០%** | **៣៤២.៣៤៩.២២៩** | **១០០,០០%** | **៣១១.៨១៣.៧៦៩** | **១០០,០០%** |

# ផ្នែកទី ៣
# ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក- អង្គការលេខ

## រចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ



## ខ- ក្រុមប្រឹក្សាភិបាល

### សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯ.ឧ លូ គឹមឈន់ | ប្រធាន | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ២ | ឯ.ឧ ស៊ុយ សាន | សមាជិក | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ៣ | ឯ.ឧ ផាន់ផល្លា | សមាជិក | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ៤ | ឯ.ឧ សុខ សុភ័ក្រ្ត | សមាជិក | ០៥-ឧសភា-២០២១ | ០៤-ឧសភា-២០២៤ |
| ៥ | លោក ហ៊ិន មុន្នីវណ្ណ | សមាជិក | ២៥-មិថុនា-២០២១ | ២៤-មិថុនា-២០២៤ |
| ៦ | លោក Hidetoshi KUME | សមាជិក | ២៥-មិថុនា-២០២១ | ២៤-មិថុនា-២០២៤ |
| ៧ | លោក លូ លីខេង | សមាជិក | ២១-មិថុនា-២០២១ | ២០-មិថុនា-២០២៤ |

## គ- បុគ្គលិកជាន់ខ្ពស់

### សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះអភិបាល | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯ.ឧ លូ គឹមឈន់ | ប្រុស | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ២ | លោក ណុំ ស៊ីនិត | ប្រុស | មន្ត្រីត្រួតពិនិត្យរដ្ឋ អមកំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ៣ | លោក ថៃ ឬទ្ធី | ប្រុស | អគ្គនាយករង អាជីវកម្ម |
| ៤ | លោក ថោង វីរ៉ូ | ប្រុស | អគ្គនាយករង រដ្ឋបាល-គ្រប់គ្រង |
| ៥ | លោក ទីសាគុណ | ប្រុស | អគ្គនាយករង បច្ចេកទេស |
| ៦ | លោក វ័ន្ន សិលា | ប្រុស | ប្រធាននាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស |
| ៧ | លោក ពិត ប្រាកដ | ប្រុស | ប្រធាននាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ |
| ៨ | លោក សូ សៀង | ប្រុស | ប្រធាននាយកដ្ឋាន ផែនការ លទ្ធកម្ម និងស្ថិតិ |
| ៩ | លោក អ៊ុក វណ្ណារ៉ា | ប្រុស | ប្រធាននាយកដ្ឋាន បច្ចេកទេស-សម្ភារៈ |
| ១០ | លោកស្រី ជ័យ សុគន្ធា | ស្រី | ប្រធាននាយកដ្ឋាន ទីផ្សារ |
| ១១ | លោក ជីវ ច័ន្ទសុផល | ប្រុស | ប្រធាននាយកដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស |
| ១២ | លោក ងួន រតនា | ប្រុស | ប្រធាននាយកដ្ឋាន អាជីវកម្ម |
| ១៣ | លោក ថៃ ម៉េងលី | ប្រុស | ប្រធាននាយកដ្ឋាន ប្រតិបត្តិការទីលានកុងតែន័រ |
| ១៤ | លោក លូ លីខេង | ប្រុស | ប្រធាននាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ |
| ១៥ | លោក ស៊ឹង សេណូ | ប្រុស | ប្រធាននាយកដ្ឋាន នាវាចរ-កណ្ណធារ និងសន្តិសុខ |
| ១៦ | លោក គឹម ហោ | ប្រុស | ប្រធាននាយកដ្ឋាន គ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី |
| ១៧ | លោក ម៉ែន ចាន់ | ប្រុស | ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង |
| ១៨ | លោក សោម ករណី | ប្រុស | ប្រធាននាយកដ្ឋាន ព័ត៌មានវិទ្យា |
| ១៩ | លោក មាន គឹង | ប្រុស | ប្រធាននាយកដ្ឋាន សំណង់-វិស្វកម្ម |

**សម្គាល់៖ ព័ត៌មានលំអិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាមួយឧបសម្ព័ន្ធ។**

# ផ្នែកទី ៤

# ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- ព័ត៌មានអំពីមូលបត្រ

ឈ្មោះមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”
និមិត្តសញ្ញាមូលបត្រកម្មសិទ្ធ : PAS (កសស)
ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”
តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ១.០០០ រៀល
ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិសទ្ធិ : ៥.០៤០ រៀល (១,២៥៩ ដុល្លារអាមេរិក)
បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សា: ២១.៤៤២.៩៩២ មូលបត្រ
មូលធនូបនីយកម្មទីផ្សា : ១០៨.០៧២.៦៧៩.៦៨០ រៀល (២៦.៩៩១.១៧៩ ដុល្លារអាមេរិក)
ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : ផ្សារមូលបត្រកម្ពុជា
កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ : ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបរមា | ១៣.៣៦០ | ១៤.១០០ | ១៤.៣០០ | ១៤.១០០ | ១៤.៣២០ | ១៤.៥០០ | ១៣.៨៦០ | ១៣.៦៨០ | ១៣.២៨០ | ១៣.០០០ | ១៣.២៤០ | ១៣.៣២០ |
| | អប្បបរមា | ១៣.២៨០ | ១៣.២៨០ | ១៣.៧៦០ | ១៣.៨៤០ | ១៣.៨៨០ | ១៣.៨០០ | ១៣.៦៨០ | ១៣.១៨០ | ១២.៨០០ | ១២.៨០០ | ១២.៩៨០ | ១២.៩២០ |
| | មធ្យម | ១៣.៣១៧ | ១៣.៥៦០ | ១៤.០៣២ | ១៣.៩៤៥ | ១៤.០៣៨ | ១៤.២២៤ | ១៣.៧៧៣ | ១៣.៣៦១ | ១៣.១២០ | ១២.៩០២ | ១៣.១២៩ | ១៣.១០៤ |
| បរិមាណជួញដូរ (ភាគហ៊ុន) | អតិបរមា | ២.០៧០ | ៧.៣២០ | ១០.២៥០ | ៣.៥១១ | ៥.៣១២ | ២១.៧៩៥ | ៥.០៧៦ | ៧.០៤៧ | ១១.៨៥៣ | ៣.៨៤៤ | ១.៥៥៩ | ៤.៦២៧ |
| | អប្បបរមា | ៤៩ | ១៥៨ | ២១៧ | ៩៦ | ១០៧ | ២៣៩ | ៩៤ | ៨៣ | ៧៧ | ១៣៨ | ១០៨ | ៣៦ |
| | មធ្យម | ៨២៨ | ២.៧៣៦ | ១.៩៤០ | ១.០៩៥ | ១.៨១០ | ៤.២៤៨ | ១.២៦៥ | ១.៣៥៤ | ១.៦៦២ | ១.០៨២ | ៧០៩ | ១.២២៩ |

## គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោត ចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៦៤.៣២៨.៩៧៥ | ៧៥,០០% |
| **សរុប** | | | **៦៤.៣២៨.៩៧៥** | **៧៥,០០%** |

## ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | KAMIGUMI CO., LTD | ជប៉ុន | ១១.១៥០.៣២៤ | ១៣,០០% |
| **សរុប** | | | **១១.១៥០.៣២៤** | **១៣,០០%** |

## ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ព្រឹត្តិការណ៍នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|
| ចំណេញសុទ្ធ | ៩៣.៧០៧.៣៩០.០០០ រៀល | ២៦.៦០៧.៥៩៤.០០០ រៀល | ៤៣.៤៦៣.៥០០.០០០ រៀល |
| ភាគលាភជាសាច់ប្រាក់សរុប | ១៦.១០៧.២៦៧.៩៦៨ រៀល | ១២.១៣៤.៦៤៩.២៧៦ រៀល | ១២.១៣៤.៦៤៩.២៧៦ រៀល |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | មិនមាន | មិនមាន | មិនមាន |
| ភាគលាភផ្សេងទៀត | មិនមាន | មិនមាន | មិនមាន |
| អនុបាតនៃការបែងចែកភាគលាភ (%) | ១៧,១៩% | ៤៥,៧៦% | ៣១,១២% |
| ទិន្នផលភាគលាភ(%) | ១០,០០% | ៨,០០% | ៨,០០% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៥០៤ រៀល | ៤០៣ រៀល | ៤០៣ រៀល |

# ផ្នែកទី ៥

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# ផ្នែក ក: ខ្លឹមសារសង្ខេប

## ១. សេចក្តីផ្តើម

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានធ្វើសវនកម្មលើសកម្មភាពគ្រប់គ្រងប្រតិបត្តិការ អនុលោមភាពនិងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលដំណើរការដោយ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ ២០២២ ដែលជាផ្នែកមួយនៃផែនការសកម្ម ភាពសវនកម្មឆ្នាំ២០២២ ក្នុងកម្មវិធីសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០២២-២០២៤ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។ របាយការណ៍នេះ ឆ្លុះបញ្ចាំងអំពីលទ្ធផលសវនកម្ម អនុសាសន៍របស់សវនករ និងវិធានការកែលម្អរបស់សវនដ្ឋាន ។

## ២. ហានិភ័យគន្លឹះ

**ជាទូទៅហានិភ័យរួមមាន៖**

- ហានិភ័យប្រតិបត្តិការ : ជាហានិភ័យលើការបាត់បង់ ដែលជាលទ្ធផលបរាជ័យនៃដំណើរការអនុវត្តរបស់មនុស្ស និងប្រព័ន្ធគ្រប់គ្រង ឬ ពីហេតុការណ៍ខាងក្រៅ;
- ហានិភ័យហិរញ្ញវត្ថុ : ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងមិនត្រឹមត្រូវធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប
- ហានិភ័យអនុលោមភាព : ជាលទ្ធភាពដែលសកម្មភាពអនុវត្ត មិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ដោយឡែក ការធ្វើសវនកម្មនៅតាមសវនដ្ឋានខាងលើ សវនករបានកំណត់ហានិភ័យគន្លឹះមួយចំនួនដូចខាងក្រោម៖

- លទ្ធភាពប៉ះពាល់លើគុណភាពនៃការផ្តល់សេវាកម្មសាធារណៈ;
- លទ្ធភាពប៉ះពាល់ដល់ការគ្រប់គ្រងបុគ្គលិក វិន័យ និងប្រសិទ្ធភាពការងារ;
- លទ្ធភាពប៉ះពាល់ដល់អនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន; និង
- លទ្ធភាពប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

## ៣. វិសាលភាពសវនកម្ម

ដំណើរការសវនកម្មនេះ គ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងកិច្ចប្រតិបត្តិការដែលបានអនុវត្តដោយនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ ២០២២។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើសវនកម្មត្រូវបានធ្វើឡើងនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសស។ ក្រុមការងារសវនកម្មនឹងរាយការណ៍តែអំពីចំណុចខ្វះខាត និងចំណុចដែលត្រូវផ្តល់អនុសាសន៍កែលម្អប៉ុណ្ណោះ ។

របាយការណ៍សវនកម្មជាភាសាអង់គ្លេស ត្រូវបានរៀបចំឡើងពីរបាយការណ៍សវនកម្មជាភាសាខ្មែរ។ ក្នុងករណីមានភាពខុសប្លែកគ្នារវាងភាសាទាំងពីរ របាយការណ៍សវនកម្មជាភាសាខ្មែរ ត្រូវមានអាទិភាពក្នុងការបកស្រាយ។

## ៤. គោលបំណងសវនកម្ម

គោលបំណងក្នុងការធ្វើសវនកម្មនេះ គឺដើម្បីវាយតម្លៃនិងធ្វើឱ្យប្រសើរឡើង នូវប្រសិទ្ធភាពនៃដំណើរការគ្រប់ គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អក្នុងទីសវនកម្ម ដែលស្ថិតក្នុងវិសាលភាពសវនកម្ម ។

ជាទូទៅ ការងារសវនកម្មផ្តោតសំខាន់លើការបញ្ជាក់ថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្តល់នូវការធានាសមហេតុផលដើម្បីសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- គោលបំណងប្រតិបត្តិការ : ការសម្រេចបានប្រកបដោយប្រសិទ្ធភាព នូវគោលបំណងប្រតិបត្តិការការងារជាក់ស្តែង;
- គោលបំណងព័ត៌មានហិរញ្ញវត្ថុ : ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ;
- គោលបំណងអនុលោមភាព : ការអនុលោមតាមច្បាប់ គោលការណ៍ និងនីតិវិធីជាធរមាន។

ក្នុងការធ្វើសវនកម្មនេះ សវនករបានកំណត់គោលបំណងសវនកម្មសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ពង្រឹងអនុលោមភាព ប្រសិទ្ធភាពអនុវត្ត និងប្រសិទ្ធផលការងារ;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង ប្រើប្រាស់និងថែរក្សាមធ្យោបាយ សម្ភារ ឧបករណ៍;
- ពង្រឹងប្រសិទ្ធភាពអនុវត្ត ជំនាញបច្ចេកទេស ថែទាំ-ជួសជុល គ្រឿងចក្រ;
- ពង្រឹងប្រសិទ្ធភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យា និងការផ្សព្វផ្សាយព័ត៌មាននៅក្នុងគេហទំព័រ;
- ពង្រឹងប្រសិទ្ធិភាពប្រតិបត្តិការអាជីវកម្ម-សេវាកម្ម ការថែទាំបរិស្ថាន និងទ្រព្យសម្បត្តិនៅក្នុង តសព;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង ថែទាំម៉ាស៊ីនភ្លើង;
- ពង្រឹងអនុលោមភាព និងប្រសិទ្ធភាពអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ កសស;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងបំណុល និងចំណូលអាជីវកម្មរបស់ កសស; និង
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្មផ្តោតសំខាន់លើដំណើរការមានហានិភ័យ ដែលត្រូវបានប្រើប្រាស់ក្នុងការងារសវនកម្មនេះ ។ អភិក្រមសវនកម្មរាប់បញ្ចូល៖

- ការកត់ត្រាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង តាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធ និងការសម្ភាសន៍មន្ត្រី;
- ការកំណត់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងគន្លឹះ និងប្រៀបធៀបជាមួយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលបានរំពឹងទុក;
- ការធ្វើតេស្តសវនកម្មអំពីប្រសិទ្ធភាពប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ។

តាមរយៈនេះ ក្រុមការងារសវនកម្មបានសហការជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាន ដើម្បីកំណត់ការរំពឹងទុក។

## ៦. សង្ខេបលទ្ធផលគន្លឹះ

**ក្រុមការងារសវនកម្ម បានសង្កេតឃើញចំណុចខ្វះចន្លោះមួយចំនួន តាមរយៈការពិនិត្យ៖**

១. របាយការណ៍វឌ្ឍនភាពការងារក្នុងត្រីមាសទី ១ ឆ្នាំ ២០២២;

២. ទំនិញស្តុកទុករយៈពេលយូរនៅក្នុងឃ្លាំងលេខ ៤ នៃ កសស;
៣. របាយការណ៍ចំណាយប្រេងឥន្ធនៈសម្រាប់មធ្យោបាយលើកដាក់;
៤. បញ្ជីសារពើភណ្ឌរថយន្ត និងគ្រឿងចក្រ;
៥. ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងឃ្លាំងលេខ ៣ និងឃ្លាំងលេខ ៥ នៃ កសស;
៦. មធ្យោបាយដើងទឹក (នាវាសណ្តោង);
៧. របាំងការពារនាវា (Fenders);
៨. របាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានសំណង់-វិស្វកម្ម;
៩. តារាងរថយន្តនិងគ្រឿងចក្រ នៃផ្នែកគ្រឿងចក្រសំណង់;
១០. របាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានបច្ចេកទេស-សម្ភារ;
១១. វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស ថែទាំ-ជួសជុល គ្រឿងចក្រ;
១២. របាយការណ៍សម្ភាសន៍តំណាងក្រុមហ៊ុនដឹកជញ្ជូនដោយនាវា (Shipping Lines) ក្រុមហ៊ុនផែស្ងួត សមាគមភស្តុភារកម្ពុជា និងសមាគមកម្ពុជាដឹកជញ្ជូនដោយរថយន្ត អំពីសេវាប្រតិបត្តិការ និងការនាំចូល-ចេញតាមច្រកទ្វារ កសស;
១៣. ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារ ២០២៣-២០២៥;
១៤. បច្ចុប្បន្នភាពនៃគេហទំព័ររបស់ កសស;
១៥. កម្មវិធី Mobile App (Mobile Application Program) របស់ កសស;
១៦. របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ក្នុងត្រីមាសទី ៣ ឆ្នាំ ២០២២ នៅ តសព នៃ កសស;
១៧. ស្ថានភាពបរិស្ថាននៅជុំវិញបរិវេណអាគារ Service Apartment និងអន្តេវាសិកដ្ឋាន (Dormitory);
១៨. វគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញបើកបរគ្រឿងចក្រ;
១៩. របាយការណ៍ម៉ាស៊ីនភ្លើងនិងការថែទាំ;
២០. ការគោរពគោលការណ៍វិន័យ និងពេលវេលាធ្វើការរបស់និយោជិត កម្មករ កសស ដែលបម្រើការងារផ្នែកអាជីវកម្ម និងផ្នែកប្រយោល (នាយកដ្ឋាន);
២១. តារាងទូទាត់ប្រាក់បៀវត្សនិយោជិតក្នុងក្របខណ្ឌ កសស;
២២. ឯកសារដេញថ្លៃផ្គត់ផ្គង់ទំនិញ សម្រាប់ឆមាសទី១ ឆ្នាំ២០២២;
២៣. របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២;
២៤. របាយការណ៍ស្ថានភាពបំណុលអតិថិជនជំពាក់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ; និង
២៥. តារាងសរុបសារពើភណ្ឌអចលនទ្រព្យឆ្នាំ២០២២ ។

## ៧. សេចក្តីសន្និដ្ឋានរួម

ផ្អែកតាមលទ្ធផលសវនកម្មសម្រាប់ការិយបរិច្ឆេទ ២០២២ នៅ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាលនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ក្រុមការងារសវនកម្មបានពិនិត្យឃើញថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយចំនួនត្រូវបានរៀបចំបានល្អប្រសើរ និងមានកិច្ចសហការពីមន្ត្រី បុគ្គលិក កម្មករ គ្រប់ជាន់ថ្នាក់ ទោះបីជាការអនុវត្តមួយចំនួននៅមិនទាន់បានពេញលេញ និងគ្រប់ជ្រុងជ្រោយដើម្បីធានាបាន នូវប្រសិទ្ធភាពនៃ

ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនៅពេលអនាគតក៏ដោយ ។ ក្រុមការងារសវនកម្មបានកត់សម្គាល់ឃើញថា ចំណុចខ្វះខាតខាងលើពាក់ព័ន្ធនឹងអនុលោមភាពតាមច្បាប់ ប្រសិទ្ធភាពអនុវត្ត និងប្រសិទ្ធផលនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើការពង្រឹងនិងកែលម្អជាបន្តបន្ទាប់ ។

## ៨. វិធានការកែលម្អ

អនុសាសន៍ដែលបានផ្ដល់ជូន ក្នុងគោលបំណងដើម្បីធ្វើឱ្យល្អប្រសើរឡើង នូវការអនុវត្តដំណើរការធុរកិច្ចនិងការគ្រប់គ្រងរបស់សវនដ្ឋាន ត្រូវបានបញ្ចូលក្នុងលទ្ធផលលម្អិត (ផ្នែក ខ)។ អនុសាសន៍អំពីការខ្វះចន្លោះមួយចំនួនត្រូវបានឯកភាព ជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាននីមួយៗជាលាយលក្ខណ៍អក្សរ។ លទ្ធផលលម្អិត (ផ្នែក ខ) ក៏បានរំលេចអំពីការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងសវនដ្ឋាន ចំពោះអនុសាសន៍របស់សវនករ និងចំណុចខ្វះខាតផងដែរ។

វិធានការរបស់ថ្នាក់ដឹកនាំសវនដ្ឋាន ត្រូវបានរំលេចនៅក្នុងផែនការកែលម្អដូចមានចែងនៅក្នុង ឧបសម្ព័ន្ធទី២ ដែលបានភ្ជាប់មកជាមួយ ។

## ៩. អំណរគុណ

ក្រុមការងារសវនកម្មដែលដឹកនាំដោយលោក **ម៉ែន ចាន់** សូមថ្លែងអំណរគុណចំពោះលោកនាយក លោកស្រីនាយិកាគ្រប់នាយកដ្ឋានរួមមាន នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ដាលជាននិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ព្រមទាំងសហការីដែលបានសហការផ្ដល់ព័ត៌មាន ឯកសារនិងមតិយោបល់ដ៏មានតម្លៃដើម្បីជួយជំរុញឱ្យការងារសវនកម្មនេះអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក ។

# ផ្នែក ខៈ លទ្ធផលសវនកម្មលម្អិត

## ១. សមាសភាពចូលរួម និងខណៈគោល

### ១.១ សមាសភាពក្រុមការងារសវនកម្មផ្ទៃក្នុង

| | | |
|---|---|---|
| - លោក ម៉ែន ចាន់ | នាយក | ប្រធានក្រុម |
| - លោក ជីវ ច័ន្ទសុភាព | នាយករង | អនុប្រធាន |
| - លោក ហោ សុជី | នាយករង | អនុប្រធាន |
| - លោក មាស សុវណ្ណា | ប្រធានការិយាល័យ | សមាជិក |
| - លោក ជីវ ច័ន្ទសុធា | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី ទូច វណ្ណា | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី រ័ត្ន និមល | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី ខន សុខុម | បុគ្គលិក | សមាជិក |
| - លោកស្រី ឈុន ហឿនរីណា | បុគ្គលិក | សមាជិក |
| - លោក ភាព ម៉េងស្រៀន | បុគ្គលិក | សមាជិក |
| - លោកស្រី តេង សុវណ្ណស្រីរ័ត្ន | បុគ្គលិក | សមាជិក |

## ១.២ សមាសភាពរួមសវនដ្ឋាន

### ១.២.១ នាយកដ្ឋានអាជីវកម្ម

- លោក ងួន រតនា — នាយក — សវនដ្ឋាន
- លោក ស៊ូ ឡុងស៊្រីន — នាយករង — សវនដ្ឋាន

### ១.២.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ

- លោក ថៃ ម៉េងលី — នាយក — សវនដ្ឋាន
- លោក ហ៊ាង សុផល — នាយករង — សវនដ្ឋាន
- លោក សេក សុវណ្ណារ៉ា — នាយករង — សវនដ្ឋាន

### ១.២.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ

- លោក លូ លីខេង — នាយក — សវនដ្ឋាន
- លោក អ៊ុក សុវណ្ណារិទ្ធ — នាយករង — សវនដ្ឋាន
- លោក យឹង កុយ — នាយករង — សវនដ្ឋាន

### ១.២.៤ នាយកដ្ឋាននាវាចរ-កណ្ណធារនិងសន្តិសុខ

- លោក ស៊ឹង សេណូ — នាយក — សវនដ្ឋាន
- លោក ចាន់ សុខា — នាយករង — សវនដ្ឋាន
- លោក សែន សុថា — នាយករង — សវនដ្ឋាន

### ១.២.៥ នាយកដ្ឋានសំណង់ - វិស្វកម្ម

- លោក មាន គឹង — នាយក — សវនដ្ឋាន
- លោក ងឹម ញ៉ — នាយករង — សវនដ្ឋាន
- លោក ឈឹម ហ៊ រ — នាយករង — សវនដ្ឋាន

### ១.២.៦ នាយកដ្ឋានបច្ចេកទេស-សម្ភារ

- លោក អ៊ុក វណ្ណារ៉ា — នាយក — សវនដ្ឋាន
- លោកស្រី សរ ម៉ាលីន — នាយិការង — សវនដ្ឋាន

### ១.២.៧ នាយកដ្ឋានទីផ្សារ

- លោកស្រី ជ័យ សុគន្ធា — នាយិកា — សវនដ្ឋាន
- លោក ម៉ៅ សាម៉ន — ប្រធានការិយាល័យ — សវនដ្ឋាន
- លោក យិន វី — ប្រធានការិយាល័យ — សវនដ្ឋាន

### ១.២.៨ នាយកដ្ឋានព័ត៌មានវិទ្យា

- លោក សោម ករុណី — នាយក — សវនដ្ឋាន
- លោក ស្រ៊ន់ ពិសី — បុគ្គលិក — សវនដ្ឋាន

### ១.២.៩ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស

| | | |
|---|---|---|
| - លោក ជីវ ច័ន្ទសុផល | នាយក | សវនដ្ឋាន |
| - លោក ហេង សុខសាន្ត | នាយករង | សវនដ្ឋាន |
| - លោក ហាក់ ណារិទ្ធ | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.១០ នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី

| | | |
|---|---|---|
| - លោក គឹម ហោ | នាយក | សវនដ្ឋាន |
| - លោក យ៉ែម សល់ | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

| | | |
|---|---|---|
| - លោក វ័ន្ត សិលា | នាយក | សវនដ្ឋាន |
| - លោក សាន ឈន់ | នាយករង | សវនដ្ឋាន |

### ១.២.១២ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ

| | | |
|---|---|---|
| - លោក សូ សៀង | នាយក | សវនដ្ឋាន |
| - លោក អ៊ុក សុមេធី | នាយករង | សវនដ្ឋាន |
| - លោក ខឹម ស៊ីថា | នាយករង | សវនដ្ឋាន |

### ១.២.១៣ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

| | | |
|---|---|---|
| - លោក ពិត ប្រាកដ | នាយក | សវនដ្ឋាន |
| - លោក សម សុភាព | នាយករង | សវនដ្ឋាន |
| - លោក អ៊ូ សុវណ្ណឫទ្ធិ | នាយករង | សវនដ្ឋាន |
| - លោក សែម សុភា | នាយករង | សវនដ្ឋាន |

## ១.៣ ខណៈគោល

**ខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្ម៖**

| | |
|---|---|
| ➢ សេចក្តីព្រាងលើកទី ១ បានបញ្ចប់ | ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២៣ |
| ➢ ការធ្វើសវនកម្មបានបញ្ចប់ | ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៣ |
| ➢ ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំសវនដ្ឋាន | ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២៣ |
| ➢ របាយការណ៍ស្ថាពរ | ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៣ |

## ២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុង គឺដើម្បីជួយថ្នាក់ដឹកនាំសវនដ្ឋាន ក្នុងដំណើរការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុងនិងអភិបាលកិច្ចល្អ។ ការគ្រប់គ្រងផ្ទៃក្នុងត្រូវបានអនុវត្ត ដោយថ្នាក់ដឹកនាំសវនដ្ឋាននិងមន្ត្រីមួយចំនួនទៀត ដើម្បីជានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- ➢ ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ
- ➢ របាយការណ៍ហិរញ្ញវត្ថុដែលអាចទុកចិត្តបាន
- ➢ អនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន ។

ការធ្វើសវនកម្មនេះ ក៏ពិនិត្យលើការរៀបចំនិងប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផងដែរ ។

## ៣. ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

ក្រុមការងារសវនកម្ម បានវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដោយផ្អែកលើសមត្ថភាពនៃដំណើរការគ្រប់គ្រងដើម្បីសម្រេចលក្ខណៈវិនិច្ឆ័យគ្រប់ចំនួន ៧ រួមមាន៖ ការផ្តល់សិទ្ធិ ភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព ការការពារសុវត្ថិភាពនិងសន្តិសុខរូបវន្ត ព្រមទាំងការដោះស្រាយកំហុសឆ្គងនិងការបែងចែកការងារ ស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ចរបស់ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តូជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ។

## ៤. ព័ត៌មានអំពីសវនដ្ឋាន

នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តូជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ស្ថិតក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយអនុលោមតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតនិងការប្រព្រឹត្តិទៅនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) និងដំណើរការតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងតួនាទី-ភារកិច្ចសម្រាប់នាយកដ្ឋាននីមួយៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់ កសស ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ និងសេចក្តីសម្រេចកែសម្រួលរចនាសម្ព័ន្ធ និងការបំពេញបន្ថែមតួនាទី-ភារកិច្ច ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២០ ។

### ៤.១ នាយកដ្ឋានអាជីវកម្ម (អជក)

នាយកដ្ឋានអាជីវកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៤ នាក់ ក្នុងនេះមានស្ត្រី ០៣ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប និងប្រធានការិយាល័យ ០៦ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦៤ សសរ/កសស/អជក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ប្រតិបត្តិការ និងកិច្ចសន្យា;
(២) ការិយាល័យ អាជីវកម្ម និងសរុបរបាយការណ៍;
(៣) ការិយាល័យ ទំនាក់ទំនង និងគ្រប់គ្រងការដឹកជញ្ជូន;
(៤) ការិយាល័យ ប្រព័ន្ធព័ត៌មានវិទ្យា;
(៥) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍; និង
(៦) ការិយាល័យ តំណាង កសស ប្រចាំភ្នំពេញ ។

### ៤.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ (ប្រទក)

នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកកម្មករសរុបចំនួន ៥១១ នាក់ ក្នុងនេះមានស្ត្រី ៣៩ នាក់ បុគ្គលិកជាប់កិច្ចសន្យា ២១២ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៨ រូបជាជំនួយការស្របតាមតួនាទី-

ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៨ សសរ/កសស/ប្រទក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ទិន្នន័យ និងរបាយការណ៍;
(២) ការិយាល័យ ផែនការនាវា;
(៣) ការិយាល័យ ផែនការទីលាន;
(៤) ការិយាល័យ ប្រតិបត្តិការ;
(៥) ការិយាល័យ គ្រប់គ្រងបុគ្គលិក;
(៦) ការិយាល័យ គ្រឿងចក្រ;
(៧) ការិយាល័យ ទីលានសំបកកុងតែន័រ (ECD); និង
(៨) ការិយាល័យឃ្លាំង (LCL) ។

## ៤.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ (ប្រទទ)

នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ២៣២ នាក់ ក្នុងនេះមានស្ត្រី ១០ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៦៥ នាក់ និងបុគ្គលិកជួល ៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៦ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៩ សសរ/ កសស/ប្រទទ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍ និងគ្រប់គ្រងសុវត្ថិភាព;
(២) ការិយាល័យ គ្រប់គ្រង ឃ្លាំង-ទីលានទំនិញទូទៅ;
(៣) ការិយាល័យ កត់ត្រា-ជញ្ជីង និងគ្រប់គ្រងព័ត៌មាននាវា;
(៤) ការិយាល័យ គ្រប់គ្រងឯកសារ និងរបាយការណ៍;
(៥) ការិយាល័យ គ្រឿងចក្រទំនិញទូទៅ; និង
(៦) ការិយាល័យ លើកដាក់ទំនិញ ។

## ៤.៤ នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ (នចកឆ)

នាយកដ្ឋាននាវាចរ-កណ្ណជារនិងសន្តិសុខ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិក កម្មករ សរុបចំនួន ១៣៣ នាក់ ក្នុងនេះមានស្ត្រី ០២ នាក់ បុគ្គលិកជាប់កិច្ចសន្យា ១៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៥ រូប និងប្រធានការិយាល័យ ១០ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦០ សសរ/កសស/នវកជ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ កណ្ណជារ;
(២) ការិយាល័យ ទិន្នន័យ និងសរុប;
(៣) ការិយាល័យ នាវាចរ;
(៤) ការិយាល័យ VTMS និង បណ្តុះបណ្តាល;
(៥) ការិយាល័យ ទំនាក់ទំនងសាធារណៈ ស្រាវជ្រាវ និងអភិវឌ្ឍន៍;
(៦) ការិយាល័យ គ្រប់គ្រងមធ្យោបាយជើងទឹក;
(៧) ការិយាល័យ គ្រប់គ្រងអាងនាវាសណ្តោង;

(៨) ការិយាល័យ សន្តិសុខ និងសុវត្ថិភាព; និង

(៩) ការិយាល័យ រៀបចំសណ្តាប់ធ្នាប់សាធារណៈ ។

## ៤.៥ នាយកដ្ឋានសំណង់-វិស្វកម្ម (សណវក)

នាយកដ្ឋានសំណង់-វិស្វកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិក កម្មករសរុប ចំនួន ១១៥ នាក់ ក្នុងនេះមានស្ត្រី ០២ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៤៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៥ រូប និងប្រធានការិយាល័យ ១២ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០២៤ សសរ/កសស/សណវក ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២០៖

(១) ការិយាល័យ សំណង់-ជួសជុល និងថែទាំ;

(២) ការិយាល័យ អគ្គិសនី;

(៣) ការិយាល័យ ស្ថាបត្យកម្ម និងសិក្សាគម្រោង;

(៤) ការិយាល័យ ឃ្លាំងសម្ភារសំណង់;

(៥) ការិយាល័យ គ្រប់គ្រងឯកសារលទ្ធកម្មសំណង់;

(៦) ការិយាល័យ វិស្វកម្ម;

(៧) ការិយាល័យ វាស់ស្ទង់;

(៨) ការិយាល័យ សរុបនិងរបាយការណ៍;

(៩) ការិយាល័យ គ្រឿងចក្រសំណង់;

(១០) ការិយាល័យ ឃ្លាំងប្រេង;

(១១) ការិយាល័យ អ៊ូនាវា; និង

(១២) ការិយាល័យ ពោងសញ្ញា ។

## ៤.៦ នាយកដ្ឋានបច្ចេកទេស-សម្ភារ (បទស)

នាយកដ្ឋានបច្ចេកទេស-សម្ភារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកកម្មករ សរុបចំនួន ៧៥ នាក់ ក្នុងនេះមានស្ត្រី ០៣ នាក់ បុគ្គលិកជាប់កិច្ចសន្យា ២២ នាក់ និងត្រូវបានដឹកនាំដោយ នាយក ០១ រូប អមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៩ រូបជាជំនួយការ៖

(១) ការិយាល័យ សម្ភារបច្ចេកទេស-បន្លាស់;

(២) ការិយាល័យ គ្រប់គ្រងឯកសារលទ្ធកម្ម;

(៣) ការិយាល័យ ឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់;

(៤) ការិយាល័យ ប្រេងឥន្ធនៈ-ប្រេងរំអិល;

(៥) ការិយាល័យ ស្រាវជ្រាវអភិវឌ្ឍន៍;

(៦) ការិយាល័យ ព័ត៌មានវិទ្យា;

(៧) ការិយាល័យ ជួសជុល-ថែទាំ មេកានិច គ្រឿងចក្រ;

(៨) ការិយាល័យ យានដ្ឋាន; និង

(៩) ការិយាល័យ យន្តសាស្ត្រ កប៉ាល់-នាវាសណ្តោង ។

### ៤.៧ នាយកដ្ឋានទីផ្សារ (ទផ)

នាយកដ្ឋានទីផ្សារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិក សរុបចំនួន ១០ នាក់ ក្នុងនេះមានស្ត្រី ០៣ នាក់ និងត្រូវបានដឹកនាំដោយនាយិកា ០១ រូប អមដោយប្រធានការិយាល័យ ០៣ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៧ សសរ/កសស/ទផ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវទីផ្សារ និងអភិវឌ្ឍគុណភាពសេវាកម្ម;
(២) ការិយាល័យ ព័ត៌មានទីផ្សារ;
(៣) ការិយាល័យ ទំនាក់ទំនងអតិថិជន; និង
(៤) ការិយាល័យ សម្របសម្រួល ។

### ៤.៨ នាយកដ្ឋានព័ត៌មានវិទ្យា (ពមវ)

នាយកដ្ឋានព័ត៌មានវិទ្យា នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៥ នាក់ ក្នុងនេះមានស្ត្រី ០១ នាក់ និងបុគ្គលិកស្ម័គ្រចិត្ត ០៣ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ១១៥ សសរ/កសស/ពម.វ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍ និងផ្សព្វផ្សាយ;
(២) ការិយាល័យ គ្រប់គ្រងបណ្តាញ; និង
(៣) ការិយាល័យ ប្រព័ន្ធព័ត៌មានវិទ្យា ។

### ៤.៩ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស (តសព)

នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ « មានមន្ត្រី បុគ្គលិក សរុបចំនួន ១០ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៣ រូប ជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ៣៩៧ សសរ/កសស/តសព ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០៖

(១) ការិយាល័យ រដ្ឋបាល និងព័ត៌មានវិទ្យា;
(២) ការិយាល័យ កស្តុការ និងស្រាវជ្រាវ-អភិវឌ្ឍន៍;
(៣) ការិយាល័យ សេវាអតិថិជន; និង
(៤) ការិយាល័យ ថែទាំ និងជួសជុល ។

### ៤.១០ នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី (គ្រចយអន)

នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ៦៧ នាក់ ក្នុងនេះមានស្ត្រី ០១ នាក់ បុគ្គលិកជួល ០១ នាក់ និងស្ម័គ្រចិត្ត ២០ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៤ រូបជាជំនួយការ៖

(១) ការិយាល័យ បច្ចេកទេសអគ្គិសនី;
(២) ការិយាល័យ រដ្ឋបាលសរុបរបាយការណ៍;
(៣) ការិយាល័យ ជួសជុលថែទាំគ្រឿងចក្រ; និង
(៤) ការិយាល័យ គ្រប់គ្រងស្ថានីយអគ្គិសនី ។

### ៤.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស (របធម)

នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ១០៨ នាក់ ក្នុងនេះមានស្ត្រី ៣២ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៥៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូបអមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៧ និងជំនួយការឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលឋានៈស្មើប្រធានការិយាល័យ ០១ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៥៩ សសរ/កសស/រប.ប ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យរដ្ឋបាលនិងកិច្ចការទូទៅ;
(២) ការិយាល័យថែទាំនិងជួសជុល;
(៣) ការិយាល័យគ្រប់គ្រងឃ្លាំង សម្ភាររដ្ឋបាល;
(៤) ការិយាល័យពិធីការ;
(៥) ការិយាល័យថែទាំសុខភាព;
(៦) ការិយល័យព័ត៌មានវិទ្យា;
(៧) ការិយាល័យធនធានមនុស្ស និងស្រាវជ្រាវ-អភិវឌ្ឍន៍;
(៨) ការិយាល័យគ្រប់គ្រងមធ្យោបាយ និងប្រេងឥន្ធនៈ;
(៩) ការិយាល័យបរិស្ថាន និងអនាម័យ; និង
(១០) ការិយាល័យរបៀបនិងឯកសារ ។

### ៤.១២ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ (ផលស)

នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ១២ នាក់ ក្នុងនេះមានស្ត្រី ០៥ នាក់ បុគ្គលិកស្ម័គ្រចិត្ត ០១ រូប និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០២ រូប និងប្រធានការិយាល័យ ០៤ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៦ សសរ/កសស/ផលស ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យផែនការ-វិនិយោគ;
(២) ការិយាល័យលទ្ធកម្មសាធារណៈ;
(៣) ការិយាល័យស្ថិតិ; និង
(៤) ការិយាល័យគ្រប់គ្រងគម្រោង ។

### ៤.១៣ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ (គណហវ)

នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានមន្ត្រី បុគ្គលិកសរុបចំនួន ២០ នាក់ ក្នុងនេះមានស្ត្រី ០៥ នាក់ និងត្រូវបានដឹកនាំដោយនាយក ០១ រូប អមដោយនាយករង ០៣ រូប និងប្រធានការិយាល័យ ០៤ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦២ សសរ/កសស/គណ.ហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យបេឡា;
(២) ការិយាល័យគណនេយ្យ;
(៣) ការិយាល័យអចលនទ្រព្យ;
(៤) ការិយាល័យទីផ្សារមូលបត្រ;

(៥) ការិយាល័យហិរញ្ញកិច្ច;
(៦) ការិយាល័យគ្រប់គ្រងបំណុល;និង
(៧) ការិយាល័យទូទាត់ ។

# ៥. លទ្ធផលសវនកម្ម

## ៥.១ ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម របស់ កសស ក្នុងគោលបំណងដើម្បីផ្តល់សេវាកម្ម ជូនអតិថិជននិងអ្នកប្រើប្រាស់ផ្ទៃប្រកបដោយភាពរលូន និងឆាប់រហ័សនិងជួយជំរុញឱ្យសវនដ្ឋាននីមួយៗ អនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន ស្របតាមសេចក្តីកំណត់និងតម្រូវការរបស់អង្គភាព និងអនុលោមតាមលក្ខន្តិកៈបុគ្គលិករបស់ កសស ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ៥.២ លទ្ធផលនៃការអង្កេតវិជ្ជមាន

ក្រុមការងារសវនកម្មបានពិនិត្យឃើញថា នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាលជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ រួមទាំងការិយាល័យនិងផ្នែកពាក់ព័ន្ធ បាននិងកំពុងអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី-ភារកិច្ចដែល កសស បានកំណត់ និងបានយកចិត្តទុកដាក់អនុវត្តការងារ តាមមុខជំនាញរៀងៗខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសហការផ្តល់ឯកសារជូនសវនករ ដើម្បីជួយជំរុញឱ្យកិច្ចដំណើរការសវនកម្មផ្ទៃក្នុងរបស់ កសស អាចប្រព្រឹត្តទៅបាន ស្របតាមផែនការសកម្មភាពការងារសវនកម្ម និងប្រកបដោយភាពរលូន ។

## ៥.៣ លទ្ធផលនៃការអង្កេតអវិជ្ជមាន

### ៥.៣.១ នាយកដ្ឋានអាជីវកម្ម

#### ៥.៣.១.១ ការពិនិត្យរបាយការណ៍វឌ្ឍនភាពការងារក្នុងត្រីមាសទី ១ ឆ្នាំ ២០២២

តាមការឆ្លើយតប ក្នុងកម្រងសំណួរប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សវនករបានកត់សម្គាល់ឃើញថាក្នុងត្រីមាសទី ១ ឆ្នាំ ២០២២ នេះ ការិយាល័យអតិថិជននិងស្រាវជ្រាវ ដែលស្ថិតក្នុងក្របខ័ណ្ឌនាយកដ្ឋានអាជីវកម្ម នៅមិនទាន់បានរៀបចំធ្វើរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ០៦៤ សសរ/កសស/អជក ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន តួនាទីនិងភារកិច្ចរបស់បណ្តាការិយាល័យនៃនាយកដ្ឋានអាជីវកម្ម ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០ នៅឡើយ ។

ប្រការនេះ អាចបណ្តាលមកពីការិយាល័យអតិថិជន និងស្រាវជ្រាវ/សវនដ្ឋានពុំទាន់មានព័ត៌មានជាមូលដ្ឋានចាំបាច់ដើម្បីរៀបចំវឌ្ឍនភាពការងារ ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃការអនុវត្តតួនាទី-ភារកិច្ចរបស់សវនដ្ឋាន ជាពិសេសពាក់ព័ន្ធនឹងការងារអតិថិជននិងស្រាវជ្រាវ ។

ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តតួនាទី-ភារកិច្ចឱ្យកាន់តែល្អប្រសើរឡើងថែមទៀត សវនករយល់ឃើញថាសវនដ្ឋានគួរជម្រុញ ឱ្យការិយាល័យអភិវឌ្ឍនិងស្រាវជ្រាវធ្វើការសិក្សា ខិតខំស្រាវជ្រាវនិងប្រមូលព័ត៌មានសំខាន់ៗ ដើម្បីបានជាធាតុចូលសម្រាប់រៀបចំវឌ្ឍនភាពការងារនៅក្នុងសវនដ្ឋាន ក៏ដូចជាក្នុងក្របខ័ណ្ឌ កសស ទាំងមូល ។

*ចាប់តាំងពីមានការរាតត្បាតដោយជម្ងឺកូវីដ-១៩ មន្ត្រីទទួលបន្ទុកការងារផ្នែកអភិវឌ្ឍនិងស្រាវជ្រាវតែងតែជួបការលំបាកក្នុងការស្នើសុំជួប អ្នកតំណាងក្រុមហ៊ុននិងកំពង់ផែក្នុងស្រុកនានាដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រ និងគោលដៅអភិវឌ្ឍនៅពេលអនាគត ជាពិសេសគឺគោលនយោបាយតម្លៃ ។ ទោះជាយ៉ាងនេះក្តី សវនដ្ឋាននឹងបន្តខិតខំឱ្យអស់ពីសមត្ថភាព។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

## ៥.៣.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ

### ៥.៣.២.១. ការពិនិត្យទំនិញស្តុកទុករយៈពេលយូរនៅក្នុងឃ្លាំងលេខ ៤ នៃ កសស

យោងតាមរបាយការណ៍សន្និធិរបស់ឃ្លាំងលេខ ៤ គិតត្រឹមថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ សវនករបានពិនិត្យឃើញសន្និធិចម្រុះក្នុងឃ្លាំង តាំងពីអំឡុងឆ្នាំ ១៩៩១, ១៩៩២, ១៩៩៧ ដល់បច្ចុប្បន្នមានចំនួន ៩,៤៥១ ដុំ ស្មើនឹង ៣២១,០៩៦ តោន ហើយរហូតដល់ត្រីមាសទី ១ ឆ្នាំ ២០២២ នេះ នៅពុំទាន់មានក្រុមហ៊ុន/តំណាងម្ចាស់ទំនិញណាមួយ ស្នើសុំសមត្ថកិច្ចពាក់ព័ន្ធដើម្បីបញ្ចេញទំនិញទាំងនេះពីឃ្លាំងនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមច្បាប់និងបទប្បញ្ញត្តិគយ បោះពុម្ពលើកទី ៣ ចុះខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងជំពូកទី ៩ មាត្រា ៥៤ ស្តីពីទំនិញគ្មានការទាមទារ ដូចមានចែងក្នុងចំណុចៈ ក) ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬ នៅក្នុងកណ្តាគារគយមានដែនកំណត់ ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃច្បាប់នេះ ខ) ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្យជនបដិសេធមិនទទួលយក ឬ គម្យជនពុំត្រូវបានរកឃើញ និងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន គ) ទំនិញនិងមធ្យោបាយដឹកជញ្ជូនពុំជាប់អាយ័តដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ស្របតាមបញ្ញត្តិមាត្រា ៥៥ នៃច្បាប់ស្តីពីគយ កាលណាពុំមានការទាមទារក្នុងរយៈពេលហុកសិប (៦០) ថ្ងៃគិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង ។ ក្នុងករណីពុំអាចរកម្ចាស់ឃើញ ប្រវេសន៍សាធារណៈត្រូវធ្វើតាមពេល និងរបៀបដែលនឹងកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃគិតចាប់ពីថ្ងៃចេញប្រវេសន៍ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ស្របតាមបញ្ញត្តិនៃមាត្រា ៥៥ នៃច្បាប់ស្តីពីគយ ។

មូលហេតុខាងលើ អាចបណ្តាលមកពីភាពខ្វះចន្លោះ ឬ មានការពន្យាពេលក្នុងការរៀបចំបែបបទស្នើសុំបញ្ចេញទំនិញដោយក្រុមហ៊ុន ឬ ភាគីតំណាងម្ចាស់ទំនិញ ។

ប្រការនេះអាចបណ្តាលឱ្យខ្វះទីធ្លាស្តុកទំនិញ ខាតបង់ថ្លៃស្តុក និងប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃ្លាំងជារួម ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការជាមួយក្រុមហ៊ុន ឬ តំណាងម្ចាស់ទំនិញជាទៀងទាត់និងរាយការណ៍ជូនថ្នាក់ដឹកនាំ កសស ឱ្យបានឆាប់ ដើម្បីស្នើសុំស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជួយអន្តរាគមន៍ក្នុងការបញ្ចេញទំនិញឱ្យបានសមស្របតាមច្បាប់និងបទប្បញ្ញត្តិគយ ដូចបានរៀបរាប់ខាងលើ ។

*នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នឹងធ្វើបច្ចុប្បន្នភាពទំនិញដែលស្តុកយូរតាមមុខទំនិញនីមួយៗ ហើយរាយការណ៍ជូនថ្នាក់ដឹកនាំ កសស ដើម្បីជំរុញខាងសមត្ថកិច្ចគយ ដើម្បីយកទំនិញស្តុកយូរទាំងនេះចេញពីឃ្លាំងលេខ ៤ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

**៥.៣.២.២. ការពិនិត្យរបាយការណ៍ចំណាយប្រេងឥន្ធនៈ លើមធ្យោបាយលើកដាក់**

យោងតាមរបាយការណ៍ចំណាយប្រេងឥន្ធនៈលើមធ្យោបាយលើកដាក់ សវនករបានពិនិត្យឃើញ៖ ១) មធ្យោបាយលើកដាក់-RTG លេខសម្គាល់ 213, 214 ផលិតឆ្នាំ 2017 និង RTG ម៉ាក ZPMC លេខសម្គាល់ 217, 218 ផលិតឆ្នាំ 2018, ២) មធ្យោបាយលើកដាក់-RTG ម៉ាក ZPMC លេខសម្គាល់ 215, 216 ផលិតឆ្នាំ 2017, ៣) STACKER ម៉ាក KALMAR លេខសម្គាល់ 111, 112, 113, 114 ផលិតឆ្នាំ 2019 កំពុងប្រើប្រាស់ប្រេងឥន្ធនៈក្នុងកម្រិត៖ 2.04 L/Box, 1.87 L/Box, និង 1.21 L/Box ជាដំណាក់កាលសាកល្បង ។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមសេចក្តីកំណត់លេខ ០០៨ សកណ/កសស/រប.ធម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលការកំណត់បទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់រថយន្តដឹកកុងតែន័រ រថយន្តដឹកទំនិញ និងតារាងសរុបឧបសម្ព័ន្ធទី ២ ស្តីពីការកំណត់បទដ្ឋានផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់មធ្យោបាយលើកដាក់ និងគ្រឿងចក្រនៅឡើយ ។

មូលហេតុខាងលើ អាចបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ ក្នុងការរៀបចំបែបបទស្នើសុំ ការកំណត់បទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈ ពីគណៈកម្មការកំណត់បទដ្ឋានប្រេងឥន្ធនៈរបស់ កសស។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ កសស ។

ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ កសស ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួរណែនាំឱ្យមន្ត្រីទទួលបន្ទុកការងារផ្ទាល់ពិនិត្យគ្រឿងចក្រចាស់និងថ្មី រួមទាំងមធ្យោបាយលើកដាក់ដែលមិនទាន់មានបទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈឱ្យបានច្បាស់លាស់ និងរៀបចំស្នើសុំបទដ្ឋានប្រើប្រាស់ពីគណៈកម្មការកំណត់បទដ្ឋានប្រេងឥន្ធនៈរបស់ កសស ឱ្យបានសមស្របតាមសេចក្តីកំណត់ខាងលើ ។

*នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ ស្នើសុំឱ្យធ្វើបទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់បណ្តាគ្រឿងចក្រ បម្រើការក្នុងនាយកដ្ឋានឡើងវិញ ទាំងបណ្តាគ្រឿងចក្រចាស់ៗ និងគ្រឿងចក្រ ដែលមិនទាន់មានបទដ្ឋានប្រើប្រាស់ប្រេង ព្រោះស្ថានភាពគ្រឿងចក្រមួយ ចំនួនមានសភាពចាស់ទ្រុឌទ្រោម និងស្ថានភាពប្រតិបត្តិការលើកដាក់កុងតែន័រ មានការកកស្ទះជាងពេលមុន ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

## ៥.៣.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ

**៥.៣.៣.១ ការពិនិត្យបញ្ជីសារពើភណ្ឌរថយន្ត និងគ្រឿងចក្រ**

ក្នុងចំណោមរថយន្ត និងគ្រឿងចក្រសរុបចំនួន ៣៣ គ្រឿង (រថយន្តស្ទូច ០៨ គ្រឿង H.M.C ០២ គ្រឿង រថយន្តដឹក ១៧ គ្រឿង និងរថចូក ០៦ គ្រឿង) និងរ៉ឺម៉ក ២៤ គ្រឿងដែលត្រូវបានគ្រប់ គ្រងនិងប្រើប្រាស់ ដើម្បីបម្រើប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ កសស ដោយនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ សវនករបានពិនិត្យឃើញរថយន្តស្ទូច ១ គ្រឿង រថយន្តដឹក ២ គ្រឿង និងរ៉ឺម៉ក ៥ គ្រឿងមានលក្ខណៈចាស់ទ្រុឌទ្រោម ត្រូវបានខូច និងរក្សាទុករយៈពេលយូរ៖

- រថយន្តស្ទូច M.H.C 301 ផលិតឆ្នាំ 2001 ខូចថ្ងៃទី 10/05/2014
- រថយន្ត KAMAZ លេខ 1684 ផលិតឆ្នាំ 2002 ខូចថ្ងៃទី 28/11/2019
- រថយន្ត KAMAZ លេខ 1686 ផលិតឆ្នាំ 2002 ខូចថ្ងៃទី 23/03/2021
- រ៉ឺម៉កលេខ 4085 ផលិតឆ្នាំ 1986 ខូចថ្ងៃទី 01/01/2010
- រ៉ឺម៉កលេខ 4088 ផលិតឆ្នាំ 1986 ខូចថ្ងៃទី 01/01/2010
- រ៉ឺម៉កលេខ 4089 ផលិតឆ្នាំ 1986 ខូចថ្ងៃទី 01/01/2010
- រ៉ឺម៉កលេខ 4119 ផលិតឆ្នាំ 2002 ខូចថ្ងៃទី 17/03/2017
- រ៉ឺម៉កលេខ 4095 ផលិតឆ្នាំ 2002 ខូចថ្ងៃទី 17/03/2017

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ កសស ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាត ថែរក្សានិងទុកដាក់ឱ្យបានគង់វង្ស និងចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍ សម្ភារការងារពេញលេញនៅឡើយ ។

មូលហេតុនេះ អាចកើតមានឡើងដោយសារភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ក្នុងការធ្វើរបាយការណ៍ អំពីស្ថានភាពរថយន្តនិងគ្រឿងចក្រ ដែលមានលក្ខណៈចាស់ទ្រុឌទ្រោមនិងខូចជូនថ្នាក់ដឹកនាំសវនដ្ឋាន ដើម្បីពិនិត្យនិងស្នើសុំជួសជុលឱ្យបានឆាប់រហ័ស និងសមស្របតាមតម្រូវការរបស់ កសស ។

កត្តានេះ អាចប៉ះពាល់ដល់គុណភាព និងផលិតភាពនៃប្រតិបត្តិការអាជីវកម្ម សេវាកម្ម ក៏ដូចជាប្រសិទ្ធភាពនៃការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ កសស ។

សវនករយល់ឃើញថាថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំនិងចាត់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ឱ្យចុះពិនិត្យ និងធ្វើរបាយការណ៍ជាក់លាក់អំពីស្ថានភាព រថយន្ត គ្រឿងចក្រ និងរ៉ឺម៉កចាស់ៗដែលខូច និង/ឬ ប្រើប្រាស់លែងបាន ដើម្បីពិនិត្យនិងស្នើសុំថ្នាក់ដឹកនាំ កសស ជួសជុល ឬ ចាត់វិធានការតាមលក្ខណៈជាក់ស្តែង ។

*H.M.C 301៖*

- *គ្រឿងបន្លាស់ជាច្រើនអន្លើត្រូវបានដោះដូរជាមួយនឹង* H.M.C 302 *។*
- *ប្រព័ន្ធបញ្ជាភ្លើងខូច ។*
- *ជើងដំរីទាំងអស់មានស្នាមជ្រាបប្រេង ។*
- *កង់ទាំងអស់ អស់គុណភាពប្រើប្រាស់ ។*
- *ប្រព័ន្ធទុយោបូម អស់គុណភាព រួមទាំងប្រព័ន្ធបូមខ្លាញ់បាញ់ប្រេងគាំងដោយអន្លើ ។*
- *ម៉ាស៊ីនមិនដែលបានបញ្ឆេះ តាំងពីឆ្នាំ ២០១៣ មកម្លេះ ។*
- *យោងតាមការវាយតម្លៃរបស់លោក អ៊ុក វណ្ណារ៉ា និងលោក គឹម ហោ* H.M.C 301 *នេះ នៅអាចជួលជុលប្រើបាន (ក្នុងករណីរកគ្រឿងបន្លាស់បាន) ។*
- *នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើពាក្យស្នើសុំថ្នាក់ដឹកនាំដើម្បីជួលជុលឡើងវិញ។*

*រថយន្តដឹក ៖*

- *រថយន្តដឹក*KAMAZ *លេខសំគាល់ 1684 និងរថយន្តដឹក*KAMAZ *លេខសំគាល់ 1686 ដែលបច្ចុប្បន្ននៅរោងជាងរបស់ កសស ទាំង 02 (ពីរ) បានដាក់ពាក្យស្នើសុំជួសជុលតាំងពីឆ្នាំ 2019 និង 2021។ រថយន្តនេះមានសភាពច្រេះស៊ីកាប៊ីនពុកផុយស្ទើគ្រប់កន្លែងទាំងអស់ ចំណែកម៉ាស៊ីនរថយន្ត*

*ក្រោយពីបានដោះទម្លាក់និងពិនិត្យឃើញម៉ាស៊ីនមានសភាព (ខ្សោត) និងពិបាកក្នុងការស្វែងរកគ្រឿងបន្លាស់មកប្តូរ ។ ដោយឡែកកង់រថយន្តទាំងអស់ខូចគុណភាពប្រើលែងបាន ។*

- *យោងការវាយតម្លៃរបស់ជាងជួសជុល រថយន្តទាំងនេះពិបាករកគ្រឿងបន្លាស់មកជួសជុល ។*
- *នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើពាក្យស្នើសុំថ្នាក់ដឹកនាំ ដើម្បីដាក់ដេញថ្លៃ ។*

*រ៉ឺម៉ករថយន្តដឹក ៖*

- *រ៉ឺម៉ក (វែង) ដែលមានលេខសម្គាល់ 4119 និង 4095 បាក់សាកស៊ីប្រើលេងបាន ។ កង់រថយន្តដែលនៅល្អប្រើបាន ត្រូវបានដោះដូរផ្លាស់ជាមួយនឹងរថយន្តដែលកំពុងប្រើរាល់ថ្ងៃអស់ហើយ ។*
- *រ៉ឺម៉ក (ខ្លី) ដែលមានលេខសម្គាល់ 4085, 4088 និង 4089 ពុំត្រូវនឹងតម្រូវការដឹកទំនិញបច្ចុប្បន្នទេ។ ចំណែកកង់រថយន្តទាំងអស់ ត្រូវបានដោះដូរផ្លាស់ជាមួយនឹងរថយន្តដែលកំពុងប្រើរាល់ថ្ងៃអស់ហើយ ។*

*នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើពាក្យស្នើសុំ ថ្នាក់ដឹកនាំដើម្បីដាក់ដេញថ្លៃ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត ។

### ៥.៣.៣.២ ការពិនិត្យប្រព័ន្ធការពារអគ្គិភ័យនៅក្នុងឃ្លាំងលេខ ៣ និងឃ្លាំងលេខ ៥ នៃ កសស

យោងតាមការចុះពិនិត្យ ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងឃ្លាំងលេខ ៣ និងឃ្លាំងលេខ ៥ សវនករ បានសង្កេតឃើញបំពង់ពន្លត់អគ្គិភ័យសរុបចំនួន ២២ (ម្ភៃពីរ) គ្រឿង ក្នុងនេះរួមមានបំពង់ពន្លត់អគ្គិភ័យធន់ធំ ០៤ (បួន) គ្រឿង និងបំពង់ពន្លត់អគ្គិភ័យធន់តូច ១៨ (ដប់ប្រាំបី) គ្រឿងត្រូវបានខូចគុណភាពនិងប្រើប្រាស់លែងបាន ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីលក្ខខណ្ឌនិងវិធានការនានា ការបង្ការនិងពន្លត់អគ្គិភ័យ ក្នុងជំពូកទី ៣ មាត្រា ៩ អ្នកគ្រប់គ្រងគោលដៅ ទីកន្លែងផលិតកែច្នៃ និង/ឬ ស្តុកទុកសារធាតុងាយឆេះ ប្រភពភ្លើងនិងប្រភពកម្តៅ ត្រូវគោរពតាមលក្ខខណ្ឌនិងវិធាន រួមមានឧបករណ៍ស្រូបផ្សែង ស្រូបកម្តៅ ម៉ាស៊ីនបាញ់ទឹកពន្លត់អគ្គិភ័យស្វ័យប្រវត្តិ បំពង់ពន្លត់អគ្គិភ័យគ្រប់ប្រភេទ ប្រព័ន្ធទឹកដើរដោយស្វ័យប្រវត្តិសម្រាប់ពន្លត់អគ្គិភ័យ បង្គោលទឹកសម្រាប់ផ្តល់ឱ្យរថយន្តពន្លត់អគ្គិភ័យ មានប្រព័ន្ធការពាររន្ទះ និងហាមដាក់វត្ថុផ្សេងៗដែលអាចប្រតិកម្មបង្កើតបានជាប្រភពភ្លើង និងប្រភពកម្តៅនៅក្បែរគោលដៅ ដែលងាយឆេះនិងងាយផ្ទុះឆេះ ។

ប្រការនេះ អាចកើតមានឡើងដោយសារភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ក្នុងការត្រួតពិនិត្យគុណភាព និងស្នើសុំបំពាក់ឧបករណ៍ការពារអគ្គិភ័យ ដើម្បីប្រើប្រាស់ឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស និងតម្រូវការចាំបាច់ ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពនៃការគ្រប់គ្រងអគ្គិភ័យ នាំឱ្យខូចខាតគុណភាពទំនិញ និង/ឬ ប៉ះពាល់អាយុជីវិតមន្ត្រី និយោជិត កម្មករ ដែលបម្រើការងារនៅក្នុងឃ្លាំងជាយថាហេតុ ។

ដើម្បីធានាប្រសិទ្ធភាពអនុវត្ត វិធានការបង្ការនិងពន្លត់អគ្គិភ័យ សំដៅកាត់បន្ថយហានិភ័យ និងការបំផ្លាញទ្រព្យសម្បត្តិដោយគ្រោះអគ្គិភ័យ សវនករយល់ឃើញថាសវនដ្ឋានត្រូវបង្កើនការប្រុងប្រយ័ត្ន និងស្នើសុំបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យ (Fire Extinguishers) ឱ្យបានឆាប់និងសមស្របតាមតម្រូវការចាំបាច់ ។

*នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងពិនិត្យអំពីចំនួននិងប្រភេទនៃបំពង់ពន្លត់អគ្គិភ័យដែលត្រូវការចាំបាច់តាមផ្នែកនីមួយៗ និងធ្វើពាក្យស្នើសុំពីថ្នាក់ដឹកនាំ ក.ស.ស ទៅតាមចំនួនជាក់ស្តែង ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្ត អនុសាសន៍សវនកម្មជាបន្តទៀត ។

## ៥.៣.៤ នាយកដ្ឋាននាវាចរ-កណ្ណធារនិងសន្តិសុខ

### ៥.៣.៤.១ ការពិនិត្យមធ្យោបាយជើងទឹក (នាវាសណ្ដោង)

យោងតាមការចុះពិនិត្យមធ្យោបាយជើងទឹក (នាវាសណ្ដោង) ដែលគ្រប់គ្រង ថែទាំនិងប្រើប្រាស់ដោយការិយាល័យគ្រប់គ្រងមធ្យោបាយជើងទឹក សវនករបានកត់សម្គាល់ឃើញ៖

- **នាវាសណ្ដោង កោះ វ៉ៃ**
  - ខ្វះភ្លើងបំភ្លឺនៅពេលបើកបរ (សុំបានហើយតែមិនទាន់បានបំពាក់-រង់ចាំឡើងអ៊ូ)
  - ត្រើយមុខ បានខូចក្នុងឆ្នាំ ២០២០ ដោយសារច្រែះស៊ីខ្លាំង (អ្នកគ្រប់គ្រងបានស្នើសុំជួសជុល/ប្តូរត្រើយថ្មី - មកដល់ត្រីមាសទី ២ ឆ្នាំ ២០២២ នេះ នៅពុំទាន់ជួសជុល/ប្តូរថ្មីទេ)
  - បន្ទប់ដេកនិងបន្ទប់ទឹក បានខូចទ្រង់ទ្រាយ-នៅពុំទាន់បានជួសជុលនៅឡើយ។
- **នាវាសណ្ដោង កោះ សេះ**
  - ម៉ាស៊ីនត្រជាក់បំពាក់នៅក្នុងបន្ទប់ដេករបស់ នាវិក បន្ទប់បើកបរ បន្ទប់ដេករបស់ ប្រធាននាវា និងបន្ទប់ទទួលភ្ញៀវ ប្រើប្រាស់លែងបាន
  - ពុំទាន់មានសម្ភារប្រើប្រាស់នៅក្នុងបន្ទប់ដេក ដូចជា ពូក ខ្នើយ ជាដើម ។
- **នាវាសណ្ដោង កោះ តាង**
  - ពុំទាន់បានជួសជុលបន្ទប់ដេករបស់នាវិកផ្នែកខាងក្រោម
  - ខ្វះអាវពោងការពារសុវត្ថិភាព
  - ពុំមានយុថ្កា (បាត់)
  - ទ្វារដែកសម្រាប់បិទ-បើក នៅជុំវិញកាប៊ីនបើកបរត្រូវបានច្រែះស៊ី(ពុកផុយ)-ពុំទាន់បានជួសជុល ។
- **នាវាសណ្ដោង កោះ រ៉ុង**

* ម៉ាស៊ីននាវាត្រូវបានប្តូរថ្មីក្នុងឆ្នាំ ២០២០ ប៉ុន្តែនៅពុំទាន់បានចេញប្រតិបត្តិការនៅឡើយពីព្រោះប្រព័ន្ធខាងក្រោម នៅពុំទាន់បានភ្ជាប់សមស្របតាមលក្ខណៈបច្ចេកទេស៖

  - ប្រព័ន្ធចង្កូតខូច (ត្រូវជួសជុល ឬ ប្តូរថ្មី)
  - ពុំទាន់មានច្រវ៉ាក់យុថ្កាគ្រប់គ្រាន់ (ខ្វះប្រមាណជា ៧០ - ៩០ ម៉ែត្រ)
  - ត្រើយក្រោយ និង ត្រើយមុខបានខូច - ពុំទាន់បានជួសជុល
  - ប្រព័ន្ធខ្សែភ្លើងបំពាក់ក្នុងនាវាមានសភាពចាស់
  - ពុំមានភ្លើងបំភ្លឺជុំវិញនាវា គ្មានភ្លើងហ្វាផ្នែកខាងមុខ និងភ្លើងហ្វាផ្នែកខាងក្រោយ
  - ពុំទាន់បានបំពាក់សម្ភារប្រើប្រាស់ប្រចាំថ្ងៃ នៅតាមបន្ទប់នីមួយៗ (ដូចជាម៉ាស៊ីនត្រជាក់ និងកង្ហារ ។ល។)
  - ផ្ទះបាយ បន្ទប់ទឹក បន្ទប់ដេក ខាងក្រោមសម្រាប់នាវិក និងបន្ទប់ដេកសម្រាប់ ប្រធាននាវានៅផ្នែកខាងលើពុំទាន់បានជួសជុល
  - កាប៊ីនបញ្ជាបើកបរ ពុំទាន់បានជួសជុល ហើយទ្វារបិទបើកចំនួន ០២ (ពីរ) និងកញ្ចក់កាប៊ីនចំនួន ០១ (មួយ) ដែលត្រូវបានស្នើសុំរួចហើយនោះ នៅពុំទាន់បានផ្តល់ជូននៅឡើយ

- ស្នើសុំឡើងអ៊ូបាញ់ខ្សាច់ និងលាបថ្នាំថ្មី សុំ Rada និង GPS ថ្មី (ដោយ GPS មានស្រាប់មានលក្ខណៈចាស់ និងត្រូវបានប្រើប្រាស់រយៈពេល ៨ ឆ្នាំមកហើយ) ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/បេ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពី ការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ កសស ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សានិងទុកដាក់ឱ្យបានគង់វង្សនៅឡើយ ។

ករណីនេះ អាចកើតមានឡើងដោយសារភាពសឹករេចរឹលនៃឧបករណ៍ និងសម្ភារដែលត្រូវបានប្រើប្រាស់រយៈពេលយូរ ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់សុវត្ថិភាព ផលិតភាពការងារ និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ កសស ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋាន គួររាយការណ៍ជូនថ្នាក់ដឹកនាំ កសស និងស្នើសុំនាយកដ្ឋានជំនាញធ្វើការជួសជុល និង/ឬ ផ្លាស់ប្តូរថ្មីនូវឧបករណ៍និងសម្ភារដែលខ្វះខាត និងខូចពិតប្រាកដឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ។

*ជាមួយនេះ នាយកដ្ឋាន នកស បានកំពុងតែធ្វើការទំនាក់ទំនងជាមួយផ្នែកពាក់ព័ន្ធរបស់ កសស ក្នុងការស្នើសុំជួសជុល បំពាក់បន្ថែមលើនាវាសណ្តោងទាំងបួនខាងលើនេះ រួចមកហើយ ហើយមានផ្នែកខ្លះ ក៏ត្រូវបានបំពេញជាបណ្តើរៗរួចមកហើយ ។ ដោយនាវាសណ្តោងទាំងនោះចេញធ្វើប្រតិបត្តិការបណ្តើរៗ ធ្វើឱ្យការងារជួសជុលត្រូវសម្របសម្រួល តាមពេលវេលាដែលទំនេរជាក់ស្តែង ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

### ៥.៣.៤.២ ការពិនិត្យរបាំងការពារនាវា (Fenders)

យោងតាមការចុះពិនិត្យរបាំងការពារនាវា (Fenders) និងជណ្តើរដែកចុះ- ឡើងទឹកសមុទ្រនៅតាមចំណតផែកុងតែន័រ និងការសាកសួរមន្ត្រីជំនាញ ទទួលបន្ទុកការងារគ្រប់គ្រង ប្រើប្រាស់និងថែរក្សា សវនករបានសង្កេតឃើញ៖ Fenders No. C.1-C.27 បំពាក់នៅតាមបណ្តោយ Post 5 និង Post 6, Fenders No. D.1-D.32 បំពាក់នៅតាមបណ្តោយ Post 7 និង Post 8 និងជណ្តើរដែកសម្រាប់ចុះពិនិត្យស្ថានភាពគែមផែក្នុងទឹកសមុទ្រ ត្រូវបានបាក់ដាច់ និងមានស្នាមប្រេះបែក ក្នុងស្ថានភាពដូចខាងក្រោម៖

- **របាំងការពារនាវា** (Fenders No. C.1-C.27) **និងជណ្តើរដែកនៅ** Post 5 **និង** Post **6**
  - Fenders នៅប្រើបាន : ១៧ គ្រឿង
  - Fender បាក់ដាច់(ខូច) : ០១ គ្រឿង
  - Fenders ដែលមានចងកង់ឡាន ២ ផ្តោបគ្នា: ០២ គ្រឿង
  - Fenders ដែលមានកង់ឡានតែ ១ : ០៧ គ្រឿង
  - ជណ្តើរដែក (ច្រែះស៊ីខូចទាំងស្រុង) : ០៧ គ្រឿង
- **របាំងការពារនាវា** (Fenders No. D.1-D.32) **និងជណ្តើរដែកនៅ** Post 7 **និង** Post 8
  - Fenders នៅប្រើបាន : ១៥ គ្រឿង
  - Fenders បាក់ដាច់(ខូច) : ០៥ គ្រឿង
  - Fenders ដែលមានចងកង់ឡាន ២ ផ្តោបគ្នា: ០៧ គ្រឿង
  - Fenders ដែលមានកង់ឡាន ១ : ០៥ គ្រឿង

- ជណ្តើរដែក : ០២ គ្រឿង (ប្រេះស៊ីខូច ០១)។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/បប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ កសស ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស នៅឡើយ ។

ប្រការនេះ អាចបណ្តាលមកពីភាពសឹករេចរឹល ដោយសារការប្រើប្រាស់រយៈពេលយូរ និង/ឬ ការប៉ះទង្គិចដោយសកម្មភាពចូលចត-ចេញដំណើរ នៃនាវាដឹកទំនិញ/កុងតែន័រដែលចូលមកធ្វើការលើកដាក់ ផ្ទេរ-ផ្ទុកនៅ Post 5 - Post 6 និង Post 7 - Post 8 ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព របាំងការពារនាវា (Fenders) និងនាំឱ្យចលនានាវាចូលចត-ចេញដំណើរ ប៉ះទង្គិចគែមផែនិងខូចខាតថែមទៀត ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំការិយាល័យទទួលបន្ទុកនិងសវនដ្ឋាន គួរចុះពិនិត្យស្ថានភាពជាក់ស្តែងនិងរាយការណ៍ជូនថ្នាក់ដឹកនាំ កសស ដើម្បីស្នើសុំនាយកដ្ឋានជំនាញធ្វើការជួសជុល និងផ្លាស់ប្តូរថ្មីឱ្យបានសមស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ កសស ។

*ស្ថានភាព Fenders របស់ កសស នាបច្ចុប្បន្ន ពិតជាមានសភាពទ្រុឌទ្រោម ដូចការរកឃើញខាងលើប្រាកដមែន ហើយនាយកដ្ឋាន នកស បានស្នើសុំនាយកដ្ឋានពាក់ព័ន្ធអោយធ្វើការជួសជុលជាបន្តបន្ទាប់ មានដូចជាការដាក់កង់ឡានជំនួសជាដើម ដោយខ្សែក Fenders ខ្លះដាច់ជ័រធ្លាក់ចុះតែម្តង ហើយនាយកដ្ឋាន នកស ក៏បានរាយការណ៍ និងដាក់ពាក្យស្នើសុំឱ្យជួសជុលដែរកន្លងមក ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

## ៥.៣.៥ នាយកដ្ឋានសំណង់-វិស្វកម្ម

### ៥.៣.៥.១. ការពិនិត្យរបាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋានសំណង់-វិស្វកម្ម

យោងតាមការពិនិត្យរបាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានសំណង់-វិស្វកម្មក្នុងត្រីមាសទី ២ នៃការិយបរិច្ឆេទ ២០២២ សវនករបានសង្កេតឃើញមានរបាយការណ៍វឌ្ឍនភាពការងាររួមក្នុងក្របខ័ណ្ឌសវនដ្ឋាន ស្របតាមរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែ របស់ការិយាល័យជំនាញនីមួយៗ ដោយសម្រេចបានលទ្ធផលការងារសំខាន់ៗជាច្រើន ទៅតាមតួនាទី-ភារកិច្ចដែល កសស បានកំណត់ ប៉ុន្តែក្នុងនេះផ្នែកគ្រប់គ្រងឯកសារលទ្ធកម្មសំណង់ នៅមានភាពខ្វះចន្លោះនិងពុំទាន់រៀបចំឯកសារបានសមស្រប និងទាន់ពេលវេលាតាមតម្រូវការរបស់ កសស នៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ០២៤ សសរ/ កសស/សណ.វក ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន តួនាទី-ភារកិច្ចរបស់បណ្តាការិយាល័យនៃនាយកដ្ឋានសំណង់-វិស្វកម្ម ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២០ នៅឡើយ ។

ប្រការនេះ អាចបណ្តាលមកពីមន្ត្រីទទួលបន្ទុកការងារ ក្នុងក្របខ័ណ្ឌការិយាល័យគ្រប់គ្រងឯកសារលទ្ធកម្មសំណង់មានភាពមមាញឹកច្រើន ក្នុងការចូលរួមសិក្សាគម្រោងចាក់បេតុងទីលានកុងតែន័រ ការងារជួសជុលនាវាកោះសេះ និងដំបូលឃ្លាំងនានារបស់ កសស ។

ទោះជាយ៉ាងនេះក្តី កត្តាខាងលើអាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃការអនុវត្ត តួនាទី-ភារកិច្ចរបស់សវនដ្ឋាន ជាពិសេសអាចធ្វើឱ្យមានការយឺតយ៉ាវដល់ការអនុវត្ត គម្រោងប្លង់ជួសជុលសំណង់មូលដ្ឋាននៅក្នុងក្របខ័ណ្ឌ កសស ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួរណែនាំឱ្យការិយាល័យគ្រប់គ្រងឯកសារលេទ្ធកម្មសំណង់ យកចិត្តទុកដាក់ក្នុងការអនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន និងសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីជម្រុញឱ្យការរៀបចំឯកសារលទ្ធកម្ម ប្រព្រឹត្តទៅបានទាន់ពេលវេលានិងស្របតាមតម្រូវការចាំបាច់របស់ កសស ។

*នាយកដ្ឋានសំណង់-វិស្វកម្ម នឹងណែនាំការិយាល័យគ្រប់គ្រង ឯកសារលទ្ធកម្មសំណង់ ឱ្យសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកែលម្អចំណុចខ្វះខាតដូចបានលើកឡើងខាងលើ និងរៀបចំឯកសារលទ្ធកម្មសំណង់ឱ្យបានឆាប់រហ័ស និងសមស្របតាមតម្រូវការរបស់ កសស ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

### ៥.៣.៥.២. ការពិនិត្យតារាងរថយន្តនិងគ្រឿងចក្រ នៃផ្នែកគ្រឿងចក្រសំណង់

យោងតាមតារាងរថយន្តនិងគ្រឿងចក្រ និងតាមការសាកសួរមន្ត្រីជំនាញនៃផ្នែកគ្រឿងចក្រសំណង់ សវនករបានសង្កេតឃើញ៖

- រថយន្តចូកដី ០១ គ្រឿង ម៉ាក Wheel Loader Hitachi LX-150 ឆ្នាំប្រើប្រាស់ ១៩៩៨ លេខសម្គាល់គ្មាន បានខូចម៉ាស៊ីនក្នុងឆ្នាំ ២០១៧ (ជួសជុលលែងបាន)
- រថយន្តស៊ីទែន ០១ គ្រឿង ម៉ាក Maz ឆ្នាំប្រើប្រាស់ ១៩៨២ លេខសម្គាល់ ៤០១០ បានខូចម៉ាស៊ីនគ្មានគ្រឿងបន្លាស់ផ្លាស់ប្តូរ
- រថយន្តស៊ីទែន ០១ គ្រឿង ម៉ាក Maz ឆ្នាំប្រើប្រាស់ ១៩៨២ លេខសម្គាល់ ៤០១១ បានខូចម៉ាស៊ីនគ្មានគ្រឿងបន្លាស់ផ្លាស់ប្តូរ ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ កសស ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សានិងទុកដាក់ឱ្យបានគង់វង្សនៅឡើយ ។

ករណីនេះ អាចកើតមានឡើងដោយសារភាពសឹករេចរឹលនៃគ្រឿងបន្លាស់ ដែលត្រូវបានប្រើប្រាស់រយៈពេលយូរ ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ផលិតភាពការងារ ប្រសិទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ កសស និងនាំឱ្យខាតបង់ទ្រព្យសម្បត្តិរដ្ឋ ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋាន ពិសេសផ្នែកគ្រឿងចក្រសំណង់គួររៀបចំតារាងត្រួតពិនិត្យប្រចាំថ្ងៃ (Daily Checklist) ដាក់ឱ្យប្រតិបត្តិករនីមួយៗ ពិនិត្យតាមដានដំណើរការគ្រឿងចក្រគ្រប់ប្រភេទ និងរៀបចំផែនការថែទាំ-ជួសជុលប្រចាំសប្តាហ៍/ខែ ឱ្យបានទៀងទាត់។

*១. ដោយសារគ្រឿងចក្រមួយចំនួនធំប្រើប្រាស់យូរឆ្នាំ មានការខូចជាញឹកញាប់ ។*

*២. កន្លងមកគ្រឿងចក្រសំណង់ បានអនុវត្តទៀងទាត់លើការជួសជុលថែទាំជាប្រចាំ ដូចខាងក្រោម៖*

- *មានក្រុមជាងជួសជុល-ថែទាំគ្រឿងចក្រ*
- *ផ្លាស់ប្តូរប្រេងរំអិល បូមខ្លាញ់ ប្តូរតម្រងប្រេង តាមម៉ោងកំណត់របស់គ្រឿងចក្រ*
- *លាងសម្អាតគ្រឿងចក្រជាប្រចាំ*

*៣. ចំពោះគ្រឿងបន្លាស់គ្រឿងចក្រ កន្លងមកជួបការលំបាក ដោយសារពេលខ្លះ កំពុងតែអនុវត្តការងារហើយខូច ចាំបាច់ត្រូវរកទិញមកផ្លាស់ប្តូរភ្លាម ប៉ុន្តែជាញឹកញាប់ត្រូវស្វះស្វែងរកបន្លាស់ដោយពុំសូវមានក្នុងទីផ្សារ ព្រោះគ្រឿងចក្រមានអាយុយូរឆ្នាំ ។*

*៤. គ្រឿងចក្រមួយចំនួនប្រើប្រាស់ច្រើនឆ្នាំ ពុំមានគ្រឿងបន្លាស់សម្រាប់ផ្លាស់ប្តូរ ធ្វើឱ្យគ្រឿងចក្រខូចលែងដំណើរការ ។*

*ការិយាល័យគ្រឿងចក្រ-ឃ្លាំងប្រេង នឹងបន្តអនុវត្តពិនិត្យតាមដានដំណើរការគ្រឿងចក្រ រថយន្តគ្រប់ប្រភេទ និងរៀបចំផែនការជួសជុល-ថែទាំជាប្រចាំឱ្យបានទៀងទាត់ និងសំណូមពរជម្រះបញ្ជីគ្រឿងចក្រចាស់ៗមួយចំនួនចេញ ។*

- *មាន Wheel Loader មួយផ្សេងទៀតកំពុងប្រើប្រាស់*
- *រថយន្ត Fuel Tankers យើងទិញបន្ថែមចំនួន ០២ គ្រឿង ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

## ៥.៣.៦ នាយកដ្ឋានបច្ចេកទេស-សម្ភារ

### ៥.៣.៦.១ ការពិនិត្យរបាយការណ៍វឌ្ឍនភាពការងារ របស់នាយកដ្ឋានបច្ចេកទេស-សម្ភារ

យោងតាមរបាយការណ៍វឌ្ឍនភាពការងាររបស់ នាយកដ្ឋានបច្ចេកទេស-សម្ភារ សម្រាប់ត្រីមាសទី ២ ឆ្នាំ ២០២២ សវនករបានពិនិត្យឃើញសវនដ្ឋាន សម្រេចបានលទ្ធផលការងារសំខាន់ៗ ជាច្រើនពាក់ព័ន្ធនឹងការថែទាំ-ជួសជុលគ្រឿងចក្រ មធ្យោបាយលើកដាក់ និងដឹកជញ្ជូនធន់ធ្ងន់/ស្រាលរួមទាំងការថែរក្សាស្តុកសម្ភារ-បន្លាស់ និងការជួសជុលនាវាសណ្តោងរបស់ កសស ប៉ុន្តែលើកលែងតែការិយាល័យឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់ និងការិយាល័យយន្តសាស្ត្រកប៉ាល់-នាវាសណ្តោង សវនដ្ឋាន នៅពុំទាន់បានតម្រូវឱ្យការិយាល័យផ្សេងៗទៀត រៀបចំរបាយការណ៍វឌ្ឍនភាពការងារទៅតាមមុខជំនាញ និងតួនាទី-ភារកិច្ចរៀងៗខ្លួននៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ២៣០ សសរ/កសស/បទស ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទី-ភារកិច្ចរបស់បណ្តាការិយា ល័យនៃនាយកដ្ឋានបច្ចេកទេស-សម្ភារ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០ នៅឡើយ ។

ករណីនេះ អាចបណ្តាលមកពីការិយាល័យផ្សេងៗទៀត ជាប់មមាញឹកក្នុងការងារអាទិភាព ពិសេសការថែទាំ-ជួសជុលគ្រឿងចក្រ និងមធ្យោបាយលើកដាក់ ដឹកជញ្ជូនរបស់ កសស ។

ទោះជាយ៉ាងនេះក្តី កត្តាខាងលើអាចបណ្តាលឱ្យប៉ះពាល់ ដល់ប្រសិទ្ធភាពនៃការអនុវត្តតួនាទី-ភារកិច្ចរបស់បណ្តាការិយាល័យ នៅក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

សវនករយល់ឃើញថាថ្នាក់ដឹកនាំសវនដ្ឋាន គួរជម្រុញឱ្យការិយាល័យនីមួយៗធ្វើរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែ ស្របតាមតួនាទី-ភារកិច្ចដែល កសស បានប្រគល់ជូន ។

*ឆ្លើយតបនឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ទាក់ទងទៅនឹងការងារតាមការិយាល័យនីមួយៗ របស់នាយកដ្ឋានបច្ចេកទេស-សម្ភារ បានរៀបចំទៅតាមរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងភាពទទួលខុសត្រូវទៅតាមមុខជំនាញជាប្រចាំ ក្នុងការងារជួសជុលថែទាំគ្រឿងចក្រ បម្រើអោយការងារអាជីវកម្មគ្រប់ប្រភេទរបស់ កសស និងសហការជាមួយនាយកដ្ឋានផ្សេងៗបានល្អប្រសើផងដែរ ។ តាមការិយាល័យនីមួយៗ មិនបានធ្វើរបាយការណ៍ដាច់ដោយឡែកពីគ្នាបានទេ ដោយការងារប្រចាំថ្ងៃមានទំនាក់ទំនងគ្នាទៅវិញទៅមក និងបានបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែជារៀងរាល់ខែ ហើយបានបញ្ជូនទៅ នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ ជាប្រចាំផងដែរ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

**៥.៣.៦.២ ការពិនិត្យវគ្គបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ថែទាំ-ជួសជុល គ្រឿងចក្រ**

យោងតាមការសម្ភាសន៍មន្ត្រីជំនាញ នៅនាយកដ្ឋានបច្ចេកទេស-សម្ភារ សវនករបានកត់សម្គាល់ឃើញថា គិតត្រឹមត្រីមាសទី ២ ឆ្នាំ ២០២២ នេះ នាយកដ្ឋានបច្ចេកទេស-សម្ភារ នៅពុំទាន់បានបើកវគ្គបណ្ដុះបណ្ដាលជំនាញថែទាំ-ជួសជុល គ្រឿងចក្រធន់ធ្ងន់ និងបច្ចេកទេសមេកានិចគ្រឿងចក្រដល់ បុគ្គលិក កម្មករ/ប្រតិបត្តិករគ្រឿងចក្ររបស់ កសស នៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុឆ្នាំ ២០២២ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ក្នុងឧបសម្ព័ន្ធទី ៨: ផែនការបណ្ដុះបណ្ដាលធនធានមនុស្សឆ្នាំ ២០២២ ត្រង់ចំណុច ក-២២ ស្ដីពីទ្រឹស្ដីត្រួតពិនិត្យ ថែទាំ-ជួសជុល គ្រឿងចក្រធន់ធ្ងន់ពេញលេញនៅឡើយ ។

ករណីនេះ អាចបណ្ដាលមកពីមន្ត្រីជំនាញ ក្នុងក្របខ័ណ្ឌសវនដ្ឋាននិងបុគ្គលិក កម្មករ គ្រឿងចក្រមានការមមាញឹកច្រើន ក្នុងការបម្រើប្រតិបត្តិការអាជីវកម្ម សេវាកម្ម របស់ កសស ។

ទោះជាយ៉ាងនេះក្ដី កត្តាខាងលើអាចបណ្ដាលឱ្យប៉ះពាល់ដល់គុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រឿងចក្រ មធ្យោបាយលើកដាក់ ដឹកជញ្ជូន ធន់ធ្ងន់/ស្រាលរបស់ កសស ជាយថាហេតុ ។

សវនករយល់ឃើញថា នាយកដ្ឋានបច្ចេកទេស-សម្ភារ គួររៀបចំផែនការបណ្ដុះបណ្ដាលនិងស្នើសុំថ្នាក់ដឹកនាំ កសស បើកវគ្គបណ្ដុះបណ្ដាលជំនាញថែទាំ-ជួសជុល និងបច្ចេកទេសមេកានិច ដល់បុគ្គលិក កម្មករ គ្រឿងចក្រ ស្របតាមផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ ឆ្នាំ ២០២២ ។

*ទាក់ទងនឹងការបើកវគ្គ បណ្ដុះបណ្ដាលជំនាញថែទាំ និងជួសជុលគ្រឿងចក្រធន់ធ្ងន់ យើងបានធ្វើការបណ្ដុះបណ្ដាលដល់ក្រុមជាង តាំងពី កសស បានបំពាក់នូវមធ្យោបាយលើកដាក់ធន់ធ្ងន់មក ។ ដោយការបណ្ដុះបណ្ដាលនេះ ជាការអនុវត្តជាក់ស្ដែងផ្ទាល់នឹងការងារតែម្ដង (On Job Training) ដោយការបណ្ដុះបណ្ដាលនេះក្រុមជាងរបស់យើងងាយយល់និងងាយចាប់បានរាល់ការងារនីមួយៗ ។ សំរាប់ការបណ្ដុះបណ្ដាលជាទ្រឹស្ដី (Class Room Training) យើងក៏មានរៀបចំបានមួយចំនួនដែរ ដោយការងារត្រួតពិនិត្យ ថែទាំ និងជួសជុលគ្រឿងចក្ររបស់យើងមានភាពមមាញឹកខ្លាំង ។ ក្រៅពីនេះបុគ្គលិកផ្នែកជួសជុលថែទាំ របស់យើងមួយចំនួនបានទៅរៀនជំនាញនៅឯភ្នំពេញរាល់ចុងសប្ដាហ៍ ដោយទទួលបានការឧបត្ថម្ភជាបន្តបន្ទាប់ពី កសស ផងដែរ ។ ទោះជាយ៉ាងនេះក្ដី ដើម្បីធានានិរន្តរភាពប្រតិបត្តិការអាជីវកម្ម ការប្រើប្រាស់គ្រឿងចក្រ មធ្យោបាយលើកដាក់ផ្ទេរ-ផ្ទុកនិងដឹកជញ្ជូន/កុងតែន័រគ្រប់ប្រភេទ សវនដ្ឋាននឹងរៀបចំផែនការបណ្ដុះបណ្ដាលឱ្យបានសមស្របតាមគោលការណ៍ណែនាំ ដូចមានចែងនៅក្នុងផែនការអាជីវកម្ម (សេវាកម្ម) ឆ្នាំ ២០២២ របស់ កសស ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

## ៥.៣.៧ នាយកដ្ឋានឧីផ្សារ (ឧផ)

**៥.៣.៧.១ របាយការណ៍សម្ភាសន៍តំណាងក្រុមហ៊ុនដឹកជញ្ជូនដោយនាវា (Shipping Lines) ក្រុមហ៊ុនផែស្ងួត សមាគមកស្តុភារកម្ពុជា និងសមាគមកម្ពុជាដឹកជញ្ជូនដោយរថយន្ត អំពីសេវាប្រតិបត្តិការ និងការនាំចូល-ចេញ តាមច្រកទ្វារ កសស**

យោងតាមរបាយការណ៍សម្ភាសន៍ តំណាងក្រុមហ៊ុនដឹកជញ្ជូនដោយនាវា (Shipping Lines) ក្រុមហ៊ុនផែស្ងួត (Dry Ports) សមាគមកស្តុភារកម្ពុជា និងសមាគមកម្ពុជាដឹកជញ្ជូនដោយរថយន្ត (Cambodia Trucking Association) មួយចំនួនរួមមាន៖ ក្រុមហ៊ុន Maersk (SHV-PNP), RCL (SHV-PNP), Teng Lay (SHV), SITC (SHV-PNP), Straits International (Wan Hai Samudera), Cambodia Logistics Association (CLA), Cambodia Trucking Association (CAMTA), Hong Leng Huor Dry Port (PNP),

GMAC, So Nguon Dry Port (PNP), និងក្រុមហ៊ុន JMG Co., LTD (PNP) អំពីសេវាប្រតិបត្តិការនិងការនាំចូល-ចេញតាមច្រកទ្វារ កសស សវនករបានកត់សម្គាល់ឃើញថាៈ អតិថិជនខាងលើបានពេញចិត្តនឹងសេវាប្រតិបត្តិការ កិច្ចសហការ និងការឆ្លើយតបរបស់ កសស ប៉ុន្តែទន្ទឹមនឹងនេះ នៅមានចំណុចលើកឡើងមួយចំនួនពាក់ព័ន្ធនឹងដំណើរការយឺតយ៉ាវនៃប្រតិបត្តិការផ្ទុកសំបកកុងតែន័រចូលនាវា ការថយចុះនៃការនាំចូល-នាំចេញតាម កសស នៅពេលថ្មីៗនេះ ពេលវេលា Transit កុងតែន័រពីប្រទេសវៀតណាមទៅសហរដ្ឋអាមេរិកតាម កសក ហាក់ដូចជាឆាប់ហ័សជាងតាម កសស និងមានការថយចុះការនាំចូលវត្ថុធាតុដើមពីប្រទេសចិន ព្រមទាំងតម្រូវការចំណាតផៃកុងតែន័រនិងឋបនីយកណ្ឋផៃសំខាន់ៗមួយចំនួនទៀត ។

ទោះជាកត្តាសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងវិបត្តិសេដ្ឋកិច្ចសាកល និង/ឬ ការថយចុះនៃការបញ្ជាទិញក៏ដោយ ប៉ុន្តែភាពយឺតយ៉ាវនៃប្រតិបត្តិការផ្ទុកសំបកកុងតែន័រចូលនាវា នៅមិនទាន់ឆ្លើយតបពេញលេញតាមតម្រូវការរបស់អតិថិជននៅឡើយ ។

ប្រការនេះ អាចបណ្តាលមកពីភាពអាក់អួលនៃមធ្យោបាយគ្រឿងចក្រ ការរើសំបកកុងតែន័រច្រើនដង និង/ឬ ក្រុមហ៊ុន Shipping Lines ដឹកជញ្ជូនសំបកកុងតែន័រមកនាវាមិនទាន់ពេល ។

ករណីខាងលើ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពការងារ និងទំនុកចិត្តរបស់អតិថិជន។ សវនដ្ឋានគួរសហការសម្របសម្រួល និងសិក្សាអំពីមូលហេតុសំខាន់ៗពាក់ព័ន្ធនឹងករណីខាងលើបន្ថែមទៀត ។

*នាយកដ្ឋានទីផ្សារ នឹងសហការសម្របសម្រួលការងារជូនអតិថិជនឱ្យបានសមស្រប និងបន្តសិក្សាអំពីសេវាប្រតិបត្តិការនិងការនាំចូល-ចេញតាមច្រកទ្វារ កសស និង កសក តាមលទ្ធភាពដែលអាចធ្វើបាន។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្ទាប់ទៀត ។

## ៥.៣.៧.២ ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារ ២០២៣-២០២៥

យោងតាមពង្រាងផែនការយុទ្ធសាស្ត្រទីផ្សាររបស់ កសស ឆ្នាំ ២០២៣-២០២៥ ដែលទទួលបានពីសវនដ្ឋាន សវនករបានពិនិត្យឃើញមានគោលការណ៍យុទ្ធសាស្ត្រសំខាន់ៗពាក់ព័ន្ធនឹងចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង ព្រមទាំងធាតុចូលសំខាន់ៗជាច្រើនផ្សេងទៀតដើម្បីវាស់វែង និងពង្រឹងប្រសិទ្ធភាពអនុវត្តផែនការសកម្មភាពរបស់ កសស ប៉ុន្តែ ដោយផែនការយុទ្ធសាស្ត្រខាងលើនៅមិនទាន់បានបញ្ចប់ សវនករបានសង្កេតឃើញចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដែលត្រូវធ្វើការកែលម្អបន្ថែមទៀត ។

ចំណុចខាងលើគឺពាក់ព័ន្ធនឹងបរិបទទីផ្សារសេរី ដូច្នេះការរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ (Marketing Strategic Plan) ត្រូវឈរលើគោលការណ៍នៃផែនការទីផ្សារ (Marketing Plan) ហើយផែនការទាំងពីរ ត្រូវអនុវត្តស្របគ្នាក្នុងពេលតែមួយ និងមិនអាចប្រើប្រាស់ជំនួយគ្នាបានទេ។ ក្នុងបរិបទនេះ ផែនការយុទ្ធសាស្ត្រទីផ្សារ រំលេចអំពីគោលបំណងនៃ Marketing Efforts និងគោលដៅរយៈពេលវែង (End Goal) ដែលអង្គភាពបានកំណត់ ។ ដោយឡែក ផែនការទីផ្សាររំលេចអំពីការអនុវត្តជាក់ស្តែងនៃ Marketing Efforts និងជាផែនការលំអិតស្តីពីរបៀបដែលអង្គភាពគ្រោងសម្រេចគោលដៅរយៈពេលវែង (End Goal) របស់ខ្លួន ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីទទួលបន្ទុកការងារ ក្នុងក្របខណ្ឌសវនដ្ឋាននៅមានភាពខ្វះចន្លោះក្នុងការរៀបចំភាពប្រទាក់ក្រឡាគ្នានៃបែបបទ និង/ឬ គោលការណ៍ដែលត្រូវកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រទីផ្សារ (Marketing Strategic Plan) និងផែនការទីផ្សារ (Marketing Plan) ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពអនុវត្ត ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារ ដែលសវនដ្ឋានបាននិងកំពុងព្រាងឡើង ។

សវនដ្ឋានគួរធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាពិសេសពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទីផ្សារ (Marketing Strategy) និងផែនការទីផ្សារ (Marketing Plan) ដើម្បីបញ្ចប់ពង្រាងផែនការយុទ្ធសាស្ត្រទីផ្សារដែលមានស្រាប់ ឱ្យបានឆាប់រហ័សនិងសមស្របតាមតម្រូវការរបស់ កសស ។

*នាយកដ្ឋានទីផ្សារ សូមឯកភាពតាមអនុសាសន៍របស់សវនករ និងប្រឹងប្រែងសិក្សាស្រាវ ជ្រាវបន្ថែមដើម្បីរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ ឱ្យចេញជារូបរាងឡើងនៅត្រីមាសទី ៤ ឆ្នាំ ២០២២ តាមធនធាននិងលទ្ធភាពមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងស្ថានការណ៍តម្រូវការ សម្រាប់ការអភិវឌ្ឍន៍របស់ កសស ពេលបច្ចុប្បន្ននិងអនាគត ។*

*ទោះយ៉ាងណាក្តី សូមបញ្ជាក់ជូនបន្ថែមថា នាយកដ្ឋានទីផ្សារយើងខ្ញុំមានបញ្ហាប្រឈមមួយចំនួន ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារនោះគឺ ៖ ១. បទពិសោធន៍និងជំនាញវិភាគស៊ីជម្រៅដែលទាមទារនូវសមត្ថភាពខ្ពស់ របស់អ្នករៀបចំយុទ្ធសាស្ត្រទីផ្សារនេះ (ធនធានមនុស្ស) ២. ប្រភពព័ត៌មានទាំងផ្ទៃក្នុង (ស្ថិតិនានា) និងខាងក្រៅ (តួលេខសេដ្ឋកិច្ច) ៣. ការយល់ដឹងនិងផ្តល់សារសំខាន់ចំពោះកិច្ចការនេះនៅមានកម្រិត។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសទី ៤ ជាបន្តទៀត ។

## ៥.៣.៨ នាយកដ្ឋានព័ត៌មានវិទ្យា (ពមវ)

### ៥.៣.៨.១. បច្ចុប្បន្នភាពនៃគេហទំព័ររបស់ កសស

យោងតាមការពិនិត្យព័ត៌មានពាក់ព័ន្ធនឹងសកម្មភាព សមិទ្ធផលការងារ និងការអភិវឌ្ឍន៍ដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ កសស សវនករបានសង្កេតឃើញមានភាពយឺតយ៉ាវ កំហុសឆ្គងតួលេខ និងចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដូចខាងក្រោម៖ ១) ការចូលរួមក្នុងការងារសង្គម (CSR "Corporate Social Responsibility") របស់ កសស នៅលើទំព័រដើម (Homepage) មានសកម្មភាពត្រឹមឆ្នាំ ២០១៩; ២) តារាងស្ថិតិបរិមាណទំនិញនិងកុងតែន័រឆ្លងកាត់ត្រូវបានចុះផ្សាយត្រឹមឆ្នាំ ២០១៨; ៣) ទំហំផ្ទៃដីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានចុះផ្សាយចំនួន ៦៨ ហិកតារ ដែលបច្ចុប្បន្នមានត្រឹម ៦៣.២ ហិកតារ; ៤) រូបភាព Background ក្នុង link ផ្សេងៗទៀតនៅមិនទាន់បានប្តូរថ្មី (រូបភាពចាស់តាំងពីចំណតផែពហុបំណង នៅមិនទាន់បានសាងសង់រួច); ៥) រថយន្តស្ទូចចល័តលើគែមផែ (QC) ត្រូវបានចុះចំនួន ៤ គ្រឿង ដែលបច្ចុប្បន្នមាន ៥ គ្រឿង; ៦) ច្បាប់និងបទប្បញ្ញត្តិផ្សេងៗនៅមិនទាន់បាន Update ទាន់ពេល; ៧) ផែនការអភិវឌ្ឍន៍ទាំង ៥ គម្រោងដែលកំពុងផ្សព្វផ្សាយក្នុងគេហទំព័រ ត្រូវបានបញ្ចប់តាំងពីឆ្នាំ ២០១៧; ៨) ពុំទាន់បាន Update ដៃគូអាជីវកម្ម/ចំនួនក្រុមហ៊ុន Shipping Lines ដែលបានចុះកិច្ចព្រមព្រៀងជាមួយ កសស គ្រប់ចំនួន; ៩) នៅមិនទាន់បាន Update តួលេខ/ចំនួនអ្នកចូលទស្សនា ព័ត៌មាននីមួយៗនៅក្នុងគេហទំព័ររបស់ កសស ។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមសេចក្តីសម្រេចលេខ ១១៥ សសរ/ កសស/ពមវ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២០ ស្តីពីការរៀបចំរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ចរបស់បណ្តាការិយាល័យនៃនាយកដ្ឋានព័ត៌មានវិទ្យា ដែលត្រូវចុះប្រមូល និងរៀបចំមាតិកាព័ត៌មាន រូបភាព វីដេអូ និងឯកសារនានាដើម្បីផ្សព្វផ្សាយអំពីសកម្មភាព និងសមិទ្ធផលការងារពាក់ព័ន្ធនឹង កសស តាមរយៈគេហទំព័រនិងប្រព័ន្ធបណ្តាញសង្គម។

ករណីនេះបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារផ្ទាល់ក្នុងក្របខ័ណ្ឌការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍ នៃនាយកដ្ឋានព័ត៌មានវិទ្យា ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្ត សេចក្តីសម្រេចស្តីពីការរៀបចំរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ចរបស់សវនដ្ឋាន។

យោងបរិបទខាងលើ ថ្នាក់ដឹកនាំសវនដ្ឋានគួរណែនាំការិយាល័យជំនាញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ឱ្យបន្តពិនិត្យមាតិកាព័ត៌មាន រូបភាព វីដេអូ និងឯកសារនានាឡើងវិញនិង Update ព័ត៌មានពាក់ព័ន្ធនឹងសកម្មភាព សមិទ្ធផលការងារ និងការអភិវឌ្ឍន៍ដែលបានផ្សព្វ ផ្សាយក្នុងគេហទំព័រ និងបណ្តាញសង្គមរបស់ កសស ក្នុងរយៈពេលកន្លងមកឱ្យបានសមស្របនិងទាន់ពេលវេលា។

*នាយកដ្ឋានព័ត៌មានវិទ្យានឹងធ្វើការ Update Website ឡើងវិញឱ្យរួចរាល់នៅក្នុងខែមករា ឆ្នាំ ២០២៣ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសទី ១ ឆ្នាំ ២០២៣ ។

**៥.៣.៨.២. កម្មវិធី Mobile App (Mobile Application Program) របស់ កសស**

តាមការចុះពិនិត្យ និងសម្ភាសន៍មន្ត្រីជំនាញ ក្នុងក្របខ័ណ្ឌនាយកដ្ឋានព័ត៌មានវិទ្យា សវនករបានសង្កេតឃើញថា ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ កសស កាលពីដើមត្រីមាសទី ២ ឆ្នាំ ២០២២ សវនដ្ឋានបានបង្កើតកម្មវិធី Mobile App (Application Program) ថ្មីមួយដែលមាន ៦ (ប្រាំមួយ) Menu សំខាន់ៗដូចខាងក្រោម៖ ១) Gate Registration, ២) Container Information, ៣) Vessel, ៤) News Feed , ៥) Report, និង ៦) Camera ដោយក្នុងចំណោម Menu ទាំង ៦ មាន Menu ៤ ស្តីពី Gate Registration, Container Information, Vessel និង News Feed ត្រូវបានធ្វើរួចរាល់ហើយ ប៉ុន្តែនៅមិនទាន់បានប្រើប្រាស់ជាផ្លូវការនៅឡើយ ពីព្រោះសវនដ្ឋានត្រូវធ្វើការកែសម្រួលលក្ខណៈបច្ចេកទេសបន្ថែមទៀត ។ ដោយឡែក Menu ២ ទៀតស្តីពី Report និង Camera នៅមិនទាន់បានធ្វើរួចរាល់នៅឡើយទេ ។

ដើម្បីអនុលោមតាមកំពង់ផែនានាក្នុងតំបន់ និងឆ្លើយតបតាមតម្រូវការរបស់ កសស ក៏ដូចជាអតិថិជន និងអ្នកប្រើប្រាស់ផែ សវនដ្ឋានគួរបន្តធ្វើ Menu ២ ទៀតស្តីពី Report និង Camera អោយបានឆាប់ដើម្បីបានដាក់ប្រើប្រាស់ក្នុងពេលដំណាលគ្នា ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីទទួលបន្ទុកការងារ ក្នុងក្របខ័ណ្ឌការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍នៃនាយកដ្ឋានព័ត៌មានវិទ្យា ត្រូវធ្វើការសិក្សាអំពីលក្ខណៈបច្ចេកទេស និងតម្រូវការសំខាន់ៗរបស់នាយកដ្ឋានពាក់ព័ន្ធក្នុងក្របខ័ណ្ឌ កសស បន្ថែមទៀត ។

កត្តាខាងលើអាចបណ្តាលឱ្យខាតបង់ពេលវេលា ក្នុងការងារគ្រប់គ្រងនិងសម្របសម្រួលកិច្ចប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ កសស ។

សវនដ្ឋានគួរជំរុញការងារខាងលើឱ្យបានឆាប់រហ័ស និងសមស្របតាមទំហំការងារ ក៏ដូចជាតម្រូវការរបស់ កសស និងអតិថិជនដែលកំពុងប្រើប្រាស់សេវាកំពង់ផែ ។

*នាយកដ្ឋាននឹងស្នើសុំថ្នាក់ដឹកនាំដាក់ Mobile App ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៣ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មនៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៥.៣.៩ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស (តសព)

**៥.៣.៩.១ របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ក្នុងត្រីមាសទី ៣ ឆ្នាំ ២០២២ នៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (តសព)**

យោងតាមការពិនិត្យរបាយការណ៍ ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ក្នុងត្រីមាសទី ៣ (កក្កដា-សីហា) ឆ្នាំ ២០២២ នៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ និងការចុះពិនិត្យស្ថានភាពទីតាំងផ្ទាល់

សវនករបានសង្កេតឃើញចំណូលសរុប ដែលទទួលបានពីការជួលរោងចក្រ ឃ្លាំង ដីឡូត៍ និងការិយាល័យចំនួន 645,799.93 USD ដោយរាប់បញ្ចូលទាំង VAT 10% ។ បន្ថែមលើនេះ សវនដ្ឋានបានរៀបចំផែនការសំអាត ថែទាំ និងជួសជុលអាគារ Service Apartment ចំនួន ០៨ Units ស្មើនឹង ៨៤ បន្ទប់ជាប្រចាំ និងអាគារអន្តេវាសិកដ្ឋាន (Dormitory) ចំនួន ០២ Units ស្មើនឹង ៩២ បន្ទប់តាមផែនការ Periodical Maintenance រៀបចំប្រជុំដោះស្រាយបញ្ហាប្រចាំខែ (Tenant Meeting) ស្នើសុំបញ្ជាក់សិទ្ធិជួលរយៈពេលវែងជូនក្រុមហ៊ុន Aeon Mall រួចរាល់ ផ្តល់ព័ត៌មានជូន Advisor Team ដើម្បីផលិត Promotion Tolls ចូលរួមប្រជុំស្តីពីវឌ្ឍនភាពគម្រោង Free Port ជាមួយអង្គការ JICA, GDCE និងក្រុមហ៊ុន Aeon Mall ព្រមទាំងកំណត់បញ្ហាប្រឈមនិងដំណោះស្រាយ និងទិសដៅការងារសម្រាប់ត្រីមាសទី ៤ ឆ្នាំ ២០២២ ។ល។

ពាក់ព័ន្ធនឹងលទ្ធផលការងារខាងលើ សវនករបានពិនិត្យឃើញថាតំបន់សេដ្ឋកិច្ចពិសេសនៅមានការងារមួយចំនួនដែលត្រូវបំពេញបន្ថែម រួមមានការបើកច្រកទ្វារថ្មីមួយទៀតនៅជិតការដ្ឋានសាងសង់របស់ក្រុមហ៊ុន Aeon Mall ការបន្ថែមកម្លាំងសន្តិសុខដើម្បីយាមល្បាតឱ្យបានទៀតទាត់ និងការបង្កើនប្រសិទ្ធភាពថាមពល ពីព្រោះបណ្តាញភ្លើងអគ្គិសនីនៅក្នុង តសព ក្នុងរយៈពេលកន្លងមកមានភាពអាក់អួលគួរឱ្យកត់សម្គាល់ ហើយក្នុងពេលឆាប់ៗខាងមុខនេះ កសស ក៏ត្រូវផ្គត់ផ្គង់ថាមពលអគ្គិសនីជូនក្រុមហ៊ុន Aeon Mall តាមរយៈតសព ផងដែរ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមលក្ខន្តិកៈ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៩ ក្នុងប្រការ ៥ ស្តីពីកម្មវត្ថុអាជីវកម្មៈ កសស មានកម្មវត្ថុអាជីវកម្ម សេវាកម្មកំពង់ផែ ព្រមទាំងគ្រប់គ្រង ថែទាំឋបនីយកណ្ឌផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍន៍ សម្រាប់តម្រូវការនៃពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សេវាកម្មទេសចរណ៍និងអ្នកដំណើរ ព្រមទាំងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឱ្យ កសស បានរីកចម្រើននិងលូតលាស់ទៅមុខ ។

ភាពយឺតយ៉ាវនៃការរៀបចំបែបបទ ស្នើសុំបំពេញការងារខាងលើនេះ អាចបណ្តាលមកពីកង្វះខាតបុគ្គលិកនៅក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

ប្រការនេះ អាចបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិរបស់ កសស ប៉ះពាល់ដំណើរការធុរកិច្ចនិងបាត់បង់ចំណូលអាជីវកម្មរបស់ កសស ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឱ្យរៀបចំតារាងពេលវេលា/ផែនការសមស្រប ដើម្បីងាយស្រួលក្នុងការចុះពិនិត្យ សំអាត ថែរក្សា និងជួសជុលផ្នែកខូចខាតនៃ អាគារអន្តេវាសិកដ្ឋាន (Dormitory) ឱ្យបានទៀងទាត់ និងបន្តផ្សព្វផ្សាយអំពីសក្តានុពល តសព ដើម្បីទាក់ទាញវិនិយោគិន និងបង្កើនប្រភពចំណូលជូន កសស បន្ថែមទៀត ។

*នាយកដ្ឋាននិងបន្តអនុវត្តផែនការថែទាំ ជួសជុលសម្បទាបន្តទៀត ។ ជាពិសេស Dormitory បន្តទៀតតាមរូបភាព Preventive Nature រួមទាំងបរិវេណជុំវិញនិងបន្តផ្សព្វផ្សាយ តសព ដើម្បីទាក់ទាញ Foreign Direct Investment (FDI) បន្ថែមទៀត ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្ទាប់ទៀត ។

៥.៣.៩.២ ស្ថានភាពបរិស្ថាននៅជុំវិញបរិវេណអាគារ Service Apartment និង អន្តេវាសិកដ្ឋាន (Dormitory)

តាមការចុះពិនិត្យស្ថានភាពបរិស្ថាននៅជុំវិញបរិវេណអាគារ Service Apartment និង អន្តេវាសិកដ្ឋាន (Dormitory) សវនករបានសង្កេតឃើញសវនដ្ឋាន កំពុងរៀបចំស្តារភក់/យកដីចេញពីប្រព័ន្ធលូជុំវិញបរិវេណអាគារ កាត់ស្មៅក្រាស់ៗដែលដុះគ្របលើផ្លូវចូល-ចេញតាមច្រកទ្វារទី ៣ ដើម្បីសម្រួលលំហូរទឹកភ្លៀង និងយក

កូនឈើ និង/ឬ វល្លិ ដែលដុះក្នុងទទឹកភ្លៀងជុំវិញដំបូល អាគារ ប៉ុន្តែដោយកម្លាំងពលកម្មមានកម្រិត សវនដ្ឋាននៅពុំទាន់បានរៀបចំស្តារប្រឡាយ និងសំអាតស្លែដែលកាន់ជាប់ផ្ទៃជញ្ជាំងជុំវិញអាគារនៅឡើយ ។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមបទបញ្ជាផ្ទៃក្នុងរបស់ កសស លេខ ០០១.បបផក/កសស/របប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងប្រការ V ចំណុចទី ៣ ត្រូវប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារ មធ្យោបាយ ឬ ឧបករណ៍របស់ កសស ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាត ថែរក្សានិងទុកដាក់ឱ្យបានគង់វង្ស។

កត្តានេះ អាចបណ្តាលមកពីពុំមានកម្លាំងពលកម្ម/បុគ្គលិកសំអាតនិងអនាម័យគ្រប់គ្រាន់ ។

ប្រការនេះ អាចបណ្តាលឱ្យស្ទះលំហូរទឹកភ្លៀង ប៉ះពាល់សោភ័ណភាពអាគារ មិនមានភាពទាក់ទាញ និងការប្រើប្រាស់ពុំទាន់មានប្រសិទ្ធភាព ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរបន្តណែនាំមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឱ្យចុះពិនិត្យស្ថានភាពបរិស្ថាន និងសម្ភារប្រើប្រាស់គ្រប់ប្រភេទនៅក្នុងអាគារ Service Apartment និងអន្តេវាសិកដ្ឋាន (Dormitory) ក៏ដូចជា តសព ទាំងមូលឱ្យបានទៀងទាត់ ដើម្បីឱ្យសវនដ្ឋានអាចចាត់វិធានការសំអាតនិងជួសជុលបានទាន់ពេលវេលា ។

*នាយកដ្ឋាននិងបន្តបញ្ជូនអ្នកទទួលបន្ទុក ចុះត្រួតពិនិត្យទៅតាមតារាងពេលវេលាថែទាំដើម្បីរក្សាបាននូវសម្ផទាដែល តសព អាចប្រើប្រាស់បានតាមអាយុកាលរបស់វា និងជួសជុលទាន់ពេល ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្ទាប់ទៀត ។

## ៥.៣.១០ នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី (គ្រចយអន)

### ៥.៣.១០.១ វគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញបើកបរគ្រឿងចក្រ

យោងតាមការឆ្លើយតប ក្នុងកម្រងសំណួរស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សវនករបានកត់សម្គាល់ឃើញថា គិតត្រឹមត្រីមាសទី ៣ ឆ្នាំ ២០២២ នេះ សវនដ្ឋាននៅពុំទាន់បានរៀបចំបើកវគ្គបណ្តុះបណ្តាលបន្ថែមអំពីបច្ចេកទេស និងជំនាញបើកបរគ្រឿងចក្រធន់ធ្ងន់ រួមទាំងបច្ចេកទេសអគ្គិសនី ដល់កម្មករ/ប្រតិបត្តិករគ្រឿងចក្រ និងបុគ្គលិកអគ្គិសនីនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ ឆ្នាំ ២០២២ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ក្នុងឧបសម្ព័ន្ធទី ៨: ផែនការបណ្តុះបណ្តាលធនធានមនុស្សឆ្នាំ ២០២២ ចំណុច ក-២ ហ្វឹកហ្វឺនបើកបរគ្រឿងចក្រធន់ធ្ងន់ និងចំណុច ក-២២ ស្តីពីទ្រឹស្តីត្រួតពិនិត្យ ថែទាំ-ជួសជុល គ្រឿងចក្រធន់ធ្ងន់ ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីជំនាញក្នុងក្របខ័ណ្ឌសវនដ្ឋាន មានភាពមមាញឹកក្នុងការងារជួសជុល ថែទាំ គ្រឿងចក្រ និងឋបនីយភណ្ឌអគ្គិសនីសំខាន់ៗ ដែលជាការងារអាទិភាពក្នុងការបម្រើប្រតិបត្តិការអាជីវកម្មសេវាកម្មរបស់ កសស ។

ទោះជាយ៉ាងណាក៏ដោយ កត្តានេះអាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្តផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុរបស់ កសស ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួររៀបចំផែនការ និងស្នើសុំថ្នាក់ដឹកនាំ កសស បើកវគ្គបណ្តុះបណ្តាលអំពី បច្ចេកទេសនិងជំនាញបើកបរ រួមទាំងបច្ចេកទេសអគ្គិសនី និងទ្រឹស្តីត្រួតពិនិត្យ ថែទាំ-ជួសជុល គ្រឿងចក្រធន់ធ្ងន់និងអគ្គិសនី ដល់កម្មករ/ប្រតិបត្តិករ និងបុគ្គលិកអគ្គិសនីស្របតាមគោលការណ៍ ដូចមានចែងនៅក្នុងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុឆ្នាំ ២០២២ របស់ កសស ។

*១. ការបណ្តុះបណ្តាលបច្ចេកទេសអគ្គិសនី*

- *ដោយសារស្ថានភាពការងារ មានភាពមមាញឹកខ្លាំង គួបផ្សំនឹងចំនួនបុគ្គលិកមានចំនួនតិច ដូច្នេះនាយកដ្ឋានមិនអាចមានឱកាស និងធ្វើការបែងចែកកម្លាំងសម្រាប់ទទួលការបណ្តុះបណ្តាលបានឡើយ ។*

*២. ការបណ្តុះបណ្តាលបើកបរគ្រឿងចក្រ*

- *ការបណ្តុះបណ្តាលត្រូវបានពន្យាពេល ដោយសារនាយកដ្ឋានទើបតែមានការរួមបញ្ចូលរវាងអគ្គិសនី និងគ្រឿងចក្រនិងជួនជាមួយគ្នានេះផងដែរ អតីតអ្នកទទួលបន្ទុកកិច្ចការបណ្តុះបណ្តាលមានជម្ងឺប្រចាំកាយត្រូវសម្រាកព្យាបាលអស់មួយរយៈពេលយូរ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម/វិធានការបន្ទាប់របស់សវនដ្ឋាន ។

### ៥.៣.១០.២ របាយការណ៍ម៉ាស៊ីនភ្លើងនិងការថែទាំ

យោងតាមរបាយការណ៍ម៉ាស៊ីនភ្លើង ការថែទាំ និងការសម្ភាសន៍មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រង សវនករបានពិនិត្យឃើញ កសស បំពាក់ម៉ាស៊ីនភ្លើងសរុបចំនួន ១៣ (ដប់បី) គ្រឿងដើម្បីផ្គត់ផ្គង់ថាមពលអគ្គិសនីនៅក្នុងតំបន់ កសស ទាំងមូល ។ ម៉ាស៊ីនភ្លើងទាំងនេះរួមមាន៖

| | |
|---|---|
| ១. IVECO 200 KVA | គ្មានលេខសម្គាល់ |
| ២. IVECO 300 KVA | គ្មានលេខសម្គាល់ |
| ៣. IVECO 300 KVA | គ្មានលេខសម្គាល់ |
| ៤. MITSUBISHI 250 KVA | លេខសម្គាល់ 201 |
| ៥. MITSUBISHI 250 KVA | លេខសម្គាល់ 202 |
| ៦. IVECO 500 KVA | លេខសម្គាល់ 306 |
| ៧. MITSUBISHI 1000 KVA | លេខសម្គាល់ 307 |
| ៨. MITSUBISHI 1000 KVA | លេខសម្គាល់ 308 |
| ៩. MITSUBISHI 1000 KVA | លេខសម្គាល់ 309 |
| ១០. MITSUBISHI 1000 KVA | លេខសម្គាល់ 310 |
| ១១. MITSUBISHI 1000 KVA | លេខសម្គាល់ 311 |
| ១២. MITSUBISHI 1000 KVA | លេខសម្គាល់ 312, និង |
| ១៣. MITSUBISHI 1000 KVA | លេខសម្គាល់ 313 ។ |

ពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងថែទាំម៉ាស៊ីនភ្លើងខាងលើ សវនដ្ឋានបានរៀបចំផែនការ/តារាងពេលវេលាដោយមានការកំណត់កាលបរិច្ឆេទ លេខសម្គាល់ អំណានចាស់/ថ្មី ដើម្បីប្តូរប្រេងម៉ាស៊ីន តម្រងប្រេង លាងសំអាត បាញ់ខ្លាញ់ បូមធូលី ។ល។ និងគម្រោងពេលថែទាំ ជួសជុលត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

ជាមួយនេះ ចាប់តាំងពីពេលដែល កសស បានប្រើប្រាស់បណ្តាញអគ្គិសនីកម្ពុជា (EDC) ពីថ្ងៃទី ៣១ ខែមីនា ដល់ត្រីមាសទី ៣ ឆ្នាំ ២០២២ សវនដ្ឋានបានរៀបចំចាត់ចែងការងារនិងត្រៀមលក្ខណៈដូចខាងក្រោម៖ ១) ត្រៀមម៉ាស៊ីនភ្លើង ០៥ (ប្រាំ) គ្រឿងម៉ាក MITSUBISHI 1000 KVA លេខសម្គាល់ 308, 309, 310, 311 និង 312 ដើម្បីប្រើប្រាស់នៅពេលអគ្គិសនីកម្ពុជាមានភាពរអាក់ រអួល/ដាច់ការផ្គត់ផ្គង់ជាយថាហេតុ, ២) រៀបចំជួសជុលម៉ាស៊ីនភ្លើង ០២ (ពីរ) គ្រឿងរួមមាន MITSUBISHI 1000 KVA លេខសម្គាល់ 307 (ខូចនៅថ្ងៃទី ២៥ ខែ

ឧសភា ឆ្នាំ ២០២១) កំពុងជួសជុលធំនៅភ្នំពេញ និង MITSUBISHI 1000 KVA លេខសម្គាល់ 313 (ខូចនៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២១) កំពុងរៀបចំយកទៅជួសជុលនៅភ្នំពេញ។

ទោះជាយ៉ាងណាក៏ដោយ សវនករបានសង្កេតឃើញថា គិតចាប់តាំងពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២១ រហូតដល់ត្រីមាសទី ៣ ឆ្នាំ ២០២២ នេះម៉ាស៊ីនភ្លើងម៉ាក MITSUBISHI 1000 KVA លេខសម្គាល់ 307 ដែលបាននិងកំពុងជួសជុលធំនៅភ្នំពេញនោះ នៅពុំទាន់រួចរាល់នៅឡើយ។

ប្រការខាងលើអាចបណ្តាលមកពីក្រុមហ៊ុនផ្គត់ផ្គង់ មានកង្វះខាតគ្រឿងបន្លាស់ ឬ បញ្ហាបច្ចេកទេសរបស់ផ្នែក Mechanics ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពការងារ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ កសស ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនផ្គត់ផ្គង់ និងជួយជំរុញឱ្យក្រុមជាងធ្វើការជួសជុលឱ្យបានឆាប់។

*នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី និងសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីធ្វើទំនាក់ទំនងជាមួយក្រុមជាង និងជំរុញការងារជួសជុលម៉ាស៊ីនភ្លើងទាំងពីរគ្រឿងឱ្យបានឆាប់។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មនៅត្រីមាសបន្ទាប់ទៀត ។

## ៥.៣.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

### ៥.៣.១១.១ ការគោរពគោលការណ៍វិន័យ និងពេលវេលាធ្វើការរបស់ និយោជិត កម្មករ កសស ដែលបម្រើការងារផ្នែកអាជីវកម្ម និងផ្នែកប្រយោល (នាយកដ្ឋាន)

តាមការណែនាំរបស់រាជរដ្ឋាភិបាល កសស បានចូលរួមអនុវត្តវិធានការការពារនិងរក្សាគម្លាតសុវត្ថិភាពសង្គម ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដល់និយោជិត កម្មករយ៉ាងខ្ជាប់ខ្ជួន។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីពេលដែលរាជរដ្ឋាភិបាល បានប្រកាសបើកប្រទេសជាសាកលឡើងវិញ សវនករបានសង្កេតឃើញនិយោជិត កម្មករ មួយចំនួននៅបន្តអូសបន្លាយពេលវេលាធ្វើការ ពិសេស ផ្នែកប្រយោល (នាយកដ្ឋាន) នៅមិនទាន់បានអនុវត្តគោលការណ៍វិន័យ ជាប្រក្រតីភាពឡើងវិញនៅឡើយ ។

ប្រការខាងលើ អាចនាំឱ្យមានគម្លាតអនុលោមភាពគោលការណ៍ ដែលបានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ កសស លេខ ០០១.បបផក/កសស/បេ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងប្រការ I ចំណុចទី ៦៖ និយោជិត កម្មករ កសស ត្រូវគោរពទង់ជាតិនៅរៀងរាល់ពេលព្រឹក លើកលែងតែមានបញ្ហាបេសកកម្ម ឬ ធុរៈចាំបាច់បន្ទាន់ដែលត្រូវបានចាត់តាំង ឬ ទទួលស្គាល់ដោយមន្ត្រីគ្រប់គ្រងផ្ទាល់ និងប្រការ II ចំណុច ២.២ ស្តីពីថេរៈវេលាបំពេញការងារ (ពេលម៉ោងផ្នែកប្រយោល "នាយកដ្ឋាន") ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១៦:០០ ដោយឈប់សម្រាកពីម៉ោង ១២:០០ ដល់ម៉ោង ១៣:០០ រសៀល ។

ករណីនេះ អាចបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតែបន្តកើតមាន ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ការងារ និងប្រសិទ្ធភាពអនុវត្តបទបញ្ជាផ្ទៃក្នុង កសស ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរពិចារណារៀបចំឱ្យមានការគោរពទង់ជាតិឡើងវិញ ដើម្បីពង្រឹងវិធានការវិន័យ និងពេលម៉ោងបម្រើការងារស្របតាមគោលការណ៍ ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ កសស ។

*នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលយកអនុសាសន៍របស់សវនកម្មផ្ទៃក្នុង ហើយនឹងខិតខំពង្រឹងវិធានការវិន័យ និងពេលម៉ោងបម្រើការងារស្របតាមគោលការណ៍ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ កសស។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

### ៥.៣.១១.២ តារាងទូទាត់ប្រាក់បៀវត្សនិយោជិតក្នុងក្របខ័ណ្ឌ កសស

យោងតាមតារាងទូទាត់ប្រាក់បៀវត្សនិយោជិត ក្នុងក្របខ័ណ្ឌ កសស សម្រាប់ខែតុលានិងខែវិច្ឆិកា ឆ្នាំ ២០២២ សវនករបានពិនិត្យឃើញថា សវនដ្ឋាននៅពុំទាន់បានបន្ថែមជួរ (*Column*) ស្ដីពីប្រាក់ទ្រទ្រង់សុខភាព សម្រាប់កម្មករដែលប្រើប្រាស់ពលកម្មផ្ទាល់ (ក្របខ័ណ្ឌផលិត) ចំនួន ៥០,០០០ រៀល/នាក់ខែ សម្រាប់កម្មករទាំង ៣ កងនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ និងកម្មករបច្ចេកទេសលើកដាក់នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នៅក្នុងតារាងប្រាក់បៀវត្សប្រចាំខែនៅឡើយ ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមសេចក្ដីកំណត់លេខ ០៦៦ សកណ/កសស/រប.ប ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៩ ស្ដីពីការផ្ដល់ប្រាក់ទ្រទ្រង់សុខភាព ក្នុងប្រការ ១ ផ្ដល់ប្រាក់ទ្រទ្រង់សុខភាពជូនកម្មករ ដែលប្រើប្រាស់ពលកម្មផ្ទាល់ (ក្របខ័ណ្ឌផលិត) ចំនួន ៥០,០០០ (ហាសិបពាន់រៀល) រៀល/នាក់ខែ រួមមាន ៖ ១) កម្មករទាំង ៣ កងនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ២) កម្មករបច្ចេកទេសលើកដាក់ នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រនិងប្រការ ២ ការឧបត្ថម្ភប្រាក់ទ្រទ្រង់សុខភាពនេះ ត្រូវបានគិតបញ្ចូលក្នុងតារាងប្រាក់បៀវត្សប្រចាំខែ ។

ករណីនេះ អាចបណ្ដាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

កត្តានេះ អាចបណ្ដាលឱ្យខាតបង់អត្ថប្រយោជន៍កម្មករ ក្នុងក្របខ័ណ្ឌផលិតនិងប៉ះពាល់ប្រសិទ្ធភាពអនុវត្តសេចក្ដីកំណត់ ស្ដីពីការផ្ដល់ប្រាក់ទ្រទ្រង់សុខភាពរបស់ កសស ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឱ្យពិនិត្យនិងរៀបចំបញ្ចូលជួរ (*Column*) ស្ដីពីប្រាក់ទ្រទ្រង់សុខភាព សម្រាប់កម្មករក្នុងក្របខ័ណ្ឌផលិតខាងលើ ក្នុងតារាងប្រាក់បៀវត្សប្រចាំខែ ស្របតាមសេចក្ដីកំណត់ស្ដីពីការផ្ដល់ប្រាក់ទ្រទ្រង់សុខភាព និងលក្ខន្តិកៈបុគ្គលិករបស់ កសស ។

*ករណីនេះ ដោយសារនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស បានប្រើប្រាស់ឃ្លា "ប៉ះពាល់សុខភាពជំនួសពាក្យ ប្រាក់ទ្រទ្រង់សុខភាព" នៅក្នុងជួរឈរ (Column) នៃតារាងបៀវត្ស ។*

*នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលយកអនុសាសន៍ និងកែសម្រួលពាក្យពេចន៍ឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារ នៃសេចក្ដីកំណត់លេខ ០៦៦ សកណ/កសស/រប.ប ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៥.៣.១២ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ

### ៥.៣.១២.១ ឯកសារដេញថ្លៃផ្គត់ផ្គង់ទំនិញសម្រាប់ឆមាសទី ១ ឆ្នាំ ២០២២

យោងតាមការពិនិត្យ ឯកសារដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ស្ដីពីការផ្គត់ផ្គង់ទំនិញសម្រាប់ឆមាសទី ១ ឆ្នាំ ២០២២ សវនករបានកត់សម្គាល់ឃើញមានភាពខ្វះចន្លោះ ឯកសារមួយចំនួនពាក់ព័ន្ធនឹងសេចក្ដីប្រកាសស្ដីពីក្រមសីលធម៌លទ្ធកម្មដូចខាងក្រោម៖

- ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីក្រមសីលធម៌លទ្ធកម្ម។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីក្រមសីលធម៌លទ្ធកម្ម ក្នុងប្រការ ៨ ចែងថា គណៈកម្មាធិការលទ្ធកម្មត្រូវចុះហត្ថលេខា លើសេចក្ដីប្រកាសស្ដីពីក្រមសីលធម៌លទ្ធកម្ម នៅគ្រប់ពេលចូលរួមក្នុងការវាយតម្លៃសំណើដេញថ្លៃ ។

ករណីនេះ អាចបណ្ដាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារលទ្ធកម្ម។

ប្រការនេះ អាចបណ្ដាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្ត ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីក្រមសីលធម៌លទ្ធកម្ម។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំមន្ត្រីទទួលបន្ទុកការងារលទ្ធកម្ម ឱ្យអនុវត្តតាមប្រកាសស្ដីពីក្រមសីលធម៌លទ្ធកម្ម នៅគ្រប់ពេលចូលរួមក្នុងការវាយតម្លៃសំណើដេញថ្លៃ ស្របតាមប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

*សវនដ្ឋានសូមទទួលយក និងខិតខំអនុវត្តឱ្យបានពេញលេញតាមអនុសាសន៍ របស់សវនករសម្រាប់ឆ្នាំបន្តបន្ទាប់ទៅមុខទៀត ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

### ៥.៣.១២.២ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២

យោងតាមការពិនិត្យ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ សវនករបានកត់សម្គាល់ឃើញ សវនដ្ឋានដាក់ចេញនូវផែនការប្រចាំឆ្នាំ និងលទ្ធផលអនុវត្តដាក់ស្ដែងដោយធ្វើការប្រៀបធៀបបរិមាណទំនិញ/កុងតែន័រឆ្លងកាត់ និងចំនួននាវាចូលចតជាមួយបរិមាណឆ្នាំ ២០២១ ដើម្បីកំណត់អត្រាកំណើន/ថយចុះនៃការិយបរិច្ឆេទនីមួយៗ ។ ក្នុងនេះ បរិមាណទំនិញឆ្លងកាត់មានចំនួន ៧,០០៣,១៥៨ តោន កើនឡើង ១.៦៦% បរិមាណកុងតែន័រឆ្លងកាត់ ចំនួន ៧៥០,១៤៨ *TEUs* កើនឡើង ២.៤៣% និងចំនួននាវាចូលចតចំនួន ១,៤៤២ គ្រឿងថយចុះ ០.៤១% ។ ប៉ុន្តែ ភ្ជាប់នឹងករណីខាងលើ សវនករបានសង្កេតឃើញពុំមានការបញ្ជាក់គោលដៅ និងប្រភពនាំទំនិញ/កុងតែន័រ ចូល-ចេញ នៅក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារនោះទេ ។

ប្រការខាងលើ អាចបណ្ដាលឱ្យមានភាពមិនច្បាស់លាស់ ក្នុងការកត់សម្គាល់បរិមាណទំនិញ/កុងតែន័រនាំចូល-នាំចេញនៅតាមគោលដៅ និងប្រភពសំខាន់ៗមួយចំនួនដូចជា អាស៊ី អឺរ៉ុប និងអាមេរិកជាដើម ។ល។

មូលហេតុនេះ អាចបណ្ដាលមកពីនាយកដ្ឋានពាក់ព័ន្ធ ខកខានមិនបានផ្ដល់ឯកសារទំនិញ និង/ឬព័ត៌មានពាក់ព័ន្ធនឹងគោលដៅ និងប្រភពទំនិញ/កុងតែន័រនាំចូល-នាំចេញទាន់ពេលវេលា។

កត្តានេះ អាចនាំឱ្យមានការយល់ច្រឡំ និងពិបាកកត់សម្គាល់គោលដៅនាំទំនិញ/កុងតែន័រ ចូលនិងប្រភពនាំចេញច្បាស់លាស់ ។

សវនដ្ឋានគួរសហការ/ស្នើសុំឯកសារទំនិញ ដែលមានឈ្មោះប្រទេសនាំចូល-នាំចេញច្បាស់ លាស់ដើម្បីកំណត់គោលដៅនាំទំនិញ/កុងតែន័រ ចូលនិងប្រភពនាំចេញបានសមស្រប ។

- *នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ បានទទួលប្រភេទទំនិញ ប្រភព និងប្រទេសគោលដៅ ពីនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ និងនាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រដោយកត់ត្រាតាម BL & Manifest ។ ទំនិញភាគច្រើនឆ្លងកាត់តាមកំពង់ផែសិង្ហបុរី នៅពេលនោះក្រុមហ៊ុនមួយចំនួនច្រើនតែប្រកាសគោលដៅនិងប្រភពមកពីកំពង់ផែសិង្ហបុរី ។ ប្រភេទទំនិញផ្សេងៗទៀត ច្រើនតែដាក់ក្នុងកុងតែន័រមួយដែលមានមុខទំនិញជាច្រើនមុខ។*
- *ករណីនេះ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ បានស្នើសុំឱ្យនាយកដ្ឋានពាក់ព័ន្ធ ពិនិត្យនិងសហការជាមួយក្រុមហ៊ុនដឹកជញ្ជូនបំពេញទិន្នន័យឱ្យបានច្បាស់លាស់សម្រាប់យកមកបំពេញបន្ថែម ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាននិងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៥.៣.១៣ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

### ៥.៣.១៣.១ របាយការណ៍ស្ថានភាពបំណុលអតិថិជនជំពាក់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ

យោងតាមរបាយការណ៍ស្ដីពីស្ថានភាពបំណុល ដែលអតិថិជនជំពាក់ កសស គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២ សវនករបានសង្កេតឃើញក្រុមហ៊ុនចំនួន ៣៤ ក្រុមហ៊ុនជំពាក់បំណុល កសស ជាទឹកប្រាក់សរុបចំនួន ៧,៣៤១,៤២១.៨១ ដុល្លារអាមេរិក ស្មើនឹង ៣០,២២៤,៦៣៣,៥៩១.៧៧ រៀល ។ បំណុលទាំងនេះ រាប់បញ្ចូលទាំងបំណុលរបស់ក្រុមហ៊ុន Shipping Lines ០៥ ក្រុមហ៊ុន និងក្រុមហ៊ុន Royal Railway Co., Ltd ចំនួន៖

១). ក្រុមហ៊ុន Maersk ជំពាក់ : ២,០៣៣,៨២០.៣៨ ដុល្លារអាមេរិក

២). ក្រុមហ៊ុន Arrow Shipping ជំពាក់ : ៣១៧,១៧៧.៦០ ដុល្លារអាមេរិក

៣). ក្រុមហ៊ុន SITC Container ជំពាក់ : ១,១៧២,២៩៧.៦៨ ដុល្លារអាមេរិក

៤). ក្រុមហ៊ុន Danaka Logistics Co., Ltd ជំពាក់ : ១,៥០៥,៥៥២.៦០ ដុល្លារអាមេរិក

៥). ក្រុមហ៊ុន STRAITS INTERNATIONAL PTE., Ltd ជំពាក់: ៨៣២,៦៧៩.១៩ ដុល្លារអាមេរិក; និង

៦). ក្រុមហ៊ុន Royal Railway Co., Ltd ជំពាក់ : ៣៨០,២៩៦.៤០ ដុល្លារអាមេរិក។

ប្រការខាងលើ នៅមិនទាន់អនុលោមពេញលេញតាមលក្ខខណ្ឌកិច្ចព្រមព្រៀង រវាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) និងក្រុមហ៊ុន Shipping Lines ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២២ ក្នុងប្រការ ៧ ចែងថា Line (s) ត្រូវពិនិត្យនិងចុះហត្ថលេខាលើវិក្កយបត្រក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ក្រោយពីបានបញ្ចប់ប្រតិបត្តិការផ្ទេរ-ផ្ទុកកុងតែន័រ និងត្រូវធ្វើការទូទាត់ក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃបន្ទាប់ពីបានចុះហត្ថលេខាលើវិក្កយបត្ររួច។ ប្រសិនបើ Line (s) មិនបានទូទាត់ថ្លៃឈ្នួលក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃក្រោយពីបានចុះហត្ថលេខាលើវិក្កយបត្រ នោះប្រតិបត្តិករ (កសស) មានសិទ្ធិផ្អាកសកម្មភាពនាវា ឬ ការបញ្ចេញកុងតែន័ររបស់ Line (s) រហូតដល់ Line (s) បានទូទាត់បំណុលរួចរាល់ ។

មូលហេតុខាងលើ អាចបណ្ដាលមកពីតំណាងក្រុមហ៊ុននាវា (Shipping Lines) ក្នុងស្រុកត្រូវការពេលវេលាបញ្ជូនវិក្កយបត្រទាំងអស់ទៅការិយាល័យ (Head Office) នៃក្រុមហ៊ុននាវាមេនៅក្រៅប្រទេសដើម្បីពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃវិក្កយបត្រ និងភាពត្រឹមត្រូវក្នុងការប្រើប្រាស់សេវា ។

កត្តានេះ អាចបណ្ដាលឱ្យប៉ះពាល់ដល់ ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងរវាង កសស និងបណ្ដាក្រុមហ៊ុននាវា ។

ថ្នាក់ដឹកនាំសវនដ្ឋាន ត្រូវខិតខំអនុវត្តឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរវាង កសស និងក្រុមហ៊ុននាវា (Shipping Lines) និងត្រូវខិតខំទារបំណុលឱ្យបានទាន់ពេលវេលា ។

***បំណុលដែលក្រុមហ៊ុននាវាមួយចំនួននៅជំពាក់ កសស រួមមាន៖***

- *ក្រុមហ៊ុននាវាមួយចំនួន ដែលមានតំណាងការិយាល័យនៅកម្ពុជា ត្រូវការពេលវេលា បញ្ជូនវិក្កយបត្រទាំងអស់ទៅក្រុមហ៊ុននាវាមេនៅក្រៅប្រទេស ដើម្បីធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់មុននឹងធ្វើការទូទាត់ប្រាក់ជូន កសស។ ជាមួយគ្នាផងដែរ ក្នុងការអនុវត្តកិច្ចព្រមព្រៀងរវាង កសស និងក្រុមហ៊ុននាវា គឺក្រុមហ៊ុននាវាបានតម្កល់ប្រាក់កក់ជូន កសស ។*
- *សវនដ្ឋានបានអនុវត្តជាប្រចាំ ដោយធ្វើលិខិតទារបំណុលជាទៀងទាត់ ចំពោះក្រុមហ៊ុននាវាណាដែលបានជំពាក់ កសស ។*
- *រហូតមកដល់បច្ចុប្បន្ន មិនមានក្រុមហ៊ុននាវាណាដែលជំពាក់បំណុល កសស ហើយមិនបានទូទាត់ជូន កសស នោះទេ គ្រាន់តែក្រុមហ៊ុននាវាត្រូវការពេលវេលាក្នុងការបញ្ជូនវិក្កយបត្រទៅក្រុមហ៊ុននាវាមេនៅក្រៅប្រទេសប៉ុណ្ណោះ ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

**៥.៣.១៣.២. តារាងសរុបសារពើភណ្ឌអចលនទ្រព្យ ឆ្នាំ ២០២២**

យោងតាមការពិនិត្យ តារាងសរុបសារពើភណ្ឌអចលនទ្រព្យ បញ្ចប់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២ សវនករបានកត់សម្គាល់ឃើញថា បណ្ដាគ្រឿងចក្រមួយចំនួនដូចជា៖ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនទៀតដែលអស់តម្លៃរំលស់ និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត នៅពុំទាន់មានការលើកសំណើសុំជម្រះបញ្ជី ចេញពីតារាងសារពើភណ្ឌរបស់ កសស នៅឡើយ ។

ប្រការខាងលើ នៅមិនទាន់អនុលោមតាមប្រកាសរបស់ **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** លេខ ០០២ សហវ.ប្រក ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ២០២០ ស្ដីពីវិធាននិងនីតិវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្នុងប្រការ ១២ ចែងថា ប្រភេទទ្រព្យសម្បត្តិរដ្ឋដូចមានចែងក្នុងប្រការ ១១ ក្រៅពីដីដែលជាកម្មវត្ថុនៃការអនុញ្ញាតឱ្យជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះមានស្ថានភាពចាស់ទ្រុឌទ្រោម ប្រើប្រាស់លែងកើត ខូចខាតធ្ងន់ធ្ងរ បាត់បង់ ឬ ខូចខាតធ្ងន់ធ្ងរ បាត់បង់ដោយមូលហេតុប្រធានស័ក្តិ ឬ ជាការផ្ទេរការប្រើប្រាស់រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ករណីនេះ អាចបណ្ដាលមកពីសវនដ្ឋាន កំពុងពិនិត្យផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌអចលនទ្រព្យដូចជា៖ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនទៀតដែលអស់តម្លៃរំលស់ និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត ជាមួយបណ្ដាសាមីនាយកដ្ឋានដែលប្រើប្រាស់ដើម្បីស្នើសុំជម្រះបញ្ជីចេញពីតារាងសារពើភណ្ឌរបស់ កសស ។

កត្តាខាងលើ អាចបណ្ដាលឱ្យរថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនទៀតដែលផុតកំណត់ប្រើប្រាស់ អស់តម្លៃរំលស់ និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើតស្ថិតនៅក្នុងបញ្ជីសារពើភណ្ឌអចលនទ្រព្យច្រើន និងប៉ះពាល់ប្រសិទ្ធភាពនៃការគ្រប់គ្រងអចលនទ្រព្យរបស់ កសស ។

សវនដ្ឋាន គួរស្នើសុំថ្នាក់ដឹកនាំ កសស ជម្រះចេញនូវ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់និងឧបករណ៍-សម្ភារមួយចំនួន ដែលផុតកំណត់នៃការប្រើប្រាស់ អស់តម្លៃរំលស់និងចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត ចេញពីបញ្ជីសារពើភណ្ឌរបស់ កសស ។

*សវនដ្ឋាន បានរៀបចំរួចរាល់នូវបញ្ជីសារពើភណ្ឌអចលនទ្រព្យ កសស ក្នុងឆ្នាំ ២០២២ ដោយបានបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (Standard Registration Management System "SARMIS") របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

*ចំពោះ រថយន្ត រថយន្តស្ទូច គ្រឿងចក្រលើកដាក់ និងឧបករណ៍-សម្ភារមួយចំនួនដែលបានបាត់បង់រូបរាងចាស់ទ្រុឌទ្រោម និងអស់តម្លៃរំលស់ សវនដ្ឋានបាននឹងកំពុងសហការជាមួយសាមីនាយកដ្ឋានដែលប្រើប្រាស់ដើម្បីពិនិត្យនិងកំណត់មុខសញ្ញាឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការសម្រេចពីថ្នាក់ដឹកនាំ កសស ដាក់ក្នុងរបៀបវារៈអង្គប្រជុំក្រុមប្រឹក្សាភិបាល កសស ដើម្បីពិនិត្យ និងសម្រេច ក្នុងការជម្រះចេញពីបញ្ជីសារពើភណ្ឌរបស់ កសស ស្របតាមប្រកាសលេខ ០០២ សហវ.ប្រក ស្ដីពី " វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ" ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម នៅត្រីមាសបន្តបន្ទាប់ទៀត ។

## ៦. សេចក្តីសន្និដ្ឋានរួម

នៅក្នុងអំឡុងពេលនៃការធ្វើសវនកម្មនេះ សវនករបានពិនិត្យឃើញសវនដ្ឋាននីមួយៗខិតខំប្រឹងប្រែងរៀបចំដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាព ផលិតភាពប្រតិបត្តិការនិងការទទួលខុសត្រូវ ។ ជាមួយនេះ ក្រុមការងារសវនកម្មបានសង្កេតឃើញថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកគ្រប់នាយកដ្ឋាន មានឆន្ទៈរួមសហការ និងយកចិត្តទុកដាក់បំពេញតួនាទី-ភារកិច្ចរបស់ខ្លួន ដោយអនុលោមតាមលក្ខន្តិកៈបុគ្គលិក កសស គោលការណ៍ច្បាប់និងបទប្បញ្ញត្តិ ជាធរមាន ។

## ៧. ផែនការសកម្មភាពកែលម្អ

ដើម្បីជានាប្រសិទ្ធភាពអនុវត្ត និងកែលម្អតាមអនុសាសន៍ដែលសវនករបានផ្តល់ជូន ថ្នាក់ដឹកនាំនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតែន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាលជារនិងសន្តិសុខ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានទីផ្សារ នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគ្រឿងចក្រ-យន្តសាស្ត្រអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ បានឯកភាពតាមផែនការសកម្មភាពកែលម្អ ដូចបានកំណត់នៅក្នុងតារាងនៃ **ឧបសម្ព័ន្ធទី ២** ។

ថ្ងៃព្រហស្បតិ៍ ០៩ កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តព្រះសីហនុ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៣

**បានឃើញ និងឯកភាព**
ខេត្តសៀមរាប ថ្ងៃទី...៣......ខែ..កុម្ភៈ.... ឆ្នាំ ២០២៣
**ប្រធានគណៈកម្មាធិការសវនកម្ម**

**ហ៊ុន មុន្នីវណ្ណា**

**ហ៊ុន មុន្នីវណ្ណា**

**នាយកសវនកម្មផ្ទៃក្នុង**

**ម៉ែន ចាន់**

# ផ្នែកទី ៦

# របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្ស ក្នុងការដាក់ជូនរបាយការណ៍របស់ខ្លួនរួមជាមួយ និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស" ឬ "ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

## ក្រុមហ៊ុន

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស" ឬ "ក្រុមហ៊ុន") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលរបស់ខ្លួន នៅក្នុងខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិបុគ្គលដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពទូទៅឲ្យក្រុមហ៊ុនជាស្ថាប័នស្វយ័តសាធារណៈ។

ក.ស.ស បានចុះបញ្ជីជាសហគ្រាសសាធារណៈគ្រប់គ្រងដោយរដ្ឋ នៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៩៧៨៩ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផមក") នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។

សកម្មភាពចម្បងរបស់ ក.ស.ស គឺទាក់ទងនឹងការផ្តល់សេវាកម្មនៃបបនីយភណ្ឌកំពង់ផែសមុទ្រ និងសេវាកម្មទាក់ទងនឹងកំពង់ផែ និងប្រតិបត្តិការភតិសន្យា នៃតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួន។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានទីតាំងស្ថិតនៅតិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។ ភាគលាភបានប្រកាស និងទូទាត់ក្នុងអំឡុងឆ្នាំ ត្រូវបានកំណត់នៅក្នុងកំណត់សម្គាល់លេខ 30 នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ក្រុមប្រឹក្សាភិបាល

អភិបាលក្រុមប្រឹក្សាភិបាលដែលបានកាន់តំណែងចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍មុនរួមមាន៖

| | | |
|---|---|---|
| ឯកឧត្តម លូ គឹមឈន់ | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក | ប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ផាន់ ផល្លា | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

| | | |
|---|---|---|
| ឯកឧត្តម ស៊ុយ សាន | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ឯកឧត្តម សុខ សុភ័ក្រ្ត | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| លោក លូ លីខេង | តំណាងនិយោជិត ក.ស.ស | សមាជិក |
| លោក ហ៊ុន មុន្នីវណ្ណ | អភិបាលឯករាជ្យ | សមាជិក |
| លោក Hidetoshi Kume | អភិបាលមិនប្រតិបត្តិ | សមាជិក |

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ព្រឹត្តិការណ៍ណាមួយដែលនឹងបណ្តាលឲ្យតម្លៃសន្មតលើទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស មិនត្រឹមត្រូវជាសារវន្តនោះទេ។

## វិធីសាស្ត្រក្នុងការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ព្រឹត្តិការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឲ្យមានការអនុវត្តវិធីសាស្ត្រដែលមានស្រាប់ នៃការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬ មិនសមស្របជាសារវន្តណាមួយនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក) មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ ក.ស.ស ដែលបានកើតឡើងចាប់តាំងពីចុងបញ្ចប់នៃកាលបរិច្ឆេទហិរញ្ញវត្ថុដោយសារការដាក់បញ្ចាំ សម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(ខ) មិនមានបំណុលយថាភាពណាមួយរបស់ ក.ស.ស ដែលបានកើតឡើងចាប់តាំងពីចុងបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុ លើកលែងតែក្នុងដំណើរការអាជីវកម្មធម្មតា។

ពុំមានបំណុលយថាភាព ឬ បំណុលផ្សេងៗរបស់ ក.ស.ស ដែលត្រូវបានទាមទារឲ្យសង ឬ អាចត្រូវបានទាមទារឲ្យសងក្នុងរយៈពេលពេល ១២ខែ បន្ទាប់ពីការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ដែលនឹងអាចមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ ក.ស.ស ក្នុងការបំពេញកាតព្វកិច្ច របស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

## បម្រែបម្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានកត់សម្គាល់ពីកាលៈទេសៈណាមួយដែលបាន កើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ដែលធ្វើឲ្យតួលេខ រាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គងជាសារវន្តណាមួយនោះទេ។

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

### សមាសធាតុមិនប្រក្រតី

តាមមតិយោបល់របស់គណៈគ្រប់គ្រង លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ ក.ស.ស ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយធាតុណាមួយ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ជាសារវន្ត និងព្រឹត្តិការណ៍មិនប្រក្រតីនោះទេ។ មិនមានសមាសធាតុ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ជាសារវន្ត និងជាលក្ខណៈមិនប្រក្រតីណាមួយកើតឡើងនៅក្នុងចន្លោះពេលរវាងចុងបញ្ចប់នៃការិយបរិច្ឆេទហិរញ្ញវត្ថុ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ (តាមមតិរបស់គណៈគ្រប់គ្រង) ដែលទំនងជាប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនៃរបាយការណ៍បានរៀបចំឡើងនោះទេ។

### សវនករ

ក្រុមហ៊ុនអឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) គឺជាសវនកររបស់ក្រុមហ៊ុន។

### របាយការណ៍ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs")។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យមើលទៅលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរៀបចំដោយគណៈគ្រប់គ្រងដោយតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របដោយគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនោះឲ្យបានខ្ជាប់ខ្ជួន
- អនុលោមតាម ("CIFRSs") ប្រសិនបើមានគម្លាតនៃការអនុវត្តណាមួយ ដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត ត្រូវធានាថាគំលាតទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- រក្សាកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាពអាជីវកម្ម លើកលែងតែក្នុងករណីដែលសន្មតថា ក.ស.ស មិនអាចបន្តសកម្មភាពអាជីវកម្មនាពេលអនាគតដែលអាចព្យាករណ៍បាន
- បង្កើតគោលនយោបាយទូទៅសម្រាប់ ក.ស.ស អនុម័តរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងឡាយណាដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលប្រតិបត្តិការរបស់ ក.ស.ស ហើយនិងធានាថាប្រតិបត្តិការ និងលទ្ធផលទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យត្រូវបានរក្សាទុក និងលាតត្រដាង អំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស ជាមួយសុក្រឹត្យភាពឲ្យសមហេតុផលគ្រប់ពេលវេលា និងត្រូវធានាដែរថាបញ្ជីគណនេយ្យអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏ជាអ្នកទទួលខុសត្រូវផងដែរក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន ដោយត្រូវចាត់វិធានការឲ្យបានសមស្រប ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក.ស.ស បានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយនេះ ថាបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាម CIFRSs។

តំណាងឲ្យក្រុមប្រឹក្សាភិបាល

ឯកឧត្តម លូ គឹមឈន់
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ

លោក ពិត ប្រាកដ
នាយក គណនេយ្យ និងហិរញ្ញវត្ថុ

ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

Building a better working world

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
#64 Norodom Boulevard corner Street 178
Sangkat Chey Chumneah, Khan Daun Penh
12206 Phnom Penh, Kingdom of Cambodia

Tel: +855 23 860 450/451
Fax: +855 23 217 805
ey.com

យោង៖ 61803762/66906078

# របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះ៖ ភាគទុនិក នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## *មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងរបាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ជាមួយនេះបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs")។

## *មូលដ្ឋានក្នុងការផ្តល់មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារទាំងនោះត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ *"ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ"* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានឯករាជ្យភាពពី ក.ស.ស ដោយយោងទៅតាមក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា រួមជាមួយតម្រូវការផ្នែកសីលធម៌ដែលពាក់ព័ន្ធនឹងការងារសវនកម្មចំពោះរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

## *បញ្ហាសវនកម្មសំខាន់*

បញ្ហាសវនកម្មសំខាន់យោងតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ គឺជាបញ្ហាដែលមានសារៈសំខាន់បំផុតនៅក្នុងការងារសវនកម្មរបស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហានេះត្រូវបានដោះស្រាយនៅក្នុងបរិបទនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល និងក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ ហើយយើងខ្ញុំមិនផ្តល់មតិយោបល់ដាច់ដោយឡែកលើបញ្ហាទាំងនេះទេ។

***បញ្ហាសវនកម្មសំខាន់*** (តពីទំព័រមុន)

*ការវាយតម្លៃលើកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

ដូចដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ១៧ ក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ដល់បុគ្គលិករបស់ខ្លួនអនុលោមតាមគោលនយោបាយចូលនិវត្តន៍របស់ក្រុមហ៊ុនដែលមានបំណុលប្រាក់សោធននិវត្តន៍ចំនួន ៧៦.០៣៨.៩១៦ ពាន់រៀល ដែលត្រូវជា ១៩% នៃបំណុលសរុបរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងមានបរិបទសំខាន់សម្រាប់ស្ថានភាពហិរញ្ញវត្ថុទាំងមូលរបស់ក្រុមហ៊ុន។ គណៈគ្រប់គ្រងបានវាយតម្លៃកាតព្វកិច្ចដោយផ្អែកលើទិន្នន័យប្រវត្តិសាស្ត្រ និងប្រជាសាស្ត្រ និងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន។ គណៈគ្រប់គ្រងក៏បានជួលអ្នកជំនាញគណនាពីខាងក្រៅ (external actuary) ដើម្បីធ្វើការគណនាដ៏មានភាពស្មុគស្មាញនេះ។

ការវាយតម្លៃលើកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ តម្រូវឲ្យមានការវិនិច្ឆ័យកម្រិតខ្ពស់ និងជំនាញបច្ចេកទេស នៅក្នុងការជ្រើសរើសការសន្មតដែលសមស្រប។ ការសន្មតសំខាន់ៗ ដែលរួមកំណើនប្រាក់បៀវត្សរ៍ អតិផរណា អត្រាអប្បហារ និងអត្រាមរណៈភាព អាចមានផលប៉ះពាល់ជាសារវន្តលើការគណនាបំណុលនេះ។

នីតិវិធីសវនកម្មរបស់យើងខ្ញុំទៅលើការប៉ាន់ស្មានបំណុលរបស់គណៈគ្រប់គ្រង រួមមាន៖

- ស្វែងយល់អំពីដំណើរគ្រប់គ្រងលើការវាយតម្លៃ រួមទាំងការពឹងផ្អែកលើអ្នកជំនាញគណនាពីខាងក្រៅក្នុងការអនុវត្តនៃការវាយតម្លៃ (actuarial valuation) លើតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍។
- ដោយផ្អែកលើមូលដ្ឋានគំរូ (on a sample basis) យើងធ្វើតេស្តលើភាពពេញលេញ និងភាពត្រឹមត្រូវនៃទិន្នន័យបុគ្គលិកដែលត្រូវបានប្រើនៅក្នុងការគណនាកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍។
- វាយតម្លៃលើឯករាជ្យភាព ភាពមិនលម្អៀង និងសមត្ថភាពរបស់អ្នកជំនាញគណនាពីខាងក្រៅរបស់ក្រុមហ៊ុន។
- ដោយមានជំនួយពីអ្នកជំនាញ យើងខ្ញុំបានធ្វើការវាយតម្លៃលើការប្រើប្រាស់ការសន្មតសម្រាប់គណនារបស់គណៈគ្រប់គ្រង និងវិធីសាស្ត្រវាយតម្លៃទាក់ទងនឹងកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍។
- បានត្រួតពិនិត្យរបាយការណ៍ការគណនាដើម្បីបញ្ជាក់ពីភាពស្របគ្នានៃទិន្នន័យដែលបានប្រើក្នុងការវាយតម្លៃ។

***បញ្ហាផ្សេងទៀត***

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិយោបល់មិនមានបញ្ហាលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងទៀតដែលយើងខ្ញុំទទួលបាននាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមាន របាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ មិនគ្របដណ្តប់លើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនធ្វើ ហើយនិងមិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយលើព័ត៌មានផ្សេងៗដែរ។

ទាក់ទងនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺអានព័ត៌មានផ្សេងៗនេះ ហើយធ្វើការពិចារណាថាតើព័ត៌មានផ្សេងៗនេះមានភាពខុសគ្នាជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬ ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការងារសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ (ដោយផ្អែកលើការងារដែលបានអនុវត្ត) យើងខ្ញុំត្រូវតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាម CIFRSs ហើយនិងទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពបន្តនិរន្តរភាពអាជីវកម្មរបស់ ក.ស.ស និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ ក.ស.ស លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការរបស់ ក.ស.ស ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ចមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ ក.ស.ស។

## ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុ ទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា ការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមទៅតាម CISAs តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្ត ដែលបានកើតឡើងនោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាមានភាពជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

***ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ជាផ្នែកមួយនៃការងារសវនកម្ម អនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យ នៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ មានកម្រិតខ្ពស់ជាងហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ ក.ស.ស ទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមានភាពមិនប្រាកដប្រជា ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌទាំងឡាយណាដែលនាំឲ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ ក.ស.ស ឬ ទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍របស់សវនករលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នោះពុំមានលក្ខណៈគ្រប់គ្រាន់ទេ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺ ពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬ លក្ខខណ្ឌនាពេលអនាគត ក៏អាចបង្កឲ្យ ក.ស.ស មិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃលើការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

***ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកនៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ឡុន ស៊ីនរ៉ា

ដៃគូសវនករ

**អ៊ីនស្ទ៍ អែន យ៉ាំង (ខេមបូឌា)**

ក្រុមហ៊ុនគណនេយ្យករជំនាញ

សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល (បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* |
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យ និងបរិក្ខារ | ៦ | ៩៦៣.៧១២.៧៨១ | ៩៦៦.១៦៥.៨៤៤ |
| ទ្រព្យវិនិយោគ | ៧ | ២៤៨.២៩៦.៧០៥ | ២៥៣.១៩៥.៦៩៩ |
| ទ្រព្យសកម្មអរូបី | ៨ | ៤.០១៩.០៩១ | ៤.៩៣៦.៣៣២ |
| | | **១.២១៦.០២៨.៥៧៧** | **១.២២៤.២៩៧.៨៧៥** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៩ | ២៩.០៨៣.៣៦៤ | ២៧.២២៥.០០៦ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ១០ | ៣៧.៩៥៦.៨៦២ | ៣៥.៦៥៩.៩១១ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១១ | ១០២.៩០៨.២៦៤ | ១០១.៣០៦.៦៨១ |
| សាច់ប្រាក់ | ១២ | ២៣.៥៨៦.៣៦៨ | ២២.៤៦៨.៩២៩ |
| | | **១៩៣.៥៣៤.៨៥៨** | **១៨៦.៦៦០.៥២៧** |
| ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | ១៣ | ១៦.៥៨២.១៦១ | ១៦.១៩១.២៦៨ |
| | | **២១០.១១៧.០១៩** | **២០២.៨៥១.៧៩៥** |
| **ទ្រព្យសកម្មសរុប** | | **១.៤២៦.១៤៥.៥៩៦** | **១.៤២៧.១៤៩.៦៧០** |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន | ១៤ | ៤៥០.៣០២.៨២៨ | ៤៥០.៣០២.៨២៨ |
| បុព្វលាភភាគហ៊ុន | ១៤ | ៦៧.៧១៥.២៣៥ | ៦៧.៧១៥.២៣៥ |
| ទុនបម្រុងផ្សេងៗ | ១៥ | ៤១.០៩០.៥៧២ | ៣១.៧១៩.៨៣២ |
| ប្រាក់ចំណេញរក្សាទុក | | ៣០៤.៦៩២.៣១១ | ២៣៤.១៥៦.២៦៤ |
| **មូលធនសរុប** | | **៨៦៣.៨០០.៩៤៦** | **៧៨៣.៨៩៤.១៥៩** |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៦ | ៣៦៤.៦៧៧.០៨៧ | ៤៣៥.០២៥.៤២៥ |
| ប្រាក់តម្កល់ពីភតិក: | | ១.០២៩.២៥០ | ១.០១៨.៥០០ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៧ | ៦៩.៨២៤.០៥៣ | ៨៣.៦៤៦.៥៥៩ |
| កាតព្វកិច្ចប្រាក់បំណាច់អតីតភាពការងារ | | ១.៣១៦.៧១៦ | ១.០៨០.១៤៩ |
| ចំណូលពន្យារ | ១៨ | ១២.២០៣.២០០ | ៥.៣១០.៤៥៩ |
| បំណុលពន្ធពន្យារ | ២៦ | ៣៣.០០៣.៣៥៤ | ២៩.៤១៩.០១៤ |
| | | **៤៨២.០៥៣.៦៦០** | **៥៥៥.៥០០.១០៦** |

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** (តពីទំព័រមុន)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល (បានធ្វើចំណាត់ថ្នាក់ឡើងវិញ កំណត់សម្គាល់លេខ ៣២)* |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ១៩ | ៣៥.០៦៦.០៧៣ | ៤៣.១៨៩.៦៥៩ |
| កម្ចី | ១៦ | ៣០.៤៣៣.៤៩០ | ៣៣.៩៦១.៥៧២ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៧ | ៦.២១៤.៣៦៣ | ៤.៥៣៤.៤២៥ |
| កាតព្វកិច្ចប្រាក់បំណាច់អតីតភាពការងារ | | ១២៧.៧៣៩ | - |
| ចំណូលពន្យារ | ១៨ | ១៧១.៦៧៩ | ១៣៤.៤៤២ |
| បំណុលពន្ធលើប្រាក់ចំណូល | ២៦ | ៨.២៧៧.៦៤៦ | ៥.៩៣៥.៣០៧ |
| | | **៨០.២៩០.៩៩០** | **៨៧.៧៥៥.៤០៥** |
| **បំណុលសរុប** | | **៥៦២.៣៨៤.៦៥០** | **៦៤៣.២៥៥.៥១១** |
| **មូលធន និងបំណុលសរុប** | | **១.៤២៦.១៩៥.៥៩៦** | **១.៤២៧.១៩៩.៦៧០** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* |
| **ចំណូល** | | | |
| ចំណូលពីកិច្ចសន្យាជាមួយអតិថិជន | ២០ | ៣៩១.៣៦៨.៨៤៩ | ៣៩០.១៥៣.៣៦០ |
| ចំណូលពីការជួល | ៧ | ២.៣៧៤.៦៩៦ | ២.១៩៥.៨៦៩ |
| | | **៣៩៣.៧៤៣.៥៤៥** | **៣៩២.៣៤៩.២២៩** |
| **ចំណាយ** | | | |
| សម្ភារៈផ្គត់ផ្គង់ការប្រើប្រាស់ | ២១ | (១០៦.៣៦៤.៨៦១) | (៩៣.៧៣៩.២៤៦) |
| ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២២ | (១០៥.៦៧២.០៩៧) | (១០៤.៣៦៦.៩៤៩) |
| ចំណាយរំលស់ទ្រព្យរូបី និងអរូបី | ២៣ | (៤៥.៦៩៧.៧៤៨) | (៣៩.៩២២.៦៧៧) |
| ការជួសជុល និងថែទាំ | | (២.២៨៨.១១៦) | (៤.៨៥៧.០៥៣) |
| ចំណាយផ្សេងៗ | ២៤ | (២៧.១២៦.៨៩៩) | (២០.៣៩៧.៤០៦) |
| ចំណេញ (ខាត) ផ្សេងៗ - សុទ្ធ | | ៤៤៩.៥៨៥ | (២៧៣.៣០០) |
| | | **(២៨៦.៧០០.១៣៦)** | **(២៦៣.៥០៦.៦៣១)** |
| **ចំណេញប្រតិបត្តិការ** | | **៥៧.០៤៣.៤០៩** | **៧៨.៨៤២.៥៩៨** |
| ចំណូល ហិរញ្ញវត្ថុ - សុទ្ធ | ២៥ | ៤០.៨៥៣.៦៧១ | ៣២.២០៣.០៣៩ |
| **ចំណេញមុនគិតពន្ធលើប្រាក់ចំណូល** | | **៩៧.៨៩៧.០៨០** | **១១១.០៤៥.៦៣៧** |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៦ | (១៣.៧៤១.៨៦៥) | (១៧.៣៣៨.២៤៧) |
| **ចំណេញក្នុងគ្រា** | | **៨៤.១៥៥.២១៥** | **៩៣.៧០៧.៣៩០** |
| **ចំណេញក្នុងគ្រារបស់ភាគហ៊ុនិក** | | **៨៤.១៥៥.២១៥** | **៩៣.៧០៧.៣៩០** |
| ចំណេញពីការវាស់វែងឡើងវិញលើការកំណត់ | | | |
| កាតព្វកិច្ចអត្ថប្រយោជន៍ - ក្រោយគិតពន្ធ | ១៧, ២៦ | ១១.៨៥៨.៨៤០ | - |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រាក្រោយគិតពន្ធរបស់ភាគហ៊ុនិក** | | **៩៦.០១៤.០៥៥** | **៩៣.៧០៧.៣៩០** |

ប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិករបស់ ក.ស.ស សម្រាប់ការិយបរិច្ឆេទបញ្ចប់មានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| មូលដ្ឋានប្រាក់ចំណេញក្នុងមួយភាគហ៊ុន (រៀល) | ២៧ | **៩៨១,១៥** | **១.០៩២,៥២** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *ដើមទុនដែលបានបោះផ្សាយ* | *បុព្វលាភភាគហ៊ុន* | *ទុនបម្រុង* | *ប្រាក់ចំណេញរក្សាទុក* | *សរុប* |
|---|---|---|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | | ៤៥០.៣០២.៨២៨ | ៦៧.៧១៥.២៣៥ | ៣១.៧១៩.៨៣២ | ២៣៤.១៥៦.២៦៤ | ៧៨៣.៨៩៤.១៥៩ |
| ប្រាក់ចំណេញក្នុងគ្រា | | - | - | - | ៨៤.១៥៥.២១៥ | ៨៤.១៥៥.២១៥ |
| ចំណេញពីការវាស់វែងឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍ | ១៧, ២៦ | - | - | - | ១១.៨៥៨.៨៤០ | ១១.៨៥៨.៨៤០ |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រា** | | **-** | **-** | **-** | **៩៦.០១៤.០៥៥** | **៩៦.០១៤.០៥៥** |
| ផ្ទេរទៅទុនបម្រុង | ១៥ | - | - | ៩.៣៧០.៧៤០ | (៩.៣៧០.៧៤០) | - |
| ភាគលាភដែលបានប្រកាស | ៣០.២ | - | - | - | (១៦.១០៧.២៦៨) | (១៦.១០៧.២៦៨) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៤១.០៩០.៥៧២** | **៣០៤.៦៩២.៣១១** | **៨៦៣.៨០០.៩៤៦** |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | | ៤៥០.៣០២.៨២៨ | ៦៧.៧១៥.២៣៥ | ២៩.០៥៩.០៧២ | ១៥៥.២៨៤.២៨៣ | ៧០២.៣៦១.៤១៨ |
| ប្រាក់ចំណេញក្នុងគ្រា | | - | - | - | ៩៣.៧០៧.៣៩០ | ៩៣.៧០៧.៣៩០ |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រា** | | **-** | **-** | **-** | **៩៣.៧០៧.៣៩០** | **៩៣.៧០៧.៣៩០** |
| ផ្ទេរទៅទុនបម្រុង | ១៥ | - | - | ២.៦៦០.៧៦០ | (២.៦៦០.៧៦០) | - |
| ភាគលាភដែលបានប្រកាស | ៣០.២ | - | - | - | (១២.១៧៤.៦៤៩) | (១២.១៧៤.៦៤៩) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៣១.៧១៩.៨៣២** | **២៣៤.១៥៦.២៦៤** | **៧៨៣.៨៩៤.១៥៩** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | *កំណត់សម្គាល់* | *២០២២* | *២០២១* |
|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* |
| **សកម្មភាពប្រតិបត្តិការ** | | | |
| ប្រាក់ចំណេញមុនគិតពន្ធ | | ៩៧.៨៩៧.០៨០ | ១១១.០៥៥.៦៣៧ |
| *និយ័តកម្ម៖* | | | |
| ចំណូលហិរញ្ញវត្ថុ - សុទ្ធ | ២៥ | (៤០.៨៥៣.៦៧១) | (៣២.២០៣.០៣៩) |
| ចំណាយរំលស់ទ្រព្យរូបី និងទ្រព្យអរូបី | ២៣ | ៤៥.៦៩៧.៧៤៨ | ៣៩.៩២២.៦៧៧ |
| បម្រែបម្រួលកាតព្វកិច្ចប្រាក់សោធននិវត្តន៍ | | ២.៦៨០.៩៨១ | ១.៦៩៩.០១៧ |
| បម្រែបម្រួលប្រាក់បំណាច់អតីតភាពការងារ | | ៣៦៤,៣០៦ | (៣.០២៩.០២៩) |
| រំលស់អត្ថប្រយោជន៍ឥណទានបុគ្គលិក | | - | ៣២៧.៧២៨ |
| *បម្រែបម្រួលដើមទុន៖* | | | |
| សន្និធិ | | (១.៨៥៨.៣៥៨) | (៣.៣៧១.៩៨៤) |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | | (១.៩៩៩.០៨៩) | (៦.០៨៧.៨៥៣) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | | (១០.៣៤៣.៦៤០) | ២២.១២៦.០៣៧ |
| ចំណូលពន្យារ | | ៦.៩២៩.៩៧៨ | (៩៤.៧២៧) |
| | | **៩៨.៥១៥.៣៣៥** | **១៣០.៣៣៤.៤៦៤** |
| ពន្ធលើប្រាក់ចំណូលបានបង់ | ២៦ | (១០.៧៧៩.៨៩៥) | (៨.១៩១.៩៣៨) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **៨៧.៧៣៥.៤៤០** | **១២២.១៤២.៥២៦** |
| **សកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ៦ | (៣៩.៣៨២.៨២៦) | (៨៥.៣៣១.២៣៨) |
| ការទិញទ្រព្យវិនិយោគ | ៧ | (១.២៧៧.៦៤៥) | (១.៨៧៤.១៧០) |
| ការទិញទ្រព្យអរូបី | ៨ | (២៥១.២៩៨) | (៣៦៦.៩៣១) |
| ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | | ៥២៦.៥៣៨ | - |
| ប្រាក់ទទួលបានពីប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | | ៩៩.៦៣៨.៩៤៤ | ១៥.៤៤១.៩៧០ |
| ការដាក់ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | | (១០០.៨៥២.៥៩០) | (១២.១៦៥.០០០) |
| ការប្រាក់បានទទួល | | ៣.៨៧០.៤៣៣ | ៣.៨៦៧.៣២៤ |
| ប្រាក់សំណងទទួលបានពីឥណទានបុគ្គលិក | | - | ១.២៨៣.៣៦៣ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(៣២.៧២៨.៤៤៤)** | **(៧៩.១៤៤.៦៨២)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | ១.៧៩៦.០៨២ | ១.១៣៧.៥៣២ |
| ការសងប្រាក់កម្ចី | | (២៨.៩៤០.៤៥២) | (៣២.៤៤២.៥១១) |
| ភាគលាភបានបង់ | ៣០.២ | (១៦.១០៧.២៦៨) | (៨.៦៤១.៥២៧) |
| ការប្រាក់បានបង់ | | (១០.៦៣៧.៩១៩) | (១១.៣៧៣.៨៨៤) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(៥៣.៨៨៩.៥៥៧)** | **(៥១.៣១៩.៩៩០)** |
| **កំណើន (តំហយ) សុទ្ធលើសាច់ប្រាក់** | | **១.១១៧.៤៣៩** | **(៨.២៧២.១៤៦)** |
| សាច់ប្រាក់ដើមគ្រា | | ២២.៤៦៨.៩២៩ | ៣០.៧៤១.០៧៥ |
| **សាច់ប្រាក់ចុងគ្រា** | ១២ | **២៣.៥៨៦.៣៦៨** | **២២.៤៦៨.៩២៩** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់ លេខ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

### ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការត្រួតពិនិត្យលើផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្ដាលរបស់ខ្លួននៅក្នុងខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិបុគ្គលដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពទូទៅឲ្យក្រុមហ៊ុនជាស្ថាប័នស្វយ័តសាធារណៈ។

ក.ស.ស បានចុះបញ្ជីជាសហគ្រាសសាធារណៈគ្រប់គ្រងដោយរដ្ឋ នៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៨ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផមក") នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។

បច្ចុប្បន្ន ក.ស.ស គឺជាកំពង់ផែសមុទ្រអន្តរជាតិ និងជាកំពង់ផែសមុទ្រជ្រៅពាណិជ្ជកម្មតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមទៅតាមអនុក្រឹត្យស្តីពី បេសកកម្មរបស់ ក.ស.ស គឺផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗ ដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រដូចខាងក្រោម៖

- កណ្តាធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា ធ្វើបែបបទនាវា ចេញ ចូល
- លើកដាក់ ផ្ទេរចេញ និងដឹកជញ្ជូនទំនិញ
- រក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរបស់ ក.ស.ស ដែលមានស្រាប់
- ទទួលខុសត្រូវ លើសុខមាលភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង និង
- ប្តេជ្ញាធ្វើការគ្រប់គ្រង និងចាត់ចែងសកម្មភាពប្រតិបត្តិការឲ្យមានប្រសិទ្ធភាព និងមានការរីកចម្រើន។

ក.ស.ស ក៏មានប្រតិបត្តិការនៅតំបន់សេដ្ឋកិច្ចពិសេស ប្រតិបត្តិការភតិសន្យាជាភតិបតី។

ក្នុងនាមជាស្ថាប័នស្វយ័តសាធារណៈ ក.ស.ស ទទួលអំណាច និងកាតព្វកិច្ចទាំងឡាយពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុទាំងនេះ។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានអាសយដ្ឋាននៅតិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានអនុម័តឲ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

## ២. មូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំអនុលោមតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs") ដែលបានចេញផ្សាយដោយ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀល ត្រូវបានរៀបចំឡើងដោយមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ។ ចំនួនទឹកប្រាក់ត្រូវបានបង្គត់ជាខ្ទង់ពាន់ លុះត្រាតែមានការ បង្ហាញផ្សេងទៀត។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងគ្នា ហើយចំនួនសុទ្ធបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលមានសិទ្ធិដែលអាចអនុវត្តបានស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានទទួលស្គាល់ ហើយមានចេតនាដើម្បីទូទាត់តាមមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម ហើយធ្វើការទូទាត់បំណុលក្នុងពេលជាមួយគ្នា។

*ឆ្នាំសារពើពន្ធ*

ឆ្នាំសារពើពន្ធរបស់ ក.ស.ស ចាប់ផ្តើមនៅថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

*ការប្តូររូបិយប័ណ្ណបរទេស*

*រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបង្ហាញ*

ធាតុទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណ នៃស្ថានភាពសេដ្ឋកិច្ចចម្បង ដែល ក.ស.ស ធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណមុខងារ")។ ក.ស.ស រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល (រៀល) ជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណបង្ហាញ។

*ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារ តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការបកប្រែអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទ នៃទ្រព្យសកម្មសន្ទនីយភាព និងបំណុលជាសាច់ប្រាក់ដែលជារូបិយប័ណ្ណផ្សេងក្រៅពីប្រាក់រៀល ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ខាត។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងប្រាក់ចំណេញ ឬ ខាត នៅក្នុង "ចំណូល និងចំណាយហិរញ្ញវត្ថុ"។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

### *៣.១ ស្តង់ដារថ្មី និងវិសោធនកម្ម និងការបកស្រាយ*

គោលនយោបាយគណនេយ្យដែលត្រូវបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គឺស្របជាមួយនឹងអ្វីដែលបានអនុវត្តតាមឆ្នាំមុន លើកលែងតែការអនុម័ត (ដែលអាចអនុវត្តបាន) នៃវិសោធនកម្មចំពោះ CIFRSs ដែលនឹងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។ ក្រុមហ៊ុនមិនទាន់បានអនុម័តស្តង់ដារ ឬ វិសោធនកម្មផ្សេងទៀតដែលបានចេញផ្សាយ តែមិនទាន់មានប្រសិទ្ធភាពនោះទេ។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៣.១ *ស្តង់ដារថ្មី និងវិសោធនកម្ម និងការបកស្រាយ* (តពីទំព័រមុន)

វិសោធនកម្មមួយចំនួនដូចដែលបានសង្ខេបខាងក្រោមអនុវត្តជាលើកដំបូងក្នុងឆ្នាំ២០២២ ប៉ុន្តែមិនមានឥទ្ធិពលលើស្ថានភាពហិរញ្ញវត្ថុ និងដំណើរការរបស់ ក.ស.ស ទេ។

- វិសោធនកម្មចំពោះ CIFRS ៩ *ឧបករណ៍ហិរញ្ញវត្ថុ* - ថ្លៃសេវា "១០ ភាគរយ"សម្រាប់ការមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុ
- វិសោធនកម្មចំពោះ CIFRS ៣៖ *ការរួមបញ្ចូលអាជីវកម្ម*- យោងទៅក្របខ័ណ្ឌគោលគំនិត
- វិសោធនកម្មចំពោះ CIAS ១៦៖ *ទ្រព្យ រោងចក្រ និងបរិក្ខារ*- ប្រាក់ទទួលបានមុនប្រើប្រាស់តាមគោលបំណង
- វិសោធនកម្មចំពោះ CIAS ៣៧៖ *សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព* - កិច្ចសន្យាធ្ងន់ធ្ងរ - ចំណាយលើការបំពេញកិច្ចសន្យា
- វិសោធនកម្មចំពោះ CIFRS ១៖ *ការអនុម័តលើកដំបូងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា* - ក្រុមហ៊ុនបុត្រសម្ព័ន្ធជាអ្នកអនុម័តលើកដំបូង
- វិសោធនកម្មចំពោះ CIAS ៤១៖ *កសិកម្ម* - ការវាស់វែងពន្ធដារក្នុងតម្លៃសមស្រប

### ៣.២ *ស្តង់ដារ និងការបកស្រាយដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព*

ស្តង់ដារ និងវិសោធនកម្មដែលបានចេញផ្សាយ (ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព) រហូតដល់ថ្ងៃចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានលាតត្រដាងដូចខាងក្រោម។ ស្តង់ដារ និងការបកស្រាយទៅលើ CIFRSs ទាំងនេះដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ត្រូវបានរំពឹងនឹងមិនមានផលប៉ះពាល់ជាសារវន្តទៅលើស្ថានភាពហិរញ្ញវត្ថុ ឬ លទ្ធផលរបស់ក្រុមហ៊ុនទេ។

មានប្រសិទ្ធភាពនៅដើម ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

(i) CIFRS ១៧ *កិច្ចសន្យាធានារ៉ាប់រង*

(ii) វិសោធនកម្មចំពោះ CIAS ៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរនៃការប៉ាន់ស្មានគណនេយ្យ និងកំហុសគណនេយ្យ* - និយមន័យនៃការប៉ាន់ស្មានគណនេយ្យ

(iii) វិសោធនកម្មចំពោះ CIAS ១ ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្ត CIFRS របាយការណ៍លេខ២ *ការប្រើប្រាស់ការវិនិច្ឆ័យជាសារវន្ត*- ការបង្ហាញគោលនយោបាយគណនេយ្យ។

(iv) វិសោធនកម្មចំពោះ CIAS ១២ *ពន្ធលើប្រាក់ចំណូល* ពន្ធពន្យារទាក់ទងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការមួយ

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### ៣.២ *ស្តង់ដារ និងការបកស្រាយដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព* (តពីទំព័រមុន)

មានប្រសិទ្ធភាពនៅដើម ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤

(i) វិសោធនកម្មចំពោះ CIFRS ១៦ *ភតិសន្យា* - បំណុលភតិសន្យា ក្នុងការលក់ និងភតិសន្យាត្រឡប់មកវិញ

(ii) វិសោធនកម្មចំពោះ CIAS ១ *ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ* - ការចាត់ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី និងរយៈពេលវែង

### ៣.៣ *រូបិយប័ណ្ណមុខងារ*

ក្រុមហ៊ុនរក្សាកំណត់ត្រាគណនេយ្យរបស់ខ្លួន និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដើម្បីឆ្លុះបញ្ចាំងពីប្រតិបត្តិការ ព្រឹត្តិការណ៍ និងលក្ខខណ្ឌដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន។

ប្រាក់ចំណូលរបស់ក្រុមហ៊ុនត្រូវបានចេញវិក្កយបត្រ និងប្រមូលជារូបិយប័ណ្ណគោលជាប្រាក់រៀល។ ថ្លៃដើមនៃការលក់ ការចំណាយទូទៅ និងរដ្ឋបាល ព្រមទាំងចំណូល និងចំណាយផ្សេងទៀតត្រូវបានទិញ និងបង់ជាប្រាក់រៀលផងដែរ។ ផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃកាលៈទេសៈដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន ប្រាក់រៀលគឺជារូបិយប័ណ្ណដែលក្រុមហ៊ុនបានទទួល និងចំណាយយ៉ាងច្រើន នៅក្នុងប្រទេសដែលខ្លួនធ្វើប្រតិបត្តិការ។

### ៣.៤ *ទ្រព្យ និងបរិក្ខារ*

ទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយដោយ ផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យ និងបរិក្ខារទាំងអស់នោះ។

សំណង់កំពុងសាងសង់ ត្រូវបានកត់ត្រាតាមថ្លៃដើម ដកអ៊ីមភែរមិនបង្គរ (បើសិនជាមាន)។

ចំណាយបន្តបន្ទាប់ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ឬ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែក (តាមការសមស្រប) នៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូល ក.ស.ស ហើយចំណាយទាំងនោះអាចវាស់វែងគួរឲ្យជឿជាក់បាន។ តម្លៃយោងនៃ ផ្នែកដែលត្រូវបានជំនួសឡើងវិញត្រូវបានឈប់កត់ត្រា។ រាល់ចំណាយលើការជួសជុល និងថែទាំផ្សេងៗត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬ ខាតក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលប្រតិបត្តិការនោះបានកើតឡើង។

ដីធ្លីមិនត្រូវបានធ្វើការរំលស់ទេ។ សំណង់កំពុងសាងសង់មិនត្រូវបានធ្វើរំលស់ទេរហូតដល់ទ្រព្យ និងបរិក្ខារពាក់ព័ន្ធមានភាពរួចរាល់សម្រាប់ការប្រើប្រាស់។ រំលស់លើទ្រព្យសកម្មផ្សេងៗត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីបែងចែក ថ្លៃដើមនៃទ្រព្យសកម្មដកតម្លៃសំណល់ របស់ទ្រព្យសកម្មលើអាយុកាលប្រើប្រាស់បានប៉ាន់ស្មានដូចខាងក្រោម៖

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.៤ ទ្រព្យ និងបរិក្ខារ* (តពីទំព័រមុន)

| | *ឆ្នាំ* |
|---|---|
| ការកែលម្អដីធ្លី | ៧ - ៥០ |
| អគារ | ៧ - ៥០ |
| បរិក្ខារបច្ចេកទេស | ៥ - ៣០ |
| គ្រឿងសង្ហារិម និងបរិក្ខារបំពាក់ | ៣ - ១០ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៣ - ៥ |
| យានយន្ត | ៥ - ១៥ |
| បរិក្ខារកំពង់ផែសមុទ្រ | ២០ - ៣០ |
| ប៉ាឡែត | ១០ |

តម្លៃកាកសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ (និងកែតម្រូវ តាមភាពសមស្រប) នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។

ចំណេញ និងខាតពីការលក់ទ្រព្យ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀប សាច់ប្រាក់លក់បានជាមួយនឹងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬ ខាត។

### *៣.៥ ទ្រព្យវិនិយោគ*

ទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់សម្រាប់ការជួលរយៈពេលវែង ឬ សម្រាប់ការកើនតម្លៃដើមទុន ឬ ទាំងពីរយ៉ាង និងមិនត្រូវបានប្រតិបត្តិដោយ ក.ស.ស ត្រូវបានចាត់ថ្នាក់ជាទ្រព្យវិនិយោគ។ ទ្រព្យវិនិយោគ ក៏រួមបញ្ចូលនូវទ្រព្យសម្បត្តិដែលកំពុងសាងសង់ ដើម្បីអភិវឌ្ឍសម្រាប់ការប្រើប្រាស់ពេលអនាគតឲ្យជាទ្រព្យវិនិយោគ។ ទ្រព្យវិនិយោគត្រូវបានកត់ត្រាជាដំបូងតាមថ្លៃដើមដករំលស់បង្គរ និងអ៊ីមភែរមិន។ ក.ស.ស ប្រើប្រាស់គំរូថ្លៃដើម និងគណនីសម្រាប់ទ្រព្យវិនិយោគដោយអនុលោមទៅតាម CIAS ១៦ *ទ្រព្យ និងបរិក្ខារ*។

ទ្រព្យវិនិយោគត្រូវបានផ្ទេរទៅជាសន្និធិ តែនៅពេលដែលមានការផ្លាស់ប្តូរក្នុងការប្រើប្រាស់ដោយមានភស្តុតាងបង្ហាញពីការចាប់ផ្តើមការអភិវឌ្ឍ ក្នុងទស្សនវិស័យដើម្បីលក់។ នៅពេលដែល ក.ស.ស សម្រេចលក់ទ្រព្យវិនិយោគមួយចេញដោយមិនមានការអភិវឌ្ឍ ក្រុមហ៊ុនបន្តចាត់ទុក ទ្រព្យសម្បត្តិនោះជាទ្រព្យវិនិយោគរហូតដល់ពេលឈប់ទទួលស្គាល់ និងត្រូវបានលុបចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយមិនចាត់ទុកវាជាសន្និធិទេ។ ប្រសិនបើទ្រព្យវិនិយោគ ត្រូវបាន អភិវឌ្ឍឡើងវិញដើម្បីប្រើប្រាស់បន្តទៅទៀតជាទ្រព្យវិនិយោគនោះ ទ្រព្យសម្បត្តិនោះ នៅរក្សាទុកជាទ្រព្យវិនិយោគដដែល ហើយមិនត្រូវបានចាត់ថ្នាក់ឡើងវិញជាទ្រព្យសម្បត្តិ ដែល កាន់កាប់ដោយម្ចាស់ក្នុងអំឡុងពេលការអភិវឌ្ឍឡើងវិញទេ។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៣.៥ *ទ្រព្យវិនិយោគ* (តពីទំព័រមុន)

នៅពេលលក់ទ្រព្យវិនិយោគមួយ ឬ នៅពេលដែលទ្រព្យវិនិយោគណាមួយ ត្រូវបានដកចេញពីការប្រើប្រាស់ជាអចិន្ត្រៃយ៍ និងមិនមានការរំពឹងថានឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការលក់ទ្រព្យវិនិយោគនោះនឹងត្រូវឈប់ទទួលស្គាល់ (លុបចេញពីតារាងតុល្យការ)។ ចំនួនលម្អៀងរវាងសាច់ប្រាក់សុទ្ធដែលបានពីការលក់ និងតម្លៃយោង ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ខាត ក្នុងការិយបរិច្ឆេទឈប់ប្រើ ឬ ការិយបរិច្ឆេទលក់។

ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ ចំណែកការកែលម្អដីធ្លី និងអគារត្រូវបានធ្វើរំលស់ដោយប្រើវិធីសាស្ត្ររំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានក្នុងរយៈពេលពី ១០ឆ្នាំ ទៅ ៥០ឆ្នាំ។

### ៣.៦ *ទ្រព្យសកម្មអរូបី*

ទ្រព្យសកម្មអរូបីរួមមានប្រព័ន្ធគណនេយ្យ និងប្រព័ន្ធប្រតិបត្តិការកំពង់ផែ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងអ៊ីមភែរមិន (ប្រសិនបើមាន)។ ទ្រព្យសកម្មអរូបីទាំងនេះត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញ និងយកកម្មវិធីនោះមកប្រើប្រាស់។ ក.ស.ស បានធ្វើរំលស់ទ្រព្យសកម្មអរូបីដែលនៅមានអាយុកាលប្រើប្រាស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរអាស្រ័យទៅតាមរយៈពេលដូចខាងក្រោម៖

| | *ឆ្នាំ* |
|---|---|
| កម្មវិធីគណនេយ្យ | ១០ |
| ប្រព័ន្ធប្រតិបត្តិការកំពង់ផែ | ១០ |

### ៣.៧ *អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនាកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានសូចនាករណ៍ណាមួយនៃអ៊ីមភែរមិនឬទេ។ ការខាតបង់លើអ៊ីមភែរមិន ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម លើសពីតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន។ តម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងរវាង តម្លៃសមស្របនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃអាចប្រើប្រាស់បានរបស់ទ្រព្យសកម្មនោះ។ តាមគោលបំណងនៃការវាយតម្លៃអ៊ីមភែរមិន ទ្រព្យសកម្មត្រូវបានបែងចែក ជាក្រុមតូចៗបំផុតដែលបង្កើតលំហូរចូលសាច់ប្រាក់ដោយឯករាជ្យ (ឧបករណ៍បង្កើតសាច់ប្រាក់)។ ខាតអ៊ីមភែរមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

បញ្រ្ចាស់នៃខាតលើអ៊ីមភែរមិន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញត្រឹមកម្រិតមួយដែលតម្លៃយោងនៃទ្រព្យសកម្មត្រូវបានកំណត់ពីមុន (តម្លៃសុទ្ធក្រោយការរំលស់ទ្រព្យរូបី និងអរូបី) មិនដែលមានអ៊ីមភែរមិនត្រូវបានទទួលស្គាល់លើទ្រព្យសកម្មក្នុងឆ្នាំមុន។ បន្ទាប់ពីបញ្រ្ចាស់បែបនេះ រំលស់ទ្រព្យរូបី និងអរូបី ត្រូវបានកែតម្រូវក្នុងពេលអនាគត ដើម្បីបែងចែកតម្លៃយោងរបស់ទ្រព្យសកម្មដែលបានកែសម្រួល (ដកតម្លៃកាកសំណល់ទាំងអស់) ដោយផ្អែកលើមូលដ្ឋានជាប្រព័ន្ធលើអាយុកាលនៅសល់។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.៨ សន្និធិ*

សន្និធិត្រូវបានកត់ត្រាតាមតម្លៃមួយណាដែលទាបជាងរវាងថ្លៃដើម (ថ្លៃដើមក្នុងការទិញ និងថ្លៃដើមផ្សេងៗ ទៀតក្នុងការនាំយកសន្និធិនោះមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា) និងតម្លៃពិតជាក់ស្តែង។ តម្លៃពិតជាក់ស្តែងសុទ្ធ គឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកការប៉ាន់ស្មានថ្លៃដើមដើម្បីបញ្ចប់ និងការប៉ាន់ស្មានថ្លៃដើមសំខាន់ៗដើម្បីលក់។

សន្និធិរួមមានវត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិផ្សេងៗដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ត្រូវបានវាយតម្លៃតាមថ្លៃដើមជាក់ស្តែងសុទ្ធ ក្នុងការនាំយកសន្និធិនោះមកប្រើប្រាស់ទៅតាមគោលបំណង ដែលបានគ្រោងទុក ដក សំវិធានធនលើការបែកបាក់ ខូចខាត និងមានចលនាយឺតដោយប្រើប្រាស់វិធីសាស្ត្រមូលដ្ឋានចូលមុន - ចេញមុន។

### *៣.៩ ឧបករណ៍ហិរញ្ញវត្ថុ*

ឧបករណ៍ហិរញ្ញវត្ថុ គឺជាកិច្ចសន្យាទាំងឡាយណាដែលផ្តល់នូវការកើនឡើងនៃទ្រព្យសកម្ម និងទ្រព្យអសកម្ម ឬ ឧបករណ៍មូលធន របស់អង្គភាពមួយផ្សេងទៀត។

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ*

#### *៣.១០.១ ការធ្វើចំណាត់ថ្នាក់*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់តាមការទទួលស្គាល់ដំបូង បន្ទាប់មកទៀតត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម តម្លៃសមស្របតាមលទ្ធផលពេញលេញផ្សេងៗ (OCI) និងតម្លៃសមស្របតាមប្រាក់ចំណេញ ឬ ខាត ("FVTPL")។

ក.ស.ស បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនផ្លាស់ប្តូរតែប៉ុណ្ណោះ។

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ, ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងសាច់ប្រាក់ដែលបានបំពេញតាមលក្ខខណ្ឌក្នុងការសងតែប្រាក់ដើម និងការប្រាក់ (SPPI) ដោយតាមលក្ខខណ្ឌក្នុងកិច្ចសន្យាបានធ្វើឲ្យលំហូរសាច់ប្រាក់កើនឡើង ព្រមទាំងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីមូលដ្ឋានដើម។ ទ្រព្យសកម្មទាំងនេះក៏ត្រូវបានប្រមូលផ្តុំនៅក្នុងគំរូអាជីវកម្មកាន់កាប់ដល់ប្រមូលត្រលប់ ដូច្នេះនឹងត្រូវបានចាត់ថ្នាក់ និងវាស់វែងតាមរំលស់ថ្លៃដើម។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

*៣.១០.២ ការទទួលស្គាល់ និងការវាស់វែង*

នៅពេលទទួលស្គាល់ដំបូង ក.ស.ស វាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូក (ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនវាស់វែងតម្លៃសមស្របតាមប្រាក់ចំណេញ ឬ ខាត (FVTPL)) ចំណាយប្រតិបត្តិការដោយផ្ទាល់ភ្ជាប់ជាមួយការទិញទ្រព្យសកម្មហិរញ្ញវត្ថុ។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុយោងតាម FVPL ត្រូវបានកត់ត្រាជាចំណាយនៅក្នុងប្រាក់ចំណេញ ឬ ខាត។

បម្រែបម្រួលតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុតាម FVPL ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬ ខាតផ្សេងៗ នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាត តាមការជាក់ស្តែង។

ទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានចាត់ថ្នាក់ឡើងវិញបន្ទាប់ពី ការទទួលស្គាល់ដំបូងឡើយ លើកលែងតែក្រុមហ៊ុនផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីនេះទ្រព្យហិរញ្ញវត្ថុដែលរងផលប៉ះពាល់ទាំងអស់ ត្រូវបានចាត់ថ្នាក់ឡើងវិញនៅថ្ងៃដំបូងនៃការិយបរិច្ឆេទរាយការណ៍ដំបូង បន្ទាប់ពីការផ្លាស់ប្តូរគំរូអាជីវកម្ម។

*រំលស់ថ្លៃដើម*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុបំពេញលក្ខខណ្ឌដែលមិនបានកំណត់ដូចនៅ FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងនៅក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងរក្សាទ្រព្យសកម្មដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ការកើនឡើងនៅកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) លើសមតុល្យប្រាក់ដើម។

*FVOCI - មូលបត្របំណុល*

មូលបត្របំណុលត្រូវបានវាស់វែងតាម FVOCI ប្រសិនបើបំពេញលក្ខខណ្ឌ និងមិនបានកំណត់ដូចនៅ FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងនៅក្នុងគំរូអាជីវកម្ម ដែលគោលបំណងត្រូវបានសម្រេចទាំងពីរតាមរយៈការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ការកើនឡើងនៅកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់តែប្រាក់ដើម និងការប្រាក់លើ សមតុល្យប្រាក់ដើម។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

*៣.១០.២ ការទទួលស្គាល់ និងការវាស់វែង* (តពីទំព័រមុន)

*FVOCI - មូលបត្រមូលធន*

លើការទទួលស្គាល់ដំបូងនៃការវិនិយោគភាគហ៊ុន ដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ក្រុមហ៊ុនអាចជ្រើសរើសដោយមិនបង្ហាញការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃសមស្របនៅក្នុង OCI លើមូលដ្ឋានតាមវិនិយោគនីមួយៗនោះទេ។

*FVPL*

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលមិនត្រូវបានចាត់ថ្នាក់ជាការវាស់វែងតាមថ្លៃដើមរំលស់ ឬ FVOCI ដូចដែលបានពិពណ៌នាខាងលើត្រូវបានវាស់វែងតាម FVPL។ នៅពេលទទួលស្គាល់ដំបូង ក្រុមហ៊ុនមិនអាចកំណត់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមតម្រូវការដើម្បីវាស់វែងរំលស់តាមថ្លៃដើម ឬ តាម FVOCI ដូចតាម FVPL ប្រសិនបើការធ្វើដូច្នេះលុបបំបាត់ ឬ កាត់បន្ថយយ៉ាងខ្លាំងនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ (លើកលែងតែការវាស់វែងតាម FVPL និងការវិនិយោគភាគហ៊ុនត្រូវបានវាស់វែងតាម FVOCI) ជាកម្មវត្ថុនៃការវាយតម្លៃលើអ៊ីមភែរមិន។

*ការវាយតម្លៃអាជីវកម្មគំរូ*

ក្រុមហ៊ុនបានធ្វើការវាយតម្លៃលើគោលបំណងនៃគំរូអាជីវកម្ម ដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងនៅកម្រិតផលប័ត្រ ពីព្រោះវាឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីវិធីដែលអាជីវកម្មត្រូវបានគ្រប់គ្រងហើយព័ត៌មានត្រូវបានផ្តល់ជូនដល់អ្នកគ្រប់គ្រង។ ព័ត៌មានដែលបានពិចារណារួមមាន៖

- គោលនយោបាយ និងកម្មវត្ថុដែលបានចែងសម្រាប់ផលប័ត្រ និងប្រតិបត្តិការនៃគោលនយោបាយទាំងនោះក្នុងការអនុវត្ត។ ទាំងនេះរួមបញ្ចូលថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រងផ្តោតលើការទទួលប្រាក់ចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សាទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ការផ្គូផ្គងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេល នៃបំណុលដែលពាក់ព័ន្ធ ឬ លំហូរចេញសាច់ប្រាក់ដែលបានរំពឹងទុក ឬ ការសម្រេចលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- របៀបដែលលទ្ធផលនៃផលប័ត្រត្រូវបានវាយតម្លៃ និងរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន
- ហានិភ័យដែលជះឥទ្ធិពលដល់ការអនុវត្តគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងរបៀបដែលហានិភ័យទាំងនោះត្រូវបានគ្រប់គ្រង
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មត្រូវបានផ្តល់សំណង - ឧ. ថាតើសំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬ លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងកាលបរិច្ឆេទមុន មូលហេតុសម្រាប់ការលក់ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

*៣.១០.២ ការទទួលស្គាល់ និងការវាស់វែង* (តពីទំព័រមុន)

*ការវាយតម្លៃលើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការបង់ប្រាក់តែប្រាក់ដើម និងការប្រាក់*

ក្នុងគោលបំណងនៃការវាយតម្លៃនេះ 'ប្រាក់ដើម' ត្រូវបានកំណត់ថាជាតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង។

'ការប្រាក់' ត្រូវបានកំណត់ថាជាការពិចារណាលើតម្លៃពេលវេលានៃសាច់ប្រាក់ និងសម្រាប់ហានិភ័យឥណទានដែលទាក់ទងនឹងសមតុល្យប្រាក់ដើម ក្នុងអំឡុងការិយបរិច្ឆេទជាក់លាក់នៃពេលវេលា និងសម្រាប់ហានិភ័យលើប្រាក់កម្ចី និងចំណាយជាមូលដ្ឋានគោល (ឧ. ហានិភ័យសាច់ប្រាក់ និងចំណាយរដ្ឋបាល) ក៏ដូចជាកម្រិតប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា ជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ក្រុមហ៊ុនពិចារណាលើលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។ នេះរួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬបរិមាណនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលវានឹងមិនបំពេញតាមលក្ខខណ្ឌនេះ។ ក្នុងការធ្វើការវាយតម្លៃនេះ ក្រុមហ៊ុនចាត់ទុកថា៖

- ព្រឹត្តិការណ៍យថាភាពដែលអាចនឹងផ្លាស់ប្តូរចំនួន ឬ ពេលវេលានៃលំហូរសាច់ប្រាក់។
- លក្ខខណ្ឌដែលអាចកែតម្រូវអត្រាខ័ណ្ឌប័ណ្ណតាមកិច្ចសន្យា រួមទាំងលក្ខណៈពិសេសអត្រាអថេរ
- ចំណាយបង់មុន និងពង្រីកនូវទម្រង់ និង
- លក្ខខណ្ឌដែលកំណត់ការទាមទារសំណងរបស់ក្រុមហ៊ុន ចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មដែលបានបញ្ជាក់ (ឧ. ទម្រង់ដែលមិនមានការកែច្នៃ)។

លក្ខណៈនៃការបង់ប្រាក់ជាមុនគឺស្របជាមួយនឹងលក្ខណៈវិនិច្ឆ័យ 'ការទូទាត់តែប្រាក់ដើម និងការប្រាក់' ប្រសិនបើចំនួនទឹកប្រាក់បង់ប្រាក់ជាមុនតំណាងឲ្យតម្លៃមិនទាន់ទូទាត់នៃប្រាក់ដើម និងការប្រាក់ លើសមតុល្យប្រាក់ដើម ដែលអាចរួមបញ្ចូលសំណងបន្ថែមសមហេតុផលសម្រាប់ការបញ្ចប់កិច្ចសន្យាមុនកាលកំណត់។ លើសពីនេះទៀត សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានទិញតាមតម្លៃអប្បហារចំពោះកិច្ចសន្យានៃតម្លៃ លក្ខណៈដែលអនុញ្ញាត ឬ តម្រូវឲ្យបង់ប្រាក់ជាមុនតាមតម្លៃដែលដែលតំណាងឲ្យចំនួនសរុបនៃកិច្ចសន្យា បូកនឹងការប្រាក់តាមកិច្ចសន្យាដែលបានបង្គរ (ប៉ុន្តែមិនទាន់ទូទាត់) កិច្ចសន្យាការប្រាក់ (ដែលអាចរួមបញ្ចូលផងដែរនូវសំណងបន្ថែមសមរម្យសម្រាប់ការបញ្ចប់មុនកាលកំណត់) ត្រូវបានចាត់ទុកថាស្របនឹងលក្ខណៈវិនិច្ឆ័យនេះ ប្រសិនបើតម្លៃទីផ្សារនៃការបង់ប្រាក់ជាមុនគឺមិនសំខាន់នៅពេលទទួលស្គាល់ដំបូង។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

#### *៣.១០.៣ ការឈប់ទទួលស្គាល់*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្នុងករណីដែលអាចអនុវត្តបាន ផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ផ្នែកនៃក្រុមទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) មិនត្រូវបានទទួលស្គាល់ជាចម្បង (ឧ. ដកចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន) នៅពេលៈ

- សិទ្ធិទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្មបានផុតកំណត់ ឬ
- ក្រុមហ៊ុនបានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ បានសន្មតកាតព្វកិច្ចទូទាត់លំហូរសាច់ប្រាក់ដែលបានទទួលពេញលេញ ដោយគ្មានការពន្យាពេលជាសារវន្តដល់ភាគីទីបីក្រោមការរៀបចំ 'ឆ្លងកាត់' (pass-through) និងណាមួយនៃ (ក) ក្រុមហ៊ុនបានផ្ទេរហានិភ័យ និងផលប្រយោជន៍ទាំងអស់នៃទ្រព្យសកម្ម ឬ ក្រុមហ៊ុនមិនបានផ្ទេរ ឬ រក្សានូវហានិភ័យ និងផលប្រយោជន៍ទាំងអស់នៃទ្រព្យសកម្មនោះទេ ប៉ុន្តែបានផ្ទេរការគ្រប់គ្រងនៃទ្រព្យសកម្ម។

នៅពេលដែលក្រុមហ៊ុនបានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ បានចូលទៅក្នុងការរៀបចំឆ្លងកាត់ នោះវាបានវាយតម្លៃថាតើវានៅរក្សាហានិភ័យ និងផលប្រយោជន៍ដែលសំខាន់ក្នុងនាមជាម្ចាស់កម្មសិទ្ធិដល់កម្រិតណា។ នៅពេលដែលក្រុមហ៊ុនមិនបានផ្ទេរ ឬ រក្សានូវហានិភ័យ និងផលប្រយោជន៍ទាំងអស់របស់ទ្រព្យសកម្ម ឬមិនបានផ្ទេរការគ្រប់គ្រងទ្រព្យសកម្មនោះ ក្រុមហ៊ុននៅតែបន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរត្រឹមកម្រិតនៃការចូលរួមបន្តរបស់ទ្រព្យសកម្មនោះ។ ក្នុងករណីនោះ ក្រុមហ៊ុនក៏ទទួលស្គាល់បំណុលដែលពាក់ព័ន្ធផងដែរ។ ទ្រព្យសកម្មដែលបានផ្ទេរ និងបំណុលដែលពាក់ព័ន្ធត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានដែលឆ្លុះបញ្ចាំងពីសិទ្ធិ និងកាតព្វកិច្ចដែលក្រុមហ៊ុនបានរក្សាទុក។

ការបន្តចូលរួមដែលបង្កើតទម្រង់នៃការធានាលើទ្រព្យសកម្មដែលបានផ្ទេរ គឺត្រូវបានវាស់វែងនៅកម្រិតទាបជាងរវាងតម្លៃយោងដើមនៃទ្រព្យសកម្ម និងតម្លៃពិចារណាអតិបរមាដែលក្រុមហ៊ុនអាចត្រូវបានទាមទារឲ្យទូទាត់វិញ។

#### *៣.១០.៤ អ៊ីមភែរមិនលើទ្រព្យសកម្មហិរញ្ញវត្ថុ*

ក្រុមហ៊ុនទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក (ECLs) សម្រាប់ឧបករណ៍បំណុលទាំងអស់ដែលមិនវាស់វែងតាមតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាត។ ECLs គឺផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់ពេលកំណត់ដោយអនុលោមតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ទាំងអស់ដែលក្រុមហ៊ុនរំពឹងថានឹងទទួលបាន ដោយធ្វើអប្បហារក្នុងអត្រាការប្រាក់ប្រសិទ្ធិភាពដើម។ លំហូរសាច់ប្រាក់ដែលរំពឹងទុក រួមបញ្ចូលលំហូរសាច់ប្រាក់ពីការលក់វត្ថុបញ្ចាំ ឬ ការបង្កើនឥណទានផ្សេងទៀត ដែលរួមបញ្ចូលទៅនឹងលក្ខខណ្ឌនៃកិច្ចសន្យា។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១០ ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

#### *៣.១០.៤ អ៊ីមភែរមិនលើទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

ECLs ត្រូវបានចែកចេញជាពីរដំណាក់កាល។ សម្រាប់ការបង្ហាញឥណទានដែលមិនមានការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ECLs ត្រូវបានផ្តល់សម្រាប់ការបាត់បង់ឥណទានដែលបណ្តាលមកពីព្រឹត្តិការណ៍លំនាំដើម ដែលអាចធ្វើទៅបានក្នុងរយៈពេល ១២ខែបន្ទាប់ (ECL ១២ខែ)។ ចំពោះហានិភ័យឥណទានទាំងនោះ ដែលមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង សំវិធានធនគឺត្រូវបានទាមទារសម្រាប់ការបាត់បង់ឥណទាន ដែលរំពឹងទុកក្នុងអាយុកាលដែលនៅសល់នៃហានិភ័យនោះ ដោយមិនគិតពីពេលវេលានៃលំនាំដើម (Lifetme ECL )។

សម្រាប់គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ក្រុមហ៊ុនអនុវត្តវិធីសាស្ត្រសាមញ្ញក្នុងការគណនា ECLs។ ដូច្នេះហើយ ក្រុមហ៊ុនមិនបានតាមដានការផ្លាស់ប្តូរហានិភ័យឥណទានទេ ប៉ុន្តែជំនួសមកវិញនូវសំវិធានធនទៅលើការខាតបង់ដោយផ្អែកលើ Lifetime ECLs នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ក្រុមហ៊ុនបានបង្កើតតារាងសំវិធានធនដែលផ្អែកលើបទពិសោធន៍ការបាត់បង់ឥណទាននៅពេលអតីតកាល ដោយកែសម្រួលសម្រាប់អថេរឆ្ពោះទៅមុខដែលជាក់លាក់ចំពោះអ្នកជំពាក់ និងបរិយាកាសសេដ្ឋកិច្ច។

ក្រុមហ៊ុនចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុមានការខូចខាត នៅពេលដែលការទូទាត់តាមកិច្ចសន្យាគឺហួសកំណត់ក្នុងរយៈពេល ៦០ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីខ្លះ ក្រុមហ៊ុនក៏អាចពិចារណាលើទ្រព្យសកម្មហិរញ្ញវត្ថុមិនមានការខូចខាត នៅពេលដែលព័ត៌មានខាងក្នុង ឬ ខាងក្រៅបង្ហាញថាក្រុមហ៊ុនទំនងជា ទទួលបានទឹកប្រាក់កិច្ចសន្យាដែលនៅសេសសល់ពេញលេញមុនពេលពិចារណាលើការបង្កើនឥណទានដែលគ្រប់គ្រងដោយក្រុមហ៊ុន។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាត់ចេញនៅពេលដែលមិនមានការរំពឹងទុកសមហេតុផល ក្នុងការស្តារលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

ក.ស.ស បានវាយតំលៃលើមូលដ្ឋានអថេរឆ្ពោះទៅមុខ សម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុ កត់ត្រាតាមរំលស់ថ្លៃដើម។ វិធីសាស្ត្រអ៊ីមភែរមិនត្រូវបានអនុវត្តអាស្រ័យលើ ថាតើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ឬ ទេ។

ចំពោះគណនីអតិថិជនត្រូវទទួល ក.ស.ស អនុវត្តវិធីសាស្ត្រសាមញ្ញដែលអនុញ្ញាតឲ្យប្រើប្រាស់ដោយ CIFRS ៩ ដែលទាមទារឲ្យមានការទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុកពេញមួយជីវិតចាប់តាំងពីពេលទទួលស្គាល់ដំបូងសម្រាប់គណនីអតិថិជនត្រូវទទួល *(កំណត់សម្គាល់លេខ ៣០.១)*។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៣.១១ *គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ*

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ជាទឹកប្រាក់ដែលត្រូវទទួលបានពីការផ្តល់សេវាកម្មផ្សេងៗដល់អតិថិជនក្នុងដំណើរការអាជីវកម្មធម្មតា។ ប្រសិនបើការប្រមូលប្រាក់កំណត់ក្នុងរយៈពេល ១ឆ្នាំ ឬ តិចជាង (ឬ នៅក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា) គណនីអតិថិជនត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលខ្លី។ ប្រសិនបើលើសពី ១ឆ្នាំ វាត្រូវបានចាត់ទុកជាទ្រព្យសកម្មរយៈពេលវែង។

គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មក ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ដកសំវិធានធនលើអ៊ីមភែរមិន និងការខាតបង់ឥណទានរំពឹងទុក *(កំណត់សម្គាល់លេខ ៣០.១)*។

### ៣.១២ *ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី*

ការវិនិយោគរយៈពេលខ្លី តំណាងឲ្យប្រាក់បញ្ញើមានកាលកំណត់ដែលដាក់នៅធនាគារ មានកាលកំណត់ពី ៦ខែ ទៅ ១២ខែ។ ចំណូលបានពីការប្រាក់ និងការប្រាក់ត្រូវទទួល បានទទួលស្គាល់ទៅតាមកាលកំណត់នៃប្រាក់បញ្ញើ។

### ៣.១៣ *សាច់ប្រាក់*

សាច់ប្រាក់ រួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារ និងការវិនិយោគរយៈពេលខ្លីដែលអាចបង្វិលទៅជាសាច់ប្រាក់បានភ្លាមៗ និងមានកាលកំណត់បីខែ ឬ តិចជាងបីខែ។

### ៣.១៤ *បំណុលហិរញ្ញវត្ថុ*

*ការទទួលស្គាល់ និងការវាស់វែងដំបូង*

បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ (តាមការទទួលស្គាល់ដំបូង) ជាបំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របក្នុងប្រាក់ចំណេញ ឬ ខាត ឥណទាននិងប្រាក់កម្ចី គណនីត្រូវទូទាត់ ឬ ជាឧបករណ៍និស្សន្ទដែលបានកំណត់ជាឧបករណ៍ការពារហានិភ័យដ៏មានប្រសិទ្ធភាពមួយ។

បំណុលហិរញ្ញវត្ថុទាំងអស់ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃទីផ្សារនិង (ក្នុងករណីឥណទាននិងកម្ចី និងគណនីត្រូវទូទាត់) តម្លៃសុទ្ធនៃថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធផ្ទាល់។

*ការវាស់វែងជាបន្តបន្ទាប់*

ចំពោះគោលបំណងនៃការវាស់វែងជាបន្តបន្ទាប់ បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាពីរប្រភេទ៖

- បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬ ខាត
- បំណុលហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម (ឥណទាន និងកម្ចី)។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.១៤ បំណុលហិរញ្ញវត្ថុ* (តពីទំព័រមុន)

*បំណុលហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម (ឥណទាន និងកម្ចី)*

បំណុលហិរញ្ញវត្ថុប្រភេទនេះ គឺប្រភេទដែលទាក់ទងនឹងក្រុមហ៊ុនបំផុត។ បន្ទាប់ពីការទទួលស្គាល់ដំបូង ឥណទាន និងប្រាក់កម្ចីដែលមានការប្រាក់ត្រូវបានវាស់វែងជាបន្តបន្ទាប់តាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព (EIR)។ ប្រាក់ចំណេញ និងខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ នៅពេលដែលបំណុលត្រូវបានឈប់ទទួលស្គាល់ក៏ដូចជាតាមរយៈដំណើរការរំលស់ EIR។

រំលស់ថ្លៃដើមត្រូវបានគណនាដោយគិតពីអប្បហារ ឬ បុព្វលាភលើការទិញ និងថ្លៃសេវា ឬចំណាយដែលជាផ្នែកសំខាន់នៃ EIR។ រំលស់តាម EIR ត្រូវបានរួមបញ្ចូលជាការចំណាយហិរញ្ញវត្ថុនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ប្រភេទនេះជាទូទៅអនុវត្តចំពោះឥណទាន និងប្រាក់កម្ចីដែលមានការប្រាក់។

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលវាស់វែងតាមតម្លៃរំលស់រួមមាន គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ បំណុលភតិសន្យា និងកម្ចី។

*ការឈប់ទទួលស្គាល់*

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចបំណុលត្រូវបានលុបចោល ឬ ផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយបំណុលមួយផ្សេងទៀតពីអ្នកឲ្យខ្ចីដូចគ្នា ក្នុងលក្ខខណ្ឌខុសគ្នាខ្លាំង ឬ លក្ខខណ្ឌនៃការទទួលខុសត្រូវដែលមានស្រាប់ត្រូវបានកែប្រែយ៉ាងច្រើន ការផ្លាស់ប្តូរ ឬ ការកែប្រែនេះត្រូវបានចាត់ទុកថាជាការឈប់ទទួលស្គាល់បំណុលដើម និងទទួលស្គាល់បំណុលថ្មី។ ភាពលម្អៀងគ្នានៃតម្លៃយោងនីមួយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### *៣.១៥ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងជាមួយគ្នា ហើយចំនួនសុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានកត់ត្រា និងនៅពេលដែលក្រុមហ៊ុនមានបំណងទូទាត់តាមមូលដ្ឋានសុទ្ធបន្ទាប់ពីកាត់កង ឬ មានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។ តែនេះមិនមែនជាករណីនេះទេចំពោះការកាត់កងកិច្ចសន្យាមេ និងទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុពាក់ព័ន្ធ ត្រូវបានបង្ហាញនៅតម្លៃដុលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១៦ ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់*

ទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មសម្រាប់លក់) ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មសម្រាប់លក់ នៅពេលដែលតម្លៃយោងរបស់ទ្រព្យសកម្មនោះ ត្រូវបានទទួលយកមកវិញជាចម្បងតាមរយៈប្រតិបត្តិការលក់ ហើយការលក់នោះត្រូវបានចាត់ទុកថាមានភាពច្បាស់លាស់។ ទ្រព្យសកម្មទាំងនោះ ត្រូវបានវាស់វែងតាមតម្លៃដែលទាបជាងរវាងតម្លៃយោង ជាមួយនឹងតម្លៃសមស្រប ដកចំណាយលើការលក់ លើកលែងតែទ្រព្យសកម្មទាំងនោះជាទ្រព្យវិនិយោគវាស់វែងតាមតម្លៃសមស្រប ឬ ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតក្នុងវិសាលភាពរបស់ CIFRS ៩ ករណីនេះទ្រព្យសកម្មទាំងនោះត្រូវបានវាស់វែងស្របតាមស្តង់ដារទាំងនោះ។

### *៣.១៧ ដើមទុន និងបុព្វលាភភាគហ៊ុន*

ដើមទុនដែលបានបង់ ត្រូវបានវាស់វែងតាមតម្លៃចារឹកលើភាគហ៊ុនទាំងអស់ដែលបានបោះផ្សាយ និងនៅសល់។ នៅពេលដែលភាគហ៊ុនត្រូវបានលក់ក្នុងតម្លៃបុព្វលាភ ភាពខុសគ្នារវាងប្រាក់ទទួលបាន និងតម្លៃចារឹកលើភាគហ៊ុនត្រូវបានបញ្ចូលទៅក្នុងបុព្វលាភភាគហ៊ុន។

ភាគហ៊ុនធម្មតាដែលមានភាគលាភ ត្រូវបានចាត់ថ្នាក់ជាមូលធន។ ការបែងចែកភាគលាភទៅម្ចាស់ភាគហ៊ុន ត្រូវបានកត់ត្រាដោយផ្ទាល់ក្នុងមូលធន។

### *៣.១៨ ភាគលាភ*

ភាគលាភលើភាគហ៊ុនធម្មតា ត្រូវបានទទួលស្គាល់ជាបំណុលនៅពេលប្រកាសមុនកាលបរិច្ឆេទរាយការណ៍។ ភាគលាភដែលបានប្រកាសបន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតចេញផ្សាយ មិនត្រូវបានទទួលស្គាល់ថាជាបំណុលនាកាលបរិច្ឆេទរបាយការណ៍នោះទេ។

សំវិធានធនត្រូវបានធ្វើឡើងសម្រាប់ទឹកប្រាក់នៃភាគលាភណាមួយដែលបានប្រកាស ដែលត្រូវបានអនុម័តត្រឹមត្រូវ និងលែងជាការសម្រេចចិត្តរបស់ ក.ស.ស នៅឬមុនចុងបញ្ចប់នៃរយៈពេលរាយការណ៍ ប៉ុន្តែមិនត្រូវបានចែកចាយនៅចុងបញ្ចប់នៃកាលបរិច្ឆេទរាយការណ៍នោះទេ។

### *៣.១៩ ប្រាក់កម្ចី*

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលបានកើតឡើង។ ប្រាក់កម្ចីត្រូវបានយោងបន្តតាមរំលស់ថ្លៃដើម ។ ភាពលម្អៀងរវាងសាច់ប្រាក់ទទួលបាន (ដកចំណាយប្រតិបត្តិការ) និងទឹកប្រាក់ដែលបង្វិលសងវិញត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬ ខាតលើរយៈពេលនៃប្រាក់កម្ចី ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់មានប្រសិទ្ធិភាព។

កម្រៃបានបង់លើដំណើរការចាប់ផ្តើមឥណទាន ត្រូវបានកត់ត្រាជាចំណាយប្រតិបត្តិការប្រាក់កម្ចី ត្រឹមទំហំដែរកម្រៃនោះមានភាពជឿជាក់ថាឥណទានទាំងអស់ដែលត្រូវដក។ ក្នុងករណីនេះ កម្រៃបានបង់លើដំណើរការឥណទានត្រូវបានពន្យាររហូតដល់ពេលដកសាច់ប្រាក់ជាក់ស្តែង។ នៅពេលមិនមានភស្តុតាងបញ្ជាក់ថាមានការដកឥណទានមួយចំនួន ឬ ឥណទានទាំងអស់ នោះកម្រៃបានបង់លើដំណើរការឥណទាន ត្រូវបានចាត់ថ្នាក់ជាចំណាយបង់មុនសម្រាប់សេវាសាច់ប្រាក់ និងត្រូវបានធ្វើរំលស់លើរយៈពេលឥណទានដែលពាក់ព័ន្ធ។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.១៩ ប្រាក់កម្ចី* (តពីទំព័រមុន)

***ថ្លៃដើមនៃប្រាក់កម្ចី***

ថ្លៃដើមនៃកម្ចីជាក់លាក់ និងទូទៅដែលបានចំណាយផ្ទាល់ក្នុងការទិញ ក្នុងការសាងសង់ ឬ ការផលិតទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវចំណាយពេលវេលាចាំបាច់សម្រាប់បញ្ចប់ ដើម្បីអាចប្រើប្រាស់តាមការគ្រោងទុករបស់ ឬ សម្រាប់លក់ ត្រូវបានកត់ត្រាបន្ថែមនៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ទ្រព្យសកម្មនោះមានភាពរួចរាល់សម្រាប់ការប្រើប្រាស់ ឬ អាចលក់បាន។

ចំណូលលើការវិនិយោគដែលបានពីការវិនិយោគបណ្តោះអាសន្ននៃប្រាក់កម្ចីជាក់លាក់ ដែលមិនទាន់ជាចំណាយរបស់ទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានដកចេញពីថ្លៃដើមនៃប្រាក់កម្ចីដែលត្រូវធ្វើមូលធនកម្ម។

ថ្លៃដើមនៃប្រាក់កម្ចីផ្សេងៗទៀតទាំងអស់ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាត ក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង។

*ការឈប់ទទួលស្គាល់*

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចបំណុលត្រូវបានរំសាយ លុបចោល ឬ ផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយបំណុលមួយផ្សេងទៀតពីអ្នកឲ្យខ្ចីដូចគ្នា ក្នុងលក្ខខណ្ឌខុសគ្នាខ្លាំង ឬ លក្ខខណ្ឌនៃការទទួលខុសត្រូវដែលមានស្រាប់ត្រូវបានកែប្រែយ៉ាងច្រើន ការផ្លាស់ប្តូរឬការកែប្រែនេះត្រូវបានចាត់ទុកថាជាការឈប់ទទួលស្គាល់បំណុលដើម និងត្រូវទទួលស្គាល់បំណុលថ្មី។ ភាពលម្អៀងគ្នានៃតម្លៃយោងនីមួយៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ***៣.២០ អត្ថប្រយោជន៍បុគ្គលិក***

*៣.២០.១ អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី*

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីរួមមាន ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល ប្រាក់បុព្វលាភបន្ថែម ប្រាក់បំណាច់អតីតភាពការងារ និងការរួមចំណែកដល់មូលនិធិសន្តិសុខសង្គម ត្រូវបានទទួលស្គាល់ជាចំណាយក្នុងអំឡុងការិយបរិច្ឆេទដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ដោយនិយោជិត។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

ក.ស.ស បានផ្តល់ឲ្យគម្រោងចំនួនពីរសម្រាប់អត្ថប្រយោជន៍បុគ្គលិក ទៅដល់បុគ្គលិកនៅពេលដែលដល់អាយុចូលនិវត្តន៍៖

- កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍
- ប្រាក់លើកទឹកចិត្ត

ក.ស.ស ក៏បានប្រតិបត្តិគម្រោងអត្ថប្រយោជន៍នេះដូចខាងក្រោម៖

- វិភាគទានរបស់បុគ្គលិក ១០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានប្រចាំខែរបស់បុគ្គលិក
- វិភាគទានរបស់ ក.ស.ស ១០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានប្រចាំខែរបស់បុគ្គលិក
- ជាមូលដ្ឋានប្រចាំឆ្នាំ ក្រុមប្រឹក្សាភិបាលសម្រេចលើប្រាក់បន្ថែមដែលនឹងត្រូវបញ្ចូលទៅក្នុងគម្រោងអត្ថប្រយោជន៍នេះ អាស្រ័យទៅតាមលទ្ធផលក្នុងអំឡុងឆ្នាំរបស់ ក.ស.ស។

បុគ្គលិកត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នេះ៖

- ជាបុគ្គលិកអចិន្ត្រៃយ៍។
- បានបំពេញការងារជូន ក.ស.ស ចំនួន ២៥ឆ្នាំ ឬ ច្រើនជាងនេះ
- បានចូលរួមវិភាគទុនក្នុងគម្រោងអត្ថប្រយោជន៍នេះដែលបានតម្រូវ
- មានប័ណ្ណបុគ្គលិក និង

ប្រសិនបើចូលនិវត្តមុនពេលដល់អាយុចូលនិវត្ត ការចូលនិវត្តនោះ ត្រូវមានការអនុម័តដោយប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(i) កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

(ក) បុគ្គលិកដែលបានបម្រើការងាររយៈពេល២៥ឆ្នាំ ឬ ច្រើនឆ្នាំជាងនេះ មានជម្រើសក្នុងការជ្រើសរើសទទួលបានអត្ថប្រយោជន៍នេះ គឺបើកប្រាក់ផ្តាច់តែមួយដងនៅពេលដល់អាយុចូលនិវត្ត ឬ បើកប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណៈភាព។ ការបង់ប្រាក់ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ គឺអាស្រ័យទៅតាមប្រការ និងលក្ខខណ្ឌដូចខាងក្រោម៖

*ការបង់ប្រាក់ផ្តាច់៖*

បុគ្គលិក ដែលសម្រេចទទួលយកការបង់ប្រាក់ផ្តាច់នៅពេលដល់អាយុចូលនិវត្តនឹងទទួលបាននូវទឹកប្រាក់ស្មើនឹង ១២,៥ដង នៃប្រាក់បៀវត្សរ៍មូលដ្ឋានខែចុងក្រោយរបស់ពួកគេ។

*ការបង់ប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណៈភាព៖*

ការបង់ប្រាក់ប្រចាំខែជូនបុគ្គលិក ដែលសម្រេចជ្រើសរើសយកអត្ថប្រយោជន៍ប្រចាំខែរហូតដល់ពេលទទួលមរណៈភាព អាស្រ័យទៅតាមចំនួនឆ្នាំនៃអតីតភាពការងាររបស់បុគ្គលិក ដូចបានកំណត់ខាងក្រោម៖

| *អតីតភាពការងារ* | *អត្ថប្រយោជន៍* |
|---|---|
| ២៥ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍មូលដ្ឋានសុទ្ធនៃខែចុងក្រោយរបស់ពួកគេ។ |
| ២៦ឆ្នាំ ដល់ ៤០ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍មូលដ្ឋានសុទ្ធនៃខែចុងក្រោយសុទ្ធរបស់ពួកគេ បូកនឹង ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ២៥ឆ្នាំ។ |
| ៤០ឆ្នាំឡើងទៅ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៩០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានសុទ្ធនៃខែចុងក្រោយរបស់ពួកគេ។ |

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(i) កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

(ខ) បុគ្គលិកដែលបានបម្រើការងាររយៈពេលតិចជាង ២៥ឆ្នាំ មិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នេះទេ ក៏ប៉ុន្តែពួកគេមានសិទ្ធិទទួលបានការបង់ប្រាក់ផ្តាច់មួយចំនួនដូចខាងក្រោម៖

| *អតីតភាពការងារ* | *អត្ថប្រយោជន៍* |
|---|---|
| តិចជាង ១០ឆ្នាំ | មិនទទួលបានអត្ថប្រយោជន៍ និងមិនទទួលបានវិភាគទានសរុបមកវិញទេ។ វិភាគទានសរុបនឹងក្លាយទៅជាចំណូលអត្ថប្រយោជន៍។ |
| ១០ឆ្នាំ ដល់ ២៤ឆ្នាំ | ទទួលបាន ២០០% នៃវិភាគទានសរុបពី ក.ស.ស និងបុគ្គលិក។ |

ប្រសិនបើគម្រោងនេះត្រូវបានលុបចោលដោយមូលហេតុណាមួយ បុគ្គលិកអាចទាមទារនូវចំណែកបដិភាគរបស់ខ្លួនពីគម្រោងនេះវិញបាន អាស្រ័យទៅតាមលក្ខខណ្ឌជាក់ស្តែងរបស់គម្រោង ព្រមទាំងនីតិវិធីដែលបានចែងក្នុងគោលការណ៍។

(គ) អត្ថប្រយោជន៍ចូលនិវត្តមុនកំណត់

បុគ្គលិកដែលបានចូលនិវត្ត ឬ ត្រូវបណ្តេញចេញមុនពេលដល់អាយុចូលនិវត្ត នឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

| *អតីតភាពការងារ* | *អត្ថប្រយោជន៍* |
|---|---|
| តិចជាង ១០ឆ្នាំ | មិនទទួលបានវិភាគទានសរុបរបស់បុគ្គលិកមកវិញទេ។ |
| ពី ១០ឆ្នាំ ដល់ ២០ឆ្នាំ | ១២០% នៃវិភាគទានសរុបរបស់បុគ្គលិក និងបូក ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ១០ឆ្នាំ។ |
| ពី ២១ឆ្នាំ ដល់ ៣០ឆ្នាំ | ១៣៥% នៃវិភាគទានសរុបរបស់បុគ្គលិក និងបូក ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ២១ឆ្នាំ។ |
| ពី ៣១ឆ្នាំ ដល់ ៤០ឆ្នាំ | ១៥៥% នៃវិភាគទានសរុបរបស់បុគ្គលិក និងបូក ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ៣១ឆ្នាំ។ |
| លើសពី ៤០ឆ្នាំ | ១៦៤% នៃវិភាគទានសរុបរបស់បុគ្គលិក។ |

(ឃ) អត្ថប្រយោជន៍មរណៈភាព

ការបង់ប្រាក់ផ្តាច់មួយដង នឹងធ្វើការទូទាត់នៅពេលដែលបុគ្គលិកដែលទទួលមរណៈភាព។ អត្ថប្រយោជន៍នេះ អាស្រ័យទៅលើការចូលរួមវិភាគទានសរុបពី ក.ស.ស និងបុគ្គលិក និងអាស្រ័យលើចំនួនឆ្នាំនៃអតីតភាពការងាររបស់បុគ្គលិកនោះ៖

| *អតីតភាពការងារ* | *មរណៈភាពទាក់ទងនឹងការងារ* | *មរណៈភាពមិនទាក់ទងនឹងការងារ* |
|---|---|---|
| តិចជាង ១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១ - ២០ ឆ្នាំ | ១៤៥% | ១៣៥% |
| ពី ២១ - ៣០ ឆ្នាំ | ១៥៥% | ១៤៥% |
| ពី ៣០ឆ្នាំឡើងទៅ | ១៦៥% | ១៥៥% |

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

*(i) កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

(ង) អត្ថប្រយោជន៍ពិការភាព៖

បុគ្គលិកដែលបានបម្រើការងារតិចជាង២៥ឆ្នាំ ហើយបានធ្លាក់ខ្លួនពិការ នឹងទទួលបានការបង់ប្រាក់ផ្តាច់មួយដង អាស្រ័យទៅតាមការចូលរួមវិភាគទានរបស់ ក.ស.ស និងបុគ្គលិកដូចខាងក្រោម៖

| *អតីតភាពការងារ* | *ពិការភាពបណ្តាលមកពីការងារ* | *ពិការភាពមិនបណ្តាលមកពីការងារ* |
|---|---|---|
| តិចជាង ១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១ឆ្នាំ ដល់ ២៥ឆ្នាំ | ១២៥% បូក ៣% លើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ១០ឆ្នាំ។ | ១១៥% បូក ៣% លើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ១០ឆ្នាំ។ |
| លើសពី ២៥ឆ្នាំ | | |
| ជម្រើសទី១ | ១៧០% | ១៦០% |
| ជម្រើសទី២ | អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ប្រចាំខែ | អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ប្រចាំខែ |

*(ii) ប្រាក់លើកទឹកចិត្ត*

ក.ស.ស ក៏បានផ្តល់ឲ្យនូវគម្រោងអត្ថប្រយោជន៍បុគ្គលិកផ្សេងមួយទៀត (ប្រាក់លើកទឹកចិត្ត) ដល់បុគ្គលិកដែលបម្រើការងារឲ្យ ក.ស.ស រហូតដល់អាយុចូលនិវត្តន៍។

នៅពេលចូលនិវត្តន៍ បុគ្គលិកនឹងទទួលបានប្រាក់លើកទឹកចិត្ត (ចំនួនទឹកប្រាក់សរុប) ដែលបានកំណត់ក្នុងរូបមន្ត = (ក) × (ខ)

(ក) ចំនួនឆ្នាំដែលបានបម្រើការងាររបស់បុគ្គលិក គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងាររហូតដល់អាយុចូលនិវត្តន៍

(ខ) អត្រាអត្ថប្រយោជន៍អាស្រ័យលើឆ្នាំដែលបានបម្រើការងាររបស់ពួកគេ ដែលបានចែងដូចខាងក្រោម៖

| *អតីតភាពការងារ* | *អត្រាអត្ថប្រយោជន៍* |
|---|---|
| រហូតដល់ ២៥ឆ្នាំ | ៧៥% នៃប្រាក់បៀវត្សរ៍គោលនៃខែចុងក្រោយរបស់ពួកគេនៅអាយុចូលនិវត្តន៍ |
| ២៦ឆ្នាំ ដល់ ៥០ឆ្នាំ | ៧៥% បូមបន្ថែម ១% បន្ថែមលើឆ្នាំនីមួយៗនៃអតីតភាពការងារដែលលើសពី ២៥ឆ្នាំ នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់ពួកគេ នៅអាយុចូលនិវត្តន៍ |
| លើសពី ៥០ឆ្នាំ | ៥០% គត់នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់ពួកគេនៅអាយុចូលនិវត្តន៍ |

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.២ អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍* (តពីទំព័រមុន)

(ii) *ប្រាក់លើកទឹកចិត្ត* (តពីទំព័រមុន)

(ខ) អត្រាអត្ថប្រយោជន៍អាស្រ័យលើឆ្នាំដែលបានបម្រើការងាររបស់ពួកគេ ដែលបានចែងដូចខាងក្រោមៈ (តពីទំព័រមុន)

បំណុលដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយអនុវត្តតាមគម្រោងអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ (កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ និងប្រាក់លើកទឹកចិត្ត) ជាតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍បានកំណត់ នាចុងការិយបរិច្ឆេទនៃរាយការណ៍ ដកតម្លៃសមស្របនៃគម្រោងទ្រព្យសកម្ម (ប្រសិនបើមាន)។ ការកំណត់កាតព្វកិច្ចប្រាក់សោធននិវត្តន៍ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន (projected unit credit)។ តម្លៃបច្ចុប្បន្ននៃការកំណត់កាតព្វកិច្ចប្រាក់សោធននិវត្តន៍ ត្រូវបានកំណត់ដោយអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមធ្យម នៃប្រាក់បម្រុងមូលនិធិ សម្រាប់បង់អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ដែលបានផ្ញើរនៅធនាគារនាកាលបរិច្ឆេទ ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណសាជីវកម្មមានគុណភាពខ្ពស់ ឬ មិនមានប័ណ្ណបំណុលដោយរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។

ចំណេញ និងខាតពីការវាយតម្លៃឡើងវិញដែលកើតពីការធ្វើនិយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មតការគណនាឬការវាយតម្លៃ (actuarial assumption) ត្រូវបានទទួលស្គាល់ក្នុងការិយបរិច្ឆេទ នៅពេលដែលកើតឡើង ដោយផ្ទាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

ក៏ប៉ុន្តែនៅក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានធ្វើវិសោធនកម្មលើគោលការណ៍ដោយកំណត់រយៈពេលអតិបរមាដែលនិយោជិតផ្តល់សេវាគឺ ៤០ឆ្នាំ។

*៣.២០.៣ កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ*

*ប្រាក់បំណាច់អតីតភាពការងារ*

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ("MoLVT") បានចេញសេចក្តីប្រកាសលេខ ៩៤៣ ដល់គ្រប់សហគ្រាស គ្រឹះស្ថាន និងអ្នកដែលត្រូវបានគ្របដណ្តប់ដោយមាត្រា ៨៩ (ថ្មី) នៃច្បាប់ការងារ ជាមួយនឹងសេចក្តីណែនាំស្តីពីការអនុវត្តដែលបានចេញនៅ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។ ប្រកាសនេះតម្រូវឲ្យធ្វើការទូទាត់ប្រាក់បំណាច់អតីតភាពការងារស្មើនឹងដប់ប្រាំថ្ងៃក្នុងមួយឆ្នាំនៃសេវាកម្មនិយោជិត សម្រាប់រយៈពេលអតិបរមាមិនលើសពី ៦ខែដោយផ្អែកលើប្រាក់ឈ្នួលសុទ្ធជាមធ្យមសម្រាប់ឆ្នាំនីមួយៗ។ និយោជិតមិនមានសិទ្ធិទទួលបានការទូទាត់ទេ ប្រសិនបើពួកគេលាលែងពីតំណែងមុននឹងទទួលបានការទូទាត់។ ការទូទាត់នឹងត្រូវបែកចែងតាមពេលពេលវេលាចាប់ពីខែធ្នូ ឆ្នាំ២០២១ ដូចខាងក្រោមៈ

- ស្មើនឹងបីថ្ងៃដែលត្រូវបង់រៀងរាល់ខែធ្នូ និង
- ស្មើនឹងបីថ្ងៃដែលត្រូវបង់រៀងរាល់ខែមិថុនា

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២០ អត្ថប្រយោជន៍បុគ្គលិក* (តពីទំព័រមុន)

*៣.២០.៣ កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ* (តពីទំព័រមុន)

*ប្រាក់បំណាច់អតីតភាពការងារ* (តពីទំព័រមុន)

ប្រាក់បំណាច់អតីតភាពការងារ ឡើងវិញមិនត្រូវលើសពីប្រាំមួយខែនៃប្រាក់ឈ្នួលជាមធ្យមរបស់និយោជិតនៃឆ្នាំបន្តបន្ទាប់នីមួយៗ។ និយោជិតមិនមានសិទ្ធិទទួលបានការទូទាត់ទេ ប្រសិនបើពួកគេលាលែងពីតំណែងមុនដល់កំណត់ការបង់ប្រាក់។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ក្រសួងបានចេញសេចក្តីណែនាំស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ ដែលបញ្ជាក់ថាការទូទាត់ប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ អាចពន្យារពេលដល់ខែមិថុនា ឆ្នាំ២០២២។ ប៉ុន្តែក្រុមហ៊ុនបានចាប់ផ្តើមការទូទាត់ប្រាក់បំណាច់អតីតភាពការងារចាប់ពីខែធ្នូ ឆ្នាំ២០២១។

ក.ស.ស ប៉ាន់ប្រមាណការផ្តល់ប្រាក់បំណាច់អតីតភាពការងារដោយប្រើតម្លៃបច្ចុប្បន្ននៃការទូទាត់ដែលរំពឹងទុកនាពេលអនាគត ដោយប្រើការសន្មតជាក់លាក់លើការលាឈប់របស់បុគ្គលិក ដោយផ្អែកលើបទពិសោធន៍ថ្មីៗរបស់ក្រុមហ៊ុន អត្រាមរណៈភាព និងអត្រាការប្រាក់ទីផ្សារ។

### *៣.២១ ពន្ធលើប្រាក់ចំណូល*

ចំណាយពន្ធរួមមានពន្ធក្នុងគ្រា និងពន្ធពន្យារ។ ពន្ធត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ពេញលេញ។

*៣.២១.១ ពន្ធលើប្រាក់ចំណូលក្នុងគ្រា*

ពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាលើមូលដ្ឋាននៃអត្រាពន្ធ និងច្បាប់ដែលបានអនុម័ត នៅចុងបញ្ចប់នៃកាលបរិច្ឆេទរាយការណ៍នៅក្នុងប្រទេសកម្ពុជា ដែល ក.ស.ស បង្កើតប្រាក់ចំណូលជាប់ពន្ធ។

*៣.២១.២ ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានផ្តល់ជូនដោយប្រើវិធីសាស្ត្របំណុល លើភាពខុសគ្នាបណ្តោះអាសន្នរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងទ្រព្យសកម្ម សម្រាប់គោលបំណងការរាយការណ៍នៃរបាយការណ៍ហិរញ្ញវត្ថុនៅចុងបញ្ចប់នៃកាលបរិច្ឆេទ។

បំណុលពន្ធពន្យារត្រូវបានទទួលស្គាល់រាល់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ លើកលែងតែករណីដែលបំណុលពន្ធពន្យារកើតឡើងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬ បំណុលនៅក្នុងប្រតិបត្តិការដែលមិនមែនជាការរួមបញ្ចូលអាជីវកម្ម និងនាពេលប្រតិបត្តិការ មិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ ឬ ប្រាក់ចំណេញ ឬខាតតាមពន្ធ។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២១ ពន្ធលើប្រាក់ចំណូល* (តពីទំព័រមុន)

*៣.២១.២ ពន្ធពន្យារ* (តពីទំព័រមុន)

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់រាល់ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន នៃឥណទានពន្ធដែលមិនបានប្រើប្រាស់ និងការខាតពន្ធមិនបានប្រើប្រាស់ ក្នុងកម្រិតមួយដែលអាចជឿជាក់បានថាប្រាក់ចំណេញជាប់ពន្ធនឹងមានសម្រាប់ការកាត់កង ជាមួយភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន និងយោងទៅមុខនៃឥណទានពន្ធមិនទាន់ប្រើប្រាស់ និង ខាតពន្ធមិនទាន់ប្រើប្រាស់ ដែលអាចប្រើប្រាស់បានលើកលែងតែករណីដែលទ្រព្យសកម្មពន្ធពន្យារ ទាក់ទងនឹងភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន កើតឡើងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬ បំណុលក្នុងប្រតិបត្តិការដែលមិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ ឬ ប្រាក់ចំណេញឬខាតតាមពន្ធ។

តម្លៃយោងសុទ្ធនៃទ្រព្យសកម្មពន្ធពន្យារ ត្រូវបានពិនិត្យឡើងវិញនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយដល់កម្រិតដែលមានភាពជឿជាក់ថា ប្រាក់ចំណេញជាប់ពន្ធមិនមានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យទ្រព្យសកម្មពន្ធពន្យារ អាចប្រើប្រាស់ទាំងអស់ ឬ មួយផ្នែក។ ទ្រព្យសកម្មពន្ធពន្យារដែលមិនទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនៅចុងបញ្ចប់នៃកាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានទទួលស្គាល់ក្នុងកម្រិតដែលមានភាពជឿជាក់ថា ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត នឹងអនុញ្ញាតឲ្យទ្រព្យសកម្មពន្ធពន្យារត្រូវបានប្រមូលមកវិញ។

ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងអនុវត្តចំពោះឆ្នាំ ដែលទ្រព្យសកម្មត្រូវបានសម្រេច ឬ បំណុលត្រូវបានទូទាត់ដោយផ្អែកលើអត្រាពន្ធ (និងច្បាប់ពន្ធ) ដែលត្រូវបានអនុម័ត ឬ អនុម័តយ៉ាងសំខាន់ក្នុងអំឡុងពេលនៃការរាយការណ៍។

ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារត្រូវបានកាត់កង ប្រសិនបើក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងទ្រព្យសកម្មពន្ធក្នុងគ្រា ជាមួយបំណុលពន្ធក្នុងគ្រា និងចំណូលពន្ធពន្យារទាក់ទងជាមួយក្រុមហ៊ុនដែលជាប់ពន្ធតែមួយ និងអាជ្ញាធរពន្ធដារដូចគ្នា។

ពន្ធ និងពន្ធពន្យារក្នុងគ្រាត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬ ខាត លើកលែងក្នុងកម្រិតមួយដែលវាទាក់ទងនឹងការទទួលស្គាល់នៃធាតុនៅក្នុងលទ្ធផលលេញលេញផ្សេងៗ ឬ ដោយផ្ទាល់នៅក្នុងមូលធន។ ក្នុងករណីនេះ ពន្ធក៏ត្រូវទទួលស្គាល់នៅក្នុងលទ្ធផលពេញលេញផ្សេងៗ ឬ ដោយផ្ទាល់នៅក្នុងមូលធនដែរ (រៀងគ្នា)។

### *៣.២២ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន*

ក.ស.ស ទទួលស្គាល់ប្រាក់ចំណូលនៅពេលដែល ក.ស.ស បំពេញកាតព្វកិច្ចអនុវត្តដោយការផ្ទេរទំនិញ ឬ សេវាកម្មដែលបានសន្យាទៅឲ្យអតិថិជន (នៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងលើទំនិញ ឬ សេវាកម្មនោះ)។ កាតព្វកិច្ចអនុវត្ត គឺជាការសន្យាដើម្បីផ្ទេរទំនិញ ឬ សេវាកម្មជាក់លាក់មួយទៅកាន់អតិថិជន។ ប្រាក់ចំណូលដែលត្រូវបានទទួលស្គាល់ គឺជាចំនួនដែលបានបែងចែកដើម្បីបំពេញកាតព្វកិច្ចអនុវត្ត។

## ៣. **សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### ៣.២២ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* (តពីទំព័រមុន)

*ចំណូលកំពង់ផែ*

ចំណូលកំពង់ផែជាចម្បងរួមមាន កម្រៃដែលទទួលបានពីការដឹកជញ្ជូនទំនិញ (ការលើកដាក់ទំនិញពីនាវា/ចូលនាវា) ការលើកដាក់ទំនិញ (ការលើកដាក់ទំនិញពីយានយន្ត/ចូលយានយន្ត) សេវាកម្មច្រកចេញចូលកំពង់ផែ (ការបញ្ជានាវា/ចំណត) ការរក្សាទុកកុងតឺន័រ និងសេវាផ្សេងៗ។ ប្រាក់ចំណូលពីការផ្តល់សេវាទាំងនេះត្រូវបានកត់ត្រានៅពេលដែលបានបំពេញសេវាជូនអតិថិជន។

*បម្រែបម្រួលនៃការពិចារណា*

កិច្ចសន្យាជាមួយអតិថិជនមិនរួមបញ្ចូលបម្រែបម្រួលនៃការពិចារណាដូចជា សិទ្ធបង្វិលត្រលប់អប្បហារអតិថិជន ឬ ការបង្វិលត្រលប់។

*ចំណូលពីការជួល - ក.ស.ស គឺជាភតិបតី*

ភតិសន្យាដែលផ្ទេរកសខាន់មួយនៃហានិភ័យ និងផលប្រយោជន៍ជាម្ចាស់កម្មសិទ្ធ ត្រូវបានរក្សាទុកដោយភតិបតី ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ចំណូលពីការជួលរបស់ភតិសន្យាប្រតិបត្តិត្រូវបានកត់ត្រាក្នុងរយៈពេលនៃភតិសន្យាតាមមូលដ្ឋានរំលស់ថេរ។

ទ្រព្យដែលបានជួលក្រោមប្រតិបត្តិការភតិសន្យា ត្រូវបានបញ្ចូលនៅក្នុងទ្រព្យវិនិយោគ *(កំណត់សម្គាល់លេខ ៧)* នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ចំណូលផ្សេងៗ*

ចំណូលផ្សេងៗរួមមាន កម្រៃពីការចូលឡានធំៗ និងកម្រៃផ្សេងៗ។ ចំណូលផ្សេងៗត្រូវបានទទួលស្គាល់នៅពេលសេវាកម្មត្រូវបានបំពេញ។

### ៣.២៣ *ចំណូលការប្រាក់*

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់ដោយប្រើវិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព EIR និងកត់ត្រាក្នុងចំណូលហិរញ្ញវត្ថុនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ៣.២៤ *ចំណេញក្នុងមួយភាគហ៊ុន*

*(i) មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន (Basic Earnings Per Share)*

មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ត្រូវបានបែងចែកការគណនាដោយៈ

- យកចំណេញរបស់ម្ចាស់ភាគហ៊ុន ក.ស.ស មិនរាប់បញ្ចូលចំណាយក្នុងការលក់ភាគហ៊ុនក្រៅពីភាគហ៊ុនធម្មតា
- ចែកជាមួយនឹងចំនួនភាគហ៊ុនធម្មតាជាមធ្យមដែលនៅសល់ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ (កែតម្រូវសម្រាប់ធាតុបន្ថែមនៅក្នុងភាគហ៊ុនធម្មតា ដែលបានបោះផ្សាយក្នុងអំឡុងឆ្នាំ និងមិនរាប់បញ្ចូលភាគហ៊ុនដែលអាចទិញយកមកវិញ (treasury shares) (ប្រសិនបើមាន))។

## ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២៤ ចំណេញក្នុងមួយភាគហ៊ុន* (តពីទំព័រមុន)

*(ii) ការថយចុះចំណេញក្នុងមួយភាគហ៊ុន (Diluted Earnings Per Share)*

ការថយចុះចំណេញក្នុងមួយភាគហ៊ុន កែតម្រូវតួលេខដែលបានប្រើប្រាស់ក្នុងការកំណត់មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុនដោយគិតទៅលើ៖

- ផលប៉ះពាល់ក្រោមប្រាក់ចំណូលក្រោយគិតពន្ធ នៃការប្រាក់ និងចំណាយហិរញ្ញវត្ថុផ្សេងៗ ដែលទាក់ទិននឹងសក្តានុពលនៃការថយចុះភាគហ៊ុនធម្មតា
- ចំនួនមធ្យមនៃភាគហ៊ុនធម្មតាបន្ថែម ដែលអាចត្រូវបានសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលនៃការថយចុះភាគហ៊ុនធម្មតាទាំងអស់។

### *៣.២៥ សំវិធានធន និងបំណុលយថាភាព*

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែល ក.ស.ស មានកាតព្វកិច្ចស្របច្បាប់ ឬ កាតព្វកិច្ចនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល។ វាទំនងថាលំហូរចេញនៃធនធានតំណាងឲ្យផលផលប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានតម្រូវឲ្យទូទាត់កាតព្វកិច្ចនោះ ហើយការប៉ាន់ស្មានដែលអាចទុកចិត្តបានអាចត្រូវបានធ្វើឡើងពីចំនួនទឹកប្រាក់នៃកាតព្វកិច្ច។ ប្រសិនបើតម្លៃពេលវេលានៃទឹកប្រាក់មានភាពជាសារវន្ត នោះសំវិធានធននឹងអប្បហារដោយប្រើប្រាស់អត្រាមុនគិតពន្ធក្នុងគ្រា ដែលឆ្លុះបញ្ចាំង (ដែលសមរម្យ) អំពីហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ នៅពេលដែលការធ្វើអប្បហារត្រូវបានបើប្រាស់ កំណើននៃសំវិធានធនដោយសារ ពេលវេលាកន្លងផុតត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

បំណុលយថាភាព មិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។ បំណុលយថាភាពត្រូវបានលាតត្រដាង ប្រសិនបើលទ្ធភាពនៃលំហូរចេញនៃធនធានតំណាងផលប្រយោជន៍សេដ្ឋកិច្ចមានកម្រិតទាប។ ទ្រព្យសកម្មយថាភាពមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវបានលាតត្រដាងនៅពេល ដែលលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអាចកើតមាន។ ទ្រព្យសកម្មយថាភាព ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដើម្បីធានាថាការអភិវឌ្ឍន៍ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើមានភាពពិតប្រាកដថាលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងកើតឡើង ទ្រព្យសកម្ម និងប្រាក់ចំណូលដែលពាក់ព័ន្ធត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

នៅពេលដែលការចំណាយមួយចំនួន ឬ ទាំងអស់តម្រូវឲ្យទូទាត់សំវិធានធន ត្រូវបានរំពឹងថានឹងត្រូវសងដោយភាគីផ្សេងមួយទៀត សំណងនឹងត្រូវទទួលស្គាល់ថានៅពេលដែល នឹងតែនៅពេលដែល ភាពប្រាកដប្រជានៃសំណងនឹងទទួលបានប្រសិនបើក្រុមហ៊ុនទូទាត់កាតព្វកិច្ច។ សំណងត្រូវចាត់ទុកជាទ្រព្យសកម្មដាច់ដោយឡែក។ ចំនួនទឹកប្រាក់បានទទួលស្គាល់សម្រាប់សំណង មិនត្រូវលើសពីទឹកប្រាក់សំវិធានធនទេ។

## ៣. សេចក្ដីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### *៣.២៦ ការរាយការណ៍តាមផ្នែក*

ប្រតិបត្តិការតាមផ្នែកត្រូវបានរាយការណ៍ឲ្យស៊ីសង្វាក់ជាមួយនឹងការរាយការណ៍ផ្ទៃក្នុង ដែល បាន ផ្ដល់ជូនប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (អគ្គនាយក)។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ជាអ្នកទទួលខុសត្រូវលើការបែងចែកធនធាន និងជាអ្នកវាយតម្លៃលទ្ធផលប្រតិបត្តិការតាមផ្នែក) ត្រូវបានកំណត់ជាក្រុមគណៈគ្រប់គ្រង (រួមបញ្ចូលទាំងអគ្គនាយកទូទៅ និងអគ្គនាយករងទាំងអស់) ដែលធ្វើការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រ។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRSs តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលប៉ះពាល់ដល់តួរលេខដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការកំណត់សម្គាល់ដែលភ្ជាប់ជាមួយ។

នៅក្នុងមតិយោបល់របស់គណៈគ្រប់គ្រង របាយការណ៍ហិរញ្ញវត្ថុទាំងនេះឆ្លុះបញ្ចាំងពីការកែតម្រូវទាំងអស់ដែលចាំបាច់ដើម្បីបង្ហាញលទ្ធផលសមស្រប សម្រាប់ការិយបរិច្ឆេទដែលបានបង្ហាញ។ លទ្ធផលជាក់ស្ដែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនេះ ហើយឥទ្ធិពលនៃការផ្លាស់ប្ដូរណាមួយនៅក្នុងការប៉ាន់ស្មាន នឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលការប៉ាន់ស្មានទាំងនេះត្រូវបានកំណត់ដោយសមហេតុផល។

*ការវិនិច្ឆ័យ*

នៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យដូចខាងក្រោម ក្រៅពីអ្វីដែលមានការទាក់ទងនឹងការប៉ាន់ស្មាន ដែលមានឥទ្ធិពលខ្លាំងបំផុតទៅលើទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

*ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន*

ក្រុមហ៊ុនបានអនុវត្តការវិនិច្ឆ័យដូចខាងក្រោមដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ការកំណត់ចំនួន និងពេលវេលានៃប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជនៈ

- *ការកំណត់អត្តសញ្ញាណកាតព្វកិច្ចអនុវត្ត*

  ក្រុមហ៊ុនកំណត់កាតព្វកិច្ចអនុវត្តដោយពិចារណា ថាតើសេវាកម្មដែលបានសន្យានៅក្នុងកិច្ចសន្យាមានភាពខុសគ្នាដែរ ឬ ទេ។ សេវាកម្មមួយមានភាពខុសគ្នានៅពេលដែលអតិថិជនអាចទទួលបានអត្ថប្រយោជន៍ពីសេវាកម្មដោយខ្លួនឯង ឬ រួមជាមួយធនធានផ្សេងៗដែលមានសម្រាប់អតិថិជន ហើយក្រុមហ៊ុនសន្យាក្នុងការផ្ទេរសេវាកម្មទៅឲ្យអតិថិជន អាចកំណត់អត្តសញ្ញាណដាច់ដោយឡែកពីការសន្យាផ្សេងទៀតនៅក្នុងកិច្ចសន្យា។

៤. **ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ** (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន* (តពីទំព័រមុន)

- *ការកំណត់អត្តសញ្ញាណកាតព្វកិច្ចអនុវត្ត* (តពីទំព័រមុន)

  ក្រុមហ៊ុនវាយតម្លៃកាតព្វកិច្ចអនុវត្តជាក្រុមនៃទំនិញ និងសេវាកម្មដាច់ដោយឡែកដែលមានលក្ខណៈដូចគ្នា និងមានលំនាំនៃការផ្ទេរដូចគ្នា ប្រសិនបើ (i) រាល់ទំនិញ ឬ សេវាកម្មផ្សេងគ្នាជាក្រុមត្រូវបានផ្ទេរតាមពេលវេលា និង (ii) វិធីសាស្ត្រដូចគ្នានៃវឌ្ឍនភាពនឹងត្រូវបានប្រើ (ឧ. ឯកតានៃការដឹកជញ្ជូន) ដើម្បីវាស់វែងវឌ្ឍនភាពរបស់អង្គភាពឆ្ពោះទៅរកការបំពេញការចិត្ត នៃកាតព្វកិច្ចអនុវត្ត។

- *ការកំណត់ពេលវេលានៃការបំពេញសេវាកម្មកំពង់ផែ*

  ក្រុមហ៊ុនទទួលស្គាល់ប្រាក់ចំណូល នៅពេលដែលបានបំពេញកាតព្វកិច្ចអនុវត្តដែលបានកំណត់ដោយផ្ទេរសេវាកម្មដែលបានសន្យាទៅឲ្យអតិថិជន។ សេវាកម្មមួយត្រូវបានចាត់ទុកថាត្រូវបានផ្ទេរនៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រង។ ក្រុមហ៊ុនកំណត់ (នៅពេលចាប់ផ្តើមកិច្ចសន្យា) ថាតើវានឹងផ្ទេរការគ្រប់គ្រងលើសេវាកម្មដែលបានសន្យាតាមរយៈពេលដែរ ឬទេ។ ប្រសិនបើក្រុមហ៊ុនមិនបំពេញកាតព្វកិច្ចអនុវត្តតាមរយៈពេលនោះ កាតព្វកិច្ចអនុវត្តត្រូវបានបំពេញក្នុងពេលមួយជាក់លាក់។

- *ការកំណត់វិធីសាស្ត្រសម្រាប់ការវាស់វែងវឌ្ឍនភាពនៃប្រាក់ចំណូលដែលត្រូវបានទទួលស្គាល់តាមពេលវេលា*

  ក្រុមហ៊ុនកំណត់វិធីសាស្ត្រសមស្របក្នុងការវាស់វែងវឌ្ឍនភាព ដែលតាមរយៈការប្រើប្រាស់វិធីសាស្ត្រធាតុចូល ឬ ធាតុចេញ។ វិធីសាស្ត្រធាតុចូល ទទួលស្គាល់ប្រាក់ចំណូលដោយផ្អែកលើលទ្ធភាពរបស់ក្រុមហ៊ុន ឬ ធាតុចូលក្នុងការបំពេញកាតព្វកិច្ចអនុវត្ត ខណៈពេលដែលវិធីសាស្ត្រធាតុចេញ ទទួលស្គាល់ប្រាក់ចំណូលដោយផ្អែកលើការវាស់វែងដោយផ្ទាល់នៃតម្លៃដល់អតិថិជននៃសេវាកម្មដែលបានផ្ទេរដល់ការិយបរិច្ឆេទ។

  ក្រុមហ៊ុនបានកំណត់ថា វិធីសាស្ត្រធាតុចេញ ជាវិធីសាស្ត្រល្អបំផុតក្នុងការវាស់វែងវឌ្ឍនភាពសម្រាប់សេវាកម្មកំពង់ផែ ហើយក៏ត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងតម្លៃប្រតិបត្តិការផងដែរ។

- *ការកំណត់វិធីសាស្ត្រក្នុងការប៉ាន់ស្មានការពិចារណាអថេរ និងវាយតម្លៃឧបសគ្គ*

  ក្រុមហ៊ុនរួមបញ្ចូលនូវចំនួនមួយចំនួន ឬ ទាំងអស់នៃការពិចារណាអថេរដែលបានប៉ាន់ស្មាន ប៉ុន្តែត្រឹមតែក្នុងកម្រិត ដែលវាមានលទ្ធភាពខ្ពស់នៃការកត់ត្រាបញ្ច្រាស់យ៉ាងសំខាន់នៃចំណូលបង្គបានទទួលស្គាល់ នឹងមិនកើតឡើងនៅពេលដែលភាពមិនច្បាស់លាស់ដែលទាក់ទងនឹងការពិចារណាអថេរត្រូវបានដោះស្រាយជាបន្តបន្ទាប់។ ក្រុមហ៊ុនពិចារណាទាំងលទ្ធភាព និងទំហំនៃការកត់ត្រាបញ្ច្រាសនៃប្រាក់ចំណូល ក្នុងការវាយតម្លៃវិសាលភាពនៃការពិចារណាអថេរដែលក្រុមហ៊ុននឹងត្រូវដាក់កំហិត។ កត្តាដូចជា (i) ភាពងាយរងគ្រោះខ្លាំងចំពោះកត្តាដែលនៅក្រៅឥទ្ធិពលរបស់ក្រុមហ៊ុន (ii) ពេលវេលានៃការដោះស្រាយភាពមិនច្បាស់លាស់ និង (iii) មានចំនួនច្រើន និងទូលំទូលាយនៃការពិចារណាដែលអាចធ្វើបាន ត្រូវបានពិចារណា។

## ៤. **ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ** (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន* (តពីទំព័រមុន)

- *ការកំណត់វិធីសាស្ត្រក្នុងការប៉ាន់ស្មានការពិចារណាអថេរ និងវាយតម្លៃឧបសគ្គ* (តពីទំព័រមុន)

  ក្រុមហ៊ុនបានកំណត់ថាវិធីសាស្រ្តតម្លៃដែលរំពឹងទុក គឺជាវិធីសាស្រ្តសមស្របដើម្បីប្រើក្នុងការប៉ាន់ស្មានការពិចារណាអថេរដោយផ្តល់នៃលទ្ធផលអាចកើតមាន។

  មុននឹងរួមបញ្ចូលចំនួនណាមួយនៃការពិចារណាអថេរទៅក្នុងតម្លៃប្រតិបត្តិការ ក្រុមហ៊ុនពិចារណាថាតើតម្លៃនៃការពិចារណាអថេរត្រូវបានរឹតបន្តឹង។ ក្រុមហ៊ុនបានកំណត់ថាការប៉ាន់ស្មាននៃការពិចារណាអថេរត្រូវដាក់រឹតបន្តឹងយ៉ាងពេញលេញ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្រ្តរបស់ខ្លួន (ចន្លោះនៃលទ្ធផលដែលអាចកើតមាន) និងភាពមិនអាចព្យាករណ៍មុនបាននៃកត្តាផ្សេងទៀតនៅខាងក្រៅឥទ្ធិពលរបស់ក្រុមហ៊ុន។

*ចំណាត់ថ្នាក់នៃភតិសន្យា - ក្រុមហ៊ុនជាភតិបតី*

ក្រុមហ៊ុនបានកំណត់ (ដោយផ្អែកលើការវាយតម្លៃបញ្ញតិ និងលក្ខខណ្ឌនៃការរៀបចំ ដូចជារយៈពេលជួលនៃការជួលបន្តដែលបង្កើតរយៈពេលដែលនៅសល់នៃការជួល ថាវាមិនរក្សាបាននូវហានិភ័យ និងផលប្រយោជន៍ដែលកើតឡើងចំពោះកម្មសិទ្ធិរបស់ទ្រព្យសម្បត្តិ និងគណនីសម្រាប់កិច្ចសន្យាជាភតិសន្យាហិរញ្ញវត្ថុ។

*ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ*

ក្រុមហ៊ុនអនុវត្តការវិនិច្ឆ័យក្នុងការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ (ឬផ្នែកសមាសភាគរបស់ឧបករណ៍ហិរញ្ញវត្ថុ) លើការទទួលស្គាល់ដំបូងជាទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬ ឧបករណ៍មូនធនស្របតាមខ្លឹមសារនៃការរៀបចំកិច្ចសន្យា និងនិយមន័យនៃទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬ ឧបករណ៍មូលធន។ ខ្លឹមសារនៃឧបករណ៍ហិរញ្ញវត្ថុ (ជាជាងទម្រង់ច្បាប់របស់វា) គ្រប់គ្រងការចាត់ថ្នាក់របស់ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ការវាស់វែងតម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ*

នៅពេលវាស់តម្លៃទីផ្សារនៃទ្រព្យសកម្ម ឬ បំណុល ក្រុមហ៊ុនប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានតាមទីផ្សារតាមដែលអាចធ្វើទៅបាន។ តម្លៃទីផ្សារ ត្រូវបានចាត់ថ្នាក់ទៅតាមកម្រិតផ្សេងៗគ្នាក្នុងឋានានុក្រមតម្លៃសមរម្យ ដោយផ្អែកលើធាតុចូលដែលបានប្រើក្នុងបច្ចេកទេសវាយតម្លៃខាងក្រោម៖

កម្រិតទី១៖ តម្លៃដែលបានដកស្រង់ (មិនបានកែតម្រូវ) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ បំណុលដូចគ្នា។

កម្រិតទី២៖ ធាតុចូលក្រៅពីតម្លៃដែលបានដកស្រង់ដែលបានរួមបញ្ចូលក្នុងកម្រិតទី១ ដែលអាចសង្កេតបានលើទ្រព្យសកម្ម ឬ បំណុលដោយផ្ទាល់ (ឧ. ជាតម្លៃ) ឬ ដោយប្រយោល (ឧ. បានមកពីតម្លៃ)។

កម្រិតទី៣៖ ធាតុចូលនៃទ្រព្យសកម្ម ឬ បំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុដែលមិនអាចសង្កេតបាន)។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*ការវាស់វែងតម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ* (តពីទំព័រមុន)

នៅពេលដែលតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មិនអាចវាស់វែងបានដោយផ្អែកលើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម តម្លៃសមស្របរបស់ពួកគេត្រូវបានវាស់វែងដោយប្រើបច្ចេកទេសវាយតម្លៃ រួមទាំងលំហូរសាច់ប្រាក់អប្បហារ ("DCF")។ ធាតុចូលសម្រាប់ម៉ូឌែលទាំងនេះគឺត្រូវបានយកចេញពីទីផ្សារដែលអាចសង្កេតបាន (ប្រសិនបើអាចធ្វើទៅបាន) ប៉ុន្តែនៅពេលដែលវាមិនអាចទៅរួចកម្រិតនៃការវិនិច្ឆ័យគឺត្រូវបានតម្រូវឲ្យបង្កើតតម្លៃសមស្រប។ ការវិនិច្ឆ័យរួមមានការពិចារណាលើធាតុចូលដូចជា ហានិភ័យសន្ទនីយភាពសាច់ប្រាក់ ហានិភ័យឥណទាន និងម៉ូឌែលធាតុចូលដូចជាការប្រែប្រួលសម្រាប់និស្សន្ទវត្ថុដែលមានកាលបរិច្ឆេទយូរជាង និងអត្រាអប្បហារ អត្រាការបង់ប្រាក់មុន និងការសន្មតអត្រាលំនាំដើមសម្រាប់មូលបត្រដែលផ្អែកលើទ្រព្យសកម្ម។

សម្រាប់ការវិភាគលំហូរសាច់ប្រាក់អប្បហារ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត និងអត្រាអប្បហារ គឺផ្អែកលើព័ត៌មានទីផ្សារបច្ចុប្បន្ន និងអត្រាអនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុដែលគុណភាពឥណទាន និងលក្ខណៈដែលដល់កាលកំណត់ស្រដៀងគ្នា។ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតត្រូវបានជះឥទ្ធិពលដោយកត្តាដូចជា លក្ខខណ្ឌសេដ្ឋកិច្ច (រួមទាំងហានិភ័យជាក់លាក់របស់ប្រទេស) ការប្រមូលផ្តុំនៅក្នុងឧស្សាហកម្មជាក់លាក់ ប្រភេទឧបករណ៍ ឬរូបិយប័ណ្ណ សាច់ប្រាក់ងាយស្រួលទីផ្សារ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់ដៃគូ។ អត្រាអប្បហារត្រូវបានជះឥទ្ធិពលដោយមិនមានហានិភ័យអត្រាការប្រាក់ និងហានិភ័យឥណទាន។ បម្រែបម្រួលនៃការសន្មតទាក់ទងនឹងកត្តាទាំងនេះអាចប៉ះពាល់ដល់តម្លៃទីផ្សារ ដែលបានរាយការណ៍នៅក្នុងឧបករណ៍ហិរញ្ញវត្ថុ។

*រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ*

ស្តង់ដារ CIAS ២១ ស្តីពីផលប៉ះពាល់នៃការប្តូរអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស តម្រូវឲ្យគណៈគ្រប់គ្រងប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន ដើម្បីកំណត់នូវរូបិយប័ណ្ណមុខងាររបស់ក.ស.ស ដែលវាបង្ហាញយ៉ាងច្បាស់នូវឥទ្ធិពលសេដ្ឋកិច្ច នៃប្រតិបត្តិការព្រឹត្តិការណ៍ និងលក្ខខណ្ឌទាំងឡាយដែលមានការពាក់ព័ន្ធទៅនឹងក.ស.ស។ ដើម្បីធ្វើការវិនិច្ឆ័យនេះ ក.ស.ស ត្រូវពិចារណាដូចខាងក្រោម៖

(i) រូបិយប័ណ្ណដែលមានឥទ្ធិពលជាសារវន្តលើតម្លៃឧបករណ៍ហិរញ្ញវត្ថុ និងសេវាកម្ម (នេះច្រើនតែជារូបិយប័ណ្ណដែលដាក់តម្លៃលើឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន និង សេវាត្រូវបានកំណត់ និងធ្វើការទូទាត់)

(ii) រូបិយប័ណ្ណមានក្នុងមូលនិធិដែលទទួលបានពីសកម្មភាពហិរញ្ញប្បទាន និង

(iii) រូបិយប័ណ្ណដែលចំណូលទទួលបានពីសកម្មភាពប្រតិបត្តិការ តែងតែត្រូវបានរក្សាទុក។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការវិនិច្ឆ័យ* (តពីទំព័រមុន)

*រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ* (តពីទំព័រមុន)

ដោយផ្អែកទៅតាមខ្លឹមសារសេដ្ឋកិច្ច នៃព្រឹត្តិការណ៍ និងហេតុការណ៍សំខាន់ៗ របស់ក.ស.ស

រូបិយប័ណ្ណមុខងាររបស់ ក.ស.ស ត្រូវបានកំណត់ជាខ្មែររៀល។ ខ្មែររៀល គឺជារូបិយប័ណ្ណ នៃស្ថានភាពសេដ្ឋកិច្ចចម្បងក្នុងប្រតិបត្តិការរបស់ ក.ស.ស និងជារូបិយប័ណ្ណមានឥទ្ធិពលចម្បងទៅលើចំណូល និងចំណាយ។

*ការប៉ាន់ស្មាន និងការសន្មត*

ការសន្មតសំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃភាពមិនប្រាកដប្រជានៃការប៉ាន់ស្មាននាកាលបរិច្ឆេទរបាយការណ៍ ដែលមានហានិភ័យជាសារវន្តក្នុងការបង្កឲ្យមានការកែតម្រូវជាសារវន្តទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ត្រូវបានពិពណ៌នាខាងក្រោម។ ក្រុមហ៊ុនផ្អែកលើការសន្មត និងការប៉ាន់ស្មានរបស់ខ្លួនលើព័ត៌មានដែលមាននៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ។ ទោះជាយ៉ាងនេះក្តី កាលៈទេសៈ និងការសន្មតដែលមានស្រាប់អំពីការវិវឌ្ឍនាពេលអនាគតអាចផ្លាស់ប្តូរដោយសារតែ បម្រែបម្រួលទីផ្សារ ឬ កាលៈទេសៈដែលកើតឡើងដែលក្រុមហ៊ុនមិនអាចគ្រប់គ្រងបាន។ បម្រែបម្រួលបែបនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសន្មតនៅពេលដែលវាកើតឡើង។

*សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុកចំពោះគណនីអតិថិជន*

ការវាស់វែងសំវិធានធន នៃការខាតបង់ឥណទានដែលរំពឹងទុកចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមវិធីរំលស់ថ្លៃដើម និង FVOCI គឺជាផ្នែកដែលទាមទារការប្រើប្រាស់ម៉ូឌែលស្មុគស្មាញ និងការសន្មតសំខាន់ៗអំពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត និងឥរិយាបទឥណទាន (ឧទាហរណ៍ លទ្ធភាពនៃការខូចខាតរបស់អតិថិជន និងលទ្ធផលខាតបង់)។

ក.ស.ស អនុវត្តស្តង់ដារ CIFRS ៩ តាមវិធីសាស្ត្រសាមញ្ញ ក្នុងការវាស់វែកការខាតបង់ឥណទានដែលរំពឹងទុក (ECL) ដែលប្រើការខាតបង់ដែលរំពឹងទុកមួយអាយុកាល (Lifetime ECL) សម្រាប់គណនីអតិថិជនទាំងអស់។

ដើម្បីវាស់វែងការបាត់បង់ឥណទានដែលរំពឹងទុក គណនីអតិថិជនត្រូវបានចាត់ថ្នាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យឥណទានរួម និងថ្ងៃផុតកំណត់។

*ពន្ធ*

ពន្ធត្រូវបានគណនាលើមូលដ្ឋាននៃបទប្បញ្ញត្តិច្បាប់ពន្ធ និងការបកស្រាយនាពេលបច្ចុប្បន្ន។ តែទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះមានការប្រែប្រួលតាមកាលកំណត់ ហើយការកំណត់ចុងក្រោយលើចំណាយពន្ធ នឹងត្រូវធ្វើតាមការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ ("GDT")។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយនៃបញ្ហាទាំងនេះ ខុសពីចំនួនដែលបានកត់ត្រាដំបូងដោយក្រុមហ៊ុន ភាពខុសគ្នានេះនឹងជះឥទ្ធិពលលើសំវិធានធនពន្ធលើប្រាក់ចំណូល និងពន្ធពន្យារក្នុងគ្រាដែលការកំណត់ចុងក្រោយនេះត្រូវបានធ្វើឡើងដោយ GDT។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការប៉ាន់ស្មាន និងការសន្មត* (តពីទំព័រមុន)

*តម្លៃពិតជាក់ស្តែងសុទ្ធនៃសន្និធិ*

ក្រុមហ៊ុនលុបថ្លៃដើមនៃសន្និធិ ដែលបណ្តាលមកពីការខូចខាត ខូចទ្រង់ទ្រាយនៃរូបរាង ភាពហួសសម័យ បម្រែបម្រួលកម្រិតតម្លៃ ឬ មូលហេតុផ្សេងៗ។ តម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃពិតជាក់ស្តែងសុទ្ធរបស់សន្និធិ ត្រូវបានពិនិត្យជារៀងរាល់ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ធាតុនៃសន្និធិ ដែលត្រូវបានកំណត់ថាលែងប្រើប្រាស់ និងមិនអាចប្រើប្រាស់បានក៏ត្រូវបានលុបចេញ និងគិតជាការចំណាយសម្រាប់ការិយបរិច្ឆេទការរាយការណ៍។

*ការប៉ាន់ស្មាន់អាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបី*

អាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបី ត្រូវបានប៉ាន់ស្មានដោយផ្អែកលើរយៈពេលដែលទ្រព្យសកម្មទាំងនេះ ត្រូវបានគេរំពឹងថានឹងមានសម្រាប់ប្រើប្រាស់។ អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មទាំងនេះត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពប្រសិនបើមានការរំពឹងទុកខុសពីការប៉ាន់ស្មានពីមុន ដោយសារតែភាពហួសសម័យ បច្ចេកទេស និងពាណិជ្ជកម្ម និងដែនកំណត់ផ្សេងទៀតលើការប្រើប្រាស់ទ្រព្យសកម្ម។ រាល់ការថយចុះនៃតម្លៃកាកសំណល់ និងការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃទ្រព្យ រោងចក្រនិងបរិក្ខារ និងទ្រព្យអរូបី អាចបង្កើនការចំណាយប្រតិបត្តិការដែលបានកត់ត្រារបស់ក្រុមហ៊ុន និងកាត់បន្ថយទ្រព្យសកម្មដែលពាក់ព័ន្ធ។

*ការវាស់វែងតម្លៃសមស្របនៃទ្រព្យវិនិយោគ*

តម្លៃសមស្របនៃទ្រព្យវិនិយោគ ត្រូវបានកំណត់ដោយការប្រើប្រាស់បច្ចេកទេសវាយតម្លៃ។ សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីវិធីសាស្ត្រនៃការវាយតម្លៃ សូមមើលនូវកំណត់សម្គាល់លេខ ៧។

*អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

ក្រុមហ៊ុនវាយតម្លៃរាល់កាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ថាតើមានសូចនាករណាមួយនៃអ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទាំងអស់ (ទ្រព្យ រោងចក្រនិងបរិក្ខារ និងទ្រព្យអរូបី)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទាំងនេះ ត្រូវបានពិនិត្យមើលថាមានអ៊ីមភែរមិន នៅពេលណាដែលព្រឹត្តិការណ៍ ឬ បម្រែបម្រួលកាលៈទេសៈណាមួយបង្ហាញថាតម្លៃយោងនៃទ្រព្យសកម្ម អាចនឹងមិនអាចប្រមូលមកវិញបាន។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (តពីទំព័រមុន)

*ការប៉ាន់ស្មាន និងការសន្មត* (តពីទំព័រមុន)

*អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ* (តពីទំព័រមុន)

ទាំងនេះតម្រូវឲ្យមានការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម។ តម្លៃដែលអាចប្រមូលមកវិញបាន ជាតម្លៃដែលខ្ពស់ជាងវាងតម្លៃសមស្របរបស់ទ្រព្យសកម្មមួយ ដកចំណាយក្នុងការលក់ និងតម្លៃប្រើប្រាស់។ តម្លៃសមស្រប ដកថ្លៃដើមដើម្បីលក់ ជាតម្លៃដែលអាចទទួលបានពីការលក់ទ្រព្យសកម្មក្នុងប្រតិបត្តិការជហោងដៃ (arm's length transaction) ខណៈពេលដែលតម្លៃប្រើប្រាស់ ជាតម្លៃបច្ចុប្បន្ននៃការរំពឹងទុកនៃលំហូរសាច់ប្រាក់បានប៉ាន់ស្មាននាពេលអនាគត ថានឹងកើតឡើងពីការបន្តប្រើប្រាស់ទ្រព្យសកម្ម និងពីការលក់ទ្រព្យសកម្មនោះនៅចុងបញ្ចប់អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ។ តម្លៃដែលអាចទទួលបានមកវិញត្រូវបានប៉ាន់ស្មានចំពោះទ្រព្យសកម្មនីមួយៗ (ប្រសិនបើវាមិនអាចធ្វើទៅបាន) សម្រាប់ឯកតាបង្កើតសាច់ប្រាក់ដែលជាកម្មសិទ្ធិរបស់ទ្រព្យសកម្ម។

*ការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ*

ក្រុមហ៊ុនពិនិត្យលើតម្លៃយោង នៃទ្រព្យសកម្មពន្ធពន្យារនៅចុងគ្រានៃកាលបរិច្ឆេទរាយការណ៍នីមួយៗ និងកាត់បន្ថយពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ដល់កម្រិតមួយដែលវាលែងមានលទ្ធភាពដែលនឹងអាចមានប្រាក់ចំណូលជាប់ពន្ធគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យប្រើប្រាស់ទាំងអស់ ឬ ផ្នែកមួយនៃពន្ធពន្យារលើប្រាក់ចំណូល។

*កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍*

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ពឹងផ្អែកលើកត្តាមួយចំនួន ដែលត្រូវបានកំណត់នៅក្នុងមូលដ្ឋានការគណនា/វាយតម្លៃ (actuarial) ដោយប្រើការប៉ាន់ស្មានមួយចំនួន។ ការប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃសុទ្ធនៃប្រាក់ចូលនិវត្តន៍រួមមាន អត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាចលនានៃបុគ្គលិក និងការរំពឹងទុកអាយុជីវិត។ បម្រែបម្រួលណាមួយក្នុងប៉ាន់ស្មានទាំងនេះ នឹងប៉ះពាល់ដល់ តម្លៃយោងគណនេយ្យនៃកាតព្វកិច្ចប្រាក់សោធននិវត្តន៍។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៥. ព័ត៌មានតាមផ្នែក

ចំណូលសំខាន់ៗ បានមកពីសេវាកំពង់ផែ។ លើសពីនេះ ក.ស.ស ក៏មានតំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការជាភតិបតី និងរកចំណូលបានពីការជួលផងដែរ*(កំណត់សម្គាល់លេខ ៧)*។

ក.ស.ស មានប្រតិបត្តិការតាមផ្នែកមួយដែលអាចរាយការណ៍បាន ហៅថាសេវាកំពង់ផែ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (អគ្គនាយកប្រតិបត្តិ) ពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផលនៃសេវាតាមផ្នែករបស់កំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ ("CODM") ដោយផ្អែកការវាស់វែងចំណូលដុល។ CODM ក៏ពិនិត្យឡើងវិញលើចំណេញមុនគិតពន្ធ និងចំណេញសុទ្ធទាំងមូល ធៀបនឹងការិយបរិច្ឆេទមុនៗ។

ក.ស.ស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយប្រាក់ចំណូលភាគច្រើនមានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

ប្រាក់ចំណូលចំនួន ១២២.១៤២ ពាន់រៀល បានមកពីអតិថិជនធំៗចំនួនបីក្រុមហ៊ុនក្នុងអំឡុងឆ្នាំ។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៦. ទ្រព្យ និងបរិក្ខារ

| | ២០២២ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | *ដីធ្លី* | *ការកែលម្អដីធ្លី* | *អគារ* | *បរិក្ខារ បច្ចេកទេស* | *គ្រឿងសង្ហារិម និងបរិក្ខារបំពាក់* | *កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ* | *យានយន្ត* | *បរិក្ខារ កំពង់ផែសមុទ្រ* | *ប៉ាឡែត* | *សំណង់កំពុង សាងសង់* | *សរុប* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ២៩៦.៧៣៥.៤០៩ | ៥៨.៨៥០.៩២២ | ៣៤៧.៥០៧.៦៩៥ | ៣៧.៥០៨.១០០ | ២.៤៧១.៧៧៦ | ១១.៧២៨.១២៦ | ៤៨.៨០៤.៦៥៩ | ២៧៦.៩៦៦.៩៦៩ | ១.០២២.៧៦១ | ២៥.៥២៤.៨០១ | ១.១០៧.១២១.២១៨ |
| ទិញបន្ថែម | - | ១.៥១៧.៣០៦ | ១.៦៥០.៨០៥ | ២.២៣៤.២១៧ | ៣៨៥.៣៣៣ | ១.៤៥៩.១៥២ | ១២.៤៧៧.០៣៥ | ៥៨៧.៤០៨ | ៩៤.០៩៤ | ១៦.០២០.៦៩៥ | ៣៦.៤២៦.០៤៥ |
| ការលក់ | - | - | - | - | - | - | (៩៧៣.១០០) | - | - | - | (៩៧៣.១០០) |
| ការផ្ទេរ | - | - | ៩៩.៥៥៨ | - | - | - | - | - | - | (៩៩.៥៥៨) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២៩៦.៧៣៥.៤០៩** | **៦០.៣៦៨.២២៨** | **៣៤៩.២៥៨.០៥៨** | **៣៩.៧៤២.៣១៧** | **២.៨៥៧.១០៩** | **១៣.១៨៧.២៧៨** | **៦០.៣០៨.៥៩៤** | **២៧៧.៥៥៤.៣៧៧** | **១.១១៦.៨៥៥** | **៤១.៤៤៥.៩៣៨** | **១.១៤២.៥៧៤.១៦៣** |
| **រំលស់បង្គរ** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | (៧.៣២២.៣៣៧) | (៣៩.៩២៣.១៩៣) | (១៣.៨២៧.៥៤១) | (១.៧៦៣.១២០) | (៧.៧១២.៦១១) | (១៣.២៥២.៣៣២) | (៥៦.១៣៦.៨៤៣) | (១.០១៧.៣៩៧) | - | (១៤០.៩៥៥.៣៧៤) |
| រំលស់ | - | (២.៩៦២.៥២១) | (៩.៧០៩.៩៤៦) | (៤.១០២.៤៨៣) | (៤៧០.៦០០) | (២.៧៤២.៣៥៤) | (៤.៣៨៦.៥២១) | (១៣.៩៥៨.៦២៥) | (១៩.៥២០) | - | (៣៨.៣៥២.៥៧០) |
| ការលក់ | - | - | - | - | - | - | ៤៤៦.៥៦២ | - | - | - | ៤៤៦.៥៦២ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **(១០.២៨៤.៨៥៨)** | **(៤៩.៦៣៣.១៣៩)** | **(១៧.៩៣០.០២៤)** | **(២.២៣៣.៧២០)** | **(១០.៤៥៤.៩៦៥)** | **(១៧.១៩២.២៩១)** | **(៧០.០៩៥.៤៦៨)** | **(១.០៣៦.៩១៧)** | **-** | **(១៧៨.៨៦១.៣៨២)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | | | | | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២៩៦.៧៣៥.៤០៩** | **៥០.០៨៣.៣៧០** | **២៩៩.៦២៤.៩១៩** | **២១.៨១២.២៩៣** | **៦២៣.៣៨៩** | **២.៧៣២.៣១៣** | **៤៣.១១៦.៣០៣** | **២០៧.៤៥៨.៩០៩** | **៧៩.៩៣៨** | **៤១.៤៤៥.៩៣៨** | **៩៦៣.៧១២.៧៨១** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៦. **ទ្រព្យ និងបរិក្ខារ** (តពីទំព័រមុន)

| | *២០២១* | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | *ដីធ្លី* | *ការកែលម្អដីធ្លី* | *អគារ* | *បរិក្ខារ បច្ចេកទេស* | *គ្រឿងសង្ហារិម និងបរិក្ខារបំពាក់* | *កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ* | *យានយន្ត* | *បរិក្ខារ កំពង់ផែសមុទ្រ* | *ប៉ាឡែត* | *សំណង់កំពុង សាងសង់* | *សរុប* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ២៥០.៩២៩.៩០៩ | ៣៨.១២១.៦៣៨ | ៣៤៦.៦៩៣.៩៣៥ | ៣៥.៨២៨.៣៣៤ | ២.១៣៦.៣៤៦ | ៩.០៣៨.៧៤៦ | ៤១.៨៩៥.៦៥៥ | ២៣២.០៨៨.៣៥៥ | ១.០២២.៧៦១ | ៦៦.២៥៦.៣២៧ | ១.០២៤.០១២.០០៦ |
| ទិញបន្ថែម | ៤៥.៨០៥.៥០០ | ៦៨១.១៥២ | ៨១៣.៧៦០ | ៣២០.៦៦៦ | ៣៣៥.៤៣០ | ២.៦៨៩.៣៨០ | ៧.០៩២.២៨៤ | ៧.៤១៨.៥៦០ | - | ១៨.១៣៥.៧៦០ | ៨៣.២៩២.៤៩២ |
| លុបចោល | - | - | - | - | - | - | (១៨៣.២៨០) | - | - | - | (១៨៣.២៨០) |
| ការផ្ទេរ | - | ២០.០៤៨.១៣២ | - | ១.៣៥៩.១០០ | - | - | - | ៣៧.៤៦០.០៥៤ | - | (៥៨.៨៦៧.២៨៦) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **២៩៦.៧៣៥.៤០៩** | **៥៨.៨៥០.៩២២** | **៣៤៧.៥០៧.៦៩៥** | **៣៧.៥០៨.១០០** | **២.៤៧១.៧៧៦** | **១១.៧២៨.១២៦** | **៤៨.៨០៤.៦៥៩** | **២៧៦.៩៦៦.៩៦៩** | **១.០២២.៧៦១** | **២៥.៥២៤.៨០១** | **១.១០៧.១២១.២១៨** |
| **រំលស់បង្គរ** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | (៥.៧៥០.៥៤១) | (៣០.២៧៨.៦៦៣) | (៩.៨១១.១៨៥) | (១.៣២៩.៧០៦) | (៦.៣២៧.១៨៩) | (៩.៦៣៨.៤៥៧) | (៤៤.៥៣៤.៧៤៥) | (៩៧២.៥០៥) | - | (១០៨.៦៤២.៩៩១) |
| រំលស់ | - | (១.៥៧១.៧៩៦) | (៩.៦៤៤.៥៣០) | (៤.០១៦.៣៥៦) | (៤៣៣.៤១៤) | (១.៣៨៥.៤២២) | (៣.៧៩៧.១៥៥) | (១១.៦០២.០៩៨) | (៤៤.៨៩២) | - | (៣២.៤៩៥.៦៦៣) |
| លុបចោល | - | - | - | - | - | - | ១៨៣.២៨០ | - | - | - | ១៨៣.២៨០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **-** | **(៧.៣២២.៣៣៧)** | **(៣៩.៩២៣.១៩៣)** | **(១៣.៨២៧.៥៤១)** | **(១.៧៦៣.១២០)** | **(៧.៧១២.៦១១)** | **(១៣.២៥២.៣៣២)** | **(៥៦.១៣៦.៨៤៣)** | **(១.០១៧.៣៩៧)** | **-** | **(១៤០.៩៥៥.៣៧៤)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | | | | | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **២៩៦.៧៣៥.៤០៩** | **៥១.៥២៨.៥៨៥** | **៣០៧.៥៨៤.៥០២** | **២៣.៦៨០.៥៥៩** | **៧០៨.៦៥៦** | **៤.០១៥.៥១៥** | **៣៥.៥៥២.៣២៧** | **២២០.៨៣០.១២៦** | **៥.៣៦៤** | **២៥.៥២៤.៨០១** | **៩៦៦.១៦៥.៨៤៤** |

## ៦. **ទ្រព្យ និងបរិក្ខារ** (តពីទំព័រមុន)

សូមយោងទៅលើការផ្ទៀងផ្ទាត់ជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់នៃការទិញបន្ថែមខាងក្រោម (ការទិញទ្រព្យ និងបរិក្ខារ) សម្រាប់កាលបរិច្ឆេទបញ្ចប់។

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ការទិញ (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) ក្នុងគ្រា (មិនរួមបញ្ចូលថ្លៃកម្ចីមូលធន) | ៣៦.២៤១.៨៥៦ | ៨៣.១៥៥.៧៨៤ |
| (កំណើន) តំហយទឹកប្រាក់ត្រូវទូទាត់ទៅអ្នកផ្គត់ផ្គង់ | (១.៨៥៩.០៣០) | ២.១៨៥.៤៥៤ |
| **សាច់ប្រាក់ដែលប្រើក្នុងការទិញទ្រព្យ និង បរិក្ខារ** | **៣៤.៣៨២.៨២៦** | **៨៥.៣៣១.២៣៨** |

ចំណាយការប្រាក់លើកម្ចី ដែលត្រូវបានធ្វើមូលធនកម្មលើទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កាលបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានចំនួន ១៨៤.១៨៩ ពាន់រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ១៤៦.៧០៨ ពាន់រៀល)។

តារាងខាងក្រោមសង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោង។

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ | ៤៦.៥៤០.៥០០ | ៤៦.៥៤០.៥០០ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ២៥០.១៩៤.៩០៩ | ២៥០.១៩៤.៩០៩ |
| | **២៩៦.៧៣៥.៤០៩** | **២៩៦.៧៣៥.៤០៩** |

ដីដែលមិនមានប័ណ្ណកម្មសិទ្ធិ ជាដីដែលមានប័ណ្ណកម្មសិទ្ធិប្លង់ទន់ចុះបញ្ជីត្រឹមស្រុក។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៧. ទ្រព្យវិនិយោគ

| | *ដីធ្លី* | *អគារ និង ការកែលម្អដីធ្លី* | *សំណង់កំពុង សាងសង់* | *សរុប* |
|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ *(បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* | ១២១.៦៣៣.៥៦៣ | ១៦៨.៥៧៩.៦៥៣ | - | ២៩០.២១៣.២១៦ |
| ទិញបន្ថែម | - | ១៩៥.២៤៥ | ១.០៨២.៤០០ | ១.២៧៧.៦៤៥ |
| ការផ្ទេរ | ១.០៨២.៤០០ | - | (១.០៨២.៤០០) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១២២.៧១៥.៩៦៣** | **១៦៨.៧៧៤.៨៩៨** | **-** | **២៩១.៤៩០.៨៦១** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | (៣៧.០១៧.៥១៧) | - | (៣៧.០១៧.៥១៧) |
| រំលស់ | - | (៦.១៧៦.៦៣៩) | - | (៦.១៧៦.៦៣៩) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **(៤៣.១៩៤.១៥៦)** | **-** | **(៤៣.១៩៤.១៥៦)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១២២.៧១៥.៩៦៣** | **១២៥.៥៨០.៧៤២** | **-** | **២៤៨.២៩៦.៧០៥** |

| | *ដីធ្លី* | *អគារ និង ការកែលម្អដីធ្លី* | *សំណង់កំពុង សាងសង់* | *សរុប* |
|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១៣៦.០៣០.៨៨៥ | ១៦៨.១៤០.១៤៩ | ៣៥៩.២៨០ | ៣០៤.៥៣០.៣១៤ |
| ទិញបន្ថែម | - | ១៦៥.៣១០ | ១.៧០៨.៨៦០ | ១.៨៧៤.១៧០ |
| ការផ្ទេរ | ២.០៦៨.១៤០ | - | (២.០៦៨.១៤០) | - |
| ផ្ទេរទៅទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ *(កំណត់សម្គាល់លេខ ១៣)* | (១៣.០៥៨.៧០៨) | - | - | (១៣.០៥៨.៧០៨) |
| ចំណាត់ថ្នាក់ឡើងវិញ *(កំណត់សម្គាល់លេខ ៣២)* | (៣.៤០៦.៧៥៤) | ២៧៤.១៩៤ | - | (៣.១៣២.៥៦០) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** *(បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* | **១២១.៦៣៣.៥៦៣** | **១៦៨.៥៧៩.៦៥៣** | **-** | **២៩០.២១៣.២១៦** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | (៣០.៦៩៤.៨៤៧) | - | (៣០.៦៩៤.៨៤៧) |
| រំលស់ | - | (៦.៣២២.៦៧០) | - | (៦.៣២២.៦៧០) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **-** | **(៣៧.០១៧.៥១៧)** | **-** | **(៣៧.០១៧.៥១៧)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** *(បានធ្វើចំណាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ ៣២)* | **១២១.៦៣៣.៥៦៣** | **១៣១.៥៦២.១៣៦** | **-** | **២៥៣.១៩៥.៦៩៩** |

## ៧. **ទ្រព្យវិនិយោគ** (តពីទំព័រមុន)

*ដំណើរការនៃការវាយតម្លៃ (បច្ចេកទេស/ធាតុចូល) ប្រើប្រាស់ដើម្បីកំណត់តម្លៃសមស្រប*

ទ្រព្យវិនិយោគត្រូវបានវាយតម្លៃ ដោយក្រុមហ៊ុនវាយតម្លៃដែលមានការទទួលស្គាល់ដោយ និយ័តករមូលបត្រនៃកម្ពុជា។ ក.ស.ស បានទទួលការវាយតម្លៃឯករាជ្យចំពោះទ្រព្យវិនិយោគរបស់ខ្លួន គិតត្រឹមថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ហើយគណៈគ្រប់គ្រងជឿជាក់ថា មិនមានបម្រែបម្រួលជាសារវន្តណាមួយទៅលើការវាយតម្លៃរហូតដល់កាលបរិច្ឆេទការវាយការណ៍នេះទេ។

តម្លៃសមស្របកម្រិតបី របស់ទ្រព្យវិនិយោគ ត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ជាមួយនឹងវិធីសាស្ត្រវាយតម្លៃដីធ្លី និងវិធីសាស្ត្រថ្លៃដើមសម្រាប់អគារ។ ដីធ្លីត្រូវបានវាយតម្លៃដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ គិតទៅតាមដីធ្លីដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ តម្លៃទាំងនេះត្រូវបានកែតម្រូវសម្រាប់ភាពខុសគ្នាក្នុងការសន្មតសំខាន់ៗដូចជា ទំហំ ទីតាំង ស្ថានភាព និងកត្តាពាក់ព័ន្ធផ្សេងទៀត។

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ដីធ្លីតាមតម្លៃសមស្រប | ៣.០៣១.១៩៩.៨៩៦ | ២.៨៦២.៧៣២.៥៧៩ |
| អគារ និងការកែលម្អដីធ្លីតាមតម្លៃសមស្រប | ១២០.៥០៤.៥៩០ | ១៣៧.៦៦៨.៦០៨ |
| | **៣.១៥១.៦៥៤.៨៨៦** | **៣.០០០.៤០១.១៨៧** |

តារាងខាងក្រោមនេះសង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោង៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់សេដ្ឋកិច្ចពិសេស(*) | ៨៣.២៧៣.៦០៤ | ៨១.៨០៥.៦១៦ |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់ផ្សេងៗ | ៩.៥០៨.៨៥៥ | ៩.៤០២.៤៥៥ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ៣៩.៩៣៣.៥០៤ | ៣៥.៤២៥.៤៩២ |
| | **១៣២.៧១៥.៩៦៣** | **១២៦.៦៣៣.៥៦៣** |

ចំនួនទឹកប្រាក់ខាងក្រោមដែលត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬ ខាត ដែលបានមកពីការធ្វើអាជីវកម្មនៃទ្រព្យវិនិយោគ៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណូលពីការជួល | ២.៣៧៤.៦៩៦ | ២.១៩៥.៨៦៩ |
| ចំណាយរំលស់ | (៦.១៧៦.៦៣៩) | (៦.៣២២.៦៧០) |
| ចំណាយប្រតិបត្តិការផ្ទាល់ដែលកើតចេញពីទ្រព្យវិនិយោគដែលបង្កើតប្រាក់ចំណូលពីការជួល | (២.៨៦៩.៥៨៥) | (២.៥៤៥.៦០២) |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៧. **ទ្រព្យវិនិយោគ** (តពីទំព័រមុន)

ប្រាក់អប្បបរមាបានពីការជួលទ្រព្យវិនិយោគមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ក្នុងអំឡុង១ឆ្នាំ | ៥៦៨.១៩៦ | ៧៣.៣៣២ |
| ចន្លោះពី១ឆ្នាំ ដល់ ២ឆ្នាំ | ៥៦៨.១៩៦ | ៥៦២.២១២ |
| ចន្លោះពី២ឆ្នាំ ដល់ ៣ឆ្នាំ | ៥៦៨.១៩៦ | ១.៥៣៩.៩៧២ |
| ចន្លោះពី៣ឆ្នាំ ដល់ ៤ឆ្នាំ | ៥៧៦.៣៨០ | ១.៥៣៩.៩៧២ |
| ចន្លោះពី៤ឆ្នាំ ដល់ ៥ឆ្នាំ | ៥៧៦.៣៨០ | ១.៥៥៨.១២០ |
| លើសពី ៥ឆ្នាំ | ៣៨.៤៧២.៧០៦ | ៣៩.៩៧៨.៣៧៤ |
| | **៤១.៣២៩.៩០៤** | **៤៥.២៤១.៩៨២** |

## ៨. **ទ្រព្យអរូបី**

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | |
| នាថ្ងៃទី១ ខែមករា | ១១.២៨៨.០៨៣ | ១០.៩២១.១៥២ |
| បន្ថែម | ២៥១.២៩៨ | ៣៦៦.៩៣១ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **១១.៥៣៩.៣៨១** | **១១.២៨៨.០៨៣** |
| **រំលស់បង្គរ** | | |
| នាថ្ងៃទី១ ខែមករា | (៦.៣៥១.៧៥១) | (៥.២៤៧.៤០៧) |
| រំលស់ | (១.១៦៨.៥៣៩) | (១.១០៤.៣៤៤) |
| **នាថ្ងៃទី៣១ ខែធ្នូ** | **(៧.៥២០.២៩០)** | **(៦.៣៥១.៧៥១)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៤.០១៩.០៩១** | **៤.៩៣៦.៣៣២** |

## ៩. **សន្និធិ**

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| សម្ភារៈផ្គត់ផ្គង់ប្រើប្រាស់ | ២៥.៥០៧.៥៦៣ | ២៤.០០៧.៧៨៧ |
| វត្ថុធាតុដែលងាយឆេះ | ២.០២១.៦៧៨ | ២.៧០៩.៩៩៧ |
| ប្រេង និងប្រេងរំអិល | ១.៦៤៩.៥២៧ | ១.២៥០.២១៦ |
| សំវិធានធនលើអ៊ីមតែរមិននៃសន្និធិ | (៩៥.៤០៤) | (៧៤២.៩៩៤) |
| | **២៩.០៨៣.៣៦៤** | **២៧.២២៥.០០៦** |

## ៩. **សន្និធិ** (តពីទំព័រមុន)

បម្រែបម្រួលនៃសំវិធានធនលើអ៊ីមភែរមិននៃសន្និធិមានដូចខាងក្រោមៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៧៤២.៩៩៤ | ៧៤២.៩៩៤ |
| បញ្ច្រាស់ក្នុងអំឡុងគ្រា | (៦៤៧.៥៩០) | - |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៩៥.៤០៤** | **៧៤២.៩៩៤** |

សន្និធិដែលបានទទួលស្គាល់ជាចំណាយសម្រាប់កាលបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានចំនួន ១០២.៣៣៦ លានរៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ៨៩.០០៦ លានរៀល)។

## ១០. **គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ**

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអតិថិជន | ៣០.៥៦៧.៩១០ | ៣៣.៩៨៥.៥១៩ |
| សំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក *(ក)* | (២៣២.៩៥០) | (៣២៩.២៤១) |
| **គណនីអតិថិជនសុទ្ធ** | **៣០.៣៣៤.៩៦០** | **៣៣.៦៥៦.២៧៨** |
| បុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន *(ខ)* | ៧.២២១.៣០៣ | ១.២២១.៣០៣ |
| បុរេប្រទាន | ៣១៤.៤៨៨ | ៦៩៦.៥០២ |
| ចំណាយបង់មុន | ៨៦.១១១ | ៨៥.៨២៨ |
| **គណនីត្រូវទទួលផ្សេងៗ** | **៧.៦២១.៩០២** | **២.០០៣.៦៣៣** |
| | **៣៧.៩៥៦.៨៦២** | **៣៥.៦៥៩.៩១១** |

គណនីអតិថិជនរបស់ ក.ស.ស គឺជាគណនីត្រូវទទួលរយៈពេលខ្លីបានពីក្រុមហ៊ុន និងភ្នាក់ងារដឹកជញ្ជូនក្នុងស្រុក និងអន្តរជាតិ។

(ក) បម្រែបម្រួលសំវិធានធន លើការខាត់បង់ឥណទានរំពឹងទុករបស់គណនីអតិថិជនមានដូចខាងក្រោមៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៣២៩.២៤១ | ២.៦៥៥.៤៧៨ |
| បញ្ច្រាស់ក្នុងអំឡុងគ្រា | (៩៦.២៩១) | (២.៣២៦.២៣៧) |
| **នាថ្ងៃទី៣១ ខែធ្នូ** *(កំណត់សម្គាល់លេខ ៣០.១)* | **២៣២.៩៥០** | **៣២៩.២៤១** |

## ១០. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ (តពីទំព័រមុន)

(ខ) គណនីនេះជាសមតុល្យបុរេប្រទានសាច់ប្រាក់ទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានចំនួន ១.២២១.៣០៣ ពាន់រៀល ដោយយោងទៅតាមលិខិតចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ និងត្រូវសងក្នុងឆ្នាំ២០១៩។ បុរេប្រទានសាច់ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់អគារការិយាល័យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ រយៈពេលនៃការទូទាត់សងមិនត្រូវបានបញ្ជាក់។

ក្នុងឆ្នាំ២០២២ បុរេប្រទានសាច់ប្រាក់បន្ថែមចំនួន ៦ ពាន់លានរៀលត្រូវបានផ្តល់ទៅក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីប្រើប្រាស់សម្រាប់ការសាងសង់ផ្លូវ ដោយយោងទៅលិខិតស្នើសុំចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ក្រសួងសាធារណការ និងដឹកជញ្ជូនបានសង ៥ ពាន់លានរៀល ដល់ ក.ស.ស។

បុរេប្រទានដែលនៅសល់របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន មិនទាន់សងនៅឡើយទេ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

## ១១. ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១០០.៨៥២.៥៩០ | ៩៩.៦៣៨.៩៤៤ |
| បង្គរការប្រាក់ត្រូវទទួល | ២.០៧៤.៧៩២ | ១.៦៦៧.៧៣៧ |
| | **១០២.៩២៧.៣៨២** | **១០១.៣០៦.៦៨១** |
| សំវិធានធនសម្រាប់ការបាត់បង់ឥណទានបានរំពឹងទុក | (១៩.១១៨) | - |
| | **១០២.៩០៨.២៦៤** | **១០១.៣០៦.៦៨១** |

ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី គឺជាប្រាក់បញ្ញើមានកាលកំណត់ដែលបានដាក់តម្កល់នៅគ្រឹះស្ថានហិរញ្ញវត្ថុ ហើយមានកាលកំណត់រយៈពេលពី ៦ខែ ទៅ ១២ខែ ហើយទទួលបានការប្រាក់ចន្លោះពី ២,៧៥% ទៅ ៦,៥០% ក្នុងមួយឆ្នាំ (ឆ្នាំ២០២១៖ ២,៧៥% ទៅ ៤,៥០% ក្នុងមួយឆ្នាំ)។

## ១២. សាច់ប្រាក់

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| សាច់ប្រាក់ក្នុងដៃ | ៧៣០.៨១៧ | ១.៣៤១.៨០៨ |
| សាច់ប្រាក់នៅធនាគារ | ២២.៨៥៥.៥៥១ | ២១.១២៧.១២១ |
| | **២៣.៥៨៦.៣៦៨** | **២២.៤៦៨.៩២៩** |

សាច់ប្រាក់នៅធនាគារគឺជាគណនីចរន្ត ដែលមិនមានការប្រាក់ និងបានដាក់តម្កល់នៅធនាគារពាណិជ្ជកម្មក្នុងស្រុក។

## ១៣. ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ក.ស.ស បានចុះហត្ថលេខាលើកិច្ចសន្យាលក់ និងទិញជាមួយអតិថិជនដើម្បីលក់ដីទំនេរមួយកន្លែង (ទំហំ ១៣០ហិកតា) មានទីតាំងស្ថិតនៅឃុំបិតត្រាង ដែលដីនេះត្រូវបានទិញក្នុងគោលបំណងដើម្បីទុកចំណេញ។ តម្លៃក្នុងកិច្ចសន្យាសរុបមានចំនួន ២៦ លានដុល្លារអាមេរិក ឬ ១០៥.៣០០ លានរៀល ដែលមានតម្លៃ ២០ ដុល្លារអាមេរិក ឬ ៨១.០០០ រៀលក្នុងមួយម៉ែត្រការ៉េ។ ក.ស.ស បានទទួលទឹកប្រាក់ចំនួន ២ លានដុល្លារអាមេរិក ជាប្រាក់កក់នៅថ្ងៃចុះកិច្ចសន្យា ហើយអ្នកទិញនឹងទូទាត់ប្រាក់ដែលនៅសល់នៅពេលបញ្ចប់ការផ្ទេរសិទ្ធ។ ទំហំដីអាចនឹងត្រូវកាត់បន្ថយ ក្នុងដំណើរការការផ្ទេរសិទ្ធដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដោយសារគម្រោង និងការសាងសង់ផ្លូវសារធារណ:)។ អ្នកទិញនឹងទូទាត់តាមទំហំដីដែលបានបញ្ជាក់ក្នុងប្លង់ជាក់ស្តែងក្នុងតម្លៃ ២០ ដុល្លារអាមេរិក ឬ ៨១ ពាន់រៀល ក្នុងមួយម៉ែតការ៉េ។ ពីពេលនោះមក ទ្រព្យសកម្មនោះត្រូវបានចាត់ថ្នាក់ និងបង្ហាញជាទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ មានចំនួន ១៦.៥៨២.១៦១ ពាន់រៀល (ឆ្នាំ២០២១៖ ១៦.១៩១.២៦៨ ពាន់រៀល)។ មិនមានការទទួលស្គាល់ចំណេញណាមួយនោះទេក្នុងអំឡុងឆ្នាំ ដោយសារប្រតិបត្តិនេះមិនទាន់បានបញ្ចប់នៅឡើយ ហើយហានិភ័យ និងកម្មសិទ្ធមិនទាន់ត្រូវបានផ្ទេរទៅអ្នកទិញពេញលេញនោះទេ។

នៅខែមករា ឆ្នាំ២០២៣ ដំណើរការផ្ទេរសិទ្ធិប្លង់រឹងត្រូវបានបញ្ចប់។ តម្លៃចារឹកតាមកិច្ចសន្យាដែលនៅសល់ត្រូវបានទូទាត់ និងទទួលបាននៅខែកុម្ភៈ ឆ្នាំ២០២៣។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន

| | *ភាគហ៊ុនប្រភេទ "ក"* | | *ភាគហ៊ុនប្រភេទ "ខ"* | | *ភាគហ៊ុនប្រភេទ "គ"* | | *ដើមទុន* | | *បុព្វលាភភាគហ៊ុន* | *សរុប* |
|---|---|---|---|---|---|---|---|---|---|---|
| | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៣៦៤.៥៣០.៨៦១** | **៣៦៤.៥៣០.៨៦១** | **៦៤.៣២៨.៩៧៥** | **៦៤.៣២៨.៩៧៥** | **២១.៤៤២.៩៩២** | **២១.៤៤២.៩៩២** | **៤៥០.៣០២.៨២៨** | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៥១៨.០១៨.០៦៣** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **៣៦៤.៥៣០.៨៦១** | **៣៦៤.៥៣០.៨៦១** | **៦៤.៣២៨.៩៧៥** | **៦៤.៣២៨.៩៧៥** | **២១.៤៤២.៩៩២** | **២១.៤៤២.៩៩២** | **៤៥០.៣០២.៨២៨** | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៥១៨.០១៨.០៦៣** |

(*) យោងតាមមាត្រា ៥ នៃលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ដើមទុនដែលមានស្រាប់ចំនួន ៤២៨.៨៥៩.៨៣៦.០០០ រៀល ត្រូវបានបែងចែកទៅជាភាគហ៊ុនប្រភេទ "ក" ចំនួន ៣៦៤.៥៣០.៨៦១ ហ៊ុន ដើមទុនប្រភេទ "ខ" ចំនួន ៦៤.៣២៨.៩៧៥ ហ៊ុន ដោយមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនទាំងពី ប្រភេទ "ក" និងភាគហ៊ុនប្រភេទ "ខ" ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ភាគហ៊ុនប្រភេទ "ក" មិនមានសិទ្ធិទទួលបានភាគលាភទេ ហើយក៏មិនមានសិទ្ធិបោះឆ្នោតដែរ លើកលែងតែលក្ខខណ្ឌមួយចំនួនដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈក្រុមហ៊ុនចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិទទួលបានភាគលាភ នៅពេលដែលក្រុមប្រឹក្សាភិបាលបានអនុម័ត។

(**) សេចក្តីលម្អិតនៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតមានដូចខាងក្រោមៈ

| **ភាគហ៊ុនិក** | *ភាគរយ* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* |
|---|---|---|---|
| ភាគហ៊ុនប្រភេទ "ខ" | | | |
| រាជរដ្ឋាភិបាលកម្ពុជា | ៧៥% | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ |
| ភាគហ៊ុនប្រភេទ "គ" | | | |
| ក្រុមហ៊ុន Kamigumi | ១៣% | ១១.១៥០.៣២៤ | ១១.១៥០.៣២៤ |
| អ្នកវិនិយោគសារធារណ | ១២% | ១០.២៩២.៦៦៨ | ១០.២៩២.៦៦៨ |
| | ២៥% | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ |
| | **១០០%** | **៨៥.៧៧១.៩៦៧** | **៨៥.៧៧១.៩៦៧** |

ចំនួនភាគហ៊ុនដែលបានបោះផ្សាយក្នុងប្រភេទ "គ" មានចំនួន ២១.៤៤២.៩៩២ ភាគហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀលក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ "គ" ដែលបានបោះផ្សាយទាំងអស់ ត្រូវបានបង់ប្រាក់រួចរាល់ទាំងស្រុង។

## ១៥. ទុនបម្រុងផ្សេងៗ

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៣១.៧១៩.៨៣២ | ២៩.០៥៩.០៧២ |
| បូក៖ ទុនបម្រុងទូទៅ | ៤.៦៨៥.៣៧០ | ១.៣៣០.៣៨០ |
| បូក៖ ទុនបម្រុងតាមច្បាប់ | ៤.៦៨៥.៣៧០ | ១.៣៣០.៣៨០ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៤១.០៩០.៥៧២** | **៣១.៧១៩.៨៣២** |

មាត្រា ៦៥ នៃលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ចែងថា ប្រាក់ចំណេញប្រចាំឆ្នាំរបស់ ក.ស.ស បន្ទាប់ពីទូទាត់ការខាតយោងទៅមុខ (ប្រសិនបើមាន) ត្រូវបានបែងចែកទៅជាទុនបម្រុងទូទៅក្នុងអត្រា ៥% និងទុនបម្រុងតាមច្បាប់នៅអត្រា ៥%។ នៅថ្ងៃទី៧ខែឧសភា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានអនុម័តផ្ទេរប្រាក់ចំណេញរក្សាទុកសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ទៅជាទុនបម្រុងទូទៅចំនួន ៤.៦៨៥.៣៧០ ពាន់រៀល និងទៅទុនបម្រុងតាមច្បាប់ចំនួន ៤.៦៨៥.៣៧០ ពាន់រៀល។

## ១៦. ប្រាក់កម្ចី

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៣ | ៤៤.៩១៨.៩០៣ | ៥៧.៧៣៥.៨១៣ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៤ | ៩១.៤៦៦.៤៧២ | ៩៨.០៥៣.៩១៨ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៦ | ៥.៣៥៤.៣៨៦ | ៦.៦១៤.៦៧៧ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៨ | ៩០.៥៩០.០០៩ | ១០៨.២៨១.៧៧០ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P១០ | ១៤៩.៥៨២.០៣៩ | ១៨៣.២២៧.៧១២ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P២១ | ១៣.១៩៨.៧៥៨ | ១៥.០៧៣.១០៧ |
| | **៣៩៥.១១០.៥៦៧** | **៤៦៨.៩៨៦.៩៩៧** |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយ JICA និង JBIC ទាក់ទិនទៅនឹងប្រតិបត្តិការដែលពាក់ព័ន្ធនឹង ក.ស.ស។ ប្រាក់កម្ចីត្រូវបាន JICA និង JBIC ទូទាត់ដោយផ្ទាល់ទៅឲ្យអ្នកផ្គត់ផ្គង់របស់ ក.ស.ស។ ក.ស.ស នឹងសងប្រាក់ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកាលវិភាគសងប្រាក់។

**១៦. ប្រាក់កម្ចី** (តពីទំព័រមុន)

កាលកំណត់របស់ប្រាក់កម្ចីទាំងនេះមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **រយៈពេលខ្លី** | | |
| មិនលើសមួយឆ្នាំ | **៣០.៨៣៣.៤៩០** | **៣៣.៩៦១.៥៧២** |
| **រយៈពេលវែង** | | |
| លើសមួយឆ្នាំ ប៉ុន្តែតិចជាងពីរឆ្នាំ | ២៨.០៧២.៧៥៣ | ៣១.០៦៧.៩៣៨ |
| លើសពីរឆ្នាំ ប៉ុន្តែតិចជាងប្រាំឆ្នាំ | ៨៤.២១៨.២៦០ | ៩៣.២០៣.៨១៣ |
| លើសប្រាំឆ្នាំ | ២៥២.៣៨៦.០៧៤ | ៣១០.៧៥៣.៦៧៤ |
| | **៣៦៤.៦៧៧.០៨៧** | **៤៣៥.០២៥.៤២៥** |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

តម្លៃសមស្របរបស់ប្រាក់កម្ចីមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| រយៈពេលខ្លី | ៣០.៤៣៣.៤៩០ | ៣៣.៩៦១.៥៧២ |
| រយៈពេលវែង | ៣៦៤.៦៧៧.០៨៧ | ៤៣៥.០២៥.៤២៥ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

តម្លៃសមស្របត្រូវបានគណនាអាស្រ័យទៅតាមកិច្ចសន្យាលំហូរសាច់ប្រាក់អប្បហារនាពេលអនាគត់ ដោយប្រើអត្រាប្រាក់កម្ចីក្នុងគ្រា។ ប្រាក់កម្ចីទាំងនោះត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្របដោយសារ មានការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមានហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

## ១៦. **ប្រាក់កម្ចី** (តពីទំព័រមុន)

ប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណមុខងារមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | ៣០៣.៦៤៤.១០៥ | ៣៧០.៩៣៣.០៧៩ |
| ប្រាក់ដុល្លារអាមេរិក | ៩១.៤៦៦.៤៧២ | ៩៨.០៥៣.៩១៨ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់កម្ចីនីមួយៗមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៣ | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៤ | ៣,៧០% | ៣,៧០% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៦ | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៨ | ២,៦៥% | ២,៦៥% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P១០ | ១,៦៥% | ១,៦៥% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P២១ | ១,២៦% | ១,២៦% |

## ១៧. **កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍**

បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៨៨.១៨០.៩៨៤ | ៨៦.៩៨១.៩៦៧ |
| ចំណាយលើសេវាកម្មក្នុងគ្រា | ២.០៥៧.៧៥៩ | ១.៧០៩.០០០ |
| ចំណាយការប្រាក់ | ៤.៦៣៨.៤៤៦ | ៤.៦១៤.០០០ |
| អត្ថប្រយោជន៍បានបង់ | (៤.០១៥.២២៤) | (៥.១២៣.៩៨៣) |
| ចំណេញពីការវាយតម្លៃឡើងវិញនៃបម្រែបម្រួល ការសន្មតនៃការវាយតម្លៃ | (១៤.៨២៣.៥៤៩) | - |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៧៦.០៣៨.៤១៦** | **៨៨.១៨០.៩៨៤** |

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| រយៈពេលខ្លី | ៦.២១៤.៣៦៣ | ៤.៥៣៤.៤២៥ |
| រយៈពេលវែង | ៦៩.៨២៤.០៥៣ | ៨៣.៦៤៦.៥៥៩ |
| | **៧៦.០៣៨.៤១៦** | **៨៨.១៨០.៩៨៤** |

## ១៧. **ភាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍** (តពីទំព័រមុន)

ចំណាយអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ និងការវាស់វែងឡើងវិញកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នៅក្នុងរបាយការណ៍ពេញលេញមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណាយលើសេវាកម្មក្នុងគ្រា | ២.០៥៧.៧៥៩ | ១.៧០៩.០០០ |
| ចំណាយការប្រាក់ | ៤.៦៣៨.៤៤៦ | ៤.៦១៤.០០០ |
| **ទឹកប្រាក់សរុបបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬខាត***(កំណត់សម្គាល់លេខ ២២)* | **៦.៦៩៦.២០៥** | **៦.៣២៣.០០០** |

ការសន្មតសំខាន់ជាចម្បងមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| អត្រាអប្បហារក្នុងមួយឆ្នាំ | ៦,៥% | ៦,០% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ក្នុងមួយឆ្នាំ | ៥,០% | ៥,០% |
| អត្រាបម្រែបម្រួលបុគ្គលិកក្នុងមួយឆ្នាំ | ០,៥% | ០,៥% |
| អត្រាមរណៈ | ១០០%នៃតារាងមរណៈភាពធម្មតារបស់ប្រទេសថៃឆ្នាំ២០១៧ | ១០០%នៃតារាងមរណៈភាពធម្មតារបស់ប្រទេសថៃឆ្នាំ២០១៧ |
| អត្រាពិការភាព | ១០% នៃអត្រាមរណៈមុនពេលចូលនិវត្តន៍ | ១០% នៃអត្រាមរណៈមុនពេលចូលនិវត្តន៍ |

តារាងក្រោមនេះ បង្ហាញពីវិយិតភាព (sensitivity) នៃបម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍តាមការសន្មតការគណនា/វាយតម្លៃ (actuarial assumption) ដូចខាងក្រោម៖

| *វិយិតភាព* | *ការសន្មត* | *រៀល* |
|---|---|---|
| ២០២២ | | |
| *អត្រាអប្បហារ* | | |
| មូលដ្ឋានការសន្មត | ៦,៥% | ៧៦.០៣៨ |
| +១,០០% | ៧,៥% | ៦៧.៦៦៨ |
| -១,០០% | ៥,៥% | ៨៩.១៩៨ |
| *អត្រាកើនឡើងនៃប្រាក់បៀវត្សរ៍* | | |
| មូលដ្ឋានការសន្មត | ៥,០% | ៧៦.០៣៨ |
| +១,០០% | ៦,០% | ៧៩.១៧១ |
| -១,០០% | ៤,០% | ៧៣.០៤០ |
| ២០២១ | | |
| *អត្រាអប្បហារ* | | |
| មូលដ្ឋានការសន្មត | ៦,០% | ៨៨.១៨១ |
| +០,៥០% | ៦,៥% | ៨៣.៦៤២ |
| -០,៥០% | ៥,៥% | ៩៣.១៨៤ |
| *អត្រាកើនឡើងនៃប្រាក់បៀវត្សរ៍* | | |
| មូលដ្ឋានការសន្មត | ៥,០% | ៨៨.១៨១ |
| +២,៥០% | ៧,៥% | ៩៩.១០១ |
| -២,៥០% | ២,៥% | ៨០.១៩៨ |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ១៨. ចំណូលពន្យារ

ទ្រព្យវិនិយោគរបស់ ក.ស.ស ត្រូវបានដាក់ជួល ក្រោមកិច្ចសន្យាភតិសន្យាប្រតិបត្តិរយៈពេលពី ២ឆ្នាំ ទៅ ៥០ឆ្នាំ។ ប្រាក់ដែលទទួលបានមុនត្រូវបានកត់ត្រាក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាតតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| រយៈពេលខ្លី | ១៧១.៦៧៩ | ១៣៤.៤៤២ |
| រយៈពេលវែង | ១២.២០៣.២០០ | ៥.៣១០.៨៥៩ |
| | **១២.៣៧៤.៨៧៩** | **៥.៤៤៤.៩០១** |

បម្រែបម្រួលចំណូលពន្យារក្នុងគ្រាមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៥.៤៤៤.៩០១ | ៥.៥៣៩.៦២៨ |
| ប្រាក់ទទួល | ៧.៥៥២.៧៩៨ | ៣២៥.៤៣៩ |
| ការទទួលស្គាល់ជាចំណូលជួល | (៧៤៧.៣៥៨) | (៤៦០.៩៣០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ១២៤.៥៣៨ | ៤០.៧៦៤ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **១២.៣៧៤.៨៧៩** | **៥.៤៤៤.៩០១** |

## ១៩. គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអ្នកផ្គត់ផ្គង់ | ៨៧៩.២០៤ | ៦.៩០១.០៣៤ |
| លាភការបង្គរ | ១៦.៤២០.៤៣៧ | ១៧.៧២៣.៧៤៦ |
| បុរេប្រទានពីអតិថិជន | ៨.៥៩២.៦៩៨ | ៨.៦០៦.៣១៣ |
| បង្គរវិភាគទានមូលនិធិសង្គម | ៤.៦១៩.៦៨៥ | ៥.៦៩៥.១០៧ |
| ប្រាក់តម្កល់ពីភតិក: | ១.៦៥៥.២៩១ | ១.៨៣៨.៧៤៣ |
| ធាតុចេញនៃអាករលើតម្លៃបន្ថែមត្រូវបង់ - សុទ្ធ | ១.៦៣៨.១០២ | ១.៥១២.៣១៥ |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | ៣៣៥.៩៨៥ | ៩៣៩.៤៨៧ |
| ផ្សេងៗ | ៩២៤.៦៧១ | ៩៧៧.៩៥៤ |
| | **៣៥.០៦៦.០៧៣** | **៤៣.១៩៩.៦៥៩** |

## ២០. ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

### *២០.១ ព័ត៌មានការបែងចែកចំណូល*

ខាងក្រោមនេះគឺជាការបែងចែកប្រាក់ចំណូលរបស់ ក.ស.ស ពីកិច្ចសន្យាជាមួយអតិថិជន៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណូលលើកដាក់ពីនាវា | ១៦៩.៨៧៣.៩៤៥ | ១៥៨.៥៦៦.៩៩៩ |
| ចំណូលពីការលើកដាក់ និងចំណូលពីការរក្សាទុកកុងតឺន័រ | ១១២.៩៣៧.១៧១ | ១១៩.៩៧៦.៥៣៤ |
| ចំណូលពីសេវាកម្មកំពង់ផែ | ៦២.២៨៥.០៥០ | ៦៥.០១៦.២៦៧ |
| ផ្សេងៗ | ១.៧៧៣.១៨៣ | ១.៥៩៩.០៦០ |
| | **៣៤១.៣៦៨.៨៤៩** | **៣៤០.១៥៣.៣៦០** |
| ពេលវេលានៃការទទួលស្គាល់ចំណូល | | |
| នៅពេលតែមួយ | ៣២៤.៤៦៦.៣២០ | ៣២៤.៦១០.៦២៤ |
| តាមដំណាក់កាល | ១៦.៩០២.៥២៩ | ១៥.៥៤២.៧៣៦ |
| | **៣៤១.៣៦៨.៨៤៩** | **៣៤០.១៥៣.៣៦០** |

### *២០.២ សមតុល្យកិច្ចសន្យា*

សមតុល្យកិច្ចសន្យារបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអតិថិជន *(កំណត់សម្គាល់លេខ ១០)* | **៣០.៣៣៤.៩៦០** | **៣៣.៦៥៦.២៧៨** |

### *២០.៣ កាតព្វកិច្ចអនុវត្ត*

*ចំណូលលើកដាក់ពីនាវា ចំណូលលើកដាក់លើទីលាន (LO-LO) និងចំណូលពីការរក្សាទុកកុងតឺន័រ និងចំណូលពីសេវាកម្មកំពង់ផែ*

ប្រាក់ចំណូលពីសេវាកម្មកំពង់ផែ ត្រូវបានទទួលស្គាល់នៅពេលតែមួយ និងទទួលស្គាល់តាមដំណាក់កាល នៅពេលកាតព្វកិច្ចអនុវត្តបានបំពេញ និងកំពុងបានបំពេញ ដែលស្របពេលជាមួយនឹងការផ្តល់សេវាកម្ម និងការទទួលយកដោយអតិថិជន។

មិនមានសមាសភាពហិរញ្ញប្បទានជាសារវន្ត នៅក្នុងចំណូលដែលបានពីសេវាកម្មកំពង់ផែទេ ដោយសារសេវាកម្មត្រូវបានផ្តល់ជូនក្នុងលក្ខខណ្ឌឥណទានធម្មតាដែលមិនលើសពីដប់ពីរខែ។

## ២១. សម្ភារៈផ្គត់ផ្គង់ការប្រើប្រាស់

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ចំណាយលើសម្ភារងាយឆេះ | ៥៥.៣៧៧.២៩៥ | ៤៥.៦៧៦.៩២២ |
| គ្រឿងបន្លាស់ | ៣៦.៥៨៥.២៧៨ | ៣២.៩០៨.០១៧ |
| សម្ភារផ្គត់ផ្គង់ឃ្លាំង | ៦.៦៩៧.០៧៨ | ៧.៦០៩.៦៧០ |
| ប្រេង និងប្រេងរំអិល | ៣.៧២៦.៧៣៤ | ៣.៨១០.៩១៤ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ២.១៧៩.៦៧០ | ២.៨៣៦.៧១៥ |
| ផ្សេងៗ | ១.៨៤៨.៨០៦ | ១.៨៩៧.០០៨ |
| | **១០៦.៣៦៤.៨៦១** | **៩៣.៧៣៩.២៤៦** |

## ២២. ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់បៀវត្សរ៍បុគ្គលិក | ៧០.៨៩០.៨៨៩ | ៦៩.៣១៨.៩៩៨ |
| លាភការ | ១៦.៤២០.៨៣៧ | ១៧.៧២៣.៧៤៦ |
| អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ *(កំណត់សម្គាល់លេខ ១៧)* | ៦.៦៩៦.២០៥ | ៦.៣២៣.០០០ |
| ប្រាក់រំលឹកអតីតភាពការងារ | ៤.០៣១.៧២៩ | ៣.៨៧០.៩២៨ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ១.៥៤៦.៨០០ | ១.៣៨៦.៨០០ |
| សន្តិសុខសង្គម | ១.៥៤៦.៥៣១ | ៧៨៣.០២២ |
| ចំណាយផ្សេងៗ | ៤.៥៣៩.៥០៦ | ៥.៣៥០.៤៥៥ |
| | **១០៥.៦៧២.០៩៧** | **១០៤.៣៦៦.៩៤៩** |

## ២៣. ចំណាយរំលស់ទ្រព្យរូបី និងទ្រព្យអរូបី

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ទ្រព្យ និងបរិក្ខារ *(កំណត់សម្គាល់លេខ ៦)* | ៣៨.៣៥២.៥៧០ | ៣២.៤៩៥.៦៦៣ |
| ទ្រព្យវិនិយោគ *(កំណត់សម្គាល់លេខ ៧)* | ៦.១៧៦.៦៣៩ | ៦.៣២២.៦៧០ |
| ទ្រព្យសកម្មអរូបី *(កំណត់សម្គាល់លេខ ៨)* | ១.១៦៨.៥៣៩ | ១.១០៤.៣៤៤ |
| | **៤៥.៦៩៧.៧៤៨** | **៣៩.៩២២.៦៧៧** |

## ២៤. ចំណាយផ្សេងៗ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| វិភាគទាន និងអំណោយ | ១១.១៩៣.៩០៦ | ១២.០២៩.៣២៦ |
| ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស | ២.៨៦៩.៥៨៥ | ២.៥៥៥.៦០២ |
| ទឹកភ្លើង | ២.៨៤៨.៩៩២ | ៣៦៦.៣៧៤ |
| ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | ២.៤៩២.២៩៤ | ១.៤២២.៧៥៧ |
| ការផ្គត់ផ្គង់ | ១.៨០១.៣៥៤ | ២.២០៣.២១៨ |
| បេសកម្ម | ១.៦១៦.០៨៤ | ៧៨៤.៩០៧ |
| កម្រៃសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធ | ១.៦១៥.៣៦៣ | ១.០៥១.២៥០ |
| ការបោះផ្សាយ | ១.១៩៦.៥៦៥ | ១.០១៥.៣៥៩ |
| កម្មសិក្សារ រោងជាង និងសិក្ខាសាលា | ៥៣០.៧៧២ | ២៤៣.៤៩១ |
| ការទំនាក់ទំនង | ៣៩៣.៩៦៧ | ៣៩០.២៣៤ |
| ការជួលបរិក្ខារ និងឡាន | ២២៤.២៤៦ | ២៦.៨៤៥ |
| ការផ្គត់ផ្គង់សម្ភារថៃទាំសុខភាព | ២១៩.៣៤៤ | ៣៤៩.៤២៨ |
| បញ្រ្ចាស់នៃសំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក | (៧៧.១៧៣) | (២.៣២៦.២៣៧) |
| ចំណាយផ្សេងៗ | ២០២.៣០០ | ២៤៩.៨៥២ |
| | **២៧.១២៦.៨៩៩** | **២០.៣៤៧.៤០៦** |

## ២៥. ចំណូលហិរញ្ញវត្ថុ - សុទ្ធ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| *ចំណូលហិរញ្ញវត្ថុ៖* | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ | ៤.២៧៧.៤៨៨ | ៣.៨១០.៧៧៦ |
| ចំណេញសុទ្ធពីការប្តូររូបិយវត្ថុរបស់ប្រាក់កម្ចី (គ) | ៤៦.៥១៥.៩៧៦ | ៣៩.៥៣១.៣៦៧ |
| ចំណូលការប្រាក់ពីការកត់ត្រាអប្បហារត្រឡប់មកវិញរបស់ឥណទានផ្តល់ឲ្យបុគ្គលិក | - | ៥៥.៣៤២ |
| | **៥០.៧៩៣.៤៦៤** | **៤៣.៣៩៧.៤៨៥** |
| *ចំណាយហិរញ្ញវត្ថុ៖* | | |
| ចំណាយការប្រាក់លើប្រាក់កម្ចី *(កំណត់សម្គាល់លេខ ១៦)* | **(៩.៩៣៩.៧៩៣)** | **(១១.១៩៤.៤៤៦)** |
| **ចំណូលហិរញ្ញវត្ថុ - សុទ្ធ** | **៤០.៨៥៣.៦៧១** | **៣២.២០៣.០៣៩** |

## ២៥. ចំណូលហិរញ្ញវត្ថុ - សុទ្ធ (តពីទំព័រមុន)

ក.ស.ស មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក *(កំណត់សម្គាល់លេខ ១៦)*។ ក.ស.ស ក៏មានប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លីជាប្រាក់ដុល្លារអាមេរិកផងដែរ *(កំណត់សម្គាល់លេខ ១១)*។ ដោយសារតែការឡើងចុះនៃតម្លៃប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក បណ្តាលឲ្យមានការចំណេញ/ខាតជាសារវន្តពីការប្តូរអត្រារូបិយប័ណ្ណលើប្រាក់កម្ចី និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លីរបស់ ក.ស.ស។ អត្រាប្តូរប្រាក់ ត្រូវបានផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជាគិតត្រឹមដំណាច់កាលបរិច្ឆេទការរាយការណ៍។ ចំណេញពីការប្តូររូបិយប័ណ្ណភាគច្រើនបណ្តាលមកពីការធ្លាក់ចុះនៃប្រាក់យ៉េនជប៉ុនធៀបទៅនឹងការិយបរិច្ឆេទមុនៗ។

| | *២០២២* | *២០២១* | *២០២០* | *២០១៩* |
|---|---|---|---|---|
| ប្រាក់យ៉េនជប៉ុន/ប្រាក់រៀល | ៣០,៩៥៥ | ៣៥,៥៩០ | ៣៩,២៧៥ | ៣៧,៦២០ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.១១៧ | ៤.០៧៤ | ៤.០៩៥ | ៤.០៧៥ |

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល

អនុលោមតាមបទប្បញ្ញត្តិពន្ធដារក្នុងប្រទេសកម្ពុជា ពន្ធលើប្រាក់ចំណូលក្នុងគ្រាត្រូវបានគណនាតាមភាពខ្ពស់ជាងរវាង ប្រាក់ចំណូលជាប់ពន្ធសម្រាប់ការិយបរិច្ឆេទ គុណនឹងអត្រាពន្ធលើប្រាក់ចំណូលតាមច្បាប់ ២០% នាកាលបរិច្ឆេទនៃការរាយការណ៍ និង ១% នៃចំណូល។

### *(ក) ចំណាយពន្ធលើប្រាក់ចំណូល*

សមាសភាគសំខាន់ៗនៃចំណាយពន្ធលើប្រាក់ចំណូលក្នុងគ្រាមានៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| *ចំណាយពន្ធលើប្រាក់ចំណូលទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលចំណេញ* | | |
| ពន្ធលើប្រាក់ចំណូលក្នុងគ្រា | ១១.៤៩២.៦៣៤ | ៧.៥៩៥.៥៤៩ |
| កង្វះសំវិធានធនសម្រាប់ពន្ធក្នុងគ្រានៃការិយបរិច្ឆេទមុន | ១.៦២៩.៦០០ | - |
| ពន្ធពន្យារ | ៦១៩.៦៣១ | ៩.៧៤២.៦៩៨ |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **១៣.៧៤១.៨៦៥** | **១៧.៣៣៨.២៤៧** |
| *ចំណាយពន្ធលើប្រាក់ចំណូលទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ* | | |
| **ពន្ធពន្យាទាក់ទងនឹងចំណេញពីការវាយតម្លៃឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍** | **២.៩៦៤.៧០៩** | **-** |

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល (តពីទំព័រមុន)

### *(ក) ចំណាយពន្ធលើប្រាក់ចំណូល* (តពីទំព័រមុន)

ការផ្ទៀងផ្ទាត់នៃពន្ធលើប្រាក់ចំណូលដែលបានគណនាតាមអត្រាពន្ធតាមច្បាប់ ២០% ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញមានដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| **ប្រាក់ចំណូលគណនេយ្យមុនគិតពន្ធលើប្រាក់ចំណូល៖** | **៩៧.៨៩៧.០៨០** | **១១១.០៤៥.៦៣៧** |
| ចំណូលពន្ធគិតតាមអត្រា ២០% | ១៩.៥៧៩.៤១៦ | ២២.២០៩.១២៧ |
| ផលប៉ះពាល់នៃចំណាយមិនអាចកាត់កងបាន | ៣.២៦០.៤០០ | ៣.០៣៥.៣៩០ |
| ផលប៉ះពាល់នៃប្រាក់ចំណូលមិនជាប់ពន្ធ | (៨.៨៥៨.១៣២) | (៧.៩០៦.២៧០) |
| ផលប៉ះពាល់នៃពន្ធពន្យារមិនទទួលស្គាល់ពីមុន | (១.៨៦៩.៤១៩) | - |
| កង្វះសំវិធានធនលើពន្ធក្នុងគ្រានៃការិយបរិច្ឆេទមុន | ១.៦២៩.៦០០ | - |
| | **១៣.៧៤១.៨៦៥** | **១៧.៣៣៨.២៤៧** |

### *(ខ) បំណុលពន្ធពន្យារ - សុទ្ធ*

ពន្ធពន្យារ ត្រូវបានគណនាទៅលើភាពខុសគ្នាបណ្ដោះអាសន្នក្រោមវិធីសាស្ត្របំណុលដោយប្រើប្រាស់អត្រាពន្ធតាមច្បាប់ ២០%។

ចំនួនខាងក្រោមត្រូវបានកំណត់បន្ទាប់ពីបានកាត់កងយ៉ាងត្រឹមត្រូវ បានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ទ្រព្យសកម្មពន្ធពន្យារ | ១៩.៦៨២.៨៤៧ | ១៩.១៦៧.៨៥៩ |
| បំណុលពន្ធពន្យារ | (៥២.៦៨៦.២០១) | (៤៨.៥៨៦.៨៧៣) |
| **បំណុលពន្ធពន្យារ -សុទ្ធ** | **(៣៣.០០៣.៣៥៤)** | **(២៩.៤១៩.០១៤)** |

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល (តពីទំព័រមុន)

### *(ខ) បំណុលពន្ធពន្យារ - សុទ្ធ* (តពីទំព័រមុន)

ពន្ធពន្យារជាទ្រព្យសកម្ម (បំណុល) មានដូចខាងក្រោមទៅៈ

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| ទ្រព្យសកម្មពន្ធពន្យារលើៈ | | |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៥.២០៧.៦៨៣ | ១៧.៦៣៦.១៩៧ |
| ចំណូលពន្យារ | ២.៩៧៤.៩៧៤ | ១.០៨៨.៩៨០ |
| បុរេប្រទានទទួលពីអតិថិជន | ១.៦២៩.៦០០ | - |
| កាតព្វកិច្ចលើប្រាក់បំណាច់អតីតភាពការងារ | ២៨៨.៨៩១ | ២១៦.០៣០ |
| សំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក | ៦២.៦១៨ | ៧៨.០៥៣ |
| សំវិធានធនលើអ៊ីមភែរមិននៃសន្និធិ | ១៩.០៨១ | ១៤៨.៥៩៩ |
| | **១៩.៦៨២.៨៤៧** | **១៩.១៦៧.៨៥៩** |
| បំណុលពន្ធពន្យារលើៈ | | |
| រំលស់ទ្រព្យអរូបី និងទ្រព្យរូបី | (៥២.៦៨៦.២០១) | (៤៨.៥៨៦.៨៧៣) |
| **បំណុលពន្ធពន្យារ - សុទ្ធ** | **(៣៣.០០៣.៣៥៤)** | **(២៩.៤១៩.០១៤)** |

### *(គ) បំណុលពន្ធលើប្រាក់ចំណូល*

| | *២០២២* | *២០២១* |
|---|---:|---:|
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា | ៥.៩៣៥.៣០៧ | ៧.៦០៧.៤៩៣ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១១.៩៩២.៦៣៤ | ៧.៥៩៥.៥៤៩ |
| កង្វះសំវិធានធនពន្ធក្នុងគ្រាពីការិយបរិច្ឆេទមុន | ១.៦២៩.៦០០ | - |
| ពន្ធលើប្រាក់ចំណូលបានបង់ | (១០.៧៧៩.៨៩៥) | (៨.១៩១.៩៣៨) |
| ឥណទានពន្ធកាត់ទុក | - | (១.១២៥.៧៩៧) |
| | **៨.៧៧៧.៦៤៦** | **៥.៩៣៥.៣០៧** |

## ២៧. ប្រាក់ចំណេញក្នុងមួយភាគហ៊ុន

### *(i) មូលដ្ឋានប្រាក់ចំណេញក្នុងមួយភាគហ៊ុន*

មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ភាគហ៊ុនិក របស់ ក.ស.ស ចែកនឹងចំនួនជាមធ្យមនៃភាគហ៊ុនធម្មតាបោះផ្សាយក្នុងការិយបរិច្ឆេទ។

| | *២០២២* | *២០២១* |
|---|---|---|
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក *(ពាន់រៀល)* | ៨៤.១៥៥.២១៥ | ៩៣.៧០៧.៣៩០ |
| ចំនួនភាគហ៊ុនជាមធ្យម | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |
| **មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន** *(រៀល)* | **៩៨១,១៥** | **១.០៩២,៥២** |

### *(ii) ការថយចុះចំណេញក្នុងមួយភាគហ៊ុន (Diluted earnings per share)*

ការថយចុះចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយនិយ័តកម្មលើចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ ក.ស.ស មិនមានការថយចុះភាគហ៊ុនដែលមានសក្តានុពល ផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ នាចុងការិយបរិច្ឆេទនេះ។ ដូចនេះ ការថយចុះចំណេញក្នុងមួយភាគហ៊ុន គឺមានតម្លៃស្មើនឹងមូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន។

## ២៨. ប្រតិបត្តិការភាគីពាក់ព័ន្ធ

ក.ស.ស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("MoEF") និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសដោយក្រសួងសាធារណការ និងដឹកជញ្ជូន ("MoPWT")។ ប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានចាត់ទុកថាជាភាគីពាក់ព័ន្ធ។

### *(ក) សមតុល្យភាគីពាក់ព័ន្ធ*

(i) ទឹកប្រាក់ជំពាក់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| *ប្រាក់កម្ចីពី៖* | | |
| MoEF – (JICA) | ១៦៣.២៨០.៧៩៧ | ១៩៨.៣០០.៨១៩ |
| MoEF – (JBIC) | ២៣១.៨២៩.៧៨០ | ២៧០.៦៨៦.១៧៨ |
| | **៣៩៥.១១០.៥៧៧** | **៤៦៨.៩៨៦.៩៩៧** |

## ២៨. ប្រតិបត្តិការភាគីពាក់ព័ន្ធ (តពីទំព័រមុន)

### *(ក) សមតុល្យភាគីពាក់ព័ន្ធ* (តពីទំព័រមុន)

(ii) គណនីត្រូវទទួលពីក្រសួងសាធារណការ និងដឹកជញ្ជូន

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| បុរេប្រទានទៅឲ្យ MoPWT *(កំណត់សម្គាល់លេខ ១០)* | **៧.២២១.៣០៣** | **១.២២១.៣០៣** |

### *(ខ) ប្រតិបត្តិការភាគីពាក់ព័ន្ធ*

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| បុរេប្រទានទៅ MoPWT *(កំណត់សម្គាល់លេខ ១០)* | ៦.០០០.០០០ | - |
| ចំណាយការប្រាក់លើប្រាក់កម្ចីពី MoEF *(កំណត់សម្គាល់លេខ ១៦)* | ៩.៩៣៩.៧៩៣ | ១១.១៩៩.៤៥៦ |

### *(គ) ចំណាយលើគណៈគ្រប់គ្រងសំខាន់ៗ*

ចំណាយលើគណៈគ្រប់គ្រងសំខាន់ៗសម្រាប់ការិយបរិច្ឆេទបញ្ចប់មានដូចខាងក្រោមៈ

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **ក្រុមប្រឹក្សាភិបាល** | | |
| កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | **១.៣៩៦.៨០០** | **១.៣៩៦.៨០០** |
| **គណៈគ្រប់គ្រងសំខាន់ៗ** | | |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | **៣.២៦៨.១៩៧** | **៣.០៦៣.៤៩៥** |
| ចំណាយអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ (*) | **២៣៥.៣៦៦** | **២៤៥.៧១៨** |

គណៈគ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយកប្រតិបត្តិ និងនាយកប្រតិបត្តិ ដែលជាអ្នកសម្រេចចិត្តលើយុទ្ធសាស្ត្រនៃការដឹកនាំលើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ ក.ស.ស។

(*) គម្រោងអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ត្រូវបានដាក់ឲ្យប្រតិបត្តិក្នុង ក.ស.ស ទាំងមូល ក្នុងនោះគណៈគ្រប់គ្រងសំខាន់ៗ ក៏ទទួលបានគម្រោងអត្ថប្រយោជន៍នេះដូចគ្នានឹងបុគ្គលិក ក.ស.ស ដទៃទៀតដែរ។

## ២៩. ភាគពួកិច្ច

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក.ស.ស មានកាតព្វកិច្ចលើការចំណាយមូលធនចំនួន ១.១៣៨.០០៧ លានរៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ៨២១.៩១៦ លានរៀល) សម្រាប់ការសាងសង់ និងការទិញទ្រព្យ និងបរិក្ខារ។

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ*

សកម្មភាពរបស់ ក.ស.ស អាចប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជា៖ ហានិភ័យទីផ្សារ (រួមបញ្ចូលទាំងហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ និងហានិភ័យអត្រាប្តូររូបិយប័ណ្ណ) ហានិភ័យឥណទាន និងហានិភ័យសន្ទនីយភាព។ ក.ស.ស គ្រប់គ្រង និងសន្ទតហានិភ័យទាំងនេះដោយការតាមដានអត្រាការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃដៃគូរបស់ ក.ស.ស អត្រាប្តូររូបិយប័ណ្ណ និងលំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដើម្បីការពារហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណរបស់ខ្លួននោះទេ។

***ហានិភ័យទីផ្សារ***

*ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលបម្រែបម្រួលការប្រាក់លើទីផ្សារនាពេលអនាគតនឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ ក.ស.ស។

ក.ស.ស បានទទួលប្រាក់កម្ចី (តាមអត្រាការប្រាក់ថេរ) ពី Japan International Cooperation Agency ("JICA") និង Japan Bank for International Cooperation ("JBIC") តាមរយៈ MoEF។ ក.ស.ស មិនមានការផ្តោះប្តូរអត្រាការប្រាក់ ឬ ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដើម្បីការពារហានិភ័យអត្រាការប្រាក់ទេ។ ក្រុមហ៊ុនមានផលប៉ះពាល់ដល់ហានិភ័យតម្លៃសមស្រប ទោះជាយ៉ាងណាក៏ដោយ គណៈគ្រប់គ្រងកំពុងពិនិត្យមើលយ៉ាងជិតដល់នូវការប្រែប្រួលនៅក្នុងទីផ្សារ ហើយនឹងឈានដល់ការផ្តោះប្តូរអត្រាការប្រាក់ ប្រសិនបើចាំបាច់។ ប្រាក់កម្ចីរបស់ ក.ស.ស ត្រូវបានយោងតាមរំលស់ថ្លៃដើម។

*ហានិភ័យតម្លៃ*

ក.ស.ស មិនប្រឈមនឹងហានិភ័យតម្លៃទេ។ បន្ថែមពីនេះ ក.ស.ស ក៏មិនប្រឈមនឹងហានិភ័យតម្លៃមូលបត្រដែរ ដោយសារ ក.ស.ស មិនមានឧបករណ៍ហិរញ្ញវត្ថុដែលត្រូវកត់ត្រាតាមតម្លៃសមស្រប នាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ។

*ហានិភ័យអត្រាប្តូររូបិយប័ណ្ណ*

ក.ស.ស ប្រឈមមុខនឹងហានិភ័យអត្រាប្តូររូបិយប័ណ្ណ ដែលសំខាន់គឺការប្តូរពីប្រាក់រៀល ទៅជាប្រាក់យ៉េនជប៉ុន និងទៅជាប្រាក់ដុល្លារអាមេរិក ដោយសារប្រាក់កម្ចីពី JICA និង JIBC តាមរយៈ MoEF ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក ក៏ប៉ុន្តែ ក.ស.ស កត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណមុខងារ។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ការការពារ ឬ ប្រើកិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត ដើម្បីការពារហានិភ័យនេះទេ។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

***ហានិភ័យទីផ្សារ*** (តពីទំព័រមុន)

*ហានិភ័យអត្រាប្តូររូបិយប័ណ្ណ* (តពីទំព័រមុន)

ភាពងាយទទួលរងនូវផលប៉ះពាល់របស់ ក.ស.ស ពីអត្រាប្តូររូបិយប័ណ្ណទៅលើឧបករណ៍ហិរញ្ញវត្ថុជាប្រាក់យ៉េនជប៉ុន និងឧបករណ៍ហិរញ្ញវត្ថុជាប្រាក់ដុល្លារអាមេរិករបស់ខ្លួន ត្រូវបានវិភាគដូចខាងក្រោម។ ឧបករណ៍ហិរញ្ញវត្ថុជាចម្បងរបស់ ក.ស.ស គឺរូបិយប័ណ្ណបរទេសទាំងពីរនេះ។ ក.ស.ស បានវិភាគបម្រែបម្រួលនៃរូបិយប័ណ្ណទាំងនេះក្នុងរយៈពេលបីឆ្នាំចុងក្រោយ ហើយបានសន្និដ្ឋានថាអត្រាបម្រែបម្រួល ៨,៩៥% (ឆ្នាំ២០២១៖ ៥,៥០%) និង ០,៨៥% (ឆ្នាំ២០២១៖ ០,៩៦%) សម្រាប់ប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក (រៀងគ្នា) គឺមានភាពសមហេតុផល។

ខាងក្រោមនេះ បង្ហាញពីផលប៉ះពាល់ទៅលើចំណូលក្រោយគិតពន្ធដែលបណ្តាលមកពីបម្រែបម្រួលនៃអត្រាប្តូរប្រាក់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖

*២០២២*

| *វិយិតភាព* | *បម្រែបម្រួលនៃអត្រាប្តូរប្រាក់* | *ផលប៉ះពាល់ទៅលើចំណូលក្រោយគិតពន្ធ* |
|---|---|---|
| | | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | - ៨,៩៥% ការធ្លាក់ចុះ | ២១.៧២៧.០០០ |
| ប្រាក់យ៉េនជប៉ុន | + ៨,៩៥% ការកើនឡើង | (២១.៧២៧.០០០) |
| ប្រាក់ដុល្លារអាមេរិក | - ០,៨៥% ការធ្លាក់ចុះ | (៣៦៩.០០០) |
| ប្រាក់ដុល្លារអាមេរិក | + ០,៨៥% ការកើនឡើង | ៣៦៩.០០០ |

*២០២១*

| *វិយិតភាព* | *បម្រែបម្រួលនៃអត្រាប្តូរប្រាក់* | *ផលប៉ះពាល់ទៅលើចំណូលក្រោយគិតពន្ធ* |
|---|---|---|
| | | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | - ៥,៥០% ការធ្លាក់ចុះ | ១៦.៤១៧.០០០ |
| ប្រាក់យ៉េនជប៉ុន | + ៥,៥០% ការកើនឡើង | (១៦.៤១៧.០០០) |
| ប្រាក់ដុល្លារអាមេរិក | - ០,៩៦ % ការធ្លាក់ចុះ | (២៩២,០០០) |
| ប្រាក់ដុល្លារអាមេរិក | + ០,៩៦% ការកើនឡើង | ២៩២,០០០ |

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យទីផ្សារ* (តពីទំព័រមុន)

តារាងខាងក្រោមនេះ សង្ខេបពីការប្រឈមមុខនឹងហានិភ័យនៃអត្រាប្តូរប្រាក់រូបិយប័ណ្ណរបស់ ក.ស.ស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ក្នុងតារាងខាងក្រោម គឺជាឧបករណ៍ហិរញ្ញវត្ថុ តាមតម្លៃយោងជារូបិយប័ណ្ណជាសមមូលពាន់រៀល។

| | *សមមូលនឹងពាន់រៀល* | | | |
|---|---|---|---|---|
| | *ប្រាក់យ៉េនជប៉ុន* | *ប្រាក់ដុល្លារអាមេរិក* | *ប្រាក់រៀល* | *សរុប* |
| **ឆ្នាំ២០២២** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗដុល | - | ៣០.៣៣៤.៩៦០ | ៧.៥៣៥.៧៩១ | ៣៧.៨៧០.៧៥១ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | - | ៩៧.១២១.៨៤៥ | ៥.៧៨៦.៤១៩ | ១០២.៩០៨.២៦៤ |
| សាច់ប្រាក់ | - | ២២.៨៨៣.១៨៨ | ៧០៣.១៨០ | ២៣.៥៨៦.៣៦៨ |
| | - | **១៥០.៣៣៩.៩៩៣** | **១៤.០២៥.៣៩០** | **១៦៤.៣៦៥.៣៨៣** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣០៣.៦៤៤.១០៥) | (៩១.៤៦៦.៤៧២) | - | (៣៩៥.១១០.៥៧៧) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | - | (២.៧១៧.៤២៣) | - | (២.៧១៧.៤២៣) |
| ប្រាក់តម្កល់ពីភតិក: | | (១.០២៩.២៥០) | | (១.០២៩.២៥០) |
| | **(៣០៣.៦៤៤.១០៥)** | **(៩៥.២១៣.១៤៥)** | - | **(៣៩៨.៨៥៧.២៥០)** |
| **ស្ថានភាពសុទ្ធ** | **(៣០៣.៦៤៤.១០៥)** | **៥៥.១២៦.៨៤៨** | **១៤.០២៥.៣៩០** | **(២៣៤.៤៩១.៨៦៧)** |
| **ឆ្នាំ២០២១** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗដុល | - | ៣៣.៩៨៥.៥១៩ | ១.៩១៧.៨០៥ | ៣៥.៩០៣.៣២៤ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | - | ៩៥.៨៧២.៣៦៧ | ៥.៤៣៤.៣១៤ | ១០១.៣០៦.៦៨១ |
| សាច់ប្រាក់ | - | ២១.៩៨០.៦៨៨ | ៤៨៨.២៤១ | ២២.៤៦៨.៩២៩ |
| | - | **១៥១.៨៣៨.៥៧៤** | **៧.៨៤០.៣៦០** | **១៥៩.៦៧៨.៩៣៤** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣៧០.៩៣៣.០៧៩) | (៩៨.០៥៣.៩១៨) | - | (៤៦៨.៩៨៦.៩៩៧) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | - | (១៤.៦៣៦.៦៦៩) | (៦.០២៥.២៣៦) | (២០.៦៦១.៩០៥) |
| ប្រាក់តម្កល់ពីភតិក: | - | (១.០១៨.៥០០) | - | (១.០១៨.៥០០) |
| | **(៣៧០.៩៣៣.០៧៩)** | **(១១៣.៧០៩.០៨៧)** | **(៦.០២៥.២៣៦)** | **(៤៩០.៦៦៧.៤០២)** |
| **ស្ថានភាពសុទ្ធ** | **(៣៧០.៩៣៣.០៧៩)** | **៣៨.១២៩.៤៨៧** | **១.៨១៥.១២៤** | **(៣៣០.៩៨៨.៤៦៨)** |

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យឥណទាន*

ក.ស.ស ប្រឈមមុខនឹងហានិភ័យឥណទាន ដែលពាក់ព័ន្ធជាចម្បងទៅនឹង គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងសាច់ប្រាក់នៅធនាគារ យោងតាមថ្លៃដើមរំលស់។

*ការគ្រប់គ្រងហានិភ័យ*

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ក.ស.ស តម្រូវឲ្យក្រុមហ៊ុនដឹកជញ្ជូនតាមនាវានីមួយៗ តម្កល់ប្រាក់កក់មុននឹងបំពេញសេវាណាមួយឲ្យក្រុមហ៊ុននោះ។ ចំពោះគ្រឹះស្ថានរបស់រដ្ឋាភិបាល មិនតម្រូវឲ្យមានប្រាក់កក់ទេ ដោយសារ ក.ស.ស ជឿជាក់ថាខ្លួនអាចប្រមូលប្រាក់ពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ដែលជាប្រភពហិរញ្ញវត្ថុ នៃគ្រឹះស្ថានរដ្ឋទាំងនោះ)។ ចំពោះក្រុមហ៊ុនដឹកជញ្ជូនតាមនាវាដែលមិនប្រើប្រាស់សេវាញឹកញាប់របស់ ក.ស.ស មិនតម្រូវឲ្យកក់ប្រាក់នោះទេ ដោយសារក្រុមហ៊ុនដឹកជញ្ជូនទាំងនោះតម្រូវឲ្យទូទាត់ប្រាក់នៅពេលទទួលបានសេវាកម្មរួចរាល់។ ក.ស.ស មានគោលការណ៍កាត់ប្រាក់កក់ចំពោះអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេ ទៅតាមលក្ខខណ្ឌ និងកិច្ចសន្យាឥណទាន។ ហានិភ័យឥណទានរបស់ ក.ស.ស ចំពោះគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានកំណត់ឲ្យនៅត្រឹមតម្លៃយោងនៃគណនីអតិថិជននោះ ដកសំវិធានធនចំពោះការខាតឥណទានបានរំពឹងទុក នៃគណនីអតិថិជន ផ្អែកតាមការត្រួតពិនិត្យលើចំនួនដែលនៅមិនទាន់ទូទាត់នាការិយបរិច្ឆេទបញ្ចប់។ មិនមានការប្រមូលផ្តុំហានិភ័យឥណទានជាសារវន្តទេ ទាំងហានិភ័យតាមរយៈអតិថិជនម្នាក់ៗ អាជីវកម្មជាក់លាក់ និង/ឬ តំបន់អាជីវកម្ម។

ចំពោះប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងសាច់ប្រាក់នៅធនាគារ ការដាក់ប្រាក់ត្រូវបានធ្វើឡើងតែជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកេរ្តិ៍ឈ្មោះល្អតែប៉ុណ្ណោះ។

*ទ្រព្យធានា*

ចំពោះគណនីអតិថិជនពាណិជ្ជកម្មខ្លះ ក.ស.ស ទទួលទ្រព្យធានាក្នុងទម្រង់ជាការតម្កល់ជាសាច់ប្រាក់ ដែលអាចឲ្យបង់ប្រាក់បាន ប្រសិនបើភាគីដៃគូខកខានមិនបានបង់ប្រាក់តាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀង។

*អ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ក.ស.ស មានទ្រព្យសកម្មហិរញ្ញវត្ថុដូចជា សាច់ប្រាក់ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី និងគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗដែលត្រូវអនុវត្តតាមគំរូការខាតឥណទានរំពឹងទុក។

សាច់ប្រាក់ ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី គឺមិនមានហានិភ័យឥណទានសំខាន់ទេ។ យោងតាមតម្រូវការនៃអ៊ីមភែរមិនរបស់ CIFRS ៩ ការខាតបង់បណ្តាលមកពីអ៊ីមភែរមិន ដែលគេបានរកឃើញ គឺមិនមានភាពជាសារវន្តទេ ដោយសារ ក.ស.ស ធ្វើការដាក់ប្រាក់តែជាមួយធនាគារដែលមានកេរ្តិ៍ឈ្មោះ និងប្រវត្តិល្អតែប៉ុណ្ណោះ។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

***ហានិភ័យឥណទាន*** (តពីទំព័រមុន)

គណនីអតិថិជន

ក.ស.ស អនុវត្តវិធីសាស្ត្រដែលមានលក្ខណៈសាមញ្ញក្នុង CIFRS ៩ ដើម្បីវាស់វែងការខាតបង់ឥណទានរំពឹងទុក (ECL) ដែលប្រើប្រាស់អាយុកាលសំវិធានធនខាតបង់រំពឹងទុក ចំពោះគណនីអតិថិជនទាំងអស់។

ក្នុងការវាស់វែងការខាតបង់ឥណទានរំពឹងទុក គណនីអតិថិជនបានដាក់ជាក្រុម អាស្រ័យទៅតាមលក្ខណៈនៃហានិភ័យឥណទានជារួម និងចំនួនថ្ងៃផុតកំណត់។

ជាទូទៅគណនីអតិថិជនរបស់ ក.ស.ស រួមមានទឹកប្រាក់ត្រូវទទួលពីកូនបំណុលចន្លោះពី ៣១ ទៅ ៣៩ កូនបំណុល ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២២។ យោងទៅតាមបទពិសោធន៍នៃការខាតបង់ឥណទានរបស់ ក.ស.ស ក្នុងគ្រាកន្លងមកចំពោះគណនីអតិថិជន មិនមានករណីមិនសងប្រាក់រយៈពេល ៨ឆ្នាំចុងក្រោយនេះទេ។ វិក្កិយបត្រទាំងអស់ត្រូវបានទូទាត់មិនលើសរយៈពេលមួយឆ្នាំទេ។ ផ្អែកទៅតាមរបាយការណ៍នៃចិរវេលាកំណត់សងដែលបានផ្តល់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ភាគច្រើននៃសមតុល្យដែលមានចិរវេលាកំណត់សងលើសពី ១២០ថ្ងៃ ត្រូវបានទូទាត់រួចរាល់នាពេលបន្ទាប់ក្នុងខែមករា ឆ្នាំ២០២៣។

អត្រាការខាតបង់ក្នុងគ្រាកន្លងមក ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីព័ត៌មាននាពេលបច្ចុប្បន្ន និងព័ត៌មាននាពេលអនាគត ទៅលើកត្តាម៉ាក្រូសេដ្ឋកិច្ចផ្សេងៗ ដែលមានផលប៉ះពាល់ដល់លទ្ធភាពរបស់អតិថិជនក្នុងការទូទាត់សង។ ក.ស.ស បានកំណត់អំពីផលិតផលសរុបក្នុងស្រុក និងអត្រាកំណើននៅប្រទេសកម្ពុជា ដែល ក.ស.ស កំពុងផ្តល់សេវារបស់ខ្លួនត្រូវបានចាត់ទុកថាជាកត្តាដែលមានការពាក់ព័ន្ធក្នុងចំណោមកត្តាផ្សេងៗទៀត ដូចនេះហើយ ក.ស.ស បានកែតម្រូវអត្រាខាតបង់ក្នុងគ្រាកន្លងមក អាស្រ័យទៅតាមបម្រែបម្រួលរំពឹងទុកនៃកត្តាទាំងអស់នេះ។

គណនីអតិថិជនត្រូវបានលុបចោលពីបញ្ជី នៅពេលដែលមិនមានការរំពឹងទុកសមហេតុផលណាមួយដែលអាចប្រមូលបានមកវិញ។ សញ្ញាណដែលបង្ហាញថាមិនមានការរំពឹងទុកសមហេតុផលក្នុងការប្រមូលបានមកវិញរួមមានកត្តាមួយចំនួនក្នុងចំណោមកត្តាជាច្រើនដូចជា បរាជ័យរបស់កូនបំណុលក្នុងការសងប្រាក់តាមពេលវេលាកំណត់ និងបរាជ័យក្នុងការសងប្រាក់តាមកិច្ចសន្យាក្នុងរយៈពេលមួយលើសថ្ងៃផុតកំណត់សងជាក់លាក់ នឹងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ការខាតបង់អ៊ីមភែរមិនលើគណនីអតិថិជន ត្រូវបានដាក់បង្ហាញដោយការខាតបង់អ៊ីមភែរមិនសុទ្ធក្នុងប្រាក់ចំណេញប្រតិបត្តិការ។ ការប្រមូលបានមកវិញនាពេលបន្ទាប់ នៃចំនួនទឹកប្រាក់ដែលបានលុបចោលពីបញ្ជីរួចហើយ ត្រូវបានកត់ត្រាក្នុងខ្ទង់ឥណទាន ក្នុងប្រភេទគណនីដូចគ្នា។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

***ហានិភ័យឥណទាន*** (តពីទំព័រមុន)

គណនីអតិថិជន (តពីទំព័រមុន)

យោងតាមមូលដ្ឋាននេះ សំវិធានធនសម្រាប់ការខាតបង់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានកំណត់ដូចខាងក្រោមចំពោះគណនីអតិថិជនៈ

| | *២០២២* | | |
|---|---|---|---|
| | *អត្រាខាតបង់រំពឹងទុក* | *តម្លៃយោងដុល* | *សំវិធានធនសម្រាប់ការខាតបង់* |
| | *%* | *ពាន់រៀល* | *ពាន់រៀល* |
| ក្នុងគ្រា | 0% | ២៦.៩១០.៩៣៦ | - |
| ហួសកាលកំណត់លើសពី ៣០ថ្ងៃ | 0% | ១.៦១៤.៥៥៩ | - |
| ហួសកាលកំណត់លើសពី ៦០ថ្ងៃ | 0% | ៥៨៦.៩៥៣ | - |
| ហួសកាលកំណត់លើសពី ៩០ថ្ងៃ | 0% | ៧៩១.១២៧ | - |
| ហួសកាលកំណត់លើសពី ១២០ថ្ងៃ | (*) ១៩.៩៩% | ១.១៦៥.៣៣៥ | ២៣២.៩៥០ |
| សរុប | | **៣០.៥៦៧.៩១០** | **២៣២.៩៥០** |

| | *២០២១* | | |
|---|---|---|---|
| | *អត្រាខាតបង់រំពឹងទុក* | *តម្លៃយោងដុល* | *សំវិធានធនសម្រាប់ការខាតបង់* |
| | *%* | *ពាន់រៀល* | *ពាន់រៀល* |
| ក្នុងគ្រា | 0% | ២៥.៥៨០.២៨៧ | - |
| ហួសកាលកំណត់លើសពី ៣០ថ្ងៃ | 0% | ៤.៦១៦.០៥៩ | - |
| ហួសកាលកំណត់លើសពី ៦០ថ្ងៃ | 0% | ៨៣៤.២៥៤ | - |
| ហួសកាលកំណត់លើសពី ៩០ថ្ងៃ | 0% | ៣២១.៩៧១ | - |
| ហួសកាលកំណត់លើសពី ១២០ថ្ងៃ | (*) ១០,៨៦% | ៣.០៣២.៩៤៨ | ៣២៩.២៩១ |
| | | **៣៣.៨៨៥.៥១៩** | **៣២៩.២៩១** |

(*) ផលប៉ះពាល់ចំពោះការវាស់វែង ECL គឺដោយសារតែការផ្លាស់ប្តូរប្រូបាបនៃការមិនសងប្រាក់ ("PD") ដែលកើតឡើងពីការធ្វើនិយ័តកម្មនាពេលអនាគតចំពោះការព្យាករម៉ាក្រូសេដ្ឋកិច្ច។

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យសាច់ប្រាក់ងាយស្រួល*

ក.ស.ស ប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួល កើតពីការបង្វិលសាច់ប្រាក់ទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ហានិភ័យសាច់ប្រាក់ងាយស្រួលរួមមានហានិភ័យដែលអាចធ្វើឲ្យ ក.ស.ស មិនមានលទ្ធភាពបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនឲ្យទាន់ពេលវេលា។

គោលការណ៍របស់ ក.ស.ស គឺត្រូវរក្សាទុកសាច់ប្រាក់ ឲ្យបានគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទានជាមួយនឹងមូលនិធិផ្ទាល់ដើម្បីបង់ការចំណាយវិនិយោគ។

ក.ស.ស មានប្រាក់កម្ចីមិនទាន់ដកយកដូចខាងក្រោមនាការិយបរិច្ឆេទបញ្ចប់៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| **អត្រាការប្រាក់ថេរ** | | |
| មានកាលកំណត់លើសពី ១ឆ្នាំ | **៧១៣.៦១៨.២៧៧** | **៨២១.៤១៥.៩៦២** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យសាច់ប្រាក់ងាយស្រួល* (តពីទំព័រមុន)

ទម្រង់កាលកំណត់នៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលត្រូវបានប្រើដើម្បីគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងបំណុលហិរញ្ញវត្ថុត្រូវបានសង្ខេបដូចខាងក្រោម៖

| | *២០២២* | | | *២០២១* | | |
|---|---|---|---|---|---|---|
| | *ក្នុងមួយឆ្នាំ* | *ច្រើនជាងមួយឆ្នាំ* | *សរុប* | *ក្នុងមួយឆ្នាំ* | *ច្រើនជាងមួយឆ្នាំ* | *សរុប* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| *ទ្រព្យសកម្មហិរញ្ញវត្ថុ* | | | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងដុល | ៣៧.៨៧០.៧៥១ | - | ៣៧.៨៧០.៧៥១ | ៣៥.៥៧៤.០៨៣ | - | ៣៥.៥៧៤.០៨៣ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១០២.៩០៨.២៦៤ | - | ១០២.៩០៨.២៦៤ | ១០១.៣០៦.៦៨១ | - | ១០១.៣០៦.៦៨១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ២៣.៥៨៦.៣៦៨ | - | ២៣.៥៨៦.៣៦៨ | ២២.៤៦៨.៩២៩ | - | ២២.៤៦៨.៩២៩ |
| | **១៦៤.៣៦៥.៣៨៣** | **-** | **១៦៤.៣៦៥.៣៨៣** | **១៥៩.៣៤៩.៦៩៣** | **-** | **១៥៩.៣៤៩.៦៩៣** |
| *បំណុលហិរញ្ញវត្ថុ* | | | | | | |
| ប្រាក់កម្ចី | ៣០.៤៣៣.៤៩០ | ៣៦៤.៦៧៧.០៨៧ | ៣៩៥.១១០.៥៧៧ | ៣៣.៩៦១.៥៧២ | ៤៣៥.០២៥.៤២៥ | ៤៦៨.៩៨៦.៩៩៧ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២.៧១៧.៤២៣ | - | ២.៧១៧.៤២៣ | ២.៧១៧.៤២៣ | - | ២.៧១៧.៤២៣ |
| ប្រាក់តម្កល់ពីភតិក: | - | ១.០២៩.២៥០ | ១.០២៩.២៥០ | - | ១.០១៨.៥០០ | ១.០១៨.៥០០ |
| | **៣៣.១៥០.៩១៣** | **៣៦៥.៧០៦.៣៣៧** | **៣៩៨.៨៥៧.២៥០** | **៣៦.៦៧៨.៩៩៥** | **៤៣៦.០៤៣.៩២៥** | **៤៧២.៧២២.៩២០** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (តពីទំព័រមុន)

### *៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ* (តពីទំព័រមុន)

*ហានិភ័យសាច់ប្រាក់ងាយស្រួល* (តពីទំព័រមុន)

តារាងវិភាគខាងក្រោមនៃបំណុលហិរញ្ញវត្ថុរបស់ ក.ស.ស ដោយតាមរយៈពេលដែលនៅសល់រហូតដល់កំណត់ការិយបរិច្ឆេទនៃតារាងតុល្យការ។ តួរលេខដែលបានលាតត្រដាងខាងក្រោម លំហូរសាចប្រាក់មិនមានអប្បហារតាមកិច្ចសន្យារ។

| | *តិចជាង ១ឆ្នាំ* | *ពី ១ឆ្នាំ ដល់ ២ឆ្នាំ* | *ពី ២ឆ្នាំ ដល់ ៥ឆ្នាំ* | *លើសពី ៥ឆ្នាំ* | *លំហូរសាច់ប្រាក់ តាមកិច្ចសន្យាសរុប* | *បំណុល តម្លៃយោងសរុប* |
|---|---|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ឆ្នាំ២០២២** | | | | | | |
| ប្រាក់កម្ចី | ៣៧.៧៤៧.៩៣៧ | ៣៧.០៣៥.៤០៨ | ១០៦.៦១៣.១៦២ | ២៩៣.៩១៩.១៣៩ | ៤៧៥.៣១៥.៦៤៦ | ៣៩៥.១១០.៥៧៧ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២.៧១៧.៤២៣ | - | - | - | ២.៧១៧.៤២៣ | ២.៧១៧.៤២៣ |
| ប្រាក់តម្កល់ពីភតិក: | | | | ១.០២៩.២៥០ | ១.០២៩.២៥០ | ១.០២៩.២៥០ |
| | **៤០.៤៦៥.៣៦០** | **៣៧.០៣៥.៤០៨** | **១០៦.៦១៣.១៦២** | **២៩៤.៩៤៨.៣៨៩** | **៤៧៩.០៦២.៣១៩** | **៣៩៨.៨៥៧.២៥០** |
| **ឆ្នាំ២០២១** | | | | | | |
| ប្រាក់កម្ចី | ៤៧.០៧៤.២៣៩ | ៤៣.២៥១.៣៦១ | ១២៤.២២៤.១៩៦ | ៣៦៦.៧៦៤.៣០៩ | ៥៨១.៣១៤.១០៥ | ៤៦៨.៩៨៦.៩៩៧ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២០.៦៦១.៩០៥ | - | - | - | ២០.៦៦១.៩០៥ | ២០.៦៦១.៩០៥ |
| ប្រាក់តម្កល់ពីភតិក: | - | - | - | ១.០១៨.៥០០ | ១.០១៨.៥០០ | ១.០១៨.៥០០ |
| | **៦៧.៧៣៦.១៤៤** | **៤៣.២៥១.៣៦១** | **១២៤.២២៤.១៩៦** | **៣៦៧.៧៨២.៨០៩** | **៦០២.៩៩៤.៥១០** | **៤៩០.៦៦៧.៤០២** |

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.២ ការគ្រប់គ្រងហានិភ័យដើមទុន*

ទិសដៅរបស់ ក.ស.ស ក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគហ៊ុនិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុតដើម្បីកាត់បន្ថយចំណាយដើមទុន។

ក.ស.ស មិនមានគោលការណ៍ជាក់លាក់ចំពោះអនុបាតបំណុលធៀបនឹងដើមទុននោះទេ។

*ភាគលាភ*

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ និងថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានអនុម័តបែងចែកភាគលាភ ចំពោះប្រាក់ចំណេញសម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (រៀងគ្នា) ដូចខាងក្រោម៖

| | *២០២២* | *២០២១* |
|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* |
| ភាគលាភបានបង់ឲ្យភាគហ៊ុនប្រភេទ ខ | ៥.៣០០.០០០ | ៣.៥៣៣.១២២ |
| ភាគលាភបានបង់ឲ្យភាគហ៊ុនប្រភេទ គ | ១០.៨០៧.២៦៨ | ៨.៦៤១.៥២៧ |
| **ភាគលាភបានបង់សរុប** | **១៦.១០៧.២៦៨** | **១២.១៧៤.៦៤៩** |

ប្រតិបត្តិការមិនមែនជាសាច់ប្រាក់គឺជាភាគលាភដែលបានបង់ទៅភាគហ៊ុនប្រភេទ ខ គិតជាប្រាក់រៀលស្មើសូន្យ ដែលបានកាត់កងបុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ៣.៥៣៣.១២២ ពាន់រៀល នៃចំនួនភាគលាភសរុបដែលបានបញ្ចេញចំនួន ១២.១៧៤.៦៤៩ ពាន់រៀល ត្រូវបានកាត់កងបុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន)។

### *៣០.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម*

វិធីសាស្រ្ត និងការសន្មតដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

(ក) សាច់ប្រាក់ និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របដោយសារវាមានរយៈពេលខ្លី។

(ខ) គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ - តម្លៃយោងដកសំវិធានធនដែលបណ្តាលមកពីអ៊ីមភែរមិន មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ - តម្លៃយោងនៃគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ ត្រូវបានចាត់ទុកថាមានតម្លៃស្មើគ្នានឹងតម្លៃសមស្របរបស់វា ដោយសារវាមានរយៈពេលខ្លី។

(ឃ)ប្រាក់កម្ចី - តម្លៃសមស្របនៃប្រាក់កម្ចីត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ចេញក្នុងកិច្ចសន្យានាពេលអនាគតដោយប្រើអត្រាប្រាក់កម្ចីនាដំណាច់ឆ្នាំ។

## ៣០. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### *៣០.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម*

(តពីទំព័រមុន)

*ឋានានុក្រមតម្លៃសមរម្យ*

ក្រុមហ៊ុនប្រើប្រាស់ឋានានុក្រោមដូចខាងក្រោមសម្រាប់ការវាស់វែង និងលាតត្រដាងតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ តាមបច្ចេកទេសវាយតម្លៃដូចខាងក្រោម៖

- តម្លៃដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ បំណុលដូចគ្នា (កម្រិតទី១)
- ធាតុចូលក្រៅពីតម្លៃដែលបានដកស្រង់ដែលបានរួមបញ្ចូលក្នុងកម្រិតទី១ ដែលអាចសង្កេតបានលើទ្រព្យសកម្ម ឬ បំណុលដោយផ្ទាល់ (ឧ. ជាតម្លៃ) ឬ ដោយប្រយោល (ឧ. បានមកពីតម្លៃ) (កម្រិតទី២)
- ធាតុចូលនៃទ្រព្យសកម្ម ឬ បំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុដែលមិនអាចសង្កេតបាន) (កម្រិតទី៣)។

មិនមានការផ្ទេររវាងរង្វាស់តម្លៃសមស្របកម្រិតទី១ និងកម្រិតទី២ និងគ្មានការផ្ទេរចូល និងចេញពីកម្រិតទី៣ ទេ។

*ការកាត់កងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

មិនមានការកាត់កងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំនោះទេ។

## ៣១. **យថាភាពពន្ធ**

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួលសេចក្តីជូនដំណឹងអំពីការវាយតម្លៃសារពើពន្ធឡើងវិញ ("NTR") ពី GDT សម្រាប់សវនកម្មលើលិខិតស្នាមចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្រុមហ៊ុនបាននឹងកំពុងបន្តពិភាក្សាជាមួយ GDT អំពីបញ្ហាពន្ធដែលនៅសល់ទាំងនេះ ជាមួយនឹងជំហររឹងមាំដែលមិនយលស្របជាមួយ GDT។ ដោយមើលឃើញពីភាពមិនច្បាស់លាស់ នៃលទ្ធផលចុងក្រោយ នៃការវាយតម្លៃឡើងវិញទាំងនេះ គណៈគ្រប់គ្រងជឿជាក់ថាលំហូរចេញ នៃធនធានមិនអាចប៉ាន់ស្មានដោយភាពជឿជាក់បាន នាកាលបរិច្ឆេទបច្ចុប្បន្ន។

ប្រព័ន្ធពន្ធដារនៅកម្ពុជាមានលក្ខណៈដោយពន្ធជាច្រើន និងច្បាប់ដែលមានការផ្លាស់ប្តូរជាញឹកញាប់ ដែលតែងតែមិនច្បាស់លាស់ផ្ទុយគ្នានិងមានការបកស្រាយ។ ជានិច្ចកាល ការបកស្រាយផ្សេងៗគ្នាមានក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការជាច្រើន។ ពន្ធគឺជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការស៊ើបអង្កេតដោយអាជ្ញាធរមួយចំនួន ដែលត្រូវបានអនុញ្ញាតដោយច្បាប់ដើម្បីដាក់ពិន័យធ្ងន់ធ្ងរ ការដាកពិន័យ និងការគិតការប្រាក់។ គណៈគ្រប់គ្រងជឿជាក់ថា ខ្លួនបានផ្តល់យ៉ាងគ្រប់គ្រាន់សម្រាប់បំណុលពន្ធដោយផ្អែកលើការបកស្រាយច្បាប់ពន្ធដាររបស់ខ្លួន។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរពាក់ព័ន្ធអាចមានការបកស្រាយខុសគ្នា និងផលប៉ះពាល់អាចមានសារៈសំខាន់។

ការបង្ហាញផ្សេងទៀតដែលទាមទារដោយ CIFRSs មិនត្រូវបានផ្តល់ឱ្យទេព្រោះវាអាចប៉ះពាល់ដល់ទីតាំងរបស់ក្រុមហ៊ុនក្នុងការវាយតម្លៃពន្ធដែលកំពុងបន្តនោះទេ។

## ៣២. ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃតួលេខប្រៀបធៀប

តួលេខប្រៀបធៀបជាក់លាក់ ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញដើម្បីអនុលោមតាមការបង្ហាញក្នុងការិយបរិច្ឆេទដូចតទៅៈ

| | *២០២១* | | |
|---|---|---|---|
| | *ពាន់រៀល (បានបង្ហាញពីមុន)* | *ពាន់រៀល (ធ្វើចំណាត់ថ្នាក់ឡើងវិញ)* | *ពាន់រៀល (បានធ្វើចំណាត់ថ្នាក់ឡើងវិញ)* |
| *របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ* | | | |
| ទ្រព្យវិនិយោគ - ដីធ្លី | ១២៥.០៤០.៣១៧ | (៣.៤០៦.៧៥៤) | ១២១.៦៣៣.៥៦៣ |
| ទ្រព្យវិនិយោគ - អគារ និងការកែលម្អដីធ្លី | ១៦៨.៣០៥.៤៥៩ | ២៧៤.១៩៤ | ១៦៨.៥៧៩.៦៥៣ |
| ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | ១៣.០៥៨.៧០៨ | ៣.១៣២.៥៦០ | ១៦.១៩១.២៦៨ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ៩៤.២០៨.១៥៩ | (១.០១៨.៥០០) | ៩៣.១៨៩.៦៥៩ |
| ប្រាក់តម្កល់ពីភតិក: | - | ១.០១៨.៥០០ | ១.០១៨.៥០០ |

## ៣៣. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

ក្រៅពីអ្វីដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ពុំមានព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងគួរឲ្យកត់សម្គាល់ណាមួយឡើង បន្ទាប់ពីការិយបរិច្ឆេទរបាយការណ៍ដែលតម្រូវឲ្យមានការកែតម្រូវ ឬ បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

# ផ្នែកទី ៧

# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

**ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**គ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ឃ- ប្រតិបត្តិការសំខាន់ៗ ជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ង- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលកាន់មុខតំណែងណាមួយ នៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ជ- ប្រតិបត្តិការសំខាន់ៗ ជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

គិតត្រឹមឆ្នាំ២០២២ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

# ផ្នែកទី ៨

# ការពិភាក្សា និងការវិភាគ
# របស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

កសស គឺជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ ហិកតា ដែលមានទីតាំងនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ កំណត់ក្នុង អនុក្រឹត្យលេខ ៥០ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ កសស មានតួនាទីជាប្រតិបត្តិករផែ ដូចមានលម្អិតនូវអាជីវកម្ម និងសេវាកម្មក្នុងផ្នែកទី១ ចំណុចទី២ ខាងលើនៃរបាយការណ៍ឆ្នាំ២០២២ នេះ ។

សម្រាប់ឆ្នាំ២០២២ នេះ បរិមាណកុងតេន័ររបស់ កសស មានការកើនឡើងចំនួន ១៧.៧៦១ TEUs ស្មើនឹង ២,៤៣% បើធៀបនឹងឆ្នាំ២០២១។ ចំណែកបរិមាណទំនិញឆ្លងកាត់គិតជាតោនមានកំណើន ០,១៨% ស្មើនឹង ១២.៨២០ តោន ដែលក្នុងនោះទំនិញកុងតេន័រ គិតជាតោនមានកំណើន ១,៦៦% ស្មើនឹង ៨២.១៨៧ តោន ប្រេង និងហ្គាសកើនឡើង ២,១៥% ស្មើនឹង ៣៨.៤២៤ តោន ចំណែកទំនិញរាយឆ្លងកាត់មានការថយចុះ ៤២,៩៩% ស្មើនឹង ១០៧.៧៩១តោន បើធៀបនឹងឆ្នាំ២០២១។ ចំពោះនាវាឆ្លងកាត់ កសស មានការថយចុះចំនួន ១៤០ នាវា ប្រមាណជា ៨,៨៥% រីឯចំណុះផ្ទុកនាវាមានការកើនឡើង ៥,៥៥% ស្មើនឹង ៧៤១.៦៣៣ តោន សម្រាប់ឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ កសស និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ ដោយសវនករឯករាជ្យសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២១ ដូចបង្ហាញក្នុងផ្នែកទី៦ នៃរបាយការណ៍ឆ្នាំ២០២២ នេះ ។

កសស មានប្រភពចំណូលសំខាន់ដូចខាងក្រោម ៖

- ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services)៖ គឺជាចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ចំណូលលើចំណុះផ្ទុក សំចតផែ ប្រឡាយ ថ្លៃឈ្នួលកណ្តាលកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលប្រមូលសំរាម ។
- ចំណូលពីសេវាកម្មលើកដាក់កុងតេន័រពីនាវាទៅទីលានកុងតេន័រ (Stevedoring Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតេន័រចូល ឬចេញពីនាវានៅលើស្ពានផែ ។
- ចំណូលពីសេវាកម្មលើកដាក់កុងតេន័រនៅលើទីលាន (LOLO Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតេន័រ ចូល ឬចេញនៅលើទីលាន ។
- ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតេន័រ (Storage Fees)៖ គឺជាចំណូលដែលបានមកពីការស្តុកទំនិញរាយ ឬកុងតេន័រនៅក្នុងឃ្លាំង និងលើទីលាន ។
- ចំណូលដឹកជញ្ជូន (Transportation Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មដឹកជញ្ជូនទំនិញ ឬកុងតេន័រក្នុងបរិវេណផែ ។
- ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស (Special Economic Zone)៖ គឺជាចំណូលដែលទទួលបានពីការជួលដីធ្វើរោងចក្រ អគារ ពីតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កសស កត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិរបស់ខ្លួន ចំណែកប្រតិបត្តិការដែលជារូបិយប័ណ្ណអន្តរជាតិផ្សេងៗ ត្រូវបានបង្ហាញជាប្រាក់រៀលដោយប្រើអត្រាប្តូរប្រាក់ផ្លូវការជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ ។

## ១. ការវិភាគចំណូល

### សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូល | ៣៤៣.៧៤៣.៥៤៥ | ៣៤២.៣៤៩.២២៩ | ១.៣៩៤.៣១៦ | 0,៤១% |

សម្រាប់ឆ្នាំ២០២២ នេះ ចំណូលរបស់ កសស មានការកើនឡើងចំនួន ១.៣៩៤.៣១៦.០០០ រៀល ស្មើនឹង 0,៤១% ដោយកើនពី ៣៤២.៣៤៩.២២៩.០០០ រៀល សម្រាប់ឆ្នាំ២០២១ មក ៣៤៣.៧៤៣.៥៤៥.០០០ រៀល សម្រាប់ឆ្នាំ២០២២។ ការកើនឡើងនៃចំណូលនេះ បណ្តាលមកពីសេវាកម្មលើកដាក់កុងតែន័រ ពីនាវាទៅទីលាន ( Stevedoring Charges ) និងចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតែន័រជាដើម។

## ១.១. ការវិភាគចំណូលតាមផ្នែក

### តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកទៅនឹងប្រាក់ចំណូលសរុបសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន ( Stevedoring ) | ១៦៤.៨៧៣.៤៤៥ | ៤៧,៩៦% | ១៥៨.៥៦៦.៤៩៩ | ៤៦,៣២% |
| ចំណូលលើកដាក់លើទីលាន ( LOLO ) | ៩៦.៩២០.១៩៦ | ២៨,២០% | ១០០.៦០២.០៤៦ | ២៩,៣៩% |
| ចំណូលពីសេវាកម្មនាវាចរ | ៦២.២៨៥.០៥០ | ១៨,១២% | ៦៥.០១៦.២៦៧ | ១៨,៩៩% |
| ចំណូលស្តុកឃ្លាំងនិងទីលាន | ១៥.៥១៦.៩៧៥ | ៤,៥១% | ១៤.៣៧៤.៤៨៨ | ៤,២០% |
| ចំណូលដឹកជញ្ជូន | ៩២.០៩០ | 0,០៣% | ១២២.៣២៦ | 0,០៤% |
| ចំណូលនាវាទេសចរណ៍ | 0 | 0,00% | 0 | 0,00% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ២.៣៧៤.៦៩៦ | 0,៦៩% | ២.១៩៥.៨៦៩ | 0,៦៤% |
| ចំណូលជួលទីតាំង | ១.៣៨៥.៥៤៣ | 0,៤០% | ១.១៦៨.២៤៨ | 0,៣៤% |
| ចំណូលផ្សេងៗទៀត | ២៩៥.៥៣៩ | 0,០៩% | ៣០៣.៤៨៦ | 0,០៩% |
| **ចំណូលសរុប** | **៣៤៣.៧៤៣.៥៤៥** | **១០០,០០%** | **៣៤២.៣៤៩.២២៩** | **១០០,០០%** |

សម្រាប់ឆ្នាំ២០២២ ក៏ដូចជាឆ្នាំ២០២១ មានចំណូលសំខាន់ ៤ ប្រភេទដែលមានចំនួនប្រមាណ ៩៨% នៃចំណូលអាជីវកម្ម និងសេវាកម្មសរុបរបស់ កសស។ ចំណូលទាំងនោះរួមមាន ៖ ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) ចំណូលលើកដាក់លើទីលាន (LOLO) ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services) និងចំណូលស្តុកឃ្លាំង និងទីលាន ។

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ១៦៤.៨៧៣.៨៤៥ | ១៥៨.៥៦៦.៨៩៩ | ៦.៣០៦.៩៤៦ | ៣,៩៨% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ៩៦.៩២០.១៩៦ | ១០០.៦០២.០៤៦ | (៣.៦៨១.៨៥០) | -៣,៦៦% |
| ចំណូលពីសេវាកម្មនាវាចរ | ៦២.២៨៥.០៥០ | ៦៥.០១៦.២៦៧ | (២.៧៣១.២១៧) | -៤,២០% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ១៥.៥១៦.៩៧៥ | ១៤.៣៧៤.៤៨៨ | ១.១៤២.៤៨៧ | ៧,៩៥% |

ចំណូលពីការលើកដាក់ពីនាវាទៅទីលានកុងតែន័រ (Steverdoring) កើនឡើងចំនួន ៦.៣០៦.៩៤៦.០០០ រៀល ស្មើនឹង ៣,៩៨% សម្រាប់ឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ និងចំណូលពីការលើកដាក់នៅលើទីលាន (LOLO) មានការថយចុះប្រមាណ ៣,៦៦% ស្មើនឹង ៣.៦៨១.៨៥០.០០០ រៀល បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១។ ការកើនឡើងលើចំណូលលើកដាក់ពីនាវាទៅទីលាន គឺបណ្តាលមកពីការកើនឡើងនៃបរិមាណកុងតែន័រឆ្លងកាត់ កសស មានចំនួន ១៧.៧៦១ TEUs ស្មើនឹង ២,៤៣% សម្រាប់ឆ្នាំ២០២២ នេះ និងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ចំនួន ០,១៨%។ ទន្ទឹមគ្នានេះផងដែរការថយចុះចំណូលលើកដាក់លើទីលាននៅឆ្នាំ២០២២ គឺមកពីបរិមាណទំនិញលើករៀបដោយការប្រគល់ដោយផ្ទាល់ មានការថយចុះចំនួន ៣៩,៩៩%។

ចំពោះចំណូលសេវាកម្មនាវាចរ (Port Charges for Vessel Services) គឺអាស្រ័យលើចំនួន និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ កសស ហើយសម្រាប់ឆ្នាំ២០២២ នេះ នាវាសរុបដែលឆ្លងកាត់ កសស មានការថយចុះ ១៤០ នាវា ស្មើនឹង ៨,៨៥% ហើយចំណុះផ្ទុកនាវាមានការកើនឡើងប្រមាណ ៥,៥៥% ស្មើនឹង ៧៤១.៦៣៣ តោន ធ្វើឱ្យចំណូលពីសេវាកម្មផែមានការថយចុះបន្តិចពី ៦៥.០១៦.២៦៧.០០០ រៀល សម្រាប់ឆ្នាំ២០២១ មក ៦២.២៨៥.០៥០.០០០ រៀល សម្រាប់ឆ្នាំ២០២២ គឺប្រមាណ ៤,២០% ស្មើនឹង ២.៧៣១.២១៧.០០០ រៀល។ ការថយចុះនៃចំណូលសេវាកម្មនាវាចរនេះ ដោយនាវាដឹកទំនិញទូទៅ ក្នុងឆ្នាំ២០២២ ចំណុះផ្ទុកនាវាដឹកទំនិញទូទៅមានការថយចុះប្រមាណ ៣,៩៣% និងចំនួននាវាដឹកទំនិញទូទៅថយចុះ ៧២ គ្រឿង បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។

ចំណូលពីសេវាកម្មស្តុកឃ្លាំង និងទីលានមានការកើនឡើងចំនួន ១.១៤២.៤៨៧.០០០ រៀល ស្មើនឹង ៧,៩៥% បើប្រៀបធៀបចំណូលឆ្នាំ២០២២ មាន ១៥.៥១៦.៩៧៥.០០០ រៀល និងឆ្នាំ២០២១ មានចំណូល ១៤.៣៧៤.៤៨៨.០០០ រៀល។ ការកើនឡើងនេះបណ្តាលមកពី បរិមាណកុងតែន័រ និងទំនិញកើន ។

## ២. ការវិភាគគំលាតចំណេញដុល

កសស បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមយថាប្រភេទ ដូចនេះ ពុំមានការបង្ហាញឱ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការបានដោយទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ ។

ចំណាយប្រតិបត្តិការនឹងលើកមកពិភាក្សា និងវិភាគនៅផ្នែកខាងក្រោមគឺ ចំណុច គ-ការវិភាគចំណេញមុនបង់ពន្ធ។

## ៣. ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធ គឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិ និងចំណូល ឬចំណាយហិរញ្ញវត្ថុ-សុទ្ធ។ ក្នុងការវិភាគនៃចំណាយប្រតិបត្តិការ យើងនឹងលើកយកចំណាយសម្ភារៈផ្គត់ផ្គង់ ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ចំណាយរំលស់ (ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) ចំណាយជួសជុល និងថែទាំ ចំណាយផ្សេងៗ និងចំណេញ (ឬខាត) ផ្សេងៗ សុទ្ធ ដូចខាងក្រោម៖

### សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូលសរុប | ៣៨៣.៧៨៣.៩៨៥ | ៣៨២.៣៨៩.២២៩ | ១.៣៩៤.៣១៦ | ០,៤១% |
| ចំណាយសម្ភារៈផ្គត់ផ្គង់ | (១០៦.៣៦៤.៨៦១) | (៩៣.៧៣៩.២៤៦) | (១២.៦២៥.៦១៥) | ១៣,៤៧% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (១០៥.៦៧២.០៩៧) | (១០៤.៣៦៦.៩៤៩) | (១.៣០៥.១៤៨) | ១,២៥% |
| ចំណាយរំលស់(ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) | (៤៥.៦៩៧.៧៤៨) | (៣៩.៩២២.៦៧៧) | (៥.៧៧៥.០៧១) | ១៤,៤៧% |
| ចំណាយជួសជុល និងថែទាំ | (២.២៨៨.១១៦) | (៤.៨៥៧.០៥៣) | ២.៥៦៨.៩៣៧ | -៥២,៨៩% |
| ចំណាយផ្សេងៗ | (២៧.១២៦.៨៩៩) | (២០.៣៤៧.៤០៦) | (៦.៧៧៩.៤៩៣) | ៣៣,៣២% |
| ខាត/(ចំណេញ)ផ្សេងៗ-សុទ្ធ | ៤៤៩.៥៨៥ | (២៧៣.៣០០) | ៧២២.៨៨៥ | -២៦៤,៥០% |
| (ចំណាយ)/ចំណូលហិរញ្ញវត្ថុ-សុទ្ធ | ៤០.៨៥៣.៦៧១ | ៣២.២០៣.០៣៩ | ៨.៦៥០.៦៣២ | ២៦,៨៦% |
| ចំណេញមុនបង់ពន្ធ | ៩៧.៨៩៧.០៨០ | ១១១.០៤៥.៦៣៧ | (១៣.១៤៨.៥៥៧) | -១១,៨៤% |

សម្រាប់ឆ្នាំ២០២២ កសស មានចំណាយសម្ភារៈផ្គត់ផ្គង់ ១០៦.៣៦៤.៨៦១.០០០ រៀល ដែលមានការកើនឡើងចំនួន ១២.៦២៥.៦១៥.០០០ រៀល ស្មើនឹង ១៣,៤៧% បើធៀបនឹងឆ្នាំ២០២១ ដែលមានចំណាយ ៩៣.៧៣៩.២៤៦.០០០ រៀល។ កត្តាចម្បងដែលបណ្តាលឱ្យមានការកើនឡើងនេះ គឺដោយសារចំណាយសម្ភារៈងាយឆេះ (ប្រេងឥន្ធនៈ) កើនឡើង ២៣,៩៥% ស្មើនឹង ១០.៧០០.៣៧៣.០០០ រៀល ដោយតម្លៃជាមធ្យមរបស់ប្រេងឥន្ធនៈមានការកើនឡើងពី ០,៦៨ ដុល្លារ ក្នុងមួយលីត្រ សម្រាប់ឆ្នាំ២០២១ ទៅ ១,០៦ ដុល្លារ ក្នុងមួយលីត្រ សម្រាប់ឆ្នាំ២០២២។ ចំពោះចំណាយលើគ្រឿងបន្លាស់មានការកើនឡើង ១១,១៧% ស្មើនឹង ៣.៦៧៧.២៦១.០០០ រៀល បើធៀបនឹងឆ្នាំ២០២១ ។

មូលដ្ឋានក្នុងការគណនាប្រាក់បៀវត្សរបស់ កសស គឺយោងទៅលើទិន្នផល (ចំណូលពីការលើកដាក់) ពោលគឺនៅពេលចំណូលពីការលើកដាក់កើនឡើង ចំណាយបៀវត្សនឹងកើនឡើង ផ្ទុយទៅវិញបើចំណូលពីការលើកដាក់មានការថយចុះ ចំណាយលើប្រាក់បៀវត្សនឹងត្រូវថយចុះដូចគ្នា ហើយយើងសង្កេតឃើញថាចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) និងចំណូលលើកដាក់លើទីលាន (LOLO) មានការកើនឡើងបន្តិចសម្រាប់ ឆ្នាំ២០២២នេះ។ ចំពោះចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ មានការកើនឡើងប្រមាណ ១,២៥% ស្មើនឹង ១.៣០៥.១៤៨.០០០ រៀល បើប្រៀបធៀបចំណាយសម្រាប់ឆ្នាំ២០២២ ដែលមានចំនួន ១០៥.៦៧២.០៩៧.០០០ រៀល និងឆ្នាំ២០២១ ដែលមានចំណាយ ១០៤.៣៦៦.៩៤៩.០០០ រៀល។ កត្តាសំខាន់ដែលធ្វើអោយមានកំណើននេះ គឺបណ្តាលមកពីប្រាក់បៀវត្សបុគ្គលិកមានការកើនឡើង ២,២៧% ស្មើនឹង ១.៥៧១.៨៩១.០០០ រៀល និងការចំណាយលើចំណាយសន្តិសុខសង្គមផ្សេងៗ មានការកើនឡើងចំនួន ៧៦៣.៥០៩.០០០រៀល ស្មើនឹង ៩៧,៥១% សម្រាប់ឆ្នាំ២០២២នេះ ។

ចំណាយរំលស់រួមមាន រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបីនៅក្នុងឆ្នាំ២០២២ មានចំនួន ៤៥.៦៩៧.៧៤៨.០០០ រៀល មានកំណើន ៥.៧៧៥.០៧១.០០០ រៀល ស្មើនឹង ១៤,៤៧% បើធៀបនឹងឆ្នាំ២០២១ ដែលមានចំនួន ៣៩.៩២២.៦៧៧.០០០ រៀល។ កត្តាដែលធ្វើឱ្យមានការកើនឡើងនេះគឺដោយសារចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារមានកំណើន ៥.៨៥៦.៩០៧.០០០ រៀល ស្មើនឹង ១៨,០២% និងកំណើនលើចំណាយរំលស់ទ្រព្យសម្បត្តិអរូបី ៥,៨១% ស្មើនឹង ៦៤.១៩៥.០០០ រៀល ។

ចំណែកចំណាយជួសជុល និងថែទាំមានការថយចុះ ២.៥៦៨.៩៣៧.០០០ រៀល ស្មើនឹង ៥២,៨៩% ដោយមានចំណាយសរុបស្មើនឹង ២.២៨៨.១១៦.០០០ រៀល សម្រាប់ឆ្នាំ២០២២ និង ៤.៨៥៧.០៥៣.០០០ រៀល សម្រាប់ឆ្នាំ២០២១ ។

ចំពោះចំណាយផ្សេងៗសរុប មានការកើនឡើងប្រមាណ ៣៣,៣២% ស្មើនឹង ៦.៧៧៩.៤៩៣.០០០ រៀល ពោលគឺកើនឡើងពី ២០.៣៤៧.៤០៦.០០០ រៀល សម្រាប់ឆ្នាំ២០២១ មក ២៧.១២៦.៨៩៩.០០០ រៀល សម្រាប់ឆ្នាំ២០២២។ កត្តាដែលធ្វើអោយមានការកើនឡើងនេះ គឺបណ្តាលមកពីការកើនឡើងចំណាយទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច ៧៥,១៧% ស្មើនឹង ១.០៦៩.៥៣៧.០០០រៀល និងចំណាយលើបេសកកម្មមន្ត្រី-បុគ្គលិកកើនឡើងប្រមាណ ១០៥,៨៩% ស្មើនឹង ៨៣១.១៧៧.០០០ រៀល ហើយចំណាយទឹកភ្លើងមានការកើនឡើងប្រហែល ៦៧៧,៤៣% ស្មើនឹង ២.៤៨១.៩១៨ បើធៀបនឹងឆ្នាំ២០២១ គឺដោយសារការប្រើប្រាស់អគ្គិសនីរបស់ កសស។ សម្រាប់ឆ្នាំកន្លងៗមក កសស បានប្រើប្រាស់អគ្គិសនីដោយដំណើរការម៉ាស៊ីនភ្លើងដោយខ្លួនឯងសម្រាប់ប្រើប្រាស់អគ្គិសនីក្នុងតំបន់ កសស នេះផ្ទាល់។ ដោយឡែកសម្រាប់ឆ្នាំ២០២២ វិញ កសស បានតបណ្តាញអគ្គិសនីរដ្ឋចូលដើម្បីប្រើប្រាស់ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២២ មក ទើបធ្វើអោយចំណាយទឹកភ្លើងមានការកើនឡើងខ្លាំងសម្រាប់ឆ្នាំ២០២២ នេះ។

ខាត/(ចំណេញ)ផ្សេងៗ-សុទ្ធ (Realized Foreign Exchange Gain-Losses) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេច ដែលសម្រាប់ឆ្នាំ២០២២ នេះ មានការចំណេញចំនួន ៤៤៩.៥៨៥.០០០ រៀល បើធៀបនឹងឆ្នាំ២០២១ មានការខាតចំនួន ២៧៣.៣០០.០០០ រៀល ធ្វើឱ្យមានការកើនឡើងពីការចំណេញប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេចប្រមាណ ២៦៤,៥០% ស្មើនឹង ៧២២.៨៨៥.០០០ រៀល ក្នុងឆ្នាំ២០២២ នេះ។

ចំណែក ចំណាយ/(ចំណូល)ហិរញ្ញវត្ថុ-សុទ្ធ (Unrealized Foreign Exchange Gain-Loss ) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទមិនទាន់សម្រេច ដោយឆ្នាំ២០២២ មាន ចំណាយ/(ចំណូល) ហិរញ្ញវត្ថុ-សុទ្ធ ចំនួន ៤០.៨៥៣.៦៧១.០០០ រៀល ដែលមានការកើនឡើងប្រមាណ ២៦,៨៦%

ស្មើនឹង ៨.៦៥០.៦៣២.០០០ រៀល បើធៀបនឹងឆ្នាំ២០២១ ដែលមានចំណាយ/(ចំណូល)ហិរញ្ញវត្ថុ-សុទ្ធ ចំនួន ៣២.២០៣.០៣៩.០០០ រៀល។ កត្តាសំខាន់ដែលបណ្តាលឱ្យមានបំរែបំរួលលើចំណាយ/(ចំណូល)ហិរញ្ញវត្ថុ-សុទ្ធ គឺដោយសារការកើនឡើងនៃការចំណេញពីការប្តូររូបិយវត្ថុមិនទាន់សម្រេចរបស់ប្រាក់កម្ចី (ប្រាក់យ៉េន) ប្រមាណ ១២,០៤% ស្មើនឹង ៤.៧៥៩.៤២៨.០០០ រៀល ដោយក្នុង ឆ្នាំ២០២២ មានការចំណេញចំនួន ៤៤.២៩០.៧៩៤.០០០ រៀល ធៀបនឹងឆ្នាំ២០២១ មានការចំណេញចំនួន ៣៩.៥៣១.៣៦៦.០០០ រៀល។

ជាសរុប ចំណេញមុនបង់ពន្ធសម្រាប់ឆ្នាំ២០២២ របស់ កសស មានចំនួន ៩៧.៨៩៧.០៨០.០០០ រៀល ថយចុះចំនួន ១៣.១៤៨.៥៥៧.០០០ រៀល ប្រមាណជា ១១,៨៤% បើធៀបនឹងឆ្នាំ២០២១ ចំណេញមុនបង់ពន្ធមានចំនួន ១១១.០៤៥.៦៣៧.០០០ រៀល ។

## ៤. ការវិភាគចំណេញក្រោយបង់ពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា ២០%។ ចាប់ពីឆ្នាំ២០២០ នេះតទៅ កសស នឹងបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួន ក្នុងអត្រា ២០% វិញ ក្រោយពីទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រចំនួនបីឆ្នាំកន្លងមក (ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩) ។

### សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០២១

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណេញមុនបង់ពន្ធ (ក) | ៩៧.៨៩៧.០៨០ | ១១១.០៤៥.៦៣៧ | (១៣.១៤៨.៥៥៧) | -១១,៨៤% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (១៣.៧៤១.៨៦៥) | (១៧.៣៣៨.២៤៧) | ៣.៥៩៦.៣៨២ | -២០,៧៤% |
| ចំណេញក្នុងការិយបរិច្ឆេទ | ៨៤.១៥៥.២១៥ | ៩៣.៧០៧.៣៩០ | (៩.៥៥២.១៧៥) | -១០,១៩% |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ | ១១.៨៥៨.៨៤០ | ០ | ១១.៨៥៨.៨៤០ | ១០០,០០% |
| លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក | ៩៦.០១៤.០៥៥ | ៩៣.៧០៧.៣៩០ | ២.៣០៦.៦៦៥ | ២,៤៦% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ១៤,០៤% | ១៥,៦១% | | |

កសស មានចំណេញក្នុងការិយបរិច្ឆេទចំនួន ៨៤.១៥៥.២១៥.០០០ រៀល សម្រាប់ឆ្នាំ២០២២ ដែលមានការថយចុះចំនួន ៩.៥៥២.១៧៥.០០០ រៀល ស្មើនឹង ១០,១៩% ធៀបនឹងឆ្នាំ២០២១ ដែលមានចំណេញក្នុងការិយបរិច្ឆេទចំនួន ៩៣.៧០៧.៣៩០.០០០ រៀល។ កត្តាដែលធ្វើឱ្យចំណេញក្នុងការិយបរិច្ឆេទមានការថយចុះនេះ គឺបណ្តាលមកពីចំណាយប្រតិបត្តិការមានការកើនឡើង ក្នុងឆ្នាំ២០២២ បើធៀបនឹងឆ្នាំ២០២១ ។

បើសង្កេតទៅលើអត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញមានការថយចុះពី ១៥,៦១% សម្រាប់ឆ្នាំ២០២១ ដល់ ១៤,០៤% សម្រាប់ឆ្នាំ២០២២ ដោយសារមានការថយចុះនៃចំណេញមុនបង់ពន្ធ ក្នុងឆ្នាំ២០២២ នេះ ។

## ៥. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កត្តាមួយចំនួនអាចមានឥទ្ធិពលលើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ កសស ដូចជា៖

- **កត្តានានាដែលធ្វើឱ្យមានកំរិតលើការធ្វើពាណិជ្ជកម្មអន្តរជាតិ**

ដោយសារប្រភពចំណូលចម្បងរបស់ កសស បានមកពីចរាចរណ៍ទំនិញឆ្លងកាត់ដែលជាការធ្វើ ពាណិជ្ជកម្មអន្តរជាតិ ដូចនេះកត្តានានាដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ និងមានឥទ្ធិពលលើអាជីវកម្មរបស់ កសស ដែលកត្តាទាំងនោះមានដូចជា ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ក្នុងតំបន់ និងសាកលលោក ស្ថេរភាពសង្គម បញ្ហាសន្តិសុខ ឬកិច្ចសហប្រតិបត្តិការនាវាចរតាមសមុទ្រ។ យោងតាមមូលនិធិរូបិយ ប័ណ្ណអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៣,២% សម្រាប់ឆ្នាំ២០២២ ចំណែកសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៥,៣% យោងតាម ASIAN DEVELOPMENT BANK (ADB) នេះបង្ហាញថាស្ថានភាពសេដ្ឋកិច្ចកម្ពុជានៅតែមានភាពរឹងមាំង ដែលជាកត្តាវិជ្ជមានចំពោះអាជីវកម្មកំពង់ផែ ។

- **សមត្ថភាព និងប្រសិទ្ធភាពបំពេញការងាររបស់ កសស**

សម្រាប់ឆ្នាំ២០២២ កសស មានសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់មធ្យោបាយលើកដាក់កុងតែន័រ ធុនធ្ងន់ ប្រភេទ រថស្ទូចចល័តលើគែមផែ (QC) ចំនួន ០១ គ្រឿង និងរថស្ទូចចល័តនៅទីលាន (RTG) ចំនួន ០២ គ្រឿង រថលើកដាក់កុងតែន័រទទេ (Empty Reach Stacker) ចំនួន ០៤ គ្រឿង បន្ថែមទៀត កាលពីឆ្នាំ២០២១នេះ។ កត្តានេះធ្វើឱ្យសមត្ថភាព និងប្រសិទ្ធភាពការងារមានការកើនឡើងក្នុងការបំពេញសេវាកម្មរបស់ខ្លួន ស្របទៅនឹងកំណើនទំនិញឆ្លងកាត់របស់ កសស ។

- **ស្ថានភាពបណ្តាញដឹកជញ្ជូនក្នុងស្រុក**

សម្រាប់ ឆ្នាំ២០២២ នេះ បណ្តាញដឹកជញ្ជូនក្នុងស្រុក ពិសេសផ្លូវជាតិលេខ៤ ដែលតភ្ជាប់ពី កសស ទៅរាជធានីភ្នំពេញ ពុំមានបង្កជាឧបសគ្គដល់ការដឹកជញ្ជូនទំនិញឡើយ។ រីឯការដឹកជញ្ជូនតាមផ្លូវដែកបច្ចុប្បន្នក្រុមហ៊ុន Royal Railway ឆ្លងកាត់ កសស មានចំនួន ៦ជើង ក្នុងមួយសប្តាហ៍ក្នុងការនាំទំនិញចេញចូល ហើយការដឹកជញ្ជូនតាមផ្លូវដែកនេះ ក៏ប្រព្រឹត្តទៅដោយរលូនតាមធម្មតាមិនមានបញ្ហាធ្វើឱ្យខកខានដំណើរនោះទេ ។

- **កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់**

កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់ ពិសេសគឺការតភ្ជាប់ជាមួយកំពង់ផែមេក្នុងតំបន់មានសារៈសំខាន់ក្នុងការសំរួលចរាចរណ៍ទំនិញរវាង កសស និងទីផ្សារអន្តរជាតិសំខាន់ៗ ដោយមានឥទ្ធិពលលើចំណាយ និងរយៈពេលដឹកជញ្ជូន ដែលជាលទ្ធផលធ្វើឱ្យមានផលប៉ះពាល់លើភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនានា។ ក្នុងករណីនេះ កសស បានខិតខំរក្សាទំនាក់ទំនងល្អជាមួយបណ្តាកំពង់ផែសំខាន់ៗ ក្នុងតំបន់ដើម្បីធានាឱ្យប្រតិបត្តិការមានភាពរលូន។

- **រំលស់**

ដោយអាជីវកម្មរបស់ កសស មានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រើន ចំណាយលើរំលស់លើហេដ្ឋា រចនាសម្ព័ន្ធផែដូចជា ចំណតនាវា គ្រឿងចក្រ អគារ មានទំហំធំដែលអាចប៉ះពាល់ដល់អាជីវកម្មរបស់ កសស។ ដូចនេះ កសស ចាំបាច់ត្រូវមានការត្រួតពិនិត្យលើគោលនយោបាយរំលស់ឱ្យបានសមស្រប និងធ្វើការកែតម្រូវ តាមការចាំបាច់រៀងរាល់ការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ។ សម្រាប់ឆ្នាំ២០២២នេះ ពុំមានការកែសម្រួល ឬការស្នើឱ្យមានការកែសម្រួលគោលនយោបាយរំលស់នេះពីសវនករឯករាជ្យឡើយ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សកម្មភាពអាជីវកម្មរបស់ កសស មានទំនាក់ទំនងដោយផ្ទាល់ជាមួយសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសាកលលោក។ ជាពិសេសនៅពេលសេដ្ឋកិច្ចជាតិមានបម្រែបម្រួល និងមានឥទ្ធិពលដោយផ្ទាល់ទៅលើអាជីវកម្ម សេវាកម្មកំពង់ផែ ពោលគឺនៅពេលសេដ្ឋកិច្ចជាតិកើនឡើងនាំឱ្យអាជីវកម្ម សេវាកម្ម កំពង់ផែក៏កើនឡើងស្របនឹងនេះផលចំណូលរបស់ កសស ក៏មានកំណើនដូចគ្នា ផ្ទុយទៅវិញ បើសេដ្ឋកិច្ចជាតិថយចុះ នឹងមានផលអវិជ្ជមានទៅលើផលចំណូល កសស ផងដែរ។ យោងតាម ASIAN DEVELOPMENT BANK (ADB) សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងអត្រារំពឹងទុកប្រមាណ ៣,២% ចំណែកសេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៥,៣% (IMF) សម្រាប់ឆ្នាំ២០២២ នេះ។ ទោះយ៉ាងណាក៏ដោយ កសស អាចមានកត្តាផលប៉ះពាល់ទៅដល់តម្រូវការ និងការផ្គត់ផ្គង់ដោយសារស្ថានភាពសង្គ្រាម រុស្ស៊ីនិងអ៊ុយក្រែនបច្ចុប្បន្ន និងការនាំចេញនាំចូលទៅប្រទេស ចិនដោយសារការបិទខ្ទប់ព្រោះគោលនយោបាយCovidសូន្យផងដែរ ។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រេងឥន្ធនៈ ជាវត្ថុធាតុដើមចម្បងបំផុតក្នុងការបម្រើសេវាកម្មកំពង់ផែ ដោយជាតម្រូវការសំខាន់សម្រាប់ប្រតិបត្តិការគ្រឿងចក្រ។ កសស នៅតែរក្សាតម្លៃសេវារបស់ខ្លួនដដែល បើទោះជាតម្លៃប្រេងឥន្ធនៈមានការកើនឡើង ឬថយចុះ ក៏ដោយ។ ហេតុដូចនេះ កសស បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លៃរបស់វត្ថុធាតុដើមទាំងនេះមានភាពសមស្រប និងប្រកួតប្រជែងក្នុងតម្លៃទីផ្សារ ។

### ៣. ការវិភាគលើពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ កសស ត្រូវបង់ពន្ធអាករទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំចាប់ពីឆ្នាំ២០២០ នេះតទៅ កសស ត្រូវបំពេញកាតព្វកិច្ចបង់ពន្ធក្នុងអត្រា ២០% វិញក្រោយពីទទួលបានការលើកទឹកចិត្តក្នុងវិស័យមូលបត្ររយៈពេលបីឆ្នាំកន្លងមក ចំណែកពន្ធផ្សេងៗ កសស បានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ កសស មានចំណូលលើកដាក់ និងចំណូលពីសេវាកម្មផែដែលរួមចំណែកប្រមាណ ៩៨% នៃចំណូលសរុបសម្រាប់ឆ្នាំ២០២២ ហើយកត្តាចម្បងដែលជំរុញឱ្យមានការកើនឡើងនៃប្រាក់ចំណូល គឺកំណើននៃនាវា និងទំនិញឆ្លងកាត់កំពង់ផែ ជាពិសេសទំនិញកុងតែន័រ ដែលជាប្រភពចំណូលដ៏សំខាន់របស់ កសស។ ការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យសំណង់ និងវិស័យឧស្សាហកម្ម គឺបានឆ្លុះបញ្ចាំងនូវស្ថានភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ហើយស្របនឹងនេះក៏មានឥទ្ធិពលជាវិជ្ជមានលើអាជីវកម្ម សេវាកម្ម និងផលចំណូលរបស់ កសស ផងដែរ។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity)

### ១. ផលប៉ះពាល់ពីអត្រាប្តូរប្រាក់

កសស បានទទួលប្រាក់កម្ចីបន្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី JICA និង JBIC ដោយតម្រូវឱ្យ កសស សងប្រាក់ដើម និងការប្រាក់ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក នៅពេលដែលរូបិយវត្ថុមុខងាររបស់ កសស គឺជាប្រាក់រៀល។ ដូចនេះ បំរែបំរួលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េនជប៉ុន នឹងមានផលប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ កសស ។

### ២. ផលប៉ះពាល់ពីអត្រាការប្រាក់

បច្ចុប្បន្ន កសស មិនមានកម្ចីណាដែលមានអត្រាការប្រាក់ប្រែប្រួលនោះទេ។ កសស បានទទួលប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាកម្ចីបន្តពី JICA និង JBIC ក្នុងអត្រាការប្រាក់ចាប់ពី ២,៦៥% ដល់ ៣,៧០%។ ហេតុដូចនេះ សម្រាប់ឆ្នាំ២០២២ នេះ មិនមានផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នេះទេ ។

### ៣. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ការប្រែប្រួលតម្លៃប្រេងឥន្ធនៈនឹងមានផលប៉ះពាល់ដល់ផលចំណេញរបស់ កសស ដោយប្រតិបត្តិការកំពង់ផែពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រដែលប្រើប្រាស់ប្រេងឥន្ធនៈ។ ហេតុដូចនេះ កសស បានពង្រឹងប្រសិទ្ធភាពលើកដាក់ និងការគ្រប់គ្រងទីលានកុងតែន័រ ដើម្បីកាត់បន្ថយការរើ ឬការបំលាស់ទីកុងតែន័រដែលមិនចាំបាច់ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកំពស់សេវាកម្មរបស់ខ្លួន ។

## ង- ផលប៉ះពាល់នៃអតិផរណា

កសស បានរក្សានូវតម្លៃសេវាកម្មរបស់ខ្លួនថេរ ដោយមិនធ្វើការប្រែប្រួល ឬកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុបានយ៉ាងប្រសើរ ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

គោលនយោបាយ សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើអាជីវកម្មរបស់ កសស ដោយសារគោលនយោបាយនេះមានទិសដៅគាំទ្រ និងលើកស្ទួយវិស័យពាណិជ្ជកម្មអន្តរជាតិ និងផ្តល់ផលវិជ្ជមានដល់អាជីវកម្មរបស់ កសស។ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន៖

- គោលនយោបាយលើកស្ទួយវិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលមានគំពោងប្រែក្លាយខេត្តព្រះសីហនុ ឱ្យទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឡូជីស្ទីក និងផលិតកម្ម តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផែពង្រីកផ្លូវជាតិលេខ៤ និងហេដ្ឋារចនាសម្ព័ន្ធព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុផងដែរ ។
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវល្បឿនលឿនពី ភ្នំពេញ-ខេត្តព្រះសីហនុ ចំណេញពេលវេលា និងចំណាយផ្សេងៗ។
- វិស័យឧស្សាហកម្មរ៉ែ ថាមពល ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា កំពុងមានការអភិវឌ្ឍន៍ ហើយ កសស បានត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រវិស័យទាំងនោះ
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- គោលនយោបាយនាំចេញអង្ករចេញទៅទីផ្សារក្រៅប្រទេស កំពុងផ្តល់ផលវិជ្ជមានដល់ កសស

- គោលនយោបាយលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ ដោយខិតខំកាត់បន្ថយឧបសគ្គនានា ចំពោះការធ្វើពាណិជ្ជកម្មរវាងកម្ពុជា និងបណ្តាប្រទេសជាដៃគូក្នុងសាកលលោក
- រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិ បានអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈយន្តការ ទីផ្សារប្តូរប្រាក់សេរីតែស្ថិតនៅក្រោមអន្តរាគមន៍ ដើម្បីរក្សាស្ថិរភាពរូបិយប័ណ្ណជាតិ ហើយលំនឹងរូបិយវត្ថុនេះបានរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលបានកសាងទំនុកចិត្តចំពោះវិនិយោគិន និងជម្រុញការធ្វើអាជីវកម្មវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាននឹងកំពុងជម្រុញឱ្យសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជនចូលទីផ្សារមូលបត្រកាន់តែច្រើនដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

# ផ្នែកទី ៩

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

សម្រាប់ឆ្នាំ២០២២ នេះ កសស មានព័ត៌មានចាំបាច់សម្រាប់ការ ការពារវិនិយោគិនដូចខាងក្រោម ៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission និងបានស្នើអោយ កសស រៀបចរបាយការណ៍ស្តីពីផលប្រយោជន៍ និងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ ជូនក្រសួងអាណាព្យាបាលទាំងពីរ និងស្នើសុំអោយ លោក KUME Hidetoshi ជួយសម្របសម្រួល និងចរចារបន្ថែមទៀតទៅភាគីជប៉ុនលើការបញ្ចុះអត្រាការប្រាក់ជាអប្បបរិមា ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័ត ដូចខាងក្រោម ៖
  - ឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ឆ្នាំ២០២១
  - ឯកភាពលើវិធានការណ៍ដោះស្រាយបន្ទាន់ និងស្នើអោយ កសស ត្រូវរៀបចំលិខិតគោរពជូនឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីស្នើសុំគោលការណ៍ផ្លាស់ប្តូរទីតាំងរបស់សមត្ថកិច្ចត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅដើមទី ពីក្នុងបរិវេណ កសស ទៅក្រៅបរិវេណ កសស វិញ
  - ឯកភាពជាគោលការណ៍លើ គម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ក្នុងស្រុក នៅច្រកលេខ១ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ( Financial performance review ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី ការអនុគ្រោះថ្លៃឈ្នួល សេវារបស់ កសស ចំពោះទំនិញរាជរដ្ឋាភិបាល ប្រចាំឆ្នាំ២០២១ មានចំនួនជាទឹកប្រាក់សរុប ៨៨.៣១២,១៩ USD ( ប៉ែតសិបប្រាំបីពាន់ បីរយដប់ពីរ ដុល្លារអាមេរិក និងដប់ប្រាំបួនសេន ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃការសិក្សា Feasibility Study របស់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មីជំហានទី២ និងជំហានទី៣ និងលទ្ធផលនៃការប្រជុំ Fact-Finding Mission និង Appraisal Mission ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ត្រីមាសទី១ ឆ្នាំ២០២២ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី១ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young ( Financial Performance Review ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាព លើកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈសម្រាប់មហាសន្និបាតភាគហ៊ុនិក លើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម ៖
  - កាលបរិច្ឆេទ : ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
  - កាលបរិច្ឆេទកំណត់ទុក : ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២
  - ទីកន្លែងប្រារព្ធមហាសន្និបាត ( Venue ) : សុខា ប៊ិច រីសត, ខេត្តព្រះសីហនុ ជាមួយនឹងប្រព័ន្ធវីដេអូខល ZOOM ( ទៅតាមស្ថានភាពជាក់ស្តែង )

- របៀបវារៈមហាសន្និបាត
  - មតិស្វាគមន៍របស់ ប្រធានមហាសន្និបាត
  - បទបង្ហាញ ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២១ និងទិសដៅអនុវត្តការងារ ឆ្នាំ២០២២
  - ពិនិត្យ និងអនុម័ត បែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពឱ្យ កសស ស្នើសុំការអនុម័តការបែងចែកភាគលាភ (Dividend) ការកំណត់កាលបរិច្ឆេទកំណត់ទុកដែលត្រូវបែងចែកភាគលាភ (Record Date) និងកាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) ជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ២០២១ នៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥ ឆ្នាំ២០២២ ដូចខាងក្រោម ៖
  - បែងចែកភាគលាភជូន
    - ភាគហ៊ុនិកប្រភេទ "ខ" ស្មើនឹងទឹកប្រាក់ចំនួន ៥,៣០០,០០០,០០០ រៀល
    - ភាគហ៊ុនិកប្រភេទ "គ" ក្នុងអត្រា ៨%, ៩%, ១០%, ១១% ឬ ១២% នៃតម្លៃមូលបត្របោះផ្សាយលក់លើកដំបូង (IPO Price) ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី៥ ពិនិត្យ និងអនុម័ត
    - ប្រភេទភាគលាភដែលត្រូវបែងចែក : សាច់ប្រាក់
    - រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២១
  - ចំនួនមូលបត្រដែលបានចុះបញ្ជីសរុប : ៨៥.៧៧១.៩៦៧ មូលបត្រ
    - ចំនួនមូលបត្រ ប្រភេទ "ខ" : ៦៤.៣២៨.៩៧៥ មូលបត្រ
    - ចំនួនមូលបត្រ ប្រភេទ "គ" : ២១.៤៤២.៩៩២ មូលបត្រ
  - ចំនួនភាគលាភសរុបដែលត្រូវបែងចែក
    - បែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៥.៣០០.០០០.០០០ រៀល
    - បែងចែកជូនភាគហ៊ុនប្រភេទ "គ": បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
  - អនុបាតនៃការបែងចែកភាគលាភសរុបជូនភាគហ៊ុនប្រភេទ "ខ" និង "គ"
    - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "ខ": ៦,២៨ %
    - អនុបាតនៃការបែងចែកភាគលាភជូនភាគហ៊ុនប្រភេទ "គ": បោះឆ្នោតសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
  - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ
    - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "ខ" : ៨២,៣៩ រៀល
    - ភាគលាភបែងចែកជូនភាគហ៊ុនប្រភេទ "គ" : សម្រេចក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៥
  - កាលបរិច្ឆេទកំណត់ទុក (Record Date) : ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២២
  - កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) : ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ កសស ស្វែងរកដំណោះស្រាយឱ្យបានអស់ពីលទ្ធភាពទៅលើការតឹងទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ដោយត្រូវអញ្ជើញក្រុមហ៊ុនមកប្រជុំពិភាក្សា និងពន្យល់កាតព្វកិច្ច ដែលត្រូវអនុវត្តទៅលើកិច្ចសន្យា ដោយកិច្ចការនេះ ត្រូវមានការចូលរួមពី លោក ណុំ ស៊ីនិត មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស ហើយ

ត្រូវរៀបចំជាកំណត់ហេតុ និងការទទួលស្គាល់អោយបានច្បាស់លាស់រវាងគូភាគី មុននឹងអនុវត្តនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមានបន្តទៀត។ ក្នុងករណីដែលដំណោះស្រាយក្នុងការតើងទារបំណុលខាងលើពុំមានប្រសិទ្ធភាព ក្រុមប្រឹក្សាភិបាលគាំទ្រទៅលើវិធានការដែលបានស្នើឡើង របស់ កសស ដែលមានលក្ខណៈជាជំហានៗ សម្រាប់អនុវត្តការតើងទារបំណុលរបស់ក្រុមហ៊ុន Royal Railway ដែលនៅជំពាក់ កសស ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្មគណៈកម្មាធិការតែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង។ អង្គប្រជុំបានស្នើអោយ កសស ធ្វើលិខិតគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីស្ថានភាពកកស្ទះចរាចរណ៍ក្នុងកំពង់ផែ និងទំនិញគ្មានការទាមទារ ដើម្បីស្នើសុំគោលការណ៍ណែនាំអនុវត្ត ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែប្រាំងជាផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងពង្រីកចំណតផែកុងតែន័រថ្មី (ជំហានទី២ និងជំហានទី៣) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី គម្រោងពង្រឹងសមត្ថភាពការគ្រប់គ្រង និងប្រតិបត្តិការចំណតផែកុងតែន័រនៅកំពង់ផែក្រុងព្រះសីហនុ-ដំណាក់កាលទី៣ (២០២២-២០២៦) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពការងារប្រព័ន្ធព័ត៌មានវិទ្យារបស់ កសស និងសូមអោយសហការសិក្សាបន្ថែមជាមួយ JICA Experts Team ដើម្បីជ្រើសរើសជម្រើសដ៏ល្អបំផុត និងជឿទុកចិត្តបាន សម្រាប់ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង កសស ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័ត ដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុ ត្រីមាសទី២ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។
- បានអនុម័តឯកភាពរបាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែប្រាំងជាផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ) ។
- បានអនុម័តឯកភាពលើ របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម កសស ០៩ ខែ ដើមឆ្នាំ២០២២ ។
- បានអនុម័តឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០២២ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Financial Performance Review) ។
- បានអនុម័តឯកភាពគាំទ្រ គម្រោងផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ២០២៣ ។

- បានឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម កសស ឆមាសទី១ ឆ្នាំ២០២២ ។
- បានអនុម័តដោយឯកភាពអោយ កសស អភិវឌ្ឍទីតាំងដីជួលខាងលើនេះ ទៅជាទីលានស្តុកកុងតែន័រ និងសម្រាប់បម្រើអោយការងារអាជីវកម្មរបស់ កសស នៅក្រោយពេលកិច្ចសន្យាជួលទីតាំង និងមធ្យោបាយលើកដាក់ នឹងត្រូវផុតសុពលភាពនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ខាងមុខនេះ ។

## ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**លូ គឹមឈន់**
ប្រធានអគ្គនាយក

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ុយ សាន**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ផាន់ ផល្លា**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**សុខ សុភ័ក្ត្រ**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ុន មុន្នីវណ្ណ**
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
Hidetoshi KUME
អភិបាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**លូ លីខេង**
អភិបាល

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ





## អាសយដ្ឋាន

តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ព្រះរាជាណាចក្រកម្ពុជា

## ទំនាក់ទំនង

០៣៤ ៩៣៣ ៤១៦
០៣៤ ៩៣៣ ៥១១
០៧៨ ៤៩៦ ៧៨៩

pas.gov.kh
pasinfo@pas.gov.kh
Sihanoukville Autonomous Port